# ចលនាកុម្មុយនីសកម្ពុជា
# និងគំរូវៀតណាម

ភាគ ១

## ការចម្លងតាម និងឯករាជភាព
## ១៩៣០-១៩៧៥

**CAMBODIAN COMMUNISM**
**AND THE VIETNAMESE MODEL**
**Volume I**
**Imitation and Independence**
**1930-1975**

*និពន្ធ ដោយ*

*ស្ទីវ ហេឌឺរ (STEPHEN ROUSSEL HEDER)*

*បកប្រែសំរួល ដោយ*

*ហេង ហាំង ខេង*

*ភ្នំពេញ*

*ខែកញ្ញា ឆ្នាំ ២០០៩*

មាតិកា

សេចក្តីផ្តើម

ជំពូក ១. បក្សកុម្មុយនីសឥណ្ឌូចិន និងបក្សប្រជាជនបដិវត្តន៍ខ្មែរ

ជំពូក ២. ការតស៊ូសន្និសិទទីក្រុងហ្សឺណែវ និងដំណើរថយក្រោយ ឆ្នាំ១៩៥៤-១៩៥៧

ជំពូក ៣. ហឹង្សានៅវៀតណាម, នយោបាយនៅកម្ពុជា

ជំពូក ៤. សមាជបក្សឆ្នាំ ១៩៦០ នៅវៀតណាម និងនៅកម្ពុជា

ជំពូក ៥. ការស្នាក់នៅបរទេស

ជំពូគ ៦. ពីការតស៊ូនយោបាយ ឆ្ពោះទៅការតស៊ូប្រដាប់អាវុធ

ជំពូក ៧. សេចក្តីសំរេចបានធ្វើឡើងហើយ

ជំពូក ៨. ការអនុវត្តន៍ សង្រ្គាមប្រជាជន តាមឯកសារដើម

ជំពូក ៩. ឆ្ពោះទៅរដ្ឋប្រហារមួយ

សេចក្តីសន្និដ្ឋាន. សង្រ្គាមប្រជាជន, បដិវត្តន៍ និងប្រជាប្រិយភាព , ឆ្នាំ ១៩៧០-១៩៧៥

# កាលប្បវត្តិ

ឆ្នាំ ១៩១៧ ៖ រដ្ឋ និងបដិវត្តន៍ របស់ ឡេនីន ជំរុញឱ្យធ្វើបដិវត្តន៍វណ្ណៈអធន ដោយគ្មានវណ្ណៈអធន។

ឆ្នាំ ១៩២៧៖ បន្ទាប់ពីមរណភាពរបស់ ឡេនីន, ស្តាលីន ដែលទទួលដំណែងបន្ត បានកំណត់ថាបដិវត្តន៍រំដោះជាតិ គឺជាបដិវត្តន៍កំរិតទាបបំផុត ។

ឆ្នាំ ១៩២៨៖ លទ្ធិកុម្មុយនីសនិយមអន្តរជាតិកំណត់ពិភពលោកដោយឈរលើកំរិតនៃការអភិវឌ្ឍន៍របស់ប្រទេសនិមួយៗ។

ឆ្នាំ ១៩៣០៖ ដោយបានទទួលអាណត្តិពី កូមីនទែន (Comintern) ហូ ជីមិញ បានបង្កើតបក្សកុម្មុយនីសឥណ្ឌូចិន (បកឥ) ដើម្បីដឹកនាំធ្វើបដិវត្តន៍នៅ វៀតណាម កម្ពុជា និងឡាវ ។

ឆ្នាំ ១៩៣៧៖ បក្សកុម្មុយនីសចិនរបស់ ម៉ៅ សេទុង (បកច) បានអភិវឌ្ឍន៍គំនិតអំពីសង្គ្រាមប្រជាជន ។

ឆ្នាំ ១៩៤៤៖ ការរស់ឡើងវិញនូវទស្សនៈរបស់សូវៀត អំពីការយកការធ្វើបដិវត្តន៍រំដោះជាតិសំរាប់អនុវត្តនៅប្រទេសអ៊ឺរ៉ុបខាងកើត ។ ទស្សនៈនេះលើកឡើងថា ជនកុម្មុយនីសត្រូវកំណត់ខ្លួនឯងថាជាអ្នកជាតិនិយមផង និងជាអ្នកប្រជាធិបតេយ្យផង ពោលគឺមិនមែនជាអ្នកបដិវត្តន៍ឡេនីននិយមទេ។

ឆ្នាំ ១៩៤៥៖ កុប្បកម្មរបស់ប្រជាជនវៀតណាម ដើម្បីទាមទារឯករាជ្យពីបារាំង ។ បកឥ ដណ្តើមអំណាច ប្រកាសថាបដិវត្តន៍រំដោះជាតិបានបង្កើតសាធារណៈរដ្ឋប្រជាធិបតេយ្យវៀតណាម(សបវ) បន្ទាប់មកប្រកាសដោយក្លែងក្លាយថារំលាយខ្លួន តែជាក់ស្តែងពួកគេបានចូលលាក់ខ្លួនជាសម្ងាត់នៅទូទាំងឥណ្ឌូចិន ។

ឆ្នាំ ១៩៤៦៖ សហភាពសូវៀតប្រកាសថា ទស្សនៈប្រជាធិបតេយ្យប្រជាជនជាទ្រង់ទ្រាយទាបបំផុតនៃសង្គមនិយម ដោយភ្ជាប់អំណាចសូវៀតឱ្យគ្របដណ្តប់លើការកែទម្រង់ប្រជាធិបតេយ្យនានា ។ បកឥ បានធ្វើការជាសម្ងាត់នៅកម្ពុជា ដើម្បីបង្កើតចលនាកុម្មុយនីសកម្ពុជា ។

ឆ្នាំ ១៩៤៩៖ លទ្ធិប្រជាធិបតេយ្យប្រជាជន ត្រូវបានកំណត់ឡើងវិញយ៉ាងទូលំទូលាយ ដោយពួកអ្នកទ្រឹស្តីសូវៀត ដើម្បីបង្កើនអត្តន័យកុម្មុយនីសរបស់វា ដោយធ្វើឱ្យវាកាន់តែបដិវត្តន៍ និងដាក់ឱ្យស្ថិតក្រោមការដឹកនាំរបស់អ្នកកុម្មុយនីសនិយមដោយចំហ ។ ជាការឆ្លុះបញ្ចាំងនូវការប្តូរទិសនេះ ជ័យជំនះនៃ បកច របស់ប្រធាន ម៉ៅ បានប្រកាសការចាប់បដិសន្ធិនៃសាធារណៈរដ្ឋប្រជាមានិតចិន ដោយពិពណ៌នាថាជា របបផ្តាច់ការប្រជាធិបតេយ្យប្រជាជន ។ សាឡុត ស បានទៅរៀននៅប្រទេសបារាំង។

ឆ្នាំ ១៩៥០៖ បកឥ នាំយកគំនិតសង្គ្រាមប្រជាជនរបស់ប្រធាន ម៉ៅ ចូលក្នុងប្រទេសកម្ពុជា និងបានបញ្ចូលមនុស្សដែលមានមុខមាត់មិនមែនកុម្មុយនីសជារូបភាពក្រៅនៅទីនោះ ដោយនិយាយបំផ្លើសអំពីតួនាទីរបស់ពួកបញ្ញាជនដែលបានទទួលការអប់រំនៅប្រទេសបារាំង ។ នួន ជា ត្រូវបានផ្ទេរខ្លួនពីបក្សកុម្មុយនីសថៃទៅក្នុង បកឥ ។ តាម៉ុក បានចូល បកឥ នៅខេត្តតាកែវ ។

ឆ្នាំ ១៩៥១៖ ការងើបឡើងវិញនៃ បកឥ នៅវៀតណាម ក្នុងឋានៈជាបក្សពលករវៀតណាម (បពវ) ដើម្បីដឹកនាំធ្វើ "បដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យ" មានលក្ខណៈជឿនលឿនដោយមានកំរិតនៅវៀតណាម ។ នៅកម្ពុជា វាបានដកថយក្រោយ ប៉ុន្តែនៅបន្តដឹកនាំ "បដិវត្តន៍រំដោះជាតិ" ដោយសម្ងាត់ និងបង្កើតបក្សប្រជាជនបដិវត្តន៍

ខ្មែរ (បបបខ) ដែលជាកុម្មុយនីសអាច់កំបាំង ដើម្បីជាថ្នាលសំរាប់បណ្តុះបណ្តាលជនកុម្មុយនីសកម្ពុជាបន្ថែមទៀត ។ សាឡុត ស បានចូលជាមួយក្រុមម៉ាក្ស-ឡេនីន (Cercle marxiste-leniniste) នៅប្រទេសបារាំង ។

ឆ្នាំ ១៩៥២៖ ទូន ជា ដែលជាកម្មាភិបាលនៃ បកឥ បានទៅវៀតណាម ដើម្បីរៀនសូត្រនយោបាយ ។ សម្តេច សីហនុ រំលាយរដ្ឋាភិបាលជាប់ឆ្នោត ។ សាឡុត ស បានចូលបក្សកុម្មុយនីសបារាំង និងអំពាវនាវឱ្យមានការផ្លាស់ប្តូររបបរាជានិយមនៅកម្ពុជាទៅជា "របបប្រជាធិបតេយ្យ"។

ឆ្នាំ ១៩៥៣៖ សាឡុត ស បានត្រឡប់មកប្រទេសកម្ពុជាវិញ ហើយបានផ្ទេរខ្លួនទៅក្នុង បកឥ ។ សម្តេច សីហនុ ប្រកាសឯករាជ្យ [នៃប្រទេសកម្ពុជា]។

ឆ្នាំ ១៩៥៤៖ សន្និសិទទីក្រុងហ្សឺណែវត្រូវបានកោះប្រជុំ ដើម្បីបញ្ចប់សង្គ្រាមឥណ្ឌូចិនលើកទី ១ ប្រកាសការឈប់បាញ់នៅ វៀតណាម កម្ពុជា និងឡាវ និងសន្យាថានឹងរៀបចំការបោះឆ្នោតដោយសេរី និងត្រឹមត្រូវ ក្រោមការត្រួតពិនិត្យអន្តរជាតិ នៅក្នុងប្រទេសទាំងបីនេះ ។ ប្រទេសវៀតណាម ត្រូវបែងចែកជា "បណ្តោះអាសន្ន" រវាងរដ្ឋបាលកុម្មុយនីសនៅភាគខាងជើង (សបវ) និងរដ្ឋបាលប្រឆាំងកុម្មុយនីសនៅភាគខាងត្បូង ។ សមាជិក បកឥ ខ្មែរជាច្រើននាក់ ដែលជាអតីតអ្នកតស៊ូ ហៅថាខ្មែរយៀកមិញ បានជម្លៀសទៅ សបវ ។ បពវ ប្រកាសមាគាំនៃការតស៊ូនយោបាយសំរាប់ប្រទេស វៀតណាម និងកម្ពុជា ។ សាឡុត ស ត្រឡប់ចូលទីក្រុងភ្នំពេញវិញដើម្បីដឹកនាំការតស៊ូនេះ ក្រោមការតាមដានជាសម្ងាត់នៃ បពវ ។ តាម៉ុក រក្សាមូលដ្ឋានកុម្មុយនីសនៅជនបទនៃភូមិភាគនិរតី ។

ឆ្នាំ ១៩៥៥៖ សម្តេចសីហនុ បានរៀបចំការបោះឆ្នោតដោយបន្លំ និងបង្ក្រាបក្រុមប្រឆាំងទាំងអស់ ក្នុងនោះរួមមានពួកកុម្មុយនីសខ្មែរដែលនៅក្នុងសម្ងាត់ផង ប៉ុន្តែអន្តរជាតិប្រកាសថា កិច្ចដំណើរការនៃការបោះឆ្នោតត្រូវបានប្រព្រឹត្តទៅដោយសេរី និងត្រឹមត្រូវ ។ ទូន ជា មកដល់ភ្នំពេញ ។ ពួកមេដឹកនាំ បពវ នៅភាគខាងត្បូង ចាប់ផ្តើមទទួលការគាំទ្រឱ្យវិលទៅធ្វើការតស៊ូដោយអាវុធនៅភាគខាងត្បូងវិញ ដោយសារថាវាមានភាពកាន់តែច្បាស់ហើយថា របបប្រឆាំងកុម្មុយនីសនឹងមិនរៀបចំឱ្យមានការបោះឆ្នោតទេ និងថែមទាំងប៉ុនប៉ងកម្ទេចរចនាសម្ព័ន្ធកុម្មុយនីសទៀតផង ។

ឆ្នាំ ១៩៥៦៖ ស៊ីវ ហេង, ទូ សាមុត និង ទូន ជា ដែលបានទទួលការបណ្តុះបណ្តាលពី បកឥ គឺជាមេដឹកនាំជាក់ស្តែងនៃចលនាកុម្មុយនីសខ្មែរដែលកំពុងស្ថិតនៅជាសម្ងាត់នៅឡើយ ប៉ុន្តែ ស៊ីវ ហេង បានទាក់ទងជាមួយប៉ូលីសសម្ងាត់របស់សម្តេចសីហនុ ។ ពួកកុម្មុយនីសវៀតណាមនៅភាគខាងត្បូង - ដែលកំពុងប្រឈមមុខនឹងការបង្ក្រាបយ៉ាងខ្លាំងក្លា - បានចាប់ផ្តើមស្វ័យការពារខ្លួនដោយអាវុធ និងបង្កើតក្រុមឃោសនិកប្រដាប់អាវុធ ។

ឆ្នាំ ១៩៥៧៖ បណ្តាញទីប្រឹក្សាកុម្មុយនីសវៀតណាមសម្ងាត់នៅកម្ពុជា អស់អនុភាពហើយ ។ ទូ សាមុត, ទូន ជា និង សាឡុត ស គឺជាមេដឹកនាំជាក់ស្តែងរបស់ចលនាកុម្មុយនីស ។

ឆ្នាំ ១៩៥៨៖ សម្តេចសីហនុ រៀបចំការបោះឆ្នោតដោយប្រញាប់ប្រញាល់ ដោយធ្វើការបង្ក្រាបពួកកុម្មុយនីសខ្មែរកាន់តែខ្លាំងថែមទៀត ។ ស៊ីវ ហេង បានបំបែកខ្លួនចូលខាងសម្តេចសីហនុ ។ ពួកកុម្មុយនីសវៀតណាមខាងត្បូងបានដឹកនាំធ្វើប្រតិបត្តិការយោធាដោយមានកំរិត ដើម្បីទប់ទល់ការបង្ក្រាបនៅភាគខាងត្បូង ។

ឆ្នាំ ១៩៥៩៖ គណៈកម្មាធិការមជ្ឈឹម បពវ នៅ សបវ អនុញ្ញាតឱ្យធ្វើការបះបោរដោយអាវុធនៅភាគខាងត្បូងវៀតណាម។ ពួកកុម្មុយនីសខ្មែរបានពិភាក្សាគ្នាថាតើត្រូវប្រកាន់គោលជំហរយ៉ាងដូចម្តេច ចំពោះរបបសម្តេចសីហនុ។

ឆ្នាំ ១៩៦០៖ បពវ និងពួកកុម្មុយនីសខ្មែរ កោះប្រជុំដោយឡែកពីគ្នា ។ បពវ ប្រថាប់ត្រាដល់ការធ្វើ "បដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យ" ដោយអាវុធនៅភាគខាងត្បូង [វៀតណាម] ។ ពួកកុម្មុយនីសខ្មែរបានបង្កើតបក្សពលករខ្មែរសម្ងាត់មួយ (បពខ) ដែលពិពណ៌នាប្រទេសកម្ពុជា ថាដូចប្រទេសវៀតណាមខាងត្បូង និងត្រៀមរៀបចំធ្វើបដិវត្តន៍ដូចគ្នាមួយផងដែរ ។ គណៈកម្មាធិការអចិន្ត្រៃយ៍នៃ បពខ រួមមាន ទូ សាមុត, នួន ជា និង សាឡុត ស ។

ឆ្នាំ ១៩៦១៖ បពខ បានបង្កើត "កងការពារ" ប្រដាប់អាវុធដូចគ្នានឹងអ្វីដែលបានបង្កើតឡើងដោយ បពវ នៅវៀតណាមខាងត្បូងនៅក្នុងឆ្នាំ ១៩៥៦ ដែរ ។

ឆ្នាំ ១៩៦២៖ សម្តេចសីហនុ ប្រើការរៀបចំការបោះឆ្នោតជាឱកាសដើម្បីបង្កើនការបង្ក្រាបពួកឆ្វេងនិយម ។ ទូ សាមុត "បាត់ខ្លួន" និងត្រូវសម្លាប់ ។ បពខ បានដកខ្លួនចេញពីការបោះឆ្នោត ។ សាឡុត ស ក្លាយជាលេខា បពខ បណ្តោះអាសន្ន ។ បពខ ទាញយកផលចំណេញពីពួកបញ្ញាជនកុម្មុយនីស និងមិនមែនកុម្មុយនីសឆ្វេងនិយម ដែលសម្តេចសីហនុសង្ស័យថាជា "ខ្មែរក្រហម"។

ឆ្នាំ ១៩៦៣៖ សមាជ បពខ បញ្ជាក់ថា សាឡុត ស ជាមេដឹកនាំ ដោយមាន នួន ជា ជាអនុ តាម៉ុក ឡើងជា សមាជិកមជ្ឈឹម ។ ការគំរាមពីការចាប់ខ្លួន ជំរុញឱ្យ សាឡុត ស និងមេដឹកនាំ បពខ ដទៃមួយចំនួនទៀតរត់ទៅវៀតណាមខាងត្បូង ។ តែ នួន ជា ស្ថិតនៅជាសម្ងាត់ជាមេបក្សនៅក្នុងទីក្រុងភ្នំពេញ លាក់ខ្លួននៅពីក្រោយសកម្មភាពសាធារណៈរបស់ "ពួកខ្មែរក្រហម" កុម្មុយនីស និងមិនមែនកុម្មុយនីស។

ឆ្នាំ ១៩៦៤៖ សម្តេចសីហនុ យល់ព្រមឱ្យពួកកុម្មុយនីសវៀតណាមបង្កើតជម្រកតូចៗ ជាបណ្តោះអាសន្នក្នុងទឹកដីកម្ពុជា។ សហរដ្ឋអាមេរិកបានចាប់ផ្តើមទម្លាក់គ្រាប់បែកលើភាគខាងជើងវៀតណាម ។ វិបត្តិសេដ្ឋកិច្ចនៅតាមជនបទប្រទេសកម្ពុជា ។ បពខ រៀបចំខ្លួនសំរាប់ធ្វើការតស៊ូដោយអាវុធនាពេលអនាគត ។

ឆ្នាំ ១៩៦៥-១៩៦៦៖ សហរដ្ឋអាមេរិកបញ្ជូនទ័ពទៅវៀតណាមខាងត្បូង ។ សម្តេចសីហនុ អនុញ្ញាតឱ្យចិនដឹកជញ្ជូនគស្តុការឆ្លងកាត់ប្រទេសកម្ពុជា ទៅផ្តល់ឱ្យពួកកុម្មុយនីសវៀតណាម។ សាឡុត ស ទៅបំពេញទស្សនៈកិច្ចនៅប៉ែកខាងជើងវៀតណាម និងប្រទេសចិន ក្នុងសេចក្តីសង្ឃឹមថានឹងទទួលបានជំនួយសំរាប់ចលនារបស់គាត់ ។ ការឃោសនារបស់វៀតណាម គូសសង្កត់អំពីសង្គ្រាមបដិវត្តន៍របស់ប្រជាជន តែពួកគេប្រាប់ សាឡុត ស កុំឱ្យយកវាមកអនុវត្តនៅកម្ពុជា ។ ចិនផ្តល់យោបល់ដល់ បពខ ឱ្យរៀនសូត្រគំរូសង្គ្រាមប្រជាជនរបស់វៀតណាម តែសំរាប់ទុកអនុវត្តនៅពេលអនាគតប៉ុណ្ណោះ ។

ឆ្នាំ ១៩៦៦៖ សម្តេចសីហនុ រៀបចំការបោះឆ្នោត ក្នុងពេលដែលមានការកើនឡើងនូវរលកនៃការរំដើបរំជួលខាងនយោបាយដឹកនាំដោយ "ខ្មែរក្រហម" និងអ្នកដទៃទៀតក្នុងទីក្រុងដែល បពខ ប៉ុនប៉ងជំរុញ និងទាញយកផលចំណេញ ។ សាឡុត ស ត្រឡប់មកវៀតណាមខាងត្បូងវិញ ហើយសំរេចរើទីតាំងទៅនៅភាគឦសាននៃកម្ពុជា និងធ្វើការត្រៀមរៀបចំបន្ថែមទៀត ដើម្បីដឹកនាំធ្វើសង្គ្រាមប្រជាជន ។

ឆ្នាំ ១៩៦៧៖ សាឡុត ស បង្កើតមូលដ្ឋាននៅក្នុងតំបន់ត្រួតត្រាដោយពួកកុម្មុយនីសវៀតណាម នៅភូមិភាគឦសាន ទុកឱ្យ នួន ជា ទទួលបន្ទុកតំបន់ដ៏ធំទូលាយដទៃទៀតនៃកម្ពុជា ។ ពួកកុម្មុយនីស ចូលរួមក្នុងការបះបោរនៅជនបទឦសាននៃកម្ពុជា ។ សម្តេចសីហនុ ប្រថាប់ត្រាឱ្យធ្វើការបង្ក្រាបដោយហឹង្សាលើពួកអ្នកបះបោរនៅជនបទ និង "ពួកខ្មែរក្រហម" នៅក្នុងទីក្រុងដែលត្រូវបង្ខំចិត្តចូលក្នុងជួរ បពខ ។ វៀតណាម និង ចិន ច្រៀង សរសើរសង្គ្រាមប្រជាជននៅវៀតណាមខាងត្បូង និងត្រៀមរៀបចំធ្វើការវាយសំរុកទូទៅមួយនៅទីនោះ តែផ្តល់ហេតុផលប្រឆាំងនឹងការធ្វើការបះបោរនៅកម្ពុជា ។ ទោះបីយ៉ាងនេះក្តី ក៏ នួន ជា នៅតែសំរេចបើកធ្វើការបះបោរទូទាំងប្រទេស ដើម្បីដណ្តើមអាវុធ និងចាប់ផ្តើមធ្វើសង្គ្រាមប្រជាជន ដោយផ្តល់ព័ត៌មានទៅ ប៉ុល ពត ជាក្រោយ ។ ពួកកុម្មុយនីសវៀតណាម រៀបចំផែនការវាយសំរុកក្នុងថ្ងៃចូលឆ្នាំវៀតណាម [ហៅថាការវាយសំរុកតេត] ដោយរំលោភលើកិច្ចព្រមព្រៀងនៃការយោគយល់គ្នាទៅវិញទៅមកជាមួយសម្តេចសីហនុ ដោយបង្កើតមូលដ្ឋានអចិន្ត្រៃយ៍ជាច្រើននៅក្នុងប្រទេសកម្ពុជា។ សម្តេចសីហនុ ចាប់ផ្តើមឃុបឃិតជាចំហជាមួយសហរដ្ឋអាមេរិក ដើម្បីគៀបសង្កត់វៀតណាមឱ្យចាកចេញទៅវិញ ។

ឆ្នាំ ១៩៦៨៖ បពវ ធ្វើការវាយសំរុកតេត និង បពខ ចាប់ផ្តើមធ្វើសង្គ្រាមប្រជាជន ។ ចិន និង វៀត ណាម បានសាកល្បងឃាត់ដែរ តែនៅតែមិនអាចបញ្ចុះបញ្ចូល បពខ ឱ្យផ្លាស់ប្តូរទិសរបស់ គេបាន ។ តាម៉ុក ក្លាយជាលេខាភូមិភាគឦសាន្ត ។ សម្តេចសីហនុ សុំជាសម្ងាត់ដល់ទីភ្នាក់ងារស៊ើបការណ៍របស់សហរដ្ឋអាមេរិក អំពីជម្រករបស់វៀតណាម ដែល លន់ ណុល មេបញ្ជាការយោធារបស់សម្តេចធ្លាប់បានធ្វើការវាយប្រហារទៅលើ ។ បន្ទាប់ពីដណ្តើមបាន ជោគជ័យជាបឋមមក ការវាយសំរុកតេត និង បពខ បានទទួលរងនូវបរាជ័យដោយវាយបកវិញយ៉ាងធ្ងន់ធ្ងរ ។

ឆ្នាំ ១៩៦៩៖ នៅវៀតណាម និង កម្ពុជា ជោគជ័យយោធាជាបឋមរបស់ពួកកុម្មុយនីស រងការវាយបកវិញកាន់តែធ្ងន់ធ្ងរថែមទៀត ប៉ុន្តែទាំង បពវ ទាំង បពខ បន្តប្រកាសថាការផ្សងព្រេងដោយអាវុធ ឆ្នាំ ១៩៦៨ របស់ពួកគេ បានធ្វើឱ្យបដិវត្តន៍របស់ពួកគេរៀងៗខ្លួនរីកចំរើនទៅមុខ ។ សម្តេចសីហនុ បានភ្ជាប់ចំណងផ្លូវទូតជាមួយសហរដ្ឋអាមេរិកជាផ្លូវការឡើងវិញ និងបោសសំអាតពួកកុម្មុយនីសបង្កប់ខ្លួននៅក្នុងទីក្រុងភ្នំពេញ ។ បពខ បានកែសំរួលនយោបាយចំពោះសម្តេចសីហនុ ។ សាឡុត ស ចេញដំណើរទៅបំពេញទស្សនៈកិច្ចនៅវៀតណាមខាងជើង និងចិន មួយលើកទៀត ។

ឆ្នាំ ១៩៧០៖ សម្តេចសីហនុ ត្រូវបានទម្លាក់ចេញពីអំណាចដោយរដ្ឋប្រហារដឹកនាំដោយ លន់ ណុល ដែលបន្ទាប់មកទទួលបានការគាំទ្ររបស់សហរដ្ឋអាមេរិក ។ សហរដ្ឋអាមេរិក ឈ្លានពានចូលផ្នែកខាងកើតនៃកម្ពុជា ។ បពខ បដិសេធការស្នើផ្តល់ជំនួយសំបូរបែបរបស់ បពវ តែ បពវ នៅតែធ្វើតាមអ្វីដែលគេបានស្នើ ។ បពខ ស្ថិតនៅជាសម្ងាត់ដដែលហើយដាក់ "ពួកខ្មែរក្រហម" នៅពីមុខ ឱ្យដើរតួជាតំណាងរបស់ពួកគេ ។

ឆ្នាំ ១៩៧១៖ បពខ ប្តូរឈ្មោះជាបក្សកុម្មុយនីសកម្ពុជា (បកក) ហើយចាប់ផ្តើមបណ្តេញកងកម្លាំងកុម្មុយនីសវៀតណាមឱ្យចេញពីកម្ពុជា ។

ឆ្នាំ ១៩៧៣៖ ពួកកុម្មុយនីសវៀតណាម ចុះហត្ថលេខាលើកិច្ចព្រមព្រៀងទីក្រុងប៉ារីស៍ ជាមួយសហរដ្ឋអាមេរិក ដែលប្រកាសអំពីការឈប់បាញ់ និងសន្យាថានឹងរៀបចំការបោះឆ្នោត តែរក្សាទុករដ្ឋាភិបាលប្រឆាំងកុម្មុយនីសឱ្យនៅដដែល។ បពវ រំពឹងថានឹងប្រែក្លាយការឈប់បាញ់នេះជាការវាយសំរុកខាងនយោបាយនៅតំបន់ជនបទ។

បពខ បដិសេធការទូន្មានរបស់វៀតណាម និងចិន ឱ្យធ្វើដូចគ្នានេះ ហើយប្ដេជ្ញាថាបន្តធ្វើសង្គ្រាមប្រជាជនរហូតដល់ដណ្ដើមបានជ័យជំនះទាំងស្រុង ។

ឆ្នាំ ១៩៧៤៖ បពវ ផ្ដល់ហេតុផលនៃការតស៊ូដោយអាវុធឡើងវិញរបស់ពួកគេ និងភាគខាងត្បូងវៀតណាម ដោយបកអាក្រាតសហរដ្ឋអាមេរិក និងរបបប្រឆាំងកុម្មុយនីសវៀតណាមខាងត្បូង ថាបានធ្វើវិទ្ធង្សនាកិច្ចព្រមព្រៀងទីក្រុងប៉ារីស៍ ដោយរាំងខ្ទប់ការវាយសំរុកខាងនយោបាយ របស់ពួកគេនៅតំបន់ជនបទ ។

ឆ្នាំ ១៩៧៥៖ សង្គ្រាមប្រជាជនរបស់ បកក បញ្ចប់ដោយជោគជ័យដោយដណ្ដើមបានទីក្រុងភ្នំពេញ ពីរអាទិត្យមុន បពវ ដណ្ដើមបានទីក្រុងព្រៃនគរ ។

ឆ្នាំ ១៩៧៦៖ បកក ប្រកាសការចាប់បដិសន្ធិនៃ កម្ពុជាប្រជាធិបតេយ្យ (កប) ។

ឆ្នាំ ១៩៧៧៖ ទីបំផុត បកក ប្រកាសចេញមុខជាចំហ ហើយ ប៉ុល ពត (សាឡុត ស) ជាមេដឹកនាំបក្ស។

ឆ្នាំ ១៩៧៧-១៩៧៨៖ ប៉ុល ពត និង នួន ជា ដឹកនាំធ្វើការបោសសំអាតដោយទ្រង់ទ្រាយធំលើកម្មាភិបាល បកក ក្នុងនេះរួមមានភាគច្រើនលើសលប់ជាអតីតកម្មាភិបាល បកឥ និង "ពួកខ្មែរក្រហម" ផង ។ តាម៉ុក ក្លាយជាមនុស្សទី៣ នៃ បកក បន្ទាប់ពី ប៉ុល ពត និង នួន ជា ។ កម្មាភិបាលជាន់ខ្ពស់ដែលនៅរស់ ភាគច្រើនលើសលប់ សុទ្ធតែមានឈ្មោះក្នុងបញ្ជីនៃមនុស្សត្រូវបោសសំអាត ។

ឆ្នាំ ១៩៧៩៖ របប កប រលំដួលដោយការឈ្លានពានរបស់វៀតណាម ។

# សេចក្តីផ្តើម

សៀវភៅនេះ ជាការបកស្រាយឡើងវិញនូវការទាក់ទងរវាងចលនាកុម្មុយនីសកម្ពុជា និងវៀតណាម ពីឆ្នាំ ១៩៣០ ដល់ឆ្នាំ ១៩៧៥ នៅពេលដែលចលនាទាំងពីរនេះដណ្តើមបានអំណាច និងបង្ហាញអំពីទំហំនៃបំណុលរបស់ពួកកុម្មុយនីសខ្មែរ ចំពោះទ្រឹស្តីកុម្មុយនីសរបស់វៀតណាម នារយៈពេលដែលចលនាកុម្មុយនីសខ្មែរចាប់បដិសន្ធិ ទោះបីជាចលនាទាំងពីរនេះមានការមិនចុះសម្រុងគ្នាអំពីអ្វីដែលត្រូវអនុវត្តនៅកម្ពុជាក៏ដោយ ។ ទិដ្ឋភាពមួយនៃការបកស្រាយឡើងវិញនេះ គឺការវាយតម្លៃលើរូបភាពដែលបង្កើតឡើងដោយពួកកុម្មុយនីសវៀតណាមនិងខ្មែរខ្លួនឯង ដែលត្រូវបានទទួលស្គាល់ដោយសម្តេចសីហនុ និងដែលត្រូវបានបរិយាយតាមដោយពួកអ្នកសិក្សាស្រាវជ្រាវ និងប្រព័ន្ធផ្សព្វផ្សាយព័ត៌មានអំពីការដែលថាចលនាកុម្មុយនីសខ្មែរគឺត្រូវបានដឹកនាំដោយពួកបញ្ញាជនដែលបានទទួលការអប់រំនៅប្រទេសបារាំងនោះ ។ វាជាការត្រួសត្រាយនូវមូលដ្ឋានសំរាប់ការយល់ជ្រួតជ្រាបពីអត្តចរិករបស់ពួកកុម្មុយនីសខ្មែរ ដែលបានរៀបចំមាគ៌ានយោបាយអនុញ្ញាតឱ្យដោយពួកកុម្មុយនីសវៀតណាម ដែលមានបំណងចង់ធ្វើជាមេដឹកនាំបដិវត្តន៍ក្នុងតំបន់ទាំងមូល ។ វាជាការនិពន្ធនូវកាលប្បវត្តិអំពីថា តើចលនាកុម្មុយនីសខ្មែរដឹកនាំដោយ សាឡុត ស (ប៉ុល ពត) និង នួន ជា (ឡាវ ឡុង ឡឺត) រហូតដល់ចលនានេះទទួលបានអំណាចក្នុងឆ្នាំ ១៩៧៥ យ៉ាងដូចម្តេច ។ ជាក់ស្តែង ជាប្រយោល វាជាការចំអក និងអត់ន័យទេ ដែលថាអ្វីដែលពួកកុម្មុយនីសខ្មែរបានដឹកនាំធ្វើរហូតដល់ឆ្នាំ ១៩៧៥ អាចត្រូវបានយល់បានថាជាការយកតម្រាប់តាម - និងជាប្រតិកម្ម - ទៅនឹងទ្រឹស្តីនិងចារិករបស់ពួកកុម្មុយនីសវៀតណាម បើប្រមើលមើលត្រឡប់ទៅក្រោយវិញ ទៅក្នុងទសវត្ស ១៩៣០ នោះ ។ វាជាការរៀបរាប់អំពីថា តើពួកវៀតណាមបានបង្រៀនពួកកុម្មុយនីស អំពីវិធានទូទៅនៃបដិវត្តន៍ និងយុទ្ធសាស្ត្រ និងយុទ្ធវិធីដោយឡែក ដើម្បីធ្វើបដិវត្តន៍ក្នុងក្របខ័ណ្ឌឥណ្ឌូចិន និងថាតើវិធានទាំងនេះត្រូវបានបញ្ចូលមកក្នុងប្រទេសកម្ពុជា យ៉ាងដូចម្តេច ។ វាជាការជួយបំភ្លឺអំពីឥរិយាបទ និងសកម្មភាពរបស់ពួកកុម្មុយនីសខ្មែរ ចំពោះពួកកុម្មុយនីសវៀតណាមដែល នៅឆ្នាំ ១៩៧៥ ស និង នួន បានកំណត់ថា "អមិត្ត" របស់បដិវត្តន៍កម្ពុជា [មិត្តដែលមានទំនាស់] ។

សៀវភៅនេះ គូសបញ្ជាក់ថា ស, នួន និងមេដឹកនាំកុម្មុយនីសដទៃទៀត ដូចជា សោ ភឹម និង តាម៉ុក ត្រូវបានបំពាក់បំប៉ន និង បើពុំដូច្នោះទេ ត្រូវបានជ្រួតជ្រាបអំពីលទ្ធិកុម្មុយនីសវៀតណាមតាំងពីដើមទសវត្ស ១៩៥០ មក នៅពេលដែលពួកគេជាសមាជិកបក្សកុម្មុយនីសឥណ្ឌូចិនដឹកនាំដោយវៀតណាម (បកឥ) និងចលនាកុម្មុយនីសខ្មែរស្ថិតក្រោមការដឹកនាំរបស់ពួកកុម្មុយនីសវៀតណាម ។ ចំពោះ ស ការណ៍នេះធ្វើឱ្យយល់ថា ក្នុងរយៈពេលយូរអង្វែងវាមានសារសំខាន់ជាងការបំពាក់បំប៉នខាងទ្រឹស្តី ដែលរូបគេបានទទួលក្នុងរយៈពេលរស់នៅដ៏ខ្លីជានិស្សិតរៀនខាងវិជ្ជាជីវៈនៅប្រទេសបារាំង ទោះបីជាយុគសម័យនៃគម្ពីរនិយម [orthodoxy] របស់សូវៀត ដែលរូបគេបានឆ្លងកាត់នៅអឺរ៉ុប បានជួយដល់រូបគេក្នុងការកំណត់បន្ទាត់មនោគមវិជ្ជានាពេលអនាគត ក៏ដោយ ។ វាធ្វើឱ្យមានទស្សនៈថ្មីមួយចំពោះតួនាទីមុនឆ្នាំ ១៩៧៥ របស់ ខៀវ សំផន និងពួកបញ្ញាជនដែលបានទទួលការអប់រំនៅប្រទេសបារាំង ដូចជា ហ៊ូ យន់, ហ៊ូ នឹម, អៀង សារី និង សុន សេន ក្នុងចលនាកុម្មុយនីសខ្មែរ ។ វាសន្និដ្ឋានថា យ៉ាងហោចណាស់ក៏រហូតដល់ចុងទសវត្ស ១៩៦០ ដែរ ខៀវ សំផន, ហ៊ូ យន់ និង ហ៊ូ នឹម ពុំមានអត្តសញ្ញាណក្នុងចលនាទេ តែប្រជាប្រិយភាពរបស់ពួកគេត្រូវបានពួកកុម្មុយនីសកែប្រែយកចំណេញ ដើម្បីផ្តល់ដល់ចលនារបស់ពួកគេនូវមុខមាត់ជាសាធារណៈដែលនាំឱ្យមានការយល់ច្រឡំ ។ វានាំឱ្យយល់ថា ក្រោយពេលត្រឡប់មកពីប្រទេសបារាំងវិញ អៀង សារី ជាមនុស្សមាននិន្នាការកណ្តាលដោយប្រៀបធៀប នៅក្នុងបក្សកុម្មុយនីសកម្ពុជា ក៏ប៉ុន្តែ ទាំងរូបគេ ទាំង សុន សេន សឹងតែបានចូលជ្រៅទៅក្នុងមនោគមវិជ្ជារបស់វៀតណាមដូច ស, នួន, សោ ភឹម និងតាម៉ុក នៅពេលពួកគេស្ថិតក្រោមការគ្រប់គ្រងរបស់អ្នកបីនាក់ដំបូង ក្នុងចំណោមមនុស្សទាំងបួននាក់នេះ ។

*សៀវភៅនេះបង្ហាញថា មេរៀនដំបូងៗបំផុតនិងដែលសឹងតែទទួលផ្ទាល់ពីពួកវៀតណាម បានបង្រៀនដល់ពួកខ្មែរថា ដើម្បីដណ្តើមអំណាចបានទាមទារឱ្យចេះលាក់ការសម្ងាត់ ធ្វើជាមិនដឹងមិនឮអំពីលទ្ធិកុម្មុយនីស កសាងមុខមាត់មិនមែនកុម្មុយនីសមួយ ដាច់ខាតប្រើមធ្យោបាយហឹង្សា - សំខាន់បំផុតគឺ "សង្គ្រាមប្រជាជន" - ដើម្បីសំរេចទិសដៅនៃបដិវត្តន៍ និងបដិសេធការពាក់ព័ន្ធរបស់វៀតណាម និងបំណុលខាងទ្រឹស្តីដ៏ជ្រាលជ្រៅចំពោះកុម្មុយនីសនិយមវៀតណាម ។*

*ដូច្នេះ វាជាការបើកកកាយថា ការប្រកាសទាំងឡាយយ៉ាងទទូច និងស្រដែលៗ របស់ ស និងថ្នាក់ដឹកនាំកុម្មុយនីសខ្មែរដទៃទៀតក្រោយឆ្នាំ ១៩៧៥ ដែលថាពួកគេមិនដែលបានចម្លងអ្វីៗទាំងអស់ពីអ្នកដទៃទាល់តែសោះ ហើយជាងនេះទៅទៀតពីពួកវៀតណាមនោះ វាមិនត្រឹមតែមិនអាចការពារបានក្នុងន័យនៃភាពជិតស្និទ្ធ ដែលពួកគេបានធ្វើតាមផែនការរបស់វៀតណាមប៉ុណ្ណោះទេ តែជាក់ស្តែង ពួកគេខ្លួនឯងផ្ទាល់គឺជាស្រមោលនៃភាពស្មោះត្រង់ចំពោះគំរូរបស់វៀតណាមថែមទៀតផង ។ តាមគំរូនេះ ពួកកុម្មុយនីសខ្មែរបានបិទបាំងបំណុលទាំងអស់របស់ពួកគេចំពោះវៀតណាម ដោយបញ្ចេញមុខមាត់ជាសាធារណៈមួយដើម្បីលាក់បាំងនូវការពិតនេះ និងលាក់វិសាលភាពនៃឥទ្ធិពលរបស់វៀតណាមលើពួកគេ ។ នេះគឺជាទស្សនៈវិន័យមួយដែល ស, នួន, សោ ភឹម, អៀង សារី, សុន សេន និង តាម៉ុក បានប្រកាន់យ៉ាងខ្ជាប់ខ្ជួន ។ នៅទីបញ្ចប់ ពួកគេអាចមានជោគជ័យក្នុងការកុតកុហកខ្លួនឯងរហូតដល់ជឿលើការបដិសេធរបស់ពួកគេផ្ទាល់ទៀតផង ។*

*ក្នុងចំណោមមេរៀនដទៃទៀត ដែលខ្មែរនៅតែស្មោះត្រង់ជានិច្ចនោះ - ប្រហែលជាអ្វីដែលសំខាន់ជាងគេបំផុតផងនោះ - គឺការសន្មត់ជាតួយ៉ាងដ៏ជ្រាលជ្រៅមួយ នោះគឺៈ ការធ្វើតាមរូបមន្តដោយមិនអើពើនឹងអង្គហេតុអ្វីទាំងអស់ ហើយការប្រើហឹង្សាគឺជាទ្រឹស្តីចាំបាច់ទូទៅ មិនត្រឹមតែនៅពេលអង្គហេតុមិនច្បាស់លាស់ប៉ុណ្ណោះទេ តែទោះបីជាអង្គហេតុនោះវាផ្ទុយនឹងរូបមន្តក៏ដោយ ។ មេរៀនជាមូលដ្ឋានបំផុតនេះរបស់ពួកកុម្មុយនីសវៀតណាម បាននៅរស់រានមានជីវិត និងបានក្លាយជាមូលដ្ឋានដែលពួកកុម្មុយនីសខ្មែរបានបំពាន និងនៅទីបំផុតបដិសេធបញ្ហាចំនួនពីររបស់វៀតណាម ពោលគឺថាៈ បដិវត្តន៍កម្ពុជាត្រូវតែស្ថិតនៅពីក្រោយបដិវត្តន៍វៀតណាម និងត្រូវតែធ្វើតាមដំបូន្មានរបស់វៀតណាមជានិច្ច ។ ពេញមួយរយៈពេលដ៏យូរ ចាប់តាំងពីទសវត្ស ១៩៥០ មក ពួកកុម្មុយនីសខ្មែរបានទប់ទល់នឹងដំបូន្មាននេះ ដោយបង្កើននូវភាពភៀវក្លា និងនៅទីបញ្ចប់អំពើហឹង្សាដាច់ខាតនិយមមួយ ។*

*ពួកវៀតណាម ជានិច្ចកាលតែងតែជជែកថាប្រទេសកម្ពុជាជាការលើកលែងមួយដែលមានសារសំខាន់ក្នុងកម្រិតណាមួយ ទាំងចំពោះវិធានទូទៅនៃបដិវត្តន៍ និងទាំងការអនុវត្តនៃវិធាននេះនៅឥណ្ឌូចិន ។ ពួកគេជជែកថា ដោយយោលទៅលើស្ថានភាពសង្គមនៃប្រទេសកម្ពុជានោះ គេមិនអាចអនុវត្តនូវវិធានទាំងអស់បានទេ យ៉ាងហោចណាស់ក្នុងផ្លូវដូចដែលពួកគេបានអនុវត្តនៅវៀតណាមនោះដែរ ។ ក្រោយមកទៀតពួកគេបានជជែកថា បើអនុវត្តវាដូច្នោះ នោះប្រទេសកម្ពុជានឹងប្រព្រឹត្តផ្ទុយទៅនឹងផលប្រយោជន៍រួមនៃបដិវត្តន៍ឥណ្ឌូចិនទាំងមូល។*

*មូលហេតុ គឺកិច្ចព្រមព្រៀងទីក្រុងហ្សឺណែវឆ្នាំ ១៩៥៤ ដែលបានបញ្ចប់សង្គ្រាមឥណ្ឌូចិនលើកទី ១ ដែលបានចាប់ផ្តើមនៅឆ្នាំ ១៩៤៦ នោះ ។ ជាសំខាន់ កិច្ចព្រមព្រៀងទាំងនោះ បានធ្វើឱ្យពួកកុម្មុយនីសវៀតណាមខាតបង់នូវការត្រួតត្រាលើចលនាកុម្មុយនីសខ្មែរ ។ មុនកិច្ចព្រមព្រៀងទីក្រុងហ្សឺណែវនេះ នៅពេលដែលពួកវៀតណាមបានដឹកនាំធ្វើការតស៊ូដោយអាវុធដោយផ្ទាល់ប្រឆាំងអាណានិគមនិយមបារាំង (និងចក្រពត្តិនិយមអាមេរិក) នៅពាសពេញឥណ្ឌូចិនទាំងមូលនោះ ទ្រឹស្តីរបស់វៀតណាមបានដាក់ជនកម្ពុជាក្នុងប្រភេទនៃអារ្យធម៌នយោបាយទាបជាងពួកគេ រហូតដល់ស្មើនឹងពួកកុលសម្ព័ន្ធនៃប្រទេសអាហ្វ្រិក និងពួកពនេចរនៃទ្វីបអាស៊ីកណ្តាលទៀតផង ។ ទោះបីជាវាមានការពិតខាងសេដ្ឋកិច្ចសង្គមខ្លះនៅក្នុងចំណាត់ថ្នាក់របស់វៀតណាមក៏ដោយ ក៏វាជាការបំផ្លើសដើម្បីធ្វើយុត្តិកម្មសំរាប់ឱ្យវៀតណាមដឹកនាំនៅកម្ពុជា និងធ្វើការបដិវត្តន៍កំរិតទាបនៅកម្ពុជានោះដែរ ។*

ប៉ុន្មានឆ្នាំភ្លាមៗក្រោយសន្និសិទទីក្រុងហ្សឺណែវ វៀតណាមហាក់ដូចជាសុខចិត្តទទួលស្គាល់ថាមានការប្រៀបធៀបគ្នាបានមួយកំរិត រវាងកម្ពុជា និងវៀតណាម ។ នៅឆ្នាំ ១៩៦០ ក្រៅពីពួកគេបានបោះបង់ចោលខ្មែរឱ្យស្ថិតនៅតាមមធ្យោបាយផ្ទាល់របស់ពួកគេនោះ ខ្មែរបានប្រកាសស្ថានភាពដូចគ្នាទៅនឹងវៀតណាម និងដែលវៀតណាមមិនមានការជំទាស់ ។ នៅឆ្នាំដដែលនោះ ខ្មែរបានបង្កើតបក្សកុម្មុយនីសផ្ទាល់របស់ពួកគេ នោះគឺបក្សពលករខ្មែរ (បពខ) ដែលជាការចម្លងស្ទើរតែទាំងស្រុងមកពីបក្សពលករវៀតណាម (បពវ) ដែលវៀតណាមបានយកចេញមកពី បកឥ កាលពីមុន ។ បពវ មិនបានជំទាស់ទៅនឹងគំរោងជាច្រើននៃវិធីដោះស្រាយរបស់ បពខ ឆ្ពោះទៅការធ្វើបដិវត្តន៍នៅកម្ពុជា ដែលបានធ្វើត្រាប់តាមដែលមិនគួរឱ្យជឿនូវការរៀបរាប់របស់វៀតណាមស្តីអំពីសង្គមកម្ពុជានិងនយោបាយ តែបានយល់ស្របទៅនឹងដំបូន្មានរបស់វៀតណាម ដែលថាកម្ពុជាមិនទាន់បានត្រៀមខ្លួនធ្វើបដិវត្តន៍ដូចនៅវៀតណាមទេ ។ ជាពិសេស បពខ បានយល់ស្របថា ជនកម្ពុជាមិនត្រូវដេញដើងនូវអ្វីដែល បពវ - ដែលបានគ្រប់គ្រងភាគខាងជើងវៀតណាម - ទើបបានធ្វើនៅភាគខាងត្បូងវៀតណាមទេ ។ នេះគឺការចាប់ផ្តើមការតស៊ូដោយអាវុធឡើងវិញ ដែលត្រូវបានផ្អាកនៅទូទាំងឥណ្ឌូចិន តាមខ្លឹមសារនៃកិច្ចព្រមព្រៀងទីក្រុងហ្សឺណែវ ដូច្នេះ បពវ កំពុងចូលខ្លួនក្នុងសង្គ្រាមឥណ្ឌូចិនលើកទី ២ ដោយបានធ្វើការតស៊ូដោយអាវុធប្រឆាំងរដ្ឋបាលមិនមែនកុម្មុយនីសគាំទ្រដោយសហរដ្ឋអាមេរិកនៅភាគខាងត្បូងវៀតណាម មានលទ្ធភាពប្រកាសការតម្លើងស្ថានភាពថ្មីមួយ តាមរយៈសង្គ្រាមប្រជាជនប្រឆាំងចក្រពត្តិអាមេរិករបស់ពួកគេ ។ នៅពាក់កណ្តាលឆ្នាំ ១៩៦០ ការនេះបានដាក់ពួកគេឱ្យស្ថិតនៅជួរខ្ពស់បំផុតនៃបដិវត្តន៍សកលលោក ដែលជាស្ថានភាពមួយដែលខ្មែរបានបដិសេធ ។

ដូច្នេះ ទោះបីជាហេតុផលអាចផ្លាស់ប្តូរ - ឬត្រួតលើគ្នា - ចំពោះវៀតណាមក៏ដោយ ក៏កម្ពុជាមិនដែលបានរៀបចំខ្លួនដើម្បីធ្វើបដិវត្តន៍បែបវៀតណាមទាល់តែសោះ ។ មុនសន្និសិទទីក្រុងហ្សឺណែវ កម្ពុជាត្រូវបានមើលឃើញថាជាប្រទេសឱនថយដូចប្រទេសនានានៅទ្វីបអាហ្វ្រិក បន្ទាប់ពីសន្និសិទទីក្រុងហ្សឺណែវនិងការប្រែប្រួលសង្គមសេដ្ឋកិច្ចមក បានធ្វើឱ្យការវាយតម្លៃបែបនេះលែងមានទម្ងន់ទៀតហើយ វៀតណាមក៏បានផ្លាស់ប្តូរការវិភាគរបស់ពួកគេដែរ ។ ផ្នែកមួយសំខាន់ក្នុងការវាយតម្លៃជាថ្មី បានពិនិត្យឡើងវិញនូវទស្សនៈរបស់ពួកគេស្តីពីតួនាទីរបស់សម្តេចព្រះនរោត្តមសីហនុ ។ ដោយត្រូវបានជ្រើសរើសដោយបារាំង ឱ្យឡើងគ្រងរាជ្យសម្បត្តិនៅកម្ពុជាក្នុងឆ្នាំ ១៩៤១ សម្តេចសីហនុ បានដាក់រាជ្យនៅឆ្នាំ ១៩៥៥ តែនៅតែស្ថិតនៅជាអ្នកនយោបាយដ៏មានឥទ្ធិពលយ៉ាងខ្លាំងនៃប្រទេសនេះ ។ មុនកិច្ចព្រមព្រៀងទីក្រុងហ្សឺណែវ សម្តេចត្រូវបានទទួលរងការវាយប្រហារពីវៀតណាមថាជាស្តេចប្រតិកិរិយា និងជាអាយ៉ងដាច់ថ្លៃរបស់ចក្រពត្តិនិយមអាមេរិក ។ ក្រោយហ្សឺណែវ លោកត្រូវបានពិព័ណនាថាជាអ្នកចំរើន ជាស្តេច ប្រឆាំងចក្រពត្តិនិយម ដែលការតស៊ូដោយអាវុធប្រឆាំងព្រះអង្គជាការមិនត្រឹមត្រូវទៅវិញ។ នៅពេលដែលទឡ្ហីករនេះមានអត្ថន័យក្នុងការជាក់ស្តែង វាក៏ត្រូវបានបំភ្លៃ និងប្រើ ដើម្បីរក្សាបដិវត្តន៍កម្ពុជាឱ្យនៅនឹងកន្លែងដដែល។ ការនេះបានក្លាយកាន់តែច្បាស់ នៅពេលសម្តេចសីហនុបានធ្វើការបង្ក្រាបពួកកុម្មុយនីស និងពួកឆ្វេងនិយមកាន់ តែខ្លាំង ហើយការបំភ្លៃនេះមានសភាពកាន់តែចំហ នៅពេលវៀតណាមខិតខំអះអាងថា លន់ ណុល ដែលជាមេបញ្ជាការយោធារបស់សម្តេចសីហនុ -ដែលទទួលខុសតាំងពីដំបូងចំពោះការបង្ក្រាបប្រឆាំងកុម្មុយនីស- ថាជាមិត្តនៃបដិវត្តន៍ឥណ្ឌូចិន ដោយសារគាត់បានសម្របខ្លួនទៅនឹងចរន្តប្រឆាំងអាមេរិកក្នុងនយោបាយការទូតរបស់បារាំង ដែលមិននិយមសហរដ្ឋអាមេរិក។

ការនេះបានបញ្ចេញឱ្យឃើញនូវហេតុផលសំខាន់បំផុត ចំពោះការប្រឆាំងរបស់វៀតណាមដល់ការតស៊ូដោយអាវុធនៅកម្ពុជា នៅទសវត្ស៍ ១៩៦០ និងថេរវេលាដែលពួកគេបានទៅដឹកនាំឱ្យវាចេញដំណើរ ។ ការនេះបានធ្វើឱ្យមានការខកចិត្តដល់កិច្ចព្រមព្រៀងរបស់សម្តេចសីហនុ និង លន់ ណុល ដើម្បីអនុញ្ញាតឱ្យចិនកុម្មុយនីសដឹកជញ្ជូនភស្តុភារសង្គ្រាមឆ្លងកាត់ទឹកដីកម្ពុជាទៅឱ្យ បពវ និងអនុញ្ញាតឱ្យកងកម្លាំងវៀតណាមធ្វើជម្រកនៅក្នុងទឹកដីកម្ពុជា ដើម្បីគេចពីប្រតិបត្តិការយោធានៅភាគខាងត្បូង ។ គឺដើម្បីការពារផ្លូវដឹកជញ្ជូន និងជម្រកនេះហើយ ដែលទឡ្ហីកររបស់វៀតណាមបានយកមកធ្វើជាលេសម្តងហើយ

ម្តងទៀតពេញមួយរយៈពេលពាក់កណ្តាលទី ២ នៃទសវត្ស ១៩៦០ នៅពេលដែលវោហាសាស្រ្តជាសាធារណៈ និងសកម្មភាពផ្ទាល់របស់ពួកគេនៅភាគខាងត្បូងវៀតណាម បានផ្តល់ឱ្យ បពវ នូវការលើកទឹកចិត្តដើម្បីដឹកនាំធ្វើកុប្បកម្មប្រដាប់អាវុធ តែពួកគេបានទទូចជាសម្ងាត់ថា បពខ មិនត្រូវធ្វើដូច្នេះនោះទេ ។ ពួកគេបានទទួលការគាំទ្រដោយពេញទំហឹងដល់ការហក់លោតរបស់ពួកគេនេះដោយពួកកុម្មុយនីសចិន ដែលតែងតែជំរុញវៀតណាមឱ្យទប់បដិវត្តន៍កម្ពុជាកុំឱ្យវាកញ្ជ្រោលឡើង ។

ចំពោះពួកគេវិញ ពួកកុម្មុយនីសកម្ពុជាបានធ្វើដំណើរដូចគ្នានឹងវៀតណាមដែរ តែក្នុងទិសបញ្ច្រាសទៅវិញ ។ នៅពេលដែលពួកកុម្មុយនីសវៀតណាមនិយាយបំផ្លើសអំពីហេតុផលដែលថា កម្ពុជាខុសពីវៀតណាមនោះ ពួកកុម្មុយនីសខ្មែរបានខិតខំយ៉ាងខ្លាំង ដើម្បីប្រឹងឱតឡើងនូវភាពដូចគ្នារវាងកម្ពុជានិងភាគខាងត្បូងវៀតណាម ដែលធ្វើឱ្យទ្រឹស្តីរបស់វៀតណាមអាចអនុវត្តបាននៅកម្ពុជាដែរនោះ ។ ជាពិសេស បពខ បានអះអាងថា កម្ពុជារបស់សម្តេចសីហនុ ជាអាណានិគមនិយមថ្មីរបស់សហរដ្ឋអាមេរិក ដូចរបបប្រឆាំងកុម្មុយនីសព្រៃនគរនៅភាគខាងត្បូងវៀតណាមដែរ និងថាជនបទកម្ពុជាត្រូវបានពិព័ណនាថាមានទំនាស់ក្នុងប្រពលភាពដូចគ្នារវាងម្ចាស់ដីនិងកសិករ ដូចនៅភាគខាងត្បូងវៀតណាមដែរ បើទោះបីជាគោលជំហរទាំងពីរនេះ ជាក់ស្តែង មានភាពផ្ទុយគ្នាទៅនឹងអង្គហេតុដែលទទួលបានក៏ដោយ ។

ដោយចេះតែបន្តផ្តល់ឱវាទដល់ជនកម្ពុជាកុំឱ្យធ្វើការតស៊ូដោយអាវុធ ដើម្បីផ្តួលរំលំរបបសម្តេចសីហនុ នាចុងទសវត្ស ១៩៦០ វៀតណាមក៏បានរំលឹកជាថ្មីឡើងវិញនូវការសន្យាជាយូរមកហើយរបស់គេ ដែលថានឹងធ្វើឱ្យសភាពការណ៍ប្រែប្រួលនៅពេលសហរដ្ឋអាមេរិកត្រូវបរាជ័យនៅវៀតណាម ដោយបន្ទាប់មកពួកគេនឹងជួយកម្ពុជាដើម្បីរំដោះប្រទេសកម្ពុជាចេញ ពីចក្រពត្តិនិយមនិងសក្តិភូមិនិយម ។ ការនេះបានផ្តល់ដល់ពួកកុម្មុយនីសខ្មែរនូវជម្រើស ៣៖ បោះបង់ចោលផែនការធ្វើបដិវត្តន៍របស់ពួកគេ ធ្វើតាមផែនការធ្វើបដិវត្តន៍របស់ពួកគេដោយពឹងលើអន្តរាគមន៍យោធាវៀតណាម ឬបំពានលើឱវាទរបស់វៀតណាម ។ ដោយបន្តធ្វើតាមចរន្តចុងក្រោយនេះ បពខ សង្ឃឹមថានឹងជៀសវាងការត្រួតត្រារបស់វៀតណាមបាន ដោយធ្វើតាមក្រិត្យក្រមទូទៅនៃបដិវត្តន៍នៅទូទាំងសកលលោក និងក្រិត្យក្រមដោយឡែកនៃបដិវត្តន៍នៅឥណ្ឌូចិន ដោយផ្តាច់ចេញពីវៀតណាម ក្នុងនេះរួមមានការតស៊ូដោយអាវុធតាមរយៈសង្គ្រាមប្រជាជនជាសំខាន់ជាងគេ ។

ដោយយោងទៅលើពុតត្បុតរបស់វៀតណាម ពួកកុម្មុយនីសខ្មែរដែលបានជ្រើសរើសយកផ្លូវនេះបានបដិសេធមិនពិចារណាថាវៀតណាមមានយោបល់ត្រឹមត្រូវ ដែលថាសភាពការណ៍នៅកម្ពុជាមិនសមស្របនឹងការប្រើហិង្សាប្រភេទដូចដែលវៀតណាមបានប្រើដោយជោគជ័យ ដើម្បីផ្តួលរំលំរដ្ឋបាលប្រឆាំងកុម្មុយនីសនៅតំបន់ជនបទនៃភាគខាងត្បូងវៀតណាម នាដើមទសវត្ស ១៩៦០ នោះទេ ។ នៅទីនោះ ហិង្សាអាចដំណើរការទៅបាន មិនមែនបណ្តាលមកតែពីវាបានធ្វើឱ្យមន្ត្រីនិងរដ្ឋបាលមូលដ្ឋានមានការភិតភ័យនោះទេ តែដោយសាររចនាសម្ព័ន្ធវណ្ណៈ និងសភាពការណ៍នយោបាយ ស្ថិតក្នុងសភាពដែលអំណោយផលឱ្យមានមូលដ្ឋានសង្គមនយោបាយមួយ សំរាប់ធ្វើឱ្យរដ្ឋបាលនោះរង្គោះរង្គើរបាន ។

នៅពេល បពខ សាកល្បងធ្វើដូចគ្នានៅចុងទសវត្ស ១៩៦០ ដែរនោះ លទ្ធផលយ៉ាងល្អបំផុតគឺចំរុះ ។ បើមើលថយទៅក្រោយវិញនោះ ស និង នួន នឹងប្រកាសថាជាជោគជ័យយ៉ាងធំ ចំណែកឯ បពវ វិញ បានវាយប្រហារថា ការផ្សងព្រេងបដិវត្តន៍របស់ពួកគេនោះបានបណ្តាលឱ្យមានការហិនហោចយ៉ាងច្បាស់ដល់ចលនាកុម្មុយនីសខ្មែរ ។ មានការពិបាកនឹងស្ទង់ណាស់រវាងការឃោសនាទាំងពីរនេះ តែជាការច្បាស់ណាស់ដែលថា ទោះបីជាការធ្វើកុប្បកម្មរបស់ខ្មែរទទួលបានជោគជ័យដោយប្រការណាមួយនោះ នៅទីកន្លែងខ្លះ ក៏រដ្ឋបាលរបស់រដ្ឋាភិបាលមូលដ្ឋានមិនមានការរង្គោះរង្គើរនៅកន្លែងណាមួយទេ បើប្រៀបធៀបទៅវិសាលភាពនៅភាគខាងត្បូងវៀតណាមនោះ ។

ដូច្នេះ បើយោងតាមភស្តុតាង ពួកកុម្មុយនីស្តខ្មែរបានប្រទូស្តរ៉ាយចំពោះការពិត នៅពេលពួកគេបានទទួចចាត់ទុកកម្ពុជាថាដូចវៀតណាម ក្នុងន័យជាចារិកលក្ខណៈខាងសង្គមនិងនយោបាយ រចនាសម្ព័ន្ធវណ្ណៈ និងការឃុបឃិតគ្នារវាងវរជនរបស់គេ និងចក្រពត្តិអាមេរិកនោះ ។ ការបកស្រាយរបស់វៀតណាមចំពោះប្រទេសកម្ពុជា គឺខាងវិស័យសេដ្ឋកិច្ចផងដែរ ដោយសារថានៅពេលវៀតណាមបដិសេធថាគ្មានទំនាស់សង្គម និងនយោបាយដែលចេះតែធ្ងន់ធ្ងរឡើងៗនៅទីនោះ ពួកគេក៏បានសាកល្បងទាក់ទាញពួកអ្នកនៅជុំវិញសម្តេចសីហនុ និង លន់ ណុល ដោយធ្វើការបំពាក់បំប៉នជាបណ្តើរៗ ដែលពួកគេមានលទ្ធភាពទទួលយកបាន ។ មិនតែប៉ុណ្ណោះ សៀវភៅនេះថែមទាំងបានលើកឡើងថា ទោះបីមានជម្លោះទាំងនេះ - ដែលបានផ្ទុះបញ្ចាំងពីការប្រឆាំងចេះតែកើនឡើងរបស់ប្រជាជនចំពោះសម្តេចសីហនុ និង លន់ ណុល ក្តី - ក៏ដោយ ក៏មិនអាចពន្យល់ដោយមានហេតុផលទៅលើការពិព័ណនាអំពីកម្ពុជាដោយ បពវ ដូចដែលវៀតណាម ឬបពវ រៀបរាប់អំពីរបបសម្តេចសីហនុ ដោយពួកគេបានផ្តល់មូលដ្ឋានគ្រប់គ្រាន់ដើម្បីដឹកនាំធ្វើបដិវត្តន៍បែបវៀតណាមនៅកម្ពុជា និងដើម្បីគាំទ្រការប្រឌិតរបស់ពួកកុម្មុយនីសកម្ពុជានាពេលក្រោយមកនិងកលល្បិចវិភាគដោយអសុទ្ធចិត្តរបស់ពួកកុម្មុយនីសវៀតណាមដែរ ។

ជាពិសេស ទោះបីជាពុំមានវត្តមាននៃជម្លោះវណ្ណៈជាកំណត់មួយរវាងពួកម្ចាស់ដី និងកសិករនៅក្នុងប្រទេសកម្ពុជា និងដោយមិនបានគិតគូដល់ថាតើវៀតណាមមើលមកការទាក់ទងរវាងវណ្ណៈនៅជនបទកម្ពុជាក៏ដោយ ក៏តាមការពិតមានភាពមិនស្រួលកាន់តែខ្លាំងឡើងៗនៅតំបន់ជនបទហើយ ។ ការណ៍នេះ បានបង្កើតមូលដ្ឋាននៃកុប្បកម្មហឹង្សាមួយចំនួន ដោយមានការចូលរួមរបស់អ្នកជនបទមួយចំនួនគួរឱ្យកត់សំគាល់ ដែលអាចធ្វើឱ្យពួកគេជឿថា មូលហេតុនៃទុគ៌តភាពរបស់ពួកគេ គឺបណ្តាលមកពីការជិះជាន់របស់ពួកសក្តិភូមិសីហនុ និងការគៀបសង្កត់របស់ពួក លន់ ណុល លើកសិករក្រ ដោយពួកសក្តិភូមិម្ចាស់ដី ។ ភាពមិនស្រួលនៅជនបទនេះ បាននាំឱ្យមានវិបត្តិនយោបាយនៅតាមទីក្រុងនានាៈ ដោយមានការលេចឡើងនូវការចាប់កំណើតនៃសង្គមស៊ីវិលទីក្រុងមួយ បង្កើតឡើងដោយចលនាកែទម្រង់និយម និងចលនាដាច់ខាត ដែលឯករាជពីរដ្ឋ របស់សម្តេចសីហនុ និងពី បពខ ដែលគំរាមកំហែងនឹងធ្វើការវាយទន្ទ្រះទម្លាយមួយបាននោះ ។ ការណ៍នេះអាចជំរុញឱ្យមានការមានប្រៀបរបស់ពួកកុម្មុយនីស និងមានការបកស្រាយថយក្រោយវិញថាជាការអំណោយផលដល់ការធ្វើបដិវត្តន៍ដឹកនាំដោយពួកកុម្មុយនីសមួយបាន ។

ការរំជើបរំជួលរបស់កសិករនៅជនបទ និងចលនានយោបាយក្នុងទីក្រុង ដែលបានលេចចេញឡើងនៅក្នុងប្រទេសកម្ពុជាតាំងពីដើមទសវត្សរ៍ ១៩៦០ បានផ្ទុះឡើងជាប្រពលកម្មនៅឆ្នាំ ១៩៦៧ ហាក់ដូចជាបញ្ជាក់ថា សភាពការណ៍នយោបាយត្រូវបានវិវត្តន៍ហើយ ។ ការណ៍នេះបានផ្តល់ភស្តុតាងគ្រប់គ្រាន់ អំពីភាពដូចគ្នា រវាងកម្ពុជានិងភាគខាងត្បូងវៀតណាម ដើម្បីគាំទ្រដល់ការប៉ុនប៉ងគួរឱ្យជឿទុកចិត្តបានគ្រប់គ្រាន់ដ៏ត្រឹមត្រូវ ក្នុងការដឹកនាំធ្វើសង្គ្រាមប្រជាជនមួយដើម្បីបញ្ជាក់នូវការសន្និដ្ឋាននេះ ។ រដ្ឋប្រហាររបស់ លន់ ណុល ដែលបានទម្លាក់សម្តេចសីហនុ ក្នុងឆ្នាំ ១៩៧០ និងព្រឹត្តការណ៍ជាបន្តបន្ទាប់ក្រោយមក បានបង្អាក់លទ្ធភាពនៃការលាតត្រដាងសភាពការណ៍ពិតនេះ ។ បន្ទាប់មក ពួកកុម្មុយនីសខ្មែរមានការងាយស្រួល ដើម្បីប្រកាស - និងដើម្បីបញ្ចុះបញ្ចូលពួកគេផ្ទាល់អំពីសេចក្តីប្រកាសរបស់ពួកនេះ - ថាមុននេះ ពួកគេហៀបតែបានទទួលជោគជ័យក្នុងការអនុវត្តក្រិត្យក្រមនៃសង្គ្រាមប្រជាជនបែបវៀតណាមនៅកម្ពុជាទៅហើយ ។ ជ័យជំនះយ៉ាងរហ័សនៅតំបន់មួយចំនួន ត្រូវបានប្រកាសថាជាជោគជ័យជាមូលដ្ឋាននៅគ្រប់ទិសទី ដែលធ្វើឱ្យជំនឿអកុសលរបស់ពួកកុម្មុយនីសខ្មែរ ឬយ៉ាងហោចណាស់រូបមន្តរបស់ពួកគេអាចដំណើរការបាន ។ ដូច្នេះ លទ្ធផលនៃការសាកល្បងរបស់ពួកកុម្មុយនីសខ្មែរ ចំពោះការប៉ាន់ស្មានថាកម្ពុជាទុំហើយដើម្បីបដិវត្តន៍នោះ - ទោះបីការណ៍នេះបានឈរលើមូលដ្ឋាននៃទ្រឹស្តី និងការដាក់ស្តែង មិនត្រឹមត្រូវក៏ដោយ - មានភាពស្រពិចស្រពិលដែលថាបន្ទាប់ពីការទម្លាក់សម្តេចសីហនុក្នុងឆ្នាំ ១៩៧០ ពួកកុម្មុយនីសខ្មែរមានលទ្ធភាពប្រកាសថា ទ្រឹស្តីរបស់ពួកគេត្រឹមត្រូវ ពោលគឺៈ ហឹង្សាបែបវៀតណាមគឺជាជោគជ័យមួយនោះ ។ ចំពោះហេតុផលផ្ទាល់

*របស់ពួកគេ បពវ បានក្រឡាស់ខ្លួនគេចេញ និងគាំទ្រដល់សើរើនិយមមិនមែនជាប្រវត្តិសាស្ត្រនេះវិញ ។ ការណ៍នេះបានផ្តល់ជាឱកាសមួយដល់ពួកកុម្មុយនីសខ្មែរ ដើម្បីធ្វើការបកស្រាយជ័យជំនះនៃសង្គ្រាមប្រជាជន ឆ្នាំ ១៩៧០-១៩៧៥ ដែលមិនបានគិតទុកជាមុន ដែលនាំពួកគេទៅកាន់អំណាចមួយអាទិត្យ មុនពួកកុម្មុយនីសវៀតណាមដណ្តើមបានព្រៃនគរនោះ ថាជាកស្តុតាងបន្ថែមទៀតអំពីទេពកោសល្យនយោបាយរបស់ពួកគេ និងប្រសិទ្ធិភាពនៃហឹង្សានយោបាយនោះ ។ ជ័យជំនះនេះក៏បានផ្តល់ជំនឿលើសញ្ញាណដែលថា ដោយសារខ្លួនជាជនកុម្មុយនីសល្អ ទើបអាចដើរលឿនជាងអ្វីដែលវៀតណាមនិយាយថាមិនអាចធ្វើកើត និងអ្វីដែលពួកកុម្មុយនីសវៀតណាមខ្លួនឯងមិនមានលទ្ធភាពអាចសំរេចបាន នោះ។*

*ដូច្នេះ សៀវភៅបានអះអាងថា ក្រោយកិច្ចព្រមព្រៀងទីក្រុងហ្សឺណែវ នួន ជា, សាឡុត ស, សោ ភឹម, អៀង សារី, សុន សេន និង តាម៉ុក (តែមិនមែន ខៀវ សំផន, ហ៊ូ យន់ ឬ ហ៊ូ នឹម ទេ) បានក្លាយខ្លួនជាជនកុម្មុយនីស ដែលវៀតណាមជាងពួកវៀតណាមទៅទៀត នៅពេលដែលវាចូលដល់កម្ពុជា ។ ទោះបីជាពួកគេប្រឆាំងការគ្រប់គ្រងរបស់វៀតណាមលើកម្ពុជានោះ ពួកគេក៏ប្រឆាំងនឹងផ្លូវដើររបស់វៀតណាមដែរ ។ អ្វីដែលដើមឡើយបានបំបែកបំបាក់ពួកគេពីវៀតណាម គឺការទទូចរបស់ពួកគេឱ្យចាត់ទុកកម្ពុជាថាដូចវៀតណាមដែរ នៅពេលដែលវៀតណាមថាមិនដូចគ្នាទេនោះ និងការដាក់ពួកគេជាការចម្លងពីពួកកុម្មុយនីសវៀតណាម នៅពេលដែលវៀតណាមថាពួកគេមិនអាច និងមិនត្រូវធ្វើដូច្នេះទេ ។ គឺដោយសារអនុវត្តទ្រឹស្តីរបស់វៀតណាមនៅកម្ពុជានេះហើយដែល បព២ បានរឹងទទឹងទៅនឹងអំណាចរបស់វៀតណាម ។ ដោយសារការធ្វើផ្ទុយនឹងដំបូន្មានរបស់វៀតណាម ឯករាជ្យពីវៀតណាម និងដោយគ្មានជំនួយរបស់វៀតណាម ដើម្បីធ្វើនូវអ្វីដែលវៀតណាមបានធ្វើនៅវៀតណាមនោះ ទើបពួកគេក្លាយទៅជាពួក"ប្រឆាំងវៀតណាម" ។ ពួកកុម្មុយនីសខ្មែរទាំងនេះ មានជំនឿកាន់តែស៊ុបឡើងៗថាខ្លួនជាជនកុម្មុយនីសល្អ បានសេចក្តីថាល្អជាងសមភាគីវៀតណាមរបស់ពួកគេ ទោះបីជាពួកគេអាចធ្វើ ហើយទីបំផុតធ្វើបានលឿនជាងពួកវៀតណាម ដោយអនុវត្តរូបមន្តរបស់វៀតណាមនៅកម្ពុជា ដើម្បីធ្វើឱ្យកម្ពុជាកុម្មុយនីសដូចនៅវៀតណាម ទោះបីថាការណ៍នេះមានន័យថាធ្វើឆាប់ជាង និងលឿនជាងអ្វីដែលវៀតណាមបាននិយាយនោះ អាចធ្វើទៅបាន ។*

*និន្នាការទាំងអស់នេះមានភាពកាន់តែស្រួចស្រាវឡើង ក្នុងចំណោមពួកកុម្មុយនីសខ្មែរក្រោយឆ្នាំ ១៩៧៥ និងនៅតែរក្សាលក្ខណៈពិសេសរបស់វាក្នុងទសវត្ស ១៩៨០ និង ១៩៩០ តទៅទៀត ។ ខ្ញុំធ្លាប់បានលើកឡើងអំពីបញ្ហានេះនៅកន្លែងមួយចំនួនដទៃទៀត នូវអ្វីដែលបានស្តែងចេញចំពោះពួកកុម្មុយនីសខ្មែរក្នុងពេលពួកគេកាន់អំណាច ពីខែមេសា ឆ្នាំ ១៩៧៥ រហូតដល់ខែមករា ឆ្នាំ ១៩៧៩ ។ ទាំងនេះគឺនៅពេល ស និង នួន កាន់ដំណែងជាលេខា និងអនុលេខា នៃគណៈកម្មាធិការមជ្ឈឹមបក្សកុម្មុយនីសកម្ពុជាដែលកាន់អំណាច (បកក) តាម៉ុក បានឡើងជាអនុលេខាទី ២ បកក បន្ទាប់ពីការបោសសំអាត និងការធ្វើអត្តឃាត របស់ សោ ភឹម, ខៀវ សំផន បានក្លាយជាប្រធានគណៈប្រធានរដ្ឋនៃកម្ពុជាប្រជាធិបតេយ្យរបស់ បកក, អៀង សារី ជាឧបនាយរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការបរទេស និង សុន សេន ឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកការការពារជាតិ ។ ក្នុងរយៈពេលជាង ៣ ឆ្នាំ ដែល បកក បានគ្រប់គ្រងកម្ពុជា ការវាយសំរុករបស់ពួកគេដើម្បីធ្វើឱ្យបានល្អជាងវៀតណាម និងសំរេចនូវអ្វីដែលវៀតណាមបានទទូចថាមិនអាចទៅរួចទេនោះ ត្រូវបានពួកគេរក្សាទុក ក្រោមផ្លាកនៃរូបមន្តរបស់ ស្តាលីន និង ម៉ៅ ដើម្បីកសាងសង្គមនិយម និងដើរឱ្យដល់កុម្មុយនីសនិយម ។ តក្កវិជ្ជានេះ ត្រូវបានពង្រីករហូតដល់មានការប៉ុនប៉ងអនុវត្តរូបមន្តទាំងនេះឱ្យលឿនជាង និងល្អជាង ស្តាលីន និង ម៉ៅ ទៅទៀត ។ អំពើហឹង្សាដោយទ្រង់ទ្រាយធំ ផ្តាច់ផ្តិលជីវិត ត្រូវបានប្រើជាផ្នែកមួយនៃការប៉ុនប៉ងធ្វើឱ្យបដិវត្តន៍កម្ពុជាទទួលបានជោគជ័យលើសពីសហភាពសូវៀតក្រោមស្តាលីន និងមានជោគជ័យជាងទ្រឹស្តីមហាលោតផ្លោះនៃប្រទេសរបស់ប្រធានម៉ៅទៅទៀត ។ លទ្ធផលដ៏មហន្តរាយ ត្រូវបានសំដែងចេញជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដោយទ្រង់ទ្រាយធំ ក្នុងនេះរួមមានការសម្លាប់ជីវិតមនុស្សយ៉ាងច្រើនក្នុងជួរបក្សកុម្មុយនីស ដោយ ស និង នួន និងការសម្លាប់មនុស្សរាប់រយពាន់នាក់ផ្សេងទៀត ដែលត្រូវចោទថាជា ខ្មាំង ឬជាពួកក្បត់បដិវត្តន៍ ។ ដំណើរការបោសសំអាត ដែល*

រហូតដល់ចុងឆ្នាំ ១៩៧៨ បានផ្តោតរហូតដល់ទៅលើ សុន សេន និង អៀង សារី និងជាចុងក្រោយទៅលើ តាម៉ុក ត្រូវបានបញ្ឈប់ដោយការឈ្លានពានរបស់វៀតណាមមកលើកម្ពុជាប្រជាធិបតេយ្យ នៅចុងខែធ្នូ ឆ្នាំ ១៩៧៨ ដែលបានជំរុញឱ្យ បកក រលំដួលពីអំណាច ក្នុងរយៈពេលតែ ២ អាទិត្យប៉ុណ្ណោះ ហើយការណ៍នេះជាចំណុចនៃការចាប់ផ្តើមសង្គ្រាមឥណ្ឌូចិនលើកទី ៣ ។

ទាំងក្នុងការឃោសនាជាសាធារណៈ ទាំងនៅក្នុងក្រឡុកក្រលាតផ្ទៃក្នុងសម្ងាត់បំផុត នៃរបបកម្ពុជាប្រជាធិបតេយ្យ ការបោសសំអាតផ្ទៃក្នុង បកក ជាច្រើន ត្រូវបានបញ្ជាក់ថាមានទិសដៅកំទេចមនុស្ស ដែលត្រូវបានថ្កោលទោសថាជាជនក្បត់ចលនាកុម្មុយនីសកម្ពុជា ដោយធ្លាប់បានទទួលការហ្វឹកហ្វឺន និងចាត់តាំង ដោយវៀតណាមតាមរយៈ បកឥ និងដែលត្រូវបានចោទថាប៉ុនប៉ងដណ្តើមការត្រួតត្រាលើចលនាពី ស និង នួន ដោយការធ្វើឃាតនិងរដ្ឋប្រហារ ។ ពួកកុម្មុយនីសវៀតណាម បានឯកភាពនឹងការប្រឌិតការបែកបាក់គ្នានេះ ដោយទម្លាក់ការណ៍នេះ និងការសម្លាប់ក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យទៅលើពួកកុម្មុយនីសខ្មែរប្រឆាំងវៀតណាមដែលបានទទួលការអប់រំនៅទីក្រុងប៉ារីស៍ ដោយវៀតណាមនិយាយថាពួកគេបានកំទេចសមាសភាពដែលបានហ្វឹកហ្វឺនដោយ បកឥ ពីក្នុងជួរនៃចលនា ។

ការពិត ដូចដែលបានពន្យល់ក្នុងសៀវភៅ មេក្លោងនៃការបោសសំអាត ដូចជា ស និង នួន ខ្លួនឯងផ្ទាល់ ក៏មិនអន់ជាង - និងក្នុងករណីខ្លះច្រើនជាងផង - ការប្រឡាក់ប្រឡូសក្នុងការជាប់ពាក់ព័ន្ធជាមួយវៀតណាម ខ្លាំងជាងពួកជនរងគ្រោះរបស់ពួកគេទៀតផង ។ ពួកកុម្មុយនីសខ្មែរ ដែលបានពាក់ផ្លាកឱ្យអ្នកដទៃថាជាប់ឥទ្ធិពលវៀតណាមនោះ និយាយរួម យ៉ាងហោចណាស់ ក៏មានជាប់ឥទ្ធិពលយ៉ាងជ្រៅនូវទ្រឹស្តីវៀតណាម ដូចពួកអ្នកទាំងឡាយដែលពួកគេបានថ្កោលទោសនោះដែរ ។ វៀតណាម នៅពេលបង្ខំឱ្យនិយាយការពិតដោយលំអិត មានទំនាស់ជាមួយការឆ្លុះបញ្ចាំងនូវការឯកភាពរបស់ពួកគេផ្ទាល់ ទៅនឹងរូបភាពជាផ្លូវការរបស់ បកក ។

ទោះបីយ៉ាងណាក៏ដោយ ក្នុងសេចក្តីថ្លែងជាផ្លូវការនានា ចាប់ផ្តើមពីឆ្នាំ ១៩៧៨ មក សាឡុត ស និងអ្នកផ្សេងទៀតដែលបានដឹកនាំ និងបានរួចជីវិត ទទួលបានជោគជ័យខ្លះក្នុងការលាបពណ៌រូបភាពនៃការតស៊ូផ្ទៃក្នុងចលនាកុម្មុយនីសកម្ពុជា រវាងសមាសភាពដែលទទួលឥទ្ធិពលវៀតណាម និងសមាសភាពដែលមានជំហរឯករាជ្យ ដូច្នេះវាលាតត្រដាងសេចក្តីប្រកាសនៅក្នុងស្រុក និងនៅលើឆាកអន្តរជាតិ ថាពួកគេមានស្មារតីស្នេហាជាតិ និងឯករាជ្យ ។ ជាការចំអកមកវិញ ពួកគេបានជួយយ៉ាងសម្បើមដល់វៀតណាមឱ្យធ្វើអ្វីៗសព្វបែបយ៉ាងដែលពួកគេអាចធ្វើបាន ដើម្បីដកខ្លួនពួកគេចេញឱ្យឆ្ងាយពីបាតុភូតខ្មែរក្រហម និងសាកល្បងដាក់ជំនួសនូវមនុស្សមានស្មារតីឯករាជ្យជាមួយពួកប្រល័យពូជសាសន៍ដ៏ឆ្គួតលីលាទាំងនោះ ។

ការបែកបាក់គ្នាក្លែងក្លាយរវាងបញ្ញាជនទទួលការអប់រំនៅប៉ារីស៍ និងពួកអ្នកជើងចាស់នៃបក្សកុម្មុយនីសឥណ្ឌូចិន ប្រឌិតឡើងដោយជោគជ័យជាបឋមរបស់ពួកកុម្មុយនីសខ្មែរ បានធ្វើឱ្យសម្តេចសីហនុយល់ច្រឡំ ដោយធ្វើការបែងចែករវាងពួកកុម្មុយនីស "ខ្មែរវៀតមិញ" - ដែលសម្តេចនិយាយថាជាពួកត្រួតត្រាដោយវៀតណាម - និងអ្វីដែលលោកហៅថា "ខ្មែរក្រហម" ដែលបានទទួលឥទ្ធិពលពីបារាំង និងស្មានថាជាពួកអ្នកមានស្មារតីឯករាជ្យ ។ ការបែងចែកជាប្រភេទនេះមានភាពមិនត្រឹមត្រូវជាស្រេចទៅហើយ នៅពេលសម្តេចសីហនុ បានធ្វើឱ្យមានការដឹងឮអំពីពួកគេនេះនៅក្នុងទសវត្ស ១៩៦០ នោះ ។ វាពុំមានតម្លៃក្នុងការវិភាគចំពោះការពិព័ណនាថ្នាក់ដឹកនាំកុម្មុយនីសខ្មែរនាពេលនោះទេ ។ វាជាការដាក់បញ្ចូលគ្នានូវពួកខ្មែរវៀតមិញ ដូចជា នួន ជា, សោ ភឹម និង តាម៉ុក ជាមួយខ្មែរក្រហម ដូចជា អៀង សារី និង សុន សេន ដែលទាំងអស់គ្នាមានការទាក់ទងគ្នាទៅវិញទៅមកតាមរយៈ សាឡុត ស ដែលជាមនុស្សរបស់ប្រភេទទាំងពីរនេះ ពីព្រោះពួកគេបានទទួលការអប់រំនៅទីក្រុងប៉ារីស៍ និងជាអតីតសមាជិក បកឥ ។

ពាក្យពីរនេះបានបន្តធ្វើឱ្យយល់ច្រឡំក្នុងទសវត្ស ១៩៧០ ជាបន្តទៀត នៅពេល"ខ្មែរក្រហម" ដែលបង្កប់អតីតភាពនយោបាយរបស់ពួកគេនៅប៉ារីស៍ បានក្លាយជាវិសេសស័ព្ទជាបទដ្ឋានសំរាប់ពួកកុម្មុយនីសខ្មែរ ។ ភាពជំនឹតជំងល់នេះ បានបន្តរហូតដល់ទសវត្ស ១៩៩០ ទៀត ពីព្រោះទោះបីជាមានការបោសសំអាតរបស់ ស និង នួន នៅពេលពួកគេកាន់អំណាចក៏ដោយ ក៏ស្នូលនៃថ្នាក់ដឹកនាំនៅតែបន្តគ្របដណ្តប់ដោយពួកខ្មែរវៀតមិញរហូតដល់ទីបញ្ចប់នៃចលនា ទោះបីជាពួកគេនៅតែបន្តដាក់ពីមុខនូវគំរូខ្មែរក្រហម ខៀវ សំផន ក៏ដោយ ។ ខ្មែរក្រហម គឺជាផ្លាកដែលត្រូវបានបិទបាំងប្រកបដោយជោគជ័យដោយសមាសភាពក្នុងភាពជំនឹតនៃខ្មែរវៀតមិញ ។

លើសពីនេះទៅទៀត កម្លាំងនៃការបន្តទ្រឹស្តីនៃទសវត្ស ១៩៥០ និងវិសាលភាពដែល ស និង នួន បានបំពាក់បំប៉នដល់ខ្លួន ត្រូវបានបញ្ចាំងដោយផ្លូវដែលពួកគេ ពោលគឺ តាម៉ុក, អៀង សារី, សុន សេន និង ខៀវ សំផន បានបន្តដើរតាមបន្ទាប់ពី កប ត្រូវបានទម្លាក់ពីអំណាចដោយការឈ្លានពានរបស់វៀតណាមក្នុង ឆ្នាំ ១៩៧៩ ។ ដូចក្នុងទសវត្ស ១៩៦០ ដែរ ពេលនោះបញ្ហាគឺមិនមែនការកសាងសង្គមនិយមទេ ប៉ុន្តែជាការដណ្តើមអំណាចមកវិញ ដោយត្រូវបណ្តេញវៀតណាម និងរដ្ឋអំណាចដែលពួកគេកសាងសំរាប់ដាក់ជំនួស កប ។ ក្នុងបរិបទនេះ ស, នួន, តាម៉ុក និងពួកអ្នកផ្សេងទៀត នៃថ្នាក់ដឹកនាំដែលបានរួចជីវិត បានប្រែក្រឡាស់ចេញពីការដើរតាមគន្លងរបស់វៀតណាម ។

គេអាចសន្និដ្ឋានបានថា-ចាប់តាំងពីទសវត្ស ១៩៦០ មក - ស និង នួន បានឃើញការដោះស្រាយបញ្ហាកម្ពុជាថាជាៈ ការរកឃើញសេណារីយ៉ូកុម្មុយនីសត្រឹមត្រូវ, ការអនុវត្តសេណារីយ៉ូនេះ, ទោះបីជាពួកកុម្មុយនីសដទៃទៀតទទូចថាលឿនពេក ឬមិនសមស្របទៅនឹងកម្ពុជាទេនោះក៏ដោយ, ទៅឱ្យឆ្ងាយជាងអ្វីដែលអ្នកដទៃថាទៅមិនរួចទេនោះ និងធ្វើមិនដឹងមិនឮពីការផ្តល់យោបល់ថាឱ្យពួកគេមានការប្រុងប្រយ័ត្ន ។ ការបកស្រាយឡើងវិញនូវកស្តុតាងដែលមានទាំងអស់ ដើម្បីសម្របទៅនឹងអត្ថបទដើម ធ្វើឱ្យបានល្អជាងអ្នកដទៃក្នុងការធ្វើឡើងវិញ និងប្រើហឹង្សាឡើងវិញនៅពេលណាមានការចាំបាច់ដើម្បីបំពេញចន្លោះរវាងការចង់បានរបស់ពួកគេ និងការពិតជាក់ស្តែង ។

ការណ៍ទាំងនេះនាំឱ្យយល់ឃើញថា ហឹង្សារបស់ពួកកុម្មុយនីសខ្មែរចាប់ពីទសវត្ស ១៩៦០ រហូតដល់ទសវត្ស ១៩៩០ គឺចេញមកពីមហិច្ឆិតានៃរូបមន្តនិយម និងម៉ាក្ស-ឡេនីននិយម របស់ពួកគេ ។ ចំពោះពួកគេ ការប្រើហឹង្សាបដិវត្តន៍ក្នុងស្រុកដោយមិនរង់ចាំ ឬពឹងផ្អែកលើជំនួយបរទេស និងការសំរេចការជំរុញបដិវត្តន៍ តាមរយៈហឹង្សានោះ តាមអត្ថបទដើមនៃបដិវត្តន៍ដែលជឿនលឿនជាងគេបំផុត ក៏បានក្លាយជានិមិត្តរូបនៃអត្តសញ្ញាណជាតិ។

## ជំពូក ១

## បក្សកុម្មុយនីសឥណ្ឌូចិន
## និង
## បក្សប្រជាជនបដិវត្តន៍ខ្មែរ

### បក្សកុម្មុយនីសឥណ្ឌូចិន

ផែនការកុម្មុយនីសនៅកម្ពុជា ត្រូវឡប់ថយក្រោយទៅកាន់ឆ្នាំ ១៩៣០ ពោលនៅពេលពួកកុម្មុយនីសវៀតណាមបង្កើតបក្សកុម្មុយនីសឥណ្ឌូចិន (បកឥ) ព្រមជាមួយបេសកកម្ម និងសេចក្តីសង្ឃឹមថានឹងធ្វើបដិវត្តន៍នៅក្នុងអតីតឥណ្ឌូចិនរបស់អាណានិគមនិយមបារាំង ដែលជាការច្របាច់បញ្ចូលគ្នានៃប្រទេសវៀតណាម កម្ពុជា និងឡាវ ។ ផែនការនេះនៅតែចេញមិនរួចរហូតដល់ក្រោយសង្គ្រាមលោកលើកទី ២ ដែលមានខ្មែរជាច្រើនចាប់ផ្តើមកាន់អាវុធប្រឆាំងបារាំង ដោយប្រកាសថាពួកគេជាខ្មែរឥស្សរៈដែលជាចលនាសង្គមរប៉េះរប៉ោះមួយ មានគំនិតរំដោះប្រទេសកម្ពុជាចេញពីនឹមត្រួតត្រារបស់អាណានិគមនិយមបារាំង ដោយបញ្ចូលខ្លួនទៅក្នុងប្រទេសសៀម (ថៃ) ឯករាជ្យមួយ ។ ជាបន្តបន្ទាប់ក្រោយមក ថៅហ្វាយសៀមបានបោះបង់ចោលពួកខ្មែរឥស្សរៈ ឬបានបាត់បង់អំណាចតាមរយៈរដ្ឋប្រហារយោធាមួយនៅទីក្រុងបាងកក ។ សមាសភាពខ្លះនៃចលនានេះជាពិសេសពួកអ្នកមិនមានមូលដ្ឋានសង្គមជាអ្នកមានឋានៈជាវរជននោះ បានចូលបក្ស ជារណសិរ្សរួម ឬជាវរចនាសម្ព័ន្ធយោធារបស់ បកឥ ដែលបន្ទាប់មកធ្វើប្រតិបត្តិការជាសម្ងាត់នៅក្នុងប្រទេសកម្ពុជា (និងកន្លែងដទៃទៀតនៃឥណ្ឌូចិន) ដោយដាក់ឈ្មោះថាជាអង្គការបដិវត្តន៍ ឬហៅកាត់ថា អង្គការ ជាភាសាខ្មែរ ។

បកឥ បានបន្លំធ្វើជារំលាយខ្លួននៅខែវិច្ឆិកា ឆ្នាំ ១៩៤៥ ដែលជាការផ្លាស់ប្តូរមួយក្នុងកិច្ចខិតខំធ្វើឱ្យវាក្លាយទៅជាមានលក្ខណៈពេញលេញ ដើម្បីបង្កើតបក្សមួយនៅក្នុងប្រទេសកម្ពុជា ។ នៅឆ្នាំ ១៩៥១ បកឥ សម្ងាត់ត្រូវបានជំនួសដោយ បក្សពលករវៀតណាម (បពវ) ជាសាធារណៈ ទោះបីជាវានៅតែបន្តដំណើរការជាសម្ងាត់នៅក្នុងប្រទេសកម្ពុជាជា បកឥ ឬជា បពវ ដែលទើបបង្កើតថ្មីជាសាធារណៈនៅវៀតណាមហើយក៏ដោយ ក៏វានៅតែជាសម្ងាត់នៅកម្ពុជានៅឡើយដែរ ។

មកដល់ចំណុចនេះ វៀតណាមនៅតែមានផែនការបង្កើតជាយថាហេតុនៅកម្ពុជា នូវបក្សបដិវត្តន៍នៃវណ្ណៈពលករដោយឡែកមួយ ក្នុងជំនឿជឿជាក់ថាវានឹងនៅតែជាចំណែកមួយនៃចលនាកុម្មុយនីសឥណ្ឌូចិន ក្រោមការដឹកនាំរបស់ពួកគេដដែល ដោយពួកគេម្ចាស់ការលើពួកកុម្មុយនីសដែលស្មោះជាមួយពួកគេដែលជាតំណាងសម្ងាត់របស់ បកឥ និងទទួលការណែនាំពីបក្សនេះ ។ ការណ៍នេះត្រូវកំណត់ដោយការិយាល័យគណៈកម្មាធិការមជ្ឈឹមសម្ងាត់របស់ បពវ ដែលទើបបង្កើតថ្មីទទួលបន្ទុកផ្តល់ជំនួយដល់ចលនាបដិវត្តន៍កម្ពុជា និងគ្រប់គ្រងលើសកម្មភាពរបស់បក្សជាបងប្អូន ទោះជាក្នុងរូបភាពបែបណាក៏ដោយ ។ ជាសម្ងាត់ វៀតណាមសង្ឃឹមថា បក្សបដិវត្តន៍ទាំងឡាយដែលបង្កើតឡើងជាយថាហេតុនៅ វៀតណាម កម្ពុជា និងឡាវ នឹងត្រូវរួមបញ្ចូលគ្នាជាបក្សតែមួយ ។ ក្នុងទិសដៅសម្ងាត់ដូចគ្នានេះដែរ គឺការបង្កើតសហព័ន្ធនៃរដ្ឋ វៀតណាម ឡាវ និងកម្ពុជា ក្រោមការដឹកនាំរបស់ បពវ ។

ក្នុងពេលរង់ចាំការបង្កើតអង្គការបដិវត្តន៍មួយនៅកម្ពុជា និងការប្រញាប់ចូលគ្នាទៅក្នុងបក្សកុម្មុយនីសឥណ្ឌូចិនទូលំទូលាយតែមួយឡើងវិញនោះ ខ្មែរត្រូវតែធ្វើដំណើរទៅមុខដោយបង្កើតឡើងនូវបក្សបដិវត្តន៍កម្ពុជាមួយ (បបក) ។ និយមន័យរបស់វៀតណាមនៃពាក្យថាប្រជាជនបដិវត្តន៍ រួមមាន "សមាសភាពល្អ របស់អង្គការមហាជននានា ដឹកនាំនិងអប់រំដោយបក្សនេះ" ។ បក្សនេះនឹងត្រូវដឹកនាំដោយសម្ងាត់ដោយ បកឥ និងតាមសេចក្តីព្រាងលក្ខន្តិកៈធ្វើឡើងដោយវៀតណាម ត្រូវដំណើរការជា "កម្លាំងឈានមុខនៃប្រជាជនកម្ពុជា ដោយរួមបញ្ចូលពួកអ្នកស្នេហាជាតិដោយស្មោះ និងពួកអ្នកប្រជាធិបតេយ្យដែលសំគាល់ឃើញថាមានសេចក្តីស្មោះត្រង់ចំពោះពួកគេដោយមានឆន្ទៈមោះមុត និងមានស្មារតីលះបង់ ក្នុងជួរអ្នកតស៊ូ"។ បបបខ មិនមែនជា "បក្សឈានមុខរបស់វណ្ណៈពលករទេ តែជាបក្សឈានមុខរបស់ជាតិដែលប្រមូលផ្តុំកាគី និងសមាសភាពជឿនលឿនទាំងអស់នៃប្រជាជនខ្មែរ" ។ ដូច្នេះ បបបខ មិនទាន់ជាអង្គការបដិវត្តន៍របស់វណ្ណៈពលករសំរាប់ប្រទេសកម្ពុជានៅឡើយទេ បើតាមការប្រម៉ើលរបស់ បកឥ ។ គំនិតគឺថា បបបខ ដំណើរការក្រោមការត្រួតត្រាជាសម្ងាត់របស់ពួកកុម្មុយនីស ចលនាពួកអ្នកមិនមែនកុម្មុយនីសឱ្យចូលធ្វើសកម្មភាពនយោបាយក្រោមការដឹកនាំរបស់ពួកកុម្មុយនីស និងផ្តល់ជារចនាសម្ព័ន្ធមួយនៅកម្ពុជា ដោយពួកកុម្មុយនីសខ្មែរ និងដឹកនាំឱ្យមានការរៀនសូត្រទ្រឹស្តីម៉ាក្ស-ឡេនីន ដើម្បីប្រែក្លាយពួកអ្នកមានសមានចិត្តជាសក្តានុពលជាសមាជិកបក្សកុម្មុយនីសដោយពេញលេញ ។

### *កូមីនទែន* (The Comintern) *និង ប្រជាជនបដិវត្តន៍*

ជម្រើសរបស់វៀតណាមក្នុងការយករូបមន្តបក្សប្រជាជនបដិវត្តន៍ ដាក់ឈ្មោះឱ្យ បបបខ គឺចេញមកពីវាក្យស័ព្ទនៃកុម្មុយនីសសូវៀតនាទសវត្ស ១៩២០ ដែលថាបក្សប្រជាជនបដិវត្តន៍ត្រូវដឹកនាំនិងគ្រប់ដណ្តប់ដោយវណ្ណៈកម្មជីពឈានមុខពីក្រៅ ។ ពាក្យនេះ ត្រូវបានបង្កើតឡើងដើម្បីហៅក្រុមអ្នកមាននិន្នាការកុម្មុយនីសនៅកន្លែងមួយដែលមិនអាចមានបក្សកុម្មុយនីសបាន ដោយពុំមានវណ្ណៈកម្មករនៅនឹងកន្លែង ឬដោយវណ្ណៈនេះនៅខ្សោយពេក ហើយដែលបដិវត្តន៍កើតមានបានដោយសារតែអន្តរាគមន៍របស់កងទ័ពក្រហមសូវៀត ។ ពាក្យនេះត្រូវបានប្រើជាលើកទី ១ នៅប្រទេសម៉ុងហ្គោលីក្រៅ និងនៅលើទឹកដីជាប់ជាមួយគ្នាឈ្មោះ ថានូ ធូវ៉ា ដែលត្រូវបំពេញល័ក្ខខ័ណ្ឌចាំបាច់តម្រូវដោយនិយមន័យកុម្មុយនីសនិយមអន្តរជាតិរបស់ (កូមីនទែន) ឆ្នាំ ១៩២៨ ចំពោះ "ប្រទេសឱនថយ,...នៅទីណាដែលជាក់ស្តែងមិនទាន់មានចំណូលជាប្រាក់ខែពីផ្នែកឧស្សាហកម្ម,...ពុំមានវណ្ណៈនាយទុនជាតិនៅឡើយ," និងថាជោគជ័យនៃការបះបោរប្រជាជាតិ តម្រូវឱ្យមាន "ជំនួយយ៉ាងខ្លាំងក្លាពេញទំហឹង" ពីប្រទេសដែលមានអំណាចផ្តាច់ការវណ្ណៈអធនរួចមកហើយនោះ ។

ជាក់ស្តែង កូមីនទែន មានបំណងឱ្យប្រភេទនេះ គ្របដណ្តប់ទៅលើតំបន់ "កុលសម្ព័ន្ធ" នានា ដូចជានៅអាហ្វ្រិក និងទីកន្លែងដទៃទៀតដែលកំណត់ថាជាផ្នែកបុព្វកាលជាងគេបំផុតនៅលើផែនដី ដែលការរំដោះជាតិ និងការអភិវឌ្ឍន៍លទ្ធិកុម្មុយនីសអាចសំរេចទៅបានល្គឹកណាតែមាន "ជំនួយពីប្រទេសដែលលទ្ធិផ្តាច់ការវណ្ណៈអធនដណ្តើមបានជោគជ័យ នៅក្នុងប្រទេសដទៃទៀត" តែប៉ុណ្ណោះ ។ ភាពជារណបរបស់បក្សប្រជាជនបដិវត្តន៍នៃ ថានូ ធូវ៉ា និងម៉ុងហ្គោលី ចំពោះការត្រួតត្រារបស់សូវៀតនេះឆ្លុះបញ្ចាំងនូវជំនឿជឿជាក់របស់ ស្តាលីន ថាសិទ្ធិសំរេចវាសនាខ្លួនដោយខ្លួនឯងរបស់ប្រជាជាតិនានា ត្រូវតែមើលឃើញក្នុងន័យជាពាក្យសិទ្ធិសំរេចវាសនាខ្លួនដោយខ្លួនឯងនៃវណ្ណៈអធន ដោយថាប្រជាជាតិទាំងឡាយណាដែលមិនទាន់មានវណ្ណៈអធននៅឡើយនោះ យ៉ាងច្រើនបំផុតអាចបានត្រឹមតែជាប្រទេសមានសិទ្ធិសំរេចវាសនាខ្លួនដោយខ្លួនឯងប៉ុណ្ណោះ ។

នៅចុងទសវត្ស ១៩៤០ បកឥ សាកល្បងធ្វើបដិវត្តន៍នៅកម្ពុជា ដោយពុំបានធ្វើការវិភាគវណ្ណៈ និងរចនាសម្ព័ន្ធសង្គមដទៃទៀតដោយហ្មត់ចត់ឡើយ ហើយដាក់ជំនួសការទាល់ច្រកខាងនយោបាយ - បើយោងតាមការធ្វើការស្វ័យទិតៀនផ្ទាល់របស់ពួកគេ - ដោយកម្លាំងយោធា ដើម្បីដឹកនាំធ្វើបដិវត្តន៍នៅទីនោះ ។

ការវិភាគដោយសើៗ ក្នុងឆ្នាំ ១៩៥០ របស់កម្មាភិបាលជាន់ខ្ពស់វៀតណាមនៃ បពត នៅទីក្រុងហាណូយ បានសន្និដ្ឋានថា វណ្ណៈអធនដ៏តិចតួចនៃកម្ពុជា គឺសុទ្ធសឹងតែជាជនអន្តោប្រវេសន៍វៀតណាម និងចិន ស្ទើរតែទាំងអស់ ពួកនាយទុនដ៏តិចតួចនៃប្រទេសនេះ គឺជាជនជាតិបារាំង និងជនជាតិចិននាយសមុទ្រស្ទើរតែទាំងអស់ ហើយ ៩០% នៃប្រជាជនកម្ពុជាសុទ្ធតែរស់នៅជនបទ ដូច្នេះកសិករគឺជាកម្លាំងសំខាន់នៃបដិវត្តន៍កម្ពុជា ។ ការវិភាគរបស់វៀតណាមមួយនៅឆ្នាំ ១៩៥២ បានពិនិត្យឡើងវិញនូវស្ថានការណ៍នេះ តែនៅតែគូសសង្កត់នូវវិសាលភាពដែលថាប្រទេសកម្ពុជាមានកំរិតសេដ្ឋកិច្ចសង្គម និងការវិវត្តន៍ខាងនយោបាយទាបជាងវៀតណាម ។ ការវិភាគបង្ហាញថាប្រជាជនកម្ពុជាចែកចេញជាសមាសភាពវណ្ណៈសំខាន់ៗចំនួន ៥៖ កសិករ កម្មករ គហបតីតូចតាច នាយទុន និងសក្តិភូមិ ។ វានៅតែបន្តសង្កត់ថា ប្រជាជន ៩០% រស់នៅដោយពឹងផ្អែកលើកសិកម្ម ដែលភាគច្រើនលើសលប់ជាម្ចាស់ដីដ៏តូចតាច និងភាគតិចបំផុតជាម្ចាស់ដីទំហំធំៗ ។ វាបានលើកឡើងអំពីវត្តមាននៃស្រទាប់បញ្ញាជន តែក្នុងចំនួនតិចប៉ុណ្ណោះនៅក្នុងចំណោមគហបតីតូចតាច និងពួកនាយទុន តែគូសសង្កត់អំពីតួនាទីរបស់ព្រះសង្ឃពុទ្ធសាសនាក្នុងជីវភាពវប្បធម៌ ។

រូបភាពនេះមានលក្ខណៈមិនឆ្ងាយពីសភាពការណ៍ជាក់ស្តែងទេ។ យ៉ាងហោចណាស់ពេញមួយទសវត្ស ១៩៤០ សហគ្រាសឧស្សាហកម្មតែមួយគត់នៅក្នុងប្រទេសកម្ពុជា គឺសហគ្រាសកែច្នៃជ័រកៅស៊ូនៅក្នុងចំការកៅស៊ូខេត្តកំពង់ចាម ដែលស្ទើរតែទាំងស្រុង ធ្វើដោយកម្មករវៀតណាមដែលនាំចូលមកពីប្រទេសវៀតណាម ហើយនឹងសុរាគារមួយ ។ ពេងជាងដែលមានស្រាប់មានលក្ខណៈជាគ្រួសារ ឬជាសិប្បកម្ម ។ កម្លាំងការងារខាងឧស្សាហកម្ម សរុបមានចំនួនមិនលើសពី ១០០០ នាក់ទេ ចំនួនសិប្បករមានប្រហែល ១៥ ០០០ នាក់។ ការសិក្សាមួយរបស់បារាំងដែលបានធ្វើឡើងមុនសង្គ្រាមសកលលោកលើកទី ២ បន្តិចបានកត់សំគាល់ថាការវិវត្តន៍នៃវណ្ណៈកម្មជីពឧស្សាហកម្ម និងនាយទុននៅឥណ្ឌូចិន អាចឃើញមានតែនៅក្នុងចំណោមជនជាតិវៀតណាមតែប៉ុណ្ណោះ ។ ប្រភពមិនមែនកុម្មុយនីសសម័យបច្ចុប្បន្នមួយទៀត បានរាប់ឃើញចំនួនកម្មករខាងចំការមានកិច្ចសន្យាចំនួន ៥០ ០០០ នាក់ និងកម្មករចំនួន ១៤០ ០០០ នាក់ទៀតធ្វើការនៅការដ្ឋានរ៉ែ ពេងចក្រ និងសហគ្រាសពាណិជ្ជកម្មនានានៅទូទាំងប្រទេសវៀតណាម ។

ប្រភពបារាំងក៏បានលើកឡើងផងដែរ នូវវត្តមាននៃពលករកសិកម្មវៀតណាមជាច្រើននាក់ ប្រជាជនគ្មានដី ឬមានដីបន្តិចបន្តួចសំរាប់ទ្រទ្រង់ការរស់នៅរបស់ពួកគេ ។ ការរៀបរាប់នេះ បានកើតមានចំពោះប្រជាជនជនបទភាគច្រើន លើផ្ទៃដីដ៏ធំទូលាយនៃតំបន់ដីមានជីជាតិជាងគេបំផុតនៅភាគខាងជើង និងភាគខាងត្បូងវៀតណាម ។ ប្រភពខ្លះបានសន្និដ្ឋានថា ប្រជាជនជនបទវៀតណាមចំនួនពីរភាគបី ជាពលករកសិកម្មគ្មានដី ពលករកសិកម្មមានដីបន្តិចបន្តួច ឬដែលបានទទួលត្រឹមតែដីសហគមន៍ប៉ុណ្ណោះ ។

ផ្ទុយទៅវិញ ភាពជាម្ចាស់ដីជាបាតុភាពមួយដែលកើតមានយ៉ាងទូលំទូលាយនៅពាសពេញប្រទេសវៀតណាម ។ តាមស្ថិតិរបស់អាណានិគមនិយម បានបង្ហាញថាដីតិចជាង ៤០% នៅផ្នែកខាងជើងបំផុតនៃប្រទេសវៀតណាម និងផ្ទៃដីតិចជាង ៥០% នៃវៀតណាមកណ្តាល ត្រូវបានដាំដុះដោយកសិករផ្ទាល់ ។ សង្គមជនបទនៅភាគខាងត្បូងវៀតណាមមានការបែកខ្ញែកគ្នាកាន់តែខ្លាំងក្លាថែមទៀត ។ អ្នកខ្លះប៉ាន់ប្រមាណថា ផ្ទៃដីប្រមាណ ៨០% ឬលើសពីនេះ ត្រូវបានកាន់កាប់ដោយពួកម្ចាស់ដី ហើយប្រជាជនចំនួន ៧០% ឬលើសពីនេះ អាចត្រូវបានកំណត់ថាជាពលករជនបទ ។

ស្ថិតិនាសម័យបច្ចុប្បន្នដទៃទៀត ពិព៌ណនាស្រទាប់សង្គមនៅប្រទេសវៀតណាមស្រាលជាងនេះបន្តិច តែនៅតែផ្ទុយគ្នាជាមួយប្រទេសកម្ពុជា ដែលកម្មសិទ្ធិដីទំហំតូចៗក្រោម ៥ ហិកតា មានអ្នកកាន់កាប់ចំនួន ៤/៥ ដែលដាំដុះដោយផ្ទាល់ខ្លួនស្ទើរតែទាំងអស់ ហើយកម្មសិទ្ធិលើដីលើសពី ៥០ ហិកតា-ដីសហគមន៍នៅប្រទេសវៀតណាម-ស្ទើរតែគ្មានទាល់តែសោះ ។

*ទោះបីជាយ៉ាងណាក៏ដោយ ភាពប្រាកដនិយមក្នុងការវិភាគរបស់ពួកកុម្មុយនីសវៀតណាម អំពីរចនាសម្ព័ន្ធសេដ្ឋកិច្ចសង្គមកម្ពុជា ត្រូវបានបង្ហាញឱ្យឃើញដោយការទទូចរបស់ពួកគេដែលថា វាមានភាពបញ្ច្រាសគ្នាកាន់តែខ្លាំងថែមទៀតទៅលើតួលេខដែលបានបង្ហាញខាងលើនេះ ។ ដូច្នេះនៅក្នុងសន្ទរកថា និងសេចក្តីសំរេចនានា ដែលបានធ្វើឡើងនាសមាជខែកុម្ភៈ ឆ្នាំ ១៩៥១-នៅពេលដែល បកឥ បានក្លាយជា បពវ នៅវៀតណាម-បានសំដែងការយល់យ៉ាងច្បាស់ទៅលើទ្រឹស្តីរបស់ កូមីនទែន ឆ្នាំ ១៩២៨ ស្តីពីកុលសម្ព័ន្ធនៅអាហ្វ្រិក ដើម្បីយកមកធ្វើយុត្តិកម្មចំពោះផែនការរបស់ពួកគេសំរាប់ បបបខ នៅប្រទេសកម្ពុជា ។ ប្រទេសកម្ពុជា ត្រូវបានចាត់ទុកថាស្មើនឹងប្រទេសឱនថយ ដែលការជឿនលឿនទៅមុខរបស់បដិវត្តន៍អាចធ្វើទៅបាន លុះត្រាណាតែមានជំនួយពីពពួកប្រទេសកុម្មុយនីសទាំងឡាយ ដែលលេចធ្លោជាងគេតែប៉ុណ្ណោះ ។ មានតែការបង្កើតបក្សមួយនៅទីនោះដោយ បកឥ តែប៉ុណ្ណោះទេ ទើបបដិវត្តន៍របស់ខ្លួនអាចដឹកនាំដោយវណ្ណៈកម្មជីពបាន ។ លើសពីនេះទៅទៀត បដិវត្តន៍កម្ពុជាមិនមែនត្រូវដឹកនាំធ្វើទៅតាមគន្លងដូចនៅវៀតណាមទេ ។ ភាពខុសគ្នានៃរចនាសម្ព័ន្ធសង្គម មានន័យថាបដិវត្តន៍កម្ពុជាត្រូវធ្វើឡើងខុសគ្នាពីវៀតណាម ទាំងរូបភាព ទាំងទិសដៅ ។*

*បដិវត្តន៍ទាំងពីរនេះសុទ្ធតែមានទិសដៅចង់បាន "ប្រជាធិបតេយ្យប្រជាជន" ដូចគ្នា ក៏ប៉ុន្តែ - ដូចដែលនឹងពន្យល់នាពេលបន្តិចទៀតនេះ - ពាក្យនេះមានអត្ថន័យពីរផ្សេងគ្នា បើយោងតាមគម្ពីរពីរផ្សេងគ្នា នៅក្នុងនិយមន័យរបស់សូវៀតចំពោះពាក្យនេះ ដែលបានផ្លាស់ប្តូរយ៉ាងខ្លាំងក្នុងរយៈពេលនៃទសវត្ស ១៩៤០ ។ វៀតណាម បានចាត់ទុកបដិវត្តន៍របស់ពួកគេផ្ទាល់ថាជាបដិវត្តន៍ប្រជាធិបតេយ្យប្រជាជាតិប្រជាជន ដើម្បីរំដោះខ្លួនចេញពីការជិះជាន់របស់សក្តិភូមិនិយមទាំងអស់ និងដើម្បីស្ថាបនាគ្រឹះមួយសំរាប់ធ្វើបដិវត្តន៍សង្គមនិយម ។ ផ្ទុយទៅវិញ បដិវត្តន៍ខ្មែរគឺគ្រាន់តែជាបដិវត្តន៍រំដោះជាតិមួយប៉ុណ្ណោះ ទិសដៅចំពោះមុខរបស់វាគឺដើម្បីកម្រិតព្រំដែនសក្តិភូមិនិយម ប៉ុន្តែមិនទាន់ស្ថាបនាគ្រឹះសំរាប់ឈានទៅធ្វើបដិវត្តន៍សង្គមនិយមទេ។ ការងារជាយុទ្ធសាស្ត្ររបស់វាក្នុងការតស៊ូដ៏ទូលំទូលាយប្រឆាំងចក្រពត្តិនិយមនោះ គឺដើម្បីធានាថាបើពួកគេចាញ់នៅវៀតណាម បារាំងមិនត្រឹមតែដកថយទៅកម្ពុជាប៉ុណ្ណោះទេ តែនឹងវាយបកមកលើវៀតណាមវិញដោយ "ជ្រកក្រោមខែលនៃរដ្ឋាភិបាលអាយ៉ងកម្ពុជាមួយ" ។ បកឥ សង្ឃឹមថាការរំដោះវៀតណាមទាំងមូល ដែលពួកគេសង្ឃឹមថានឹងសំរេចបាននៅឆ្នាំ ១៩៥១ នោះ នឹងបង្កើតលក្ខណៈសម្បត្តិធ្វើឱ្យមានការបះបោរបដិវត្តន៍ជាទូទៅមួយនៅកម្ពុជា ប៉ុន្តែមានតែជ័យជំនះនៃបដិវត្តន៍នៅវៀតណាមប៉ុណ្ណោះ ទើបការនេះអាចធ្វើទៅបាន ។*

### *ការរំដោះជាតិ, ប្រជាធិបតេយ្យប្រជាជន និង សង្គ្រាមប្រជាជន*

*គំនិតនៃបដិវត្តន៍រំដោះជាតិមួយ ត្រូវបានអនុម័តដោយវៀតណាម ដោយយកតាមគំរូមួយដែលបានអភិវឌ្ឍន៍នាចុងទសវត្ស ១៩២០ ដោយ ស្តាលីន សំរាប់យកទៅអនុវត្តនៅក្នុងប្រទេសទាំងឡាយដែលត្រួតត្រាដោយពួកអាណានិគមនិយមបរទេស និងដែលបានចាប់ផ្តើមនូវដំណាក់កាលដំបូងបំផុត នៃបដិវត្តន៍ប្រជាធិបតេយ្យនាយទុនរួចមកហើយ តែប៉ុណ្ណោះ ។ ដើម្បីធ្វើជាកម្លាំងឈានមុខផ្តាច់មុខប្រឆាំងចក្រពត្តិនិយមបរទេស និងភ្នាក់ងាររបស់ពួកគេ បដិវត្តន៍នេះត្រូវពាក់ព័ន្ធជាមួយបដិវត្តន៍វណ្ណៈអធននៅទីកន្លែងដទៃទៀត តាមរយៈចំណងនៃការដឹកនាំបក្សកុម្មុយនីសមានស្រាប់មួយនៅនឹងកន្លែងជាមួយប្រទេសដែលអភិវឌ្ឍន៍ជាងមួយតែប៉ុណ្ណោះ ។ បដិវត្តន៍រំដោះជាតិបែបស្តាលីនមួយនេះ គឺជារូបភាពសមរម្យនៃការតស៊ូចំពោះបក្សកុម្មុយនីសតូចៗមួយចំនួន នៅក្នុងសង្គមកសិកម្មដ៏ច្រើនលើសលប់ ដែលមិនទាន់ដល់ពេលដើម្បីរៀបចំកសិករឱ្យធ្វើការកែទម្រង់កសិកម្មដ៏ដាច់ខាតមួយបាននោះ ។ នៅក្នុងដំណាក់កាលដំបូងរបស់វា បដិវត្តន៍នេះមិនអាចផលិតបាននូវផ្តាច់ការវណ្ណៈអធននិងវណ្ណៈកសិករប្រភេទដែលបានបង្កើតឡើងដោយបដិវត្តន៍ឡេនីនឆ្នាំ ១៩១៧ ទេ ដោយវាលឿនពេក ។ ប៉ុន្តែវាអាចបង្កើតរដ្ឋាភិបាលចំរុះប្រឆាំងចក្រពត្តិនិយមមួយបាន ដោយមានការចូលរួមរបស់ពួកកុម្មុយនីស ដែលត្រូវខិតខំធ្វើយ៉ាងណាឱ្យមានឥទ្ធិពលលើពួកមិនមែនកុម្មុយនីស និងបង្កើតជាស្នូលនៃរដ្ឋបាលនយោបាយបដិវត្តន៍ពិតប្រាកដមួយ ។ ជាទីបញ្ចប់*

*ស្តាលីន បានផ្តល់ដំបូន្មានថា ទោះបីវាជាគោលការណ៍ក៏ដោយក៏ពួកកុម្មុយនីសត្រូវតែមានវត្តមានជាជនកុម្មុយនីសជានិច្ច នៅក្នុងកាលៈទេសៈដែលការងារបដិវត្តន៍ជាបឋមរបស់ខ្លួនមានគ្រោះថ្នាក់*
*ពួកគេត្រូវបេះលាក់អត្តសញ្ញាណនយោបាយរបស់ពួកគេ ។*

*ពាក្យបដិវត្តន៍រំដោះជាតិ ត្រូវបានយកមកប្រើឡើងវិញដោយ ស្តាលីន នៅឆ្នាំ ១៩៤៨ ដើម្បីនិយាយយោងទៅការដណ្តើមកាន់កាប់ប្រទេសអឺរ៉ុបខាងកើតនានាដោយកងទ័ពសូវៀត ពីការកាន់កាប់របស់ពួកណាហ្ស៊ីក្នុងសង្គ្រាមលោកលើកទី ២ និងពីរដ្ឋាភិបាលរួបរួមប្រឆាំងហ្វាស៊ីសនានាដែលបង្កើតឡើងភ្លាមៗ ក្រោមការឧបត្ថម្ភរបស់សូវៀត ។ បកឥ បានយកទ្រឹស្តីនេះមកអនុវត្តចំពោះការបះបោររបស់ប្រជាជនវៀតណាម ប្រឆាំងអាណានិគមនិយម នាខែសីហា ឆ្នាំ ១៩៤៥ ដែលបក្សនេះបានឡើងកាន់អំណាច និងបានប្រកាសថា ពួកគេបានដឹកនាំនៅប្រទេសវៀតណាម បន្ទាប់ពីការចុះចាញ់របស់ពួកឈ្លានពានជប៉ុនមកលើឥណ្ឌូចិនក្នុងពេលសង្គ្រាមលោកលើកទី ២ ដែលនាំទៅឱ្យមានការប្រកាសឡើងនូវរដ្ឋាភិបាលរួបរួមនៃសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម (សបវ) ។ ទ្រឹស្តី ស្តាលីន នាពេលនោះគឺថាចលនាកុម្មុយនីសទាំងឡាយមិនត្រូវប្រកាន់ចរិតកុម្មុយនីសដោយចំហទេ ។ ការប្រកាសការរំលាយ បកឥ ភ្លាមៗបន្ទាប់ពីការបះបោរ គឺជាការអនុវត្តទស្សនៈនេះរបស់សូវៀត យុទ្ធវិធីរបស់ទ្រឹស្តីម៉ាក្ស-ឡេនីន មិនតម្រូវឱ្យពួកកុម្មុយនីសហៅខ្លួនឯងថាជាជនកុម្មុយនីសទេ តែត្រូវកំណត់ថាខ្លួនឯងឱ្យមានភាពជិតស្និទ្ធជាមួយពួកអ្នកជាតិនិយម ។ បកឥ យកសេចក្តីសំរេចយ៉ាងដូច្នេះ ដោយគិតថាទោះបីជាពួកគេទទួលបានការគាំទ្រពីប្រជាជនក៏ដោយ ក៏បក្សត្រូវបានឯកោ និងទទួលការគំរាមកំហែងពីសត្រូវគ្រប់ប្រភេទ នៅក្រៅក៏ដូចនៅក្នុងប្រទេស ។ ការបន្តឱ្យមានវត្តមានជាសាធារណៈ នៃ បកឥ អាចដាក់ពួកគេឱ្យស្ថិតចំពោះមុខការអន្តរាយទៅបាន ។ ការប្រកាសការរំលាយខ្លួនដោយខ្លួនឯងយ៉ាងដូច្នេះ ក៏នឹងអាចជួយឱ្យការសង្ស័យរបស់សម្ព័ន្ធមិត្តបរទេស និងពួកអ្នកជាតិនិយម ដែលថាពួកកុម្មុយនីសមានបំណងគ្របដណ្តប់លើឆាកនយោបាយ ។ ដូច្នេះការរស់រានមានជីវិតនៃការចាត់តាំង និងកាលានុវត្តន៍នយោបាយ បានតម្រូវឱ្យពួកគេចូលសម្ងាត់ ដែលពួកបក្សបានប្រើដើម្បីពង្រឹងការក្តោបក្តាប់ដោយសម្ងាត់របស់ពួកគេ លើអង្គការសាធារណៈផ្សេងៗ នៃរដ្ឋអំណាចនយោបាយ ។ យុទ្ធវិធីរំលាយបក្សនេះ គឺស្របទៅនឹងសេចក្តីប្តេជ្ញាដឹកនាំយូរអង្វែង ដើម្បីរិះរកផ្លូវដែលនៅទីចុងបំផុតពួកគេអាចនឹងបង្ខំដាក់អំណាចផ្តាច់ការមួយលើកម្លាំងប្រឆាំងបាន ។*

*ភ្លាមៗក្រោយសង្គ្រាមលោកលើកទី ២ មនោគមវិជ្ជារបស់ បកឥ ក៏ត្រូវបានទទួលឥទ្ធិពលពីនិយមន័យដើមនៃប្រជាធិបតេយ្យប្រជាជនរបស់ស្តាលីន ដែលពួកអ្នកទ្រឹស្តីសូវៀតបានអនុវត្តដើម្បីពង្រឹងរបបនានាដែលផុសចេញមកពីបដិវត្តន៍រំដោះជាតិនៅអឺរ៉ុបខាងកើតដែរ ។ ជាខ្លឹមសារវណ្ណៈ ប្រជាធិបតេយ្យប្រជាជនទាំងនេះត្រូវបានចាត់ទុកថានៅមានកំរិតទាបណាស់ បើប្រៀបធៀបទៅបដិវត្តន៍ផ្តាច់ការដែលលេចចេញមកពីបដិវត្តន៍បុលសេវិកឆ្នាំ ១៩១៧ ។ ប្រជាធិបតេយ្យប្រជាជនបានបណ្តេញពួកឈ្លានពានបរទេសចេញ ពួកភ្នាក់ងារក្នុងស្រុកត្រូវបានដកចេញពីអំណាច ហើយកំអែលសក្តិភូមិមួយចំនួនត្រូវបានកំទេច តែកម្មសិទ្ធឯកជនលើមធ្យោបាយបង្កបង្កើនផលបន្តនៅមានតទៅទៀត ។ ពួកគេគ្រប់គ្រងដើម្បីផលប្រយោជន៍របស់ "ពួកអ្នកបញ្ចេញកម្លាំងពលកម្មខ្លាំង" តែមិនទាន់បានចាប់ផ្តើមធ្វើអន្តរកាលឆ្ពោះទៅសង្គមនិយមនៅឡើយទេ ។ ពួកគេអាចស្ថិតនៅជារាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញថែមទៀតផង បើសិនចំណោញខាងនយោបាយ ដូចជានៅប្រទេសប៊ុលហ្គារី និងរូម៉ានីជាដើម ។ និយាយឱ្យជាក់លាក់ទៅប្រជាធិបតេយ្យប្រជាជនទាំងនេះខ្សោយខាងនយោបាយណាស់ សហភាពសូវៀតដើរតួជាអ្នកនាំផ្លូវពួកគេឆ្ពោះទៅការរីកចំរើននាពេលអនាគត ដូចដែលនៅពេលខ្លះបានប្រកាសជាចំហផងនោះ ។ នាចុងទសវត្ស ១៩៤០ ទ្រឹស្តីស្តាលីននិយមបានកំណត់ឡើងវិញទាំងស្រុង អំពីប្រជាធិបតេយ្យប្រជាជន និងជំហានត្រឹមត្រូវធ្វើឱ្យសំរេចបានការរៀបរាប់និងបញ្ញត្តិកាលពីពេលមុន ត្រូវបានបកអាក្រាតថាជា "ការកែទម្រង់ដោយរើរវាយ" ។ មនោគមវិជ្ជាសូវៀតបានសរសេរឡើងវិញនូវប្រវត្តិសាស្រ្តអឺរ៉ុបខាងកើត ដោយអះអាងថយក្រោយវិញថា ទោះបីជានៅដំណាក់កាលដំបូងបំផុតនៃការ*

កកើតរបស់វាក៏ដោយ ក៏ប្រជាធិបតេយ្យប្រជាជនមានលក្ខណៈផ្តាច់ការវណ្ណៈអធនទៅហើយដែរ ។ ទ្រឹស្តីចុះកាលបរិច្ឆេតថយក្រោយ ក៏បាននិយាយផងដែរថា ប្រជាធិបតេយ្យប្រជាជនបានស្ថាបនាសង្គមនិយមតាំងពីដំបូងទីម្ល៉េះ ។ ការប្តូរទិសមួយទៀតនោះ គឺការទទួចថា ទោះបីជាផ្តាច់ការវណ្ណៈអធនទាំងនេះមិនអាចសំដែងចេញតាមរយៈបក្សតែមួយ ដូចនៅសហភាពសាធារណរដ្ឋសង្គមនិយមសូវៀតក៏ដោយ ក៏បក្សកុម្មុយនីសត្រូវលែងចេញមុខក្នុងតួនាទីដឹកនាំទៀតហើយៈ ពួកគេត្រូវដើរតួនាទីឈានមុខនៃវណ្ណៈអធន ដឹកនាំ និងគ្រប់គ្រងអំណាចរដ្ឋ ទោះបីជាពួកគេត្រូវហៅខ្លួនឯងថាជាបក្សពលករជាជំនួសបក្សកុម្មុយនីសក៏ដោយ ។ ការនេះបានកែលំអការបកស្រាយប្រជាធិបតេយ្យប្រជាជនបច្ចុប្បន្ន តម្រូវឱ្យធ្វើការតស៊ូវណ្ណៈយ៉ាងខ្លាំងក្លា ដើម្បីពង្រឹងរដ្ឋអំណាចកុម្មុយនីស និងធ្វើដំណើរឆ្ពោះទៅការកសាងសង្គមនិយមឱ្យបានលឿន ។ ការបត់បែនខ្លាំងបំផុតត្រូវបានធ្ងុះបញ្ចាំងដោយអាកប្បកិរិយាជាចំហរបស់ពួកកុម្មុយនីសចំពោះអ្នករាជានិយមនៅក្នុងប្រទេសរូម៉ានី ។ វាចេញពីការប្រសិទ្ធិពរដល់មហាក្សត្រដោយជ័យឃោសន៍ ៖ "សូមឱ្យមានព្រះជន្មាយុយឺនយូរ សុខភាពល្អ និងជារាជបល្ល័ង្គដែលសម្បូរទៅដោយជោគជ័យក្នុងប្រជាធិបតេយ្យ" ដើម្បីបង្ខំព្រះអង្គឱ្យនិរទេសព្រះអង្គ និងបកអាក្រាតតួនាទីប្រតិកិរិយាពីអតីតកាលរបស់ទ្រង់ ។

ដូចគ្នានេះដែរ គោលការណ៍ពីអតីតដែលបដិវត្តន៍ប្រជាធិបតេយ្យប្រជាជាតិប្រជាជន ត្រូវចាត់ទុកខ្លួនឯងថាជាព្រឹត្តិការណ៍ជាតិនិយមដ៏សែនលំបាក់ជាទីបំផុតនោះ ត្រូវបានជំនួសដោយដាក់ទម្ងន់ទៅលើសមាសភាពសង្គមនិយមរបស់ពួកគេ និងដោយទទួចថាពួកគេគ្រាន់តែជាការឆ្លងកាត់ក្នុងកិច្ចដំណើរការបដិវត្តន៍កាន់តែស៊ីជំរៅជាប្រចាំប៉ុណ្ណោះ ។ មាគ៌ាត្រឹមត្រូវថ្មី ដើម្បីដឹកនាំធ្វើបដិវត្តន៍ប្រជាធិបតេយ្យប្រជាជាតិប្រជាជន គឺការរួមបញ្ចូលគ្នា-តាំងពីពេលចាប់ផ្តើម - ភារកិច្ចរំដោះជាតិពីពួកឈ្លានពានបរទេស ជាមួយពួកអ្នករំដោះសង្គមរបស់ "ពួកពលករ" ពីការជិះជាន់ក្នុងស្រុក ។ ដំណាក់កាលទីមួយ ត្រូវផ្តោតទៅលើការកំទេចកំអែលសក្តិភូមិ តែការនេះត្រូវជំរុញឱ្យទៅដល់ការចាក់គ្រឹះសង្គមនិយមតាមរយៈជំហានឆ្ពោះទៅធ្វើសមូហភាវូបនីយកម្មកសិកម្ម និងជាតូបនីយកម្មឧស្សាហកម្មជាទូទៅ ។ ការនេះធ្វើឱ្យរដ្ឋប្រជាធិបតេយ្យប្រជាជនរបស់វណ្ណៈពលករ មានលទ្ធភាព យ៉ាងហោចណាស់ជាទ្រឹស្តី ដើរដល់កំរិតសូវៀតនៃការអភិវឌ្ឍន៍បានលឿន ដោយសមស្របនៅពេលពួកគេបន្តគន្លងដដែលដូចបានត្រួសត្រាយដោយ ស្តាលីន នៅសហភាពសាធារណរដ្ឋសង្គមនិយមសូវៀត ។

ទោះបីយ៉ាងណាក៏ដោយ ក្នុងពេលជាមួយគ្នានេះ របបអឺរ៉ុបខាងកើតបន្តស្ថិតនៅក្នុងដំណាក់កាលជាបឋមនៃការអភិវឌ្ឍន៍ ប្រៀបធៀបទៅសូវៀត ។ មិនតែប៉ុណ្ណោះ គម្ពីរនិយមថ្មីបានជានាថា ការគាំទ្ររបស់សូវៀតធ្វើឱ្យមានលទ្ធភាពនៃការបង្កើតរបបផ្តាច់ការវណ្ណៈអធននៅអឺរ៉ុបខាងកើតបាន ពីព្រោះជាការចាំបាច់ណាស់ ដើម្បីធ្វើការផ្លាស់ប្តូរសេដ្ឋកិច្ចរបស់ពួកគេ និងជាពិសេស ដើម្បីជំរុញការតស៊ូវណ្ណៈឱ្យកាន់តែខ្លាំងក្លាឡើង ។ ប៉ុន្តែ មគ្គុទ្ទេសក៍សូវៀត មិនអាចទទួលយកដោយចំហតទៅទៀតបានទេ ។ ចំណងផ្លូវការដែលចងប្រជាធិបតេយ្យប្រជាជននានាទៅនឹងសហភាពសូវៀត ត្រូវបានសំដែងចេញតាមរយៈកិច្ចព្រមព្រៀងជាសាធារណៈ ដែលសង្កត់លើអធិបតេយ្យភាព សមភាព និងឯករាជភាព ។ ការបញ្ចូលដោយសម្ងាត់នៃស្ថាប័នអឺរ៉ុបខាងកើត និងវិធីចំហនានាត្រូវបានប្រើដើម្បីបំពេញការប៉ុនប៉ងដើម្បីទទួលបានឯករាជភាពកាន់តែទូលំទូលាយថែមទៀត។

បកត បានអនុវត្តដោយសម្រិតសម្រាំង និងដោយច្នៃប្រឌិត ការផ្លាស់ប្តូររបស់សូវៀត ក្នុងសេចក្តីសំរេចរបស់ខ្លួនថា បញ្ចូលវាជាចំហទៅក្នុងប្រទេសវៀតណាម តែនៅរក្សាជាការសម្ងាត់ការក្តោបក្តាប់ប្រទេសកម្ពុជាដដែល ។ វាក៏បានខ្ចីយ៉ាងច្រើនពីរបៀបដែលការផ្លាស់ប្តូររបស់សូវៀត ត្រូវបានយកមកច្នៃប្រឌិតដោយបក្សកុម្មុយនីសចិន (បកច) តាមរយៈ "គំនិតម៉ៅសេទុង" ដែលត្រូវបានបញ្ចូលជាផ្លូវការទៅក្នុងទ្រឹស្តី បពវ ក្នុងឆ្នាំ ១៩៥១ ។

បកច ក៏ដូច បកត ដែរ ដើមឡើយបានប្រើសញ្ញាណស្តីពីបដិវត្តន៍រំដោះជាតិរបស់ស្តាលីន ភ្ជាប់ទៅនឹងការតស៊ូប្រឆាំងពួកហ្វាស៊ីសជប៉ុន ។ ដើមឡើយ ពួកគេក៏បានយល់ស្របផងដែរទៅនឹងការបកស្រាយដោយសាមញ្ញ នូវគំនិតប្រជាធិបតេយ្យប្រជាជន ដោយឈរលើការអភិវឌ្ឍន៍នាពេលមុននេះដោយ ម៉ៅ នូវគំនិតកូមីនទែន អំពី "ប្រជាធិបតេយ្យថ្មី" ។ នេះគឺជាប្រព័ន្ធ

ច្បាប់មួយរបស់សម្ព័ន្ធភាពប្រជាជនប្រឆាំងចក្រពត្តិ និងប្រឆាំងសក្តិភូមិ ដឹកនាំតែ"មួយចំណែក" ដោយវណ្ណៈអធន នៅទីណាដែលដីធ្លីនៅតែជាកម្មសិទ្ធិឯកជនរបស់កសិករនៅឡើយ ។ មួយឆ្នាំមុនដណ្តើមបានអំណាចទូទាំងប្រទេសក្នុងឆ្នាំ ១៩៤៩ ម៉ៅ បានកំណត់និយមន័យរបស់ប្រជាធិបតេយ្យថ្មីជាថ្មីឡើងវិញ ក្នុងពាក្យពេចន៍ដាច់ខាតជាង ដើម្បីធ្វើឱ្យវាស្រដៀងទៅនឹងគោលជំហរថ្មីរបស់សូវៀត ។ ពេលដណ្តើមបានអំណាចហើយ បកច បានពិព័ណនារបបរបស់ខ្លួនថាជា របបផ្តាច់ការប្រជាធិបតេយ្យប្រជាមានិត ក្រោមអនុត្តរភាពរបស់វណ្ណៈអធន ជារដ្ឋមួយស្ថិតក្នុងកណ្តាប់ដៃប្រជាជនទាំងមូល បន្ថែមដោយការដឹកនាំរបស់វណ្ណៈអធន ។ ទោះបីវាមិនទាន់ជាលទ្ធិផ្តាច់ការវណ្ណៈអធន ដោយសារវានៅតែរក្សាសម្ព័ន្ធភាពនយោបាយជាមួយភាគីចំរើននៃវណ្ណៈគហបតីនៅឡើយក៏ដោយ ក៏ បកច បាននិយាយថា ប្រទេសចិននឹងដើរតាមគន្លងសង្គមនិយមដូចគ្នាបេះបិទ ទៅនឹងអ្វីដែលសហភាពសូវៀតបានឆ្លងកាត់រួចមកហើយ នៅពេលណាមួយជាយថាហេតុ ។

នៅចុងឆ្នាំ ១៩៤៨ ឯកសារផ្ទៃក្នុងរបស់ បកឥ ដែលស្ថិតនៅជាសម្ងាត់នៅឡើយ បានសាកល្បងបញ្ចូលគ្នាភាសាគម្ពីរនិយមថ្មីរបស់ សូវៀតនិងចិន ដោយប្រកាសថា វៀតណាមក៏បានផ្លាស់ប្តូរពីប្រជាធិបតេយ្យថ្មី ទៅជាបដិវត្តន៍ប្រជាធិបតេយ្យប្រជាមានិត ជាមួយនឹងសក្តានុពលដើម្បីវិវត្តទៅសង្គមនិយម ក្រោមការដឹកនាំរបស់បក្សកុម្មុយនីស ផងដែរ ។ ប៉ុន្តែ វៀតណាម បានទទួចថា បដិវត្តន៍របស់គេត្រូវធ្វើផ្សេងគ្នាពីនៅក្នុងប្រទេសកម្ពុជា ពីព្រោះការអភិវឌ្ឍន៍នៅកម្ពុជាទាបជាងនៅវៀតណាម ។ បដិវត្តន៍កម្ពុជា នឹងត្រូវស្ថិតនៅជាប្រជាធិបតេយ្យថ្មីក្នុងន័យដើមរបស់ បកច មិនមែនក្នុងបំណងធ្វើសង្គមនិយមទេ តែត្រឹមតែជាការរំដោះជាតិប៉ុណ្ណោះ៖ ដើម្បីរំដោះប្រជាជនឱ្យសំរេចបានឯករាជភាពរបស់ពួកគេ ។ លទ្ធភាពដែលថាប្រទេសកម្ពុជា អាចនឹងស្ថិតនៅជារាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ ដូចអ្វីដែលបានកើតឡើងនៅ រូម៉ានី និង ប៊ុលហ្គារី នារយៈពេលដំបូង ដែលគ្រប់គ្រងដោយសូវៀតនោះ ក៏កំពុងស្ថិតនៅជាការពិចារណានៅឡើយដែរ ទោះបីជាមិនស្ថិតនៅក្រោមព្រះមហាក្សត្រ នរោត្តម សីហនុ ដែលត្រូវបានជ្រើសរើសដោយបារាំង តែ នរោត្តម ច័ន្ទរង្សី ដែលជាសមាជិកបំបែកខ្លួននៃរាជវង្ស ដែលបានក្លាយជាខ្មែរឥស្សរៈ។ (គំនិតនេះត្រូវបានបោះបង់ចោល នៅពេលដែលទ្រង់បានបដិសេធការដឹកនាំរបស់វៀតណាម) ។

ដូចបានឃើញហើយថា បពវ នៅតែរក្សាការបែងចែករវាងកំរិតនៃបដិវត្តន៍កម្ពុជា និងវៀតណាម នៅពេលបក្សនេះបានលេចចេញឡើងនៅឆ្នាំ ១៩៥១ ដដែល ដោយប្រកាសថា សាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម គឺជាការបកស្រាយបង្កើតចេញមកពីលទ្ធិផ្តាច់ការប្រជាធិបតេយ្យប្រជាជនដែលបានអនុវត្តនៅប្រទេសចិន និងដំកល់ទុកសំយោគចុងក្រោយរបស់វាលើទស្សនៈរបស់ស្តាលីននិងម៉ៅ នៅក្នុងសញ្ញាណតែមួយគត់នៃមនោគមវិជ្ជានៃបដិវត្តន៍ប្រជាធិបតេយ្យប្រជាជាតិប្រជាជនចំពោះប្រទេសវៀតណាម ។ បពវ បាននិយាយថា បដិវត្តន៍នេះ នឹងបណ្តេញចក្រពត្តិឈ្លានពានចេញ បោសសំអាតពួកសក្តិភូមិដែលនៅសេសសល់ឱ្យអស់ និងបង្កើតលក្ខណៈសម្បត្តិអំណោយផលសំរាប់ការឈានទៅមុខនៃសង្គមនិយមនៅទីនោះ ដោយសម្របខ្លួនជាបឋមលើកម្លាំងផុសផុលរបស់កម្មករកសិករវៀតណាម ។ បពវ បានធ្វើការបែងចែកពីគ្នារវាងបដិវត្តន៍វៀតណាម និងបដិវត្តន៍កម្ពុជា ទៅក្នុងឋានានុក្រមទូទៅមួយនៃស្នាដៃរបស់បដិវត្តន៍សកលលោក ។ ការនេះបានផ្ទុះបញ្ឆាំងនូវគម្ពីរនិយមរបស់សូវៀត ដោយដាក់លទ្ធិផ្តាច់ការនិយមវណ្ណៈសូវៀត ឱ្យស្ថិតនៅលើលទ្ធិប្រជាធិបតេយ្យប្រជាជននៃអឺរ៉ុបខាងកើត ហើយនឹងនៅលើលទ្ធិផ្តាច់ការប្រជាធិបតេយ្យប្រជាជននៃប្រទេសចិន ។ វៀតណាមខ្លួនឯង ស្ថិតនៅទាបជាងចិន ដែលនៅមិនទាន់បានរំដោះខ្លួនទាំងស្រុងពីចក្រពត្តិនិយមនៅឡើយ ។ ស្ថានភាពឱនថយនៃកម្ពុជា រួមជាមួយទឹកដីរំដោះដ៏សែនតិចតួចនោះស្ថិតនៅក្រោមកាន់តែខ្លាំងថែមទៀត ។

ទោះបីយ៉ាងណាក៏ដោយ ជនខ្មែរត្រូវធ្វើបដិវត្តន៍របស់ពួកគេ ដោយរូបមន្តនៃការតស៊ូដោយអាវុធដូចគ្នានឹងពួកវៀតណាមដែរ នោះគឺ: សង្គ្រាមប្រជាជន ។ នេះគឺជាការខ្ចីមកពីប្រធានម៉ៅមួយទៀត ដែលដើមឡើយបានកំណត់សង្គ្រាមប្រជាជនថាជា "សង្គ្រាមបដិវត្តន៍ប្រជាជាតិ... ដែលត្រូវចលនាប្រជាជនទាំងអស់តែម្តង" ដើម្បីធ្វើឱ្យបរាជ័យចក្រពត្តិនិយមជប៉ុន ។ ក្នុង

រយៈពេលសង្គ្រាមស៊ីវិលនាក្រោយសង្គ្រាមលោកលើកទី ២ រវាង បកច និងរដ្ឋាភិបាលកុកម៉េងតាំងប្រឆាំងកុម្មុយនីសដឹកនាំដោយ ជៀង កាយជៀក (Chiang Kai-Shek) ម៉ៅ បានអភិវឌ្ឍន៍ទស្សនៈនេះថែមទៀត ដោយអះអាងថាសង្គ្រាមឈ្នះ និងការបង្កប់ខ្លួននៃក្រុមការងារប្រដាប់អាវុធក្នុងតំបន់កាន់កាប់ដោយខ្មាំងសត្រូវ ដើម្បីរៀបចំមហាជន និងធ្វើការតស៊ូមហាជន ប្រឆាំងរដ្ឋបាលរបស់ខ្មាំងសត្រូវ ។ មួយថ្ងៃមុនជ័យជំនះរបស់ពួកកុម្មុយនីសចិន ក្នុងខែតុលា ឆ្នាំ ១៩៤៩ ម៉ៅ បានប្រកាសថា សង្គ្រាមប្រជាជនគ្រាន់តែជាបដិវត្តន៍ដើម្បីធ្វើឱ្យបរាជ័យពួកចក្រពត្តិនិយម និងពួកប្រតិកិរិយា ប៉ុណ្ណោះ ។

ចាប់ពីឆ្នាំ ១៩៥១ មក ទាំងនេះត្រូវបានវៀតណាមប្រគល់ទៅឱ្យកម្ពុជា ដោយដាក់នៅនឹងកន្លែងនូវការសម្របសម្រួលដ៏ស្មុគ្រស្មាញមួយ ដើម្បីរក្សាការគ្រប់គ្រងដោយសម្ងាត់របស់វៀតណាមលើចលនាកុម្មុយនីសកម្ពុជា តាមរយៈសាខា បកឥ លាក់មុខដែលមានស្រាប់ និងសាខារបស់ បពវ ដែលទើបបង្កើតថ្មីនៅក្នុងប្រទេស ដែលត្រូវស្ថិតនៅជាសម្ងាត់ដូចគ្នាដែរនោះ ព្រមគ្នាជាមួយការខិតខំបង្កើតចលនាកុម្មុយនីសបន្ទំក្លែក តែដូចគ្នាទៅនឹង បបបខ ។ ពួកកុម្មុយនីសខ្មែរ បានបន្តធ្វើសកម្មភាពជាមួយសមមិត្តវៀតណាមរបស់ពួកគេ ទាំងនៅក្នុងសាខា បកឥ ទាំងនៅក្នុងសាខា បពវ ។ គណៈកម្មាធិការបក្ស បកឥ សំរាប់កម្ពុជា - ដែលនៅតែបន្តដំណើរការតទៅទៀត - ទទួលខុសត្រូវចំពោះការបង្កើតគណៈកម្មាធិការ បពវ មួយនៅក្នុងប្រទេសកម្ពុជា ដើម្បីកាន់កាប់ការងាររបស់ពួកវៀតណាមនៅក្នុងប្រទេសនេះ និងគណៈកម្មាធិការមួយដើម្បីប្រមូល [មហាជន] សំរាប់បង្កើត បបបខ ក្រោមការគ្រប់គ្រងផ្ទាល់នៃអ្វីមួយដែលត្រូវបានប្រគល់សិទ្ធិឱ្យដោយអង្គការរបស់ បកឥ កាន់កាប់ដោយវៀតណាមមួយផ្សេងទៀត ជាគណៈកម្មាធិការចំពោះកិច្ចពិសេសនៃកម្ពុជាទាំងស្រុង *(Ban Can Su Toan mien)* ។ គណៈកម្មាធិការប្រមូលមហាជន រួមមានសមាជិកជាវៀតណាមនិងខ្មែរ និងធ្វើឡើងដើម្បីរៀបចំ និងបណ្ដុះបណ្ដាលសមាជិក បបបខ ។ ក៏ប៉ុន្តែ បបបខ មិនស្ថិតនៅក្រោមគណៈកម្មាធិការចំពោះកិច្ចនេះទេ តែនៅក្រោមគណៈកម្មាធិការចំពោះកិច្ចពិសេសក្នុងស្រុករបស់ បកឥ *(Ban Can Su)* ដែលសមាជិកភាគច្រើនលើសលប់ជាជនវៀតណាម ។ គណៈកម្មាធិការ បពវ នៅកម្ពុជា និងអង្គការបក្ស បពវ ក្រោមឱវាទ ក៏ត្រូវបង្កើតអង្គការទំនាក់ទំនងក្នុងស្រុក ដើម្បីគាំពារអង្គការក្មេងខ្ចីនៃ បបបខ និងផ្ដល់ការបណ្ដុះបណ្ដាលដល់សមាជិកនៅនឹងកន្លែងរបស់គេផង ។ វៀតណាមបានសង្កត់ថា ការលាក់ការសម្ងាត់ជាការចាំបាច់ ទាក់ទងទៅនឹងសកម្មភាពរបស់ពួកគេនៅក្នុងប្រទេសកម្ពុជា ដោយពួកគេនិយាយថា ពីព្រោះការនិយាយបញ្ចេញឱ្យដឹងពីតួនាទីរបស់វៀតណាម នឹងបណ្ដាលឱ្យមានការ"យល់ច្រឡំ" ក្នុងចំណោមប្រជាជនកម្ពុជា ដែលការយល់អំពីគោលការណ៍នៃអន្តរជាតិនិយមវណ្ណៈអធនរបស់ពួកគេនៅខ្សោយនៅឡើយ ។ ការលាក់ការអំពីវត្តមាននៃ បបបខ ក៏មានការចាំបាច់ស្មើគ្នាផងដែរ។ បញ្ហានៃការចេញខ្លួនពីការសម្ងាត់ មិនត្រូវធ្វើឡើងមុនបក្សនេះត្រូវបានបង្កើតដោយពេញមុខនៅក្នុងសមាជបក្សទេ នៅពេលដែលវានឹងលើកយកមកពិចារណានោះ ។ វត្តមានរបស់បក្សនេះ មិនត្រូវនិយាយជាសាធារណៈជាដាច់ខាត ហើយកាន់តែមិនត្រូវនិយាយជាដាច់ខាតថែមទៀត អំពីការដែលថាវាត្រូវបានក្ដោបក្ដាប់ដោយពួកកុម្មុយនីសខ្មែរ ឬវៀតណាមនោះ ។

ដើម្បីជម្រះនូវការច្របូកច្របល់ បណ្ដាលមកពីការទាំងនេះ នឹងកាន់តែងងឹតថែមទៀត ដោយហេតុថាជនខ្មែរនៅតែត្រូវបានជ្រើសរើសឱ្យចូល និងស្ថិតនៅក្រោមការក្ដោបក្ដាប់របស់សាខា បកឥ និង បពវ នោះ ពាក្យថា អង្គការ ឬអង្គការបក្សត្រូវបានបន្តប្រើក្នុងចលនាកុម្មុយនីសខ្មែរ ដើម្បីឱ្យសមាជិកអាចសម្គាល់អត្តសញ្ញាណនូវអ្វីដែលពួកគេជាសមាជិកនោះ។

## មុខមាត់មិនមែនកុម្មុយនីស និងអភូតនៃអនុភាពយោធា

យ៉ាងណាក៏ដោយ គណៈកម្មាធិការចំពោះកិច្ចពិសេសកម្ពុជានៃ បកឥ ជាចំហ ប្រើមុខមាត់ជាខ្មែរ និងខ្មែរមិនមែនកុម្មុយនីសនោះ បានរៀបចំដាក់ឱ្យស្ថិតក្រោមការគ្រប់គ្រងរបស់កម្មាភិបាលជាន់ខ្ពស់ បកឥ នៅក្នុងប្រទេសកម្ពុជា ង្វៀង ថាញ់ សឺង (Nguyen Thanh Son) ផែនការនានាត្រូវបានគូសវាសនៅក្នុងសន្និបាត បកឥ នាដើមទសវត្ស ១៩៥០ ។ គណៈជាតិមុត្តាគាហារមជ្ឈឹមនគរខ្មែរ គឺជាមុខមាត់សំខាន់បំផុតរបស់ពួកខ្មែរទាំងនោះជាពួកអ្នកនាំមុខនៃរដ្ឋាភិបាលបណ្ដោះអាសន្ន ហើយសមា

*គមខ្មែរឥស្សរៈ ដែលត្រូវបានរៀបរាប់ថាជារណសិរ្សរួបរួមជាតិរំដោះប្រជាពលរដ្ឋខ្មែរ បានប្រកាសឡើងនៅខែមេសា ឆ្នាំ ១៩៥០ ។ ពួកអ្នកដឹកនាំនៃអង្គការទាំងពីរនេះ សុទ្ធតែជាសមាជិកសម្ងាត់របស់ បកឥ យ៉ាងហោចណាស់តាំងពីឆ្នាំ ១៩៤៩ មកម៉្លេះ ។ សឺង ង៉ុកមិញ ធ្វើជាប្រធានគណៈកម្មាធិការរំដោះជាតិ ស៊ីវ ហេង កាន់ដំណែងជារដ្ឋមន្ត្រីការពារជាតិ និង ទូ សាមុត ប្រធានសមាគមខ្មែរឥស្សរៈ ។ សឺង ង៉ុកមិញ និង ទូ សាមុត គឺជាខ្មែរពីរនាក់ក្នុងគណៈកម្មាធិការចំពោះកិច្ចពិសេសខ្មែរនៃ បកឥ ក្នុងស្រុក ។ រួមជាមួយ ស៊ីវ ហេង និងខ្មែរទី ៤ ម្នាក់ទៀត ចាន់ សាម៉ៃ ពួកគេបានក្លាយជាសមាជិកគណៈកម្មាធិការប្រម៉ែប្រម៉ូល នៃ បបបខ ដែលបានបង្កើតឡើងដោយ បកឥ ក្នុងឆ្នាំ ១៩៥១ ដោយ សឺង ង៉ុកមិញ ទទួលដំណែងជាអ្នកទទួលខុសត្រូវរួម ស៊ីវ ហេង ទទួលបន្ទុកកិច្ចការយោធា ទូ សាមុត ទទួលបន្ទុកខាងការបណ្តុះបណ្តាលមនោគមវិជ្ជា និង ចាន់ សាម៉ៃ ទទួលបន្ទុកបញ្ហាសេដ្ឋកិច្ច ។ តាមការឃោសនា ពួកគេបានរៀបរាប់ថាគណៈកម្មាធិការរំដោះ និងសមាគមខ្មែរឥស្សរៈ មិនមែនកុម្មុយនីសទេ ដោយបានខិតខំពិព័ណនាពួកគេថាជាចលនា ដែលពួកបញ្ញាជន និស្សិត អតីតមន្ត្រីរាជការស៊ីវិល និងព្រះសង្ឃពុទ្ធសាសនាដើរតួនាទីសំខាន់ ។ ការឃោសនា បានលើកតម្កើងភាពជឿទុកចិត្តជាមួយរូបភាពជាបញ្ញាជនរបស់ពួកគេ ដោយលើកឡើងថា ចាន់ សាម៉ៃ "បានទទួលការអប់រំនៅប្រទេសបារាំងអស់រយៈពេលជាង ១០ ឆ្នាំ" ។*

*ទន្ទឹមនេះ គំនិតសង្គ្រាមប្រជាជនត្រូវបានផ្តល់ដល់ជនកម្ពុជា ដោយអះអាងថាវាជាការសមស្របជាពិសេស ដើម្បីបង្កើតមូលដ្ឋានឈ្លបនៅតំបន់ព្រំដែន រវាងខ្ពង់រាប តាយនីញ នៃវៀតណាមកណ្តាល និងតំបន់ភ្នំភាគឦសានកម្ពុជា ដែល"ជនជាតិភាគតិចផ្សេងៗ"រស់នៅ ហើយក្នុងចំណោមពួកគេ បកឥ បានធ្វើការជ្រើសរើសទាំងសង្ខាងព្រំដែន ។ ការអនុវត្តទូទៅត្រូវបានចាប់ផ្តើមធ្វើនៅពេលក្លាមៗនោះ ដោយប្រើមេរៀនទាញយកមកពីបទពិសោធរបស់វៀតណាម ។ ជនកម្ពុជាត្រូវបានបង្រៀនឱ្យចេះធ្វើសង្គ្រាមប្រជាជន ដោយដណ្តើមយកអាវុធពីខ្មាំងដើម្បីសម្លាប់ខ្មាំង ធ្វើការឃោសនាប្រដាប់អាវុធ ផ្តល់អាវុធឱ្យកសិករ និងបើកធ្វើសង្គ្រាមឈ្លប ។ ពេញមួយរយៈកាលនៃសង្គ្រាមឥណ្ឌូចិនលើកទី ១ ពួកគេបានអនុវត្តគំនិតនេះ ក្រោមការដឹកនាំរបស់កម្មាភិបាលយោធាវៀតណាម ដែលបានបញ្ជា ឬផ្តល់ឱវាទដល់កម្លាំងកុម្មុយនីសខ្មែរ ដែលតែងតែមានសមាសភាពចម្រុះគ្នា ឬធ្វើការប្រយុទ្ធរួម ជាមួយកងឯកភាពស្រួចរបស់វៀតណាម ។*

*កិច្ចការទាំងនេះ ត្រូវបានរក្សាជាការសម្ងាត់ ដូចវត្តមានរបស់ បកឥ បពវ និង បបបខ ដែរ ។ ការរក្សាការសម្ងាត់អំពីតួនាទីរបស់កងទ័ពវៀតណាមនេះ គឺជាការផ្សព្វផ្សាយរបស់វៀតណាម អំពីចំនួនបំប៉ោងយ៉ាងទូលំទូលាយ ដើម្បីផ្តល់ឱ្យបដិវត្តន៍កម្ពុជាខ្ចីដោយបំផ្លើសខ្លឹមសារយ៉ាងខ្លាំង ។ ក្នុងឆ្នាំ ១៩៥១ វៀតណាម បានប្រកាសថា សម្ព័ន្ធមិត្តកម្ពុជារបស់ពួកគេ មានទ័ពស្រួចចំនួន ៦ ០០០ នាក់ នៅភូមិភាគឦសាន ពាយ័ព្យ និងនិរតី ប្រទេស និងកងឈ្លបចំនួន ៤៥ ០០០ នាក់ នៅទូទាំងប្រទេស ។ ប៉ុន្តែ សេចក្តីសង្ខេបរបស់ទីភ្នាក់ងារសម្ងាត់បារាំង បានប៉ាន់ប្រមាណថា កម្លាំងយោធាកុម្មុយនីសរួម វៀតណាមនិងកម្ពុជា ក្នុងឆ្នាំ ១៩៥១ ក្នុងនោះរួមទាំងកងឈ្លបផង មានចំនួនត្រឹមតែ ៤៨០០ នាក់ប៉ុណ្ណោះ ទោះបីជាចំនួនជនជាតិខ្មែរបានរីកធំធាត់ឡើងក៏ដោយ នៅទីចុងបំផុតនោះ ។ តួលេខល្អបំផុតដែលមាន បង្ហាញឱ្យថា ទោះបី ៣ ឆ្នាំក្រោយមកហើយក៏ដោយ ក៏ចំនួនក្នុងសេចក្តីអះអាងឆ្នាំ ១៩៥០ មិនមានចំនួនពិតប្រាកដទេ ។ ក្នុងឆ្នាំ ១៩៥៤ បារាំងបានដាក់ទ័ពចំនួន ៦ ០០០ នាក់នៅកម្ពុជា ដើម្បីគាំទ្រកងកម្លាំងប្រដាប់អាវុធ ៣៣០០០ នាក់នៃរាជរដ្ឋាភិបាលកម្ពុជារបស់សម្តេចសីហនុ នៅពេលដែលកម្លាំងកុម្មុយនីសទាំងអស់ត្រូវបានសហរដ្ឋអាមេរិកវាយតម្លៃថា មានចំនួនប្រមាណ ៨ ៧០០ នាក់ ។ ការវាយតម្លៃរបស់ប្រវត្តិវិទូដែលហាក់ដូចជាមានសប្បុរសធម៌ម្នាក់ ផ្តល់ការប្រយុទ្ធរបស់ជនកម្ពុជា ក្រោមបញ្ជាការវៀតណាម ឬខ្មែរ នៅក្នុងឆ្នាំ ១៩៥៤ ថាមានចំនួនរវាងពី ៤ ៥០០ នាក់ និង ៥ ៧០០ នាក់ ដោយមិនរាប់បញ្ចូលកងឈ្លបក្នុងនោះទេ ។*

*ទោះបីចំនួនជនកម្ពុជាមានប៉ុន្មាននាក់ក៏ដោយ វៀតណាមបានបំពាក់បំប៉នដល់ពួកគេនូវអាកប្បកិរិយាប្រទូស្តរ៉ាយដ៏ដាច់ខាតមួយ ចំពោះខ្មាំងសត្រូវនៃបដិវត្តន៍ ទោះបីជាបរទេស ឬក្នុងស្រុកក៏ដោយ ។ ស៊ីវ ហេង បានប្រកាសក្នុងពេលទស្សនៈ*

*កិច្ចមួយនៅវៀតណាមថា ផ្លូវតែមួយគត់សំរាប់ប្រជាជនកម្ពុជា ដើម្បីរស់ដោយសេរី គឺត្រូវសម្លាប់ពួកចក្រពត្តិឈ្លានពានទាំងអស់ ដែលវាគ្រាន់តែជា "ពពួកឆ្កែឆ្កួតដែលត្រូវតែកំទេចឱ្យអស់តែប៉ុណ្ណោះ" ។ ចំពោះពួកខ្មាំងក្នុងស្រុកវិញ វៀតណាមក៏បានពន្យល់ដូចគ្នានេះដែរថា ផ្លូវត្រឹមត្រូវមួយគត់សំរាប់បដិវត្តន៍កម្ពុជា គឺការធ្វើសង្គ្រាមរហូតដល់ទីចុងបញ្ចប់ ដើម្បីកំទេចរដ្ឋាភិបាល និងកងទ័ពអាយ៉ង ដែលប្រឆាំងពួកគេ ។ គ្មានអ្វីអាចសម្រុះសម្រួលបានជាដាច់ខាត អ្វីៗត្រូវតែជំនះបានដោយការតស៊ូក្តៅគគុកជានិច្ច ។ នៅក្នុងពេលជាមួយគ្នានេះ ជនកម្ពុជាត្រូវអនុវត្តកម្មវិធីសម្រាប់ពួកក្បត់មួយ នៅក្នុងតំបន់ដែលពួកគេរំដោះបាន និងដោះស្រាយជាមួយពួកភ្នាក់ងារសម្ងាត់ជាច្រើន ដែលបានបង្កប់ខ្លួនក្នុងចលនាដើម្បីរិះរកគ្រប់វិធីធ្វើវិទ្ធង្សនាប្រឆាំងបដិវត្តន៍ និងកំទេចអង្គការរបស់ពួកគេ ។*

*រោហាសាស្ត្ររបស់ បកត បានថ្កោលទោសថាជារដ្ឋាភិបាលអាយ៉ង រដ្ឋបាលនៃគណបក្សប្រជាធិបតេយ្យកម្ពុជានានា ដែលកើតឡើងភ្លាមៗក្រោយសង្គ្រាមសកលលោកលើកទី ២ ជាប់ឆ្នោតនាចុងទសវត្ស៍ ១៩៤០ និងដើមទសវត្ស៍ ១៩៥០ និងរដ្ឋាភិបាលរបស់ព្រះមហាក្សត្រ នរោត្តម សីហនុ បន្ទុបឡើងដោយកម្លាំងនៅឆ្នាំ ១៩៥២ ប្រឆាំងពួកប្រជាធិបតេយ្យ ។ រដ្ឋាភិបាលនានាចេញពីការបោះឆ្នោត គឺជាបនក្បត់ ដែលមិនមែនជា"តំណាងពិតប្រាកដរបស់ប្រជាជនឥណ្ឌូចិនទេ" ។ ពួកប្រជាធិបតេយ្យ គឺជាពួកស៊ីឈ្នួលរបស់អាណានិគមនិយម ដែលបានបង្កើតគណបក្សស្នេហាជាតិក្លែងក្លាយដើម្បី"អូសទាញ និងបំភាន់ប្រជាជនស្នេហាជាតិភ្លឺស្វាងទាំងឡាយ" ។ ពួកអ្នកប្រជាធិបតេយ្យ និងអង្គការនយោបាយដទៃទៀត ដែលប្រកួតប្រជែងក្នុងការបោះឆ្នោត គឺគ្មានអ្វីក្រៅពីគ្រាន់តែជា"គណបក្សសមគំនិត" បង្កើតឡើងដោយកលល្បិចបំបែកបំបាក់ដ៏ប៉ិនប្រសប់ របស់ពួកអាណានិគមនិយម ដើម្បីបោកប្រាសប្រជាជនតែប៉ុណ្ណោះ ។ សម្តេច សីហនុ គឺជាស្តេចក្បត់ ដែលបំរើជាបន្តបន្ទាប់ជាអាយ៉ងរបស់អាណានិគមនិយមបារាំង និងពួកហ្វាស៊ីសជប៉ុន បន្ទាប់មកបានក្លាយជាកញ្ចះបាតជើងរបស់ពួកឈ្លានពានបារាំងជាថ្មីម្តងទៀត និងទីចុងបញ្ចប់ជា"អាយ៉ងរបស់ចក្រពត្តិនិយមពិភពលោក" ។ បន្ទាប់ពីរដ្ឋប្រហារគាំទ្រដោយបារាំងឆ្នាំ ១៩៥២ ក្រោយពីបារាំងបានផ្តល់ដល់រាជាណាចក្រកម្ពុជា នូវឯករាជ្យស្ទើរតែពេញលេញនាខែវិច្ឆិកា ឆ្នាំ ១៩៥៣ មក វៀតណាមបានប្រកាសថា ខ្មែរត្រូវបន្តប្រយុទ្ធតទៅទៀតប្រឆាំងនឹងអ្វីដែលគ្រាន់តែជាការបោកប្រាសដ៏គួរឱ្យអស់សំណើចមួយប៉ុណ្ណោះ ។ ខ្មែរស្នេហាជាតិមិនត្រូវចាញ់បញ្ឆោតគេទេៈ សម្តេចសីហនុ និងបរិពាររបស់ព្រះអង្គ នៅតែជាអាយ៉ងដោយបន្តឱបប្រសោបអាណានិគមនិយម និងចក្រពត្តិនិយម ដដែល ។ សម្តេចសីហនុ គ្រាន់តែផ្លាស់ប្តូរចៅហ្វាយពីអាណានិគមនិយមបារាំងដែលត្រូវដកចេញ ទៅចក្រពត្តិអាមេរិកដែលកំពុងរះឡើងប៉ុណ្ណោះ៖ ទាំងនេះគឺជាជំរើសតែពីរគត់របស់ព្រះអង្គដើម្បីស្ថិតនៅក្នុងអំណាច ។ រដ្ឋមន្ត្រីការបរទេសកុម្មុយនីស នៃរដ្ឋាភិបាលបណ្តោះអាសន្នលាក់ខ្លួនរបស់ សឺង ង៉ុកមិញ បានថ្កោលទោសសម្តេចសីហនុ និងពួកអ្នកដើរតាមព្រះអង្គ ថាជាពួកប្រតិកិរិយា ចំពោះតួនាទីរបស់ពួកគេក្នុងរឿងកំប្លែងអំពីឯករាជភាព ប្រឌិតឡើងដោយពួកបារាំងនិងពួកចក្រពត្តិអាមេរិក នៅកម្ពុជា ។*

*គំនិតថាសហរដ្ឋអាមេរិកបានដឹកនាំស្តេចអាយ៉ង សីហនុ ជំនួសពួកបារាំង ដើម្បីដើរតួកលល្បិចឯករាជ្យ គឺជាការផ្លាស់ប្តូរប្រធានបទទូទៅនៃកុម្មុយនីសវៀតណាមៈ ខ្មាំងរបស់ពួកគេនៅឥណ្ឌូចិន គឺមានមុខមាត់ច្រើននិងធ្វើសកម្មភាពបណ្តាក់គ្នាដូច្នេះវាយឱ្យបរាជ័យមួយគ្រាន់តែបានសេចក្តីថា ការតស៊ូថ្មីមួយប្រឆាំងខ្មាំងមួយផ្សេងទៀតតែប៉ុណ្ណោះ ។ នេះក៏ជាការផ្លាស់ប្តូរមួយលើទស្សនៈវៀតណាមចំពោះចក្រពត្តិនិយមអាមេរិកថា ជាសត្វស្វាប់រស់ផ្តាច់ព្រាត់ផងដែរ ដែលតែងតែលាក់ខ្លួននៅពីក្រោយកម្លាំងផ្សេងទៀត តែតែងតែលេចចេញឡើងវិញជានិច្ច ពេលណាយល់ឃើញថាមានការចាំបាច់ ។ ឧទាហរណ៍ យោងតាម បកត នៅពេលកងទ័ពសម្ព័ន្ធមិត្តដែលមានជ័យជំនះនៃចក្រភពអង់គ្លេស និងបារាំង បានចូលមកឥណ្ឌូចិន ដើម្បីដកអាវុធពួកបរាជ័យជប៉ុន ពួកគេបានធ្វើក្នុងឋានៈជាអាយ៉ងរបស់សហរដ្ឋអាមេរិក បានកំណត់គៀសចលនាកុម្មុយនីសឥណ្ឌូចិនចេញ និងលើកបន្តុបរដ្ឋបាលអាយ៉ងនានា ។ ក្នុងរយៈពេលភាគច្រើននៃសង្គ្រាមឥណ្ឌូចិនលើកទី ១ វៀតណាម បាននិយាយថា*

*អាណានិគមនិយមបារាំងគឺជាសត្រូវផ្ទាល់ និងគ្រោះថ្នាក់ជាទីបំផុតនៃប្រជាជនវៀតណាម តែពួកគេត្រូវបានដឹកនាំដោយចក្រពត្តិអាមេរិក ។ ក្រោយមក ស្ថិតចំពោះមុខបរាជ័យក្នុងឆ្នាំ ១៩៥៣-១៩៥៤ បារាំងបានក្លាយជាអ្នកពឹងពាក់លើសហរដ្ឋអាមេរិកកាន់តែខ្លាំងឡើងៗ ដែលនៅតែមានះបន្តសង្គ្រាមតទៅទៀត ដោយបិទបាំងបារាំងទុកសំរាប់ធ្វើជាអាវុធមួយនៃនយោបាយរបស់ពួកគេ ។ ការណ៍នេះបានកើតឡើងនៅទូទាំងឥណ្ឌូចិន យោងតាម ហូ ជីមិញ ប្រធាន បពវ ដែលបានប្រកាសថា ចក្រពត្តិអាមេរិកបានលេចឡើងជា "សត្រូវសំខាន់ និងផ្ទាល់ នៃប្រជាជនវៀតណាម កម្ពុជា និងឡាវ" ។*

*គេអាចអះអាងដោយមានហេតុផលថា វោហាសាស្ត្រនៃការបំភ្លេចជំកាចជួរជាតិ ដែលពួកកុម្មុយនីសវៀតណាមចាត់ទុកតួនាទីរបស់សហរដ្ឋអាមេរិក ចំពោះវៀតណាមតាំងពីឆ្នាំ ១៩៤៥ នោះ គឺត្រឹមត្រូវយ៉ាងទូលំទូលាយ ។ ការប៉ុនប៉ងរបស់ពួកគេ ដើម្បីបង្ខំដាក់ការវិភាគដូចគ្នានេះមកលើកម្ពុជា ក្នុងរយៈពេលសង្គ្រាមឥណ្ឌូចិនលើកទី ១ នោះ វាដូចជាមិនសមហេតុផលទេ ។*

*យ៉ាងណាក៏ដោយ ប្រព្រឹត្តកម្មសមស្របរបស់ពួកគេ អំពីតួនាទីរបស់សហរដ្ឋអាមេរិកនៅកម្ពុជា គឺជាចំណុចជាគន្លឹះធ្វើឱ្យពួកកុម្មុយនីសខ្មែរយកចិត្តទុកដាក់ តាមរយៈឯកសារនៃការបំពាក់បំប៉ន ផលិតឡើងក្រោមការឧបត្ថម្ភរបស់គណៈកម្មាធិការប្រជាចលនារួម បបបខ កម្ពុជា-វៀតណាម និងតាមរយៈសាខារបស់ បកស និង បពវ ក្នុងឋានៈជាសមាជិក ឬដែលគណៈកម្មាធិការរួមនេះ មើលការខុសត្រូវលើសកម្មភាពរបស់ពួកគេ ។ ឯកសារទាំងនេះ បានកំណត់សហរដ្ឋអាមេរិក និងសម្តេចសីហនុ ថាជាសត្រូវដ៏មានគ្រោះថ្នាក់បំផុតនៃបដិវត្តន៍កម្ពុជា ។ ក្រោយមក ការរៀបរាប់របស់ពួកកុម្មុយនីសខ្មែរ បានគូសសង្កត់អំពីតួនាទីរបស់សមាជិកនៃគណៈកម្មាធិការប្រជាចលនា សឺង ង៉ុកមិញ, ស៊ីវ ហេង និង ទូ សាមុត ក្នុងការខិតខំរបស់ពួកគេដើម្បីបំពាក់បំប៉នមនោគមវិជ្ជាដល់ពួកអ្នកបដិវត្តន៍ខ្មែរ នូវទស្សនៈនេះ និងទស្សនៈងាយៗដទៃទៀត ដោយបញ្ជាក់ថា តាមរយៈការបង្រៀនលទ្ធិម៉ាក្ស-ឡេនីនក្នុងចលនា ពួកសមាជិកតាំងពីដើមទីមកនៃ បកស មានលទ្ធភាពធ្វើឱ្យផុសចេញមកនូវបក្សវណ្ណៈកម្មករមួយនៅកម្ពុជាបានដែរ ទោះបីជាពុំមានវណ្ណៈកម្មជីពណាមួយដែលត្រូវបានលើកយកមកនិយាយក៏ដោយ.. ។*

***នួន ជា, តាម៉ុក និង សាឡុត ស***

*ក្នុងចំណោមពួកកុម្មុយនីសខ្មែរ ដែលបានទទួលការបំពាក់បំប៉ននេះ ក្នុងឋានៈជាសមាជិក បកស មាន នួន ជា, តាម៉ុក និង សាឡុត ស ។ នួន ជា ដែលជាក្មួយប្រសាររបស់ ស៊ីវ ហេង បានទទួលការបណ្តុះបណ្តាលប្រពលកម្មនិងជឿនលឿនជាងគេបំផុត ។ រូបគេមានដើមកំណើតនៅខេត្តបាត់ដំបង ដែលជាផ្នែកមួយនៃកម្ពុជាគ្រប់គ្រងដោយប្រទេសសៀម ក្នុងពេលសង្គ្រាមសកលលោកលើកទី ២ ។ បន្ទាប់ពីបញ្ចប់ការសិក្សានាសកលវិទ្យាល័យនៅទីក្រុងបាងកក រូបគេបានរស់នៅទីនោះ និងបានចូលបក្សកុម្មុយនីសថៃក្នុងឆ្នាំ ១៩៥០ ។ ប៉ុន្មានខែក្រោយមក រូបគេបានត្រឡប់មកស្រុកវិញ ព្រមទាំងបានផ្ទេរសមាជិកភាពរបស់គេទៅ បកស និងត្រូវបានចាត់តាំងឱ្យដឹកនាំធ្វើសកម្មភាពឃោសនានៅភូមិភាគពាយ័ព្យកម្ពុជា ។ នៅឆ្នាំ ១៩៥២ រូបគេត្រូវបានជ្រើសរើសឱ្យទៅរៀនសូត្រនៅភាគខាងជើងវៀតណាម ដោយបានចំណាយពេលពីរឆ្នាំនៅ សបវ និងបានត្រឡប់មកកម្ពុជាវិញតាមភាគខាងត្បូងវៀតណាមក្នុងឆ្នាំ ១៩៥៥ ។ ជាង ២០ ឆ្នាំក្រោយមក វៀតណាម នៅតែរំលឹកឃើញរូបគេថាជាមនុស្សម្នាក់ដែលបានជ្រួតជ្រាប តាមរយៈការហ្វឹកហ្វឺនរបស់គេនៅវៀតណាម នូវអ្វីដែលពួកគេចាត់ទុកថាជា "មាគ៌ាត្រឹមត្រូវ" មួយនោះ ។*

*តាម៉ុក ត្រូវបានបញ្ចូលទៅក្នុង បកស ដោយកម្មាភិបាលវៀតណាម នៅស្រុកកំណើតរបស់គាត់ ក្នុងស្រុកត្រាំកក់ ខេត្តតាកែវ ក្នុងឆ្នាំ ១៩៥១ ហើយ តាមសេចក្តីរាយការណ៍ថា គាត់បានទៅរៀនមនោគមវិជ្ជានៅវៀតណាម ក្នុងឋានៈរបស់គាត់ជាប្រធានរដ្ឋបាលចាត់តាំងដោយ បកស របស់ស្រុកនោះនៃភូមិភាគនិរតីនៃកម្ពុជា ។ ពួកកុម្មុយនីសវៀតណាម ដែលធ្លាប់បាន*

ស្គាល់រូបគេក្នុងរយៈកាលនោះ បានរំលឹកឃើញ ម៉ុក ដូច ជា នួន ដែរ ថា "មិត្ត" ម្នាក់ដែលគាំទ្រដល់តួនាទីរបស់វៀតណាមនៅកម្ពុជា និងបានអះអាងថាទិសដៅនៃការជាប់ពាក់ព័ន្ធរបស់វៀតណាមកុម្មុយនីសនៅកម្ពុជា គឺដើម្បីជួយដល់បដិវត្តន៍នៃប្រទេសនេះ ។

សឡុត ស បានទៅប្រទេសបារាំង ដោយទទួលបានអាហារូបករណ៍ទៅរៀនផ្នែកវិជ្ជាជីវៈ នៅក្នុងឆ្នាំ ១៩៤៩ ។ ដើមឡើយ រូបគេសកម្មក្នុងមជ្ឈដ្ឋានប្រឆាំងអាណានិគមនិយមមិនមែនកុម្មុយនីសនៅទីនោះ តែនៅឆ្នាំ ១៩៥១ បានក្លាយជាអ្នកចូលរួមម្តងម្កាលនៃក្រុមម៉ាក្ស-ឡេនីន ដែលជាក្រុមនិស្សិតរៀនសូត្រ និងពិភាក្សា ។ មេដឹកនាំស្ថាបនិកក្រុម ដែលរួមមាន អៀង សារី អនាគតប្អូនថ្លៃរបស់ សាឡុត ស គឺជាសមាជិកបក្សកុម្មុយនីសបារាំង (បកប) ។ នៅឆ្នាំ ១៩៥២ សាឡុត ស បានចូល បកប ទោះបីជារូបគេគ្រាន់តែស្ថិតនៅសើរៗក្នុងការចូលរួមសកម្មភាពក្រុមនេះក៏ដោយ ដែលរួមមានការប្រជុំក្រុមរៀបចំដោយ អៀង សារី នៅផ្ទះរបស់ជនកុម្មុយនីសវៀតណាមម្នាក់ ។ អៀង សារី ក៏បានជួយសម្របសម្រួលឱ្យសមាជិកក្រុមនេះបានចូលរៀននៅសាលាម៉ាក្ស-ឡេនីន របស់ បកប ផងដែរ ដែលនៅទីនោះ សាឡុត ស បានសិក្សាអំពីអត្ថបទទស្សនៈវិជ្ជា ម៉ាក្ស ឡេនីន និង ស្តាលីន ប៉ុន្តែមិនបានរៀនអំពីការអនុវត្ត ឬការរៀបចំធ្វើការតស៊ូបដិវត្តន៍កុម្មុយនីសទេ ។ ការហ្វឹកហ្វឺននេះ បានចាប់ផ្តើមធ្វើនៅពេលរូបគេត្រូវបានផ្ទេរសមាជិកភាពរបស់គេទៅក្នុង បកឥ ក្រោយត្រឡប់មកប្រទេសវិញនៅឆ្នាំ ១៩៥៣ នៅពេលរូបគេបានទទួលការណែនាំពីវៀតណាមអំពីបច្ចេកទេសប្រជាចលនា និងចាត់តាំង ។ រូបគេក៏បានទាក់ទងជាមួយ ទូ សាមុត ដែលជាសមាជិកគណៈកម្មាធិការបានកានស៊ូ និងប្រជាចលនាផងដែរ ។ ក្នុងឋានៈជាជនកុម្មុយនីសខ្មែរជើងចាស់ម្នាក់ ទទួលបន្ទុកការឃោសនានិងអប់រំ ទូ សាមុត បានរៀបចំឱ្យមានមូលដ្ឋានបដិវត្តន៍ជាទីអគ្គបញ្ជាការកុម្មុយនីស នៅភូមិភាគបូព៌ា ក្នុងខេត្តកំពង់ចាម ដែលនៅទីនោះ សាឡុត ស បានក្លាយជាជំនួយការរបស់គាត់ ។

### *ក្រុមម៉ាក្ស-ឡេនីន និងបដិវត្តន៍នៅអឺរ៉ុបខាងកើត*

កម្មវិធីរបស់ក្រុមម៉ាក្ស-ឡេនីន គឺដើម្បីសំរេចនូវឯករាជភាព និងប្រជាធិបតេយ្យ សំរាប់កម្ពុជា តាមរយៈការតស៊ូដោយអាវុធ ដែលហាក់ដូចជាស៊ីសង្វាក់គ្នាជាមួយលក្ខន្តិកៈនានា ដែលវៀតណាមបានសរសេរឱ្យ បបបខ ដោយចាត់ទុកទិសដៅរបស់ពួកគេថាដើម្បីបង្កើតប្រជាធិបតេយ្យប្រជាជនមួយដោយៈការតស៊ូដោយអាវុធយ៉ាងសកម្មមួយ ប្រឆាំងពួកអាណានិគមនិយមឈ្លានពាន ប្រឆាំងអន្តរាគមន៍របស់អាមេរិក និងអាយ៉ង ... ដើម្បីជំរុញការអភិវឌ្ឍន៍និងការពង្រឹងអំណាចប្រឆាំងចក្រពត្តិនិយម អំណាចបដិវត្តន៍ និងដើម្បីស្ថាបនាប្រទេសកម្ពុជាមួយឯករាជ្យពេញបរិបូរណ៍ ។ ការអះអាងរបស់វៀតណាមដែលថាសត្រូវចំបងនៃការរីកចំរើននៅកម្ពុជា គឺអាណានិគមនិយម-ចក្រពត្តិនិយម បារាំង-អាមេរិក និងភ្នាក់ងារសក្តិភូមិរបស់ពួកគេត្រូវបានបន្ទរដោយ សាឡុត ស ក្នុងការវាយប្រហារទៅលើខ្មាំងសត្រូវ ក្នុងអត្ថបទមួយចុះផ្សាយក្នុងទស្សនាវដ្តីនិស្សិតកម្ពុជា ក្នុងឆ្នាំ ១៩៥២ ដែលក្នុងអត្ថបទនោះរូបគេបានធ្វើការវាយប្រហារទៅលើសម្តេចសីហនុ និងអាណានិគមនិយម និងលើកតម្កើងប្រជាធិបតេយ្យ ។ សមាជិកក្រុមឯកភាពជាមួយទ្រឹស្តីវៀតណាម ដែលថាមិនអាចមានឯករាជ្យបានទេនៅឥណ្ឌូចិន ដោយគ្មានការតស៊ូដោយអាវុធ និងចង់ធ្វើការតស៊ូស្មាទល់ស្មាជាមួយវៀតណាម ដើម្បីសំរេចឯករាជ្យនៅកម្ពុជា ។ ដូចសមាជិកម្នាក់បានរំលឹកថា "គ្មាននរណាម្នាក់ក្នុងចំណោមពួកយើងប្រឆាំងវៀតណាមទេ ។ យើងគាំទ្រការតស៊ូរបស់វៀតណាម ១០០% និងពេញចិត្តនឹងគិតថាពួកគេគាំទ្រ ១០០% ការតស៊ូរបស់ខ្មែរ" ។ ក្រុមបានគិតថា គេនិយាយ យោធសម្ព័ន្ធភាពបែបនេះមួយ គឺជា "ការសម្របសម្រួលដ៏ល្អឥតខ្ចោះមួយ ដើម្បីសំរេចបំណងរបស់ពួកគេ" ។

ដូច្នេះ ចលនាកុម្មុយនីសវៀតណាម ដើមឡើយជាកម្មវត្ថុមួយជាទីសក្ការៈរបស់សមាជិកក្រុម ហើយ អៀង សារី បានដាក់តាំងរូបថត ហូ ជីមិញ ប្រធាន បពវ នៅក្នុងផ្ទះរបស់គាត់ ។ ប៉ុន្តែ ភាពសង្ស័យខ្វះបានកើតឡើង ក្រោយពីសមាជិកក្រុមចំនួន ១០ នាក់ ដែលបានចូលរួមពិធីបុណ្យយុវជនអន្តរជាតិរៀបចំដោយអ្នកកុម្មុយនីសនិយមមួយនៅទីក្រុង បែរឡាំង ក្នុងឆ្នាំ

*១៩៥១ ដែលប្រតិភូវៀតណាមបានប្រាប់ពួកគេឱ្យដឹង អំពីគណៈកម្មាធិការរំដោះជាតិដឹកនាំដោយ សឺង ង៉ុកមិញ នោះ ។ បទពិសោធនៅពេលពិធីបុណ្យនោះ បានពង្រឹងថែមទៀតនូវជំនឿរបស់ពួកគេអំពីការចាំបាច់នៃការតស៊ូដោយអាវុធ ដើម្បីធ្វើបដិវត្តន៍នៅកម្ពុជា តែការពិភាក្សារបស់ពួកគេជាមួយវៀតណាមមិនបានប្រព្រឹត្តទៅដោយស្រួលទេ ។ ពួកគេបានលើកពេលវាទៅថ្ងៃក្រោយ ដោយវៀតណាមបដិសេធយ៉ាងដាច់ខាត ក្នុងការផ្តល់លទ្ធភាពឱ្យលើកបញ្ហានៃការចាត់តាំង សឺង ង៉ុកមិញ ជាមេដឹកនាំតែមួយគត់នៃការតស៊ូរបស់កម្ពុជា ដើម្បីឯករាជ្យ និងប្រជាធិបតេយ្យនោះ ។ ការមិនចេះលាក់អាំថកំបាំង ក្នុងការលើកយកមកជជែកអំពីលទ្ធភាពនៃការបង្កើតសហព័ន្ធឥណ្ឌូចិន និងការលើកឡើងថាកម្ពុជាអាចនឹងមិនមានលក្ខណៈសម្បត្តិជាប្រជាជាតិមួយពេញលេញទេ តាមនិយមន័យគម្ពីរនិយមរបស់ ស្តាលីន បានធ្វើឱ្យមានការភ្ញាក់ផ្អើល ។ ក្នុងការប្រជុំនានានៅពេលត្រឡប់មកដល់ប៉ារីសវិញ សមាជិកក្រុមបានយល់ស្របគ្នាថាពួកគេនឹងប្រឆាំងសហព័ន្ធឥណ្ឌូចិន តែពួកគេបានបន្តចាត់ទុកសតិអារម្មណ៍ប្រឆាំងវៀតណាមក្នុងចំណោមជនកម្ពុជាដទៃទៀត ថាជាលទ្ធផលនៃការឃុបឃិតគ្នារបស់ពួកសក្តិភូមិដោយពួកគេសង្ឃឹមថាបដិវត្តន៍ប្រជាធិបតេយ្យ នឹងដោះស្រាយបញ្ហាទាំងអស់រវាងប្រទេសទាំងពីរ និងថាក្នុងឋានៈជាជនបដិវត្តន៍ពិតប្រាកដ ពួកគេត្រូវរួមផ្សំស្នេហាជាតិនិយមរបស់ពួកគេជាមួយអន្តរជាតិនិយម ។*

*ទោះបីយ៉ាងណា ការទទួចរបស់ក្រុម[ម៉ាក្ស-ឡេនីន]អំពីឯករាជភាព និងប្រជាធិបតេយ្យ ក៏ត្រូវបានភ្ជាប់ទៅនឹងការខ្វែងយោបល់ជាមួយវៀតណាមដែលកំពុងចាប់កំណើតស្តីពីអត្ថន័យនៃពាក្យប្រជាធិបតេយ្យ និងសក្តានុពលនិងគន្លងនៃបដិវត្តន៍កម្ពុជា ។ មិនដូចទស្សនៈរបស់វៀតណាមដែលថាកម្ពុជា គឺដូចប្រទេសឱនថយបំផុតនៃទ្វីបអាហ្វ្រិក ម៉ុងហ្គោលី ឬថានូ ធូវ៉ា នោះ សាឡុត ស បានមើលឃើញប្រទេសនេះថាជា ប្រទេសដែលមានក្របខ័ណ្ឌប្រវត្តិសាស្ត្រ ដូចប្រទេសបារាំង រុស្ស៊ី និងចិន ដែរ ។ និយាយជាទូទៅជាងនេះទៅទៀត មជ្ឈដ្ឋានទ្រឹស្តីកុម្មុយនីសនៅទ្វីបអឺរ៉ុបនាដើមទសវត្ស ១៩៥០ ដែលក្រុមនេះមានវត្តមាននៅទីនោះ មិនជំរុញឱ្យសមាជិកក្រុមមើលឃើញប្រទេសកម្ពុជាថាទាបជាងអ្នកណាផ្សេងទៀត ដោយដាក់ឱ្យវានៅទាបជាងគេបំផុតនោះឡើយ ។*

*ក្នុងអត្ថបទរបស់គេមួយនាឆ្នាំ ១៩៥២ សាឡុត ស បានលើកឡើងថា ប្រទេសដែលចេញមកពីការផ្តួលរំលំរាជាធិបតេយ្យនៅកម្ពុជា អាចមានទ្រង់ទ្រាយ ៣ ប្រភេទៈ ថាវាបានលេចចេញមកពីបដិវត្តន៍បារាំង ឆ្នាំ ១៧៨៩ ពីបដិវត្តន៍បុលសេវីចឆ្នាំ ១៩១៧ ឬពីចលនាសាធារណរដ្ឋចិនឆ្នាំ ១៩២៤ ។ ការលើកឡើងនូវឆ្នាំ ១៧៨៩ និង ១៩២៤ នាំឱ្យយល់ឃើញថាបដិវត្តន៍កម្ពុជា អាចជាបដិវត្តន៍ប្រជាធិបតេយ្យនាយទុនដ៏ពេញលេញ តែដោយរូបគេជាជនកុម្មុយនីសម្នាក់នោះ រូបគេត្រូវគិតឱ្យហួសពីលទ្ធភាពដែលអាចធ្វើបានជាមុនឱ្យហើយ ។ ការយោងរបស់គេទៅឆ្នាំ ១៩១៧ (និងជៀសវាងមិននិយាយអំពីបដិវត្តន៍វៀតណាមឆ្នាំ ១៩៤៥ និងបដិវត្តន៍ចិនឆ្នាំ ១៩៤៩) បានបង្ហាញឱ្យឃើញពីមហិច្ឆិតារបស់គេចំពោះកម្ពុជានោះ បញ្ជាក់ថាពួកអ្នកបដិវត្តន៍កម្ពុជាត្រូវយកតាមការដោះស្រាយកំណត់ដោយ ឡេនីន ក្នុងសេចក្តីអំពាវនាវរបស់គាត់ឱ្យចាប់កាន់អាវុធមុនកុប្បកម្មឆ្នាំ ១៩១៧ ក្នុងសៀវភៅ រដ្ឋនិងបដិវត្តន៍ ។ ក្នុងអត្ថបទសំខាន់សំរាប់ពួកកុម្មុយនីសទាំងអស់នេះ ដែលសមាជិកក្រុមម៉ាក្ស-ឡេនីន បានអាននោះ ឡេនីន បានប្រកាសអំពីលទ្ធភាពដែលធ្វើឱ្យបដិវត្តន៍រីកចំរើនទៅមុខ ទោះបីពុំមានវណ្ណៈកម្មជីពទាល់តែសោះក៏ដោយ ល្គឹកណាតែ"មហាជនភាគច្រើន ក្រុមសង្គមស្រទាប់ទាបបំផុត ត្រូវខ្ទេចខ្ទាំដោយការជិះជាន់និងការកេងប្រវ័ញ្ច ងើបឡើងដោយប្រើហឹង្សាជាផ្នែកមួយនៃការប៉ុនប៉ង "ដើម្បីស្ថាបនាដោយខ្លួនគេ នូវសង្គមថ្មីមួយជំនួសសង្គមចាស់ដែលត្រូវបានកំទេចហើយនោះ" ។ ការយោងរបស់ សាឡុត ស ទៅឆ្នាំ ១៩១៧ ក៏បានបញ្ជាក់ផងដែរថាបដិវត្តន៍កម្ពុជាអាចដើរតាម "គំរូនៃការអនុវត្តជាក់ស្តែងនូវទ្រឹស្តីរបស់ ឡេនីន អំពីបដិវត្តន៍វណ្ណៈអធន" ដូចដែល ស្តាលីន បានដាក់វាក្នុងការទាមទាររបស់កុម្មុយនីសមួយទៀត ដែលបានអានក្នុងក្រុម [ម៉ាក្ស-ឡេនីន] ។*

ក្នុងន័យនេះ វាមានសារសំខាន់ជាចំបង ដែលសមាជិកក្រុមយកចិត្តទុកដាក់ចំពោះ និងមានការយល់ដឹង នូវ/អំពី ព្រឹត្តិការណ៍នានានៅសហភាពសូវៀត និងនៅអឺរ៉ុបខាងកើតនាពេលក្រោយមក អំពីការផ្លាស់ប្តូរខ្លឹមសារនៃប្រជាធិបតេយ្យប្រជាជនរបស់សូវៀត ដោយផ្តល់ដល់ពួកគេនូវរូបភាពនៃប្រជាធិបតេយ្យ និងគន្លងត្រឹមត្រូវសំរាប់ការរំដោះជាតិយ៉ាងខ្លាំង ទៅលើការប្រែប្រួលនៃគំរោងការរបស់វៀតណាមសំរាប់ប្រទេសកម្ពុជា ។ ស និងសមាជិកក្រុមដទៃទៀត មានការរំភើបយ៉ាងខ្លាំងចំពោះគំរូអឺរ៉ុបខាងកើត ។ បទពិសោធទទួលបានដោយផ្ទាល់តែមួយគត់របស់ពួកគេ គឺតាមរយៈការធ្វើដំណើរទៅអឺរ៉ុបខាងកើត ក្នុងនេះរួមមានប្រទេសអាល្លឺម៉ង់ខាងកើត រូម៉ានី និងយូហ្គោស្លាវី ។ ការណ៍នេះបានធ្វើឱ្យពួកគេប្រឈមមុខផ្ទាល់ ទៅនឹងទស្សនៈរបស់អឺរ៉ុបខាងកើតស្តីពីក្រិត្យក្រមនៃបដិវត្តន៍: ការតស៊ូរំដោះជាតិត្រូវដើរទន្ទឹមគ្នាជាមួយបដិវត្តន៍សង្គមនិយម និងនាំទៅការពង្រឹងឱ្យបានឆាប់រហ័សនូវលទ្ធិផ្តាច់ការវណ្ណៈអធន ដើម្បីសំរេចបាននូវបដិវត្តន៍សង្គមនិយម ។ លទ្ធិផ្តាច់ការមួយបែបនេះ គឺជាប្រភេទខ្ពស់បំផុតនៃប្រជាធិបតេយ្យ ដែលសំដែងចេញនូវ "ផលប្រយោជន៍សំរាប់មនុស្សភាគច្រើន (ពួកអ្នកត្រូវគេជិះជាន់)" ។ ចំពោះសមាជិកក្រុមវិញ ជំរើសទាបជាងគេបំផុតចំពោះការបកស្រាយអំពីបដិវត្តន៍និងប្រជាធិបតេយ្យនេះ គឺការបកស្រាយរបស់ វៀតណាម និង ចិន ដែលពួកគេបានយកចិត្តទុកដាក់យ៉ាងខ្លាំងដែរ ប៉ុន្តែចាប់ពីពេលនេះទៅលែងមានការទទួលផលពី "ការកែទម្រង់ឥតន័យ" នៃឆ្នាំ ១៩៤៥ ទៀតហើយ គឺមានតែនិយាយអំពីភាពដាច់ខាតអំពីបដិវត្តន៍ប្រជាធិបតេយ្យប្រជាជាតិប្រជាជន និងអនុត្តរភាពនិយមនៃវណ្ណៈកម្មជីពប៉ុណ្ណោះ ។ ក្នុងឋានៈជាជនកុម្មុយនីសនៅប្រទេសបារាំង ពួកគេមិនបានដឹងពីគំរូឱនថយនៃបដិវត្តន៍របស់ បពវ ដែលនៅតែស្ថិតមាននៅក្នុងអារម្មណ៍សំរាប់ប្រទេសកម្ពុជានៅឡើយប៉ុណ្ណោះ។

ភាពឆោតល្ងង់នេះ មានន័យថាពួកគេមានការញញើតញញើមខ្វះក្នុងការសំរេចឱ្យពួកគេមួយចំនួនធ្វើសកម្មភាព ក្នុងសេចក្តីសង្ឃឹមរបស់ពួកគេដើម្បីសំរេចនូវឯករាជភាពនិងប្រជាធិបតេយ្យ តាមរយៈការតស៊ូដោយអាវុធ ដោយវិលត្រឡប់ទៅផ្ទះវិញ ដើម្បីចូលរួមជាមួយចលនាកុម្មុយនីសដឹកនាំដោយ សឺង ង៉ុកមិញ វិញនោះ ។ ពួកគេបានដឹងយ៉ាងច្បាស់ថា ត្រូវចងសម្ព័ន្ធភាពយ៉ាងជិតស្និទជាមួយវៀតណាម តែ "ក្នុងជំនឿ និងក្នុងសេចក្តីសង្ឃឹមថា ... វាជាដៃគូស្មើភាពគ្នា" របស់វៀតណាម ក្នុងការធ្វើបដិវត្តន៍នៅឥណ្ឌូចិនទាំងមូល ។ ស បានប្រកាសថារូបគេមានសេចក្តីរីករាយនឹងបោះបង់ចោលការសិក្សាទាំងស្រុង ដើម្បីចូលរួមការបដិវត្តន៍គ្រប់ពេលវេលា ស្ថិតក្នុងចំណោមពួកអ្នកវិលត្រឡប់មកប្រទេសវិញមុនគេ នាដើមឆ្នាំ ១៩៥៣ ។ ក្រុមបានស្នើដល់រូបគេឱ្យធ្វើការស៊ើបអង្កេតអំពីសកម្មភាពរបស់ចលនាប្រឆាំងបារាំងដទៃទៀត នៅក្នុងប្រទេសកម្ពុជា និងមើលអំពីលទ្ធភាពដើម្បីបង្រួបបង្រួមពួកគេទាំងអស់ក្នុងរណសិរ្សតែមួយ ដើម្បីទាមទារឯករាជ្យ និងប្រជាធិបតេយ្យ តែរូបគេបានសន្និដ្ឋានថាពួកគេទាំងនោះសុទ្ធតែជាពួកចោរប្លន់ និងគ្មានបានការអ្វីទាំងអស់ ។ ផ្ទុយទៅវិញ រូបគេបានរាយការណ៍ត្រឡប់ទៅវិញថាចលនារបស់ សឺង ង៉ុកមិញ បានចាប់ធ្វើបដិវត្តន៍មួយនៅជនបទ ដោយមានកងទ័ពយ៉ាងច្រើន មានកម្មាភិបាលល្អៗជាច្រើននាក់ប្រកបដោយកម្លាំងកាន់តែធំធាត់ឡើងៗ និងក្នុងស្ថានភាពដែលអាចយកជ័យជំនះនៅទីចុងបំផុតបាន ទោះបីជាពួកគេមានជាប់ចំណងជាមួយវៀតណាម ក្នុងផ្លូវមួយដែលបង្ហាញថាវាអាចមិនឯករាជ្យក៏ដោយ ។

ជាការពិត របាយការណ៍បឋមទាំងឡាយរបស់គេ បានមើលស្រាលចំពោះវិសាលភាពដែលថាចលនានេះត្រូវបានដឹកនាំដោយវៀតណាម ពឹងផ្អែកលើជំនួយយោធារបស់វៀតណាម និងរៀនសូត្រនយោបាយតាមអត្ថបទរបស់វៀតណាម តែការណ៍នេះបានក្លាយកាន់តែច្បាស់ឡើងៗហើយចំពោះ ស ។ ពួកអ្នកវិលត្រឡប់មកពីបរទេសដទៃទៀត ដែលបានចូលព្រៃជាមួយរូបគេ មានការវិលវល់ដូចគ្នានេះដែរ ដោយបានមើលឃើញអំពីវិសាលភាពពេញទីនៃការត្រួតត្រារបស់វៀតណាមនោះ ។ នៅពេលរៀនសូត្រនយោបាយ សូម្បីតែកម្មាភិបាលជាន់ខ្ពស់កម្ពុជា ដូចជា ស៊ីវ ហេង, ទូ សាមុត និង ចាន់ សាម៉ៃ ជាដើម គ្រាន់តែអង្គុយស្ងៀម នៅពេលជនវៀតណាមចេះនិយាយភាសាខ្មែរ ធ្វើបទបង្ហាញអំពីឯកសារមនោគមវិជ្ជានានា ។

*ស្វែងរក ហូ ជីមិញ ខ្មែរម្នាក់*

*មិនមែនមានតែពួកវិលត្រឡប់មកពីបរទេសទេ ដែលមានការព្រួយបារម្ភអំពីការត្រួតត្រារបស់វៀតណាមនោះ ។ ហែម សាមីន ដែលត្រូវបានជ្រើសរើសឱ្យចូលចលនារបស់ បកត នៅភូមិភាគបូព៌ានៃកម្ពុជា ក្នុងឆ្នាំ ១៩៥០ បានរំលឹកថាបក្ស "ប្រៀបដូចជាការពិសោធផ្សាំផ្អឹងជំនីមួយ ពីព្រោះវាត្រូវបានដាក់បង្ខំឱ្យយើងដោយបរទេសមួយ ... ដូច្នេះ បក្សនេះមិនមែនជាបក្សរបស់យើងដោយពិតប្រាកដទេ ។ កែវ មាស ដែលជាកម្មាភិបាលម្នាក់ទៀតនៃភូមិភាគបូព៌ា បានរំលឹកថារូបគេបានសុខចិត្តទទួលយកការខិតខំរបស់វៀតណាមដែលបានបញ្ចូលរូបគេក្នុង បកត នៅក្នុងឆ្នាំដដែលនោះដែរ ទោះបីជាថ្នាក់ដឹកនាំរបស់បក្សនេះសុទ្ធតែជាជនវៀតណាមក៏ដោយ រូបគេបានយល់ស្របអំពីខ្លឹមសារនៃកុម្មុយនីសនិយម ដែលរូបគេមានជំនឿថា"ជាការស្ថាបនាសង្គមមួយដែលគ្មានមនុស្សជិះជាន់មនុស្ស ឬអ្នកមានជិះជាន់អ្នកក្រ ដែលធនធានរបស់ពួកអ្នកមាននឹងត្រូវរិបអូសយកទាំងអស់និងចែកទៅឱ្យអ្នកក្រ ដោយឱ្យប្រជាជនទាំងអស់រស់ស្មើភាពគ្នា" ។ កុម្មុយនីសនិយម មានន័យថា ខ្មែរលែងឈឺចាប់ដោយការអត់ឃ្លានទៀតហើយ តែចូលទៅកាន់"ស្ថានសួគ៌" នៃយុត្តិធម៌សង្គម ។ ការដែលបដិវត្តន៍កម្ពុជាមិនសប្បាយចិត្តចំពោះការដឹកនាំរបស់ វៀតណាម នោះ មាស រង់ចាំថ្ងៃណាមួយ នៅពេលរូបគាត់និងកម្មាភិបាលដទៃទៀត នឹងដោះស្រាយនៅពេលពួកគេជ្រួតជ្រាបអំពីលទ្ធិម៉ាក្ស-ឡេនីន អាចដឹកនាំខ្លួនដោយខ្លួនឯងបានហើយនោះ ។ ក្នុងឆ្នាំ ១៩៥២ រូបគេក៏បានធ្វើការសន្និដ្ឋានថា បដិវត្តន៍កម្ពុជាត្រូវមានប្រភេទដូចគ្នាទៅនឹងបដិវត្តន៍វៀតណាម និងចិន តែមានការសង្ឃឹមថា "ការណ៍នេះអាចដំណើរការទៅបាន លុះត្រាតែមេដឹកនាំរបស់ពួកគេដូចមេដឹកនាំវៀតណាមដែរ" បានសេចក្តីថា ពួកគេលែង"ជាប់ចំណងវៀតណាម ដោយរង់ចាំតែវៀតណាមប្រាប់ទើបហ៊ានធ្វើអ្វីមួយ និងមិនហ៊ាននិយាយអ្វីទាល់តែសោះនោះ" តទៅទៀតប៉ុណ្ណោះ ។ ពួកកុម្មុយនីសខ្មែរមួយចំនួននៃភូមិភាគបូព៌ា មើលឃើញឃោសនិក ទូ សាមុត ថាជាខ្មែរត្រឹមត្រូវជាងគេបំផុតដែលជំនួសវៀតណាមបាន ដោយមើលឃើញរូបគាត់ថាជាខ្មែរ ហូ ជីមិញ ជាមនុស្សម្នាក់ជា"កម្មាភិបាលដែលកម្មាភិបាលដទៃទៀតត្រូវយកគំរូតាម" ។ អ្នកដឹកនាំបែបនេះ នឹងធ្វើឱ្យកម្ពុជាមានលទ្ធភាពធ្វើបដិវត្តន៍ ក្នុងកំរិតមួយស្មើគ្នានឹងបដិវត្តន៍វៀតណាម និងចិន ដោយមិនត្រូវការពួកទាំងនេះណែនាំអ្វីទាំងអស់ ។*

*មនោសញ្ចេតនាទាំងនេះ បានបង្កើតជាមូលដ្ឋានមួយ ជាគំនិតសំរាប់ធ្វើការប្រជុំគ្នាមួយ រវាងពួកកុម្មុយនីសរបស់អង្គការនៅកម្ពុជា និងពួកអ្នកវិលត្រឡប់មកពីប្រទេសបារាំង ដើម្បីផ្លាស់ប្តូរមហិច្ឆិតារវាងគ្នាឱ្យកាន់តែធំសំរាប់បដិវត្តន៍កម្ពុជា ជាងវៀតណាម និងក្នុងបំណងប្រាថ្នាស្ថិតនៅឯករាជពីការដឹកនាំរបស់ បពវ ។ គន្លឹះនៃការរួមបញ្ចូលគ្នានេះ អាចជា នួន និង ស ដែលបានតភ្ជាប់ បកត ទៅនឹងក្រុមម៉ាក្ស-ឡេនីន, ដំបូងក្រោមការដឹកនាំរបស់ ទូ ហើយក្រោយមកដោយពួកគេផ្ទាល់ ។ ការប្រទាក់ក្រឡាគ្នានេះ បានលេចចេញមកក្រោយសន្និសិទទីក្រុងហ្សឺណែវ ឆ្នាំ ១៩៥៤ ភ្លាមៗ និងដោយមិនបានព្រាងទុកជាមុនដែលបានបញ្ចប់សង្គ្រាមឥណ្ឌូចិនលើកទី ១ ។*

## *ជំពូក ២*
## *ការតស៊ូក្រោយសន្និសិទទីក្រុងហ្សឺណែវ និង*
## *ដំណើរថយក្រោយ ឆ្នាំ ១៩៥៤-១៩៥៧*

### *កិច្ចព្រមព្រៀងទីក្រុងហ្សឺណែវ*

*កិច្ចព្រមព្រៀងទីក្រុងហ្សឺណែវបានកើតមានឡើង ដោយសារនៅឆ្នាំ ១៩៥៤ ពួកកុម្មុយនីសសូវៀត និងចិន បានបញ្ចុះបញ្ចូល បពវ ដែលមានភាពមិនច្បាស់លាស់ ឱ្យទទួលយកកិច្ចព្រមព្រៀងនេះ ដើម្បីពង្រឹងផលចំណេញរបស់គេនៅវៀតណាម និងដើម្បីជៀសវាងអន្តរាគមន៍យោធាដោយទ្រង់ទ្រាយធំ និងដោយផ្ទាល់ របស់សហរដ្ឋអាមេរិក ដើម្បីទប់ស្កាត់ការឈានទៅមុខជាបន្តទៀតរបស់ពួកកុម្មុយនីស ។ ការដោះស្រាយនេះ បានធ្វើឱ្យពួកកុម្មុយនីសខ្មែរមានការប៉ះទង្គិចយ៉ាងខ្លាំងចំពោះមុខការពិតជាក់ស្តែង (fait accompli) មួយ ។ ជាការផ្ទុយទៅនឹងការបំពាក់បំប៉នខាងមនោគមវិជ្ជាទាំងអស់របស់ បពវ ដែលបានផ្តល់ដល់ពួកគេ ស្តីពីការប្រយុទ្ធដោយមិនរាថយរហូតដល់ទីចុងបំផុត រហូតដល់ជ័យជំនះទាំងស្រុងនៃបដិវត្តន៍ កិច្ចព្រមព្រៀងនេះបានតម្រូវឱ្យមានការឈប់បាញ់មួយនៅក្នុងប្រទេសកម្ពុជា (និងនៅទីកន្លែងដទៃទៀតនៃឥណ្ឌូចិន) ការដកកម្លាំងយោធារបស់អាណានិគមនិយមបារាំងនិងរបស់ពួកកុម្មុយនីសទាំងអស់ចេញ ព្រមទាំងការរំសាយកម្លាំងប្រដាប់អាវុធរបស់ពួកកុម្មុយនីសកម្ពុជាដែលមាននៅនឹងកន្លែង តែកិច្ចព្រមព្រៀងនេះបានសន្យាថានឹងរៀបចំឱ្យមានការបោះឆ្នោតជាសម្ងាត់ ដែលភាគីទាំងអស់អាចចូលរួមបានដោយសេរី ។ រដ្ឋាភិបាលសម្តេច សីហនុ បានចាត់វិធានការដើម្បីធានាកុំឱ្យការសងសឹកប្រឆាំងទៅលើសមាជិកអតីតក្រុមប្រឆាំងប្រដាប់អាវុធ ដែលត្រូវទទួលបានការធានាដោយច្បាប់រដ្ឋធម្មនុញ្ញទាំងអស់ស្តីពីការការពារសេរីភាពប្រជាធិបតេយ្យ ។ គណៈកម្មការអន្តរជាតិមួយសំរាប់មើលការខុសត្រូវ និងត្រួតពិនិត្យ ក្នុងនោះរួមមានតំណាងមកពីប្រទេស ឥណ្ឌា ប៉ូឡូញ និង កាណាដា ត្រូវបានប្រគល់អាណត្តិឱ្យអនុវត្តការត្រួតពិនិត្យ ការសង្កេតការណ៍ ការធ្វើអធិការកិច្ច និងការស៊ើបអង្កេត ដើម្បីបំពេញកាតព្វកិច្ចស្របតាមកិច្ចព្រមព្រៀង ។*

*ដំណោះស្រាយនេះ បានធ្វើឱ្យចលនាកុម្មុយនីសខ្មែរស្ថិតក្នុងចន្លោះប្រហោងផ្នែកចាត់តាំង ដោយមានតែសមាជិកគណៈកម្មាធិការក្នុងស្រុកនៃ បបបខ មួយចំនួនប៉ុណ្ណោះដែលត្រូវបានបង្កើតឡើង ហើយពុំមានសមាជថ្នាក់ជាតិណាមួយត្រូវបានកោះប្រជុំទេ ។ យោងតាមលក្ខន្តិកៈ បបបខ ស្ថិតចំពោះមុខកាលៈទេសៈពិសេសបែបនេះ គណៈកម្មាធិការប្រតិបត្តិមជ្ឈឹមបក្សមួយត្រូវដាក់ឈ្មោះ តាមការរៀបរាប់របស់ពួកគេ ថាជាថ្នាក់លើ ដែលជាការយោងដោយបញ្ឆិតទៅលើ បានកានស៊ូ (Ban Can Su) ដែលមានសុទ្ធតែជនកម្ពុជាទាំងអស់ ។ គណៈកម្មាធិការនេះបានចាត់តាំងសមាជិកជាខ្មែរនៃគណៈកម្មាធិការប្រជាចលនា ដែលមានឈ្មោះ សឹង ង៉ុកមិញ, ស៊ីវ ហេង, ទូ សាមុត និង ចាន់ សាម៉ៃ ធ្វើជាគណៈកម្មាធិការប្រតិបត្តិបណ្តោះអាសន្ននៃបក្ស ដែលកំពុងស្ថិតក្នុងដំណាក់កាលនៃការរៀបចំបង្កើតនៅឡើយ ។*

*សមាជិកជាជនវៀតណាមនៃគណៈកម្មាធិការប្រជាចលនា និងជនកុម្មុយនីសវៀតណាមជាច្រើននាក់ដទៃទៀត បានចាកចេញពីកម្ពុជាស្របតាមការតម្រូវដែលមានចែងនៅក្នុងកិច្ចព្រមព្រៀង ឱ្យដកយុទ្ធជនវៀតណាមដែលបានទទួលការហ្វឹកហ្វឺនគ្រប់ប្រភេទ សមាសភាពវៀតណាមដែលមានការហ្វឹកហ្វឺនជាយោធាគ្រប់ប្រភេទ និងជនវៀតណាមទាំងអស់ដែលមានមុខនាទីត្រួតត្រាអង្គការនយោបាយ ឬយោធា រដ្ឋបាល សេដ្ឋកិច្ច ហិរញ្ញវត្ថុ ឬសង្គម ។ ស៊ីវ ហេង, ចាន់ សាម៉ៃ និងយុទ្ធជន និងសកម្មជនឥស្សរៈ ប្រមាណ ១,០០០ នាក់ ក្នុងនេះរួមមាន ១៩០ នាក់ ក្នុងចំណោមសមាជិកបក្សកុម្មុយនីសកម្ពុជា បានចេញទៅជាមួយពួកគេ ដើម្បីចូលរួមជាមួយ សឹង ង៉ុកមិញ ដែលកំពុងបំពេញទស្សនកិច្ចនៅសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម ពេលកិច្ចព្រមព្រៀងត្រូវបានចុះហត្ថលេខា ជាជននិរទេសខ្លួន ឬ "ធ្វើការប្រមូលផ្តុំ" នៅទីនោះ (តាប់ កេត-tap ket) ។ ប៉ុន្មានខែក្រោយមក ស៊ីវ ហេង បានត្រឡប់មកតំបន់ព្រំប្រទល់វៀតណាមខាងត្បូង-កម្ពុជា ដោយមាន នួន ជា និង កម្មាភិបាលថ្នាក់ខ្ពស់*

ដោយប្រៀបធៀបមួយចំនួនដទៃទៀតមកជាមួយដែរ ក្នុងនេះរួមមាន សោ គីម (ហៅ ជា សុវណ្ណ) ផង ។ គីម ជាអតីតទាហាន នៃកងទ័ពអាណានិគមនិយម ដែលបានផ្ដាច់ខ្លួនចូលជាមួយពួកកុម្មុយនីស ហើយត្រូវបាន បកត អប់រំឱ្យទៅជាមេបញ្ជាការ យោធាម្នាក់ ។

អង្គការនាពេលនោះ បានស្ថិតនៅក្រោមការដឹកនាំរបស់គណៈកម្មាធិការមជ្ឈឹមបណ្ដោះអាសន្នមួយ ដោយមាន ស៊ីវ ហេង ជាលេខា ទូ សាមុត ជាអនុលេខា និង សឹង ង៉ុកមិញ ដែលជាជននិរទេសខ្លួន ជាសមាជិកលំដាប់ទី ៣ ។ នៅពេលអវត្តមានរបស់អ្នកចុងក្រោយនេះ ជាក់ស្ដែង នួន ជា ត្រូវបានក្លាយជាមនុស្សទី ៣ នៃបក្ស ។ គីម ជាសមាជិកទី ៤ តែភ្លាមៗនោះរូបគាត់បានចាកចេញទៅវៀតណាមខាងជើងអស់រយៈពេល ២ ឆ្នាំ ដើម្បីទទួលការហ្វឹកហ្វឺនថែមទៀត ។ សភាពការណ៍មិនទៀងទាត់នៃកម្ពុជាបានធ្វើឱ្យ ស៊ីវ ហេង, ទូ សាមុត និង នួន ជា នៅរក្សាមូលដ្ឋាននៅតំបន់ព្រំដែនវៀតណាមខាងត្បូង-កម្ពុជាជាបន្តទៀត តែ ទូ សាមុត និង នួន ជា បានស្ថិតនៅទីក្រុងភ្នំពេញអស់រយៈពេលយ៉ាងយូរផងដែរ ដែលនៅទីនោះ ផាំ វ៉ាន់បា បាននាំ សាឡុត ស មកជាមួយដែរ ។ ផាំ វ៉ាន់បា ជាកម្មាភិបាលថ្នាក់លើវៀតណាមរបស់ ទូ សាមុត និងដែល សាឡុត ស បានចូលរួមជាមួយសាខា បកត នៅទីនោះ ។

ការកិច្ចរបស់ បា ឆ្លុះបញ្ចាំងឱ្យឃើញថា ទោះបីជាមានកិច្ចព្រមព្រៀងទីក្រុងហ្សឺណែវក៏ដោយ ក៏ពួកវៀតណាមនៅតែរក្សាបណ្ដាញទាក់ទងនៃការត្រួតត្រាដោយផ្ទាល់របស់ពួកគេ លើកិច្ចការរបស់ពួកកុម្មុយនីសដដែល ។ ង្វៀង ថាញ់សឺន កម្មាភិបាលថ្នាក់លើរបស់វៀតណាមនៅកម្ពុជាមុនកិច្ចព្រមព្រៀងទីក្រុងហ្សឺណែវ បានត្រឡប់ទៅវៀតណាមវិញ តែនៅតែទទួលបន្ទុកលើគណៈកម្មាធិការនយោបាយនៃកម្ពុជាក្នុង បពវ ដដែលរហូតដល់ ឆ្នាំ ១៩៥៦ ដោយស្ថិតក្រោមការទទួលខុសត្រូវរបស់ ឡេ យន់ សមាជិកការិយាល័យនយោបាយ ស្នងការនយោបាយ បពវ ទទួលបន្ទុកភាគខាងត្បូងវៀតណាម និងកម្ពុជា ។ ង្វៀង ថាញ់សឺន មើលការខុសត្រូវលើបណ្ដាញនៃកម្មាភិបាលកុម្មុយនីសវៀតណាមបង្កប់ខ្លួន ដូចជា បា ដែលបានស្ថិតនៅក្នុងប្រទេសកម្ពុជា ដើម្បីដឹកនាំនិងផ្ដល់ដំបូន្មានដល់បក្សកម្ពុជា រហូតដល់ប្រព័ន្ធនេះអស់សុពលភាពនៅក្នុងឆ្នាំ ១៩៥៦-១៩៥៧ (ទោះបីជាទំនាក់ទំនងនៅបន្តទៅទៀតនាពេលក្រោយពីនោះមកទៀតក៏ដោយ) ។

### មាគ៌ារបស់ បពវ សំរាប់អនុវត្តនៅកម្ពុជា

វិសាលភាពនៃការត្រួតត្រារបស់វៀតណាម ត្រូវបានឆ្លុះបញ្ចាំងឱ្យឃើញនៅពេលពួកកុម្មុយនីសខ្មែរងាកទៅអនុម័តយកមាគ៌ានយោបាយ ដែលវៀតណាមបានសំរេចសំរាប់អនុវត្តនៅក្នុងប្រទេសវៀតណាមខ្លួនឯងនោះ ។ នៅទីនោះ កិច្ចព្រមព្រៀងទីក្រុងហ្សឺណែវបានកំណត់ឱ្យមានការប្រមូលផ្ដុំកងកម្លាំងប្រដាប់អាវុធ នៅក្នុងសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាមក្នុងពេលរង់ចាំការបោះឆ្នោតទូទៅនៅទូទាំងប្រទេស ដែលគ្រោងនឹងធ្វើនៅក្នុងខែកក្កដា ឆ្នាំ១៩៥៦ ដែលក្នុងនោះពួកកុម្មុយនីសក៏ត្រូវបានអនុញ្ញាតឱ្យចូលរួមផងដែរ ។ ទោះបីជាមេដឹកនាំជាន់ខ្ពស់នៃ បពវ មានការសង្ស័យថារបបមិនមែនកុម្មុយនីសរបស់ ង៉ោ ឌិនយៀម គាំទ្រដោយសហរដ្ឋអាមេរិក - ដែលត្រូវបានរក្សាទុកឱ្យនៅនឹងកន្លែងនៅភាគខាងត្បូងដោយកិច្ចព្រមព្រៀង - ថានឹងមិនអនុញ្ញាតឱ្យមានការបោះឆ្នោតក៏ដោយ ក៏ពួកគេបានរៀបចំដើម្បីចូលរួមការតស៊ូនយោបាយ ដោយចូលរួមការបោះឆ្នោតនេះដែរ។ បើសិនជាការនេះត្រូវក្លាយទៅជាការឥតប្រយោជន៍ទៅវិញនោះ ពួកគេក៏បានរៀបចំធ្វើសង្គ្រាមឡើងវិញ ដើម្បីដណ្ដើមយកជ័យជំនះទាំងស្រុងផងដែរ ប៉ុន្តែនយោបាយចំពោះមុខរបស់ បពវ គឺត្រូវបង្កើនការតស៊ូខាងនយោបាយរបស់ប្រជាជនភាគខាងត្បូង ដើម្បីឈ្នះឆ្នោតដែរ-ពួកអ្នកសង្កេតការណ៍ភាគច្រើនមានជំនឿថានឹងមានការគាំទ្រយ៉ាងខ្លាំងចំពោះពួកកុម្មុយនីស - ហើយឈរលើមូលដ្ឋាននេះនឹងបង្រួបបង្រួមប្រទេសវៀតណាមក្រោមការគ្រប់គ្រងរបស់កុម្មុយនីស ។

ក៏ប៉ុន្តែ បពវ ក៏បានសំរេចផងដែរថា ស្ថិតចំពោះមុខកាលៈទេសៈដែលកំពុងកើតមាននៅភាគខាងត្បូង ការបន្តការតស៊ូដោយនយោបាយនេះតម្រូវឱ្យសមាជិកបក្សជាច្រើននៅទីនោះចូលសម្ងាត់ ។ ការណ៍នេះនឹងអាចការពារសមាជិកបក្សបាន ហើយសំរួលដល់ការធ្វើសកម្មភាពស្របច្បាប់របស់ពួកគេក្នុងការចូលរួមការបោះឆ្នោត ការរៀបចំបាតុកម្ម ការធ្វើកាសែត ការបង្កើតអង្គការមហាជន និងការបង្កប់ខ្លួនរបស់ពួកគេ ឱ្យបំរើក្នុងសេវាកម្មស៊ីវិល និងក្នុងរដ្ឋាភិបាល ក្នុងទិសដៅផ្សព្វផ្សាយឥទ្ធិពលរបស់បក្ស និងជ្រើសរើសសមាជិកថ្មី ។ ដូច្នេះ រចនាសម្ព័ន្ធរបស់ បពវ នៅភាគខាងត្បូងភាគច្រើនបានចូលសម្ងាត់ ព្រមជាមួយការរៀបចំធ្វើផែនការ ដើម្បីដាក់បង្ហាញអង្គការរណសិរ្សស្របច្បាប់មួយដើម្បីប្រកួតប្រជែងក្នុងការបោះឆ្នោត ។ ការប៉ុនប៉ងសំខាន់ទី ១ ក្នុងទិសនេះ ពាក់ព័ន្ធនឹងការចាត់តាំងពួកបញ្ញាវ័ន្ត និងនិស្សិត មាននិន្នាការឆ្វេងនិយម នៅទីក្រុងព្រៃនគរនៃភាគខាងត្បូង ។

នៅភ្នំពេញ តាមមតិរបស់ ផាំ វ៉ាន់បា ខ្មែរក៏ត្រូវធ្វើដូចគ្នានឹងវៀតណាមដែរ ពោលគឺខ្មែរត្រូវខិតខំធ្វើយ៉ាងណាយកឈ្នះខាងនយោបាយឱ្យបាន ក្នុងពេលរង់ចាំការបង្រួបបង្រួមប្រទេសវៀតណាមឡើងវិញ បន្ទាប់មកប្រទេសវៀតណាមនឹងធ្វើអន្តរាគមន៍ដើម្បីនាំមកនូវជ័យជំនះនៃបដិវត្តនៅកម្ពុជាផងដែរ ។ បន្ទាប់ពីកិច្ចព្រមព្រៀងទីក្រុងហ្សឺណែវ ទូ សាមុត ត្រូវបានចាត់តាំងឱ្យទទួលបន្ទុកខាងការរៀបចំធ្វើសកម្មភាពក្នុងទីក្រុង ។ ទូ សាមុត បានបង្កើតគណៈកម្មាធិការបក្សជាសម្ងាត់មួយសំរាប់ធ្វើការក្នុងទីក្រុង ដោយមាន នួន ជា ជា លេខា និង សាឡុត ស ជា អនុរបស់ នួន ជា ។ ទូ សាមុត នៅតែបន្តប្រឹក្សាយោបល់ជាមួយ ផាំ វ៉ាន់បា លើគ្រប់បញ្ហាទាំងអស់ដដែល និងទទួលការណែនាំពីរូបគេ ។ សាឡុត ស ក៏ទទួលការណែនាំពី បា ដែរ ដែល បា បានរួមជាមួយ ទូ សាមុត និង សាឡុត ស បង្កើតសាខាបក្សសម្ងាត់មួយ ដោយមិនឱ្យខ្មែរដទៃទៀតដឹង ។

នៅពេលដែលពួកកុម្មុយនីសខ្មែរ នាំគ្នាធ្វើគ្រូនៅសាលាមធ្យមសិក្សាឯកជនក្នុងរាជធានី ដើម្បីចេញមុខជាចំហនិងស្របច្បាប់ ដើម្បីធ្វើសកម្មភាពទាក់ទាញពួកនិស្សិត និងគ្រូបង្រៀនដូចពួកគេដែរ អង្គការបក្សទីក្រុងភ្នំពេញបានប្រើ សាឡុត ស ឱ្យធ្វើជាមនុស្សសំរាប់ធ្វើការទាក់ទងគ្នា ត្រួតពិនិត្យលើការបង្កើតរណសិរ្សចំហមួយដែលមានលក្ខណៈមិនមែនកុម្មុយនីស ដែលគេឱ្យឈ្មោះថាក្រុមប្រជាជន ដើម្បីប្រកួតប្រជែងក្នុងការបោះឆ្នោតដែលតម្រូវដោយកិច្ចព្រមព្រៀងទីក្រុងហ្សឺណែវ ។ កែវ មាស ដែលជាកម្មាភិបាលភូមិភាគបូព៌ា ក៏ដូច សាឡុត ស ដែរ សុទ្ធតែជាមនុស្សដែលការពារដោយ ទូ សាមុត នោះ ត្រូវបានចាត់តាំងឱ្យធ្វើជាលេខាគណៈកម្មាធិការនៃក្រុមប្រជាជនចំហផង និងជាលេខារបស់សាខាសម្ងាត់នៃអង្គការកុម្មុយនីសផង ដែលធ្វើប្រតិបត្តិការតាមរយៈអង្គការនេះ ។ សាឡុត ស ជាអ្នកពាំនាំសេចក្តីណែនាំរបស់អង្គការបក្សថ្នាក់លើទៅឱ្យក្រុមប្រជាជន ធ្វើយ៉ាងដូច្នេះវាជានាបាននូវការត្រួតត្រា និងការសម្ងាត់ ។ សាឡុត ស ក៏បានធ្វើការយ៉ាងជិតស្និទ្ធជាមួយ កែវ មាស ផងដែរ ក្នុងការកំណត់លក្ខន្តិកៈ និងកម្មវិធីនយោបាយរបស់ក្រុមប្រជាជន ដូច្នោះ គាត់អាចក្តាប់បានសកម្មភាពរបស់ពួកកុម្មុយនីសនៅទូទាំងប្រទេស ពាក់ព័ន្ធទៅនឹងយុទ្ធនាការបោះឆ្នោត ។ ក្នុងពេលជាមួយគ្នានេះដែរ សាឡុត ស បានដើរតួនាទីជាចំបងមួយក្នុងការធ្វើសកម្មភាពវិច្ឆេទកម្មរបស់ចលនាកុម្មុយនីស នៃគណបក្សប្រជាធិបតេយ្យចាស់ ដែលរូបគាត់ និង អៀង សារី បានធ្វើមុនពេលពួកគេទៅប្រទេសបារាំង ។

សាឡុត ស មានជំនឿថា គណបក្សប្រជាធិបតេយ្យមាននិន្នាការប្រឆាំងសក្តិភូមិ និងប្រឆាំងចក្រពត្តិនិយម ដែលពួកកុម្មុយនីសអាចទាញយកចំណេញ និងជំរុញបាន ។ គាត់បានទាក់ទងជាមួយពួកប្រជាធិបតេយ្យ ដែលគាត់កំណត់ថាជាជនចំរើន និងបានបង្កប់ជនកុម្មុយនីសទៅក្នុងជួរបក្សនេះ ។ ពួកនេះបានជំរុញពួកអ្នកចំរើន ឱ្យដណ្តើមយកនាទីដឹកនាំនៃបក្ស នៅពេលដែលពួកកុម្មុយនីសឈរឈ្មោះជាបេក្ខជនក្នុងការបោះឆ្នោត ។ ស ក៏បានជួយបង្កើតយុទ្ធវិធីនៃការដោះស្រាយបញ្ហារវាងពួកប្រជាធិបតេយ្យ និងក្រុមប្រជាជនដោយសម្រុះសម្រួល ធ្វើយ៉ាងណាជៀសវាងកុំឱ្យពួកគេឈរឈ្មោះប្រកួតប្រជែងគ្នាក្នុង

មណ្ឌលបោះឆ្នោតតែមួយដូចគ្នា ។ លើសពីនេះទៅទៀត គាត់បានជួយរៀបចំបង្កើតកាសែត ប្រជាធិបតេយ្យ របស់គណបក្សប្រជាធិបតេយ្យ ឡើងវិញ ។

វៀតណាមមានហេតុផលសព្វបែបយ៉ាងដើម្បីធ្វើឱ្យ សាឡុត ស ពេញចិត្តនឹងអនុវត្តមាគ៌ាដែលពួកគេបានលើកឡើងសំរាប់ប្រទេសកម្ពុជា និងភាគខាងត្បូងវៀតណាម ។ ពួកវៀតណាមមានការពេញចិត្តនឹងការធ្វើវិទ្ធង្សនារបស់ សាឡុត ស ក្នុងគណបក្សប្រជាធិបតេយ្យ ស្រាប់តែភ្លាមៗនោះពួកគេបោះបង់ចោលការបកអាក្រាតបក្សនេះ ដែលពួកគេធ្លាប់បានធ្វើនាមុនសន្និសិទទីក្រុងហ្សឺណែវ ហើយបែរមកសរសើរវាជាសាធារណៈ ថាជាអង្គការចំរើនពិតប្រាកដមួយ ទទួលបានការគាំទ្រពីមហាជនទៅវិញ ដោយមិនអើពើអំពីចក្រពត្តិអាមេរិកនៅកម្ពុជា ។ សាឡុត ស មានសេចក្តី "រំភើបយ៉ាងខ្លាំងចំពោះការបោះឆ្នោតនេះ ក្នុងជំនឿថាវានឹងបង្កើតឡើងនូវរដ្ឋាភិបាលនៃការកែទម្រង់ និងប្រឆាំងសហរដ្ឋអាមេរិកមួយបាន ។ មិនតែប៉ុណ្ណោះ វាហាក់ដូចជាថា ពួកប្រជាធិបតេយ្យទទួលបានឱកាសដ៏ល្អមួយនឹងដណ្តើមបានជ័យជំនះ" ដោយពួកកុម្មុយនីសមានឥទ្ធិពលនយោបាយទៅលើពួកគេ ។

ក៏ប៉ុន្តែ នៅពេលការបោះឆ្នោតចាប់ផ្តើមធ្វើ ក្នុងស្ថានភាពដែលប្រជាជនកម្ពុជាស្ថិតក្រោមការក្តោបក្តាប់យ៉ាងណែនរបស់សម្តេចសីហនុ និងរបស់ពួកអ្នកស្មោះត្រង់ខាងនយោបាយចំពោះសម្តេច ។ ពួកគេបានប្រើការបោះឆ្នោតនេះ ដើម្បីច្រានចោលលទ្ធភាពនៃពួកអ្នកទាំងឡាយណាដែលប្រកួតប្រជែង ដោយយកបឋមភាពខាងនយោបាយរបស់ពួកគេ តាមរយៈភាពជាតំណាងក្នុងសភានោះ ។ តាមរយៈអង្គការនយោបាយ *សង្គមរាស្ត្រនិយម* របស់ពួកគេ ពួកគេបានទប់ស្កាត់មិនឱ្យពួកប្រជាធិបតេយ្យ និងពួកប្រជាជន ចូលក្នុងរដ្ឋសភាបានទាំងស្រុង ។

ការប្រកួតប្រជែងប្រឆាំងសម្តេចសីហនុ ដែលបានដាក់រាជ្យ ដើម្បីដើរតួធ្វើជាអ្នកនយោបាយដោយផ្ទាល់ព្រះអង្គ (ក្នុងព្រះឋានៈជាព្រះអង្គម្ចាស់សាមញ្ញមួយព្រះអង្គ) បានដាក់ឱ្យពួកកុម្មុយនីសប្រឆាំងជាមួយសត្រូវដ៏ធំអស្ចារ្យមួយ ។ ដោយពុំមានការសង្ស័យអ្វីទេ ជោគជ័យរបស់សម្តេចសីហនុក្នុងការទទួលបានឯករាជភាពនៃកម្ពុជាជាផ្លូវការពីប្រទេសបារាំងក្នុងឆ្នាំ ១៩៥៣ បានជួយសម្តេចយ៉ាងខ្លាំងក្នុងការធ្វើឱ្យព្រះអង្គមានប្រជាប្រិយភាពក្នុងចំណោមមន្ត្រីរាជការស៊ីវិល និងប្រជាជនជាទូទៅ ។ ការនេះជាកត្តាចំបងមួយ ដែលគូសបញ្ជាក់អំពីឯតទគ្គកម្មយ៉ាងខ្លាំងក្នុងការបោះឆ្នោតរបស់សង្គមក្នុងឆ្នាំ ១៩៥៥ ។ ក៏ប៉ុន្តែ ជ័យជំនះរបស់សង្គមនេះ តម្រូវឱ្យយល់ក្នុងន័យថាវាជាការបង្កើនការក្តោបក្តាប់ស្ថាប័នរដ្ឋនានារបស់សម្តេចសីហនុ ។ គន្លឹះនៃការបំផ្លាញពួកកុម្មុយនីសក្នុងការបោះឆ្នោតរបស់សម្តេច គឺការប្រើស្ថាប័នសន្តិសុខ និងសារព័ត៌មានរបស់រដ្ឋ ព្រមទាំងរដ្ឋបាលមូលដ្ឋានផងដែរ ដើម្បីរំខាន ចាប់ខ្លួន បំបិទមាត់ និងពេលខ្លះសម្លាប់ពួកអ្នកប្រឆាំងថែមទៀតផង ជាពិសេស (តែមិនត្រឹមតែប៉ុណ្ណោះទេ) នៅតាមជនបទ និងដើម្បីញាត់សន្លឹកឆ្នោតទៅក្នុងប្រអប់ និងបំភ្លៃលទ្ធផលនៅពេលដែលវិធានការផ្សេងទៀតមិនទទួលបានជោគជ័យទេនោះ ។

ខេត្តកំពង់ចាមនៃភូមិភាគបូព៌ា គឺជាមជ្ឈមណ្ឌលនៃការបង្ក្រាបយ៉ាងធ្ងន់ធ្ងរជាពិសេសមួយប្រឆាំងពួកប្រជាជន ដោយឧបទ្ទវហេតុនៃការចាប់ខ្លួន និងការបាញ់ប្រហារជាច្រើន ។ រចនាសម្ព័ន្ធបក្សខេត្តដឹកនាំដោយវៀតណាមនៅទីនោះ គឺជាចំណុចកណ្តាលនៃការវាយសម្រុកដោយយោធាធំជាងគេ នៅពេលកិច្ចព្រមព្រៀងទីក្រុងហ្សឺណែវត្រូវបានចុះហត្ថលេខា ហើយដែលបទបញ្ញត្តិនានានៃកិច្ចព្រមព្រៀងបានបណ្តាលឱ្យមានការខកចិត្តយ៉ាងខ្លាំងក្នុងជួរបដិវត្តន៍ ។ ដោយអនុលោមតាមកិច្ចព្រមព្រៀង ពួកវៀតណាមជាច្រើនបានដកចេញ តែនៅរក្សាទុកខ្លះ ដើម្បីមើលការខុសត្រូវលើគណៈកម្មាធិការបក្សខេត្តថ្មីមួយដែលមានសុទ្ធសឹងជាជនខ្មែរទាំងអស់ ដែលសមាជិករបស់វាបានលាក់ខ្លួននៅតាមភូមិនានាដែលអង្គការមានមូលដ្ឋានរឹងមាំនោះ ។ កងកម្លាំងប្រដាប់អាវុធកុម្មុយនីសត្រូវបានរំសាយ តែពួកយុទ្ធជនក៏ត្រូវបានប្រាប់ផងដែរថា ការតស៊ូដោយអាវុធត្រូវផ្អាកសិន ហើយថាពួកគេត្រូវកប់ ឬបើពុំដូច្នោះទេត្រូវលាក់សម្ភារៈយោធាឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន ។ ក្នុងពេលរង់ចាំការធ្វើ

សង្គ្រាមឡើងវិញ ពួកគេបានទទួលការណែនាំឱ្យត្រឡប់ទៅភូមិកំណើតរបស់ពួកគេវិញ ដើម្បីដឹកនាំធ្វើយុទ្ធនាការបោះឆ្នោត និងរូបភាពដទៃទៀតនៃការតស៊ូនយោបាយ ។ គណៈកម្មាធិការខេត្ត បន្ទាប់ពីប្រឹក្សាយោបល់ជាមួយ កែវ មាស ដែលជាតំណាងនៃ អង្គការ បក្សទីក្រុងរបស់ ទូ សាមុត មក ត្រូវជ្រើសរើសកម្មាភិបាលដែលមានកេរ្តិ៍ឈ្មោះល្អដោយប្រៀបធៀបមួយចំនួន ឱ្យចេញពីការលាក់ខ្លួន និងឈរឈ្មោះបោះឆ្នោតជាបេក្ខជនរបស់គណបក្សប្រជាជន ។ ក៏ប៉ុន្តែ នៅពេលការបោះឆ្នោតកាន់តែខិតចូលជិតមកដល់ ថ្នាក់ដឹកនាំខេត្តបានសន្និដ្ឋានថា និន្នាការនៃជ័យជំនះរបស់បក្សប្រជាជនមុខជានឹងធ្វើឱ្យរដ្ឋាភិបាលដែលកំពុងនៅទំនេរនោះ វាយប្រហារមកលើពួកគេដោយជៀសពុំរួច ហើយជាក់ស្តែង តែប៉ុន្មានថ្ងៃមុនថ្ងៃបោះឆ្នោតចូលមកដល់ បេក្ខជនទាំងអស់របស់បក្សត្រូវបានចាប់ឃុំ ។ ពួកគេត្រូវបានដាក់ឃុំនៅខេត្តរហូតដល់ក្រោយថ្ងៃបោះឆ្នោតរួច ហើយត្រូវបានគំរាមថាបើពួកគេមិនសហការជាមួយរដ្ឋាភិបាលទេ នោះពួកគេនឹងត្រូវបញ្ជូនទៅភ្នំពេញដើម្បីសម្លាប់ចោល ។ អ្នកណាដែលនៅតែដាច់ខាតប្រឆាំងតទៅទៀតបន្ទាប់ពីការដោះលែងនោះ ត្រូវបានកម្លាំងសន្តិសុខរដ្ឋាភិបាលសម្លាប់ នៅពេលភ្លាមៗបន្ទាប់មក ។

ដើម្បីធ្វើឱ្យអស់ការសង្ស័យពីយុទ្ធវិធីដែលនាំទៅឱ្យបានទទួលជ័យជំនះនេះនោះ សម្តេចសីហនុនិងពួកអ្នកគាំទ្រលោក បានប្រកួតប្រជែងដោយជោគជ័យលើអាណត្តិរបស់គណៈកម្មការអន្តរជាតិសំរាប់ត្រួតពិនិត្យការបោះឆ្នោត ដោយជាក់ស្តែង គណៈកម្មការនេះ ជាទូទៅ បានកំរិតព្រំដែនរបស់ពួកគេត្រឹមតែធ្វើការសង្កេតការណ៍ជាទូទៅ ហើយមិនបានព្យាយាមជានាអំពីអព្យាក្រិតភាពរបស់ស្ថាប័នរដ្ឋនានា ក្នុងពេលនៃកិច្ចដំណើរការបោះឆ្នោតនេះទេ ។ បន្ទាប់ពីការរាប់សន្លឹកឆ្នោតជាផ្លូវការបានប្រកាសថាសង្គមទទួលបានសម្លេងប្រមាណ ៨២% នៃសន្លឹកឆ្នោតដែលបានបោះ ក្រុមប្រជាជនទទួលបានតែ ៤% ហើយសល់ពីនោះគឺបានទៅពួកប្រជាធិបតេយ្យមក សមាជិកទាំង ៣ រូប នៃគណៈកម្មការបានជជែកគ្នាជាឯកជនយ៉ាងតឹងតែងមួយអំពីថាតើការបោះឆ្នោតនេះត្រូវបានធ្វើឡើងដោយសេរីឬទេនោះ តំណាងមកពីប្រទេសឥណ្ឌា និងប៉ូឡូញ ប្រាកដក្នុងខ្លួនថាវាមិនសេរីទេ ។ ក៏ប៉ុន្តែ នៅពេលដែលសមាជិកមកពីប្រទេសកាណាដាគំរាមថានឹងប្រកាសនូវទស្សនៈមិនទទួលស្គាល់ជាសាធារណៈនោះ ការសម្រុះសម្រួលមួយត្រូវបានឯកភាពគ្នាថាផ្តល់ការយល់ឃើញថា គណៈកម្មការចាត់ទុកថាការបោះឆ្នោតគឺត្រឹមត្រូវ ។

### ការលំបាកក្រោយការបោះឆ្នោត

ជាការចំអក ពួកកុម្មុយនីសខ្មែរហាក់មានភាពប្រសើរជាងសមមិត្ត បពវ នៃភាគខាងត្បូងវៀតណាមរបស់ពួកគេ ក្នុងការតស៊ូនយោបាយ ។ នៅឆមាសទី ២ ឆ្នាំ ១៩៥៥ រដ្ឋាភិបាល ង៉ោ ឌិនយៀម នៅព្រៃនគរ បានបើកយុទ្ធនាការបង្ក្រាបប្រឆាំងកុម្មុយនីស បដិសេធកិច្ចសហប្រតិបត្តិការអ្វីទាំងអស់ដើម្បីរៀបចំការបោះឆ្នោត ដូចដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងទីក្រុងហ្សឺណែវ ហើយជាជំនួសបានសាកល្បងសម្របច្បាប់ឱ្យខ្លួនឯងដោយធ្វើប្រជាមតិដែលពួកកុម្មុយនីសបានធ្វើពហិការទៅវិញ ។ ក្រោយមក ទើបពួកវៀតណាម បានអះអាងដោយត្រឹមត្រូវថា ការខកខានមិនបានចាត់ចែងធ្វើការបោះឆ្នោតនេះ គឺដោយសារសហរដ្ឋអាមេរិកមានបំណងចង់រក្សា ង៉ោ ឌិនយៀម និងបរិវាឱ្យនៅនឹងកន្លែង ។ ការណ៍នេះបានធ្វើឱ្យសហរដ្ឋអាមេរិកក្លាយជាសត្រូវជាក់ស្តែង និងចំពោះមុខ នៃបដិវត្តន៍វៀតណាម ហើយ បពវ បានធ្វើយុត្តិកម្មឱ្យ បពវ ដោយពិព័ណនាពួកអាមេរិកថាជាចៅហ្វាយនៃរបប"មី-យៀម" (របបអាមេរិក-យៀម) ជារដ្ឋាភិបាល"ចក្រពត្តិនិយមសក្តិភូមិ ផ្តាច់ការ [និង] ហ្វាស៊ីស" ដែលបានប្រែក្លាយភាគខាងត្បូង [វៀតណាម] ជា "គ្រួសារ-ត្រួតត្រាដោយអាណានិគមនិយមថ្មីនៃសហរដ្ឋអាមេរិក" ។

នៅផ្នែកខ្លះនៃភាគខាងត្បូង ការកាប់សម្លាប់ ការចាប់ចងដោយទ្រង់ទ្រាយធំ និងរូបភាពដទៃទៀតនៃការបង្ក្រាប បានធ្វើឱ្យវិនាសអន្តរាយដល់អង្គការបដិវត្តន៍របស់វៀតណាម និងបានបញ្ចុះបញ្ចូលឱ្យពួកអ្នកនៅមានសេរីភាពនៅឡើយ ថាពុំមានលទ្ធភាពអាចរួមរស់ជាមួយរដ្ឋាភិបាលបានទេ ។ ចាប់ពីចុងឆ្នាំ ១៩៥៥ មក ឡេ យន់ ដែលជាស្នងការនយោបាយ បពវ សំរាប់

ភាគខាងត្បូងវៀតណាម និងកម្ពុជា បានស្នើយោបល់ថា យ៉ាងហោចណាស់ នៅវៀតណាម ប្រហែលជាត្រូវចាប់ផ្តើមធ្វើការតស៊ូដោយអាវុធឡើងវិញហើយ ។ ក្នុងខែមីនា ឆ្នាំ ១៩៥៦ គាត់បានស្នើថាត្រូវប្រើសកម្មភាពយោធានៅភាគខាងត្បូង ដើម្បីជួយគាំទ្រសកម្មភាពដទៃទៀត ហើយពួកកុម្មុយនីសភាគខាងត្បូងបានគាំទ្រគំនិតនេះ ។ ដើម្បីបង្កើតមូលដ្ឋានបង្អែកសំរាប់ទិសដៅនេះ ឡេ យន់ ក៏បានស្នើផងដែរថា កម្មាភិបាលជាន់ខ្ពស់របស់ បពវ ត្រូវគាំទ្រកម្ពុជាដើម្បីពង្រឹងអង្គការដឹកនាំនៅទីនោះ (ដែលនឹងផ្តល់ផងដែរដល់ បពវ នូវអ្វីដើម្បីសហការជាមួយ នៅពេលជ័យជំនះទីចុងបំផុតនៃបដិវត្តន៍វៀតណាមមានលទ្ធភាពធ្វើអន្តរាគមន៍ក្នុងនាមបដិវត្តន៍កម្ពុជា) ។ ប៉ុន្តែ សេចក្តីស្នើទាំងអស់របស់គេ ត្រូវបានបដិសេធដោយថ្នាក់ដឹកនាំ បពវ នៅហាណូយ ដែលបានបញ្ជាឱ្យពួកអ្នកភាគខាងត្បូងបន្តការតស៊ូនយោបាយ ដោយខិតខំទាក់ទាញការគាំទ្រនៅតាមភូមិនានា ។ ក៏ប៉ុន្តែ ក្នុងការផ្សារចាត់តាំងដើម្បីពង្រឹងគោលជំហរនយោបាយរបស់បក្សនេះ ក៏ត្រូវពិចារណាផងដែរអំពីការរៀបចំសំរាប់ធ្វើការតស៊ូដោយអាវុធបើប្រសិនជា និងនៅពេលណាមានការចាំបាច់នោះ ។ ដូច្នេះនៅពេលដែលសេចក្តីសំរេចរបស់គណៈកម្មាធិការមជ្ឈឹម បពវ ប្រកាសនៅក្នុងខែមេសា ឆ្នាំ ១៩៥៦ ថាសក្តានុភាពនៅតែមាននៅឡើយ ដើម្បីធ្វើដំណើរទៅមុខឆ្ពោះទៅសង្គមនិយមនៅភាគខាងត្បូងដោយមធ្យោបាយសន្តិវិធី ។ ហូ ជីមិញ ដែលជាប្រធានបក្ស បានបន្ថែមថា "វណ្ណៈកម្មជីពនៅតែត្រូវរៀបចំខ្លួនដើម្បីធ្វើការតស៊ូដោយអាវុធ ជានិច្ច" ។

ថ្នាក់ដឹកនាំកុម្មុយនីសកម្ពុជា អាចបានប្រើភាពរឹងរូសរបស់វៀតណាម ដែល ឡេ យន់ ចង់ផ្តល់ឱ្យពួកគេ ។ ទោះបីជា នួន ជា បានមកបោះទីតាំងអចិន្ត្រៃយ៍នៅភ្នំពេញនៅចុងឆ្នាំ ១៩៥៥ ឡើងវិញ ហើយ ស៊ីវ ហេង និង ទូ សាមុត ក៏បានមកតាមនៅដើមឆ្នាំ ១៩៥៦ ក៏ដោយ ក៏គណៈកម្មាធិការមជ្ឈឹមបក្សបណ្តោះអាសន្នមួយត្រូវបានបង្កើតឡើងដែរ ។ នេះគឺបណ្តាលមកពី ស៊ីវ ហេង ដែលបានបង្កើតគណៈកម្មាធិការមួយមានគ្នា ៣ នាក់ ទទួលខុសត្រូវដឹកនាំធ្វើសកម្មភាពនៅតំបន់ជនបទរបស់បក្សក្តី ក្នុងពេលដែលខ្លួននៅតែជាលេខាបក្សសំរាប់ទូទាំងប្រទេសនោះ កាន់តែយល់ច្បាស់ថាបន្ទាប់ពីការបោះឆ្នោត បុព្វហេតុកុម្មុយនីសនៅកម្ពុជាស្ថិតក្នុងស្ថានភាពអស់សង្ឃឹម ដោយហេតុថាកសិករជាទូទៅមានការរីករាយគ្រប់គ្រាន់ហើយជាមួយនឹងវាសនារបស់ពួកគេ និងមានការទន់ទោរកាន់តែខ្លាំងទៅគាំទ្រសម្តេចសីហនុ ជាជាងការធ្វើបដិវត្តន៍ ។ ពេលមួយក្នុងឆ្នាំ ១៩៥៦ រូបគេបានចាប់ទាក់ទងជាសម្ងាត់ជាមួយ លន់ ណុល នាយសេនាធិការកងទ័ពរបស់សម្តេច ដែលបានធានាផ្តល់កិច្ចការពារសន្តិសុខ និងឱកាសធ្វើការរកស៊ីដល់រូបគេ និងក្រុមគ្រួសាររបស់គេ ដើម្បីដោះដូរជាមួយការផ្តល់ព័ត៌មានអំពីអង្គការកុម្មុយនីស ។ ការនិយាយឱ្យដឹងនូវទស្សនៈរបស់ ស៊ីវ ហេង នេះ បានធ្វើឱ្យរូបគេកាន់តែមានទំនាស់ខ្លាំងឡើងជាមួយអង្គការបក្សទីក្រុងដែលកំពុងតែសកម្មនៅឡើយ ហើយនៅពាក់កណ្តាលឆ្នាំ ១៩៥៦ ពួកនេះបានចាប់ផ្តើមចោទប្រកាន់រូបគេថាបានប្រព្រឹត្តកំហុសខាងមនោគមវិជ្ជា និងនយោបាយ និងបានក្បត់គោលការណ៍នៃការតស៊ូរបស់បក្ស ដោយគិតថាការពុំមានទំនាស់បដិបក្សនៃវណ្ណៈនៅជនបទកម្ពុជា វណ្ណៈកសិករនឹងមិនដឹកនាំធ្វើបដិវត្តន៍ទេ តែធ្វើតែតាមវណ្ណៈកាន់អំណាច ដែលមានសម្តេចសីហនុជាប្រមុខនោះ ។ សាឡុត ស បានព្រមានដល់សកម្មជនទីក្រុងដទៃទៀតឱ្យឯកោ ស៊ីវ ហេង ដោយសារតែរូបគេមានការទាក់ទងគួរឱ្យសង្ស័យជាមួយមន្ត្រីរដ្ឋាភិបាល និងយោធា ។ ដល់ឆ្នាំ ១៩៥៨ ថ្នាក់ដឹកនាំបក្សដទៃទៀត បានយល់កាន់តែច្បាស់ថារូបគេ (ស៊ីវ ហេង) មានសម្ព័ន្ធភាពជាមួយ លន់ ណុល ដូច្នេះរូបគេបានក្បត់បដិវត្តន៍ និងប្រជាជនពេញទីហើយ ។ ក្រោយមក រូបគេត្រូវបានថ្កោលទោស ដោយសារបានផ្តល់ព័ត៌មានដល់ លន់ ណុល ដែលបានរួមចំណែកធ្វើឱ្យខូចខាតកម្មាភិបាលនិងបក្សជនអស់ ៩០% នៅតំបន់ជនបទ ពីឆ្នាំ ១៩៥៦ ដល់ ១៩៥៩ ដែលការខូចខាតនេះបានធ្វើឱ្យ ទូ សាមុត លែងមានជំនឿលើរចនាសម្ព័ន្ធបក្សទីក្រុង ថាជាអង្គការដឹកនាំបក្សតែមួយដែលស្អិតរមួតជាមួយគ្នាតទៅទៀតហើយ ។

សភាពការណ៍នៅតំបន់ជនបទដូចបាននិយាយនេះ ត្រូវបានឆ្លុះបញ្ចាំងឱ្យឃើញដោយព្រឹត្តិការណ៍ដែលបានកើតមាននៅខេត្តកំពង់ចាម ។ គណៈកម្មាធិការបក្សខេត្តនៅទីនោះ បានបញ្ឈប់សកម្មភាពជាមូលដ្ឋាននៅចុងឆ្នាំ ១៩៥៥ និងបាន

*រលំដួលក្នុងឆ្នាំ ១៩៥៧-៥៨ នៅពេលដែលលេខាគណៈកម្មាធិការបក្សខេត្ត បានចុះចូលជាមួយរដ្ឋាភិបាល ។ មេបញ្ជាការយោធាដើមចាស់នៃភូមិភាគបូព៌ា សោ ភឹម បានវិលត្រឡប់មកកម្ពុជាវិញនៅក្នុងឆ្នាំ១៩៥៦ តែសឹងតែក្រោយពេលមកដល់ភ្លាមៗត្រូវបានមកលាក់ខ្លួននៅភ្នំពេញ ដោយសារការបង្ក្រាបប្រឆាំងកុម្មុយនីសនៅកន្លែងធ្លាប់រស់នៅចាស់របស់គាត់ ដែលក្នុងនោះរួមមានការកាប់សម្លាប់មេបញ្ជាការដឹកនាំមុនសន្និសិទទីក្រុងហ្សឺណែវពីដំបូងទី របស់គាត់ផង ។ នៅក្នុងទីក្រុង រូបគាត់ត្រូវបានអង្គការបក្សក្រុងទទួលឱ្យចូល ហើយបានក្លាយទៅជាមនុស្សជិតស្និទ្ធជាមួយ សាឡុត ស ។ ទោះបីជាកម្មាភិបាលដទៃទៀតមួយចំនួននៅតែរក្សាការបន្តធ្វើសកម្មភាពបក្សនៅបូព៌ាក៏ដោយ ក៏នៅសល់តែសាខាបក្សជនបទចំនួន ២ ប៉ុណ្ណោះ ដែលនៅតែអាចប្រតិបត្តិការដោយពេញលេញបាន នោះគឺ នៅភូមិភាគនិរតី ក្នុងនេះមានមួយនៅខេត្តតាកែវ ដែលមាន តាម៉ុក ជាអ្នកទទួលខុសត្រូវ ។*

*នៅភ្នំពេញ នួន ជា និង សាឡុត ស បានបន្តធ្វើការដោយផ្ទាល់ជាមួយ ទូ សាមុត ហើយចាប់ពីពេលនោះមក អ្នកទាំង ២ នេះ មានចំណងជិតស្និទ្ធជាមួយគ្នាទៅវិញទៅមក រស់នៅ និងបំពេញភារកិច្ចតាមការចាត់តាំងបក្សជាមួយគ្នា និងហាក់ដូចជាតែងតែមានការឯកភាពគ្នារហូតនៅពេលពិភាក្សាក្នុងបក្ស ដែលបានក្លាយជាមនុស្សទុកចិត្តគ្នាទៅវិញទៅមកទាំងស្រុង ។ នួន ជា ទទួលបន្ទុកទាក់ទងជាមួយតំបន់ជនបទទាំងមូលជំនួស ស៊ីវ ហេង លើកលែងតែភូមិភាគបូព៌ាចេញ ដោយប្រើរូបភាពជាអ្នករកស៊ីមិនពាក់ព័ន្ធនឹងនយោបាយ ជាអ្នករកស៊ីពនេចរដើម្បីធ្វើជារបាំង ។ ជាសម្ងាត់ គាត់ជាកម្មាភិបាលដឹកនាំដើម្បីរៀបចំក្នុងចំណោមវណ្ណៈពលករកម្ពុជាដ៏ក្មេងខ្ចី ក្នុងពេលដែល ប៉ុល ពត ទទួលខុសត្រូវរួមចំពោះភ្នំពេញ និងបូព៌ា ។ បន្ទាប់ពី អៀង សារី ត្រឡប់មកពីប្រទេសបារាំងវិញក្នុងឆ្នាំ ១៩៥៧ រូបគេបានក្លាយជាសមាជិកគណៈកម្មាធិការបក្សភ្នំពេញ ក្រោមអំណាចរបស់ សាឡុត ស ទទួលបន្ទុកធ្វើការងារក្នុងចំណោមនិស្សិតនិងបញ្ញាជន ដោយមាន សុន សេន ដែលជាសមាជិកម្នាក់ទៀតនៃក្រុមម៉ាក្ស-ឡេនីន ជាជំនួយការ ដែលបានត្រឡប់មកប្រទេសវិញដែរ ដោយសកម្មភាពជ្រើសរើសបានផ្តោតទៅលើគ្រូបង្រៀន និងព្រះសង្ឃពុទ្ធសាសនា ។ រួមជាមួយ សាឡុត ស ពួកគេនិងជនកុម្មុយនីសដទៃទៀត ដែលបានទៅរៀននៅប្រទេសបារាំង ឬនៅកម្ពុជា បានកំណត់ពួកគេថាមានគុណសម្បត្តិធ្វើជាគ្រូបង្រៀននៅសាលាមធ្យមសិក្សាឯកជនបាន ដែលនៅទីនោះពួកគេបានបន្តប្រើធ្វើជារបាំង សំរាប់ធ្វើការងារអូសទាញមនុស្សរបស់បក្ស ។ សុន សេន ក៏បានធ្វើដូចគ្នានេះដែរ ក្រោយពីបានក្លាយជាគ្រូបង្រៀននៅវិជ្ជាស្ថានពុទ្ធសាសនបណ្ឌិតនៃរដ្ឋាភិបាល និងបន្ទាប់បានក្លាយជាចាងហ្វាងរងនៃវិជ្ជាស្ថានជាតិគរុកោសល្យរបស់រដ្ឋាភិបាល ។ ទន្ទឹមនេះ សោ ភឹម ត្រូវបានចាត់តាំងឱ្យស្ថាបនាបណ្តាញខ្សែបក្សឡើងវិញនៅភូមិភាគបូព៌ា និងឱ្យជំនួស ស៊ីវ ហេង ជាមនុស្សគន្លឹះរបស់បក្សខាងកិច្ចការយោធា ។*

*បន្ទាប់ពី ស៊ីវ ហេង ខកខានមិនបានធ្វើតាមការស្នើរបស់សមាជិកដទៃទៀត ដើម្បីជួបប្រជុំគ្នានៅក្នុងឆ្នាំ ១៩៥៧ ដើម្បីពិនិត្យឡើងវិញអំពីសកម្មភាពរបស់អង្គការ និងពិចារណាថាតើត្រូវដោះស្រាយយ៉ាងដូចម្តេចនោះ គណៈកម្មាធិការមួយដឹកនាំដោយ ទូ សាមុត, នួន ជា និង សាឡុត ស ត្រូវបានបង្កើតឡើង ដើម្បីរៀបចំឯកសារសំរាប់កោះប្រជុំសមាជបក្សមួយ ដោយពុំមាន ស៊ីវ ហេង ។ គណៈកម្មាធិការនេះបានសិក្សាអំពីប្រវត្តិនៃចលនាកុម្មុយនីសកម្ពុជា និងពិសោធនៃចលនាបដិវត្តន៍នានានៅទីកន្លែងដទៃទៀតនៃពិភពលោក ។ ចាប់ពីដំបូងទីមក សាឡុត ស បានដើរតួនាទីជាគន្លឹះក្នុងការងារនេះ ហើយពេញមួយរយៈពេល ៣ ឆ្នាំបន្ទាប់មក គាត់បានផ្តោតការយកចិត្តទុកដាក់ទៅលើកិច្ចការស្រាវជ្រាវ ដើម្បីកំណត់មាគ៌ាយុទ្ធសាស្ត្រនិងយុទ្ធវិធីសំរាប់បដិវត្តន៍កម្ពុជា និងធ្វើសេចក្តីព្រាងលក្ខន្តិកៈបក្សកុម្មុយនីសថ្មីនិងសមស្របមួយ ដើម្បីដាក់ជំនួសលក្ខន្តិកៈបក្សកុម្មុយនីសទី ១ នៃ បបបខ ។ នួន ជា បានផ្តល់មតិលើអ្វីៗទាំងអស់ មុនពួកគេសំរេចយកអត្ថបទចុងក្រោយរបស់វាហើយរូបគេបានបង្កើនការក្តោបក្តាប់ការទទួលខុសត្រូវលើបញ្ហានៃការចាត់តាំងរបស់បក្ស ជាទូទៅ ។*

*ការងារធ្វើសេចក្ដីព្រាងលក្ខន្តិកៈនេះ សាឡុត ស បានចាប់ផ្ដើមនៅពេលទីប្រឹក្សាសម្ងាត់វៀតណាមបានបាត់ស្រមោលចេញពីឆាកបង្កប់ខ្លួននៅក្នុងទីក្រុងភ្នំពេញ ដោយទុកតែកម្មាភិបាលសំរាប់ទំនាក់ទំនងនៅនឹងកន្លែងប៉ុណ្ណោះ ។ នួន ជា និង សាឡុត ស "បានខិតខំយ៉ាងខ្លាំងដើម្បីធ្វើនូវអ្វីៗសព្វបែបយ៉ាងទាំងអស់...ដោយមិនចាំបាច់សួរ [ពួកវៀតណាម] ដូចកាលពីមុនទៀតឡើយ"។ បពវ បានរក្សាទុករចនាសម្ព័ន្ធសំខាន់មួយ នៅក្នុងទីក្រុងភ្នំពេញសំរាប់ធ្វើជាកន្លែងប្រជុំដោយសុវត្ថិភាព និង សម្ងាត់ របស់កម្មាភិបាលថ្នាក់ខ្ពស់នៃភាគខាងត្បូងវៀតណាម និងផ្តល់ជាកស្តុភារដែលកងឈ្លបភាគខាងត្បូងត្រូវការទាំងអស់ ប៉ុន្តែពួកវៀតណាមកាន់តែបានក្លាយជាអកម្មចំពោះព្រឹត្តិការណ៍នានាដែលកើតមាននៅកម្ពុជា ។ ការទ្វេសប្រហែសនេះ មានន័យថា ផែនការឆ្នាំ ១៩៥១ របស់ បពវ ដើម្បីបង្កើតបក្សកុម្មុយនីសតែមួយសំរាប់ឥណ្ឌូចិនទាំងមូលនោះ បានដេកលក់ទៅវិញ ដោយ បពវ ផ្តោតការយកចិត្តទុកដាក់ជាចំបងតែទៅលើប្រទេសវៀតណាម ។ ដូច្នេះ ខ្មែរត្រូវបានទុកឱ្យមានសេរីភាពដោយប្រៀបធៀប ដើម្បីសំរេចថាតើត្រូវបន្តធ្វើបដិវត្តន៍នៅកម្ពុជាយ៉ាងដូចម្តេចនោះ ។*

*ក៏ប៉ុន្តែ ពួកគេជាច្រើន ក្នុងនេះរួមមាន ទូ សាមុត, នួន ជា និង សឡុត ស ផង នៅតែបន្តទន្ទឹងរង់ចាំមើលអំពីលទ្ធភាពនៃអន្តរាគមន៍របស់វៀតណាមមកលើកម្ពុជា នៅពេលណាដែលវៀតណាមមានលទ្ធភាពអាចធ្វើបាន ហើយទ្រឹស្តីរបស់វៀតណាមនៅតែបន្តស្ថិតនៅជាស្នូលនៃការគិតគូរបស់ពួកកុម្មុយនីសខ្មែរជានិច្ច ទោះបីជាពួកគេបានចូលជាបក្សជននៃអង្គការបក្សបោះប្រចាំចាក់ស្រេះគ្នានៅក្នុងទីក្រុងភ្នំពេញ ឬដោយផ្ទាល់ តាមរយៈទីកន្លែងរបស់វានៅវៀតណាម ដូចជាករណី ទូ សាមុត, នួន ជា, សោ ភឹម, អៀង សារី និង សុន សេន ដោយមានជំនួយពីការបកប្រែអត្ថបទជាភាសាវៀតណាមដោយ កែវ មាស និង ពួកអ្នកដទៃទៀត ឬតាមរយៈនៃការបោះពុម្ពផ្សាយរបស់វៀតណាមជាភាសាបារាំង ដូចជាករណី សាឡុត ស ក៏ដោយ ។ ពួកគេនៅតែមានលទ្ធភាពនឹងតាមទាន់ជាទៀងទាត់ ជាមួយអ្វីដែលពួកវៀតណាមបាននិយាយជានិច្ច ។*

## *ជំពូក ៣*

## *ហឹង្សានៅវៀតណាម, នយោបាយនៅកម្ពុជា*

### *កុប្បកម្មរបស់ បពវ នៅភាគខាងត្បូង*

*ជនខ្មែរបានទទួលឥទ្ធិពលទាំងដោយការបំពាក់បំប៉នខាងទ្រឹស្តីរបស់ បកឥ មុនសន្និសិទទីក្រុងហ្សឺណែវ និង ដោយមាគ៌ានយោបាយរបស់វៀតណាម ដូចដែលត្រូវបានរៀបចំឡើងពេញមួយរយៈកាលនៃចុងទសវត្ស ១៩៥០ នៅពេលដែល បពវ បានពិចារណាថាតើត្រូវបន្តធ្វើបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យប្រជាជននៅភាគខាងត្បូង ចំពោះមុខនៃការកើនឡើងនៃការបង្ក្រាបពួកនៅសេសសល់នៃចលនាកុម្មុយនីសដែលបានឡើងដល់កម្រិតខ្ពស់បំផុតនៅក្នុងឆ្នាំ ១៩៥៩ នៅទីនោះយ៉ាងដូចម្តេចៗ មាគ៌ារបស់ បពវ បានធ្វើឡើងជាជំហានៗ ឆ្ពោះទៅការប្រើហឹង្សា ដែលត្រូវបានជំរុញដោយ ឡេ យន់ ដែលបានទៅភាគខាងជើងនៅដើមឆ្នាំ១៩៥៧ ដើម្បីទទួលដំណែងជាអគ្គលេខាបណ្តោះអាសន្ននៃ បពវ។*

*ជាផ្លូវការ នយោបាយសំរាប់ភាគខាងត្បូង គឺកំរិតសកម្មភាពបដិវត្តន៍ត្រឹមតែធ្វើឱ្យមានការរំដើបរំជួលខាងនយោបាយប៉ុណ្ណោះ ទោះបីជានៅក្នុងខែសីហា ឆ្នាំ ១៩៥៦ បក្សនៅទីនោះអនុញ្ញាតឱ្យប្រើអាវុធសំរាប់ស្វ័យការពារ ដើម្បីការពារកម្មាភិបាល និងអ្នកដទៃទៀតពីការកាប់សម្លាប់ក៏ដោយ ។ ពួកកុម្មុយនីសនៅនីងកន្ទេងខ្លះបានលើកឡើងអំពីសញ្ញាណថា រដ្ឋាភិបាលមិនមែនកុម្មុយនីសត្រូវតែផ្តួលរំលំជាបន្ទាន់ដោយមធ្យោបាយយោធាក៏ដោយ ក៏ការនេះត្រូវបានបដិសេធ ។ ប៉ុន្តែ ឡេ យន់ បានធ្វើការវាយតម្លៃសភាពការណ៍ឡើងវិញនៅពេលភ្លាមៗបន្ទាប់មក ហើយលទ្ធផលគឺជាការពិនិត្យឡើងវិញអំពីនយោបាយមួយហៅថា: "ផ្លូវដើរសំរាប់បដិវត្តន៍នៅភាគខាងត្បូង" ដែលត្រូវបានបញ្ចប់នៅចុងឆ្នាំ១៩៥៦ ភ្លាមៗមុន ឡេ យន់ មកភ្នំពេញ ដើម្បីរៀបចំសន្និសិទមួយរបស់"អង្គការដឹកនាំ"នៃពួកកុម្មុយនីសភាគខាងត្បូងនៅទីនោះ ។*

*ការពិនិត្យឡើងវិញ បានកំណត់ថាភាគខាងត្បូងវៀតណាមជាអាណានិគមថ្មីរបស់សហរដ្ឋអាមេរិក ហើយមុខសញ្ញានៃបដិវត្តន៍នៅភាគខាងត្បូង គឺចក្រពត្តិនិយមអាមេរិក និងសក្តិភូមិនិយមវៀតណាម ។ វាបានអះអាងថា ចំពោះមុខ បដិវត្តន៍អាចរស់បានល្អឹកណាតែពឹងផ្អែកជាចំបងលើកម្លាំងនយោបាយរបស់ប្រជាជន ក៏ប៉ុន្តែជាទិសអនាគតត្រូវតែប្រើកម្លាំងដើម្បីផ្តួលរំលំពួក មី-យៀម (My-Diem) ។ វាបានរៀបចំនូវឡូហ្សិកសំរាប់លប់ចោលការហាមឃាត់ការប្រើកម្លាំងដែលមានស្រាប់ថែមទៀត ទោះបីជាវានៅមានកំរិតនៅឡើយក៏ដោយ ហើយនឹងការប្រើកម្លាំងកាន់តែខ្លាំងថែមទៀតនៅពេលដែលសភាពការណ៍ទុំហើយ ។*

*ឯកសារនេះត្រូវបានលើកយកមកពិភាក្សានៅក្នុងសន្និសិទបក្សភាគខាងត្បូងនាខែធ្នូ ឆ្នាំ ១៩៥៦ នៅភ្នំពេញ ដែលបានសំរេចថា "ផ្លូវដើរទៅមុខនៃបដិវត្តន៍ភាគខាងត្បូង គឺការប្រើកុប្បកម្មទូទៅដោយហឹង្សាមួយ ដើម្បីយកឈ្នះខាងនយោបាយ" ឆ្ពោះទៅការបញ្ចប់ដោយថាហេតុ ដែលបច្ចុប្បន្ន"ចាំបាច់ត្រូវមានកម្លាំងស្វ័យការពារ និងកម្លាំងប្រដាប់អាវុធសំរាប់ធ្វើការឃោសនាខាងនយោបាយ ដើម្បីគាំទ្រដល់ការតស៊ូនយោបាយ" ។ ទោះបីជានយោបាយសព្វមុខរបស់បក្សភាគខាងត្បូង នៅតែត្រូវជៀសវាងការប្រឈមមុខដោយអាវុធដើម្បីការពារកម្លាំងរបស់ខ្លួនក៏ដោយ ក៏នៅក្នុងឆ្នាំ ១៩៥៧ វាបានយល់ព្រមឱ្យមានការប្តូរទិសថែមទៀត នោះគឺការបង្កើតឡើងនូវកម្លាំងស្វ័យការពារនៅតាមភូមិ និងអង្គភាពឃោសនាប្រដាប់អាវុធដើម្បីសម្លាប់ពួក "ផ្តាច់ការ" នៅតាមមូលដ្ឋាន ដូចជាមេភូមិ នគរបាល និងកងសន្តិសុខ ដែលជាមុខព្រួញនៃការតម្លើងថ្នាក់ និងការគ្មានការត្រាប្រណី នៃយុទ្ធនាការប្រឆាំងកុម្មុយនីសរបស់ យៀម ដោយវាយទៅលើរចនាសម្ព័ន្ធកុម្មុយនីស និង ពួកអ្នកដែលគេចោទថាជាអ្នកមានសមានចិត្តចំពោះពួកកុម្មុយនីស ក្នុងចំណោមកសិករ ដោយពួកគេជាច្រើននាក់ត្រូវបានចាប់ខ្លួនឬសម្លាប់ ។*

ក្នុងឆមាសទី ១ ឆ្នាំ ១៩៥៨ ជាថ្មីម្តងទៀត ពួកកុម្មុយនីសភាគខាងត្បូងបានពង្រីកការកាប់សម្លាប់ដោយអត្តនោម័ត ដោយគិតថាអំពើទាំងនេះអាចទទួលយកបានដោយសារថាពួកគេបានរួមផ្សំការតស៊ូនយោបាយក្នុងចំណោមមហាជន និងជួយការពារពួកកសិករដែលគាំទ្រពួកគេពីគ្រោះថ្នាក់ ។ ពួកគេបានធ្វើហួសពីមាគ៌ារបស់គណៈកម្មាធិការមជ្ឈឹមដែលមានស្រាប់ ដោយធ្វើការវាយប្រហារដោយអាវុធទៅលើប៉ុស្តិ៍ការពារជួរមុខរបស់រដ្ឋាភិបាលដែលនៅដាច់ពីគេ តែនៅតែរក្សាការការពារខ្លួនខាងយោធាដដែល និងជាញឹកញាប់ ទោះបីជាមានការកើនឡើងនៃភាពឃោរឃៅដោយមិនរើសមុខរបស់រដ្ឋាភិបាលផង ។ នៅក្នុងពេលជាមួយគ្នានេះ ការតស៊ូនយោបាយរបស់បក្ស បានប្រមូលផ្តុំតែទៅលើការទាមទារឱ្យមានសុខុមាលភាពសង្គម និងប្រជាធិបតេយ្យប៉ុណ្ណោះ ។ ក្នុងការអនុវត្ត វាមានរួមបញ្ចូលការប្រឆាំងចំពោះការរំលោភដោយអាជ្ញាធរមូលដ្ឋាននៅជនបទ និងជំរុញឱ្យមានការរំដើបរំជួលក្នុងចំណោមកម្មករទីក្រុងផង តែនៅក្នុងឆ្នាំ ១៩៥៨ ភាគច្រើន ត្រូវបានបង្ក្រាប ។

ការបង្ក្រាបនេះបានបង្ខំឱ្យកម្មាភិបាលបក្សជាច្រើននាក់ដកខ្លួនចេញពីទីក្រុងទៅកាន់ជនបទ ជាពិសេសទៅតំបន់ភ្នំនៅតាយនិញនៃវៀតណាមកណ្តាល ដែលនៅទីនោះ កម្មាភិបាល បពវ ខ្លះធ្លាប់បានទៅលាក់ខ្លួននៅក្នុងឆ្នាំ ១៩៥៥-១៩៥៦ រួចមកហើយ ដោយឆ្លើយតបទៅនឹងសេចក្តីអំពាវនាវរបស់ ឡេ យន់ ដើម្បីពង្រឹងមូលដ្ឋាន បពវ នៅទីនោះ ជាផ្នែកមួយនៃការត្រៀមរៀបចំធ្វើការតស៊ូដោយអាវុធយូរអង្វែង ។ បក្សបានបង្កើនធ្វើការងារជាមួយជនជាតិភាគតិចតំបន់ខ្ពង់រាប ក្នុងឆ្នាំ១៩៥៧-៥៨ ដោយទទួលបានជោគជ័យយ៉ាងធំ និងបានប្រែក្លាយតំបន់នេះទៅជាជម្រកដ៏គួរឱ្យទុកចិត្តបានសំរាប់ពួកអ្នកនៅវាលរាបដែលទទួលរងការគំរាមកំហែង ។ បពវ បានរៀបចំក្នុងចំណោមប្រជាជនរងគ្រោះពីការរំលោភដោយរដ្ឋាភិបាលព្រៃនគរ ដែលកំហឹងរបស់ពួកគេធ្វើឱ្យពួកគេត្រេកត្រអាលចំពោះការឆ្លើយតបដោយអំពើហឹង្សាទៅវិញ ដែលកម្មាភិបាល បពវ មើលឃើញការនេះថាជារូបភាពត្រឹមត្រូវមួយនៃ "ការតស៊ូនយោបាយរួមផ្សំយោធា" ។

នៅពេលថ្នាក់ដឹកនាំភាគខាងត្បូងជួបប្រជុំគ្នាម្តងទៀតក្នុងឆ្នាំ ១៩៥៨ ការបង្ក្រាបប្រឆាំងកុម្មុយនីស មានសភាពខ្លាំងលើសពេលណាណាទាំងអស់ ។ ថ្នាក់ដឹកនាំជាន់ខ្ពស់ជាច្រើននាក់ បានជំរុញថាការ "ប្រើហឹង្សានយោបាយប្រជាជន" បន្ថែមទៀត គឺជាការឆ្លើយតបតែមួយគត់ និងថាចាំបាច់ត្រូវតែធ្វើការត្រៀមរៀបចំសំរាប់កុប្បកម្មដោយអាវុធមួយ ។ ទោះបីជាសន្និបាតបានបដិសេធសញ្ញាណនៃការបះបោរជាទូទៅក៏ដោយ ក៏វាបានសំរេចថាបក្សត្រូវតែអនុញ្ញាតឱ្យមានភាពបត់បែនកាន់តែធំថែមទៀត ក្នុងការរួមផ្សំសកម្មភាពយោធាជាមួយនយោបាយ ។ ប៉ុន្តែ នៅដើមឆ្នាំ ១៩៥៩ ពួកកុម្មុយនីសភាគខាងត្បូងជាច្រើននាក់ បានគូសបញ្ជាក់ថា ការបន្តរិតត្បិតការតស៊ូដោយអាវុធ នៅតែមិនអាចជំរុញការតស៊ូនយោបាយបានទេ ដោយឱ្យហេតុផលថា លុះត្រាណាតែមានការអនុញ្ញាតឱ្យមានកាន់តែទូលាយនូវអំពើហឹង្សាប៉ុណ្ណោះទេ ទើបចលនាកុម្មុយនីស និងពួកអ្នកគាំទ្រពួកគេ ក្នុងចំណោមកសិករ អាចរស់រានបាន ។

ក្នុងខែមករា ឆ្នាំ ១៩៥៩ គណៈកម្មាធិការមជ្ឈឹម បពវ បានឆ្លើយតបទៅនឹងការគៀបសង្កត់ ដែលផុសចេញមកយ៉ាងទូលំទូលាយ និងកាន់តែខ្លាំងឡើងៗ ថាឱ្យជំរុញឆ្ពោះទៅធ្វើការតស៊ូដោយអាវុធនោះ បានអនុម័តសេចក្តីសំរេចលេខ ១៥ យ៉ាងសម្ងាត់បំផុតមួយ ដែលត្រូវបានប្រថាប់ត្រាដោយការិយាល័យនយោបាយនៅក្នុងខែឧសភា ។ សេចក្តីសំរេចនោះនិយាយអំពីលទ្ធភាពនៃការផ្តួលរំលំរដ្ឋាភិបាល ង៉ោ ឌិនយៀម ដោយការប្រើការសម្របសម្រួលគ្នានៃកម្លាំងមហាជន និងកម្លាំងប្រដាប់អាវុធកុម្មុយនីស និងបានទស្សន៍ទាយអំពីការដាក់ជំនួស មី-យៀម ដោយរបបបដិវត្តន៍មួយ ។ ហឹង្សាលែងត្រូវប្រើគ្រាន់តែដើម្បីការពារបក្ស និងមូលដ្ឋានរបស់បក្សតទៅទៀតហើយ តែជាការវាយសម្រុកដើម្បីបំបែក និងកំទេចរដ្ឋបាលខ្លាំងនាថ្នាក់មូលដ្ឋានដ៏ច្រើនលើសលប់នៅជនបទ ដែលនឹងបង្កើតបរិស្ថានមួយនាំទៅឱ្យមានលទ្ធភាពនៃការបះបោរប្រដាប់អាវុធទូទៅមួយ នា ពេលអនាគតបាន ។ សេចក្តីសំរេចបានប្រកាសថា ដើម្បីវាយបកទៅនឹងការបង្ក្រាបប្រឆាំងកុម្មុយនីស របស់របបអាណានិគម និយមថ្មីនិងពាក់កណ្តាលសក្តិភូមិ ថាជារបបប្រតិកិរិយា និងសាហាវឃោរឃៅ ជនកុម្មុយនីសភាគខាងត្បូងវៀតណាមមិនអាចងាករេ

*ពីក្រឹត្យក្រមបដិវត្តន៍នៃការប្រើហឹង្សាបដិវត្តន៍ ដើម្បីដណ្ដើមអំណាច ទោះបីជានៅមិនទាន់យកវាមកប្រើជាទិសដៅចំពោះមុខក៏ដោយ ។*

*នៅពេលសេចក្ដីសំរេចត្រូវបានប្រថាប់ត្រាដោយការិយាល័យនយោបាយ ពួកកុម្មុយនីសនៅមូលដ្ឋានភាគខាងត្បូងបានធ្វើសកម្មភាពយោធាដ៏ទូលំទូលាយជាស្រេចទៅហើយ ហើយទូលំទូលាយជាងអ្វីដែលបានអនុញ្ញាតដោយហាណូយ ឬដោយថ្នាក់ដឹកនាំ បពវ ភាគខាងត្បូងទៅទៀត ដោយបានចាត់តាំងអង្គភាពឈ្លបដ៏ច្រើនសន្ធឹកសន្ធាប់ ដើម្បីវាយទៅលើប៉ុស្តិ៍ជួរមុខរបស់រដ្ឋាភិបាលកាន់តែច្រើន ។ ង្វៀង វ៉ាន់លិញ ដែលត្រូវបានដាក់ឱ្យជំនួស ឡេ យន់ ជាកម្មាភិបាលជាន់ខ្ពស់នៃភាគខាងត្បូង បានជំទាស់នឹងពួកដែលដើរហួសមាគ៌ា ថាការតស៊ូដោយនយោបាយទូលំទូលាយមួយត្រូវតែជាអាទិភាពខ្ពស់បំផុតរបស់ពួកគេ ពួកគេត្រូវប្រើតែកម្លាំងឃោសនាប្រដាប់អាវុធប៉ុណ្ណោះ ហើយវាមានតួនាទីត្រឹមតែគាំទ្រដើម្បីជួយក្នុងការចលនាពួកកសិករតែប៉ុណ្ណោះ។*

*ប៉ុន្តែ នៅខែមករា ឆ្នាំ ១៩៦០ ថ្នាក់ដឹកនាំភាគខាងត្បូងបានចេញបញ្ជាឱ្យលើកកំពស់អាទិភាពយុទ្ធសាស្ត្រដល់សកម្មភាពយោធា ដោយសុខចិត្តទទួលស្គាល់ថា ការតស៊ូនយោបាយដោយសម្របសម្រួលជាមួយការឃោសនាប្រដាប់អាវុធ លែងគ្រប់គ្រាន់ទៀតហើយដើម្បីការពារមូលដ្ឋានបដិវត្តន៍នោះ និងថាមហាជននឹងផ្ដល់យុត្តិកម្មដល់ការធ្វើការតស៊ូដោយអាវុធដើម្បីទប់ទល់នឹងសកម្មភាពហឹង្សា និងឃោរឃៅព្រៃផ្សៃរបស់ខ្មាំង ។ ពាក្យស្លោករបស់បក្សគឺៈ "ការតស៊ូនយោបាយនិងការតស៊ូដោយអាវុធត្រូវធ្វើស្របគ្នា ទាំងពីរនេះត្រូវដើរតួជាគន្លឹះ និងជាកំណត់ នៅក្នុងចលនា"។ និយាយម្យ៉ាងទៀតគឺ អាវុធយោធា និងអាវុធនយោបាយ របស់បដិវត្តន៍ ត្រូវទទួលបានតម្លៃស្មើគ្នា ។*

*ជាមួយយុត្តិកម្មទ្រឹស្ដីនេះ ពួកកុម្មុយនីសភាគខាងត្បូងបានដឹកនាំធ្វើរូបភាពបីនៃហឹង្សា នៅក្នុងឆ្នាំ ១៩៦០ ។ ទី ១ ពួកគេបានធ្វើយុទ្ធនាការបំភិតបំភ័យជាខ្សែសង្វាក់មួយ ប្រឆាំងមន្ត្រីរដ្ឋាភិបាលនៅមូលដ្ឋាន ហៅថា "ការកំទេចការបង្រ្កាប" ។ ទី ២ ពួកគេបានធ្វើកុប្បកម្មដោយព្រមៗគ្នាដោយកសិករប្រឆាំងរដ្ឋាភិបាលមូលដ្ឋាន ពីថ្នាក់ភូមិរហូតដល់ថ្នាក់ស្រុក ។ ទី ៣ ពួកគេបញ្ជូនកងឈ្លបឱ្យទៅវាយប្រហារពួកសេនាជន ប៉ូលីស និងយោធា របស់រដ្ឋាភិបាលនៅតាមប៉ុស្តិ៍ជួរមុខទាំងឡាយ ឱ្យបានច្រើនកន្លែងដែលអាចធ្វើទៅបាន ។ សមាជ បពវ មួយ បានកោះប្រជុំនៅដើមខែកញ្ញា ឆ្នាំ ១៩៦០ នៅហាណូយ ដើម្បីប្រថាប់ត្រាឱ្យសកម្មភាពទាំងនេះ ហើយបន្ទាប់មកពួកភាគខាងត្បូងបានរៀបចំធ្វើកុប្បកម្មជាបន្តបន្ទាប់នៅតាមខេត្តជាច្រើន និងបានបង្កើតរដ្ឋបាលបដិវត្តន៍ថ្នាក់ភូមិនៅតាមតំបន់ជាច្រើន។*

*ដូច្នេះ ពីស្ថានភាពដែលស្ទើររលំរលាយទាំងស្រុងនៅឆ្នាំ ១៩៥៩ កម្មាភិបាលកុម្មុយនីសភាគខាងត្បូងមួយចំនួនតូចនៅតែសកម្មនៅឡើយទោះបីជាទទួលរងការបង្រ្កាបរបស់ យៀម ក៏ដោយ បានប្រដាប់ដោយអាវុធកំប៉ឹកកំប៉ុកចាស់ៗ-ខិតខំចលនាប្រជាជនជនបទយ៉ាងខ្លាំង ដើម្បីបំភិតបំភ័យ និងធ្វើឱ្យគាំងស្ថាប័នជនបទ របស់រដ្ឋាភិបាលនៅតាមខេត្តវាលរាបមួយចំនួន ។ យុទ្ធវិធីភេរវកម្មកុម្មុយនីសនេះ ច្បាស់ណាស់ បានជួយធ្វើឱ្យមានការផ្លាស់ប្ដូរតុល្យភាពនៃការភិតភ័យនៅតាមតំបន់ជនបទ ធ្វើឱ្យកសិករមានការភ័យខ្លាចពួកកុម្មុយនីសជាងពួករដ្ឋាភិបាល តែការបះបោរដឹកនាំដោយពួកកុម្មុយនីស ក៏ទទួលបានជោគជ័យផងដែរពីព្រោះមានកសិករជាច្រើនមានឱកាសបញ្ចេញនូវការឈឺចាប់ ដែលពួកមន្ត្រីមូលដ្ឋានបានប្រព្រឹត្តលើពួកគេ។ កំហឹងក្រេវក្រោធដ៏រីករាលដាលរបស់ប្រជាជនទៅលើរដ្ឋាភិបាល ធ្វើឱ្យពួកកុម្មុយនីសអាចសម្របច្បាប់ដល់រដ្ឋអំណាច ដែលពួកគេបានរៀបចំឡើង នៅពេលអាជ្ញាធររដ្ឋាភិបាលរលំដួលទៅនោះ ។*

*នៅក្នុងឆ្នាំ ១៩៦០ នៅពេលដែលការប្រកួតប្រជែងសំខាន់ត្រូវបានកើតឡើងនៅវាលរាប ពួកអ្នកភ្នំតាយង្វៀង ក៏បានដើរតួនាទីសំខាន់មួយ ក្នុងការផ្លាស់ប្ដូរដោយជោគជ័យពីការតស៊ូនយោបាយទៅជាសង្រ្គាមស៊ីវិល ។ ទស្សនៈរបស់ បពវ គឺថា*

*ពួកតាយឿង គឺជាមូលដ្ឋានដ៏សំខាន់ស្ទាប់រស់មួយ ដែលបានជួយសង្គ្រោះបក្សក្នុងដំណាក់កាលនៃភាពខ្មៅងងឹតនៃការតស៊ូបដិវត្តន៍នាចុងទសវត្ស ១៩៥០ ។ បក្សបានលើកសរសើរអំពីធាតុពិតបរិសុទ្ធនិងស្មោះត្រង់នៃពួកអ្នកភ្នំជនជាតិភាគតិចនៃយុគសម័យដើមដែលរស់នៅទីនោះ ការស្មោះត្រង់ដ៏អស្ចារ្យរបស់ពួកគេចំពោះបដិវត្តន៍ និងការទទួលពួកកម្មាភិបាលមកពីវាលរាបដោយរាក់ទាក់ ដែលពួកនេះបានពិព័ណនាថាជាពួកមនុស្សស្មោះត្រង់ ដែលធ្លាប់បានឆ្លងកាត់ឧបសគ្គគ្រប់បែបយ៉ាងរបស់ពួកគេ ។ កម្មាភិបាលវៀតណាមទាំងនេះ គិតថាបដិវត្តន៍នៅភាគខាងត្បូងមិនមានលទ្ធភាពអាចរស់រានមានជីវិតបាន និងចាប់ផ្តើមធ្វើការតស៊ូដោយអាវុធឡើងវិញបានទេ ដោយពុំមានជំនួយរបស់ពួកអប្បភាគជនទាំងនេះទេនោះ ដែលពួកកម្មាភិបាល បានរស់នៅជាមួយ មុនចុះពីលើភ្នំមកវាលរាប និងទៅតំបន់បង្កបង្កើនស្រូវជាគន្លឹះ ដើម្បីចាប់ផ្តើមធ្វើការតស៊ូឡើងវិញនោះ ។*

***ការបន្តការតស៊ូនយោបាយនៅកម្ពុជា: ឆ្នាំ ១៩៥៨-១៩៦០***

*ពេលដែលដំណើរនៃការតស៊ូនៅភាគខាងត្បូងវៀតណាមកាន់តែហឹង្សាខ្លាំងឡើងៗនោះ នៅកម្ពុជា ទូ សាមុត, នួន ជា និងសាឡុត ស នៅតែបន្តជ្រើសយកផ្លូវសន្តិវិធីដែលជាកេរ្តិ៍ដំណែលតាំងពីដើមទីពី បពវ មក ដោយនៅរង់ចាំលទ្ធផលនៃការស្រាវជ្រាវរបស់ សាឡុត ស និងការកោះប្រជុំសន្និបាតបក្សមួយនោះ ។ ការស្ថិតនៅជាប់ខាតតែខាងការតស៊ូនយោបាយមានន័យថាពួកគេស្មោះត្រង់ជាមួយហាណូយ ជាងសកម្មជនភាគខាងត្បូងវៀតណាម ។ អង្គការទីក្រុងរបស់ពួកគេ ក៏ត្រូវបានដឹកនាំដោយសមាសភាពគួរឱ្យសង្ស័យក្នុងជួរបក្សកម្ពុជា ដូចជា សោ ភឹម ដែលមាននិន្នាការឆ្ពោះទៅរកផ្លូវដាច់ខាតជាងនេះមួយនោះ។*

*សោ ភឹម ក៏ដូចជាអ្នកផ្សេងទៀតដូចរូបគេដែរ ដែលបានមកភ្នំពេញដើម្បីគេចពីការបង្រ្កាបនៅជនបទនោះ បាននិយាយអំពីសេចក្តីត្រូវការនៃការចាប់ផ្តើមធ្វើការតស៊ូដោយអាវុធឡើងវិញ និងថាតើការតស៊ូតាមសភានិងនយោបាយ នឹងគ្រាន់តែនាំទៅដល់ការអន្តរាយកាន់តែខ្លាំងថែមទៀតប៉ុណ្ណោះ យ៉ាងដូចម្តេច ។ ភឹម បាននិយាយចំពោះពួកដែលខ្លាចជាងគេថា បើសិនជាពួកគេមិនគាស់យកកាំភ្លើង និងគ្រាប់រំសេវមកវិញ ដើម្បីការពារខ្លួន នោះរចនាសម្ព័ន្ធរបស់បក្សនៅជនបទមុខជានឹងត្រូវកំទេចដោយកងទ័ព លន់ ណុល ជាមិនខាន ។ ទោះបីជា ភឹម បានស្នើឱ្យធ្វើតាមទិសដូចដែលពួកកុម្មុយនីសនៅភាគខាងត្បូងវៀតណាមដែរនោះ រូបគេក៏មិនចង់ឱ្យកងទ័ពវៀតណាមត្រឡប់មកកម្ពុជាវិញដែរ ដោយបានពោលសង្កត់ថាជនកម្ពុជាត្រូវតែធ្វើកិច្ចការរបស់ខ្លួនដោយខ្លួនឯង ។*

*ភឹម ដែលជាកម្មាភិបាលថ្នាក់ខ្ពស់ម្នាក់ក្នុងចំណោមកម្មាភិបាលថ្នាក់ខ្ពស់មួយចំនួនតូច បានត្រៀមខ្លួនចេញមុខប្រឆាំងនឹងការវិលត្រឡប់ទៅភ្ជាប់ខ្លួនជាមួយវៀតណាមវិញ ។ អៀង សារី ជាមនុស្សម្នាក់ទៀត ដែលមានជំហរដូចគ្នានេះ ។ ចាប់តាំងពីវិលត្រឡប់មកពីប្រទេសបារាំងវិញ និងបានដឹងអំពីទំហំជាក់លាក់នៃការគ្របដណ្តប់របស់ បពវ មកលើចលនាកុម្មុយនីសខ្មែរនៅមុនសន្និសិទទីក្រុងហ្សឺណែវ អាកប្បកិរិយារបស់ អៀង សារី ចំពោះវៀតណាមបានប្រែក្រឡាស់ទាំងស្រុង ។ ឥឡូវរូបគេគាំទ្រការមិនពេញចិត្តក្នុងចំណោមអតីតសមាជិកក្រុមម៉ាក្ស-ឡេនីន ដែលថាវៀតណាមមិនស្មោះត្រង់ជាមួយពួកអ្នកបដិវត្តន៍កម្ពុជា និងមានផែនការយូរអង្វែងថានឹងមិនប្រគល់វាមកឱ្យពួកគេវិញទេ ។ ជាងនេះទៅទៀត សារី មានការសង្ស័យថាការសន្យារបស់វៀតណាម ថានឹងអន្តរាគមន៍មកលើកម្ពុជាក្រោយពួកគេដណ្តើមបានជ័យជំនះនៅវៀតណាមនោះ បានបង្ហាញពីបំណងរបស់វៀតណាម ដើម្បីរៀបចំឡើងវិញនូវការក្តោបក្តាប់របស់ពួកគេលើបដិវត្តន៍កម្ពុជា ។ ដូច្នេះ ភឹម និង សារី មានការទើសទែងខ្លះចំពោះទស្សនៈទូទៅដែលថា ទោះបីជាបដិវត្តន៍កម្ពុជាឯករាជ្យក៏ដោយ ក៏វៀតណាមជាយុទ្ធមិត្តរបស់វាដែរ ។*

ទស្សនៈវិលវល់ខ្លះរបស់ អៀង សារី គឺពាក់ព័ន្ធទៅនឹងសម្តេចសីហនុ ដែលបានបញ្ចេញឱ្យឃើញថាជាអ្នកសក្តិភូមិម្នាក់ខុសប្លែកពីគេ ។ ក្នុងន័យនេះ ទោះបីជាទស្សនៈរបស់ អៀង សារី ត្រូវបានកំណត់ថាចង់ឯករាជ្យពីវៀតណាមក៏ដោយ ក៏ពួកគេនៅតែធ្វើតាមលំនាំរបស់វៀតណាមដែរ ។

ទោះបីជាសម្តេចសីហនុ ត្រូវបានជាប់ចំណងទៅនឹងជំនួយរបស់សហរដ្ឋអាមេរិក ដើម្បីរក្សា និងពង្រឹងស្ថាប័នរដ្ឋ កងកម្លាំងយោធា និងប៉ូលីស ដែលសម្តេចបានទទួលកេរ្តិ៍ពីបារាំងដើម្បីកំទេចពួកកុម្មុយនីស និងពួកសត្រូវដទៃទៀតរបស់សម្តេចក៏ដោយ ក៏តំណាងរបស់សម្តេចនៅសន្និសិទទីក្រុងហ្សឺណែវបានពាក់ផ្លាកអព្យាក្រិតភាព នៅចំពោះមុខយុទ្ធនាការប្រឆាំងរបបកុម្មុយនីសនៅទូទាំងពិភពលោក របស់សហរដ្ឋអាមេរិកដែរ ។ ក្នុងសន្និសិទអាស៊ី-អាហ្វ្រិក ដែលបានប្រព្រឹត្តទៅបានឌុងក្នុងខែមេសា ឆ្នាំ ១៩៥៥ ជាថ្មីម្តងទៀត សម្តេច សីហនុ បានបង្ហាញឱ្យឃើញអំពីការត្រៀមខ្លួនជាស្រេចដើម្បីរួមរស់ដោយសន្តិសហវិជ្ជមានជាមួយរដ្ឋាភិបាលកុម្មុយនីសនៅទឹកដីទ្វីបអាស៊ី ។ ភ្លាមៗបន្ទាប់ពីជ័យជំនះរបស់សង្គមរាស្ត្រ និយមក្នុងការបោះឆ្នោតនៅឆ្នាំនោះមក សម្តេចបានពិភាក្សាអំពីលទ្ធភាពនៃការបង្កើតការទាក់ទងផ្លូវទូត ជាមួយសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម ។ ក្នុងឆ្នាំ ១៩៥៦ សម្តេចបានទប់ទល់ជាមួយសហរដ្ឋអាមេរិក ដោយបដិសេធមិនចូលរួមអង្គការប្រឆាំងកុម្មុយនីសនៅអាស៊ីអគ្នេយ៍ សេអាតូ ដែលគាំទ្រដោយសហរដ្ឋអាមេរិក ។ នៅឆ្នាំ ១៩៥៦-៥៧ ទោះបីជាអាមេរិកនៅតែបន្ត ផ្តល់ជំនួយផ្នែកសន្តិសុខ និងសេដ្ឋកិច្ចក៏ដោយ ក៏នយោបាយការបរទេសរបស់សម្តេចសីហនុត្រូវបានកត់សំគាល់ឱ្យឃើញដោយការធ្លាក់ចុះនៃការទាក់ទងជាមួយសហរដ្ឋអាមេរិក និងការកើនឡើងនៃការទាក់ទងជាមួយប្រទេសចិន និងសហភាពសូវៀត ។ នៅខែកញ្ញា ឆ្នាំ ១៩៥៧ រដ្ឋសភា បានអនុម័តច្បាប់ស្តីពីអព្យាក្រិតភាព ដែលមិនតម្រូវឱ្យកម្ពុជាចងសម្ព័ន្ធភាពយោធា និងមនោគមវិជ្ជាជាមួយអ្នកណាទាំងអស់ ។ និន្នាការអព្យាក្រិតនេះ ត្រូវបានបន្ថែមល្បឿននៅក្នុងឆ្នាំ ១៩៥៨៖ ប្រទេសកម្ពុជាបានទទួលស្គាល់ប្រទេសចិនរបស់ម៉ៅ (ម៉ៅ សេទុង) និងបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងពាណិជ្ជកម្មមួយជាមួយរដ្ឋាភិបាលទីក្រុងហាណូយ ដែលជាការបើកផ្លូវខាងការទូតមួយយ៉ាងសំខាន់ចំពោះសាធារណរដ្ឋសង្គមនិយមវៀតណាម ។ ទាំងនេះនាំឱ្យយល់ថា សក្តិភូមិនិយមរបស់សម្តេចសីហនុ មានជ្រុងប្រឆាំងចក្រពត្តិនិយមមួយដែលអាចត្រូវបានលើកទឹកចិត្ត និងអភិវឌ្ឍន៍ ។ នយោបាយការទូតរបស់ សសវ ចេះតែបន្តកើនឡើងក្នុងទិសដៅនេះ ។

ទន្ទឹមនេះ អៀង សារី បានជម្រុញ សាឡុត ស និង នួន ជា អំពីគំនិតនៃការធ្វើរណសិរ្សរួបរួមជាតិមួយជាមួយសម្តេចសីហនុប្រឆាំងចក្រពត្តិនិយមអាមេរិក និងធ្វើការងារនេះតាមរយៈបញ្ញាជនចំរើនដែលមានសញ្ញាប័ត្រ ដែលសម្តេចសីហនុអាចទទួលយកបានក្នុងឋានៈជាអ្នកបច្ចេកទេស ឱ្យចូលក្នុងបក្សសង្គមរាស្ត្រនិយម ក្នុងសភា និងក្នុងរដ្ឋាភិបាល របស់សម្តេច ថែមទៀតផង ដែលនៅទីនោះពួកគេអាចប្រើឥទ្ធិពលទៅលើសម្តេចសីហនុ ដើម្បីប្រឆាំងចក្រពត្តិនិយម និងផ្សព្វផ្សាយគំនិតវិទ្ធង្សនាដោយធ្វើយ៉ាងណាជៀសវាងការចងសម្ព័ន្ធភាពជាមួយវៀតណាមឱ្យបាន ។ ជាការការពារនូវយុទ្ធវិធីទាំងនេះដែរ នោះគឺទាក់ទិនទៅនឹងការបត់បែន ដែលសម្របខ្លួនជាថ្មីឡើងវិញជាមួយ បពវ តែប្តេជ្ញាថាត្រូវជៀសវាងការគ្របដណ្តប់របស់វៀតណាមមកលើបដិវត្តន៍កម្ពុជា។ ជាមនុស្សមានជំនឿស៊ុបលើការតស៊ូដោយអាវុធកាលពីនៅទីក្រុងប៉ារីស៍ ពេលនេះ អៀង សារី គឺជាអ្នកគាំទ្រដ៏ប៉ិនប្រសប់បំផុតមួយនៃការប្រមូលផ្តុំទៅលើសកម្មភាពអហឹង្សា ។ ដោយបានទទួលឥទ្ធិពលយ៉ាងច្បាស់ពីទ្រឹស្តីរបស់សូវៀតក្រោយស្តាលីន ស្តីពីការរួមរស់ដោយសន្តិសហវិជ្ជមាន ដែលនិយាយអំពីលទ្ធភាពនៃការឆ្លងទៅសង្គមនិយមដោយសន្តិវិធី តាមរយៈការតស៊ូតាមសភាក្នុងអតីតប្រទេសអាណានិគមនិយមនោះ អៀង សារី បានការពារថា បដិវត្តន៍នៅកម្ពុជានឹងត្រូវធ្វើបានដោយជោគជ័យ ដោយឯករាជ្យ និងដោយប្រជាធិបតេយ្យជាងនេះ បើវាប្រមូលផ្តុំទៅលើការតស៊ូនយោបាយ ក្នុងនេះរួមមានការតស៊ូតាមសភា និងនៅទីក្រុង ជាងការត្រៀមរៀបចំធ្វើការតស៊ូដោយអាវុធវិញនោះ ។ គេបានទទួលស្គាល់ថាបើសិនជាបក្សធ្វើការងារតាមរយៈសភានោះ វាអាចត្រូវប្រើពេលវេលាយូរ តែថាប្រជាជននឹងស្លាប់ក្នុងចំនួនតិចតួចហើយយើង

អាចមិនសូវជាប់ចំណងជាមួយវៀតណាមពេកទេ ។ គំនិតរបស់គេ គឺថាការប្រើហីង្សាតម្រូវឱ្យមានការជាប់ជំពាក់ជាមួយវៀតណាម ដោយទទួលការផ្គត់ផ្គង់ពីវៀតណាមជា អាវុធ គ្រាប់រំសេវ និងការហ្វឹកហ្វឺនខាងយោធា និងរហូតដល់ការពឹងពាក់កងទ័ពវៀតណាមទៀតផង ហើយថាលទ្ធផលនឹងត្រូវពឹងផ្អែកតែទៅលើវៀតណាម និងថាជនកម្ពុជាយ៉ាងច្រើននឹងត្រូវសម្លាប់ ។

គោលជំហរនេះ បានទទួលការស្វាគមន៍ពីសំណាក់សមាសភាពបញ្ញាវ័ន្តជាច្រើននាក់ក្នុងបក្ស ដែលជាមណ្ឌលសំខាន់របស់ អៀង សារី នៅក្នុងនោះ ។

ព្រមជាមួយនេះ ជាផ្នែកមួយនៃការបន្តចូលរួមធ្វើសកម្មភាពនយោបាយ កែវ មាស និងសមាជិកដទៃទៀតនៃក្រុមប្រជាជនចំហ បានខិតខំធ្វើការបោះពុម្ពផ្សាយកាសែតដែលស្ថិតក្រោមការត្រួតមើលរបស់បក្សឱ្យបានច្រើនដែលអាចធ្វើទៅបាន ហើយម្យ៉ាងទៀតធ្វើសកម្មភាពចំហស្របច្បាប់ឡើងវិញ ដើម្បីត្រៀមរៀបចំចូលរួមការបោះឆ្នោតអាណត្តិក្រោយដែលគ្រោងនឹងធ្វើនៅឆ្នាំ ១៩៥៩ ។ កាសែតទាំងនេះមួយចំនួន ត្រូវបានបង្កើតឡើងក្រោមការណែនាំរបស់ សាឡុត ស ដែលនៅតែបន្តភ្ជាប់ខ្សែជាមួយ ទូ សាមុត និងក្រុមប្រជាជន ។ កាសែតនានាដែលត្រួតត្រាដោយបក្ស ត្រូវបានផ្សព្វផ្សាយយ៉ាងទូលំទូលាយ ។

**ការបោះឆ្នោតឆ្នាំ ១៩៥៨ និងបញ្ហាជនចំរើន**

ប៉ុន្តែ នៅខែមករា ឆ្នាំ ១៩៥៨ សម្តេចសីហនុបានរៀបចំធ្វើការបោះឆ្នោតមុនពេលកំណត់ ដែលត្រូវប្រព្រឹត្តទៅនៅក្នុងខែមីនា ។ ការប្រយុទ្ធផ្ទៃក្នុងរវាងគ្នានៃរបបសីហនុ បានជំរុញឱ្យធ្វើការបោះឆ្នោតដោយប្រញាប់ប្រញាល់ ប៉ុន្តែគោលបំណងមួយក្នុងការដើរមុនសកាពការណ៍នេះ គឺដើម្បីកុំឱ្យពួកកុម្មុយនីសមានពេលរៀបចំការប្រកួតប្រជែងបានទាន់ពេលវេលា គឺជាកត្តាមួយទៀត ។ សម្តេចសីហនុបានឆ្លៀតយកចំណេញពីសេចក្តីសំរេចរបស់គណបក្សប្រជាធិបតេយ្យនៅចុងឆ្នាំ ១៩៥៧ - ដែលត្រូវបានជំទាស់ដោយពួកសកម្មជនដែលទទួលឥទ្ធិពលពីពួកកុម្មុយនីសនៅក្នុងនោះ-ដើម្បីបញ្ឈប់លែងឱ្យមានបក្សប្រឆាំងទាំងអស់តទៅទៀត និងសហការជាមួយសង្គមរាស្ត្រនិយម ក្នុងសេចក្តីសង្ឃឹមថានឹងទទួលបានអាសនៈខ្លះក្នុងអនាគតរដ្ឋាភិបាល ។ ការណ៍នេះ បានបន្តទៅឱ្យមានយុទ្ធនាការធ្វើការរំខានដោយសម្របសម្រួលគ្នាមួយ ដែលទីចុងបំផុតនាំទៅដល់ការបំផ្លាញអង្គការចាត់តាំងរបស់ពួកប្រជាធិបតេយ្យ ទុកឱ្យពួកប្រជាជនស្ថិតនៅជាជំរើសនយោបាយជាចំហតែមួយតទល់ជាមួយសង្គមរាស្ត្រនិយម ។

ដូច្នេះ សម្តេចសីហនុបានប្រើការបោះឆ្នោតនេះដើម្បីបើកយុទ្ធនាការថ្មីមួយប្រឆាំងពួកកុម្មុយនីស ។ នៅក្នុងមហាសន្និបាតរបស់សង្គមរាស្ត្រនិយមមួយ នាខែមករា ឆ្នាំ ១៩៥៨ សម្តេចហាក់ដូចជាគិតមមៃពីការគំរាមកំហែងរបស់ពួកគេទៅលើអំណាចផ្តាច់មុខរបស់ទ្រង់ និងប្តេជ្ញាថាត្រូវបំភិតបំភ័យពួកប្រជាជនឱ្យទៅជាអសកម្មនិងបំបិតមាត់ពួកគេ ។ ទ្រង់បានសំដែងថាការនេះនឹងទាក់ទាញមនោសញ្ចេតនាប្រជាជនធម្មតា និងព្រមានប្រជានុរាស្ត្ររបស់ទ្រង់ កុំឱ្យបោះឆ្នោតឱ្យបេក្ខជនរបស់ពួកគេ ដោយទ្រង់បានគូសបញ្ជាក់ថា ពួកកម្មករជាពិសេស មិនត្រូវវង្វេងរហូតដល់ទៅគាំទ្រពួកគេទេ ។ ក្រសួងការងារបានឆ្លើយតបដោយរៀបចំឱ្យកម្មកររដ្ឋធ្វើបាតុកម្មប្រឆាំងកុម្មុយនីស នៅក្នុងទីក្រុងភ្នំពេញ រីឯចៅហ្វាយខេត្តកំពតនិងតាកែវ ស្ថិតនៅទិសនិរតីទិស បានឆ្លើយតបដោយចាប់សមាជិកប្រក្សាប្រជាជន ព្រោះតែសកម្មភាពឃោសានារបស់ពួកគេ ។

បេក្ខជនរបស់ ប្រក្សាប្រជាជន សំរាប់ចូលរួមការបោះឆ្នោតឆ្នាំ ១៩៥៨ ត្រូវបានជ្រើសរើសដោយ កែវ មាស ។ មានតែបេក្ខជន ៥ នាក់ប៉ុណ្ណោះ ដែលបានចុះឈ្មោះរហូតដល់ថ្ងៃបិទបញ្ជីចុះឈ្មោះ នៅចុងខែកុម្ភៈ ក្នុងនេះរួមមាន កែវ មាស ខ្លួនឯងផ្ទាល់ ដែលឈរឈ្មោះសំរាប់មណ្ឌលភ្នំពេញ រីឯអ្នកដទៃទៀតឈរឈ្មោះនៅកំពត បាត់ដំបង ស្វាយរៀង និងតាកែវ ។ តួលេខនេះតិចជាងការដែលបានគិតពីដំបូងដែលថានឹងដាក់បេក្ខជនពី ២០ ទៅ ៣០ នាក់នោះ ។ ការបន្ថយកិច្ចខិតខំសំរាប់ការ

បោះឆ្នោតនេះ ធ្ងុះបញ្ចាំងឱ្យឃើញអំពីការណោយចិត្តក្នុងជួរបក្សអំពីលទ្ធភាពឈ្នះខាងនយោបាយតាមផ្លូវសភា ។ ដូចដែលកម្មាភិបាលម្នាក់ដែលបានចូលរួម បានសរសេរនាពេលក្រោយមកថា ការបំភិតបំភ័យរបស់សម្តេចសីហនុ បានធ្វើឱ្យអ្នកបដិវត្តន៍មួយចំនួនបាក់ទឹកចិត្ត អ្នកខ្លះបានឈប់ធ្វើសកម្មភាពនយោបាយអ្វីទាំងអស់ សូម្បីតែនៅក្នុងតំបន់ដែលពួកកុម្មុយនីសហាក់បីដូចជាមានសក្តានុពលគួរឱ្យកត់សំគាល់ក៏ដោយ ។ ពួកគេធ្វើមិនដឹងមិនឮអំពីសេចក្តីណែនាំរបស់អង្គការបក្សទីក្រុង សាឡុត ស ដែលថាឱ្យចលនាមហាជន ដើម្បីឱ្យពួកគេគាំទ្របេក្ខជនបក្សប្រជាជននោះផង ។ នៅពេលចាប់ផ្តើមសកម្មភាពយុទ្ធនាការដំបូង ពួកគេបានត្រឹមតែចែកខិត្តប័ណ្ណនៅក្នុងខេត្តស្វាយរៀង និងព្រៃវែង នៃភូមិភាគបូព៌ាប៉ុណ្ណោះ ដែលជាមណ្ឌលដែល សាឡុត ស មានសេចក្តីសង្ឃឹមផង និងអល់អែកផង តែជាមណ្ឌលដែលសកម្មជន ភឹម ជាអ្នកទទួលខុសត្រូវ ។ ក្រោយមកដើម្បីជៀសវាងការប្រជុំធ្វើយុទ្ធនាការជាចំហ ពួកគេបានធ្វើយុទ្ធនាការតាមផ្ទះនិមួយៗ នៅក្នុងតំបន់ខ្លះ ។

សម្តេចសីហនុបានយាងទៅធ្វើទស្សនកិច្ចតាមស្រុកនានាក្នុងខេត្តកំពតនិងតាកែវ ដែលសម្តេចខ្លាចក្រែងបេក្ខជនរបស់ក្រុមប្រជាជនធ្វើបានល្អ ដោយទ្រង់បានវាយប្រហារដោយពាក្យសំដីយ៉ាងខ្លាំងលើពួកគេ ។ នៅខេត្តស្វាយរៀង ប៉ូលីស និងក្រុមយុវជនសង្គមរាស្ត្រនិយម ត្រូវបានចាត់តាំងឱ្យតាមដានបេក្ខជនរបស់ក្រុមប្រជាជននៅទីនោះ ។ សារព័ត៌មានផ្លូវការបានគំរាមថានឹងបញ្ជូនប៉ូលីសខេត្តកំពត ដើម្បីដឹកនាំធ្វើការបំភិតបំភ័យប្រឆាំងពួកកុម្មុយនីសដែលធ្លាប់ទទួលបានជ័យជំនះនៅទីនោះកាលពីឆ្នាំ ១៩៥៥ ដោយយកលេសថា ដើម្បីធានាឱ្យមាន"សេរីភាពពេញលេញក្នុងការបោះឆ្នោត" ។ អាជ្ញាធររដ្ឋាភិបាល បានចាត់វិធានការបច្ចេកទេស ដើម្បីបដិសេធមិនផ្តល់ប័ណ្ណបោះឆ្នោតដល់ពួកអ្នកមានសមានចិត្តចំពោះក្រុមប្រជាជនដែលពួកគេបានស្គាល់ ។ នៅចុងបញ្ចប់ បេក្ខជនរបស់ក្រុមប្រជាជនទាំងអស់ លើកលែងតែ កែវ មាស ម្នាក់ បានដកខ្លួនចេញពីការប្រកួតប្រជែង ។ ការរាប់សន្លឹកឆ្នោតបានផ្តល់ដល់រូបគេ ៣៩៦ សម្លេង នៅពេលដែលតួលេខនៃក្រុមប្រជាជនក្នុងខេត្តត្រូវបានផ្តល់ឱ្យទទួលបាន ១៣ សម្លេង"ដោយច្រឡំ" ។

ការបោះឆ្នោតឆ្នាំ ១៩៥៨ បានបំបិទមាត់ក្រុមប្រជាជនជាងពេលណាៗទាំងអស់ ពីការចូលប្រកួតប្រជែងតាមការតស៊ូនយោបាយ និងស្របច្បាប់ ។ ក៏ប៉ុន្តែ ការជ្រើសរើសរបស់សម្តេចសីហនុយកបញ្ញាជនឆ្វេងនិយមល្បីឈ្មោះមួយចំនួន ដែលបានត្រឡប់មកពីរៀននៅប្រទេសបារាំង ឱ្យធ្វើជាបេក្ខជនសង្គមរាស្ត្រនិយម បានធ្លាក់ចូលក្នុងកណ្តាប់ដៃនៃផែនការរបស់ អៀង សារី ដើម្បីបើកច្រកមួយទៀតនៃឥទ្ធិពលសំរាប់ចលនាកុម្មុយនីស តាមរយៈពួកអ្នកចំរើនមានការអប់រំខ្ពស់ ដែលជាផែនការដែលធ្វើឱ្យ សាឡុត ស និង នួន ជា មានការរំភើបយ៉ាងខ្លាំង ។ ពួកគេបានរួមផ្សំផែនការនេះ ជាមួយកិច្ចខិតខំដើម្បីទាញយកទុនពីការលប់បំបាត់គណបក្សប្រជាធិបតេយ្យដោយសម្តេចសីហនុ ដោយធ្វើឱ្យមានការផ្លាស់ប្តូរក្នុងចំណោមពួកដែលនៅសេសសល់ ដែលភាគច្រើនលើសលប់នៃពួកគេទាំងនេះមានការខឹងសម្បានឹងអំពើពុករលួយ មានបំណងចង់ធ្វើការកែទម្រង់សេដ្ឋកិច្ចនិងសង្គម ប្រឆាំងនឹងឥទ្ធិពលរបស់សហរដ្ឋអាមេរិកមកលើកម្ពុជា និងគាំទ្រជ័យជំនះរបស់ពួកប្រឆាំងចក្រពត្តិនិយមនៅវៀតណាម ។

ពួកបញ្ញាជនល្បីឈ្មោះជាងគេ ដែលបានជាប់ឆ្នោតសភាក្នុងការបោះឆ្នោតឆ្នាំ ១៩៥៨ មាន ហ៊ូ យន់ អតីតសមាជិកក្រុមម៉ាក្ស-ឡេនីន និងជាអតីតប្រធានសមាគមនិស្សិតខ្មែរនៅប្រទេសបារាំង ដែលល្បីឈ្មោះខាងទស្សនៈនយោបាយដាច់ខាតនិងនិយាយត្រង់ៗដោយមិនសំចៃ ហើយដែលល្បីឈ្មោះចំពោះនិក្ខេបបទបណ្ឌិតដែលរូបគេបានធ្វើនៅទីក្រុងប៉ារីស៍ ដោយធ្វើការវិភាគទៅលើរចនាសម្ព័ន្ធវណ្ណៈនៃសង្គមជនបទកម្ពុជា ដោយឈរលើទស្សនៈរបស់ម៉ាក្ស ។ រូបគេត្រូវបានទាក់ទាញឱ្យចូលជាមួយគំនិតរបស់អង្គការ និងបានជួយលាក់បាំងដោយមានហេតុផលនូវសកម្មភាពរបស់អង្គការ បន្ទាប់ពីរូបគេបានក្លាយជានាយកនៃសាលាឯកជនមួយ ដែលពួកគេបានបង្រៀន តែរូបគេនៅមិនទាន់បានក្លាយជាសមាជិកនៅឡើយទេ ។

*អ្នកជាប់ឆ្នោតម្នាក់ទៀតគឺ ហ៊ូ នីម ដែលបានចូលរួមធ្វើសកម្មភាពប្រឆាំងអាណានិគមនិយមមិនមែនកុម្មុយនីសមុនឆ្នាំ ១៩៥៤ និងបន្ទាប់មកជាស្ថាបនិកដើមមិនមែនកុម្មុយនីសនៃបក្សប្រជាធិបតេយ្យក្នុងឆ្នាំ ១៩៥៥ ។ ពេលនៅជានិស្សិតម្នាក់នៅប្រទេសបារាំង ពីឆ្នាំ ១៩៥៥ ដល់ឆ្នាំ ១៩៥៧ រូបគេបានស្ថិតក្រោមឥទ្ធិពលរបស់ ហ៊ូ យន់ ហើយត្រូវបានណែនាំអំពីគំនិតម៉ាក្សនិយម តែរូបគេមិនដែលចូលក្នុងក្រុមម៉ាក្ស-ឡេនីន ទេ ដោយរក្សាចំណងជិតស្និទ្ធជាមួយពួកខ្មែរមិនមែនកុម្មុយនីសនៅទីក្រុងប៉ារីស៍ដែលប្រឆាំងសម្តេចសីហនុ ។ ទោះបីជាមានការទាក់ទងពីសំណាក់ភ្នាក់ងាររបស់អង្គការ ក្រោយរូបគេបានត្រឡប់មកភ្នំពេញវិញក៏ដោយ ក៏ពួកនេះមិនដែលប្រាប់រូបគេថាពួកគេជាសមាជិកបក្សទេ ហើយរូបគេក៏មិនដែលបានចូលជាសមាជិកបក្សដែរ ទោះបីជារូបគេបានសរសេរនិក្ខេបបទបណ្ឌិតក្រោមឥទ្ធិពលលទ្ធិម៉ាក្សនិយម នៅសាកលវិទ្យាល័យភ្នំពេញនាពេលនោះក៏ដោយ ។*

*បញ្ញាជនទី ៣ ដែលមនុស្សរបស់អង្គការភ្នំពេញបានទាក់ទងក្រោយការបោះឆ្នោត គឺ ខៀវ សំផន ។ ខៀវ សំផន បានទៅប្រទេសបារាំងនៅឆ្នាំ ១៩៥៣ និងត្រឡប់វិញនៅពាក់កណ្តាលឆ្នាំ ១៩៥៩ បន្ទាប់ពីបានបញ្ចប់និក្ខេបបទរបស់គេ ដែលជាការសិក្សាម៉ាក្សនិយមបែបថ្មីមួយស្តីពីលទ្ធភាពនៃឧស្សាហូបនីយកម្មនៅកម្ពុជា ។ ដោយមានការចាប់អារម្មណ៍ និងទាក់ទាញដោយការតស៊ូបដិវត្តន៍វៀតណាម រូបគេបានចូលរួមជាមួយក្រុមម៉ាក្ស-ឡេនីន និងត្រូវបានជ្រើសរើសឱ្យចូលជាសមាជិកបក្សកុម្មុយនីសបារាំង ហើយបានក្លាយជាប្រធាននៃសហភាពនិស្សិតខ្មែរឆ្វេងនិយម តែនិក្ខេបបទរបស់គេគឺជាឯកសារនៃការកែទម្រង់មួយ ដែលឆ្លុះបញ្ចាំងអំពីទ្រឹស្តីនៃការអភិវឌ្ឍន៍របៀបប្រទេសបារាំង ដែលរូបគេបានធ្វើឡើងជាគំរោងផ្ទាល់ខ្លួនរបស់គេ និងមិនមែនជាការចាត់តាំងពីអង្គការកុម្មុយនីសនៅកម្ពុជាទេ ។ រូបគេក៏មិនទាន់បានក្លាយជាសមាជិកនៃបក្សកម្ពុជានៅពេលត្រឡប់មកពីប្រទេសបារាំងវិញដែរ តែរូបគេបានទោរទន់ទៅធ្វើសកម្មភាពក្នុងឋានៈជាឧបករណ៍របស់បក្សនេះជាង ហ៊ូ យន់ និង ហ៊ូ នីម យ៉ាងច្រើន ។ កាសែតឈ្មោះ "អុបស៊ែវ៉ាទ័រ -Observateur" (អ្នកសង្កេតការណ៍) សរសេរជាភាសាបារាំង ត្រូវបានរូបគេបង្កើតឡើងនៅពេលត្រឡប់មកស្រុកវិញ ។ កាសែត នេះជាការឆ្លុះបញ្ចាំងការផ្តើមគំនិតមួយរបស់ សាឡុត ស ក្នុងទិសដៅរក្សាការតស៊ូនយោបាយរបស់បក្ស ដោយប្រើឥទ្ធិពលទៅលើពួកវរជននិយាយភាសាបារាំងនៃកម្ពុជា ។ គោលជំហររបស់កាសែតនេះ គឺភាគច្រើនលើសលប់យកតាមប្រធានបទរបស់គណបក្សប្រជាធិបតេយ្យ ស្តីពីការប្រឆាំងចក្រពត្តិនិយម និងទាមទារយុត្តិធម៌សង្គម ពីការបោះឆ្នោតឆ្នាំ ១៩៥៥ ។*

*សាឡុត ស និង នួន ជា មិនត្រឹមតែមិនពេញចិត្តនឹងសន្ទុះដែលការនេះបានផ្តល់ដល់ការតស៊ូនយោបាយនៅក្នុងរាជធានីប៉ុណ្ណោះទេ ។ បន្ទាប់ពី ហ៊ូ យន់ និង ហ៊ូ នីម ត្រូវបានតែងតាំងជារដ្ឋលេខាធិការឬអនុរដ្ឋលេខាធិការ ក្នុងរដ្ឋាភិបាលចេញមកពីការបោះឆ្នោត សាឡុត ស និង នួន ជា ក៏សង្ឃឹមផងដែរថាការនេះអាចនឹងមានលទ្ធភាពធ្វើអន្តរាគមន៍ ដើម្បីការពារពួកកុម្មុយនីសបង្កប់ខ្លួន ដូចជាពួកគេជាដើម ពីការបង្ក្រាបដែលបានរីករាលដាលពីការដែល ស៊ីវ ហេង ក្បត់ ពីពួកបណ្តាញនៅជនបទ រហូតដល់ខ្សែបណ្តាញរបស់ ទូ សាមុត ថែមទៀតនោះ ។ គ្រោះថ្នាក់ដែលនឹងធ្លាក់មកលើពួកចុងក្រោយនេះ បានកើនឡើងដោយសារពួកនៅសេសសល់ពីការបង្ក្រាបនៅជនបទបាននាំគ្នារត់មកភ្នំពេញ ដែលវត្តមានរបស់ពួកគេនៅក្នុងរាជធានីនឹងធ្វើឱ្យកងកម្លាំងសន្តិសុខរបស់ លន់ ណុល មានការប្រុងប្រយ័ត្នចំពោះកម្មាភិបាលដឹកនាំចលនាក្នុងទីក្រុង ។ ការភ័យខ្លាចចំពោះសុវត្ថិភាព បានកើនឡើងកាន់តែខ្លាំងបន្ទាប់ពីការធ្វើឃាតចាងហ្វាងកាសែតរបស់ក្រុមប្រជាជន ក្នុងខែវិច្ឆិកា ឆ្នាំ ១៩៥៩ ។ ភាពតឹតក័យតក្កមា និងភាពច្របូកច្របល់ បានបក់បោកមកលើផែនការកោះប្រជុំសមាជបក្ស ដែលដើមឡើយ សាឡុត ស និង នួន ជា គិតថានឹងអាចធ្វើនៅក្នុងឆ្នាំ ១៩៥៩ នោះ ។ វៀតណាម បានផ្តល់យោបល់តាមរយៈ ទូ សាមុត ឱ្យពន្យារពេលរហូតដល់សភាពការណ៍ប្រសើរឡើងវិញ ។*

ស្ថិតចំពោះមុខស្ថានភាពបែបនេះ សាឡុត ស និង នួន ជា បានធ្វើការវាយតម្លៃថែមទៀតថាសកម្មភាពរបស់ ខៀវ សំផន, ហ៊ូ យន់ និង ហ៊ូ នីម នឹងទាក់ទាញការប្រុងប្រយ័ត្នចេញពីផ្ទាល់ខ្លួនពួកគេ និងជួយធ្វើឱ្យមានការចាប់អារម្មណ៍ថាចលនាកុម្មុយនីសកម្ពុជា ត្រូវបានដឹកនាំដោយពួកបញ្ញាជនដែលបានទទួលការអប់រំនៅប្រទេសបារាំង ដោយដាក់ស្តែងពុំមានការទាក់ទងអ្វីជាមួយវៀតណាម ឬអតីតសមាជិក បកត ដែលបានទទួលការអប់រំពីវៀតណាមទេ ។ នេះគឺជាការបន្តនូវយុទ្ធវិធីដើមរបស់ បកត ដែលបានប្រើចំពោះ ចាន់ សាម៉ៃ ក្នុងរយៈពេលមុនឆ្នាំ ១៩៥៤ ។ ខៀវ សំផន បានបញ្ជាក់ឱ្យឃើញជាពិសេសចំពោះប្រសិទ្ធភាពនៃតួនាទីរបស់គាត់ ដោយសារកិត្យានុភាពរបស់គាត់កាន់តែកើនឡើង ចំពោះវីរយភាពភាពស្អាតស្អំមិនពុករលួយផ្ទាល់ខ្លួន ការយកចិត្តទុកដាក់ចំពោះយុត្តិធម៌សង្គមនិងនយោបាយ ព្រមទាំងការគាំទ្រឱ្យមានការអភិវឌ្ឍន៍សេដ្ឋកិច្ច និងការការពារសិទ្ធិមនុស្ស ។ ជោគជ័យនៃល្បិចកលរបស់អ្នកទាំងពីរនេះ បានទទួលរងនូវនាដកម្មនៅក្នុងខែ កក្កដា -សីហា ឆ្នាំ ១៩៦០ នៅពេលដែល លន់ ណុល បានធ្វើឱ្យ ខៀវ សំផន ក្លាយជាទុក្ករៈបុគ្គលបញ្ញាជនម្នាក់ ដោយបានបិទកាសែតអ្នកសង្កេតការណ៍-*Observateur* ដោយ ខៀវ សំផន ត្រូវបានទទួលរងការវាយសម្រាតខោនៅតាមដងវិថី និងជាប់ឃុំអស់រយៈពេល ១ ខែ ។

ក៏ប៉ុន្តែ សម្តេចសីហនុ បានរក្សាទស្សនៈនិងវាក្យស័ព្ទដែលមានមុខពីរ ទាក់ទិនទៅនឹងពួកកុម្មុយនីសខ្មែរដដែល ។ ចំពោះសម្តេច ក៏ដូចជាចំពោះបារាំង ពួកខ្មែរកុម្មុយនីសនៃ បកត នៅតែជា"ខ្មែរវៀតមិញដដែល" ដែលមានន័យថាពួកគេជាអាយ៉ងរបស់វៀតណាម ។ ក្រុមប្រជាជន ត្រូវបានចាត់ទុកត្រឹមតែជាមុខមាត់ផ្លូវការរបស់ក្រុមអាយ៉ងបរទេសនេះតែប៉ុណ្ណោះហើយ សម្តេចនិងសង្គមរាស្ត្រនិយមបានបន្តចាត់ទុកពួកនេះក្នុងផ្លូវនេះដដែល ដោយមិនគិតពីវិសាលភាពនៃការដែលពួកនេះមិនស្ថិតនៅក្រោមការដឹកនាំរបស់វៀតណាមតទៅទៀតក៏ទេដែរ ។ អ្វីដែលត្រឹមត្រូវជាងនេះនោះ សម្តេចសីហនុ - ក៏ដូចជា បពខ ខ្លួនឯង - បានធ្វើការបែងចែកពួកខ្មែរវៀតមិញទាំងនេះ ដាច់ពីពួកបញ្ញាជនម៉ាក្សនិយមដូចជា ហ៊ូ យន់, ហ៊ូ នីម និង ខៀវ សំផន ត្រង់ការដែលនៅសង្ស័យថាជាខ្មែរក្រហមនៅឡើយនោះ ។ យោងតាមការបែងចែកជាពីររបស់សម្តេច ពួកខ្មែរវៀតមិញ គឺជាពួកអ្នកសមគំនិតជាមួយពួកកុម្មុយនីសវៀតណាម ដែលបានធ្វើសកម្មភាពវិទ្ធង្សនានៅកម្ពុជា និងបើកផ្លូវឱ្យកម្ពុជាទៅជាអាណានិគមរបស់ និង"ការត្របាក់លេប" ដោយវៀតណាម ។ សម្តេច សីហនុ មានបន្ទូលថា ខ្មែរក្រហមក៏គាំទ្រពួកកុម្មុយនីសវៀតណាមប្រឆាំងរដ្ឋាភិបាលរបស់ពួកគេដែរ ដោយខិតខំជំរុញលទ្ធិកុម្មុយនីសមកក្នុងប្រទេសកម្ពុជា តែពួកនេះឯករាជ្យខាងស្មារតីជាង។

ច្បាស់ណាស់ សម្តេចសីហនុ មិនបានដឹងពីធាតុពិតនៃភាពស្រលាំគ្នាក្នុងចលនាកុម្មុយនីសខ្មែរ និងខ្លឹមសារលំអិតនៃការពិភាក្សាផ្ទៃក្នុងរបស់វាទេ ។ នៅពេលសភាពការណ៍ចេះតែដុនដាបទៅនោះ ការពិភាក្សាគ្នាបានយកចិត្តទុកដាក់កាន់តែខ្លាំងទៅលើ ថាតើត្រូវធ្វើតាមគំរូវៀតណាម និងផ្លាស់ប្តូរចេញពីមាគ៌ានយោបាយតែមួយនោះឬយ៉ាងណា ។ នៅពេល នួន ជា ទៅភាគខាងត្បូងវៀតណាម ដើម្បីដាក់ជូន បពវ នូវអត្ថបទចម្ងងនៃមាគ៌ានយោបាយ និងលក្ខន្តិកៈ ដែលព្រៀងឡើងដោយ សាឡុត ស គាត់បានប្រាប់ពួកវៀតណាមថា រូបគាត់ និង សាឡុត ស គាំទ្រឱ្យមានការប្តូរទិសឆ្ពោះទៅធ្វើសកម្មភាពខាងអាវុធវិញ ដូចដែលត្រូវបានគាំទ្រដោយ សោ ភឹម កាលពីពេលមុន ។ នួន បានពន្យល់ថា ពួកគេចង់ជំរុញទៅធ្វើបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យប្រជាជននៅកម្ពុជាវិញ ការជាប់ទាក់ទងគឺបដិវត្តន៍របស់គេត្រូវតែស្ថិតនៅក្នុងកំរិតដូចគ្នានឹងអ្វីដែលបានធ្វើនៅវៀតណាម ទោះតិចក្តី ច្រើនក្តី ។ ពួកវៀតណាមបានប្រឆាំង និងផ្តល់អនុសាសន៍ឱ្យស្ថិតនៅលើមាគ៌ានៃការតស៊ូនយោបាយតែមួយមុខគត់ ។ តាម នួន ឱ្យដឹង គឺថាទោះបីជាពួកគេបានបង្ហាញឱ្យដឹងថាពួកខ្មែរមិនខុសទេក្នុងការគិតគូថាត្រូវធ្វើបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យប្រជាជនដោយប្រការណាមួយនោះ តែពួកគេចោទជាសំណួរថា តើកម្ពុជាបានចែកដាច់ពីគ្នាច្បាស់លាស់សមល្មមហើយឬនៅ អំពីភាពបដិបក្សនៃវណ្ណៈក្នុងសង្គម ដើម្បីឱ្យមកគាំទ្រពួកគេនោះ ។ ពួកគេបានបង្ហាញ

ឱ្យឃើញថា ការបន្តអំពីលទ្ធភាពនៃការធ្វើសកម្មភាពតាមរយៈសភា និងឱ្យពួកសក្តិភូមិដើរតួធ្វើការងារជាអ្នកចំរើននិយម ពោលគឺ សម្តេចសីហនុ ដើរតួធ្វើជាអ្នកប្រឆាំងចក្រពត្តិនិយម ។ ប៉ុន្តែ អ្វីដែលសហភាគីវៀតណាមនៃ បពវ នៃភាគខាងត្បូង ដែល នួន បានជួប មានការបារម្ភជាងគេបំផុតនោះ គឺខ្មែរបានកំណត់មាគ៌ានយោបាយរបស់ខ្លួនដោយខ្លួនឯង ។

អ្វីដែលជាការចំអកនោះ គឺថាខ្មែរបានបង្ហាញឱ្យឃើញនូវការទោទន់នៃការព្រួយបារម្ភដូចគ្នា ឆ្ពោះទៅអ្វីដែលសកម្មជនភាគខាងត្បូង បានដាក់បង្ហាញឱ្យឃើញក្នុងការទាក់ទងរបស់ពួកគេ ជាមួយគណៈកម្មាធិការមជ្ឈិម បពវ នៅហាណូយ ។

## ជំពូក ៤
## សមាជបក្សឆ្នាំ ១៩៦០
## នៅវៀតណាម និងនៅកម្ពុជា

*ទោះបីជាមានសេចក្តីបារម្ភអំពីសេចក្តីព្រាងរបស់ ស - នួន ក៏ដោយ ក៏ពួកវៀតណាមបានធ្វើសម្បទានជាគន្លឹះមួយដែរ នោះគឺ: អង្គការមានទស្សនៈត្រឹមត្រូវក្នុងការបោះបង់ចោលការបញ្ចប់របស់ បកឥ នូវបញ្ញត្តិរបស់ស្តាលីននាចុងទសវត្ស ១៩២០ ស្តីពីការធ្វើបដិវត្តន៍រំដោះជាតិ ក្នុងពេលសង្គ្រាមលោកលើកទី ២ ហើយជាជំនួសអនុម័តយកការបកស្រាយដាច់ខាតរបស់ បកឥ នាចុងទសវត្ស ១៩៤០ នូវនិយមន័យរបស់ ស្តាលីន-ម៉ៅ ស្តីពីការធ្វើបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យមួយ ហៅថា បដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យប្រជាជន ។ ជាក់ស្តែង មនោគមវិជ្ជាផ្ទាល់របស់ បពវ ក្នុងការសរសេរឡើងវិញនូវប្រវត្តិបដិវត្តន៍វៀតណាម ធ្វើឱ្យពួកគេមិនមានជំរើសអ្វីផ្សេងទៀតទេនៅពេលគេធ្វើបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យប្រជាជន ថាជាការចាប់ផ្តើមនៃកិច្ចដំណើរការបដិវត្តន៍ណាមួយនោះ ។*

*ដោយមានសញ្ញាភ្លើងបៃតងពីមនោគមវិជ្ជានេះ ទីបំផុតសមាជបក្សកម្ពុជាត្រូវបានកោះធ្វើជាសម្ងាត់ នៅក្នុងទីក្រុងភ្នំពេញ ពីថ្ងៃទី ២៨ ដល់ថ្ងៃទី ៣០ ខែកញ្ញា ឆ្នាំ ១៩៦០ ចូលរួមដោយសមាជិក ៧ នាក់នៃអង្គការទីក្រុងរបស់បក្ស និង ១៤ នាក់មកពីសាខាបក្សនៅជនបទ ។ ឯកសារសំខាន់ៗ ចំនួន ៣ ដែលបានព្រាង ដោយ ស និងដោយមានការឯកភាពពី នួន ត្រូវបានអនុម័ត មាន: លក្ខន្តិកៈរបស់បក្ស មាគ៌ាយុទ្ធសាស្ត្រ និង យុទ្ធវិធីរបស់បក្ស និងមាគ៌ារណសិរ្សរួបរួម ។ ឯកសារទាំងនេះ បានបង្ហាញពីការខ្ចីមកពីទ្រឹស្តី ដូចដែលត្រូវរៀបចំឡើងវិញពេញមួយទសវត្ស ១៩៥០ និងត្រូវបានបូកសរុបនៅក្នុងសុន្ទរកថារបស់អគ្គលេខាបក្សវៀតណាម ឡេ យន់ និងពួកអ្នកដទៃទៀត នាមហាសន្និបាត បពវ ដែលបានកោះប្រជុំ ២ អាទិត្យមុនការប្រជុំរបស់ខ្មែរ។ នៅកន្លែងជាច្រើន ខ្មែរបានចម្លងយកអ្វីដែលវៀតណាមបាននិយាយអំពីភាគខាងត្បូងវៀតណាមដើម្បីយកមកអនុវត្តន៍នៅកម្ពុជាផងដែរនោះ ហើយកន្លែងដទៃទៀតជនកម្ពុជាបានធ្វើតាមអ្វីដែលពួកវៀតណាមបាននិយាយអំពីកម្ពុជា ។ ដើម្បីវាយតម្លៃអំពីវិសាលភាពនៃការធ្វើត្រាប់តាមនេះ មានការចាំបាច់ត្រូវពិនិត្យមើលសមាជវៀតណាមឱ្យបានលំអិតបន្តិច ។*

### *សមាជ បពវ*

*មុនឆ្នាំ ១៩៦០ ពួកកុម្មុយនីសគម្ពីរនិយមវៀតណាម បានសម្របខ្លួនទាំងស្រុងទៅនឹងទ្រឹស្តីនិងការប្រតិបត្តិបដិវត្តន៍ដែលសូវៀតបានរៀបចំឡើងវិញ នាចុងទសវត្ស ១៩៤០ ដោយលើកឡើងនូវពាក្យបដិវត្តន៍រំដោះជាតិ ដោយត្រឡប់ទៅរកគំនិតដាច់ខាតនៃការធ្វើបដិវត្តន៍ប្រជាធិបតេយ្យប្រជាជាតិប្រជាជនមួយ និងបានអនុវត្តន៍ក្នុងកុប្បកម្មខែសីហា ឆ្នាំ ១៩៤៥ ដ៏មានប្រជាប្រិយភាពដែល បកឥ បានប្រកាសថាខ្លួនបានដឹកនាំធ្វើនោះ ។ ការរៀបរាប់របស់ បពវ អំពីបដិវត្តន៍នេះ គឺគ្រាន់តែដាក់វាឱ្យស្របទៅនឹងការសរសេរឡើងវិញ នាចុងទសវត្ស ១៩៤០ របស់សូវៀត នូវប្រវត្តិនៃការបង្កើតប្រជាធិបតេយ្យប្រជាជនប៉ុណ្ណោះ ។ ឥឡូវបដិវត្តន៍រំដោះជាតិបានក្លាយជាគំនិតមួយមិនច្បាស់លាស់ ដោយគ្របដណ្តប់លើដំណាក់កាលនៃការតស៊ូប្រឆាំងអាណានិគមនិយមបូរកុម្មុយនីស និងដឹកនាំដោយអ្នកកុម្មុយនីសនិយម រហូតដល់ឆ្នាំ ១៩៤៥ ។ ការកំចាត់ការជិះជាន់របស់ពួកសក្តិភូមិ ក៏ត្រឡប់ក្រោយទៅការចាប់ផ្តើមនាឆ្នាំ ១៩៤៥ ដែរ ដែលក្រោយមកបានបន្តជាផ្នែកមួយដ៏ពេញលេញនៃការតស៊ូដោយអាវុធប្រឆាំងចក្រពត្តិនិយម ដើម្បីទាមទារឯករាជ្យដែលកំពុងប្រព្រឹត្តទៅ ។ បដិវត្តន៍ប្រជាធិបតេយ្យប្រជាជាតិប្រជាជន មានន័យថាធ្វើការកែទម្រង់ដីធ្លី (ដោយកំទេចកម្មសិទ្ធិលើដីធ្លីរបស់ពួកសក្តិភូមិ) ព្រមពេលជាមួយគ្នានឹងការបណ្តេញពួកអាណានិគមនិយម និងពួកចក្រពត្តិនិយម ។*

*យោងតាមទ្រឹស្តីគម្ពីរនិយមឆ្នាំ ១៩៦០ នេះ បដិវត្តន៍ប្រជាធិបតេយ្យប្រជាជាតិប្រជាជនខែសីហា ឆ្នាំ ១៩៤៥ បានកំទេចរដ្ឋអំណាចអាណានិគមនិយម និងសក្តិភូមិនិយម បង្កើតឡើងនូវរដ្ឋឯករាជ្យ និងប្រជាធិបតេយ្យពិតប្រាកដមួយរបស់ប្រជាជន ។ ការតស៊ូរបស់ពួកកុម្មុយនីសវៀតណាមឆ្នាំ ១៩៤៥ - ១៩៥៤ ក៏ជាផ្នែកមួយនៃបដិវត្តន៍ប្រជាធិបតេយ្យប្រជាជាតិប្រជាជន ដោយឈរលើសម្ព័ន្ធភាពកម្មករ-កសិករ ដឹកនាំធ្វើការកែទម្រង់ដីធ្លី ដើម្បីកំចាត់ការជិះជាន់ដោយវណ្ណៈសក្តិភូមិ ដើម្បីលើកទឹកចិត្តដល់ការតស៊ូប្រឆាំងអាណានិគមនិយម និងចក្រពត្តិនិយម ។ បដិវត្តន៍ប្រជាធិបតេយ្យប្រជាជាតិប្រជាជន បានបន្តធ្វើនៅភាគខាងត្បូង ក្រោយឆ្នាំ ១៩៥៤ នៅពេលដែល សបវ បន្តធ្វើសង្គមនិយម ។*

*សមាជក៏បានលើកឡើងជាថ្មីម្តងទៀតថា អ្វីដែលត្រូវធ្វើជាមុនដើម្បីឆ្ពោះទៅកាន់ជោគជ័យនៃបដិវត្តន៍ ត្រូវមានបក្សម៉ាក្ស-ឡេនីន របស់វណ្ណៈកម្មករ ជាអ្នកដឹកនាំនិងរៀបចំតែមួយគត់ ។ លក្ខន្តិកៈ បពវ បានកែសម្រួលឡើងវិញ ដែលសមាជបានអនុម័ត ដោយបានដកចេញនូវការយោងទៅលើគំនិតម៉ៅសេទុង ។ ជាជំនួស យោងតាមបុព្វកថា បពវ គ្រាន់តែយកលទ្ធិម៉ាក្ស-ឡេនីននិយម តែមួយគត់ធ្វើជា"គ្រឹះនិងត្រីវិស័យ" របស់បក្ស ។ បក្សវណ្ណៈកម្មករមួយដឹកនាំដោយត្រីវិស័យនេះ ជាការធានាថា បដិវត្តន៍ប្រជាធិបតេយ្យប្រជាជាតិប្រជាជន នឹងដណ្តើមបានជ័យជំនះ ទោះបីជានៅក្នុងប្រទេសតូច និងឱនថយក៏ដោយ មិនថាស្ថិតក្នុងស្ថានភាពលំបាក និងស្មុគ្រស្មាញ ឬថាទោះបីជាខ្មាំងខ្លាំងយ៉ាងណាក៏ដោយ ។ ក៏ប៉ុន្តែ ទោះជាកំពុងដណ្តើមបានជ័យជំនះក៏ដោយ ក៏បក្សភាគខាងត្បូងនៅតែស្ថិតនៅជាសម្ងាត់ដដែល ដូចដែលគេបានធ្វើតាំងពីឆ្នាំ ១៩៥៤ មក ។*

*សមាជបានពន្យល់ថែមទៀតថា ទិសដៅនៃការបន្តធ្វើបដិវត្តន៍នេះនៅភាគខាងត្បូងគឺដើម្បីរំដោះចេញពីការត្រួតត្រាដ៏សាហាវឃោរឃៅរបស់ចក្រពត្តិអាមេរិក និងមនុស្សដៃដល់របស់ពួកវា ការអនុវត្តគំនិតនេះឈរលើសេចក្តីសន្និដ្ឋានរបស់ បពវ តាំងពីឆ្នាំ ១៩៥៤ ដែលថាចក្រពត្តិអាមេរិក នឹងប្រែក្លាយភាគខាងត្បូងឱ្យទៅជាអាណានិគមនិយមបែបថ្មីមួយ។ ការណ៍នេះធ្វើឱ្យប្រជាជនភាគខាងត្បូងពុំមានជំរើសអ្វីក្រៅពីផ្តួលរំលំរបបផ្តាច់ការហ្វាស៊ីសរបស់ចក្រពត្តិអាមេរិក និង ង៉ោ ឌិនយៀម ប៉ុណ្ណោះ ។ ឋានៈអាណានិគមនិយមថ្មីនៃភាគខាងត្បូង ត្រូវបានដាក់បង្ហាញថាជាការពិតមួយដែលត្រូវទទួលស្គាល់ នៅចំពោះមុខនៃរូបភាពខាងក្រៅមិនធម្មតាមួយ ទៅនឹងអ្វីដែលជាការផ្ទុយពីនេះទៅវិញ ។ ដូច្នេះ "ទោះបីជាចក្រពត្តិអាមេរិកខិតខំផាត់ប្រេងលាបម្សៅឱ្យរបប ង៉ោ ឌិនយៀម និងបិទបាំងឯករាជភាពនិងប្រជាធិបតេយ្យក្លែងក្លាយយ៉ាងណាក៏ដោយ" ក៏ពុំមានអ្នកណាម្នាក់ចាញ់បោកពួកគេដែរ ដោយហេតុថាសហរដ្ឋអាមេរិកមិនបានបង្កើតម៉ាស៊ីនរដ្ឋបាល និងពុំមានកងទ័ពកាន់កាប់ភាគខាងត្បូងទេ ។ យ៉ាងណាក៏ដោយ ពួកគេបានជួយរៀបចំនៅទីនោះលើគ្រប់វិស័យៈ នយោបាយ យោធា សេដ្ឋកិច្ច និងវប្បធម៌ ។*

*បដិវត្តន៍ប្រជាធិបតេយ្យប្រជាជាតិប្រជាជន ក៏បានបន្តធ្វើដែរលើមូលដ្ឋាននៃការវិភាគវណ្ណៈមួយ ដើម្បីរកឱ្យឃើញទំនាស់ជាមូលដ្ឋានពីរនៅភាគខាងត្បូងៈ ទីមួយ ទំនាស់រវាងប្រជាជន និងចក្រពត្តិអាមេរិកឈ្លានពាន និងទីពីរ ទំនាស់រវាងប្រជាជន ជាពិសេសកសិករ និងវណ្ណៈសក្តិភូមិម្ចាស់ដី ។ បពវ បាននិយាយថា ដោយសារទំនាស់ទី ១ នេះ ទោះបីវាជាការលាក់បាំងក៏ដោយ ក៏វាបានក្លាយកាន់តែស្រួចស្រាវ និងហឹង្សាឡើងៗ បក្សត្រូវបន្តអនុវត្តមាគ៌ារណសិរ្សរួបរួមមួយ ដោយប្រមូលវណ្ណៈស្រទាប់ និងបុគ្គលស្នេហាជាតិ ទាំងអស់ ដោយមិនគិតពីវណ្ណៈភាពដើមអ្វីទាំងអស់ ឱ្យស្ថិតនៅពីក្រោយការតស៊ូប្រឆាំងសហរដ្ឋអាមេរិក ។*

*ប៉ុន្តែ បក្សត្រូវប្រមូលផ្តុំទៅលើការចាត់តាំងកម្មករ កសិករ និងបញ្ញាជន ។ ក្នុងចំណោមពួកអ្នកទាំងអស់នេះ ត្រូវកំណត់ថាកសិករជាកម្លាំងបដិវត្តន៍ធំបំផុត ពីព្រោះ បពវ បាននិយាយថាទំនាស់សំខាន់ជាងគេនៅភាគខាងត្បូង គឺទំនាស់រវាងកសិករនិងវណ្ណៈម្ចាស់ដី ហើយនឹងការជិះជាន់ និងការកេងប្រវ័ញ្ចលើកសិករ គឺជាទិសដៅចំបងរបស់ចក្រពត្តិអាមេរិកនៅវៀតណាម ។ ដើម្បីផ្តល់តួនាទីពេញលេញដល់កម្លាំងបដិវត្តន៍ដ៏មហិមារបស់កសិករ បដិវត្តន៍ត្រូវដឹកនាំជាបន្តបន្ទាប់ ការវាយប្រហារ*

របស់ពួកគេទៅលើចក្រពត្តិអាមេរិក និងប្រើវិធីសាស្ត្រនៃការកែទម្រង់បន្តិចម្តងៗ ដើម្បីឈានទៅធ្វើបដិវត្តន៍ដីធ្លី និងកំទេចវណ្ណៈម្ចាស់ដី ។

ដូច្នេះ សមាជបានកំណត់ភារកិច្ចជាមូលដ្ឋានក្នុងប្រទេសអំពីការធ្វើបដិវត្តន៍នៅភាគខាងត្បូង ថានឹងផ្តល់ដីឱ្យពួកអ្នកទាំងឡាយដែលបានធ្វើការកាប់គាស់វា បន្ទាប់ពីពួកគេត្រូវបានចលនាតាមការស្នើរបស់បក្ស ថាពួកគេនិងប្រជាជនដទៃទៀតនឹងទទួលបានសេរីភាពប្រជាធិបតេយ្យ និងជីវភាពរស់នៅកាន់តែប្រសើរឡើង ។ ទីបញ្ចប់ យោងទៅតាមសភាពការណ៍នៅភាគខាងត្បូង បពវ បានបញ្ជាក់ជាថ្មីថា ការតស៊ូនៅទីនោះតម្រូវឱ្យមានការរួមផ្សំគ្នារវាងការតស៊ូដោយអាវុធនិងការតស៊ូនយោបាយ កម្លាំងប្រដាប់អាវុធរួមជាមួយកម្លាំងនយោបាយ ធ្វើសកម្មភាពមិនស្របច្បាប់ផងនិងស្របច្បាប់ផង ។ អាទិភាពត្រូវផ្តល់ដល់ការបង្កើតកងកម្លាំងប្រដាប់អាវុធឱ្យបានឆាប់រហ័សមួយនៅភាគខាងត្បូង ដើម្បីបំរើដល់ការគាំទ្រដល់កម្លាំងនយោបាយ និងការតស៊ូដោយអាវុធ ពីព្រោះលក្ខណៈសម្បត្តិទុំហើយសំរាប់ធ្វើកុប្បកម្មដោយអាវុធក្នុងទ្រង់ទ្រាយជាសង្គ្រាមប្រជាជននោះ ។

ការវិភាគរបស់សមាជ អំពីជនបទភាគខាងត្បូង បានអនុវត្តប្រភេទវណ្ណៈដើមដែលបានកំណត់នៅភាគខាងជើងក្នុងឆ្នាំ ១៩៥៣ នៅពេល បពវ សំរេចអនុវត្តការកែទម្រង់ដីធ្លីដាច់ខាត និងទាំងស្រុង នៅពេញមួយចំហៀងប្រទេស ដែលពួកកុម្មុយនីសមានចំនួនគ្រប់ដណ្តប់ ។ ប្រភេទទាំងនោះបានឆ្លុះបញ្ចាំងសភាពការណ៍នៅភាគខាងជើង: ពួកម្ចាស់ដីមានចំនួនអប្បភាគតូចមួយ ហើយកសិករមានកាន់តែតិចជាងទៀត កសិករក្រ និងក្របំផុត មានចំនួន ៦០ ភាគរយនៃប្រជាជនជនបទទាំងមូល ។ ចេញពីស្ថានភាពបែបនេះ បពវ បានទាញយកនយោបាយបំផុសបំផុលកសិករក្របំផុត និងក្រ ដើម្បីឯកោនិងផ្តួលរំលំពួកម្ចាស់ដីភាគខាងជើង ដោយយកកសិករកណ្តាល និងកសិករមានធ្វើជាសម្ព័ន្ធមិត្ត ។ ពាក្យស្លោកនៃសមាជ បពវ ឆ្នាំ ១៩៦០ ដើម្បីបក្សធ្វើសកម្មភាពនៅជនបទភាគខាងត្បូង គឺត្រូវធ្វើការអំពាវនាវដូចគ្នាឱ្យបង្រួបបង្រួមកសិករក្របំផុត និងកសិករក្រ ឱ្យចូលក្នុងសម្ព័ន្ធភាពជាមួយកសិករកណ្តាលនិងកសិករមាន ដើម្បីផ្តួលរំលំពួកម្ចាស់ដី ទោះបីជាវាបានបញ្ជាក់ថា ការវាយប្រហារដំបូងត្រូវផ្តោតទៅលើការផ្តួលរំលំពួកម្ចាស់ដីដែល"កំណាច"ជាងគេបំផុត ពោលគឺពួកបំរើជាអាយ៉ងដ៏ស្មោះត្រង់បំផុតរបស់ចក្រពត្តិអាមេរិក និងរបប ង៉ោ ឌិនយៀម ក៏ដោយ ។

ការអនុវត្តរបស់សមាជ នូវរូបមន្តទាញចេញមកពីភាគខាងជើងនេះ មិនអើពើដល់លក្ខណៈពិសេសនៃជនបទភាគខាងត្បូងនាឆ្នាំ ១៩៦០ ដែលឆ្លុះបញ្ចាំងពីបច្ច័យដ៏ស្មុគ្រស្មាញនៃសកម្មភាពរបស់ពួកកុម្មុយនីសនៅទីនោះ ក្នុងរយៈពេលនៃសង្គ្រាមឥណ្ឌូចិនលើកទី ១ និងគោលនយោបាយរបស់ ង៉ោ ឌិនយៀម ចាប់តាំងពីសន្និសិទទីក្រុងហ្សឺណែវមកនោះទេ។ ក្នុងឆ្នាំដំបូងៗ នៃសង្គ្រាមឥណ្ឌូចិនលើកទី ១ បកត បានដឹកនាំធ្វើការកែទម្រង់ដីធ្លីមួយនៅភាគខាងត្បូង ដែលបានធ្វើឱ្យមានការប្រមូលផ្តុំកាន់តែធំថែមទៀតនូវពួកម្ចាស់ដីទំហំធំៗ និងកសិករគ្មានដី និងកម្មករកសិកម្មកាន់តែច្រើនជាងនៅភាគខាងជើងទៅទៀត តែបដិវត្តន៍ដីធ្លីនេះមានភាពមិនសូវដាច់ខាត និងពេញលេញទេ ដោយការក្តោបក្តាប់របស់បក្សនៅភាគខាងត្បូងខ្សោយ និងមិនដែលត្រូវបានពង្រឹងទេ ។ បក្សបានធ្វើការដកហូតយក-កន្លែងណាដែលអាចធ្វើទៅបាន-ការកាន់កាប់ដីធ្លីរបស់ម្ចាស់ដីធំៗជាងគេបំផុត ព្រមជាមួយដីរបស់ពួកអ្នកធ្វើការក្នុងរដ្ឋាភិបាលឬកងទ័ពប្រឆាំងកុម្មុយនីស យកទៅចែកឱ្យកសិករក្រ ។ រដ្ឋាភិបាល យៀម មិនធ្វើការផ្ទេរទាំងនេះទៅវិញទេ ក្រោយឆ្នាំ ១៩៥៤ តែបានប្រគល់ដីទាំងស្រុងទៅឱ្យពួកម្ចាស់ដើមវិញ និងបានជំរុញពួកកសិករណាដែលមានលទ្ធភាពឱ្យទិញដីទាំងនោះផង ។ ថ្វីបើវាធ្វើឱ្យខូចប្រយោជន៍ដល់ពួកកសិករក្រក៏ដោយ ក៏ការនេះបានកាត់បន្ថយអំណាចរបស់ពួកម្ចាស់ដីធំៗ ប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់"កសិករកណ្តាល"នៅជនបទនៃភាគខាងត្បូងវៀតណាមដែលធ្វើឱ្យសភាពការណ៍មានសភាពខុសគ្នាយ៉ាងខ្លាំងពីអ្វីដែលមាននៅទីនោះមុនសន្និសិទទីក្រុងហ្សឺណែវ និងពីភាគខាងជើងនៅពេលមុនការកែទម្រង់ដីធ្លីរបស់ បពវ ។ ដូច្នេះ ទោះបីជានៅពេលធ្វើសមាជ បពវ ដីស្រែ ៥៧% នៃដីសណ្តរទន្លេមេកុងភាគខាងត្បូងវៀតណាម កាន់កាប់ដោយមនុស្សចំនួន ១៥ ភាគរយ ព្រមជាមួយដី ៤៥% ត្រូវបានប្រគល់ទៅឱ្យម្ចាស់ដីធំៗ

ដែលមានដីទំហំលើសពី ៥០ ហិកតាក៏ដោយ ក៏ដីស្រែ ៤២,៥% នៃដីដណ្តារ ជារបស់ម្ចាស់ដីមធ្យមនិងតូចៗ ដែលមានដីពី ៥ ទៅ ១០ ហិកតាដែរ ។ ទោះបីជាមានស្រទាប់ជនបទ ជាគន្ទឹះនៅភាគខាងត្បូងក៏ដោយ ក៏នៅទីនោះមិនមានកសិករក្រនិងក្របំផុត ដូចករណីនៅភាគខាងជើងនាពេលមួយនោះដែរ បពវ បានចាត់វិធានការដូចជាថាភាគខាងត្បូងគឺជាភាគខាងជើង ហើយពុំមានការប្រែប្រួលអ្វីទាំងអស់តាំងពីជំនាន់អាណានិគមនិយមបារាំងមក ។

## សមាជរបស់ខ្មែរ

សមាជរបស់ពួកកុម្មុយនីសខ្មែរបានបង្កើតបក្សពលករខ្មែរ (បពខ) លួចលាក់មួយ ព្រមជាមួយមាគ៌ាទូទៅមួយនៃបដិវត្តន៍ប្រជាធិបតេយ្យប្រជាជាតិប្រជាជន ។ បពខ បានចាត់ទុកសភាពការណ៍នៅកម្ពុជាថា ដូចគ្នានឹងសភាពការណ៍នៅភាគខាងត្បូងវៀតណាម និងបានអះអាងថាមានស្ថានភាពស្មើនឹងបក្ស និងបដិវត្តន៍ វៀតណាមដែរ ។ យោងតាមការកំណត់និយមន័យថ្មីរបស់ប្រជាធិបតេយ្យប្រជាជន នៅអឺរ៉ុបខាងកើតនាចុងទសវត្សរ៍ ១៩៤០ និងសេចក្តីថ្លែងការណ៍របស់ បពវ ស្តីពីទិសដៅរបស់គេ ក្រោយពេលបដិវត្តន៍ប្រជាធិបតេយ្យប្រជាជាតិប្រជាជនដណ្តើមបានជ័យជំនះនៅភាគខាងត្បូង បពខ បានថ្លែងថា ការតស៊ូរបស់ពួកគេនឹងរីកចំរើនឆ្ពោះទៅកាន់ជ័យជំនះសង្គមនិយម និងកុម្មុយនីសនិយម ដូចដែល បពវ បានធ្វើតាំងពីឆ្នាំ ១៩៥៤ នៅភាគខាងជើង ។

ការជ្រើសរើសយកឈ្មោះ បក្សពលករខ្មែរ ជាឈ្មោះរបស់អង្គការ បានបញ្ជាក់អំពីគោលបំណងរបស់ខ្មែរចង់បង្កើតបក្សបដិវត្តន៍ដោយឡែកមួយ ដែលចេញមកពីវណ្ណៈកម្មករ-ដែលពួកវៀតណាមបាននិយាយនៅពេលសមាជ បពវ ឆ្នាំ ១៩៥១ -ហើយដែលពួកគេបានបញ្ជាក់ឡើងវិញនាសមាជឆ្នាំ ១៩៦០ របស់ពួកគេថាវាជាការចាំបាច់ និងសមស្រប ចំពោះប្រជាជាតិតូចឱនថយ និងខ្សោយ ផងទាំងឡាយ ។

ការបង្កើតបក្សមួយបែបនេះមានអត្ថន័យពីរយ៉ាង បើយោងទៅតាមគំរូរបស់ បពវ ឆ្នាំ ១៩៥១។ ទី ១ វាជានិមិត្តរូបនៃបំណងប្រាថ្នារបស់ប្រទេសដែលចង់បានបក្សកុម្មុយនីសឈានមុខសមស្របមួយ ដើម្បីជានាថាការដឹកនាំធ្វើបដិវត្តន៍ស្ថិតក្នុងកណ្តាប់ដៃរបស់វណ្ណៈកម្មករ ។ ដូច្នេះ ដូចដែល នួន បាននិយាយថាការបង្កើត បពខ ត្រូវឈរលើមូលដ្ឋាននៃសេចក្តីសន្និដ្ឋានថា "ចាំបាច់ត្រូវមានបក្សមួយដឹកនាំដោយវណ្ណៈកម្មករ" និងតាម ស ថាការបង្កើតបក្សនេះ ទីបំផុតត្រូវបានសំគាល់ថាជាការមកដល់ក្នុងប្រទេសកម្ពុជានៃ "បក្សម៉ាក្ស - ឡេនីន ពិតប្រាកដមួយ" ដែល ជាផ្លូវការ វាមិនមែនចេញមកពីលទ្ធិម៉ៅនិយម -ដូច បពវ ដែរ -។

ទី ២ សេចក្តីសំរេចបានទទួលស្គាល់ថា ទោះបីជាមានគោលបំណងបែបនេះក៏ដោយ ក៏ប្រជាជនអាចមិនទាន់បានត្រៀមខ្លួនសំរាប់ទទួលយកលទ្ធិកុម្មុយនីសនៅឡើយទេ ។ ការប្រើពាក្យថា បក្សពលករ ជាជាងពាក្យថា បក្សកុម្មុយនីស នោះនឹងសំរួលដល់ការធ្វើសកម្មភាពឃោសនាក្នុងចំណោមពួកអ្នកមិនមែនកុម្មុយនីស ដើម្បីចៀងការភ័យខ្លាចរបស់ពួកគេចំពោះលទ្ធិកុម្មុយនីស ។ ពាក្យថា បក្សកុម្មុយនីស នឹងត្រូវយកមកប្រើ លុះត្រាតែនៅពេលណាដែលលក្ខណៈសម្បត្តិអំណោយផលជាងនេះ ។ ការនេះនឹងកើតមាននៅពេលណាបក្សចេញពីការលាក់ខ្លួន ។ ដោយស្ថិតនៅជាសម្ងាត់ បពខ មិនត្រឹមតែបន្តប្រពៃណីបកឥ ដែលបក្សនេះបានយកកំណើតនោះទេ តែវាក៏ជាការធ្វើតាមនយោបាយរបស់ បពវ ចំពោះបក្សនៅភាគខាងត្បូងដែរ ។

មាគ៌ា បពខ នៃបដិវត្តន៍ប្រជាធិបតេយ្យប្រជាជាតិប្រជាជនតម្រូវឱ្យដោយសភាពការណ៍នៅកម្ពុជា និងឌីណាមិកសង្គម ដាក់ស្តែងវាមិនអាចកាត់ផ្តាច់ពីអ្វីដែលកើតមាននៅភាគខាងត្បូងបានទេ ។ ជាការដោះស្រាយជាមួយការប្រឆាំងខ្វះក្នុងជួរ សមាជបានសន្និដ្ឋានថា រាជាណាចក្រកម្ពុជារបស់សម្តេចសីហនុគឺជារណបរបស់ចក្រពត្តិនិយម ជាពិសេសចក្រពត្តិអាមេរិក ។ ដូចនៅភាគខាងត្បូងវៀតណាមដែរ ប្រទេសនេះជាអាណានិគមនិយមថ្មីរបស់ចក្រពត្តិនិយម មិនឯករាជ្យខាងសេដ្ឋកិច្ច

*វប្បធម៌ នយោបាយ ឬយោធា ទេ ទោះបីជាការនេះផ្ទុយនឹងការជាក់ស្តែងក៏ដោយ ។ ការចម្លងតាម "ការវិភាគជាវិទ្យាសាស្ត្រ" នេះជាការឆ្លើយតបទៅនឹងពួកអ្នកដែល - ដោយចាញ់បោកវណ្ណៈដឹកនាំ ដែលបានលាក់ភាពជារណបរបស់ពួកគេចំពោះចក្រពត្តិនិយម - បានសួរថា តើបក្សធ្វើការតស៊ូប្រឆាំងអ្នកណា នៅក្នុងស្ថានភាពដែលពុំមានបុគ្គលិកយោធានិងរដ្ឋបាលរបស់សហរដ្ឋអាមេរិកក្នុងប្រទេសនោះ ។ ការពិត ការវិភាគនេះបានអះអាងថា ទំនាស់រវាងជាតិកម្ពុជា និងចក្រពត្តិនិយម គឺ -ដូចនៅវៀតណាមដែរ- ស្រួចស្រាវណាស់ និងថាត្រូវតែកំចាត់ចក្រពត្តិនិយមចេញ ដើម្បីរំដោះប្រទេស និងសំរេចនូវការធ្វើបដិវត្តន៍ប្រជាធិបតេយ្យប្រជាជាតិប្រជាជននៅកម្ពុជា ។*

*ទំនាស់ក្នុងសង្គមខ្មែរ-ក្នុងចំណោមសមាសភាពវណ្ណៈសំខាន់ៗ ៥ ដែលវៀតណាមបានរកឃើញថាបានមានវត្តមាននៅកម្ពុជា នាដើមទសវត្ស ១៩៥០ (ពោលគឺ កសិករ កម្មករ នាយទុនជាតិ នាយទុន និងសក្តិភូមិ) - ក៏ត្រូវបានពិពណ៌នាថាជាការពិតដូចដែល បពវ បាននិយាយថាវាបានកើតមាននៅភាគខាងត្បូងវៀតណាមក្នុងទសវត្ស ១៩៦០ ដែរនោះ ។ សមាជ បពខ បានប្រកាសថា ភាពស្មុគ្រស្មាញផ្សេងៗ និងទំនាស់ស្រួចស្រាវនានា ត្រូវបានរកឃើញ ក្នុងនេះរួមមានទំនាស់រវាងកម្មករនិងនាយទុន តែអ្វីដែលគ្របដណ្តប់ និងបដិបក្សជាងគេបំផុតនោះ គឺទំនាស់រវាងកសិករនិងពួកម្ចាស់ដី ។ ដូច្នេះ ការតស៊ូនៅតំបន់ជនបទកម្ពុជា គឺជាការតស៊ូដ៏ចាំបាច់បំផុតរបស់បដិវត្តន៍ ដោយការនេះទាមទារឱ្យចលនាក្នុងចំណោមកសិករដែលតំណាង ៨៥% នៃប្រជាជនទូទាំងប្រទេស ។ ដោយអះអាងថាជាអ្នករងគ្រោះនៃពួកនាយទុន និងពួកម្ចាស់ដីនោះ ពួកគេបានទទួលរងនូវការជិះជាន់ខ្លាំងជាងគេ ព្រមជាមួយវណ្ណៈមួយចំនួនទៀត ។ ម្យ៉ាងទៀត ខ្លឹមសារក្នុងស្រុកសំខាន់ នៃបដិវត្តន៍កម្ពុជា គឺការរំដោះប្រជាជនចំនួន ៨៥% នេះចេញពីពួកម្ចាស់ដី ។*

*សមាជបាននិយាយថាវណ្ណៈកម្មករ មានជាតុពិតវណ្ណៈរបស់គេ គឺជាកម្លាំងដឹកនាំ ជាវណ្ណៈមូលដ្ឋាន និងជាកម្លាំងយុទ្ធសាស្ត្រ របស់បដិវត្តន៍កម្ពុជា ។ ក៏ប៉ុន្តែ ដូចដែល បកឥ បានគូសបញ្ជាក់មកហើយថា សភាពការណ៍នៅកម្ពុជាខុសគ្នានឹងប្រទេសឧស្សាហកម្មៈ វណ្ណៈកម្មករតូចណាស់ ។ ទោះបីជាកម្មករមានភាពសកម្មនៅគ្រប់សហគ្រាសក៏ដោយ ក៏ពួកគេងាយរងទទួលការឈឺចាប់ពីការបង្ក្រាបរបស់ខ្មាំងដែរ ។ ដូច្នេះ ពួកគេមិនអាចជាកម្លាំងស្នូលសំរាប់ការតស៊ូនៅកម្ពុជាទេ ។*

*ទាំងនេះ ធ្វើឱ្យភារកិច្ចនៃបដិវត្តន៍ប្រជាធិបតេយ្យប្រជាជាតិប្រជាជននៅកម្ពុជាដូចគ្នាទៅនឹងអ្វីដែលកើតមាននៅភាគខាងត្បូងវៀតណាមដែរៈ ការប្រយុទ្ធប្រឆាំងចក្រពត្តិនិយម និងពួកម្ចាស់ដីសក្តិភូមិ ។ បពខ បានឯកភាពជាមួយការទទូចរបស់វៀតណាម ដែលថា បដិវត្តន៍ប្រឆាំងសក្តិភូមិមិនអាចកាត់ផ្តាច់ពីបដិវត្តន៍ប្រឆាំងចក្រពត្តិនិយមបានទេ ការប្រឈមមុខនឹងភាពមិនធម្មតារបស់សម្តេចសីហនុ ដោយលើកហេតុផលថា អាចធ្វើបដិវត្តន៍ប្រឆាំងសក្តិភូមិបាន ទន្ទឹមនឹងការរក្សាសម្ព័ន្ធភាពជាមួយសម្តេច ។ ត្រង់នេ ពួកគេបានធ្វើតាមមតិរបស់វៀតណាមដែលថា ឥស្សរជនស្នេហាជាតិអាចមាននៅគ្រប់ស្រទាប់ប្រជាជន និងជាផ្នែកមួយនៃរណសិរ្សរួបរួមប្រឆាំងចក្រពត្តិនិយមដឹកនាំដោយបក្ស ។*

*ដូច្នេះ យោងតាមមាគ៌ារណសិរ្សរួបរួម កំណត់ឡើងដោយ ស និងមានការឯកភាពពី នួន នោះ បពខ ត្រូវខិតខំបង្រួបបង្រួមស្រទាប់និងបុគ្គលស្នេហាជាតិទាំងអស់ ក្នុងនោះរួមមានសម្តេចសីហនុផង ជាមួយកម្មករនិងកសិករ ដើម្បីប្រឆាំងចក្រពត្តិនិយម ។ ចំពោះ បពខ សម្តេចសីហនុ ស្ថិតក្នុងចំណោមសមាជិកពួកអភិជនសក្តិភូមិ និងឥស្សរជនជាន់ខ្ពស់ដទៃទៀត ក្នុងចំណោមវណ្ណៈកាន់អំណាច ក្នុងនោះរួមមានពួកកុំប្រាឌរ និងពួកនាយទុនធំៗ ពួកម្ចាស់ដី មន្ត្រីរាជការស៊ីវិល និងព្រះសង្ឃព្រះពុទ្ធសាសនា ដទៃទៀតដែលមានទស្សនវិស័យស្នេហាជាតិ ចំរើន និងជាតិ ។ បុគ្គលទាំងនេះ ត្រូវបានកំណត់ថាមានឆន្ទៈធ្វើការតស៊ូក្នុងកំរិតណាមួយប្រឆាំងសត្រូវ ដូច្នេះហើយពួកគេអាចត្រូវបញ្ចូលជាកម្លាំងបន្ថែមក្នុងជួររណសិរ្សប្រជាធិបតេយ្យប្រជាជាតិប្រជាជន របស់ បពខ ។ ដូច្នេះ ទោះបីជា បពខ មិនត្រូវពឹងផ្អែកលើសម្តេចសីហនុ ដោយសារតែសម្តេចប្រកាន់យកទស្សនៈ*

អព្យាក្រិត ដែលនាំឱ្យលោកប្រឆាំងចក្រពត្តិអាមេរិកប៉ុណ្ណោះទេ លោកក៏ជាមនុស្សម្នាក់ដែល បពខ ត្រូវទាក់ទាញឱ្យចេញពីក្រុមសក្តិភូមិ ដើម្បីបំបែកបំបាក់ពួកអភិជននាយទុន និងពួកអ្នករកស៊ីចងការប្រាក់ដោយមានអត្រាការប្រាក់ខ្ពស់ដែរ ។

ការវិភាគនេះ ត្រូវបានបរិយាយយ៉ាងល្អិតល្អន់ក្នុងកម្មវិធី[នយោបាយ] បពខ ។ ដោយជួយបន្ទរដល់គម្ពីរនិយមរបស់ បកឥ កម្មវិធីបានអះអាងថា ប្រទេសកម្ពុជាបានស្ថិតក្រោមឥទ្ធិពលរបស់ចក្រពត្តិអាមេរិក តាំងពីឆ្នាំ ១៩៥០ មកម៉្លេះ ។ វណ្ណៈកាន់អំណាចក្រោយសន្និសិទទីក្រុងហ្សឺណែវ ដឹកនាំដោយសម្តេចសីហនុ គឺជាឧបករណ៍របស់ចក្រពត្តិអាមេរិក ប៉ុន្តែសម្តេចសីហនុ និងពួកសក្តិភូមិនិងនាយទុនមួយចំនួននៅជុំវិញសម្តេច នាពេលនោះ ប្រឆាំងអាមេរិក ទោះបីវាគ្រាន់តែជា"របៀបមិនខ្លាំងក្លា" ក៏ដោយ ។ ដូច្នេះ ក្នុងពេលដែល បពខ ឯកភាពជាមួយការវិភាគពីដើមទីរបស់ បពវ ដែលថាឯករាជភាពនៃរបបសម្តេចសីហនុ ត្រូវបានស្ថិតនៅក្រោមខ្សែញាក់របស់សហរដ្ឋអាមេរិកដោយផ្ទាល់ ឬតាមរយៈផលប្រយោជន៍បារាំងនៅសេសសល់ក៏ដោយ ។ ដូច បពវ ដែរ ក្រោយសន្និសិទទីក្រុងហ្សឺណែវ បពខ លែងចាត់ទុកទស្សនៈរបស់វៀតណាមកាលពីពេលមុនដែលថា សម្តេចសីហនុ ជាអាយ៉ងដាច់ថ្លៃរបស់ពិភពចក្រពត្តិនិយមទៀតហើយ ។

### ជាតុពិតនៃរចនាសម្ព័ន្ធសង្គមកម្ពុជា ឆ្នាំ ១៩៦០

ការរៀបរាប់របស់ បពខ អំពីវណ្ណៈកម្មករឧស្សាហកម្មកម្ពុជា គឺសមហេតុសមផលមានកំរិត ។ ដូចសេដ្ឋវិទូបរទេសម្នាក់បានកត់សំគាល់ថា ទោះជាក្នុងពេលសមាជ បពខ វណ្ណៈកម្មជីពបានលេចចេញមកជាបរិមាណ ថាជាលទ្ធផលនៃកម្មវិធីឧស្សាហូបនីយកម្មដឹកនាំជាទូទៅដោយរដ្ឋក៏ដោយ តែពួកគេស្ថិតនៅរាយប៉ាយនៅតាមរោងចក្រថ្មីៗ និងសហគ្រាសខ្នាតតូចនានានៅពាសពេញប្រទេស ។ ក្នុងនិក្ខេបបទបណ្ឌិតរបស់គេ ខៀវ សំផន បានធ្វើការវាយតម្លៃដូចគ្នានេះដែរ ពោលគឺៈ ផ្នែកឧស្សាហកម្មនៅខ្សោយ និងអស្ថេរភាពនៅឡើយ ។ រោងចក្រ រោងសិប្បកម្ម និងកន្លែងជួសជុល មានសភាពដូចគ្នាទៅនឹងប្រទេសអឺរ៉ុបនាសតវត្សទី ១៧ និង ១៨ មិនដូចសហគ្រាសសម័យនៃសតវត្សទី ២០ ទេ ហើយមិនមានការរួមបញ្ចូលគ្នា ស្វ័យភាពទ្រង់ទ្រាយជាជាតិទាំងមូលទេ ។ ការណ៍នេះស្ថិតមានរហូតដល់ចុងទសវត្ស ១៩៦០ នៅពេលមានរោងចក្រឧស្សាហកម្មទំហំធំដោយប្រៀបធៀប ចំនួន ៥៧ នៅទូទាំងប្រទេស និងមានទ្រង់ទ្រាយតូចៗ ចំនួន ៣ ៧០០ តែទាំងនេះស្ថិតនៅរាយប៉ាយនៅឡើយ ។

តែការពិព័ណនារបស់ បពខ អំពីសភាពការណ៍នៅជនបទ គឺខុសទាំងស្រុង ។ ការដកស្រង់យកតម្រាប់តាមវៀតណាមរបស់ពួកគេ បាននាំមកនូវការទាក់ទងទៅនឹងស្ថានភាពជនបទបច្ចុប្បន្នតិចជាងការចម្លងតាមពុម្ពរបស់ បពវ នៅភាគខាងត្បូងវៀតណាមទៅទៀត ។ ដូច បកឥ នៅកម្ពុជាក្នុងសង្គ្រាមឥណ្ឌូចិនលើកទី១, ដូច បពវ ទាក់ទិនទៅនឹងជនបទភាគខាងត្បូងក្នុងឆ្នាំ ១៩៦០ ដែរ ស និង នួន បានយកចិត្តទុកដាក់តែទៅលើការធ្វើបដិវត្តន៍ ជាងសភាពការណ៍ជាក់ស្តែងនៃសង្គមកម្ពុជាតាមពិតទៅពួកគេបានត្រៀមជាស្រេច ហើយថាធ្វើមិនដឹងមិនឮអំពីបញ្ហានេះ ។

ដោយសារថាការនេះមិនជាក់ស្តែង ការរៀបរាប់ក្នុងសមាជ បពខ អំពីជនបទកម្ពុជា ដូចជាការចម្លងមកពីភាគខាងត្បូងវៀតណាមនោះ បានធ្វើឱ្យមានការមិនទុកចិត្តគ្នាយ៉ាងខ្លាំងនៅក្នុងផ្ទៃក្នុងបក្ស រហូតដល់ខ្លាំងជាងអ្វីដែលទាក់ទងទៅនឹងការទទួលរបស់សមាជដែលថា ប្រទេសកម្ពុជាត្រូវបានត្រួតត្រាដោយសហរដ្ឋអាមេរិកទៅទៀត ។ ដូចដែល ស បានទទួលស្គាល់ដែរ ថាសមមិត្តខ្លះមើលមិនឃើញការបែកខ្ញែកគ្នា និងការជិះជាន់វណ្ណៈនៅជនបទទេ ។ ដើម្បីជាការគាំទ្រដល់គោលជំហររបស់គេ ការសិក្សានៃភូមិចំនួនពីរ មួយនៅពាយ័ព្យរបស់ ញឹម និងមួយទៀតនៅបូព៌ារបស់ ភឹម បានអះអាងថាវាបានបង្ហាញថាមានទំនាស់ស្លាប់រស់ដែលចេះតែកើនឡើង រវាងវណ្ណៈម្ចាស់ដី និងវណ្ណៈកសិករ ។ ការសិក្សាទី ១ បានចោទថា នៅក្នុងឃុំថ្មគោល ខេត្តបាត់ដំបង ពួកម្ចាស់ដីមួយក្តាប់តូចបានកាន់កាប់ដី ៩០% ដែលជាស្ថានភាពមួយអាក្រក់និងធ្ងន់ធ្ងរជាងនៅវៀតណាមទៅទៀត ។ ការសិក្សាទី ២ បានអះអាងថា កម្មសិទ្ធិលើដីធ្លីនៅក្នុងមូលដ្ឋានចាស់របស់ បកឥ នៅក្នុងឃុំដូចតី ស្ថិតនៅ

*តាមបណ្តោយព្រំដែនវៀតណាមក្នុងខេត្តកំពង់ចាម បានតម្រូវឱ្យកសិករបង់ប្រាក់ច្រើនហួសដោយមិនប្រណី ចំពោះសេចក្តីត្រូវការបន្តិចបន្តួចដូចជាខោអាវជាដើម ដែលធ្វើឱ្យសូម្បីតែកសិករកណ្តាលក៏ថយមកនៅត្រឹមថ្នាក់ក្រោមកំរិតនៃការរស់រានតែប៉ុណ្ណោះ ។ ជាក់ស្តែង ឧទាហរណ៍នៅពាយ័ព្យក៏ទាក់ទងទៅតែនឹងស្ថានភាពតែមួយគត់នៅឃុំថ្មគោលតែមួយប៉ុណ្ណោះ ។ វាជាបញ្ហានៃជម្លោះដីធ្លីដ៏ល្បីល្បាញមួយ តាំងពីជំនាន់អាណានិគមនិយមក្នុងដំណាក់កាលចុងក្រោយប៉ុណ្ណោះ នៅពេលដែលដីស្រែដ៏ធំទូលាយត្រូវបានដកហូតយកដោយបារាំងដើម្បីធ្វើយន្តកម្មកសិកម្ម ។ សម្តេចសីហនុ បានដោះស្រាយនៅពេលភ្លាមៗនោះ ដោយបញ្ជាឱ្យប្រគល់ដីទាំងនោះទៅម្ចាស់ដើមវិញ ។ រីឯឧទាហរណ៍នៅដូនតីវិញ ពុំមានភស្តុតាងធំដុំណាមួយបញ្ជាក់ថាមានការចែកដីមិនត្រឹមត្រូវទេ ។*

*ទោះបីជាការសិក្សាអំពីភូមិទាំង ២ នេះ មិនឆ្លុះបញ្ចាំងការពិតអំពីភាពជាម្ចាស់ដី ត្រូវបានចាត់ទុកថាជាការបន្ទាប់បន្សំដែលបានកើតឡើងជាទូទៅនៅផ្នែកពាយ័ព្យនិងបូព៌ា ជាងនៅតំបន់ដទៃទៀតក៏ដោយ ក៏វាមិនតំណាងឱ្យអ្វីមួយជាពិសេសហើយការវិភាគឈរលើគោលជំហរជាផ្លូវការរបស់បក្ស ថាសភាពការណ៍នៅកម្ពុជាដូចដែល បពវ និយាយថាបានទទួលនៅភាគខាងត្បូងវៀតណាម ពោលគឺៈ ប្រជាជន ៩០% នៅជនបទ គឺជាកសិករក្រ និងកណ្តាលថ្នាក់ក្រោម ដែលត្រូវជិះជាន់ដោយពួកម្ចាស់ដី ដោយមានជំនួយពីស្រទាប់លើដទៃទៀតនៃសមាសភាពនៅជនបទ ។*

*សេចក្តីសន្និដ្ឋានបែបនេះ ជាការមិនទទួលស្គាល់ការស្រាវជ្រាវដោយប្រុងប្រយ័ត្នខ្ពស់ ដែលបានធ្វើរួចមកហើយដោយ ហ៊ូ យន់ និង ខៀវ សំផន និងក្រោយមកដោយ ហ៊ូ នឹម ។ ថ្វីបើការងាររបស់ពួកគេបានអះអាង - និងប្រហែលជាបំផ្លើសផង - អំពីនិន្នាការឆ្ពោះទៅការបង្កើតឡើងនូវវណ្ណៈនៅទីជនបទ ពួកគេមិនបានប្រៀបប្រដូចជនបទកម្ពុជាទៅនឹងជនបទវៀតណាមទេ។ សមាជ និងក្រោយមក ស និង នួន មិនបានទោរទន់ទៅតាមទិន្នន័យប្រមូលបានដោយពួកបញ្ញាជនអប់រំនៅប្រទេសបារាំងទេ ទោះបីជាដោយពួកអ្នកវិភាគបានឆ្លុះបញ្ចាំងនូវការសន្មត់ជាមុនដែលគន់គូតាមរយៈក្រុមម៉ាក្ស - ឡេនីន នៅទីក្រុងប៉ារីស៍ ក៏ដោយ។*

*ការងាររបស់ ហ៊ូ យន់ និង ហ៊ូ នឹម បានឱ្យយោបល់ថានៅជនបទកម្ពុជា ភាពជាម្ចាស់ដីកំពុងតែកើនឡើង តែនៅមានកំរិតនៅឡើយ និងថាលក្ខណៈជីវភាពសេដ្ឋកិច្ចនិងសង្គមនៅតំបន់ជនបទចេះតែអាក្រក់ទៅ តែការណ៍នេះស្ថិតក្នុងបរិបទនៃការអភិវឌ្ឍន៍ឡើងនូវវណ្ណៈកណ្តាលដ៏ធំទូលាយនៃកសិករម្ចាស់ដីទំហំតូចៗ និងការលេចឡើងនូវវណ្ណៈក្នុងចំនួនដ៏កាន់តែតិចតួចនៃវណ្ណៈកសិករគ្មានដី ឬពលកររកសិកម្មក្រីក្រ ។ ទោះបីជានិន្នាការឆ្ពោះទៅកសិករភាវូបនីយកម្មថ្នាក់កណ្តាលនៅភាគខាងត្បូងវៀតណាមក៏ដោយ ក៏នៅតំបន់ជនបទកម្ពុជាវាត្រូវបានគ្របដណ្តប់ច្រើនលើសលប់ដោយស្រទាប់ម្ចាស់ដីប្រភេទនេះដែរ ។ នេះគឺជាការពិត ទោះបីជាយោងតាមទិន្នន័យគួរឱ្យសង្ស័យខ្លះលើកឡើងដោយ ហ៊ូ យន់, ខៀវ សំផន និង ហ៊ូ នឹម ដែលមិនខ្វល់ដល់ការមួលបង្កាច់ក្នុងការវិភាគណាមួយក៏ដោយ ក៏បានផ្តល់នូវមូលដ្ឋានមួយសំរាប់ធ្វើការប្រៀបធៀបរវាងកម្ពុជា និងភាគខាងត្បូងវៀតណាមបានដែរ ។ ការណ៍នេះ បានផ្តល់ជាយោបល់ថា នៅឆ្នាំ ១៩៦០ គំរូនៃបដិវត្តន៍ប្រជាធិបតេយ្យប្រជាជាតិប្រជាជន បានធ្វើឱ្យមានអត្ថន័យតិចតួចយ៉ាងឆ្ងាយចំពោះកម្ពុជាបើប្រៀបធៀបទៅនឹងវៀតណាម។*

*និក្ខេបបទរបស់ ហ៊ូ យន់ បានផ្តល់ការវិភាគដាច់ខាតបំផុត ដោយអះអាងថានារយៈពេលចុងក្រោយនៃអាណានិគមនិយម ម្ចាស់ដីមានចំនួនស្មើរតែ ១០% នៃចំនួនអ្នកមានកម្មសិទ្ធិដីធ្លីទាំងអស់ ។ ពួកគេធ្វើអាជីវកម្មលើ ៨០% នៃប្រជាជនជនបទដែលរូបគេចាត់ទុកថាជាកសិករក្រ តាមរយៈប្រព័ន្ធនៃការជួល ការប្រវះដៃ និងការចងការប្រាក់ ។ ហ៊ូ យន់ បានទទួលស្គាល់ថាទោះបីជាពុំមានប្រតិបត្តិការប្រភេទនាយទុនធំៗ ដោយប្រើពលកម្មច្រើនក៏ដោយ ក៏ការធ្វើស្រែខ្នាតតូច និងមធ្យមមានចំនួនលើសលប់ដែរ ហើយ "នៅគ្រប់ទីកន្លែង គេអាចកត់សំគាល់ឃើញថា កសិករធ្វើការលើដីរបស់ពួកគេផ្ទាល់តែម្តង"។*

*និក្ខេបបទរបស់ ខៀវ សំផន បានរក្សាតួលេខខ្ពស់រហូតដល់ ១០% ចំពោះពួកម្ចាស់ដីដែលអាចទទួលបាន ដោយសារតែការបញ្ចូលគ្នាជាមួយពួកកសិករក្រតែប៉ុណ្ណោះ ។ ក្នុងគ្រប់ករណី កសិករកណ្តាលដែលគាត់បានប៉ាន់ប្រមាណថាមានចំនួនរហូតដល់ ៦០% នៃប្រជាជននោះ គឺជាក្រុមដែលមានចំនួនច្រើនជាងគេបំផុត ហើយពួកនេះហាក់ដូចជាបានកាន់កាប់ចំណែកដីធំជាងគេ ។ កសិករក្រ គឺជាអប្បភាគជនដោយឡែកមួយ ដែលមានចំនួន ៣០% នៃប្រជាជនជនបទដែលនៅសេសសល់ ព្រមជាមួយដី ២០%។ ដោយបន្ទរតាម ហ៊ូ យន់, ខៀវ សំផន បានចាត់ទុកកសិករកណ្តាល ដែលត្រូវបានជិះជាន់ដោយពួកអ្នកចងការប្រាក់ដោយអត្រាការប្រាក់ខ្ពស់នៅក្នុងភូមិ ថាលែងជាពួកអ្នកកាន់កាប់ដីទំហំធំ ដោយចំរ៉ាញ់យកធនធានតាមរយៈការប្រវះស្រែជាមួយកសិករក្រ ដែលសុខចិត្តលះបង់ដើម្បីជីវភាពរបស់ពួកគេទៀតហើយ ។ ក៏ប៉ុន្តែ រូបគេបានធ្វើឱ្យឃើញភាពខុសគ្នាស្រឡះ ជាពិសេសសភាពការណ៍នៅកម្ពុជា ទៅនឹងសភាពការណ៍នៅភាគខាងត្បូងវៀតណាមដែលរូបគេបានគិតថា "ម្ចាស់ដីធំៗ កាន់កាប់ដីភាគច្រើនលើសលប់ នៅពេលដែលកសិករក្រ ដែលមានចំនួនច្រើនជាង មានតែមួយភាគតូចនៃដីសំរាប់ដាំដុះប៉ុណ្ណោះ" ។*

*នៅទីចុងបំផុត ការវិភាគនាពេលក្រោយមករបស់ ហ៊ូ នីម បានផ្តល់យោបល់ថា នាដើមទសវត្សរ៍ ១៩៦០ ការកើនឡើងការរីកដុះដាលនៃចំនួនម្ចាស់ដីទំហំ ១០ ហិកតា ឬលើសពីនេះ មានន័យថា ៤% នៃគ្រួសារកសិករកាន់កាប់ដីលើសពី ១/៥ នៃដីកសិកម្ម ជាការពង្រឹងការធ្វើអាជីវកម្មសង្គមស្មុគ្រស្មាញ ដោយបូកបញ្ចូលម្ចាស់ដីនិងកសិករមាន ដែលរួមគ្នាមានចំនួន ១៨% នៃកសិករនិងកាន់កាប់ដីស្ទើរតែពាក់កណ្តាលនៃដីដាំដុះក្នុងទ្បូទំហំ ៥ ហិកតា ឬច្រើនជាង ។ ប៉ុន្តែតួលេខនេះ ក៏បានបង្ហាញផងដែរថា សមមាត្រនៃដីរបស់កសិករក្របំផុត (ពួកអ្នកមានដីតិចជាងកន្លះហិកតា) ជាក់ស្តែងបានធ្លាក់ចុះយ៉ាងខ្លាំង នៅពេលដែលជាក់ស្តែង សមមាត្រនៃដីរបស់កសិករកណ្តាល និងកសិករមាន បានកើនឡើងនោះ ។*

*ការស្រាវជ្រាវរបស់អង្គការសហប្រជាជាតិ និងពួកអ្នកស្រាវជ្រាវបច្ចឹមប្រទេស បានបង្ហាញថា ហ៊ូ យន់, ខៀវ សំផន និង ហ៊ូ នីម បាននិយាយបំផ្លើសវិសាលភាពនៃស្រទាប់វណ្ណៈ និងការបែកខ្ញែកវណ្ណៈ និងបានបង្ហាញថា ពួកគេធ្វើយ៉ាងដូច្នេះជាផ្នែកមួយនៃការទទួលខុសត្រូវនៃការជឿជាក់និងសេចក្តីសង្ឃឹមខាងនយោបាយរបស់ពួកគេ ។ អ្នកវិភាគបច្ចឹមប្រទេសម្នាក់បានអះអាងថា ដោយប្រៀបធៀបទៅកន្លែងដទៃទៀតនៃទ្វីបអាស៊ី កម្ពុជានាដើមទសវត្សរ៍ ១៩៦០ ស្ថិតក្នុងដំណាក់កាលនៃការចាប់ផ្តើមបង្ហាញពីស្រទាប់វណ្ណៈប៉ុណ្ណោះ ។ ទោះបីជាវាមានការកើនឡើង ក៏វណ្ណៈពលកររកសិកម្មនិងមិនមែនកសិកម្មមានចំនួនយ៉ាងច្រើន ៤% នៃកម្លាំងការងារសកម្មប៉ុណ្ណោះ ជាក់ស្តែងគឺស្រទាប់វណ្ណៈលើទាំងមូល មានមន្ត្រីរាជការស៊ីវិល ឬអ្នកជំនួញតូចតាចប៉ុណ្ណោះ ។ អ្នកស្រាវជ្រាវម្នាក់ទៀតបានយល់ស្របថា ពួកបញ្ញាជនបានបំផ្លើសសមមាត្រកសិករក្រនិងម្ចាស់ដី ។ តែ ដូចអ្នកស្រាវជ្រាវទី ៣ បានសន្និដ្ឋានថា ការបំភ្លៃរបស់ បពខ បានទៅហួសឆ្ងាយពីពួកអ្នកមានសញ្ញាប័ត្របណ្ឌិតទាំង ៣ នាក់នេះទៅទៀត ជាការឆ្លុះបញ្ចាំងនូវគម្ពីរនិយមមនោគមវិជ្ជារឹងត្អឹងជាងអ្វីដែលកំណត់ ស្តីពីការជឿលើវត្ថុជាទីសក្ការៈឆ្ងាយថែមទៀត ។ ចំពោះ ស និង នួន អ្វីដែលជាទីសក្ការៈនោះគឺ បដិវត្តន៍ប្រជាធិបតេយ្យប្រជាជាតិប្រជាជន ដែលតម្រូវថាទំនាស់បដិបក្សស្លាប់រស់ គឺមានពិតប្រាកដ រវាងពួកម្ចាស់ដីសក្តិភូមិ និងកសិករដែលត្រូវជិះជាន់ ។*

*ក៏ប៉ុន្តែ ទោះបីជាមានមូលដ្ឋានមួយមានឫសគល់នៅជនបទសំរាប់ការប្រឆាំងរបបសង្គមរាស្ត្រនិយម គឺជាបញ្ហាមួយដោយឡែកពីវិសាលភាពដែល ហ៊ូ យន់, ខៀវ សំផន និង ហ៊ូ នីម បាននិយាយបំផ្លើសអំពីសភាពការណ៍នៃជនបទ និងពីការបំភ្លៃរបស់ ស និង នួន អំពីសភាពការណ៍នេះ ។ ទោះបីជាការពិត គឺអវត្តមាននៃប្រភេទនៃការជិះជាន់ដែលអាចពន្យល់បានតាមពាក្យពេចន៍ចម្លងមកពី បពវ ក៏ដោយ ក៏វាអាចមានការមិនសប្បាយចិត្តនៅជនបទនៃកម្ពុជាដែរ ។ ទោះបីជា បពខ បានវាយតម្លៃដោយខុសនូវសក្តានុពលបដិវត្តន៍របស់វណ្ណៈត្រូវជិះជាន់នៅជនបទ ដោយសារថាវណ្ណៈទាំងនេះមានការលំបាកនឹង*

*កើតមានទោះក៏ដោយ ក៏គេអាចយកការមិនសប្បាយចិត្តនោះមកប្រើបាន ក្នុងផ្លូវមួយដែលហាក់ដូចជាដើម្បីផ្តល់សុពលភាពដល់ទ្រឹស្តីមួយឈរលើរូបភាពមួយបំផ្លើសទាំងស្រុង ដែលនាំទៅឱ្យយល់ថានៅទូទាំងប្រទេសកម្ពុជាគឺដូចថ្មគោលទាំងអស់ ។*

*ដោយសង្ឃឹមថាថ្ងៃណាមួយនឹងប្រើប្រាស់ការមិនពេញចិត្តរបស់ប្រជាជនបែបនេះនោះ សមាជ បពខ បានរង់ចាំធ្វើត្រាប់តាមយុទ្ធសាស្ត្រនិងយុទ្ធវិធីរបស់ បពវ នៅភាគខាងត្បូងវៀតណាម ។ ការប្តូរពីការតស៊ូនយោបាយទៅការតស៊ូនយោបាយរួមផ្សំអាវុធ ដែលភាគខាងត្បូងវៀតណាមបានដឹកនាំធ្វើពីឆ្នាំ ១៩៥៦ ដល់ ឆ្នាំ ១៩៦០ គឺជាអ្វីមួយដែលជៀសមិនផុតថាវានឹងកើតឡើងនៅកម្ពុជាដែរ ។*

*ដូច្នេះ សមាជបានទទួលស្គាល់រូបភាពពីរទាក់ទងគ្នាទៅវិញទៅមកនៃការតស៊ូ ពោលគឺ នយោបាយ និងអាវុធ ដោយសន្មត់ថា បពខ នឹងត្រូវ"ដឹកនាំធ្វើសង្គ្រាមប្រជាជន ដើម្បីជំនះលើគ្រប់ឧបសគ្គទាំងអស់ ដោយធ្វើពលីកម្មសព្វបែបយ៉ាង ដើម្បីដណ្តើមជ័យជំនះជាដាច់ខាតនៅទីចុងបំផុត" ។ ដោយសារចក្រពត្តិអាមេរិក អាយ៉ងរបស់ពួកវា និងវណ្ណៈជិះជាន់គ្រប់ប្រភេទប្រើអំណាចផ្តាច់ការ និងកម្លាំង ក្នុងការប៉ុនប៉ងរបស់ពួកគេ ដើម្បីសម្លាប់ និងបំភិតបំភ័យប្រជាជន សកម្មភាពនយោបាយតែម្យ៉ាងនឹងមិនដណ្តើមបានជោគជ័យ ក្នុងការកំទេចនិងផ្តួលរំលំពួកខ្មាំងបដិវត្តន៍ទាំងនេះបានទេ ។ ការណ៍នេះតម្រូវឱ្យប្រែក្លាយ"កម្លាំងបដិវត្តន៍គ្មានអាវុធ ទៅជាកងទ័ពបដិវត្តន៍មួយ" ។ បពខ ត្រូវតែត្រៀមខ្លួនជាស្រេច ដើម្បីប្រើគ្រប់រូបភាពនៃការតស៊ូនយោបាយ សេដ្ឋកិច្ច និងប្រដាប់អាវុធ ។ តាម ស "រូបភាពទី ១ នៃការតស៊ូទាមទារ គឺការប្រើហឹង្សាបដិវត្តន៍ តាមរយៈនយោបាយ" តែហឹង្សាបដិវត្តន៍ប្រដាប់អាវុធ ថ្ងៃណាមួយនឹងត្រូវដើរតាមក្នុងរូបភាពជាការតស៊ូនយោបាយផង និងការតស៊ូប្រដាប់អាវុធផង ។*

## *ការអនុវត្តន៍មាគ៌ារបស់ បពខ ចាប់ពីសមាជ រហូតដល់មរណភាពរបស់ ទូ សាមុត*

*ដូច្នេះ សមាជ បពខ បានលើកគំនិតថានឹងធ្វើតាមគន្លងរបស់ បពវ នៅភាគខាងត្បូង: ទី ១ ការផ្លាស់ពីស្វ័យការពារប្រដាប់អាវុធ និងការឃោសនាប្រដាប់អាវុធ បន្ទាប់មកជំរុញទៅមុខទៅឱ្យមានការបញ្ចូលដោយស្មើគ្នាការតស៊ូនយោបាយ និងការតស៊ូដោយអាវុធ និងទីបញ្ចប់បើកធ្វើសង្គ្រាមប្រជាជនដោយពេញបន្ទុកតែម្តង ដើម្បីធ្វើការតស៊ូដោយអាវុធ តាមរូបភាពបញ្ចូលដោយ បកត មកកម្ពុជានាទសវត្ស៍ ១៩៤០ ។ ជាការពិត ការនេះស្របទៅនឹងអ្វីដែលវៀតណាមបានប្រកាសកាលពីពេលថ្មីៗនេះ ថាជា"ច្បាប់បដិវត្តន៍ទូទៅ" មួយ ពោលគឺ: ជាការជៀសមិនផុតទេ ដែលថាបដិវត្តន៍ត្រូវត្រឡប់ទៅរកហឹង្សាវិញបានទេ ។ ទាំងនេះគឺឈរលើមូលដ្ឋាននៃការស្មងមតិមួយក្នុងជួរ បពខ ថាទោះបីជាមានវិស័យនានានៃសក្តានុពលរួបរួមជាមួយសម្តេច សីហនុ ក៏ដោយ ក៏ការខកខានមិនបានធ្វើការត្រៀមរៀបចំសំរាប់ធ្វើការតស៊ូដោយអាវុធនោះ វានឹងជាការធ្វើអត្តឃាដចំពោះខ្លួន។*

*សញ្ញាមួយទៀតនៃបំណងដើរតាមគន្លង បពវ គឺការអះអាងរបស់ពួកកុម្មុយនីសកម្ពុជា ថានឹងពឹងផ្អែកលើជនជាតិភាគតិចដែលរស់នៅលើភ្នំតាមព្រំដែនរវាងភូមិភាគឦសានកម្ពុជា និងខេត្តតាយនិញនៃវៀតណាមកណ្តាល ។ នៅទីនេះ កម្មវិធីរបស់ បពខ គឺការរួមបញ្ចូលគ្នានៃប្រធានបទប្រើប្រាស់ដោយវៀតណាម ក្នុងពេលសង្គ្រាមឥណ្ឌូចិនលើកទី ១ និងចាប់តាំងពីចុងទសវត្ស៍ ១៩៥០ មក ដែលថាបដិវត្តន៍ត្រូវយកចិត្តទុកដាក់ជាពិសេសចំពោះបញ្ហាជាតិពន្ធ និងចលនាអប្បភាគជនឱ្យទៅជាកម្លាំងបដិត្តន៍ ។ ពួកគេរស់នៅក្នុងតំបន់ទាំងនោះដែលមានតម្លៃខាងយុទ្ធសាស្ត្រសំខាន់ណាស់ និងអាចចលនាបានដោយសារពួកគេជាកម្មវត្ថុរបស់ពួកចក្រពត្តិ និងទទួលរងការជិះជាន់ដ៏ធ្ងន់ធ្ងរពីសំណាក់ពួកសក្តិភូមិ ពួកគេមានន្និនាការប្រឆាំងចក្រពត្តិ និងប្រឆាំងសក្តិភូមិ និងបានចិញ្ចឹមកំហឹងជាពិសេសចំពោះទាហាននិងប៉ូលីសនៃរបបកាន់អំណាច ។*

ទន្ទឹមនេះ ការសង្កត់ធ្ងន់ជាងគេគឺការតស៊ូនយោបាយអហឹង្សា ។ ទោះបីជាត្រូវប្រឈមមុខ ចំពោះការបង្ក្រាប ដូចពួកភាគខាងត្បូងវៀតណាមក៏ដោយ ក៏ជនកម្ពុជាត្រូវបន្តអនុវត្តន៍មាគ៌ាដែលពួកភាគខាងត្បូង បានបោះបង់ចោលទៅហើយដែរ ។ កម្មវិធីរបស់ បពខ បានអះអាងថាអាទិភាពនៃការតស៊ូនយោបាយដោយសន្តិវិធី ត្រូវស្ថិតលើការតស៊ូមិនមែនសន្តិវិធី ។ ដោយបន្ទរតាមគោលជំហររបស់ អៀង សារី ពួកគេបានសន្យាថានឹងជៀសវាងរូបភាពនៃការតស៊ូណាដែលអាចនាំទៅឱ្យមានការបាត់បង់ជីវិតប្រជាជនក្នុងចំនួនច្រើន ។ សកម្មភាពមិនមែនសន្តិភាព ត្រូវបានចាត់ទុកជាជំរើសស្របច្បាប់ចុងក្រោយបំផុត ដែលបដិវត្តន៍កម្ពុជាត្រូវតែរៀបចំខ្លួនជានិច្ចដើម្បីប្រកាន់យក តែល្គឹកណាតែ "ពួកចក្រពត្តិនិយម សក្តិភូមិនិយម នាយទុនកុំប្រាឧរ និង វណ្ណៈគហបតីប្រតិកិរិយាដទៃទៀត ចចេសបង្ខំឱ្យបដិវត្តន៍ចាប់យករូបភាពនោះ តែប៉ុណ្ណោះ" ។

នៅឆ្នាំ ១៩៦០ បពខ បានចាប់យកជំហានទី ១ ក្នុងទិសធ្វើការតស៊ូដោយអាវុធ ដោយបង្កើតកងស្វ័យការពារ ដើម្បីធានាសុវត្ថិភាពកម្មាភិបាល ការិយាល័យ ទីកន្លែងសំរាប់ប្រជុំ និងធ្វើជានិរសា ។ កិច្ចការរបស់ពួកគេ គឺដូចគ្នាទៅនឹងបុគ្គលិកស្វ័យការពារបង្កើតឡើងនៅខែសីហា ឆ្នាំ ១៩៥៦ នៅភាគខាងត្បូងវៀតណាម តែ បពខ មិនបានបង្កើតអង្គភាពប្រភេទជាអង្គភាពឃោសនាប្រដាប់អាវុធ ដែលភាគខាងត្បូងវៀតណាមបានបង្កើតនៅក្នុងខែធ្នូនៃឆ្នាំដដែលនោះទេ ។ កងស្វ័យការពារប្រដាប់អាវុធ នឹងស្ថិតនៅតែជាជំហានយោធាសម្ងាត់ ធ្វើឡើងដោយជនកម្ពុជា ផ្តោះទៅការធ្វើសង្គ្រាមប្រជាជន រហូតដល់ឆ្នាំ ១៩៦៨ តែប៉ុណ្ណោះ ។ ក្នុងរយៈពេលនេះ កងការពារខ្លះ ត្រូវបានបង្កើតជាអង្គភាពមានគ្នា ៣ នាក់ បង្កប់ខ្លួននៅតាមភូមិមូលដ្ឋានរបស់បក្ស និងនៅទីក្រុង តែត្រូវបានបំពាក់ត្រឹមតែអាវុធជាកាំបិត, ដំបង និងដុំថ្ម ប៉ុណ្ណោះ ។ ដោយធ្វើតាមយុទ្ធវិធីប្រើដោយ បពវ នៅភាគខាងត្បូង កងស្វ័យការពារខ្លះបានបង្កប់ខ្លួនក្នុងជួរកងស្វ័យត្រាណរបស់រដ្ឋាភិបាលតាមរយៈការធ្វើវិច្ឆេតកម្មឬវិទ្ធ័ង្សនា ដែលពួកគេដើរតួជាអ្នកការពារកម្មាភិបាលនិងអ្នកដឹកនាំ និងធ្វើឱ្យតំបន់មូលដ្ឋានមានការអភិវឌ្ឍន៍ ។

ទន្ទឹមនេះ ការតស៊ូនយោបាយរបស់ បពខ ត្រូវបានធ្វើឡើងតាមរយៈការតស៊ូស្របច្បាប់និងមិនស្របច្បាប់ ដោយប្រើរូបភាពមិនស្របច្បាប់ជាមូលដ្ឋាន នៅក្នុងទីក្រុងក៏ដូចជានៅជនបទ ។ មានការតស៊ូចំហ ពាក់កណ្តាលចំហ និងសម្ងាត់ ដោយយករូបភាពចុងក្រោយនេះជាសំខាន់ ។ ការលើកឡើងនូវសកម្មភាពមិនស្របច្បាប់និងសម្ងាត់ គឺជាការយកតម្រាប់តាមការអនុវត្តន៍នៅភាគខាងត្បូងវៀតណាមតាំងពីឆ្នាំ ១៩៥០ និងការធ្វើជាបន្តកាន់តែខ្លាំងឡើងរហូតដល់ចុងទសវត្ស ១៩៥០ ។ ការនេះតម្រូវឱ្យមានការបែងចែកជាពីរដូចគ្នា រវាងសាខាក្រុមប្រជាជនរបស់ កែវ មាស និង សាខារបស់គណៈកម្មាធិការបក្សសម្ងាត់ទីក្រុងភ្នំពេញ របស់ ប៉ុល ពត ។

ការតស៊ូស្របច្បាប់ និងចំហ ត្រូវតែប្រើរូបភាពច្រើន និងសម្បូរបែប ក្នុងនេះរួមមាន ការបន្តធ្វើកាសែត ការចូលរួមការបោះឆ្នោត ការបង្កប់ខ្លួនក្នុងជួររដ្ឋាភិបាល និងសេវាកម្មស៊ីវិល និងបង្កើតសមាគម ឬធ្វើវិច្ឆេតកម្មជាចំហ ។ ការនេះមានរួមបញ្ចូលការទទូចរបស់សមាជ បពខ អំពីការតស៊ូតាមសភា ថាជាការតស៊ូមួយដែលបក្សត្រូវតែធ្វើ ដោយមានការគាំទ្រដោយការតស៊ូតាមការសរសេរកាសែត ដើម្បីទាក់ទាញមតិមហាជន ។ សកម្មភាពបែបនេះត្រូវតែដឹកនាំធ្វើ ទោះបីជាគោលការណ៍វាគ្រាន់តែជាការបន្ទាប់បន្សំ និងចំណុះឱ្យអង្គការកសិករសម្ងាត់និងមិនស្របច្បាប់ ដើម្បីរៀបចំសំរាប់យថាហេតុនៃការប្រើហឹង្សាដើម្បីផ្តួលរំលំរបបនៅនឹងកន្លែង ។ ការមិនយកចិត្តទុកដាក់ចំពោះការងារស្របច្បាប់និងចំហ គឺជាទ្រឹស្តីឆ្វេងនិយមខុសឆ្គងមួយ ទោះបីជាការបំផ្លើសអត្ថន័យរបស់វាត្រូវបានកំណត់ថាជាការងាកវេទៅរកស្តាំនិយមក៏ដោយ ។

ការជៀសវាងមធ្យោបាយចុងក្រោយនេះ មានន័យថាកម្មាភិបាល បពខ ភាគច្រើនលើសលប់ ត្រូវចូលបង្កប់ខ្លួនជាសម្ងាត់ក្នុងចំណោមប្រជាជន និងដាស់ពួកគេតាមរយៈការឃោសនាមិនស្របច្បាប់ដែលមានខ្លឹមសារវណ្ណៈ ឧទាហរណ៍និយាយអំពីការផ្តួលរំលំពួកវណ្ណៈជិះជាន់ ។ ការញ៉ាំងឱ្យមានការផ្លាស់ប្តូរបែបនេះ ត្រូវដឹកនាំធ្វើជាបឋមនៅតំបន់ជនបទ ប៉ុន្តែនៅទីក្រុងក៏ត្រូវធ្វើដូច្នេះដែរ ។ កម្មាភិបាលភាគច្រើនលើសលប់ ត្រូវបានចាត់តាំងឱ្យទៅតំបន់ជនបទ ដើម្បីធ្វើការក្នុងចំណោម

*កសិករក្រ ក្នុងការស្ថាបនាមូលដ្ឋាននៅជនបទដាច់ស្រយ៉ាលដាច់គេ ដើម្បីជំរុញចលនាមួយប្រឆាំងពួកម្ចាស់ដី ដោយឈរលើពាក្យស្លោក: ត្រូវឱ្យដីទៅកសិករ ធ្វើឱ្យស្រូវមានតម្លៃខ្ពស់ និងលក្ខណៈរស់នៅកាន់តែល្អប្រសើរឡើង ។ មូលដ្ឋានបង្កើតឡើងដូច្នេះ ក៏ជាកន្លែងដើម្បីទទួលប្រជាជនដែលចូលរួមធ្វើការងារសម្ងាត់ក្នុងទីក្រុង នៅពេលណាការបង្ក្រាបបង្ខំឱ្យពួកគេត្រូវតែរត់ចេញនោះ ។ ដូច្នេះ ចាប់តាំងពីឆ្នាំ ១៩៦០ មក សកម្មភាពសំខាន់របស់បក្សត្រូវបានបំពាក់បំប៉នដោយមនោគមវិជ្ជា ការជៀសវាង និងការអនុវត្តន៍មាគ៌ានយោបាយរបស់បក្ស ដោយផ្តល់ការយកចិត្តទុកដាក់ ទាំងចំពោះការចាត់តាំងកម្លាំងនៃសមរភូមិមុខ និងចំពោះការងាររៀបចំឡើងវិញនិងការតម្រង់ទិសសភាពការណ៍ នៃការរៀបចំជាអាទិភាពទី ១ នៅជនបទ ដែលមានភាពច្របូកច្របល់ដោយ ស៊ីវ ហេង ក្បត់នោះ ។ ទោះបីជាមាគ៌ារបស់ បពខ បានបញ្ជាក់អំពីតម្រូវការដាច់ខាតនូវការតស៊ូដោយអាវុធ ក៏នៅមានការងារមនោគមវិជ្ជាជាច្រើនទៀតដែលត្រូវធ្វើនៅឡើយ មុននឹងជំរុញឱ្យធ្វើការតស៊ូដោយអាវុធនេះ ដែលជាការងារដែលត្រូវធ្វើក្នុងពេលធ្វើការតស៊ូកែទម្រង់ដីធ្លី សិទ្ធិប្រជាធិបតេយ្យ និងដើម្បីទទួលបានជីវភាពរស់នៅល្អប្រសើរ ដឹកនាំដោយបក្ស ។ ទាំងនេះគឺជាមូលដ្ឋានដែលបក្សត្រូវធ្វើ សំរាប់ការតស៊ូដោយអាវុធ ដើម្បីនាំទៅដណ្តើមបានអំណាចនយោបាយ ។*

*សមាជឆ្នាំ ១៩៦០ ក៏បានបង្កើតឡើងនូវគណៈកម្មាធិការមជ្ឈឹម បពខ មួយមានសមាសភាពមនុស្ស ៦ នាក់ ដែលមាន ទូ ជាលេខា និង នួន ជាអនុលេខា ។ រួមជាមួយ ស ពួកគេជាសមាសភាពនៃគណៈកម្មាធិការអចិន្ត្រៃយ៍នៃគណៈកម្មាធិការមជ្ឈឹម ។ សមាជិកឯទៀតនៃគណៈកម្មាធិការមជ្ឈឹមរួមមាន អៀង សារី និង កែវ មាស ពីអង្គការទីក្រុង កម្មាភិបាលពីរនាក់មកពីតំបន់មូលដ្ឋាននៃនិរតីទិស និង ភឹម មកពីបូព៌ាទិស ។ ក្នុងរយៈពេលក្រោយសមាជ នួន បានប្រមូលផ្តុំទៅលើជនបទ និងបានទៅធ្វើទស្សនៈកិច្ចនៅភូមិភាគនិរតី និង ពាយ័ព្យ ក្នុងពេលដែល ស ប្រមូលផ្តុំទៅលើទីក្រុង ។*

*ភ្លាមៗបន្ទាប់ពីសមាជ ឱកាសសំរាប់រៀបចំការបង្កប់ខ្លួននៅក្នុងទីក្រុងភ្នំពេញមានសភាពល្អបង្គួរ ជាពិសេសក្នុងចំណោមនិស្សិត និងគ្រូបង្រៀនជំនាន់ថ្មី ដោយពួកគេភាគច្រើនមានការស្អប់ខ្ពើមភាពអយុត្តិធម៌ និងអំពើពុករលួយ ដែលជាលក្ខណៈនៃរបបសង្គមរាស្ត្រនិយម ។ វោហាសាស្ត្រប្រឆាំងចក្រពត្តិ និងការវាយប្រហារសង្គមដ៏ខ្លាំងៗ ធ្វើឡើងដោយ ហ៊ូ យន់, ហ៊ូ នឹម និង ខៀវ សំផន បានអំណោយផលដល់ពួកគេក្នុងការជ្រើសរើសមនុស្សឱ្យចូល បពខ ដោយជួយបើកឱ្យពួកគេធ្វើការពន្យល់ដាច់ខាតកាន់តែខ្លាំងថែមទៀត ចំពោះអ្វីដែលពួកគេបានឃើញ និងបានធ្វើឱ្យពួកគេត្រៀមលក្ខណៈធ្វើសកម្មភាពបដិវត្តន៍គំរូប្រឆាំងរដ្ឋាភិបាលមួយ ដែលមិនអនុញ្ញាតឱ្យមានការប្រឆាំងអ្វីទាំងអស់នោះ ។ អ្នកស្រែចំការដែលហាក់ដូចជាត្រូវបានផ្តន្ទាទោស ដោយការធ្វើការធ្ងន់អស់មួយជីវិតដោយទទួលបានកម្រៃនិងចំណូលតិច និងបានឯកភាពជាមួយទស្សនៈវិស័យរបស់ពួកនិស្សិត ថារបបនោះជាវេវចនៈនៃពាក្យថាពុករលួយ ដែលបានផ្តល់ឱកាសឱ្យមានលទ្ធភាពជ្រើសរើសពួកគេបាន មិនថាពួកគេចេញពីស្រទាប់វណ្ណៈណាទេ ។*

*នៅពេលវៀតណាមបង្កើនសកម្មភាពតស៊ូដោយអាវុធរបស់ពួកគេ នៅភាគខាងត្បូងវៀតណាម ខ្មែរមានការរីកចំរើនក្នុងការតស៊ូនយោបាយសុទ្ធសាត និងបានបង្កើនល្បឿនឆ្ពោះទៅការបោះឆ្នោតលើកក្រោយ ដែលគ្រោងនឹងធ្វើនៅឆ្នាំ ១៩៦២ ។ អង្គការបក្សជាច្រើន ក្រោមការដឹកនាំរបស់ ស នៅតំបន់ទីក្រុង និងនៅជនបទខ្លះ បានបន្តបំពេញភារកិច្ចដឹកនាំប្រជាជនក្នុងការបោះឆ្នោត ដូចនៅឆ្នាំ ១៩៥៥ និង ១៩៥៨ ដែរ ។*

*នៅចុងឆ្នាំ ១៩៦១ ក្រុមប្រជាជនបានទទួលសេចក្តីណែនាំពី ទូ តាមរយៈគណៈកម្មាធិការបក្សក្រុងសម្ងាត់របស់ បពខ អំពីកម្មវិធីដែលពួកគេត្រូវអនុវត្តទាក់ទងទៅនឹងការបោះឆ្នោតនេះ ។ កែវ មាស បានកោះប្រជុំជាមួយសមាជិកជាសក្តានុពល ៤ នាក់ផ្សេងទៀត ដើម្បីពិភាក្សាអំពីសកម្មភាពនៃយុទ្ធនាការសំរាប់ការបោះឆ្នោតនេះ ។ ប៉ុន្តែ រហូតមកទល់ពេលនេះ សម្តេចសីហនុបានបើកធ្វើយុទ្ធនាការល្អជាស្រេចហើយ ក្នុងការនិយាយអាក្រក់ពីក្រុមប្រជាជន ។ ការនេះបានចាប់ផ្តើមតាំងពីពាក់*

*កណ្ដាលឆ្នាំ ១៩៦១ មកម្ល៉េះ នៅពេលទ្រង់បានអំពាវនាវឱ្យសង្គមរាស្ត្រនិយមវាយប្រហារប្រឆាំង"កាសែតប្រជាជន"។ នៅក្នុងសមាជជាតិពិសេសមួយរបស់សង្គមរាស្ត្រនិយម ទ្រង់បានបំភិតបំភ័យជាចំហបេក្ខជនម្នាក់ឈ្មោះ នង់ សួន ក្នុងចំណោមពួកអ្នកមានបំណងឈរឈ្មោះក្នុងការបោះឆ្នោត ដែលត្រូវបានឡោមព័ទ្ធដោយមនុស្សរាប់ពាន់នាក់ដែលជាពួកអ្នកគាំទ្រសង្គម ដោយការស្រែកចំអក និងគំរាមវាយទៅលើរូបគាត់ ។*

*នៅខែមករា ឆ្នាំ ១៩៦២ សម្ដេចសីហនុ បានប្រកាសថាការបោះឆ្នោតនឹងប្រព្រឹត្តទៅនៅខែមីនា ។ ការបង្ក្រាបដោយមិនរើសមុខ និងជាសាធារណៈដ៏ខ្លាំងបំផុតលើក្រុមប្រជាជន និងអង្គការបក្សដទៃទៀត ដែលបានចូលរួមក្នុងការបោះឆ្នោត ដោយចំហ និងសម្ងាត់ បានធ្វើឡើងនាពេលភ្លាមៗនោះដែរ ។ នេះគឺជាផ្នែកនៃការប្រព្រឹត្តដោយកំពោលប្រឆាំង បព១ ដែលបានប៉ះពាល់យ៉ាងធ្ងន់ធ្ងរជាពិសេសដល់បណ្ដាញរបស់បក្ស សំខាន់ជាងគេបំផុតៈ របស់ ស នៅក្នុងរាជធានី របស់ ភឹម នៅខេត្តកំពង់ចាមនៃភូមិភាគបូព៌ា និងនៅខេត្តតាកែវនៃភូមិភាគនិរតី របស់តាម៉ុក ។*

*ភ្លាមៗបន្ទាប់ពីការរៀបចំការបោះឆ្នោត សម្ដេចសីហនុ បានប្រកាសចាប់ខ្លួនសកម្មជនក្រុមប្រជាជន ១៤ នាក់នៅក្នុងខេត្តកំពង់ចាម ការក្រសោបចាប់នេះគឺជាលទ្ធផលនៃការតាមដានយ៉ាងប្រពលកម្មរបស់ប៉ូលីស លើបណ្ដាញទាក់ទងរបស់ក្រុមនេះជាមួយថ្នាក់ដឹកនាំបក្សលួចលាក់ និងអង្គការសម្ងាត់នៅជនបទ ។ ពួកអ្នកជាប់ឃុំទាំងនោះ គឺជាផ្នែកនៃបណ្ដាញបក្សស្រុកមួយ ។ តាមការសួរចម្លើយ ពួកគេបានឆ្លើយប្រាប់ប៉ូលីសថាពួកគេបានធ្វើការកោះប្រជុំក្រោមការដឹកនាំរបស់ នង់ សួន ដើម្បីរៀបចំការបោះឆ្នោតនៅក្នុងខេត្ត ។ ការណ៍នេះបាននាំទៅឱ្យមានការចាប់ខ្លួន នង់ សួន ភ្លាមៗនោះដែរ ។ សម្ដេច សីហនុ បានប្រកាសថា បានរកឃើញឯកសារដែលនៅជាប់ជាមួយពួកអ្នកជាប់ឃុំ និយាយអំពីផែនការនៃការធ្វើវិច្ឆេតកម្មទូទៅ ហើយបានគំរាមថានឹងសម្លាប់ពួកគេទាំងនោះ ។ ទន្ទឹមនេះ បណ្ណាធិការកាសែតប្រជាជនក៏ត្រូវបានចាប់ឃុំដែរ និងមានការចាប់ខ្លួនជាច្រើននាក់ទៀតនៃក្រុមដែលត្រូវចោទថាជាក្រុមប្រតិបត្តិការ ត្រូវបានធ្វើឡើងនៅក្នុងខេត្តព្រៃវែង និងស្វាយរៀង នៃភូមិភាគបូព៌ា ។ ជាការវាយតម្លៃចំពោះការបង្ក្រាបនេះ ស្ថានទូតសហរដ្ឋអាមេរិកបានអត្ថាធិប្បាយថា "ការជួនគ្នារវាងការបោះឆ្នោតដែលនឹងមកដល់ និងការរកឃើញផែនការធ្វើការអុកឡុក បង្កឡើងដោយក្រុមប្រឆាំងសង្គមរាស្ត្រនិយមតែមួយគត់ដែលត្រូវបានទទួលស្គាល់នោះ ហាក់ដូចជាការគ្រប់គ្រាន់ពេកទៅហើយ" ។ ការវាយតម្លៃបានកត់សំគាល់ថា ការកៀបសង្កត់កាន់តែខ្លាំងឡើង បានធ្វើឱ្យសម្លេងរបស់កាសែតឆ្វេងនិយមរួញខ្លួនលែងហ៊ាននិយាយអ្វីទាំងអស់ ។ នៅពេលសម្ដេចសីហនុ បន្តធ្វើការវាយប្រហារក្រុមប្រជាជន និងចាត់ទុកសមាជិកក្រុមនេះថាជាជនក្បត់ ក្នុងសុន្ទរកថារបស់សម្ដេចនៅតាមខេត្តនានា ដោយទ្រង់បានអំពាវនាវឱ្យប្រជាជនបោះឆ្នោតឱ្យបេក្ខជនរបស់សង្គមរាស្ត្រនិយមនោះ កាសែតប្រជាជនបានសាកល្បងបដិសេធថាក្រុមរបស់ពួកគេមិនដែលប្រឆាំងរដ្ឋាភិបាលម្ដងណាទេ តែទោះជាយ៉ាងនេះក៏ដោយ ក៏កាសែតនេះត្រូវបានបិទនៅក្នុងខែកុម្ភៈដែរ។*

*បន្ទាប់មក ជាក់ស្ដែង នៅចុងខែកុម្ភៈ ទូ ដែលជាលេខាបក្សត្រូវបានចាប់ខ្លួន និងសម្លាប់ដោយក្រុមសន្តិសុខសម្ងាត់របស់សម្ដេចសីហនុ ដោយធ្វើតាមព័ត៌មានផ្ដល់ឱ្យដោយ ស៊ីវ ហេង និងប្រហែលជាដោយព័ត៌មានទទួលបានក្នុងការសួរចម្លើយក្រុមប្រជាជន និងពួក បព១ ដែលជាប់ឃុំដទៃទៀត ។*

## *ការដកខ្លួនចេញពីការបោះឆ្នោត ការពឹងផ្អែកលើពួកបញ្ញាជន ការកោះប្រជុំសមាជម្ដងទៀត*

*ទោះបីជាមហន្តរាយបែបនេះក៏ដោយ ក៏ក្រុមប្រជាជននៅតែដាក់ផែនការនៅដើមខែមីនា ដើម្បីឱ្យបេក្ខជនរបស់គេ ៤ ឬ ៥ នាក់ ចូលរួមការបោះឆ្នោតនោះដែរ ទោះបីជាពួកគេអាចត្រឹមតែធ្វើសកម្មភាពបន្តិចបន្តួចក៏ដោយ ។ ពេលនោះ ការបោះឆ្នោតបានពន្យារពេលរហូតដល់ខែមិថុនា ។ កាលបរិច្ឆេតថ្ងៃឈប់ទទួលពាក្យសំរាប់ការចុះឈ្មោះបេក្ខជន និងកាលបរិច្ឆេតនៃការបើកធ្វើយុទ្ធនាការជាផ្លូវការ ត្រូវបានកំណត់ធ្វើនៅខែមេសា ។ ពេលកាលបរិច្ឆេតនេះកាន់តែខិតចូលមកជិតដល់ ប៉ូលីស*

*បានចាប់ខ្លួនបណ្ណាធិការកាសែត បញ្ញាសីលា ដឹកនាំដោយ បព២ ដែលបានបង្ខំឱ្យកាសែតនេះបញ្ឈប់ការផ្សាយរបស់ខ្លួន ។ ពេលកំពុងដំណើរការកាត់ទោស នង់ សួន និងពួកអ្នកជាប់ឃុំមកពីខេត្តកំពង់ចាមនោះ រដ្ឋាភិបាលបានធ្វើការវិនិច្ឆ័យសេចក្តី និងផ្តន្ទាទោសបណ្ណាធិការកាសែតនេះ ។ ច្បាស់ណាស់ ការណ៍នេះត្រូវបានធ្វើឡើងដើម្បីរក្សាការគៀបសង្កត់លើចលនាកុម្មុយនីស ទន្ទឹមគ្នានឹងការបណ្តេញចេញជាបន្តបន្ទាប់នូវ "និមិត្តរូបនៃក្រុមប្រឆាំងចំហភ្លាមៗមុនរយៈកាលនៃការបោះឆ្នោតត្រូវបានប្រព្រឹត្តឡើង" ។ ក្នុងពេលជាមួយគ្នានោះ សកម្មជន បព២ មួយក្រុមទៀត ត្រូវបានចាប់ខ្លួននៅខេត្តកំពង់ចាម ។ ទីបញ្ចប់ ដោយមិនចង់ផ្តល់អំណោយផលអ្វីមួយដល់ពួកនេះ ក្រសួងមហាផ្ទៃបានរៀបចំមណ្ឌលបោះឆ្នោតជាថ្មីឡើងវិញ ដើម្បីធានាថាភ្នំពេញមិនត្រូវឱ្យមានតំណាងច្រើន ដូច្នេះបន្ថយឥទ្ធិពលរបស់ក្រុមប្រជាជន កុំឱ្យសភាពការណ៍ ឆ្នាំ ១៩៥៨ កើតឡើងជាថ្មីម្តងទៀត ដែលក្រុមប្រជាជនទទួលបានសម្លេងច្រើនយ៉ាងច្បាស់នោះ ។ ប៉ុន្តែ ទីបំផុតពុំមានបេក្ខជនខាងក្រុមប្រជាជនណាម្នាក់អាចចុះឈ្មោះបានទេ មុនកាលបរិច្ឆេទដែលបានកំណត់នោះ ។*

*ពីរអាទិត្យក្រោយកាលបរិច្ឆេទនៃបិតការទទួលពាក្យជាបេក្ខជន តុលាការសឹកបានកាត់ទោសប្រហារជីវិត នង់ សួន និងមនុស្ស ១៤ នាក់ទៀត ដែលត្រូវបានចាប់ខ្លួននៅខេត្តកំពង់ចាមកាលពីដើមខែមករា ពីបទធ្វើការប្រជុំក្នុងបំណងក្បត់ ។ ការវិនិច្ឆ័យទោសនេះ ហាក់ដូចជាត្រូវបានធ្វើឡើងដើម្បីបំពេញចិត្តសម្តេចសីហនុ ដើម្បីជាមេរៀនដល់អ្នកដទៃទៀតឱ្យពិចារណាឡើងវិញក្នុងការធ្វើសកម្មភាពប្រឆាំងជាចំហ ក្នុងរយៈពេលយុទ្ធនាការបោះឆ្នោតដែលនៅសេសសល់ ។ ដូចស្ថានទូតសហរដ្ឋអាមេរិកបានរាយការណ៍: "ការខកខានរបស់ក្រុមប្រជាជន ដើម្បីដាក់បេក្ខភាពចំនួន ៤ នាក់របស់ពួកគេ មិនមានអ្វីគួរឱ្យភ្ញាក់ផ្អើលទេ ដោយឃើញប្រពលកម្មនៃយុទ្ធនាការនៃក្រុមប្រឆាំងក្នុងប៉ុន្មានខែចុងក្រោយនេះ ។ ក្រុម [ប្រជាជន] បាននិយាយថាពួកគេមិនចូលប្រកួតក្នុងការបោះឆ្នោតទេ ដោយសារ"សភាពការណ៍លំបាក" បានអំពាវនាវដល់ប្រជាជនឱ្យធ្វើការប្រយុទ្ធដើម្បីជ្រើសរើសរដ្ឋាភិបាលមួយត្រឹមត្រូវ ដែលនឹងជួយលើកតម្កើងកំរិតជីវភាពប្រជាជនឱ្យបានប្រសើរជាងកំរិតទាបនាបច្ចុប្បន្ននេះ និង"ប្រយុទ្ធប្រឆាំងការគំរាមកំហែងនានាទាំងអស់របស់ ... ចក្រពត្តិអាមេរិក" ។ នង់ សួន បានប្រកាសដោយត្រង់ៗ ក្នុងពេលធ្វើសេចក្តីថ្លែងការណ៍ជាសាធារណៈចុងក្រោយមួយ ដែលក្រុមប្រជាជនត្រូវបង្ខំចិត្តឱ្យបញ្ឈប់សកម្មភាពទាំងអស់ ពីព្រោះកម្លាំងសន្តិសុខរបស់សម្តេចសីហនុបាន"ធ្វើការចាប់ចង ធ្វើទារុណកម្ម ធ្វើការកាប់សម្លាប់ដោយសម្ងាត់" សមាជិករបស់ពួកគេ ហើយ "មនុស្ស និងអ្នកស្នេហាជាតិចំរើនពិតប្រាកដដទៃទៀត ជាច្រើនមក" ។*

*ការសំរេចប្តូរគោលជំហររបស់ បព២ នាពេលមុន និងការដកខ្លួនចេញពីការបោះឆ្នោត ហាក់បីដូចជាត្រូវបានធ្វើឡើងដោយ នួន ជា និង សាឡុត ស នៅក្នុងខែមីនា ឬមេសា ។ ពួកគេពីរនាក់នេះ ជាមនុស្សដែលអាចសង្កេតឃើញអំពីដំណើរថយក្រោយ ដែលបានប៉ះពាល់ដល់ក្រុមប្រជាជនជាច្រើននាក់ ដែលមានការទាក់ទងជាមួយ ស និងការគំរាមកំហែងពីការបង្ក្រាបកាន់តែខ្លាំងថែមទៀត បើសិនជា បព២ នៅតែបន្តបង្ហាញមុខកម្មាភិបាលរបស់ពួកគេឱ្យធ្វើការងារចំហ និងស្របច្បាប់ជាបន្តទៀតនោះ ។ ព្រមពេលការបាត់ខ្លួនរបស់ ទូ សាមុត ហើយបញ្ហាសុវត្ថិភាពរបស់ពួកគេផ្ទាល់ស្ថិតក្នុងភាពសង្ស័យនោះ ការដាក់ខ្លួនពួកគេឱ្យស្ថិតនៅទាបបំផុតមានសារសំខាន់ណាស់ ហោចណាស់ក៏ចំពោះមុខនេះដែរ ។ ឯកសាររបស់ បព២ មួយ ធ្វើឡើងក្នុងនាម "រដ្ឋអំណាចបក្សថ្នាក់ខ្ពស់" - ដែលក្រោយមកត្រូវបានកងស៊ើបការណ៍សម្ងាត់របស់សម្តេចសីហនុចាប់បាន - បានពន្យល់អំពីសេចក្តីសំរេចនេះដល់កម្មាភិបាលថ្នាក់មូលដ្ឋាន ។ ក្នុងការយោងមួយដែលហាក់ដូចជាចង់សំដៅចំពោះវាសនារបស់ ទូ និងសមាជិកបក្សដទៃទៀតដែលត្រូវបានសម្លាប់នោះ "រដ្ឋអំណាចថ្នាក់ខ្ពស់"ទាំងនេះ ហាក់ដូចជាអគ្គការលើ ដែលមានសមាសភាព នួន ជា និង សាឡុត ស បានត្អូញត្អែថាដំណើររបស់បដិវត្តន៍ បានបែកខ្ញែកដោយទុក្ករកម្ម ។ សេចក្តីសំរេចនោះបានអំពាវនាវដល់យុទ្ធជនធម្មតាកុំឱ្យអស់សង្ឃឹម ដោយការបង្ក្រាបធ្វើឡើងដោយពួកប្រតិកិរិយា និងសក្តិភូមិសង្គមរាស្ត្រនិយម និងដោយកងទ័ព និងប៉ូលីសរបស់សម្តេចសីហនុនោះ ។ ប៉ុន្តែ ដោយការបង្ក្រាបនេះមានសភាពធ្ងន់ធ្ងរយ៉ាងដូច្នេះ មិនបាច់*

និយាយអំពីការចូលរួមក្នុងការបោះឆ្នោតឡើយ ពីព្រោះលទ្ធផលត្រូវបានដឹងជាមុនស្រេចហើយ ។ បព១ ត្រូវប្រមូលផ្តុំការយកចិត្តទុកដាក់ក្នុងការខិតខំអូសទាញពួកបញ្ញាជនដែលមានសមានចិត្តនៅក្នុងសង្គមរាស្ត្រនិយម ដែលសម្តេចសីហនុ អាចនឹងជ្រើសរើសឱ្យធ្វើជាបេក្ខជននោះ ដែលបច្ចុប្បន្នរួមមាន ខៀវ សំផន, ហ៊ូ យន់ និង ហ៊ូ នឹម ។ សេចក្តីសំរេចបានសន្យាថា បើអាចរក្សាបក្សបាន នោះបដិវត្តន៍វណ្ណៈកម្មជីពរបស់បក្សប្រាកដជាដណ្តើមបានជ័យជំនះនៅទីចុងបំផុត ដោយបន្ថែមថា លក្ខណៈសម្បត្តិដើម្បីជ័យជំនះត្រូវបានពង្រឹងដោយការរីកចំរើនទៅមុខនៃការតស៊ូដោយអាវុធនៅវៀតណាម ហើយជ័យជំនះនៃការតស៊ូនៅវៀតណាមនោះ មុខជានឹងនាំឱ្យសង្គមរាស្ត្រនិយមរលំដួលដោយជៀសមិនផុតឡើយ ។

គំនិតប្រមូលផ្តុំការយកចិត្តទុកដាក់ទៅលើបញ្ញាជនចំរើន ក្នុងពេលរង់ចាំជ័យជំនះរបស់ បព១ នៅភាគខាងត្បូងវៀតណាម និងលទ្ធភាពដែលថាជ័យជំនះនេះនឹងបើកផ្លូវសំរាប់បដិវត្តន៍កម្ពុជា បានអំណោយផលដល់ ស, សារី និងគណៈកម្មាធិការក្រុងរបស់ពួកគេ ដើម្បីបន្តការទាក់ទងជាមួយសមាជិកអតីតក្រុម ម៉ាក្ស-ឡេនីន និងអតីតគណបក្សប្រជាធិបតេយ្យ និងសកម្មជនដទៃទៀតក្នុងចំណោមគ្រូបង្រៀន និងនិស្សិត ។ ក៏ប៉ុន្តែ សម្តេចសីហនុ បានកំណត់ដាច់ខាតថាត្រូវធ្វើការបំភិតបំភ័យពួកឆ្វេងនិយមល្បីឈ្មោះទាំងឡាយដដែល ដែល ស និង សារី ចង់គែប្រវ័ញ្ចនោះ ។ ចាប់ពីដើមឆ្នាំ ១៩៦២ មក សម្តេចបានធ្វើការវាយប្រហារយ៉ាងកងរំពងលើពួកអ្នកដែលសម្តេចបានពិព័ណនាថា ជាពួកបង្កប់ខ្លួនធ្វើវិទ្ធង្សនាក្នុងជួរសង្គម ។ សូម្បីនៅមុនពេលយុទ្ធនាការនៃការបោះឆ្នោត សម្តេចបានចេញឱសានវាទដល់តំណាងរាស្ត្រឆ្វេងនិយមនៃរដ្ឋសភា ដែលត្រូវបញ្ចប់អាណត្តិឱ្យដកការទិទៀនប្រឆាំងសង្គមចេញវិញ ។ តំណាងរាស្ត្រស្ទើរទាំងអស់ លើកលែងតែ ហ៊ូ យន់ បានដកការទិទៀនរបស់ពួកគេចេញ ។ នៅពេលថ្ងៃយុទ្ធនាការកាន់តែខិតចូលមកដល់ ជាថ្មីម្តងទៀត សម្តេចសីហនុ បានព្រមានពួកបញ្ញាជនឱ្យបញ្ឈប់សកម្មភាពប្រឆាំងរបស់ពួកគេ ។ មន្ត្រីជាសមាជិកជាន់ខ្ពស់របស់សង្គមម្នាក់ បានសុំឱ្យពួកគេធ្វើការស្បថជាសាធារណៈ ជាបុគ្គលផ្ទាល់អំពីសេចក្តីស្មោះត្រង់ខាងនយោបាយរបស់ពួកគេ ។ ការនេះ បានបង្កើតឱ្យមានញត្តិដូចទឹកបាក់ទំនប់មកពីតំណាងរាស្ត្រ រួមទាំង ហ៊ូ យន់ និង ហ៊ូ នឹម ផង ។ ក្នុងពេលប្រជុំជាសាធារណៈមួយនាចុងខែ ពួកគេហាក់ដូចជាប្រកួតប្រជែងគ្នា ដើម្បីទទួលបានការយល់ស្របរបស់សម្តេចសីហនុ ។ ការលុតក្រាបជាសាធារណៈនេះត្រូវបានសំដែងឱ្យឃើញជាបន្តបន្ទាប់ ដើម្បីរក្សាឈ្មោះពួកគេក្នុងបញ្ជីឈ្មោះចំរាញ់ដោយសម្តេចសីហនុឱ្យធ្វើជាបេក្ខជនសង្គមរាស្ត្រនិយម តែមួយក្នុងមណ្ឌលនិមួយៗ ។ សម្តេចទ្រង់ថែមទាំងបានផ្តល់រង្វាន់ដល់ ខៀវ សំផន, ហ៊ូ នឹម និង ហ៊ូ យន់ នូវឋានៈជា រដ្ឋលេខាក្រសួងពាណិជ្ជកម្ម, ហិរញ្ញវត្ថុ និងផែនការនៃគណៈរដ្ឋមន្ត្រីផង ។

វត្តមាននៃពួកអ្នកចំរើនក្នុងរដ្ឋសភា និងរដ្ឋាភិបាល បានរក្សាលទ្ធភាពរបស់បក្សដើម្បីពង្រីកឥទ្ធិពលលើសម្តេចសីហនុ និងសង្គម តាមរយៈពួកគេទាំងនេះ ដោយជំរុញសម្តេចឆ្ពោះទៅប្រឆាំងចក្រពត្តិនិយម និងពង្រឹងមតិសាធារណៈចំរើន ព្រមជាមួយការផ្តល់ដល់បក្សនូវការជឿទុកចិត្ត - ទោះបីជាការបន្ទំក៏ដោយ - នូវមុខមាត់ជាសាធារណៈ នាំឱ្យយល់ថាវាស្ថិតនៅក្រោមការត្រួតត្រារបស់ពួកគេ ។ បព១ បានចាត់ទុកពួកគេថាជាឥស្សរជនស្នេហាជាតិ ដោយពួកគេត្រូវធ្វើការឃោសនាដោយឈរលើមូលដ្ឋាននៃប្រធានបទគណបក្សរណសិរ្សរួបរួមជាតិប្រឆាំងអាមេរិក ដើម្បីយុត្តិធម៌សង្គម និងសេរីភាព សំរាប់កម្មករ-ពលករកសិករ និងបញ្ញាជន ។ នួន មានការស្ងើចសរសើរជាពិសេសចំពោះសេចក្តីស្មោះត្រង់របស់ ខៀវ សំផន ទៅលើប្រធានបទទាំងនេះនិងប្រសិទ្ធភាពរបស់រូបគេក្នុងការចលនាកម្លាំងប្រជាជន ដែលកម្លាំងនេះក្លាយជាកម្មវត្ថុនៃការជ្រើសរើសរបស់បក្សជានាថាមនុស្សខាងក្រៅបក្សមិនអាចរកឃើញថានរណាជាថ្នាក់ដឹកនាំបដិវត្តន៍ និងធ្វើឱ្យមនុស្សផងទាំងពួងយល់ច្រឡំថារូបគេ ហ៊ូ យន់ និង ហ៊ូ នឹម ជាអ្នកដឹកនាំពិតប្រាកដរបស់បក្ស ។ អៀង សារី ក៏បានវាយតម្លៃនូវសារប្រយោជន៍របស់ ខៀវ សំផន ក្នុងការប្រមូលការគាំទ្រដើម្បីប្រឆាំងចក្រពត្តិនិយម និងធ្វើឱ្យមានការកែទម្រង់ក្នុងចំណោមបញ្ញាជនទីក្រុង មន្ត្រីរាជការស៊ីវិល "នាយទុនជាតិ" និងសូម្បីនាយទាហានរបស់សង្គមរាស្ត្រនិយមថែមទៀតផង ដែលបានឱ្យតម្លៃដល់ទស្សនៈរបស់គេមួយផ្នែក

*ដោយសារតែភាពជាបញ្ញាជនរបស់គេ ។ បពខ មានសេចក្តីរីករាយដោយបានឃើញថា រូបគេ [ខៀវ សំផន] ត្រូវបានសម្តេចសីហនុ និងអ្នកដទៃទៀត ចាត់ទុកថាជាមេដឹកនាំនៃអ្វីដែលសម្តេចហៅថាជាពួកខ្មែរក្រហមនោះ ជាពិសេសដោយសារចលនានេះហាក់ដូចជាកំពុងប្រយុទ្ធតែម្នាក់ឯង ដើម្បីសិទ្ធិប្រជាធិបតេយ្យ និងស្ថានភាពរស់នៅល្អប្រសើរ តាមរយៈនេះ រក្សាបក្ស និងទិសដៅពិតប្រាកដរបស់កុម្មុយនីស នៃបដិវត្តន៍ប្រជាធិបតេយ្យប្រជាជាតិប្រជាជននិង លើសពីនេះទៅទៀត ត្រូវបានបិទបាំងឱ្យនៅជាសម្ងាត់ ។*

*ទន្ទឹមនេះ ដំណែងលេខាបក្ស បពខ នៅតែស្ថិតនៅទំនេរដដែល ។ នួន ដែលជាអនុលេខារបស់ខ្មោច ទូ នោះ អាចបានគិតថាតាមធម្មតារូបគេត្រូវឡើងជំនួសរូបគាត់ ។ រូបគេមានឋានៈខ្ពស់ជាង ស ទោះបីជា ស ត្រូវបានចាត់តាំងឱ្យធ្វើជាអនុលេខាទី ២ នៅក្នុងឆ្នាំ ១៩៦១ ក៏ដោយ ។ តែដោយសារ នួន ជាក្មួយប្រសាររបស់ជនក្បត់ ស៊ីវ ហេង រូបគេត្រូវបានបដិសេធថាមិនសមស្របខាងនយោបាយ ដោយក្រុមប្រជាជន ដែលសមាជិករបស់ក្រុមនេះមានការភ័យខ្លាចថារូបគាត់អាចនឹងនាំឱ្យពួកគេប្រឈមមុខនឹងការបង្ក្រាប ឬរហូតដល់ថាជាភ្នាក់ងារបង្កប់យ៉ាងជ្រៅសំរាប់ពួកស៊ើបការណ៍ លន់ ណុល ផង ។ ដោយមានការគាំទ្រពី នួន ដំណែងលេខាបក្សបណ្តោះអាសន្នត្រូវបានផ្តល់ទៅឱ្យ ស ដោយចៃដន្យ ដោយ ស ត្រូវតែទទួលយក ទោះបីជាមានមនុស្សខ្វះក្នុងបក្សសង្ស័យ ស ថាជាភ្នាក់ងារខ្មាំងផងដែរនោះក៏ដោយ ។*

*ជាក់ស្តែង ទោះបីជាស្ថិតក្នុងលំដាប់ថ្នាក់ទី ២ ក៏ដោយ នួន គឺជាអ្នកដឹកនាំចលនាកុម្មុយនីសក្នុងតំបន់ភាគច្រើនលើសលប់នៃកម្ពុជា អស់រយៈពេលភាគច្រើននៃទសវត្ស ១៩៦០។ ការសម្របសម្រួលរវាងរូបគេ និង ស ត្រូវបានបញ្ជាក់ដោយសមាជ បពខ សម្ងាត់មួយទៀតដែលបានធ្វើឡើងនៅភ្នំពេញ ក្នុងខែកុម្ភៈ ឆ្នាំ ១៩៦៣ នៅពេលគណៈអចិន្ត្រៃយ៍បានបង្កើនចំនួនសមាជិកថែមទៀត ដោយបញ្ចូល ភឹម និង សារី ហើយ គណៈកម្មាធិការមជ្ឈឹមក៏ត្រូវបានបង្កើនចំនួនដែរ ។ ពួកអ្នកនៅសេសសល់ពីអង្គការឆ្នាំ ១៩៦០ រួមមានកម្មាភិបាលនៃអតីត បកឥ ២ នាក់ ពីភូមិភាគនិរតី ពោលគឺលេខាភូមិភាគ ម៉ា ម៉ង់ ហៅ ប៉ង់ និងអនុលេខា ជុង ហៅ ប្រសិទ្ធ និងលេខាភូមិភាគពាយ័ព្យ រស់ ញឹម ដែលដើមឡើយត្រូវបានជ្រើសរើសឱ្យចូល បកឥ ដែរ ។ រីឯសមាជិកថ្មី រួមមាន តាម៉ុក ដែលជាមនុស្សជើងចាស់របស់បកឥ - ក្រោយមកក្លាយជាមនុស្សទី ៣ ក្នុងគណៈកម្មាធិការភូមិភាគនិរតី - ដែលត្រូវបានបញ្ចូលក្នុងថ្នាក់ដឹកនាំតាមអនុសាសន៍របស់ ភឹម ដែលបានស្ញើចសរសើរអំពីភាពស្វិតស្វាញរបស់ ម៉ុក ។ ដើម្បីឆ្លុះបញ្ចាំងអំពីសារសំខាន់នៃការងារទីក្រុងរបស់បក្ស គណៈកម្មាធិការមជ្ឈឹមក៏បានបញ្ចូលកម្មាភិបាលថ្មីបន្ថែមពីរនាក់ពីការលាក់ខ្លួនក្នុងទីក្រុងភ្នំពេញផងដែរពោលគឺ ពេញ ធួក និង គង់ សុផល ដែលទាំងពីរនាក់ត្រូវបានជ្រើសរើសតាំងពីឆ្នាំ ១៩៥៤ ក្រោមការឧបត្ថម្ភរបស់ ស ។ ធួក (ហៅ វន វ៉េត) ធ្លាប់បានពាក់ព័ន្ធក្នុងសកម្មភាពនិស្សិតមិនមែនកុម្មុយនីសប្រឆាំងអាណានិគមនិយម នៅខេត្តបាត់ដំបង និងនៅភ្នំពេញ ចាប់ផ្តើមពីឆ្នាំ ១៩៥១ ។ ប៉ុន្មានខែមុនសន្និសិទទីក្រុងហ្សឺណែវ រូបគេបានចូលព្រៃម៉ាគីកុម្មុយនីសនៅភូមិភាគបូព៌ា បានចូលរៀនវគ្គបណ្តុះបណ្តាលខាងឃោសនា ដែលបានកោះធ្វើឡើងដោយ ទូ ដែលបានបញ្ជាឱ្យ ភឹម ចូលមកទីក្រុងភ្នំពេញ ក្រោយកិច្ចព្រមព្រៀងទីក្រុងហ្សឺណែវ ។ ក្នុងខែធ្នូ ឆ្នាំ ១៩៥៤ ស បានបញ្ចូលរូបគេជាសមាជិកនៃអ្វីដែលហៅថា បបបខ ហើយបន្ទាប់មក រូបគេបានធ្វើជាភ្នាក់ងារបង្កប់ក្នុងមន្ត្រីរាជការស៊ីវិលរបស់សង្គម និងសង្គមស៊ីវិលនៅភ្នំពេញ ។ សុផល (ហៅ កឹ) ជាគ្រូបង្រៀន ដែលមានជាប់សាច់ឈាមជាមួយគ្រួសារលោកសង្ឃព្រះពុទ្ធសាសនាប្រឆាំងអាណានិគមនិយមខ្មែរមុនកុម្មុយនីស ដែលរូបគេបានទទួលឥទ្ធិពល ។ ស, សារី និង សុន សេន បានបញ្ចូលរូបគេក្នុងបក្សនៅឆ្នាំ ១៩៥៨ ។*

*សមាជឆ្នាំ ១៩៦៣ បានអនុម័តមាគ៌ាទូទៅ បពខ ជាមូលដ្ឋានឥតប្រែប្រួលមួយ នោះគឺៈ ការតស៊ូនយោបាយដែលបានបន្តធ្វើតាំងពីឆ្នាំ ១៩៥៤ មក ។ ទិសដៅយូរអង្វែង គឺមានតែការកសាងកម្លាំងបដិវត្តន៍ដដែលក្នុងទស្សនៈដើម្បីផ្តួលរំលំរបបខ្មាំងតែក្នុងពេលជាមួយគ្នានោះ ត្រូវធ្វើនយោបាយបង្វំវណ្ណៈសក្តិភូមិ និងពួកអាយ៉ងចក្រពត្តិនិយមអាមេរិក ឱ្យប្រកាន់យកនយោ*

*បាយអព្យាក្រិត ។ ទិសដៅចំពោះមុខ គឺបំផុសចលនាមួយ ដើម្បីប្រឆាំងចក្រពត្តិនិយម និងសក្តិភូមិនិយម ដើម្បីអព្យាក្រិតខ្មាំងទាំងនេះសំរាប់រយៈពេលបច្ចុប្បន្ន ។ នេះមានន័យថាបន្តខិតខំ និងកសាងរណសិរ្សរួបរួមធំទូលាយមួយ ដោយបញ្ចូលពួកអ្នកទាំងឡាយណាដែលគាំទ្រដល់កម្ពុជាមួយឯករាជ្យ អព្យាក្រិត និងមិនចូលបក្សសម្ព័ន្ធ ក្នុងនេះរួមមាន សម្តេចសីហនុ ផង ដោយធ្វើការតាមរយៈ ខៀវ សំផន និងពួកអ្នកចំរើនដទៃទៀតក្នុងចំណោមគហបតីតូចតាច បញ្ញាជន មន្ត្រីរាជការស៊ីវិល និងយកនាយទុនជាតិ ដែលចំរើន ដែលបក្សហៅថា ស្វាបឆ្វេងនៃវណ្ណៈកាន់អំណាច ។*

## ជំពូក ៥

## ការស្នាក់នៅបរទេស

### ពីភ្នំពេញទៅតាយនីញ

ការបន្តអនុវត្តន៍មាគ៌ារណសិរ្សបរួមរបស់ បពខ និងសកម្មភាពក្នុងទីក្រុង កាន់តែមានការលំបាកខ្លាំងឡើងហើយ ។ នៅខែមីនា ឆ្នាំ ១៩៦៣ ប៉ូលីសបានបង្ក្រាបការរំពើករំពើនរបស់និស្សិត កម្មករ និងព្រះសង្ឃពុទ្ធសាសនា នៅភ្នំពេញ និងនៅតាមខេត្តនានា ។ ទាំងនេះគឺជាកម្មវត្ថុនៃការកកូរកកាយរបស់ បព ខ ។ ជាការច្បាស់លាស់ជាងគេបំផុត គឺករណីនៃនិស្សិតដែលត្រូវបានទទួលឥទ្ធិពលពីកម្មាភិបាលជាន់ខ្ពស់នៃគណៈកម្មាធិការក្រុង ដែលបានធ្វើសកម្មភាពជាគ្រូបង្រៀនសាលាឯកជន ឬសាលារដ្ឋ បើទោះបីជាបក្សមិនបានចូលពាក់ព័ន្ធក្នុងការច្របូកច្របល់ដោយហឹង្សាដ៏ខ្លាំងបំផុតនៃពួកនិស្សិតដែលបង្កឡើងដោយក្រុមអធិករប្រឆាំងសម្តេចសីហនុនៅក្នុងទីក្រុងសៀមរាបក៏ដោយ ។ បន្ទាប់ពីឧបទ្ទវហេតុនេះ សាឡុត ស, អៀង សារី, ក្រុមប្រជាជន, ពួកអ្នកទើបជ្រើសរើសថ្មីនៃ បព ខ, ហ៊ូ នឹម, អតីតសមាជិកក្រុមម៉ាក្ស-ឡេនីន ខៀវ សំផន និង ហ៊ូ យន់ ព្រមទាំងពួកអ្នកឆ្វេងនិយមដទៃទៀត ទាំងអស់គ្នាបានទទួលរងការគំរាមកំហែងចាប់ខ្លួន ឬធ្ងន់ធ្ងរជាងនេះទៅទៀត នៅពេលសម្តេចសីហនុបានបញ្ចេញបញ្ជីឈ្មោះមនុស្ស ៣៤ នាក់ថាជាពួកវិទ្ធ្វតករក្នុងចំណោមពួកគេ ដោយចោទថាជាពួកធ្វើវិទ្ធ្វតកម្មដើម្បីទម្លាក់រដ្ឋាភិបាល ។ ក្រោមការជំរុញរបស់ ស និងដោយការជំទាស់របស់ អៀង សារី ដែលគាំទ្រឱ្យបង្កើនការខិតខំថែមទៀតដើម្បីចាត់តាំងកម្មករ និងបញ្ញាជនក្នុងទីក្រុង បព ខ បានសំរេចថាសមាជិកគណៈកម្មាធិការមជ្ឈឹមណាដែលមានឈ្មោះក្នុងបញ្ជីត្រូវចេញទៅព្រៃម៉ាគី ក្នុងទស្សនៈថានឹងធ្វើបដិវត្តន៍ពីជនបទនៅថ្ងៃណាមួយ ។ ក៏ប៉ុន្តែ ចំពោះមុខនេះ ជាក់ស្តែងពួកគេបានភៀសខ្លួនទៅភាគខាងត្បូងវៀតណាម តាមផ្លូវដដែលដែលពួកអ្នកជ្រើសរើស ដែល ស និង នួន បានបញ្ជូនឱ្យទៅរៀនសូត្រនៅទីនោះ ក្នុងឆ្នាំ ១៩៦២ ដោយមានពួកនិរសារបស់ បព វ ដែលនៅតែរក្សាការទាក់ទងជាមួយ បព វ នៅភ្នំពេញនៅឡើយ ជាអ្នកនាំផ្លូវ ។ ការដែលពួកគេទៅវៀតណាមនេះ បានសេចក្តីថាពួកគេបានប្រកាន់ជំហរធ្វើការផ្ទាល់ជាមួយថ្នាក់ដឹកនាំ បព វ ភាគខាងត្បូង ក្នុងន័យថា ដោយពេលនេះវាហាក់ដូចជាកាន់តែច្បាស់ហើយ បើសិនជា បព វ ឈ្នះនៅភាគខាងត្បូង ទីបំផុតពួកនេះស្ថិតក្នុងស្ថានភាពមួយដែលអាចផ្តល់ជំនួយជាចាំបាច់បំផុតដល់បដិវត្តន៍កម្ពុជា ស្របតាមកិច្ចសន្យាដែលមានតាំងពីយូរយាមកហើយក្នុងន័យនេះនោះ ។ ពួកគេក៏បានយកតម្រាប់តាមការផ្លាស់ប្តូរទីបញ្ជាការធំរបស់ពួកកុម្មុយនីសភាគខាងត្បូង ពោលគឺមន្ទីរមជ្ឈឹមសំរាប់ភាគខាងត្បូង ដែលបានផ្លាស់ប្តូរទីតាំងកាលពីពេលថ្មីៗនេះ ពីជាយក្រុងព្រៃនគរទៅព្រំដែនកម្ពុជា ។

ក្នុងខែបន្តបន្ទាប់មកទៀត ស, សារី, កែវ មាស និង សុន សេន បានចាកចេញពីភ្នំពេញ ជាមួយពួកអ្នកដើងចាស់នៃក្រុមប្រជាជនមួយចំនួន និងពួកកងការពារដែលទើបជ្រើសរើសថ្មី ។ រួមជាមួយ សោ ភឹម ពួកគេបានទៅកាន់មូលដ្ឋានកុម្មុយនីសវៀតណាមមួយ ស្ថិតនៅចម្ងាយ ១០ គីឡូម៉ែត្រក្នុងទឹកដីវៀតណាម ក្នុងខេត្តតាយនីញ ទល់មុខខេត្តកំពង់ចាមនៃភូមិភាគបូព៌ាក្បែរអតីតកន្លែងដែល ស ធ្លាប់នៅជំនាន់សង្គ្រាមឥណ្ឌូចិនលើកទី ១ និងនៅជាប់មន្ទីរមជ្ឈឹមភាគខាងត្បូងនៃ បព វ ។ នៅទីនោះ ពួក បព ខ បានស្ថាបនាមន្ទីរសហភាគីរបស់គេ ហៅថា មន្ទីរ ១០០ ដែលជាលេខសម្ងាត់សំរាប់គណៈកម្មាធិការមជ្ឈឹម បព ខ តែមន្ទីរនេះត្រួតត្រាផ្ទាល់តែទៅលើភូមិភាគបូព៌ាប៉ុណ្ណោះ តាមរយៈ សោ ភឹម ។ ភឹម ច្រើនតែនៅក្នុងទឹកដីកម្ពុជាស្ថិតនៅជាប់ទីនោះ ដោយឧស្សាហ៍ធ្វើដំណើរទៅវិញទៅមកតាមភូមិនានាដែល បព ខ មានបណ្តាញការងារសម្ងាត់នៅឡើយ តែរូបគេក៏តែងតែប្រើមន្ទីរ ១០០ សំរាប់ធ្វើជាកន្លែងប្រជុំគណៈកម្មាធិការភូមិភាគបូព៌ា និងដែលរូបគេពិភាក្សាការងារជាមួយ ស ។

នួន ដោយប្រើរូបភាពជាអ្នករកស៊ីដើម្បីបិទបាំង នៅមិនទាន់មានអ្វីប៉ះពាល់នៅឡើយទេ រូបគេបានរក្សាមូលដ្ឋានរបស់គេនៅភ្នំពេញ រក្សាការទទួលខុសត្រូវលើភ្នំពេញនិងភូមិភាគដទៃទៀត ដែលរូបគេតែងតែបានធ្វើដំណើរចុះឡើងជាញឹកញាប់

។ រូបគេក៏បានទៅមន្ទីរ ១០០ ដែរដើម្បីពិភាក្សាការងារ ។ គណៈកម្មាធិការក្រុងថ្មីមួយស្ថិតក្រោមការគ្រប់គ្រងរបស់ នួន ត្រូវបានបង្កើតឡើង ដែលដឹកនាំដោយ វន វ៉េត ។

នួន និង ស នៅតែឯកភាពគ្នាចំពោះមាគ៌ាបក្សដដែល ធ្វើសេចក្តីសន្និដ្ឋាននយោបាយជាមួយគ្នា និងដាក់បង្ហាញសេចក្តីសន្និដ្ឋានជូនកម្មាភិបាលដឹកនាំដទៃទៀត ។ នួន មានការទទួលខុសត្រូវជាពិសេសក្នុងការផ្សព្វផ្សាយមាគ៌ាដល់ថ្នាក់ក្រោម ដើម្បីឱ្យកម្មាភិបាលភូមិភាគទាំងអស់ជ្រួតជ្រាបមាគ៌ាទាំងនេះ ។ រូបគេក៏ទទួលខុសត្រូវផងដែរ ក្នុងការចម្រាញ់សកម្មជនសម្ងាត់របស់ បពខ ឱ្យចេញពីភ្នំពេញទៅកាន់ជនបទ នៅពេលពួកគេមានការគំរាមកំហែងចាប់ខ្លួន ដែលការនេះបានកើតមានជាញឹកញាប់ ។ ការងាររបស់បក្សធ្វើតាមរយៈបញ្ញាជននៅភ្នំពេញ ត្រូវបានផ្តល់ដល់ពួកបញ្ញាជន នៅពេល ខៀវ សំផន និង ហ៊ូ យន់ ត្រូវបានសម្តេចសីហនុដកចេញនាពាក់កណ្តាលឆ្នាំ ១៩៦៣ ពីដំណែងក្នុងគណៈរដ្ឋមន្ត្រី ដែលទ្រង់បានតែងតាំងពួកគេក្រោយការបោះឆ្នោតឆ្នាំ ១៩៦២ ។

ប៉ុន្តែ នៅចុងឆ្នាំ ១៩៦៣ សម្តេចសីហនុបានប្រកាសថា កម្ពុជាឈប់ទទួលជំនួយយោធា និងសេដ្ឋកិច្ច របស់សហរដ្ឋអាមេរិកតទៅទៀតហើយ ហើយការទាក់ទងរវាងព្រះអង្គជាមួយសហរដ្ឋអាមេរិកបានធ្លាក់ចុះ បន្ទាប់ពីព្រះអង្គបានទតឃើញដោយសព្វព្រះហឫទ័យនូវការធ្វើឃាតប្រធានាធិបតីសហរដ្ឋអាមេរិក ចន ហ្វ៊ីតហ្សេរ៉ាល់ កេណឺឌី (J.F. Kennedy) ។ ព្រះ អង្គមានការភ័យខ្លាចនឹងទ្រង់ខ្លាល់ ចំពោះការគាំទ្ររបស់អាមេរិកដល់ពួកសាធារណរដ្ឋនិយមខ្មែរ ដែលបានភៀសខ្លួនទៅនៅជាមួយរបបប្រឆាំងកុម្មុយនីស្តគាំទ្រដោយសហរដ្ឋអាមេរិកនៅព្រៃនគរ ។ ក្នុងខែមីនា ឆ្នាំ ១៩៦៤ សម្តេចសីហនុ ទ្រង់បានអនុញ្ញាតឱ្យមានបាតុកម្មប្រឆាំងសហរដ្ឋអាមេរិក ធ្វើឡើងដោយពួកនិស្សិត និងអ្នកដទៃទៀតនៅក្នុងទីក្រុងភ្នំពេញ ។ ភាពកញ្ជ្រោលនិងហឹង្សារបស់ពួកគេ បានធ្វើឱ្យសម្តេចមានភាពស្រឡាំងកាំងនិងបាននាំឱ្យមានការគំរាមកំហែងពីមេបញ្ជាការកងទ័ព លន់ ណុល ថានឹងចាត់វិធានការបង្ក្រាបប្រឆាំងសកម្មជននិស្សិតទាំងនោះ ដែលជាការបង្កឱ្យមានសតិអារម្មណ៍ប្រឆាំងសម្តេចសីហនុ។ ពួកលាក់ខ្លួនរបស់ បពខ ក្នុងភ្នំពេញ បានឆ្លៀតឱកាសនេះ ដើម្បីទាញយកចំណេញពីការប្រែក្រឡាស់ទៅប្រឆាំងសហរដ្ឋអាមេរិករបស់សម្តេចសីហនុ និងភាពប្រឆាំងអាមេរិករបស់ពួកនិស្សិត ដោយមិនជំរុញឱ្យធ្វើការវាយប្រហារជាចំហទៅលើសម្តេចសីហនុទេ តែនេះគ្រាន់តែជាការធ្វើឱ្យពួកគេប្រឈមមុខនឹងការតាមដានរបស់កម្លាំងសន្តិសុខរបស់សម្តេចតែប៉ុណ្ណោះ ពួកគេត្រូវបង្ខំចិត្តផ្អាកកិច្ចខិតខំរបស់ពួកគេ ។ ការប្រើកម្លាំងត្រូវបានពុះកញ្ជ្រោលខ្លាំងឡើង ដែលរដ្ឋមិនអាចត្រួតត្រា ឬបង្ក្រាបបានហើយ បពខ មិនអាចធ្វើវិទ្ធង្សនា ឬដឹកនាំបាន ។

ជាផ្នែកមួយនៃការខិតខំរបស់ទ្រង់ក្នុងការម្ចាស់ការលើកម្លាំងទាំងនេះ សម្តេចសីហនុ ទ្រង់បានផ្តុំគ្នារវាងការប្រឆាំងអាមេរិកជាមួយការធ្វើជាតូបនីយកម្មពាណិជ្ជកម្មអាហារ័ណ-និហារ័ណ , ធនាគារឯកជន និង ផ្នែកសហគ្រាសឯកជនមួយចំនួនផ្សេងទៀត ។ ការណ៍នេះបានរាំងដល់ការកើនឡើងនៃអំណាចសេដ្ឋកិច្ចឯករាជ មូលធននិយមផែនការ ដែលអាចបណ្តាលឱ្យសម្តេចសីហនុកាន់កាប់នយោបាយ ដោយផ្តាច់មុខតែមួយអង្គឯង ។ វាក៏អាចមានចេតនាអព្យាក្រិតការទិទៀនរបបរបស់ទ្រង់ដោយពួកឆ្វេងផងដែរ តែការណ៍នេះមិនបានទាក់ទាញការយកចិត្តទុកដាក់របស់បក្ស និងក្រុមនិស្សិតដាច់ខាតទេ ដែលមើលឃើញថាវាជាការពង្រឹង"រដ្ឋសក្តិភូមិ" មួយតែប៉ុណ្ណោះ ។ ជាក់ស្តែង បច្ច័យនៃជាតូបនីយកម្ម គឺបានធ្វើឱ្យពួកអ្នកហែរហមសម្តេចសីហនុកាន់តែមានបានឡើង។ ដោយសម្តេចបានតែងតាំងពួកគេឱ្យទទួលខុសត្រូវស្ថាប័នជាតូបនីយកម្មទាំងនោះ និងធ្វើឱ្យពាណិជ្ជកម្មនិងផលិតផលមិនមែនកសិកម្មធ្លាក់ចុះ ។

ទន្ទឹមនេះ សម្តេចសីហនុក៏បានសព្វព្រះទ័យឱ្យដឹកជញ្ជូនសម្ភារៈយោធាសូវៀតតាមផ្លូវលំ ហូ ជី មិញ ពីភាគខាងជើងទៅភាគខាងត្បូងវៀតណាម ដោយឆ្លងកាត់តាមប្រទេសកម្ពុជា និងឱ្យបង្កើតជម្រកតូចៗមិនអចិន្ត្រៃយ៍ នៅផ្នែកខាងក្នុងព្រំដែនកម្ពុជា ។ ការទាក់ទងជាមួយសហរដ្ឋអាមេរិកកាន់តែចុះដុនដាបថែមទៀត ជាពិសេសនៅពេលការវាយប្រហាររបស់កងទ័ព

ប្រឆាំងពួកកុម្មុយនីសវៀតណាមក្នុងទឹកដីកម្ពុជា បានសម្លាប់ជនស៊ីវិលកម្ពុជា ។ នៅខែឧសភា ឆ្នាំ ១៩៦៥ បន្ទាប់ពីបានរៀបចំសន្និសិទមួយចូលរួមដោយតំណាងពួកកុម្មុយនីសវៀតណាម ដើម្បីបកអាក្រាតអន្តរាគមន៍របស់សហរដ្ឋអាមេរិកនៅឥណ្ឌូចិនមក សម្តេចសីហនុបានផ្តាច់ការទាក់ទងផ្លូវទូតជាមួយសហរដ្ឋអាមេរិក ។ បន្ទាប់មក សម្តេចបានអនុញ្ញាតឱ្យប្រើប្រាស់កំពង់ផែសមុទ្រក្រុងព្រះសីហនុ ដើម្បីដាក់ចុះការផ្គត់ផ្គង់សម្ភារៈយោធារបស់ចិន មុនដឹកឆ្លងកាត់តាមដីគោកទៅឱ្យពួកកុម្មុយនីសវៀតណាម ។ ជាលទ្ធផល សម្តេចបានក្លាយជាមានសារសំខាន់បំផុត សំរាប់ការតស៊ូដោយអាវុធរបស់ពួកកុម្មុយនីសវៀតណាមនៅភាគខាងត្បូង ពីព្រោះសម្តេចបានជួយសំរួលដល់ការផ្គត់ផ្គង់របស់ពួកគេ ហើយការងារទូតចំហរបស់សម្តេចបានធ្វើឱ្យសម្តេចក្លាយជាមនុស្សជំនិតរបស់ហាណូយ និងប៉េកាំង ។ ក៏ប៉ុន្តែ សម្តេចមិនបានអនុគ្រោះឱ្យវៀតណាមបង្កើតជម្រកធំៗ និងអចិន្ត្រៃយ៍ដែលអស់រយៈពេលជាងពីរឆ្នាំពួកគេមិនទាន់បានធ្វើ លើកលែងតែនៅផ្នែកចុងបំផុតនៃតំបន់ព្រៃសាន្តកម្ពុជាប៉ុណ្ណោះ ។

នៅមន្ទីរ ១០០ ស និងមេដឹកនាំ បពខ ដទៃទៀត មានការស្រងាកចិត្តដោយដឹងខ្លួនថា ទោះបីយ៉ាងណាក៏ដោយ ក្នុងការជាក់ស្តែង ពួកគេត្រូវបានដាក់ក្នុងការឃុំឃាំងក្នុងផ្ទះ ដោយពួកវៀតណាមដែលពួកគេបានទៅរស់នៅជាមួយនោះ ។ ពួកវៀតណាម "ម្ចាស់ការទាំងស្រុងនៃសភាពការណ៍ ហើយអ្វីៗត្រូវធ្វើតាមពួកគេនិយាយទាំងអស់" ។ ពួកខ្មែរបានស្ថិត "ក្រោមការដឹកនាំរបស់ពួកគេតាំងពីកំពូលដល់ក្រោម" ពឹងផ្អែកលើពួកគេទាំងស្រុងចំពោះការផ្គត់ផ្គង់សព្វសារពើ និងជាទូទៅមិនអនុញ្ញាតឱ្យចេញក្រៅបរិវេណនៃជំរុំទេ ។ ឯកសារជាភាសាវៀតណាមត្រូវបានបកប្រែសំរាប់រៀនសូត្រ ហើយ អៀង សារី បានជំរុញកម្មាភិបាលថ្នាក់ក្រោមឱ្យចូលរៀនវគ្គសិក្សារៀបចំឡើងដោយពួកវៀតណាម ដើម្បីរៀនពី "គំរូនិងប្រព័ន្ធរបស់ពួកគេ" ។ "ការពេញចិត្ត" ចំពោះទ្រឹស្តីរបស់វៀតណាម គឺជា "លក្ខណៈសម្បត្តិទូទៅ" មួយ ។ ក្នុងវគ្គសិក្សានានា វៀតណាម "ត្រូវបានយកធ្វើជាគំរូនៃការធ្វើបដិវត្តន៍" ទ្រឹស្តីរបស់ពួកគេ "បានដើរតួនាទីដឹកនាំ" និងជា "អនុត្តរភាព" ។ អ្វីៗ គឺយ៉ាងដូច្នេះ ទោះបីជាមានអារម្មណ៍មិនល្អចំពោះអាកប្បកិរិយាអាជ្ញា និងជាចៅហ្វាយ ពីសំណាក់ពួកវៀតណាម ដែលខ្មែរៗត្រូវតែបង្ខំចិត្តអធ្យាស្រ័យក៏ដោយ ។ អ្វីៗគឺយ៉ាងដូច្នេះ ទោះបី ស "បានខំប្រយុទ្ធប្រឆាំងនឹងការបង្ខំដាក់ឱ្យធ្វើជារណប ដោយអង្គការបដិវត្តន៍វៀតណាម" និងឈរលើគោលការណ៍ "ឯករាជ្យ ម្ចាស់ការ និងខ្លួនទីពឹងខ្លួន" - ដែលជាគោលការណ៍ដែលវៀតណាមឯកភាព ដូចនឹងឃើញខាងក្រោមនេះក៏ដោយ ។ ចំពោះ អៀង សារី រូបគេមានការស្មុគ្រស្មាញក្នុងចិត្តដោយពុំមានការងារនយោបាយធ្វើ ដោយរូបគេបានចាកចេញពីមន្ទីរ ១០០ ទៅភ្នំពេញ ប៉ុន្តែត្រូវបានបញ្ចុះបញ្ចូលឱ្យត្រឡប់ទៅ តាយនីញ វិញនៅឆ្នាំ ១៩៦៤ ដោយកម្មាភិបាលគណៈទាក់ទង ដែលបានធ្វើក្នុងនាម ស ។

ឯកសារវៀតណាមដែលបានរៀននៅមន្ទីរ ១០០ ដោយពុំមានការសង្ស័យអ្វីទេ បានរួមបញ្ចូលឯកសារដ៏សែនសំខាន់មួយ ស្តីពីការពិនិត្យឡើងវិញរបស់ បពវ អំពីសកម្មភាពនាពេលថ្មីៗកន្លងទៅ នៅភាគខាងត្បូង ក្រោមចំណងជើងថា "ពិសោធនៃចលនាបដិវត្តន៍នៅភាគខាងត្បូងវៀតណាម ក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗកន្លងទៅនេះ" ។ ឯកសារបានគូសបញ្ជាក់ថា ការតស៊ូនយោបាយដោយមធ្យោបាយអហឹង្សា គឺគ្រាន់តែជាយុទ្ធវិធីមួយប៉ុណ្ណោះ៖ នរណាដែលពឹងផ្អែកតែទៅលើមធ្យោបាយតែមួយនេះនោះ គឺបានផ្តេកផ្តួលទៅតាម "គំនិតសេរីនិយម អំពីការផ្លាស់ប្តូរនយោបាយដោយសន្តិវិធីដោយការគិតងាយ" និងជំរុញបដិវត្តន៍ឱ្យធ្លាក់ទៅក្នុងការអន្តរាយ ដោយការគិតគូខុសដែលថា បើសិនជាជំរុញការតស៊ូប្រដាប់អាវុធ នឹងនាំទៅដល់ការមហន្តរាយខាងនយោបាយសំរាប់បក្ស ។ ពួកស្ទាក់ស្ទើរស្តាំនិយមបែបនេះ បានមើលស្រាលចំពោះទំនាស់សង្គម ដែលចេះតែកើនឡើងនៅជនបទ និងសក្តានុពលបដិវត្តន៍របស់ពួកអ្នកស្រែចំការ ដោយការខកខានមិនបានត្រៀមរៀបចំដើម្បីឱ្យមហាជនងើបឡើងប្រឆាំងដោយកាន់អាវុធនៅនឹងដៃ ។ មន្ទីរ ១០០ ក៏ប្រហែលជាបានរៀនសូត្រផងដែរ សេចក្តីសំរេចចិត្តរបស់គណៈកម្មាធិការមជ្ឈឹម បពវ ខែធ្នូ ឆ្នាំ១៩៦៣ ដែលបានគាំទ្រដល់ការវិភាគការពិនិត្យឡើងវិញអំពីភាគខាងត្បូង ដែលប្រកាសថា ដោយសារការតស៊ូប្រដាប់អាវុធនៅភាគខាងត្បូងនឹងដើរតួជាកំណត់ដោយផ្ទាល់ ដែលនឹងនាំមកនូវជ័យជំនះរបស់បដិវត្តន៍នៅទីនោះ

បញ្ហាសំខាន់ជាងគេបំផុតរបស់បដិវត្តន៍ "ក្នុងគ្រប់កាលៈទេសៈ" គឺត្រូវធ្វើអ្វីៗសព្វបែបយ៉ាងដើម្បីកសាងកម្លាំងយោធា និងធ្វើការវាយសំរុកជាបន្ទាន់ដើម្បីបង្កើតលក្ខណៈសម្បត្តិនាំទៅឱ្យធ្វើការវាយសំរុក និងធ្វើកុប្បកម្មទូទៅមួយ និងផ្តួលរំលំរដ្ឋាភិបាលប្រតិកិរិយានៅភាគខាងត្បូង" ។

អាណាប័ណ្ណ បពវ ចំពោះភាគខាងត្បូង ប្រាកដជាអាចអនុវត្តន៍នៅកម្ពុជាមួយចំនួនផងដែរ ។ ការមិនសប្បាយចិត្តនៅជនបទបានកើនឡើង នៅពេលរដ្ឋាភិបាលបញ្ចុះតម្លៃស្រូវ បណ្តាលឱ្យផលិតផលនៅនឹងថ្កល់ ហើយបង្កើតជាវិបត្តិសេដ្ឋកិច្ចទូទៅនៅជនបទ ។ ការណ៍នេះ ត្រូវបានបន្ទរដោយពាក្យចចាមអារ៉ាមក្នុងស្រុកមួយ អំពីរដ្ឋប្រហារទម្លាក់សម្តេចសីហនុ បន្តឡើងដោយសមាសភាពប្រឆាំងកុម្មុយនីសដាច់ខាតជាងគេបំផុតក្នុងកងទ័ព ។ ទន្ទឹមនេះ ក្នុងខែសីហា ឆ្នាំ ១៩៦៤ កងទ័ពអាកាសសហរដ្ឋអាមេរិកចាប់ផ្តើមទម្លាក់គ្រាប់បែកជាចំហ ជាលើកទី ១ លើ សបវ ហើយសភាសហរដ្ឋអាមេរិកបានអនុញ្ញាតឱ្យប្រើកងកម្លាំងប្រយុទ្ធថ្មើរជើងរបស់សហរដ្ឋអាមេរិក ប្រឆាំងពួកបះបោរកុម្មុយនីសនៅភាគខាងត្បូងវៀតណាម ។

គឺក្នុងបរិបទនេះហើយ ដែលនៅចុងឆ្នាំ ១៩៦៤ ថ្នាក់ដឹកនាំ បពខ បានកោះប្រជុំសន្និបាតកម្មាភិបាលមកពីទូទាំងប្រទេសមួយនៅក្នុងទឹកដីកម្ពុជា តែឱ្យធ្វើនៅក្បែរមន្ទីរ ១០០ ។ ដោយបន្ទរតាមការពិនិត្យឡើងវិញរបស់ បពវ ការបំពាក់បំប៉នមនោគមវិជ្ជា ត្រូវបានធ្វើឡើងដោយឈរលើ"គោលជំហរនៃការតស៊ូដោយហឹង្សានយោបាយ និងប្រដាប់អាវុធ តាមរយៈខ្លួនទីពឹងខ្លួន" ដូច្នេះជាការយកមកប្រើឡើងវិញនូវក្រិត្យក្រមទូទៅនៃហឹង្សាបដិវត្តន៍ - ដែលជាមូលដ្ឋានដែលវៀតណាមបានប្តូរទិសនៅភាគខាងត្បូងក្នុងឆ្នាំ ១៩៥៩ នោះ ។ បន្ទាប់ពីកិច្ចប្រជុំនេះ ភឹម បានទទួចថាមានលទ្ធភាពអាចដឹកនាំធ្វើការតស៊ូមួយបែបនេះបានហើយ ទោះបីជាការនេះមិនទាន់ជាមាគ៌ារបស់បក្សក៏ដោយ ។ នៅដើមឆ្នាំ ១៩៦៥ ក្នុងកិច្ចប្រជុំមួយនៅមន្ទីរ ១០០ គណៈកម្មាធិការអចិន្ត្រៃយ៍បានអនុម័តសេចក្តីសំរេចចិត្តមួយ បង្ហាញថាពេលវេលាត្រូវប្តូរទិសកាន់តែខិតមកជិតដល់ហើយ ដោយចក្រពត្តិអាមេរិកបានរៀបចំ"ពង្រីកសង្គ្រាមនៅទូទាំងឥណ្ឌូចិន" ។ សេចក្តីសំរេចចិត្តនេះបានបញ្ជាក់ជាគោលការណ៍ថា "ដើម្បីធ្វើការតស៊ូប្រឆាំងចក្រពត្តិនិយម ដាច់ខាតត្រូវតែប្រើហឹង្សានយោបាយ ពោលគឺ ត្រូវប្រើកម្លាំងប្រដាប់អាវុធដើម្បីឈ្នះ ... ជ័យជំនះ" ។ បន្ទាប់មក មានការប្រជុំមួយទៀតនៅមន្ទីរ ១០០ នៃកម្មាភិបាលជាន់ខ្ពស់មកពីភ្នំពេញ និងបពខ ភាគព្រៃសាន, និរតី និងឧត្តរ ដែលធ្វើឡើងក្រោមការឃាមកាមរបស់វៀតណាម ។ សេចក្តីណែនាំចំពោះភ្នំពេញគឺបង្កើនការប្រឆាំងចក្រពត្តិអាមេរិករបស់ប្រជាជន ជាពិសេសក្នុងចំណោមយុវជន និងកម្មករ ។ កម្មាភិបាលភូមិភាគខ្លះ បានចាត់ទុកការប្រជុំនេះថាជាសញ្ញាមួយដែលថា ការបំផុសប្រជាជននៅជនបទមានន័យថាត្រៀមសំរាប់ហឹង្សានយោបាយហើយ ។ ក៏ប៉ុន្តែ ការត្រៀមរៀបចំរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ គឺគ្រាន់តែជាទ្រឹស្តីប៉ុណ្ណោះ ដូច្នេះហើយបានជាពួកគេមិនជំទាស់ទៅនឹងម្ចាស់ផ្ទះភាគខាងត្បូងវៀតណាមរបស់ពួកគេ ដែលមានមតិថាសភាពការណ៍នៅកម្ពុជាដល់ពេលត្រូវស្តាបនាកម្លាំងបដិវត្តន៍ហើយ តែនៅមិនទាន់ដល់ពេល "ធ្វើបដិវត្តន៍នៅឡើយទេ"នោះ ។ ទោះបីយ៉ាងណាក៏ដោយ ក៏ថ្នាក់ដឹកនាំកម្ពុជាមានការខឹងសម្បារនៅពេល បពវ ភាគខាងត្បូងបានដឹកជញ្ជូនពួកគេឱ្យមកផ្ទះវិញ ដោយបដិសេធការស្នើសុំរបស់ បពខ ឱ្យវៀតណាមផ្តល់កាំភ្លើងខ្លះដល់ពួកគេនោះ - យ៉ាងហោចណាស់មួយចំនួនសំរាប់បំពាក់ដល់ពួកកងស្វ័យការពារបក្សដែរ និងមួយចំនួនតូចទៀតសំរាប់បំពាក់ឱ្យក្រុមឃោសនិក - ធ្វើឱ្យសមាជិកគណៈកម្មាធិការមជ្ឈឹមមានគ្រោះថ្នាក់ណាស់ពេលពួកគេត្រូវចេញពីមន្ទីរ ១០០ និងធ្វើការផ្សារចាត់តាំងនៅជនបទកម្ពុជានោះ ។

### ដំណើររបស់ ស ទៅហាណូយ និង ប៉េកាំង

ដោយសារពួកខ្មែរចង់ពិភាក្សាបញ្ហាទាំងអស់នេះបន្ថែមទៀត ជាមួយថ្នាក់លើវៀតណាម ក្នុងការចរចាជាផ្លូវការរវាងបក្សនិងបក្សនោះ ទើប ស បានចេញដំណើរពីមន្ទីរ ១០០ នៅក្នុងខែមិថុនា ឆ្នាំ ១៩៦៥ ដោយថ្មើរជើងពីតាយនីញទៅហាណូយតាមផ្លូវលំហូជីមិញដែលជាផ្លូវសំរាប់ដឹកជញ្ជូនភស្តុភារ រួមដំណើរដោយ កែវ មាស ដែលមានសុខភាពមិនល្អ និងចង់ទៅទី

*នោះដើម្បីទទួលការព្យាបាលផ្នែកពេទ្យ ។ នួន បានផ្លាស់ពីភ្នំពេញ ដើម្បីទៅទទួលបន្ទុកមន្ទីរ ១០០ ដោយធ្វើដំណើរចុះឡើងម្ដងម្កាលមកភ្នំពេញផង ។ ស បានចំណាយពេល ៩ ខែ នៅ សបវ ដែលពេលនោះកំពុងស្ថិតក្រោមការទម្លាក់គ្រាប់បែកពីលើអាកាសរបស់សហរដ្ឋអាមេរិក និងបានទៅប្រទេសចិនដើម្បីបំពេញទស្សនៈកិច្ចរយៈពេល ៤ ខែ ពីខែកុម្ភៈ ដល់ខែឧសភា ឆ្នាំ ១៩៦៦ នៅចំពេលនៃការចាប់ផ្ដើមមហាបដិវត្តន៍វប្បធម៌វណ្ណៈអធន ។ ចុងបញ្ចប់ រូបគេបានវិលត្រឡប់មកមន្ទីរ ១០០ វិញតាមផ្លូវវៀតណាមខាងជើង និងឡាវ នៅក្នុងខែកញ្ញា ឆ្នាំ ១៩៦៦ ។ នៅវៀតណាម រូបគេបានចរចាជាមួយសហភាគីរបស់គេ ឡេ យន់ និងបានរៀនសូត្រនយោបាយ ដែលរូបគេត្រូវបានណែនាំឱ្យយកចិត្តទុកដាក់ជាពិសេសចំពោះការងាររបស់អគ្គលេខាធិការ យន់, ប្រធាន បពវ ហូ ជីមិញ និងពួកអ្នកទ្រឹស្ដីយោធា ទ្រៀង ជីញ និង វ៉ូ ង្វៀងយ៉ាប់ ។ ក្នុងពេលធ្វើដំណើរនៅប្រទេសចិន រៀបចំឡើងតាមរយៈការណែនាំរបស់ បពវ រូបគេត្រូវបានទទួលដោយកម្មាភិបាលថ្នាក់ខ្ពស់ បកច ដែលមានពិសោធក្នុងកិច្ចការអាស៊ីអគ្នេយ៍ និងសេដ្ឋកិច្ច ។*

*ស សង្ឃឹមថា យ៉ាងហោចណាស់ក៏ទទួលបានកិច្ចគាំទ្រពីហាណូយ សំរាប់ធ្វើការរៀបចំជាយថាហេតុ សំរាប់ការតស៊ូដោយអាវុធនៅកម្ពុជា ជាពិសេសពី ឡេ យន់ ដែរ ។ យន់ ធ្លាប់ស្គាល់កម្ពុជា និងជាអ្នកគាំទ្រជួរមុខជាងគេបំផុតនៃនយោបាយសកម្មប្រយុទ្ធជាងនៅភាគខាងត្បូងវៀតណាម ។ ស សង្ឃឹមថា យន់ មុខជានឹងណែនាំដល់ បពវ ឱ្យផ្ដល់អាវុធដែល បព ខ ត្រូវការ ដើម្បីពង្រីកការរៀបចំនៅជនបទរបស់ពួកគេសំរាប់ការធ្វើបដិវត្តន៍ ។ សេចក្ដីថ្លែងការណ៍ជាសាធារណៈរបស់វៀតណាមមួយចំនួន អំពីសភាពការណ៍នៅកម្ពុជា នៅឥណ្ឌូចិនទាំងមូល និងក្រិត្យក្រមនៃបដិវត្តន៍ មុននិងក្នុងពេលធ្វើដំណើររបស់គេនោះ បានលើកទឹកចិត្តដល់រូបគេ ។*

*សេចក្ដីថ្លែងនានារបស់វៀតណាម បានឆ្លុះបញ្ចាំងនូវបរិយាកាសសកម្មប្រយុទ្ធដែលបានបង្កើតឡើងនៅវៀតណាមដោយការតម្លើងថ្នាក់នៃកិច្ចខិតខំរបស់សហរដ្ឋអាមេរិក ដើម្បីកំទេចការបះបោររបស់ពួកកុម្មុយនិសនៅភាគខាងត្បូង និងដាក់ទ័ណ្ឌកម្មដល់ភាគខាងជើងដែលគាំទ្រការបះបោរនេះ ។ ក្នុងខែមីនា ឆ្នាំ ១៩៦៥ សហរដ្ឋអាមេរិកបានចូលរួមយ៉ាងពេញទំហឹងក្នុងសង្គ្រាមឥណ្ឌូចិនលើកទី ២ ដោយបញ្ជូនកងទ័ពថ្មើរជើងសហរដ្ឋអាមេរិកដោយទ្រង់ទ្រាយធំទៅកាន់ភាគខាងត្បូង និងបន្តការទម្លាក់គ្រាប់បែកពីលើអាកាសនៅភាគខាងជើង ។ នេះគឺជាការឆ្លើយតបចុងក្រោយរបស់សហរដ្ឋអាមេរិក ទៅនឹងជោគជ័យរបស់ពួកកុម្មុយនីស បន្ទាប់ពីការសម្លាប់ យៀម ក្នុងរដ្ឋប្រហារខែវិច្ឆិកា ឆ្នាំ ១៩៦៣ ។ ពួកកុម្មុយនីសនៃភាគខាងត្បូង បានចាប់ផ្ដើមជំរុញសកម្មភាពយោធាយ៉ាងធំមួយ ក្នុងសេចក្ដីសង្ឃឹមថានឹងកំទេចរដ្ឋាភិបាលទីក្រុងព្រៃនគរ ឱ្យបានមុនការអន្តរាគមន៍របស់សហរដ្ឋអាមេរិក ។ ដូចការគិតទុកមែន នៅពេលពួកគេហៀបតែទទួលបានជ័យជំនះហើយនោះ ស្រាប់តែសហរដ្ឋអាមេរិកប្រតិកម្ម ។*

*ចំពោះកម្ពុជាវិញ វៀតណាមតែងតែប្រកាសថា សហរដ្ឋអាមេរិកបានប្ដេជ្ញាថានឹងបំផ្លាញនយោបាយអព្យាក្រិតរបស់សម្ដេច សីហនុ និងប្រែក្លាយប្រទេសនេះទៅជាមូលដ្ឋានមួយសំរាប់ "ឡោមព័ទ្ធ និងបង្ក្រាបបដិវត្តន៍ នៅភាគខាងត្បូងវៀតណាម" ។ បន្ទាប់ពី ស បានទៅដល់ហាណូយភ្លាម វៀតណាមបានព្រមានថា ថ្មីៗកន្លងទៅនេះ ចក្រពត្តិអាមេរិកបានប្រឹងនិងបានរៀបចំដោយយកចិត្តទុកដាក់ ដើម្បីធ្វើអំពើអាក្រក់មួយប្រឆាំងកម្ពុជា - ពោលគឺ ការរាតត្បាតប្រទេសនេះពីភាគខាងត្បូងវៀតណាម ដោយបានសំដែងទុកជាមុននូវសេចក្ដីសង្ឃឹមថា ព្យុះសង្ឃរាបដិវត្តន៍កម្ពុជាមួយអាចទប់ស្កាត់ការណ៍នេះកុំឱ្យកើតមានឡើងបាន ។ ក្រោយមក ពួកគេបាននិយាយថា ខ្មែរត្រូវត្រៀមថានឹងមានរដ្ឋប្រហារប្រឆាំងសម្ដេចសីហនុ និងរៀបចំខ្លួនដើម្បី "ឈានទៅប្រើហឹង្សាបដិវត្តន៍" ដោយអនុវត្តមេរៀននៃភាគខាងត្បូង[វៀតណាម]នៅកម្ពុជា ។ វៀតណាមក៏មានការបារម្ភយ៉ាងខ្លាំងផងដែរ អំពីការគំរាមរបស់សហរដ្ឋអាមេរិក ថានឹងដណ្ដើមកាន់កាប់តំបន់ខ្ពង់រាបតាយង្វៀងរបស់វៀតណាម មុននឹងឈានទៅតំបន់ខ្ពង់រាបព្រៃសានកម្ពុជាដើម្បីវាយប្រហារវៀតណាមពីក្រោយខ្នង ដោយចាត់តាំងសមាជិកនៃជនជាតិភាគតិចនៅ*

សង្វាត់ព្រំដែនជាជំនួយ ។ ការភិតភ័យនេះត្រូវបាន វ៉ូ ង្វៀងយ៉ាប់ យល់ស្រប ដោយបានប្រកាសថា សហរដ្ឋអាមេរិកជា"គ្រោះថ្នាក់ដ៏ធ្ងន់ធ្ងរបំផុតចំពោះសន្តិសុខរបស់ប្រជាជន" នៅក្នុងប្រទេសកម្ពុជា ។

ទន្ទឹមនេះ វៀតណាមបានប្រកាសអំពីសេចក្តីសង្ឃឹមជាទូទៅរបស់ពួកគេចំពោះជោគជ័យនៃបដិវត្តន៍ ដោយចលនាកុម្មុយនីសនៅគ្រប់ទិសទី ក្នុងការចលនាប្រជាជនរបស់ពួកគេ ប្រឆាំងការគំរាមកំហែងរបស់ចក្រពត្តិអាមេរិក និងដើម្បីសំរេចកុម្មុយនីសនិយម ។ ដោយសរសើរដល់ការតស៊ូដោយអាវុធផ្ទាល់របស់ពួកគេនៅភាគខាងត្បូង ពួកគេបានអះអាងថា ការពុះកញ្ជ្រោលនៃចលនាបដិវត្តន៍នេះមិនពឹងផ្អែកលើអ្នកដទៃទេ តែពឹងផ្អែកលើកម្លាំងផ្ទាល់របស់វៀតណាមផ្ទាល់តែម្តង ។ ភាពជាខ្លួនទីពឹងខ្លួននេះ បានជំរុញបដិវត្តន៍ពីការដែលមានតែកាំភ្លើងហួសសម័យតែមួយក្តាប់ និងចំរ៉ូងឫស្សី ទៅជាកងទ័ពប្រជាជនដ៏ខ្លាំងពូកែមួយ ដោយដណ្តើមអាវុធពីខ្មាំងដើម្បីបំពាក់ឱ្យខ្លួន ធ្វើសង្គ្រាមឈ្លប និងបន្ទាប់មកកសាងកម្លាំងរបស់ខ្លួនបានយ៉ាងលឿនបំផុត ។ ទ្រឿង ជិញ បានពន្យល់ថាជនបដិវត្តន៍នៃអតីតអាណានិគមនិយមទាំងឡាយ ត្រូវរៀបចំខ្លួនឱ្យបានលឿនដើម្បីធ្វើការតស៊ូដោយអាវុធ និងធ្វើសង្គ្រាមបដិវត្តន៍ ។ ឥស្សរជនថ្នាក់ខ្ពស់ម្នាក់ទៀតបានបញ្ជាក់ថា សង្គ្រាមប្រជាជន គឺជាផ្លូវឆ្ពោះទៅមុខសំរាប់ជនបដិវត្តន៍នៅក្នុងប្រទេសទាំងអស់ណាដែលមាន"ប្រជាជនតិច ទឹកដីតូច និងសេដ្ឋកិច្ចឱនថយ" ។ ជាមួយសង្គ្រាមប្រជាជន ពួកគេអាចប្រយុទ្ធ និងធ្វើឱ្យបរាជ័យខ្មាំងដែលខ្លាំងជាងខ្លួនដ៏លើសលប់បាន ។

ជាឯកជន វោហាសាស្ត្រនេះត្រូវបានបង្ហាញឱ្យឃើញថាខុស ដោយទទូចថាការធ្វើសកម្មភាពដោយអាវុធនៅកម្ពុជានៅមិនទាន់ដល់ពេលនៅឡើយទេ និង"ស្ថិតនៅក្រោមបន្ទាត់នៃការប្រៀបធៀបកម្លាំង" ។ ការនេះត្រូវបាន ឡេ យន់ ដាក់ជូនដល់ ស ក្នុងការប្រជុំមួយនៅថ្ងៃទី ២៩ ខែកក្កដា ឆ្នាំ ១៩៦៥ នៅពេលរូបគេធ្វើការចាប់អារម្មណ៍ដោយឡែកលើកម្មវិធីនយោបាយរបស់ បព៖ និងបដិសេធការស្នើសុំអាវុធរបស់ ស ។

យន់ បានផ្តល់អនុសាសន៍ថា ខ្មែរត្រូវរួមបញ្ចូលគ្នាក្នុងការបង្កើតមូលដ្ឋានបដិវត្តន៍នៅជនបទ តាមរយៈចលនាមហាជនដោយគ្មានអាវុធ ព្រមជាមួយការបន្តបញ្ចូលខ្លួនទៅក្នុងសភា និងរដ្ឋាភិបាល ដើម្បីដាក់ឱ្យបក្សប្រកួតប្រជែងដណ្តើមអំណាច ប្រហែលអាចតាមរយៈហឹង្សា នៅពេលវៀតណាមឈ្នះសង្គ្រាមនៅវៀតណាមតែប៉ុណ្ណោះ ។ ការរៀបចំទាំងនេះ ក៏អាចប្រើក្នុងទិសដៅធ្វើឱ្យចលនាកម្ពុជាត្រៀមខ្លួនជាស្រេច ដើម្បីចាប់កាន់អាវុធ និងងើបឡើងជាមួយវៀតណាម ក្នុងការធ្វើសង្គ្រាមដោយអាវុធនៅកម្ពុជា បើសិនជាសម្តេចសីហនុ ត្រូវបានទម្លាក់ពីអំណាចដោយសមាសភាព - ដោយមិនមានអ្វីត្រូវសង្ស័យទេ ដូចជា លន់ ណុល ជាដើម - ដែលនឹងផ្តល់ឱ្យសហរដ្ឋអាមេរិកប្រើប្រទេសកម្ពុជាធ្វើជាមូលដ្ឋានសិកមួយប្រឆាំងវៀតណាម ។ តាម ឡេ យន់ គន្លឹះគឺបន្តធក់ឱកាស និងជំរុញការប្រឆាំងចក្រពត្តិនិយមអាមេរិក របស់សម្តេចសីហនុ និងប្រជាជន ដើម្បីពង្រីកចលនាកុម្មុយនីសនៅជនបទ និងនៅក្នុងរដ្ឋាភិបាល ។ បន្ទាប់មក នៅពេលវៀតណាមឈ្នះ ឬ សម្តេចសីហនុត្រូវបានទម្លាក់ចេញពីអំណាច ពួកកុម្មុយនីសខ្មែរនឹងមានលទ្ធភាពធ្វើការតស៊ូដោយហឹង្សាដើម្បីដណ្តើមអំណាច ដោយមានជំនួយយោធាពីវៀតណាម ។ បទបញ្ញត្តិទាំងនេះ បានឈរលើមូលដ្ឋាននៃការវិភាគមួយបញ្ជាក់ថា ជញ្ជីងនៃកម្លាំងសង្គមក្នុងស្រុកនៅកម្ពុជាមិនអំណោយផលដល់ការផ្តួលរំលំសក្តិភូមិនិយមទេ ហើយការផ្តួលរំលំសម្តេចសីហនុ នឹងធ្វើឱ្យខូចប្រយោជន៍ ចំពោះមុខនៃបដិវត្តន៍ឥណ្ឌូចិនទាំងមូល ។ វាក៏បានប្រែក្រឡាស់គោលជំហររបស់ បពវ ដែលបានអនុម័តនៅវៀតណាមមុននេះ អំពីថាតើត្រូវដោះស្រាយយ៉ាងដូចម្តេច ចំពោះលទ្ធភាពនៃអន្តរាគមន៍យោធាដោយទ្រង់ទ្រាយធំរបស់សហរដ្ឋអាមេរិកនោះ ។ ជាជំនួសការធ្វើការតស៊ូដោយអាវុធ មុនអន្តរាគមន៍បែបនេះដើម្បីកំទេចពួកអ្នកចូលដៃជាមួយសហរដ្ឋអាមេរិក- ដូចដែល វៀត ណាមបានធ្វើរួចមកហើយនោះ - ខ្មែរត្រូវរង់ចាំរហូតដល់ក្រោយពេលសហរដ្ឋអាមេរិកដាក់កម្លាំងឈ្លានពានមកដល់ដីសិន ។

ព្រមជាមួយការផ្តល់មតិទាំងនេះ ឡេ យន់ បានឯកភាពចំពោះការបកស្រាយរបស់ បព៖ ដែលថា កម្ពុជាជាអ្នករងគ្រោះនៃការជិះជាន់របស់អាណានិគមនិយមថ្មីរបស់សហរដ្ឋអាមេរិក ។ ទោះបីជាមាននយោបាយការទូតប្រឆាំងសហរដ្ឋអាមេ

វិកនាពេលថ្មីៗកន្លងទៅនេះក៏ដោយ ក៏ ឡេ យន់ បានចង្អុលបង្ហាញថាសម្តេចសីហនុនៅតែជាអាយ៉ងរបស់សហរដ្ឋអាមេរិកក្នុងចិត្តនៅឡើយ ។ ពួកកុម្មុយនីសខ្មែរបានធ្វើត្រឹមត្រូវហើយ ដែលចង់ធ្វើយ៉ាងណា"បង្ខំឱ្យសម្តេចសីហនុប្រឆាំងអាមេរិកនិងអាយ៉ងរបស់គេនៅកម្ពុជា"នោះ ។ ក្នុងនេះ យន់ បានផ្តល់យោបល់ថា យកល្អ បពខ ត្រូវ"បិទបាំងឈ្មោះសម្តេចសីហនុ ដើម្បីធ្វើការអំពាវនាវ" ដល់មហាជនខ្មែរឱ្យប្រឆាំងចក្រពត្តិអាមេរិក និងពួកកញ្ជះរបស់វា ។ ដូច្នេះ ជាថ្មីម្តងទៀត វៀតណាមបានយល់ស្របថា កម្ពុជាបានប្រមូលនូវអ្វីដែលពួកគេនិយាយថាជាភាគខាងត្បូងវៀតណាមក្រោយឆ្នាំ ១៩៥៤ នោះគឺ "របបអាណានិគមនិយមក្លែងក្លាយនៃចក្រពត្តិអាមេរិក" ដែលជាអាណានិគមនិយមថ្មីដែលគ្មានក្បាលម៉ាស៊ីនដឹកនាំ ឬកាន់កាប់ដោយយោធាជាបរទេស ពីព្រោះចក្រពត្តិនិយមមានលទ្ធភាពអាចបិទបាំងធាតុពិតនៃការឈ្លានពាននិងការជិះជាន់របស់វា ដោយប្រើរូបភាពជាច្រើន និងលាក់មុខមាត់ពិតរបស់វា ។

យោងតាមប្រភពវៀតណាម បានឱ្យដឹងថា ស មិនបានគាំទ្រនឹងជំហរដំបូន្មានរបស់ ឡេ យន់ ទេ ។ ក៏ប៉ុន្តែ តាមការរៀបរាប់របស់ ស ទោះបីជារូបគេ"បានអត់ធ្មត់និងស្ងៀមស្ងាត់" ចំពោះមុខ ឡេ យន់ នៅហាណូយក៏ដោយ ក៏រូបគេបានអះអាងថា បពខ នឹងឈរយ៉ាងដាច់ខាត លើគោលជំហរឯករាជ្យ និងអធិបតេយ្យ ក្នុងការទាក់ទងរបស់គេជាមួយ បពវ ព្រមទាំងកំណត់មាគ៌ានយោបាយមួយដោយខ្លួនឯង មានន័យថា បពខ មិនដើរតាមការទូន្មានរបស់ បពវ គ្រប់ពេលវេលានោះទេ ហើយជាពិសេសអាចនឹងជំរុញសកម្មភាពយោធារបស់ពួកគេឱ្យទៅហួសពីស្វ័យការពារ ដល់ការបដិវត្តន៍ហឹង្សាដោយពេញបន្ទុកថែមទៀត ។ ទាំងប្រភពកម្ពុជា និងវៀតណាម បង្ហាញឱ្យឃើញថា អៀង សារី ឯកភាពជាមួយគោលជំហររបស់វៀតណាមជាងគេ ។ វៀតណាមបានប្រកាសថា ទាំង អៀង សារី ទាំង នួន ជា បានឯកភាពជាមួយគោលជំហររបស់វៀតណាម នៅពេល បពវ ពិភាក្សាជាមួយពួកគេនៅមន្ទីរ ១០០ ។ ម្យ៉ាងទៀត បើតាម ស ក្នុងឱកាសនៃដំណើរមួយរបស់ នួន ទៅភ្នំពេញ វៀតណាមបានចក់ឱកាសយកប្រៀបលើភាពសង្ស័យរបស់ អៀង សារី អំពីការតស៊ូដោយអាវុធ និងការស្អប់ខ្ពើមយ៉ាងច្បាស់របស់ សុន សេន ចំពោះការប្រយុទ្ធគ្នា ដើម្បីបញ្ចុះបញ្ចូលពួកគេកុំឱ្យយកចិត្តទុកដាក់ខ្លាំងពេកក្នុងការរៀបចំការតស៊ូដោយអាវុធ ហើយពួកគេទាំងពីរនាក់នេះបានបញ្ចុះបញ្ចូលលេខាភូមិភាគឦសាន ថានៅមានការត្រៀមរៀបចំខាងនយោបាយជាច្រើនទៀតតម្រូវឱ្យធ្វើមុនលទ្ធភាពនៃការតស៊ូដោយអាវុធអាចធ្វើទៅបាន ។

ព្រមជាមួយនេះ តាម នួន ឱ្យដឹង វៀតណាមមានការខកចិត្តយ៉ាងខ្លាំង ដែល ស មិនបានយកចិត្តទុកដាក់ចំពោះអ្វីដែលពួកគេបានគិត នោះគឺការផ្តល់ការគោរពដ៏ត្រឹមត្រូវចំពោះប្រធាន បពវ ហូ ជីមិញ ពីព្រោះ ស បាននិយាយទៅកាន់ ហូ ជាសមមិត្តស្មើភាពគ្នា មិនបានហៅថា "អ៊ំហូ" ទេ ។ ពួកគេក៏មិនសប្បាយផងដែរ ចំពោះព្រឹត្តិការណ៍ដែលកើតមានក្នុងរយៈពេលនៃទស្សនៈកិច្ចរបស់ ស នៅប្រទេសចិន ដែលរៀបចំឡើងដោយវៀតណាមនោះ ។

នេះគឺបណ្តាលមកពីកាលនៅប្រទេសចិន ស បានរកឃើញនូវអ្វីដែលរូបគេបានកំណត់ថាជាការរំភើបយ៉ាងខ្លាំងសំរាប់ជំរុញចលនារបស់គេឆ្ពោះទៅការប្តូរទិសដូចអ្វីដែលវៀតណាមបានធ្វើនៅភាគខាងត្បូង នៅចុងទសវត្សរ៍ ១៩៥០ និងបានទូងស្គរវាយឃ្មោះនូវការឃោសនាទូទៅរបស់ពួកគេនោះ ។ ដូច ស បាននិយាយ នាពេលក្រោយមកថា បកច បានគាំទ្រមាគ៌ានយោបាយរបស់ បពខ កាន់តែអស់ពីចិត្តពីថ្លើម ក្នុងនេះរួមទាំងការវិភាគវណ្ណៈរបស់បក្ស និងការបែងចែករវាងមិត្តនិងសត្រូវរបស់បក្សផង។ ក៏ប៉ុន្តែ ដូចវៀតណាមដែរ ចិនមិនគាំទ្រឱ្យមានការប្តូរទិសទៅធ្វើការតស៊ូដោយអាវុធទេ ហើយមិនតែប៉ុណ្ណោះថែមទាំងបានថ្លែងសរសើរដល់កម្មវិធីនយោបាយរបស់ បពខ ដែលថានឹងធ្វើសកម្មភាពមិនដោយសន្តិវិធីតែជាជំរើសចុងក្រោយតែប៉ុណ្ណោះនោះ ។ ទោះបីយ៉ាងណាក៏ដោយ ចិនបានទៅឆ្ងាយជាងវៀតណាមតែបន្តិចបន្តួច ក្នុងការគាំទ្រការត្រៀមខាងសតិអារម្មណ៍និងចាត់តាំង សំរាប់ការប្តូរទិសនាពេលអនាគត ដោយជំរុញ បពខ ឱ្យដោះស្រាយបញ្ហាកម្ពុជាដូចនៅភាគខាងត្បូងវៀតណាម ឬចំពោះបញ្ហានោះ ឱ្យធ្វើដូចប្រទេសចិន ។ យោងតាមការរៀបរាប់របស់វៀតណាមមួយ ចិនបានប្រាប់ ស ថាៈ

បច្ចុប្បន្ននេះ បក្សនីមួយៗចង់ប្រឆាំងចក្រពត្តិអាមេរិកយ៉ាងខ្លាំង ដូច្នេះបក្សនានាត្រូវតាមដានសភាពការណ៍ដោយជិតស្និទ្ធ ដើម្បីមានលទ្ធភាពចាត់យកសេចក្តីផ្តើមគំនិតប្រឆាំងចក្រពត្តិនិយម ហើយបក្សនីមួយៗត្រូវរៀបចំខ្លួន ។ អាស្រ័យហេតុនេះ បក្សកម្ពុជាក៏ដូចបក្សដទៃទៀតដែរ ត្រូវដោះស្រាយជាមួយចក្រពត្តិអាមេរិកភ្លាមៗ ពេលពួកវាពង្រីកសង្គ្រាម [នៅឥណ្ឌូចិន] ... ។ បក្សនីមួយៗ រួមទាំងបក្សកម្ពុជាផង មានភារកិច្ចប្រយុទ្ធជាមួយចក្រពត្តិអាមេរិក ដើម្បីរក្សាសន្តិភាព និងអព្យាក្រឹតភាព... ។ ហើយបើអ្នកណាមានបំណងប្រឆាំងការរួមគំនិតក្បត់របស់ចក្រពត្តិអាមេរិក ក្នុងនេះរួមទាំងគំនិតក្បត់តម្លើងថ្នាក់[សង្គ្រាម] របស់ពួកវាផង ពួកគេត្រូវតែពឹងផ្អែកលើកសិករ ។

នៅពីក្រោយដំបូន្មាននេះ គឺសេណារីយ៉ូរបស់ចិន អំពីលទ្ធភាពនៃការធ្វើបដិវត្តន៍នៅកម្ពុជា ដូចគ្នានឹងអ្វីដែលបានលើកឡើងដោយ ឡេ យន់ ទោះបីជាវាមានរួមជាមួយតួនាទីខ្វះសំរាប់សម្តេចសីហនុ និង លន់ ណុល ក៏ដោយ ។ ចិនបានប្រមើលថា បើសហរដ្ឋអាមេរិកពង្រីកសង្គ្រាមនៅឥណ្ឌូចិន ដោយចូលឈ្លានពានកម្ពុជា កងទ័ពកម្ពុជាដឹកនាំដោយ លន់ ណុល មុខជាចាប់ផ្តើមវាយពួកចក្រពត្តិ ដោយប្រើអាវុធនិងគ្រាប់រំសេវ ដែលចិនបានចាប់ផ្តើមផ្តល់ឱ្យដោយផ្ទាល់តាំងពីដើមឆ្នាំ ១៩៦៤ ក្រៅពីសម្ភារៈសង្គ្រាមដែល លន់ ណុល ដកហូតយកពីការដឹកជញ្ជូនតាមនាវាទៅឱ្យវៀតណាម ។ ដូច្នេះ ចិន សង្ឃឹមថា លន់ ណុល នឹងអនុវត្តកិច្ចសន្យាដែល លន់ ណុល បានធ្វើក្នុងពេលទស្សនៈកិច្ចមួយទៅកាន់ប៉េកាំង ក្នុងខែវិច្ឆិកា ឆ្នាំ ១៩៦៥ ថាកងកម្លាំងប្រដាប់អាវុធរបស់គាត់បានប្តេជ្ញាថានឹងប្រយុទ្ធជាមួយការឈ្លានពានណាមួយប្រឆាំងប្រទេសកម្ពុជា ពីសំណាក់ចក្រពត្តិនិយមអាមេរិក ។ ផែនការរបស់ចិន គឺគាំទ្រសម្តេចសីហនុនិងចាត់ទុកព្រះអង្គជាមេដឹកនាំជួរមុខនៃសង្គ្រាមតស៊ូប្រឆាំងចក្រពត្តិនេះ តែថាដើម្បីធ្វើយ៉ាងដូច្នេះបាន ព្រះអង្គត្រូវទទួលយកពាក្យទូន្មានរបស់ ប្រធានម៉ៅ ដែលថា "ត្រូវពឹងផ្អែកលើមហាជនដ៏ធំទូលាយ" ដែល ម៉ៅ ចង់និយាយ ដោយពុំមានការសង្ស័យអ្វីទេ អំពីកម្លាំងកសិករដែលបានរៀបចំដោយពួកកុម្មុយនីសខ្មែរ ដែលនឹងស្ថិតនៅជួរមុខក្នុងរយៈពេលនៃការតស៊ូនោះជាមិនខាន ។ ការជឿទុកចិត្តរបស់ចិនលើទស្សនៈវិស័យនេះ ត្រូវបានគាំទ្រដោយកិច្ចសន្យារបស់ សម្តេចសីហនុ ដែលថាក្នុងករណីមានការវាយប្រហាររបស់សហរដ្ឋអាមេរិក នោះសម្តេចនឹងចាកចេញទៅកាន់ទីជនបទ ។ ចិន គិតថាកងទ័ពរបស់ លន់ ណុល មិនមានសមត្ថភាពដឹកនាំសង្គ្រាមដែលមានមូលដ្ឋាននៅជនបទទេ ហើយការណ៍នេះនឹងបង្ខំរូបគេឱ្យពឹងពាក់លើការគាំទ្ររបស់ពួកកុម្មុយនីស ។ មុនពេលថ្ងៃនោះមកដល់ ចិនត្រូវប្រើឱ្យអស់លទ្ធភាពនូវផ្លូវឆ្លងកាត់តាមកម្ពុជា ដើម្បីដឹកជញ្ជូនភស្តុភារផ្តល់ទៅឱ្យពួកកុម្មុយនីស នៅភាគខាងត្បូងវៀតណាម ក្នុងពេលជាមួយគ្នាការផ្តល់ឱ្យកងទ័ព លន់ ណុល ដែរនោះ ។

ដូច្នេះ គោលជំហររបស់ចិនស៊ីសង្វាក់គ្នាជាមួយដំបូន្មានរបស់ ឡេ យន់ ។ ទាក់ទងទៅនឹងការដឹកនាំការតស៊ូប្រដាប់អាវុធប្រឆាំងចក្រពត្តិ ដែលនឹងធ្វើវិទ្ធង្សនាចំពោះភាពដឹកនាំរបស់សម្តេចសីហនុ និងសន្ទប់យកដោយកងទ័ព លន់ ណុល ពីខាងក្រោមនោះ បទបញ្ញត្តិដោយសព្វមុខរបស់ចិនសំរាប់ការធ្វើបដិវត្តន៍តាមរយៈសង្គ្រាមប្រជាជននោះ ត្រូវបានប្រកាសឡើងក្នុងអត្ថបទចុះផ្សាយក្នុង ខែកញ្ញា ឆ្នាំ ១៩៦៥ ក្រោមចំណងជើងថា: "ជយោ! ជ័យជំនះនៃសង្គ្រាមប្រជាជន" ដែលបានដាស់តឿនជនកម្ពុជាឱ្យរៀនសូត្រពី ថាតើវៀតណាមធ្វើយ៉ាងដូចម្តេច ។

អត្ថបទដែលសរសេរដោយ លីន ពាវ រដ្ឋមន្ត្រីការពារជាតិចិន បានបូកបញ្ចូលគ្នាទ្រឹស្តីរបស់ម៉ៅស្តីពីសង្គ្រាមប្រជាជន ដែលតម្រូវឱ្យមានចលនាកុម្មុយនីសមួយ ដើម្បី: ១) ស្ថាបនារណសិរ្សរួបរួមជាតិមួយនៃប្រជាជនទាំងអស់ ដែលគាំទ្រការតស៊ូប្រឆាំងចក្រពត្តិនិយម, ២) ពឹងផ្អែកលើកសិករ ស្ថាបនាមូលដ្ឋាននៅតំបន់ជនបទ និងយកជនបទដើម្បីឡោមព័ទ្ធទីក្រុង ហើយនៅទីបញ្ចប់ដណ្តើមកាន់កាប់ទីក្រុងទាំងអស់, ៣) ស្ថាបនាកងទ័ពប្រជាជនដែលជាកម្លាំងប្រយុទ្ធ ព្រមពេលជាមួយគ្នានឹងកម្លាំងការងារនយោបាយមួយ និងអង្គភាពផលិតកម្មមួយដើម្បីធ្វើការងារឃោសនាក្នុងចំណោមមហាជន ចាត់តាំងនិងបំពាក់អាវុធដល់ពួកគេ ព្រមទាំងជួយពួកគេបង្កើតរដ្ឋអំណាចនយោបាយបដិវត្តន៍ និង ៤) ធ្វើកិច្ចការទាំងអស់នេះ ដោយឈរជា

*សំខាន់លើកម្លាំងផ្ទាល់របស់ខ្លួន ជាមួយការខិតខំដើម្បីអូសទាញការគាំទ្រពីសំណាក់បរទេសឱ្យបានច្រើនបំផុតដែលអាចធ្វើបាន។*

*លីន បានពិព័ណនាទ្រឹស្ដីរបស់ ម៉ៅ ថាមានសារសំខាន់ជាទីបំផុត សំរាប់ប្រទេសដែលទទួលរងការជិះជាន់ ឱ្យប្រឈមមុខជាមួយការឈ្លានពានរបស់ពួកចក្រពត្តិនិយម ជាទ្រឹស្ដីមួយដែលអាចអនុវត្តបានសំរាប់ប្រទេសពាក់កណ្ដាលអាណានិគមនិយម និងពាក់កណ្ដាលសក្តិភូមិ ដែលខ្សោយ ដើម្បីយកជ័យជំនះលើប្រទេសចក្រពត្តិនិយមខ្លាំងបាន ។ ការណ៍នេះមិនត្រឹមតែធ្វើបាននៅប្រទេសចិនប៉ុណ្ណោះទេ តែវាក៏ជាការរួមចំណែកមួយដ៏ធំដល់ការតស៊ូបដិវត្តន៍នៃប្រជាជាតិ និងប្រជាជន ដែលទទួលរងនូវការជិះជាន់នៅទូទាំងពិភពលោកផងដែរ ជាអាវុធមួយដែលបានក្លាយទៅជាសេចក្ដីត្រូវការជាបន្ទាន់មួយសំរាប់ប្រជាជននៃប្រទេសជាច្រើន (តែច្បាស់ណាស់ មិនមែនប្រទេសកម្ពុជាទេ) ដើម្បីម្ចាស់ការ និងប្រើវាប្រឆាំងចក្រពត្តិនិយមអាមេរិក និងពួកអាយ៉ង របស់វា ។ វាទាមទារឱ្យមានសំរាប់ទប់ទល់នឹងសង្គ្រាមប្រឆាំងប្រជាជន នៅពេលដែលប្រទេសត្រូវជិះជាន់ និងប្រជាជនត្រូវជិះជាន់ ត្រូវប្រឈមមុខជាមួយសង្គ្រាមឈ្លានពាន និងការបង្ក្រាបដោយអាវុធដោយពួកចក្រពត្តិនិយម និងអាយ៉ងរបស់វា ។ ក៏ប៉ុន្តែ ក្នុងពេលរង់ចាំការបង្កើតមូលដ្ឋានបដិវត្តន៍នៅតំបន់ជនបទ វាមានសារសំខាន់ក្នុងការអនុវត្តជាសកលសំរាប់ការតស៊ូបដិវត្តន៍បច្ចុប្បន្នរបស់ប្រជាជាតិ និងប្រជាជនដែលទទួលរងការជិះជាន់ទាំងអស់នៅ អាស៊ី អាហ្វ្រិក និង អាមេរិកឡាទីន ។*

*អត្ថបទបានណែនាំថា វៀតណាមគឺជាឧទាហរណ៍ជាក់ស្ដែងនាពេលបច្ចុប្បន្ន ដែលគួរឱ្យទុកចិត្តបានជាទីបំផុត អំពីផ្លូវដ៏ត្រឹមត្រូវនៃការធ្វើឱ្យចក្រពត្តិអាមេរិកបរាជ័យ ដោយសង្គ្រាមប្រជាជន និងបានសរសើរ បពវ ចំពោះការដណ្ដើមអំណាចដោយសង្គ្រាមប្រជាជន ។ អត្ថបទបានព្រមានថា នៅឥណ្ឌូចិន ចក្រពត្តិអាមេរិកបានពង្រីកសង្គ្រាមក្នុងការប៉ុនប៉ងដើម្បីស្រោចស្រង់ខ្លួនគេពីបរាជ័យ តែបានទស្សន៍ទាយថា ការណ៍នេះនឹងនាំឱ្យមានប្រតិកម្មជាខ្សែសង្វាក់ ដែលធ្វើឱ្យប្រជាជនដទៃទៀតបង្ហាញឱ្យឃើញថា ពួកគេក៏អាចធ្វើនូវអ្វីដែលប្រជាជនវៀតណាមបានធ្វើមកហើយនោះដែរ ដោយបានរៀនសូត្រពីការធ្វើសង្គ្រាមប្រជាជននេះ ។ កាលណាពេលវេលាមកដល់ហើយ នោះពួកគេនឹងងើបឡើងដើម្បីធ្វើសង្គ្រាមនេះ បើចាំបាច់ពួកគេនឹងចាប់ផ្ដើមពីបាតដៃទទេ ដោយប្រើតែដាវកញ្ចាស់, ចំបូងខ្នារ, កាំភ្លើងហួសសម័យ និងគ្រាប់បែកដៃប៉ុណ្ណោះ ។ ក្នុងបញ្ហានេះ ក៏ដូចជាអ្វីដទៃទៀតដែរ ពួកគេត្រូវបានណែនាំថាត្រូវរៀនសូត្រឱ្យបានល្អអំពីមេរៀនដែលផ្ដល់ឱ្យដោយសង្គ្រាមរំដោះ របស់ប្រជាជនវៀតណាម និងសង្គ្រាមតស៊ូរបស់ពួកគេប្រឆាំងការឈ្លានពានរបស់សហរដ្ឋអាមេរិក ។*

*ដូច្នេះ ចំណុចសំខាន់របស់ចិនចំពោះ បពខ គឺពួកគេត្រូវរៀនសូត្រគំរូវៀតណាមជាបន្តទៀត តែមិនឱ្យហួសពីការត្រៀមរៀបចំសំរាប់ការតស៊ូដោយអាវុធនោះទេ ព្រមពេលជាមួយគ្នានឹងការតស៊ូនយោបាយ ដូចដែលពួកគេបានធ្វើតាំងពីឆ្នាំ ១៩៥៤ មក ។ ដូចវៀតណាមដែរ ចិនប្រាកដជាមិនទាន់ផ្ដល់អាវុធដល់អ្នកណាម្នាក់នៅកម្ពុជាក្រៅពី លន់ ណុល ទេ ។ ទោះបីជាមេដឹកនាំកុម្មុយនីសចិនដាច់ខាតជាងគេជាទីបំផុត ដូចជា យ៉ាវ វ៉ិនយាន់ ដែលជាសមាជិកម្នាក់នៃ "ក្រុម ៤ នាក់" នៃបដិវត្តន៍វប្បធម៌ ក៏មិនគាំទ្រការតស៊ូដោយអាវុធប្រឆាំងសម្ដេចសីហនុដែរ ។*

# ជំពូក ៦

## ពីការតស៊ូនយោបាយ ឆ្ពោះទៅការតស៊ូប្រដាប់អាវុធ

### វិបត្តិនយោបាយកម្ពុជា នាចុងទសវត្សរ៍ ១៩៦០

ពេល ស កំពុងបំពេញទស្សនៈកិច្ចនៅហាណូយ ក្នុងឆ្នាំ ១៩៦៥ មេដឹកនាំ បពខ នៅមន្ទីរ ១០០ និងនៅទូទាំងប្រទេស បានបន្តធ្វើតាមដំបូន្មានវៀតណាម ដែលថាត្រូវអត់ធ្មត់កុំធ្វើការតស៊ូដោយអាវុធ និងកុំធ្វើការវាយប្រហារសម្តេចសីហនុដោយផ្ទាល់ ។ ទោះបីដូច្នេះក៏ដោយ ក៏ពួកគេបានព្យាយាមធ្វើការតស៊ូនយោបាយរបស់ បពខ នៅក្នុងទីក្រុងភ្នំពេញ ដែលបានប្រឈមមុខនឹងរលកនៃការបង្ក្រាបកាន់តែខ្លាំងឡើងនៅក្នុងឆ្នាំ ១៩៦៥ បង្ខំឱ្យជម្លៀសសកម្មជនជាច្រើននាក់ទៅកាន់តំបន់ជនបទ ។ សកម្មភាពចាត់តាំងរបស់បក្សក្នុងចំណោមកម្មករនៅភ្នំពេញ ដែលទទួលបានជោគជ័យនាពេលកន្លងមក ក្នុងការបង្កការរំជើបរំជួល ត្រូវបានបញ្ឈប់ទៅវិញដោយវិធានការទប់ទល់របស់រដ្ឋាភិបាល បណ្តាលឱ្យកម្មាភិបាលក្លាយទៅជាអសកម្ម ។ ក៏ប៉ុន្តែការអត់ធ្មត់របស់ថ្នាក់ដឹកនាំបក្សចំពោះសម្តេច ពេលខ្លះបានទំនាស់ជាមួយខាងក្រោម ។ នៅដើមឆ្នាំ ១៩៦៦ ពេល ស កំពុងស្ថិតនៅប្រទេសចិននៅឡើយ សម្តេចសីហនុ បានបញ្ជាឱ្យចាប់អ្នកដែលត្រូវចោទថាជាកុម្មុយនីសជាច្រើននាក់នៅក្នុងទីក្រុង អ្នកខ្លះទៀតត្រូវទទួលការព្រមានថាបើមិនបញ្ឈប់សកម្មភាពទេ នោះពួកគេនឹងត្រូវសម្លាប់ ។ ក្រោយមក ឯកសាររបស់ពួកកុម្មុយនីសបង្កប់ខ្លួន ត្រូវបានផ្សព្វផ្សាយក្នុងភូមិភាគបូព៌ារបស់ សោ ភឹម ដែលផ្ទុយនឹងនយោបាយរបស់ បពវ និង បពខ ដោយឯកសារទាំងនោះបានអំពាវនាវឱ្យផ្តួលរំលំសម្តេច ។

ការនេះបង្ហាញឱ្យឃើញថា តើសភាពការណ៍នៅកម្ពុជាបានក្លាយកាន់តែស្មុគ្រស្មាញយ៉ាងដូចម្តេច ពេល ស កំពុងស្នាក់នៅបរទេសនៅឡើយនោះ ។ ការផ្លាស់ប្តូរនយោបាយសេដ្ឋកិច្ចជាតិនិងរចនាសម្ព័ន្ធសង្គម ត្រូវបានចាត់ឱ្យមានឡើង របបសង្គមរាស្ត្រនិយមត្រូវបានរំខានឥតឈប់ឈរ ដោយវិបត្តិនយោបាយសង្គមកាន់តែជ្រាលជ្រៅទៅៗ ដែលបណ្តាលឱ្យការប្រឆាំងកាន់តែកើនឡើង ។ នៅជនបទ កសិករជាច្រើនបានស្តីបន្ទោសការគ្រប់គ្រងរបស់សម្តេចសីហនុ ថាបានពង្រីកគម្លាតកាន់តែធំរវាងអ្នកមាននៅទីក្រុង និងអ្នកក្រនៅជនបទ និងបានធ្វើឱ្យការលំបាកវេទនាផ្នែកកសិកម្មកាន់តែអាក្រក់ កសិករក្រជាងគេមានការមិនសប្បាយចិត្តជាពិសេស ហើយជួរពួកគេបានចាប់ផ្តើមកើនឡើង ទោះបីពួកគេនៅមានចំនួនតិចនៅឡើយក៏ដោយ ។ នៅភ្នំពេញ និងទីក្រុងដទៃទៀត ប្រជាប្រិយភាពរបស់សម្តេចក៏បានថយចុះផងដែរ៖ ពួកអ្នកដើងចាស់នៃគណបក្សប្រជាធិបតេយ្យមិនមែនកុម្មុយនីសខ្លះ ដែលបានភ្ជាប់ខ្លួនជាមួយសម្តេច និងសង្គមរាស្ត្រនិយម ក្នុងទសវត្សរ៍ ១៩៥០ បានវិលមកប្រឆាំងព្រះអង្គវិញ ដូចពួកអ្នកបច្ចេកទេសដែលកំពុងរីកលូតលាស់ដែរ ។ ពួកអ្នកមានការអប់រំ និងយុវជន បានរត់ចោលព្រះអង្គ ជំរុញដោយបំណងចង់លើកតម្កើងយុត្តិធម៌សង្គម និងប្រឆាំងអំពើពុករលួយ និងអសមភាពក្នុងសង្គម ។ ពួកគេជាច្រើននាក់ បដិសេធសញ្ញាណដែលថា ពួកអ្នកមានគឺមានដោយសារពួកគេសមនឹងទទួលបាន និងមិនសប្បាយចិត្តអំពីរបៀបដែលពួកអ្នកមានអំណាចប្រព្រឹត្តចំពោះប្រជាជនធម្មតា ដោយវិធីដៃក្តៅ និងដោយក្រអឺតក្រទម ។ ពួកគេមានជំនឿថា យុត្តិធម៌សង្គមនឹងអាចទទួលបានដោយការលប់បំបាត់នូវអ្វីដែលពួកគេមើលឃើញថាជាសក្តិភូមិនិយមនៅក្នុងប្រទេសកម្ពុជា មានន័យថា "សិទ្ធិ និងសេរីភាពកាន់តែខ្ពស់ និងការបញ្ចប់នូវនយោបាយត្រួតត្រាដោយបណ្តាញការងាររបុគ្គលរបស់ពួកអ្នកគ្រប់គ្រងដែលមានបុព្វសិទ្ធិនោះ" ។ អ្នកខ្លះត្រូវបានទាក់ទាញដោយលទ្ធិម៉ាក្សនិយម ម៉ៅនិយម បដិវត្តន៍វៀតណាម ឬរហូតដល់គំរូរបស់ឆេហ្គេវ៉ារ៉ា ថែមទៀតផង អ្នកផ្សេងទៀតបានយល់ស្របឱ្យមានលទ្ធិប្រជាធិបតេយ្យសភានិយម ។ ក្នុងពេលនៃការផ្ទុះឡើងរបស់ពួកនិស្សិតសកម្មនិយម ពួកនិស្សិតឆ្វេងនិយមដែលស្វ័យអប់រំខាងនយោបាយ និងស្វ័យចាត់តាំង បានក្លាយជាកម្លាំងដ៏សំខាន់មួយ

ហើយ ទោះបីជាមានការបង្ក្រាបនិងការកំចាត់កំចាយក៏ដោយ ក៏វណ្ណៈកម្មករនៅតាមរោងចក្រនានាត្រូវបានពង្រីក និងពុះកញ្ជ្រោលឡើងដែរ ។ ពួកអ្នកបដិវត្តនិយម ក៏ដូចពួកដាច់ខាតនិយម មានការភ្ញាក់ផ្អើលកាន់តែខ្លាំងឡើង ដោយសម្តេចសីហនុបានទទួលយក លន់ ណុល និងសមាសភាពដទៃទៀត ដែលពួកគេបានកំណត់ថាជាពួកផ្តាច់ការ និងពុករលួយជាទីបំផុតនោះ។

ដូច្នេះ ការតវ៉ារបស់អ្នកទីក្រុងនិងការរំជើបរំជួលរបស់កសិករ ប្រឆាំងរបបសង្គមរាស្ត្រនិយម បានផ្ទុះឡើងនៅក្នុងឆ្នាំ ១៩៦៦ និងមានសភាពកាន់តែខ្លាំងក្លានៅដើមឆ្នាំ ១៩៦៧។ ការណ៍នេះបានបង្កើតលទ្ធភាពសំរាប់ឱ្យ បពខ រៀបចំការប្រឆាំងដោយផ្ទាល់ ឬតាមរយៈ ខៀវ សំផន និងពួកបញ្ញាជនប្រឆាំងដទៃទៀត ឱ្យទៅតាមទស្សនៈរបស់បក្ស ហើយតាមរយៈពួកគេទាំងនេះ បក្សបន្តសាកល្បងបញ្ចូលឥទ្ធិពលរបស់ខ្លួន និងរូបភាពនៃបដិវត្តន៍កម្ពុជាមួយ ដឹកនាំដោយពួកបណ្ឌិតទស្សនវិជ្ជាមកពីប្រទេសបារាំង ។ យោងតាមយុទ្ធវិធីរបស់ បពខ អនុម័តឡើងសំរាប់ការបោះឆ្នោតឆ្នាំ ១៩៦២ បណ្តាញបង្កប់របស់ បពខ បានខិតខំធ្វើការយ៉ាងខ្លាំងដើម្បីធានាឱ្យ ខៀវ សំផន បានជាប់ឆ្នោតជាថ្មីទៀត ក្នុងការបោះឆ្នោតនាពេលខាងមុខ ក្នុងខែកញ្ញា ឆ្នាំ ១៩៦៦ ។ បក្សក៏បានជួយ ហ៊ូ នឹម ផងដែរ តែមិនបានជួយ ហ៊ូ យន់ ទេ ក្នុងយុទ្ធនាការមួយដែលអ្នកទាំងបីនាក់នេះបានឈរឈ្មោះប្រឆាំងបេក្ខជនសង្គមរាស្ត្រនិយមដទៃទៀតដែលគាំទ្រដោយសម្តេចសីហនុ ។

ក៏ប៉ុន្តែ ជ័យជំនះនៃការបោះឆ្នោតនេះគឺបានមកដោយការខិតខំជាសំខាន់បំផុត ពីការគាំទ្រយ៉ាងខ្លាំង ដែលពួកគេទាក់ទាញបានពីមណ្ឌលជនបទនានា ដែលពួកគេបានឈរឈ្មោះ ជាដើរឯកនៃកំហឹងយ៉ាងប្រពលកម្ម របស់ពួកកសិករដែលប្រឆាំងការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម និងការរំលោភពីសំណាក់រដ្ឋអំណាចមូលដ្ឋានរបស់រដ្ឋាភិបាល ។ ពួកគេបានឈ្នះឆ្នោតដោយសម្លេងភាគច្រើនលើសលប់ ដែលជាការចុះបញ្ជាំងអំពីប្រជាប្រិយភាពនៃគោលជំហរទិតៀនរបស់ពួកគេ ចំពោះរបបសម្តេចសីហនុ ទោះបីជាពួកគេបានកំណត់យកយុទ្ធវិធីរបស់ បពខ ដែលគាំទ្រដោយវៀតណាម ដោយប្រកាសថាស្មោះត្រង់ចំពោះសម្តេចសីហនុ ដោយគ្រាន់តែថ្កោលទោសតែពីការងាកវេពីនយោបាយរបស់សម្តេចតែប៉ុណ្ណោះ ។

ចំណែក ហ៊ូ យន់ និង ហ៊ូ នឹម វិញ ក៏បានធ្វើការឱ្យ បពខ ដោយឡែកដែរ តែជាមួយពួកបញ្ញាជនដាច់ខាត និងបដិវត្តនិយមដទៃទៀតនៅក្នុងទីក្រុងភ្នំពេញ ដើម្បីចាត់តាំងពួកនិស្សិត គ្រូបង្រៀន មន្ត្រីរាជការស៊ីវិល ពួកអ្នកបច្ចេកទេស ពាណិជ្ជករ និងកម្មករ ដែលប្រឆាំងរបបសង្គមរាស្ត្រនិយម ។ ពួកគេបានយកមកប្រើប្រាស់នូវបន្ទូនយោបាយ និងសង្គមដូចគ្នាខ្លះ ដែលបក្សបានខិតខំប្រើធ្វើជាមូលដ្ឋាននៃការជ្រើសរើស ប៉ុន្តែពួកគេស្ថិតក្នុងស្ថានភាពល្អជាងអង្គការបង្កប់ខ្លួនយ៉ាងច្រើន ក្នុងមនោគតិរបស់ប្រជាជន និងក្នុងន័យនៃការទាក់ទងខាងសង្គមកិច្ចវិញ ដើម្បីយកប្រៀបលើការកើនឡើងនៃការមិនសប្បាយចិត្ត។ ជាការចំអក ពួកគេត្រូវបានគំរាមថាចង់ប្រែក្លាយរូបភាព បពខ ដែលថាពួកគេជាមេដឹកនាំនៃបដិវត្តន៍មួយសំរាប់យុត្តិធម៌សង្គម ឱ្យទៅជាការពិត ដែលនឹងធ្វើឱ្យពួកគេក្លាយជាអ្នកប្រកួតប្រជែងរបស់បក្សក្នុងសំបុក ។ ជាក់ស្តែង នៅចុងឆ្នាំ ១៩៦៦ ហ៊ូ យន់ និង ហ៊ូ នឹម បានបង្កើតគណៈកម្មាធិការសម្ងាត់មួយ - ដែលក្នុងនោះ ខៀវ សំផន ពុំមានតួនាទីអ្វីទាំងអស់ - ដើម្បីសម្របសម្រួលសកម្មភាពប្រឆាំង និងពិចារណាអំពីជំរើសនានាដែលត្រូវប្រកាន់យក ដើម្បីផ្តួលរំលំ មិនត្រឹមតែ លន់ ណុល ប៉ុណ្ណោះ តែសម្តេចសីហនុផងដែរ ក្នុងនេះរួមមានការធ្វើសកម្មភាពនយោបាយ និងប្រដាប់អាវុធផង ។

សម្តេចសីហនុ បានដឹងច្បាស់អំពីការគំរាមកំហែងរបស់ពួកគេ ដែលមានទំហំធំ និងចេះតែកើនឡើង តែជាជំពៅសម្តេចមិនបានយល់អំពីការទាក់ទងរបស់ពួកគេជាមួយបពខ និង បពវ ទេ ។ ក្រោយពីការទិតៀនរបស់ពួកគេ ចំពោះរបបសម្តេចក្នុងពេលយុទ្ធនាការបោះឆ្នោតខែកញ្ញា ឆ្នាំ ១៩៦៦ មក សម្តេចបានត្រៀមថានឹងផ្តល់ការសរសើរដល់របាយការណ៍មិនត្រឹមត្រូវនៃបណ្តាញព័ត៌មានរបស់ លន់ ណុល ស្តីពីតួនាទីខ្ពស់ក្នុងចលនាកុម្មុយនីសនិងចំណងជាមួយហាណូយ របស់ពួកគេ។ រហូតដល់ពេលនេះ សម្តេចបានចាត់ទុកចលនាកុម្មុយនីសខ្មែរ ថាត្រូវបានគ្រប់គ្រងដោយពួកខ្មែរវៀតមិញនៃអតីត បកស ដែលទ្រង់នៅតែ

មានជំនឿថា ធ្វើអ្វីៗតាមតែបញ្ជារបស់ពួកកុម្មុយនីសវៀតណាមដែលជាគ្រូរបស់ពួកគេ ។ លោកមានជំនឿជឿជាក់ថា ពួកបញ្ញាជនដែលបានចូលរួមជាមួយសង្គម បន្ទាប់ពីត្រឡប់មកពីប្រទេសបារាំងវិញនោះ ទោះបីជាពួកគេស្ថិតក្រោមឥទ្ធិពលមនោគមវិជ្ជាបរទេសក៏ដោយ ក៏ពួកគេនៅតែជាផ្នែកមួយនៃក្រុមនយោបាយរបស់ព្រះអង្គ ឬបែរខ្នងដាក់វិញបើសិនជាពួកគេវង្វេង ។ ឥឡូវ សម្តេចបានចោទពួកខ្មែរក្រហមប្រភេទនេះ ថាបានដឹកនាំការអំពាវនាវឱ្យផ្តួលរំលំព្រះអង្គ ដោយទ្រង់បានប្រកាសថា ពួកគេបានធ្វើសកម្មភាពតាមបញ្ជារបស់ បពវ ដូចពួកខ្មែរវៀតមិញដែរ និងចង់ឱ្យប្រទេសកម្ពុជាទៅជាអាណានិគមរបស់វៀតណាម ។ ក្រោយមក ព្រះអង្គទ្រង់មានបន្ទូលអំពីការដណ្តើមកាន់កាប់ការដឹកនាំ បពខ ដោយពួកបញ្ញាជនខ្មែរក្រហម ដែលបានបែរមកប្រឆាំងព្រះអង្គវិញ តាមបញ្ជារបស់ បពវ ។

*ការវិលត្រឡប់របស់ ស*

ក្នុងគ្រាជាមួយគ្នានោះ ពេល ស បានវិលត្រឡប់ពី សបវ មកតាយនីញវិញ ក្នុងខែកញ្ញា ឆ្នាំ ១៩៦៦ ទើបបានដឹងថា វៀតណាមបានជម្លៀសមេដឹកនាំ បពខ ដទៃទៀត នៅមន្ទីរ ១០០ ឱ្យចូលជ្រៅទៅក្នុងខេត្តនេះថែមទៀត បន្ទាប់ពីជំរុំបានទទួលរងការវាយប្រហារជាច្រើនលើកដោយកងកម្លាំងសហរដ្ឋអាមេរិក និងការវាយឆ្មក់ចូលរបស់កងពិសេសនៃពួកព្រៃនគរ ដែលហៀបតែនឹងចាប់បានកម្មាភិបាល បពខ ជាន់ខ្ពស់ម្នាក់នៅទីនោះទៅហើយ ។ ក្នុងមូលដ្ឋានចាស់នេះ មាននៅសេសសល់តែខ្មែរមួយចំនួនប៉ុណ្ណោះ ។

អនាគតផ្លូវដើរនៃបដិវត្តន៍កម្ពុជា ត្រូវបានលើកយកមកពិភាក្សានៅកន្លែងថ្មី ក្នុងការប្រជុំគណៈកម្មាធិការមជ្ឈិម បពខ មួយ នាពេលក្រោយមក ក្នុងខែកញ្ញាដដែលនោះ ដែលត្រូវបានធ្វើឡើងស្របពេលគ្នានឹងសន្និបាតបក្ស ដែលមានកម្មាភិបាលប្រមាណ ៦០ នាក់ចូលរួម ។ ស បានប្រកាន់ខ្ជាប់នូវគោលជំហរដើម អំពីការតស៊ូនយោបាយ ។ រូបគេបានធ្វើការផ្លាស់ប្តូរសេចក្តីសំរេចដែលបានធ្វើឡើងក្រោមឥទ្ធិពលវៀតណាម ដោយ អៀង សារី, សុន សេន និង សោ ភឹម ក្នុងពេលរូបគេអវត្តមាន ដើម្បីបន្ថយដល់កំរិតអប្បបរិមានូវការតស៊ូប្រដាប់អាវុធ អំពាវនាវឱ្យខិតខំថែមទៀតក្នុង"ការរៀបចំបង្កើតលក្ខណៈសម្បត្តិ ដើម្បីដឹកនាំធ្វើសង្គ្រាមប្រជាជន" ក្នុងនេះរួមទាំងការរៀនសូត្រពីបច្ចេកទេសសង្គ្រាមឈ្លបរបស់វៀតណាមផង ។ ជាទូទៅ មាគ៌ាបក្សនៅតែស្ថិតលើការខិតខំបន្ថែម បង្កើនការធ្វើសកម្មភាពនយោបាយ ក្នុងនេះរួមទាំងតាមរយៈការធ្វើសកម្មភាពក្នុងទីក្រុង និងការឃោសនាសំរាប់ការបោះឆ្នោតផង តែក្នុងពេលជាមួយគ្នានេះ ត្រូវត្រៀមខ្លួនជាស្រេចសំរាប់ធ្វើការតស៊ូដោយអាវុធជាយថាហេតុនៅតំបន់ជនបទ ដើម្បីទប់ទល់ការបង្ក្រាបនៅជនបទ និងឆ្លៀតឱកាសយកប្រៀបលើសញ្ញានៃការរំដើបរំជួលកាន់តែកើនឡើងនៅជនបទ ជាពិសេសនៅប៉ៃលិន ដែលប្រជាជនមានការមិនសប្បាយចិត្តកាន់តែខ្លាំងហើយនោះ ហាក់ដូចជាបានផ្តល់នូវគ្រឹះនយោបាយដ៏មានផលច្រើនជាពិសេស ។ សេចក្តីប្តេជ្ញារបស់ ស ដើម្បីបង្កើនការងារនៅនឹងកន្លែង ដើម្បីដើរតាមគន្លងរបស់វៀតណាមដែលទទួលបានការគាំទ្ររបស់ចិន បានបង្ហាញអំពីការទោរទន់របស់រូបគេដើម្បីបំពានលើដំបូន្មានរបស់វៀតណាម និងចិន ដែលថាឱ្យរូបគេទប់ខ្លួនកុំធ្វើការបះបោរដោយអាវុធមុនពេលឱ្យសោះនោះ ។

ឧបនិស្ស័យនេះ ត្រូវបានផ្តល់សញ្ញាថែមទៀត ដោយសកម្មភាពជានិមិត្តរូប និងជាក់ស្តែង ដើម្បីដក ស និងសមាជិកដទៃទៀត នៃគណៈកម្មាធិការអចិន្ត្រៃយ៍ ដែលស្ថិតនៅមន្ទីរ ១០០ ពីការរាំងខ្ទប់ស្ទើរតែទាំងស្រុងដោយវៀតណាម ឱ្យទៅនៅក្នុងតាយនីញដែលកាន់តែអសន្តិសុខខ្លាំងឡើងៗ ។ ជានិមិត្តរូប គោលបំណងបំបែកខ្លួនចេញ ត្រូវបានសំដែងចេញនៅក្នុងអនុសាសន៍មួយក្នុងពេលសមាជបក្សលើកក្រោយមកទៀតដែល បពខ ត្រូវបានប្រែឈ្មោះមកជា បក្សកុម្មុយនីសកម្ពុជា(បកក) ។ ការណ៍នេះនឹងបំបែកពួកកុម្មុយនីសខ្មែរចេញពី បពវ ក្នុងផ្លូវមួយដែលបញ្ជាក់អំពីឧត្តមភាពរបស់ខ្មែរ និងក្នុងសេចក្តីសង្ឃឹមថាប្រជាជនកម្ពុជាបានត្រៀមខ្លួនសំរាប់ធ្វើកុម្មុយនីសនិយមហើយ ដែលជាការផ្ទុយនឹងទស្សនៈតាំងពីយូរយាមកហើយរបស់វៀតណាម លើបញ្ហានេះ ។ ការវិវត្តន៍ជាក់ស្តែងនេះ បានកើតឡើងបន្ទាប់ពីសន្និបាតរបស់កម្មាភិបាល ដែលនៅពេលនោះ តាម

ការស្នើរបស់ អៀង សារី, ស បានសំរេចផ្លាស់ប្តូរទីតាំងរបស់មន្ទីរ១០០ ទៅនៅភូមិភាគឦសាននៃកម្ពុជា ដែល អៀង សារី ដែលជាអ្នកនយោបាយអន្ទះអន្ទែងនៅឡើយ បានទៅពីតាយនីញ ទៅទស្សនាកាលពីឆ្នាំ ១៩៦៥ និងដែល ស បានឆ្លងកាត់ក្នុងពេលធ្វើដំណើរទៅបរទេស និងពេលត្រឡប់មកវិញនោះ ។

សេចក្តីសំរេចទី ៣ បានសំដែងអំពីការកំណត់សំរាប់អនាគត ដើម្បីជៀសវាងការពឹងពាក់លើការគាំទ្ររបស់វៀតណាមខាងយោធានិងនយោបាយ ។ នេះគឺមានន័យថា បក្សកម្ពុជានឹងបដិសេធការផ្តល់នាពេលអនាគតរបស់វៀតណាម នូវអន្តរាគមន៍យោធានិងនយោបាយដោយទ្រង់ទ្រាយធំណាមួយ ដើម្បីជួយដល់បដិវត្តន៍នៅកម្ពុជា ដែលការណ៍នេះនឹងមានន័យថាជាការគ្រប់គ្រងប្រទេសកម្ពុជាដោយ បពវ នោះ ។ ជាពិសេស ប្រភេទនៃការ "ងើបឡើង" នៃកម្លាំងដែលបានលើកឡើងដោយ ឡេយន់ ត្រូវបានមើលឃើញថាជាសញ្ញានៃការរស់ឡើងវិញ ក្នុងការដាក់ស្តែង នូវគំរោងគ្រប់គ្រងឥណ្ឌូចិនរបស់វៀតណាម ដែលគណៈកម្មាធិការអចិន្ត្រៃយ៍ ទាំងអតីតក្រុមម៉ាក្ស-ឡេនីន និងសមាជិក បកឥ ប្រឆាំង ដោយបានអនុម័តយកគោលជំហរដែលបានលើកឡើងដោយ អៀង សារី និង កឹម តាំងពីដំបូងទីមកនោះ ។

ប៉ុន្តែ ការស្នើរបស់ អៀង សារី ដើម្បីប្តូរទីតាំងមន្ទីរ ១០០ ទៅឦសាន និងការយល់ស្របរបស់ ស នេះ ស៊ីសង្វាក់គ្នានឹងទស្សនៈលើកឡើងជាបន្តបន្ទាប់ដោយវៀតណាម តាំងពីសង្គ្រាមឥណ្ឌូចិនលើកទី ១ អំពីអត្ថន័យនយោបាយ និងយុទ្ធសាស្ត្រនៃតំបន់ខ្ពង់រាប ចំពោះកម្ពុជានិងឥណ្ឌូចិន ។ ទស្សនៈទាំងនេះ ត្រូវបានលើកឡើងជាថ្មីដែលយកជាការបាន នៅក្នុងឯកសារផ្ទៃក្នុង និងចំហទាំងឡាយ ដែលបានផ្សព្វផ្សាយបន្ទាប់ពីការបង្កើតមន្ទីរ ១០០ និងនៅពេល ស ស្ថិតនៅ សបវ ក្នុងឆ្នាំ ១៩៦៥ ។ ពួកគេបានគូសបញ្ជាក់អំពីសារសំ ខាន់បដិវត្តន៍នៅតាយង្វៀង ថាជាតំបន់មូលដ្ឋានឈ្លបជាយុទ្ធសាស្ត្រមួយដែលមានព្រំដែនរួមជាមួយកម្ពុជា ។ ពួកគេបាននិយាយថាតំបន់ខ្ពង់រាប គឺមានសារសំខាន់ជាអាយុជីវិតសំរាប់ឥណ្ឌូចិនទាំងមូល ពីព្រោះ - ដូចបារាំងធ្លាប់បានធ្វើរួចមកហើយ - សហរដ្ឋអាមេរិកចង់ប្រើវាធ្វើជាមូលដ្ឋានយោធាជាគន្លឹះមួយ និងធ្វើការឈ្លានពានប្រឆាំងប្រទេសទាំងបីនេះ ។ ជាសំណាងល្អ បើយោងតាម បពវ ជនជាតិភាគតិចដែលរស់នៅច្រកគាវតាមព្រំដែន មានប្រពៃណីតស៊ូមិនអាចបង្ក្រាបបាន ប្រឆាំងការជិះជាន់នៃពួកមនុស្សវាលរាប អាណានិគមនិយម និងចក្រពត្តិនិយម ដែលធ្វើឱ្យពួកគេប្រឆាំងរបបព្រៃនគរ តែមិនប្រឆាំងនឹងកម្មាភិបាលកុម្មុយនីសវៀតណាមទេ ។ ដោយមិនអើពើនឹងលទ្ធភាពនៃការសង្ស័យជាទូទៅរបស់ជនជាតិភាគតិច ចំពោះពួកវៀតណាមវាលរាប បពវ បានរំលឹកអំពីតើ - ដោយចាប់ផ្តើមពីអាវុធបុរាណ ដូចជាចំរ៉ូង ខ្នារ អន្ទាក់ និងព្រួញជ័រធក់ - ជនជាតិភាគតិចបានធ្វើការបះបោរប្រឆាំងនៅមូលដ្ឋានក្នុងប្រទេសវៀតណាមក្នុងឆ្នាំ ១៩៥៩ បានចូលពាក់ព័ន្ធតាំងពីពេលនោះមក ជាមួយការតស៊ូមិនដាច់រយៈ និងដោយមានះ រួមផ្សំជាមួយសកម្មភាពនយោបាយ និងប្រដាប់អាវុធ យ៉ាងដូចម្តេចនោះ ។ ការរំលឹករឿងថយក្រោយឡើងវិញនានា បានអបអរសាទរអំពីថាតើការបះបោរកុម្មុយនីស នៅភាគខាងត្បូងបានផ្តល់នូវការជួយជ្រោមជ្រែងដ៏ខ្លាំងក្លាមួយ បន្ទាប់ពីកម្មាភិបាលវៀតណាមរៀបចំពួកជនជាតិឱ្យដណ្តើមកាំភ្លើងនិងអាវុធទំនើប ពីកងកម្លាំងប្រដាប់អាវុធរបស់ យៀម ដោយពឹងផ្អែកលើប្រជាជនខ្ពង់រាប ដែលមានគុណសម្បត្តិគួរឱ្យកោតស្ញប់ស្ញែង ចំពោះភាពទៀងត្រង់ ភាពត្រឹមត្រូវ ភាពស្មោះត្រង់ ភាពសប្បុរសធម៌ និងភាពក្លាហានដ៏អស្ចារ្យ ដែលទាំងអស់នេះធ្វើឱ្យពួកគេក្លាយជាកងឈ្លបដ៏ល្អជាទីបំផុតរកគ្មាន ដែលមិនដែលក្បត់បដិវត្តន៍ទាល់តែសោះ យ៉ាងដូចម្តេច ។ ទោះបីជាពួកជនជាតិមានការឱនថយដាក់ស្តែងយ៉ាងណាក៏ដោយ ក៏វៀតណាមបានទទួចថា ពួកគេមានសតិអារម្មណ៍នយោបាយខ្ពស់ដែរ ពួកគេបានយកតាយង្វៀងធ្វើជាមូលដ្ឋានដ៏រឹងមាំមួយសំរាប់គ្រប់ទិដ្ឋភាពនៃសង្គ្រាមប្រជាជន ដោយសន្មត់ថាត្រូវបានរំដោះបាន "ទាំងស្រុង" នៅឆ្នាំ ១៩៦៤ ។

មែនទែនទៅ អនុសាសន៍របស់ អៀង សារី ស្របពេលគ្នានឹង - និងប្រហែលជាឆ្លើយតបទៅនឹង - ការស្នើដាក់ស្តែងរបស់ បពវ ឱ្យពង្រីកសង្គ្រាមនៅតាយង្វៀង ទៅតំបន់ខ្ពង់រាបផ្នែកខាងក្នុងព្រំដែនកម្ពុជា ។ នា សមាជ បពវ ក្នុងខែកញ្ញា ឆ្នាំ

១៩៦៦ កម្មាភិបាលតាយង្វៀងបានអំពាវនាវដល់ប្រជាជនជនជាតិភាគតិច នៅសងខាងព្រំដែន ឱ្យប្រយុទ្ធនឹងសត្រូវរួមរបស់ពួកគេតាមរយៈសកម្មភាពយោធា ដើម្បីបន្សោះការប៉ុនប៉ងណាមួយរបស់សហរដ្ឋអាមេរិក ដើម្បីប្រែក្រឡាស់ផលចំណេញរបស់ បពវ ។ សមាជបានប្រកាសថាពួកអប្បភាគជននឹង "ងើបឡើងដើម្បីរំដោះខ្លួន នៅពេលពួកគេមានហេតុផលនឹងធ្វើដូច្នេះ" ព្រមទាំងធ្វើឱ្យបរាជ័យខ្មាំងសត្រូវនៃបដិវត្តន៍ និងការពារមេដឹកនាំរបស់បដិវត្តន៍ ទោះបីជាពួកគេមានតែអាវុធបុរាណក៏ដោយ ។

ទីបញ្ចប់ ការផ្តល់យោបល់ឱ្យប្តូរទីតាំងទៅលើភ្នំនេះ ក៏ជាការនឹកទៅដល់រឿងដើមនៃសង្គ្រាមឥណ្ឌូចិនលើកទី១ជាទីសក្ការៈ ការយកមកប្រើដ៏ល្បីល្បាញរបស់ បកឥ នូវតំបន់ដីខ្ពស់នៃជនជាតិភាគតិចវៀតបាក់នៃភាគខាងជើងវៀតណាម ក្នុងការបង្កើនការរៀបចំរបស់ពួកគេដើម្បីធ្វើការតស៊ូប្រដាប់អាវុធប្រឆាំងបារាំង នៅឆ្នាំ ១៩៤៥ ។ អស់រយៈពេលជាច្រើនឆ្នាំមកហើយពួកវៀតណាមបានធ្វើឱ្យស្របគ្នារវាង វៀតបាក់ និង តាយង្វៀង ជាទីកំណើតនៃបដិវត្តន៍នៅភាគខាងជើងក្នុងទសវត្ស ១៩៤០ និងនៅភាគខាងត្បូងក្នុងទសវត្ស ១៩៥០ ។ ការទៅកាន់រ៉ាតាណាគីរីនេះ ធ្វើឱ្យ ស នឹកឃើញដល់ការយល់សប្តិនៃ បបបខ ចាស់នៃកម្ពុជាមួយរបស់ ហូ ជីមិញ ដោយធ្វើឱ្យរស់ឡើងវិញនូវតួនាទីដែល ហូ ជីមិញ និង វៀតបាក់ បានធ្វើក្នុងប្រវត្តិសាស្ត្ររបស់ បកឥ ឆ្នាំ ១៩៤៥ ។ នោះគឺការវិលត្រឡប់នៃមេដឹកនាំបក្សមកពីការស្នាក់នៅក្នុងមណ្ឌលបដិវត្តន៍នៅឯនាយប្រទេស (សហភាពសូវៀតនិងចិន ក្នុងករណី ហូ, ចិន និង សបវ ក្នុងករណី ស) មកកាន់តំបន់មួយ ដែល-ជាភូមិសាស្ត្រ-បានអនុគ្រោះដល់ការទាក់ទងជាមួយកម្លាំងបដិវត្តន៍បរទេស និងដែលមានប្រជាជនជនជាតិភាគតិចរស់នៅ ដែលមានសមានចិត្តពីធម្មជាតិចំពោះបដិវត្តន៍ ដែលអាចពឹងពាក់ពួកគេដើម្បីការពារមេដឹកនាំបក្ស ។ ដូច វៀតបាក់ ដែរ រ៉ាតាណាគីរីគឺជាកន្លែងមួយដែល ស អាចធ្វើការដោយផ្ទាល់ជាមួយជនជាតិភាគតិច ដើម្បីបណ្តុះបណ្តាលពួកគេអំពីគោលការណ៍ម៉ាក្ស-ឡេនីន ក្នុងការតស៊ូវណ្ណៈ ការតស៊ូរំដោះជាតិ ធ្វើការងារនយោបាយក្នុងកងទ័ពបដិវត្តន៍ និងសង្គ្រាមឈ្លប ។ ដូច ហូ ដែរ រូបគេបានចូលពាក់ព័ន្ធផ្ទាល់ក្នុងការកំណត់វិធានការដើម្បីរៀបចំធ្វើការបះបោរជាទូទៅមួយជាយថាហេតុនៅទូទាំងប្រទេស ។ រូបគេអាចចាប់ផ្តើមដោយកងការពារប្រដាប់អាវុធអចិន្ត្រៃយ៍មួយ ដើម្បីការពារអង្គការដឹកនាំបក្ស ដែលនឹងជួយបង្ហាត់បង្រៀនអំពីការប្រយុទ្ធបែបសេនាជនក្នុងភូមិ ដែលក្រុមស្វ័យការពារប្រដាប់អាវុធត្រូវបានបង្កើតរួចហើយ ។ ការនេះនឹងក្លាយជាការត្រៀមរៀបចំសំរាប់ថ្ងៃណាមួយដែលខ្មាំងធ្វើជំហានខុស ដូចជារដ្ឋប្រហារជាដើម វានឹងបង្កើតជាឱកាសមួយដែលកម្លាំងបដិវត្តន៍នឹងឆក់យកបានដ៏ល្អបំផុត ។ ស បានធ្វើតាមគំរូនេះ ជាវគ្គជាវគ្គ រវាងឆ្នាំ ១៩៦៧ និង ឆ្នាំ ១៩៦៩ ។

អង្គការកុម្មុយនីសនៅរ៉ាតាណាគីរី រួមជាមួយអង្គការភូមិភាគដទៃទៀតនៃកម្ពុជា បានទទួលរងយ៉ាងធ្ងន់ធ្ងរនូវការបង្ក្រាបនាចុងទសវត្ស ១៩៥០ បន្ទាប់ពី ស៊ីវ ហេង ចុះចូលជាមួយ លន់ ណុល និងរលកនៃការចាប់ខ្លួននិងការសម្លាប់ ក្នុងឆ្នាំ ១៩៦២-១៩៦៣ ដែលបានបង្ខំឱ្យសកម្មជនរត់ចេញពីភូមិទៅចូលព្រៃកាន់តែជ្រៅថែមទៀត ។ មិនដូចទីកន្លែងដទៃទៀតនៃកម្ពុជាទេ ពេញមួយចុងទសវត្ស ១៩៥០ និងនៅដើមទសវត្ស ១៩៦០ ផ្នែកនានានៃចលនាកុម្មុយនីសនៅរ៉ាតាណាគីរី នៅត្រូវរៀបចំជាសំខាន់ដោយពួកវៀតណាម និងដោយនៅឆ្នាំ ១៩៦៤ កងឈ្លបប្រដាប់អាវុធវៀតណាមបានប្រើប្រាស់តំបន់រ៉ាតាណាគីរីធ្វើជាជម្រកបណ្តោះអាសន្ន ដើម្បីធ្វើការជ្រើសរើសជនកម្ពុជា - រួមទាំងជនជាតិភាគតិចផង - ឱ្យចូលក្នុងអង្គភាពយោធាចំរុះ ។ ក៏ប៉ុន្តែយោងតាមមាគ៌ារបស់ បពខ និង បពវ មិនត្រូវធ្វើការវាយប្រហារទៅលើប៉ុស្តិ៍ជួរមុខរបស់រដ្ឋាភិបាលសង្គមទេ ។ បពខ បានកំរិតខ្លួនគេឱ្យធ្វើការជំរុញប្រជាជនធ្វើការតវ៉ាប្រឆាំងនយោបាយរបស់រដ្ឋាភិបាល និងការរំលោភនានា ។ ការឃោសនារបស់ បពខ គូសសង្កត់អំពីអនាគតសហប្រតិបត្តិការជាមួយវៀតណាម ដោយព្រលយពាក្យថា ថ្ងៃមួយពួកវៀតណាមអាចធ្វើអន្តរាគមន៍ដោយយោធាដើម្បីជួយបដិវត្តន៍កម្ពុជា ។ វត្តមានតាំងពី ឆ្នាំ ១៩៦៥ នៃទីបញ្ជាការកងពលកុម្មុយនីសវៀតណាមមួយនៅទីនោះ និងការកើនឡើងនៃវត្តមាននៅទីនោះក្នុងឆ្នាំ ១៩៦៦ បានបង្កឱកាសសំរាប់លទ្ធភាពនេះ ។

*ពេល អៀង សារី ទៅធ្វើទស្សនកិច្ចនៅឦសាន រូបគេបានកោះប្រជុំកម្មាភិបាល អំពាវនាវឱ្យពួកគេពង្រីកបណ្តាញអង្គការសម្ងាត់នៅទីនោះ និងត្រៀមប្រឆាំងការឈ្លានពានរបស់សហរដ្ឋអាមេរិកណាមួយមកលើកម្ពុជា ដោយបង្កើតក្រុមចល័តជាស្រេចដើម្បីវាយទៅលើពួក លន់ ណុល ប៉ុន្តែមិនមែនសម្តេចសីហនុទេ ។ ទោះបីជា - និងដោយហេតុថា - ការបង្ក្រាបរបស់រដ្ឋាភិបាល ភូមិភាគឦសានមិនជានាថានឹងមានឱកាសល្អដើម្បីធ្វើសកម្មភាពប្រឆាំងសង្គមទេ ។ ប្រជាជននៅមូលដ្ឋានជាច្រើនស្អប់ពួករដ្ឋាភិបាលយ៉ាងខ្លាំង ដែលតាំងពីឆ្នាំ ១៩៥៩ មក បានក្លាយជាកម្មវត្ថុនៃនយោបាយសមាហរណកម្មជាតិមួយដែលផ្តើមគំនិតដោយសម្តេចសីហនុ ក្រោមការដឹកនាំនៃយោធារបស់ លន់ ណុល ។ ក្នុងការអនុវត្ត ការនេះមានន័យថាឱ្យពួកគេផ្លាស់ប្តូរទីកន្លែងរស់នៅនិងធ្វើការដោយបង្ខំទារពន្ធដារខ្ពស់ ធ្វើការធក់ប្ញន់ ធ្វើខ្មែរូបនីយកម្មក្នុងការដាក់ស្ពែង ព្រមទាំងចាប់ខ្លួន និងសម្លាប់ ពួកប្រឆាំង ឬពួករឹងទទឹង ។*

*ក្នុងឆ្នាំ ១៩៦៦ សង្គមរាស្រ្តនិយម បានអនុវត្តកម្មវិធីធ្វើអាណានិគមដីថ្មី ដោយបញ្ជូនពួកខ្មែរឱ្យទៅរស់នៅ ដោយមានការគាំទ្រពីពួកកងកម្លាំងយោធា ដើម្បីបង្កើតចំការកៅស៊ូនៅរតនគីរី ។ ការនេះបានបង្កឱ្យមានហឹង្សារបស់ពួកជនជាតិភាគតិចដោយឯកឯង ជំរុញឱ្យ ស ទទួលយកហេតុផលរបស់ សារី ដែលថាតំបន់ភ្នំជាទីកន្លែងដ៏ល្អសំរាប់ជំរុញបដិវត្តន៍ឱ្យទៅមុខ ។ ការប្តូរទីតាំងរបស់មន្ទីរ ១០០ បានចាប់ផ្តើមនៅដើមខែវិច្ឆិកា ឆ្នាំ ១៩៦៦ នៅពេលមានការវាយប្រហារដ៏ធំមួយទៀតរបស់សហរដ្ឋអាមេរិក នៅតាមបណ្តោយព្រំដែន តាយនីញ-កម្ពុជា ។ សារី បានទៅមុនគេ ដោយធ្វើដំណើរឡើងតាមផ្លូវលំ ហូ ជីមិញ និងរៀបចំការទាក់ទងជាមួយវៀតណាមសំរាប់ពួកអ្នកដែលត្រូវធ្វើដំណើរទៅតាមក្រោយទៀត ។ នៅពេលទៅដល់ឦសានភ្លាមរូបគេបានបើកវគ្គសិក្សាមួយសំរាប់កម្មាភិបាលកុម្មុយនីសនៅនឹងកន្លែង ដោយពន្យល់ពួកគេថាអង្គការបានសំរេចបង្កើតលក្ខណៈសម្បត្តិនៅទីនេះ ដើម្បីដឹកនាំធ្វើសង្រ្គាមបដិវត្តន៍ ។ សារី និងកម្មាភិបាលទាំងនេះ បានបន្តពឹងពាក់លើជំនួយរបស់វៀតណាម ដូចជាការព្យាបាលផ្នែកពេទ្យដល់កម្មាភិបាលដែលមានជម្ងឺជាដើម ។*

*ពេលត្រឡប់មកដល់តាយនីញវិញ ស និងកម្មាភិបាលថ្នាក់ខ្ពស់ដែលនៅសេសសល់បានត្រឡប់ទៅ មន្ទីរ ១០០ ចាស់ដើម្បីចាត់តាំងបុគ្គលិកថ្នាក់ក្រោមឡើងវិញ ដោយខ្លះត្រូវជូនពួកគេទៅឦសាន អ្នកដទៃទៀតត្រូវពង្រាយតាមតំបន់មូលដ្ឋានផ្សេងទៀតនៃកម្ពុជា ជាពិសេសភូមិភាគបូព៌ា និងនិរតី ។ ស ខ្លួនឯងបានស្ថិតនៅជាមួយវៀតណាមនៅតាយនីញ ដែលតាំងពីខែឧសភា ឆ្នាំ ១៩៦៧ មក ជាទិសដៅនៃប្រតិបត្តិការរបស់សហរដ្ឋអាមេរិកម្តងទៀត ដែលជាប្រតិបត្តិការធំបំផុតនៃសង្រ្គាមរបស់ពួកគេប្រឆាំងពួកកុម្មុយនីសភាគខាងត្បូងរហូតមកទល់ពេលនេះ ។ ទើបតែដល់ខែកក្កដា ឬសីហា ឆ្នាំ ១៩៦៧ ទើបរូបគេបានទៅដល់ឦសាន ដោយធ្វើដំណើរជាថ្មីម្តងទៀតតាមផ្លូវលំហូជីមិញ បង្កើតឡើងដោយពួកនីរសាវៀតណាម ។*

*ពេលមន្ទីរ ១០០ ត្រូវបានបង្កើតឡើងនៅលើទឹកដីកម្ពុជារៀបរយហើយ ហើយ ស មានវត្តមាននៅ ឦសាន គណៈកម្មាធិការភូមិភាគមានគ្នា ៣ នាក់មួយ ត្រូវបានបង្កើតឡើង ដោយ ស ជាលេខា សារី ជាអនុលេខា និង សុន សេន ជាមនុស្សទី ៣ ។ ពួកគេបានចាត់តាំងអតីតសមាជិកក្រុមប្រជាជនជាច្រើននាក់មកពីតាយនីញ ឱ្យទទួលបន្ទុករៀបចំនៅមូលដ្ឋាន ។*

*ទោះបីជាត្រូវបានផ្លាស់ប្តូរទីតាំងហើយក៏ដោយ ក៏មន្ទីរ ១០០ នៅតែត្រូវថយទៅនៅជាប់នឹងមូលដ្ឋានយោធារបស់ បពវ នៅផ្នែកខាងក្នុងព្រំដែនវៀតណាម ដោយទទួលបានការការពារសន្តិសុខខ្លះពីការវាយប្រហាររបស់សហរដ្ឋអាមេរិក ។ ទោះបីជានៅលើដីខ្មែរក៏ដោយ ក៏បុគ្គលិកដោយឡែកនៃទីបញ្ជាការរបស់ ស និង សារី ស្ថិតនៅក្នុងតំបន់គ្រប់គ្រងដោយជម្រកអចិន្ត្រៃយ៍របស់វៀតណាមទី ១ នៅក្នុងទឹកដីកម្ពុជា ផ្តល់ឱ្យពួកគេចេញចូលជាមួយ បពវ បានដោយងាយ ។ យោងតាមប្រភពវៀតណាម ពីរនាក់នេះបានបន្តធ្វើការជាមួយសាខារបស់ បពវ និងចំណាយពេលរស់នៅក្នុងទឹកដីវៀតណាម ។ យោងតាមកម្មាភិបាលខ្មែរ នៅរតនគីរី ស ត្រូវបានហ៊ុំព័ទ្ធដោយវៀតណាម ចំណាយពេលវេលាជាច្រើនលើសលប់រស់នៅជំសមរម្យនៅ*

ក្នុងទឹកដីវៀតណាម ហើយចូលមកកាន់កម្ពុជាសំរាប់តែប្រជុំប៉ុណ្ណោះ ។ ដូច្នេះ ការផ្លាស់ប្តូរទីតាំងមិនមានន័យថាជាការផ្តាច់មន្ទីរ ១០០ ចេញពីការសាកសួរយោបល់ ឬពីការពឹងផ្អែកលើវៀតណាមនោះទេ ។

ម្យ៉ាងទៀត ការប្តូរទីតាំង គ្រាន់តែធ្វើឱ្យ ស, សារី និង សុន សេន ទទួលបន្ទុកលើខេត្តតែពីរប៉ុណ្ណោះ គឺ រតនគីរី និង មណ្ឌលគីរី ។ នួន ដែលបានត្រឡប់ពីការដឹកនាំការប្រជុំថ្នាក់ដឹកនាំនៅមន្ទីរ ១០០ ដើម្បីបង្កប់ខ្លួននៅក្នុងទីក្រុងភ្នំពេញ ជាអ្នកទទួលខុសត្រូវលើផ្នែកដទៃទៀតដែលនៅសល់នៃកម្ពុជា ។ ទាំងនេះរួមមាន បូព៌ាទិស ដែលលេខាភូមិភាគ សោ ភឹម បន្តសកម្មនៅព្រំដែនវៀតណាម និងរក្សាមូលដ្ឋាននៅសងខាងព្រំដែន ដូច្នេះជាការបើកច្រកសំរាប់ការទាក់ទងរវាង នួន និងពួកវៀតណាម ។ តំបន់ដទៃទៀត រួមមាននិរតីទិសដែលលេខាភូមិភាគ ម៉ា ម៉ង់ (ហៅ ប៉ង់) ដឹកនាំតំបន់មូលដ្ឋានមួយ ហើយ តាម៉ុក ដែលជាអនុលេខា ដឹកនាំតំបន់មួយទៀត ទាំងពីរនាក់នេះស្ថិតនៅឆ្ងាយពីព្រំដែនវៀតណាម ។ ពាយ័ព្យទិស ដែលលេខាភូមិភាគ រស់ ញឹម (ហៅ មូល អ៊ុន) និងអនុរបស់គាត់ គង់ សុផល (ហៅ កឺ) ជាអ្នកទទួលខុសត្រូវមូលដ្ឋានដោយឡែកពីគ្នាដែរ និងឧត្តរទិសដែល នួន បានរៀបចំឡើងវិញ ហើយ ដូចនៅពាយ័ព្យដែរ មិនមានព្រំដែនជាប់ជាមួយវៀតណាមទេ ។ ដូច្នេះ ជាក់ស្តែង នួន បន្តដឹកនាំបក្សដូចដែលរូបគេបានធ្វើតាំងពី ស ធ្វើដំណើរទៅហាណូយ កាលពីពាក់កណ្តាលឆ្នាំ ១៩៦៥ ដែរ ។

### *វោហាសាស្រ្ត និងដំបូន្មានរបស់វៀតណាម និងសច្ចធម៌ខ្មែរ*

ទោះបីជាពួកគេនៅទីណាក៏ដោយ នាចុងឆ្នាំ ១៩៦៦ និងដើមឆ្នាំ ១៩៦៧ ស, នួន និងពួកកុម្មុយនីសខ្មែរថ្នាក់ខ្ពស់ដទៃទៀត ត្រូវប្រឈមមុខនឹងការទូងស្គរវាយឃ្មោះនៃការឃោសនាជាសាធារណៈ កាន់តែខ្លាំងរបស់វៀតណាម ស្តីពីការគំរាមកំហែងរបស់សហរដ្ឋអាមេរិកមកលើកម្ពុជា ស្តីពីថាតើ ជាគោលការណ៍ នៅពេលណាត្រូវធ្វើការតស៊ូប្រដាប់អាវុធ និងស្តីពីភាពអស្ចារ្យនៃសង្គ្រាមប្រជាជន ។ ការណ៍នេះ បានផ្តល់នូវយុត្តិកម្មជាសក្តានុពលសំរាប់ពួកគេ ដើម្បីជំរុញការតស៊ូប្រដាប់អាវុធ ដើម្បីចម្លងចូលមកកម្ពុជា នូវអ្វីដែលសង្គ្រាមប្រជាជនត្រូវបាននិយាយថា ត្រូវធ្វើបានសំរេចនៅភាគខាងត្បូងវៀតណាម តែចំពោះមុខជនកម្ពុជានៅតែបន្តទោរទន់ទៅតាមការទទូចជាឯកជនរបស់វៀតណាម និងចិន ថាពួកគេត្រូវទប់ទល់ការប៉ុនប៉ងធ្វើបែបនេះ ។

សេចក្តីថ្លែងការណ៍នានារបស់វៀតណាមព្រមានថា សហរដ្ឋអាមេរិកមានការវក់វីនឹងតម្លើងថ្នាក់ការឈ្លានពានរបស់វាឱ្យហួសពីប្រទេសវៀតណាម ។ សេចក្តីថ្លែងការណ៍ បានសំដែងនូវសេចក្តីបារម្ភយ៉ាងខ្លាំងថា ឥណ្ឌូចិនកំពុងប្រឈមមុខនឹងសង្គ្រាមមួយដោយអាមេរិកឈ្លានពានចូលកម្ពុជា តែពួកគេមានជំនឿថា ការឈ្លានពានមួយបែបនេះនឹងត្រូវធ្វើឱ្យបរាជ័យដោយ"សង្គ្រាមបែបវៀតណាម" នៅទីនោះ ។ មេដឹកនាំបក្ស ឡេ យន់ បានប្រកាសថា វៀតណាមទទួលបានមេរៀនដ៏មានប្រយោជន៍មួយដើម្បីចែកឱ្យពួកកុម្មុយនីស ដែលប្រឈមមុខនឹងការគំរាមកំហែងនៃការឈ្លានពានរបស់សហរដ្ឋអាមេរិក ទៅលើប្រទេសតូច ក្រ និង មានប្រជាជនតិចៈ ទោះបីពួកគេចាប់ផ្តើមពីកម្លាំងតូចនិងខ្សោយ ក៏ពួកគេអាចស្ថាបនា តាមរយៈសង្គ្រាមប្រជាជន នូវកងទ័ពដ៏ខ្លាំងមួយ ដែលនឹងធ្វើឱ្យបរាជ័យ សូម្បីតែ "សត្រូវដែលហឹង្សា និងបំពាក់ដោយអាវុធពេញខ្លួន" បាន ។ ឡេ យន់ ក៏បានព្រមានផងដែរថា "របស់ដែលហៅថាប្រទេសអ្នកជាតិនិយម" មិនអាចគេចផុតពីការត្រួតត្រារបស់ចក្រពត្តិនិយមបានទេ វារលែងតែប្រទេសទាំងនោះស្ថិតក្រោមការដឹកនាំរបស់វណ្ណៈកម្មជីព តាមរយៈការតស៊ូមួយបែបនេះប៉ុណ្ណោះ ។

ដោយរំលឹកឡើងវិញពីស្នាដៃកាលពីអតីតកាលរបស់ពួកគេ ការឃោសនារបស់វៀតណាមបានបញ្ជាក់ឡើងវិញថា ផ្លូវដ៏ល្អបំផុតដើម្បីអនុវត្តហឹង្សាបដិវត្តន៍គឺ - តាមរយៈការរួមបញ្ចូលគ្នា នូវកុប្បកម្មនយោបាយ និងសកម្មភាពប្រដាប់អាវុធ - បង្កើតឡើងនូវរបបបដិវត្តន៍មួយនៅតំបន់ជនបទ និងតំបន់ភ្នំ ។ មុននឹងកំទេចកម្លាំងប្រឆាំងកុម្មុយនីសនៅមូលដ្ឋាន មានការ

*ទាមទារឱ្យបន្សោះការប៉ុនប៉ងទាំងឡាយណាដើម្បីកំចាត់ចលនាកុម្មុយនីស ។ ការនេះនឹងជំរុញបដិវត្តន៍ឱ្យទៅហួសពីស្វ័យការពារ ទៅជាការបះបោរដើម្បីដណ្តើមអំណាចនៅក្នុងមូលដ្ឋាននីមួយៗ ដោយដណ្តើមអាវុធពីខ្មាំង ដើម្បីចាត់តាំងកងកម្លាំងប្រដាប់អាវុធបដិវត្តន៍ ។ វៀតណាមនិយាយថា ពេលបង្កើតបានហើយ កម្លាំងទាំងនេះអាច"អភិវឌ្ឍន៍បានយ៉ាងលឿន ទាំងគុណភាព ទាំងបរិមាណ" ។ ពួកគេនិយាយថា ការដើរតាមមាគ៌ាទាំងនេះវានឹងបញ្ជាក់ការពិតកុម្មុយនីស ដែលថា"បើប្រជាជនមួយទោះបីតូចក្តី ជំជាត់ឡើងតាមមាគ៌ាត្រឹមត្រូវមួយ រួបរួមគ្នា និងប្រយុទ្ធដាច់ខាត ដើម្បីឯករាជ្យនិងសេរីភាព ពួកគេមានលទ្ធភាពពេញទីធ្វើមិនឱ្យសំរេចបាននូវគ្រប់រូបភាពនៃការឈ្លានពានរបស់ពួកចក្រពត្តិ" និងថាសង្គ្រាមប្រជាជនគឺជា"ក្រិត្យក្រមដែលជៀសមិនរួចសំរាប់ការតស៊ូបដិវត្តន៍ទាំងអស់ ដើម្បីធ្វើឱ្យបរាជ័យខ្មាំងសត្រូវទាំងអស់" ។*

*ការសរសើររបស់វៀតណាមដល់ការបះបោរប្រដាប់អាវុធ និងសង្គ្រាមប្រជាជន ក៏ទទូចផងដែរថា អ្នកបដិវត្តន៍ដែលធ្វើការបះបោរប្រដាប់អាវុធ និងសង្គ្រាមប្រជាជននេះ ត្រូវជៀសវាងការប្រកាន់ថាខ្លួនទាប តូចជាងគេ និងនិន្នាការពឹងពាក់លើអ្នកដទៃ ត្រូវបន្តដើរតាមមាគ៌ាត្រឹមត្រូវនៃ "ឯករាជ្យ ម្ចាស់ការ ខ្លួនទីពឹងខ្លួន" ។ ការវាយតម្លៃសភាពការណ៍ថាមិននាំទៅឱ្យមានការតស៊ូប្រដាប់អាវុធនោះ គឺជាធាតុស្តាំនិយមមិនត្រឹមត្រូវ ជាគោលជំហរអវិជ្ជមាន ជាការធ្ចុះបញ្ចាំងការភ័យខ្លាចជាសត្យានុម័តចំពោះការលំបាក និងសេចក្តីទុក្ខវេទនា ។ អាកប្បកិរិយាត្រឹមត្រូវគឺ មិនថាទោះបីជាកម្លាំងបដិវត្តន៍តូចតាចយ៉ាងណាក្តី ក៏កម្លាំងប្រជាជនគឺជាកម្លាំងដែលមិនអាចអ្នកណាជំនះបាន ទោះជាខ្លាំងយ៉ាងណាក៏ដោយ កម្លាំងសីលធម៌របស់អ្នកបដិវត្តន៍ក៏មិនអាចអ្នកណាយកឈ្នះបាន និងអាចប្រែក្លាយជាកម្លាំងជាក់ស្តែងបានយ៉ាងប្រាកដ ។ កាលណាកម្លាំងដ៏មហិមា និងមិនរាថយនៃស្មារតីបដិវត្តន៍ ត្រូវបានរួមផ្សំជាមួយស្មារតីប្រយុទ្ធ និងសេចក្តីប្តេជ្ញាជំនះលើគ្រប់ការលំបាក ការនេះអាចធ្វើពី"គ្មាន"ទៅ"មាន" ពីខ្សោយទៅខ្លាំង សំរេចបាននូវការពិតដែលជៀសមិនរួច ដែលថាបដិវត្តន៍ប្រាកដជាអាច"ធ្វើឱ្យខ្មាំងបរាជ័យបាន" ជាដាច់ខាត។ ជាការពិតហើយដែលថា ច្បាស់ណាស់ថាខ្មាំងនឹងប្រើគ្រប់មធ្យោបាយដើម្បីបំផ្លាញបដិវត្តន៍ យើងត្រូវបង្កើតកម្លាំងប្រដាប់អាវុធបដិវត្តន៍ផ្ទាល់របស់យើង ដូច្នេះមិនត្រឹមតែមិនត្រូវបានកំទេចទេ បដិវត្តន៍នឹងអភិវឌ្ឍន៍ទៅមុខជាបន្តបន្ទាប់ ។*

*វោហាសាស្ត្រដ៏អង់អាចក្លាហាន អំពីវីរភាពនិងជោគជ័យនាពេលកន្លងមក មានទិសដៅធ្វើឱ្យរឹងមាំសេចក្តីប្តេជ្ញារបស់ពួកកុម្មុយនីសភាគខាងត្បូងវៀតណាម នៅចំពោះមុខការធ្លាក់ចូលក្នុងកណ្តាប់ដៃនៃកម្លាំងរបស់សហរដ្ឋអាមេរិក និងរដ្ឋាភិបាលទីក្រុងព្រៃនគរ ។ ប្រតិបត្តិការរបស់សហរដ្ឋអាមេរិកនៅតាយនីញ គឺជាផ្នែកមួយនៃការវាយសម្រុកដ៏ធំទូលាយខ្លាំងជាងនេះយ៉ាងច្រើនថែមទៀត ដែលកម្លាំងប្រយុទ្ធរបស់សហរដ្ឋអាមេរិក និងយុទ្ធនាការសន្តិសម្ព័ន្ធរបស់ពួកព្រៃនគរ បានរុញច្រានពួកកុម្មុយនីសភាគខាងត្បូងឱ្យដកថយខាងយោធា ធ្វើឱ្យមានការខូចខាតយ៉ាងធ្ងន់ធ្ងរ ទប់ស្កាត់ផ្លូវដឹកជញ្ជូនភស្តុភាររបស់ពួកគេ បំផ្លាញរចនាសម្ព័ន្ធនយោបាយរបស់ពួកគេ ធ្វើឱ្យបណ្តាញរដ្ឋបាលរបស់ពួកគេរប៉ាត់រប៉ាយ ធ្វើឱ្យបែកបាក់អង្គការលាក់មុខរបស់ពួកគេ បដិសេធមិនឱ្យពួកគេត្រួតត្រាប្រជាជន និងមូលដ្ឋានសំរាប់ធ្វើការជ្រើសរើសប្រជាជន និងបង្កឱ្យមានការរត់ចោលជួរដោយទ្រង់ទ្រាយធំ ។ ការឃោសនាជាសាធារណៈ បានឆ្លុះបញ្ចាំងឱ្យឃើញការចាប់ផ្តើមនៃការខិតខំរបស់គណៈកម្មាធិការមជ្ឈឹម បពវ ដើម្បីស្តារឡើងវិញនូវសតិអារម្មណ៍របស់ពួកកុម្មុយនីសភាគខាងត្បូង ក្នុងការរៀបចំសំរាប់ធ្វើការវាយបកដោយសព្វមុខមួយ ដែលថ្នាក់ដឹកនាំនៅហាណូយបានចាប់ផ្តើមពិភាក្សាគ្នាជាសម្ងាត់ នៅក្នុងខែមករា ឆ្នាំ ១៩៦៧ ។*

*ដោយវិបត្តិជាបន្តបន្ទាប់ស្មុគស្មាញៈ និងលទ្ធភាពដែលពួកកុម្មុយនីសខ្មែរត្រូវប្រឈមមុខ បញ្ញត្តិរបស់ បពវ ក៏ហាក់ដូចជាមានការសមស្របកាន់តែខ្លាំងឡើងចំពោះសភាពការណ៍របស់ពួកគេដែរ ។ ភ្លាមៗបន្ទាប់ពីការចេញដំណើរពីមន្ទីរ ១០០ ទៅ សភាពការណ៍នៅភូមិភាគបូព៌ាហាក់ដូចជាមានសភាពកាន់តែមិនទៀងទាត់ហើយ ការបង្ក្រាបរបស់រដ្ឋាភិបាលមានសភាពកាន់តែខ្លាំង ដោយសម្ងាប់ប្រជាជនក្នុងភូមិដែល គឹម ប្រើធ្វើជាមូលដ្ឋានសំខាន់របស់គេនោះ ។ បន្ទាប់មក កម្មាភិបាលរបស់ គឹម បានកោះប្រជុំសកម្មជនបក្សមូលដ្ឋាន ដើម្បីពន្យល់ឱ្យពួកគេត្រៀមរៀបចំខ្លួនចំពោះមុខរដ្ឋប្រហាររបស់ លន់ ណុល ប្រឆាំងសម្តេច*

សីហនុ ដែលអាចកើតឡើងនៅគ្រប់ពេលវេលា ។ ពួកគេត្រូវខិតខំប្រឹងប្រែងដើម្បីរៀបចំបណ្តាញសម្ងាត់ ដែលអាចនឹងក្លាយជាស្នូលរដ្ឋបាលប្រឆាំងនៅជនបទ ដើម្បីប្រឆាំងរដ្ឋប្រហារនៅពេលដែលវាផ្ទុះឡើង ។ ពួកគេក៏ត្រូវបង្កើតទ្រង់ទ្រាយនៃអង្គភាពយោធា ដែលនឹងអាចទទួលអាវុធពីពួកបង្កប់ខ្លួនក្នុងជួរសេនាជនរដ្ឋាភិបាល នៅពេលរដ្ឋប្រហារកើតឡើង ។

អ្វីដែលបន្ទាន់ជាងនេះទៀតនោះ គឺសភាពការណ៍ពុះកញ្ជ្រោលនៅភូមិភាគពាយ័ព្យ ជាពិសេសនៅផ្នែកនិរតីនៃភ្នំតូចៗនៃខេត្តបាត់ដំបង ដែល នួន បានយកធ្វើជាមូលដ្ឋានក្នុងពេលសង្គ្រាមឥណ្ឌូចិនលើកទី១ ។ ភាពតានតឹងបានកើតមាននៅទីនោះពេញមួយឆ្នាំ ១៩៦៦ ដោយកំហឹងរបស់ប្រជាជនបានកើនឡើងពីការប្រមូលស្រូវដោយបង្ខំក្រោមការដឹកនាំរបស់កងទ័ពការរឹបអូសយកដីនិងការរំលោភដទៃទៀតពីសំណាក់មន្ត្រីរដ្ឋាភិបាល និងរូបភាពនៃការផ្លាស់ប្តូរទីកន្លែងរស់នៅដឹកនាំដោយរដ្ឋាភិបាល ។ ទាំងនេះត្រូវបានធ្វើឱ្យកាន់តែធ្ងន់ធ្ងរថែមទៀត ដោយសកម្មភាពនៃការពង្រាយកម្លាំងសន្តិសុខរបស់រដ្ឋាភិបាល ដែលបានធ្វើទុក្ខបុកម្នេញដល់អ្នកដែលត្រូវបានស្គាល់ថាជាសមាជិកបក្សកុម្មុយនីស និងដែលត្រូវបានចោទប្រកាន់ជាសមាជិកបក្សកុម្មុយនីសបង្កប់ខ្លួននៅក្នុងតំបន់ ។ ជាការសងសឹក នៅដើមឆ្នាំ ១៩៦៧ កសិករនៅក្នុងស្រុកសំឡូត - ដោយមានជំនួយពីអ្នកចាត់ចែងបក្សមូលដ្ឋាន បានធ្វើសកម្មភាពដោយការផ្តើមគំនិតផ្ទាល់របស់ពួកគេ - បានសម្លាប់ពួកអ្នកដែលសង្ស័យថាជាអ្នកផ្តល់ព័ត៌មានរបស់រដ្ឋាភិបាល និងដឹកនាំធ្វើបាតុកម្មប្រឆាំងអាជ្ញាធរ ។ ទាំងនេះបានវិវត្តន៍ជាការប្រឈមមុខគ្នាដោយទ្រង់ទ្រាយធំ រវាងកសិករនិងកម្លាំងយោធានិងប៉ូលីសរបស់សង្គម ដែលពេលនោះ ភូមិភាគជ្រើសរើសបានទាហានរត់ចោលជួរ ១០០ នាក់ នៅពេលដែលអ្នកភូមិរាប់ពាន់នាក់បាននាំគ្នារត់ចូលព្រៃ ។ ការរំដើបរំជួលនេះត្រូវបានបង្ក្រាបដោយអង្គភាពយោធា ក្រោមបញ្ជាផ្ទាល់របស់ លន់ ណុល មាន: ការបោសសំអាតដោយកងទ័ពថ្មើរជើង ការទម្លាក់គ្រាប់បែកពីលើអាកាស ការដុតបំផ្លាញភូមិប្រជាជន និងការសម្លាប់ដោយទទឹងទិសពួកអ្នកត្រូវចោទថាជាកុម្មុយនីស និងជាអ្នកមានសមានចិត្តចំពោះកុម្មុយនីស ដែលបានបន្តធ្វើរហូតដល់ខែសីហា ឆ្នាំ ១៩៦៧ ។

ចលាចលនៅបាត់ដំបង បានធ្វើឱ្យការបែកបាក់កាន់តែជ្រៅថែមទៀតនៃសង្គមជនបទកម្ពុជា ។ ក៏ប៉ុន្តែ នៅខែឧសភាឆ្នាំ១៩៦៧ នួន ជា បានសុំដាក់បញ្ចូលទៅក្នុងមាគ៌ាបក្សនូវការតស៊ូដោយគ្មានអាវុធ ដោយបញ្ជាទៅពាយ័ព្យឱ្យបញ្ឈប់ហឹង្សាប្រឆាំងរដ្ឋាភិបាល ។ រូបគេបានណែនាំដល់គណៈកម្មាធិការភូមិភាគ ឱ្យធ្វើការចរចាជាមួយអាជ្ញាធររដ្ឋាភិបាលនៅបាត់ដំបងដើម្បីឱ្យមានការយល់ព្រមលើការឈប់បាញ់មួយ និងអនុញ្ញាតឱ្យកសិករដែលបានរត់ចោលផ្ទះសម្បែងពួកគេ វិលត្រឡប់មកវិញដោយគ្មានឧបសគ្គ និងការធ្វើទុក្ខទោស ។ នួន រក្សាជំហរថាចលនាកុម្មុយនីសនៅមិនទាន់ចាស់ទុំសមល្មមអាចធ្វើការបះបោរដោយទ្រង់ទ្រាយធំបាននៅឡើយទេ ។ បើបាត់ដំបងនៅតែបន្តធ្វើដោយខ្លួនឯង នោះ"ខ្មាំងប្រាកដជាកំទេចកម្លាំងបដិវត្តន៍អស់ ជាមិនខាន" ។

សភាពការណ៍ដែល នួន កំពុងប្រឈមមុខនៅភ្នំពេញ ក៏មានគ្រោះថ្នាក់ណាស់ដែរ ។ នៅពីលើសភាពការណ៍នៅបូព៌ា និងពាយ័ព្យ មានបញ្ហាដែលត្រូវសំរេចឱ្យបាននូវកិច្ចខិតខំរបស់ បព១ ដើម្បីជៀសវាងការប្រឈមមុខជាមួយសម្តេចសីហនុ បញ្ហាឥទ្ធិពលនៃឆាកនយោបាយនៅទីក្រុង ដោយធ្វើការជាសម្ងាត់តាមរយៈបញ្ញាជនល្បីឈ្មោះមានសមានចិត្តដែលមិនមែនជាសមាជិកបក្ស និងបញ្ហារៀបចំសាខាបក្សសម្ងាត់ក្នុងចំណោមកម្មករ គ្រូបង្រៀន និងនិស្សិត ដែលកំពុងប្រណាំងប្រជែងជាមួយពួកគេ ។

ដោយត្រូវបានបង្អើលយ៉ាងខ្លាំងក្លា ដោយសញ្ញានៃការប្រឆាំងគ្នារវាងទីក្រុង និងជនបទ សម្តេចសីហនុបានតែងតាំង លន់ ណុល ឱ្យធ្វើនាយករដ្ឋមន្ត្រី នៅក្នុងខែតុលា ឆ្នាំ ១៩៦៦ ។ ដោយលះបង់ការដឹកនាំរដ្ឋបាលទៅឱ្យពួកយោធា នៅពេលការប្រឆាំងកំពុងកើនឡើងដូច្នេះ សម្តេចសីហនុដឹងច្បាស់ថា នឹងមានការប្រឈមមុខគ្នាដោយផ្ទាល់រវាងកងកម្លាំងសន្តិសុខ និងពួកនិស្សិត គ្រូបង្រៀន និងបញ្ញាជនដែលមិនសប្បាយចិត្ត ។ សម្តេចបានអែបទៅខាង លន់ ណុល រហូតដល់អ្នកដែលត្រូវទទួលរង

ការបង្ក្រាបអាចត្រូវបានអូសទាញដោយពួកឆ្វេង ។ សម្តេចមានជំរើសតិចណាស់សំរាប់ធ្វើការបត់បែនៈ បើសម្តេចមិនអនុញ្ញាតឱ្យ លន់ ណុល កំទេចពួកឆ្វេងទេ ទាំងសម្តេច និងមេបញ្ជាការកងទ័ព នឹងត្រូវរុញទម្លាក់ពីអំណាចដោយតាពនិករនៃកម្លាំងប្រឆាំងពួកយោធា ប្រឆាំងរាជវាំង ប្រឆាំងសហរដ្ឋអាមេរិក ។

ក្នុងខែមីនា ឆ្នាំ ១៩៦៧ បាតុកម្មរបស់និស្សិត និងពួកអ្នកដទៃទៀត បានផ្ទុះឡើងនៅទីក្រុងភ្នំពេញ ប្រឆាំងការរំលោភរបស់កងទ័ពទៅលើកសិករនៅពាយ័ព្យ ។ បក្សបានសាកល្បងបញ្ចូល និងដឹកនាំបាតុកម្មនេះ បញ្ចុះបញ្ចូលពួកគេឱ្យថ្កោលទោស លន់ ណុល តែអត់ធ្មត់កុំទិតៀនសម្តេចសីហនុ តែពួកនិស្សិតជាសកម្មជនដាច់ខាតដែលមិនមែនជារបស់ បពខ បានទទូចឱ្យធ្វើការទិតៀនសម្តេច ។ តាមការផ្តល់មតិរបស់ លន់ ណុល សម្តេចសីហនុ បានប្រតិកម្មក្នុងសុន្ទរកថារបស់សម្តេចនាចុងខែមីនា និងក្នុងខែមេសា ដោយបន្ទោសការរំជើបរំជួលនៅជនបទ និងក្នុងទីក្រុងទាំងអស់នោះ ទៅលើ ខៀវ សំផន, ហ៊ូ យន់, ហ៊ូ នីម និងពួកខ្មែរក្រហមល្បីឈ្មោះដទៃទៀត ។ ទោះបីជាអ្នកទាំង ៣ នាក់នេះ ជាក់ស្តែងមិនមានជាប់ពាក់ព័ន្ធទាល់តែសោះនឹងឧបទ្ទវហេតុនានានៅបាត់ដំបងក៏ដោយ ក៏សម្តេចបានគំរាមថានឹងឱ្យ លន់ ណុល រៀបចំធ្វើយ៉ាងណាឱ្យពួកគេ"បាត់ខ្លួន" - ដូច ទូ សាមុត - ឬ ឱ្យតុលាការសិកកាត់ទោស ឬបាញ់ចោល ។ នៅចុងខែមេសា ខៀវ សំផន និង ហ៊ូ យន់ បានលួចរត់ចេញពីភ្នំពេញដោយសម្ងាត់ តាមការផ្តល់យោបល់របស់ វន វ៉េត ដែលជាកម្មាភិបាលគណៈកម្មាធិការបក្សភ្នំពេញ ដែលបានធ្វើឡើងតាមការណែនាំរបស់ នួន ដែលបានរៀបចំការចេញដំណើររបស់ពួកគេដោយមិនបានសាកសួរយោបល់ ស ទេ ។ ពួកគេមិនបានដឹងថាតើពួកគេត្រូវទៅណាទេនៅពេលពួកនិរសា បព ខ បាននាំពួកគេទៅកាន់ភូមិភាគនិរតីនោះ ។ នៅទីនោះ ពួកគេពុំមានការអ្វីធ្វើទាំងអស់ លើកលែងតែទទួលបញ្ជាឱ្យធ្វើយ៉ាងណាកុំឱ្យអ្នកណាឃើញឱ្យសោះ នៅក្នុងភូមិដែលពួកគេបានលាក់ខ្លួននោះ ។ ខៀវ សំផន បានដឹងខ្លួនថារូបគេស្ថិតនៅក្រៅពីសមាសភាពនយោបាយរបស់គេទាំងស្រុងនៅជនបទ នៅពេលដែល ហ៊ូ យន់ រអ៊ូរទាំថា ជាក់ស្តែងរូបគេត្រូវបង្ខំដាក់ឱ្យស្ថិតនៅជាប់ឃុំឃាំងក្នុងផ្ទះដោយមិនបានការអ្វីទាំងអស់ ។

សម្តេចសីហនុ ក៏បានបញ្ចេញឱ្យដឹងផងដែរថា ព្រះអង្គគាំទ្រការបង្ក្រាបខ្សែបណ្តាញពួក បព ខ បង្កប់ខ្លួននៅជនបទទាំងអស់ មិនត្រឹមតែនៅពាយ័ព្យប៉ុណ្ណោះទេ ។ ការចាប់ខ្លួន និងការសម្លាប់ បានកើនទ្វេឡើងនៅបូព៌ា ពាយ័ព្យ និងឧត្តរ ។ ទោះបីជាគោលជំហរជាផ្លូវការរបស់ បព ខ ចំពោះសម្តេចស្ថិតនៅដដែលមិនប្រែប្រួលក៏ដោយ ក៏កម្មាភិបាលមូលដ្ឋាននៅភូមិភាគពាយ័ព្យ បូព៌ា និរតី និងឧត្តរ បានប្រតិកម្មឆ្លើយតបដោយការឃោសនាប្រឆាំងសម្តេចសីហនុយ៉ាងខ្លាំងក្លា ដោយចោទព្រះអង្គថាជាជនក្បត់ដែលបានធ្វើការបង្ក្រាប ដោយប្រកាសថាត្រូវតែទម្លាក់ព្រះអង្គចេញពីអំណាច ។ នៅភូមិភាគបូព៌ា សកម្មជនបក្សបានបន្ទោសសម្តេចចំពោះការកាប់សម្លាប់ដ៏រីករាលដាល កំណត់ថាព្រះអង្គជាតំណាងឱ្យផលប្រយោជន៍ពួកវណ្ណៈជិះជាន់សក្តិភូមិនៅកម្ពុជា និងជាខ្មាំងសត្រូវនៃបដិវត្តន៍ប្រជាធិបតេយ្យ ។ កម្មាភិបាលភូមិភាគបូព៌ាខ្លះ បានប្រើហឹង្សានយោបាយ ដែលឆ្ងាយហួសពីមាគ៌ាបក្ស ដូចជាការវាយប្រហារទៅលើប៉ុស្តិ៍ជួរមុខរបស់រដ្ឋាភិបាលជាដើម ។ ដូចនៅភូមិភាគពាយ័ព្យដែរ សកម្មភាពឈ្លបនៅភូមិភាគបូព៌ាទាំងនេះ បានឆ្លុះបញ្ចាំងយ៉ាងច្បាស់អំពីប្រតិកម្មតាមមូលដ្ឋាន ទៅនឹងការរំលោភរបស់រដ្ឋាភិបាល ។ អវត្តមាននៃហឹង្សាបែបនេះនៅភូមិភាគដទៃទៀត ដូចជានៅ ឦសាន និងនិរតី ជាដើម បានឆ្លុះបញ្ចាំងអំពីការបន្តចូលរួមរបស់ពួកគេទៅនឹងមាគ៌ាបក្សប្រឆាំងនឹងអំពើបែបនេះ ។

សេចក្តីសំរេចរបស់ នួន ឱ្យបញ្ឈប់ហឹង្សាបដិវត្តន៍នៅបាត់ដំបង ត្រូវបានស្វាគមន៍ដោយវៀតណាម តែវៀតណាមជំទាស់ទៅនឹងការដែល នួន បញ្ចេញ ខៀវ សំផន និងខ្មែរក្រហមដទៃទៀតពីភ្នំពេញ ។ ថ្វីបើមានសេចក្តីព្រមាន និងវោហាសាស្ត្ររបស់ពួកគេទាំងនេះក៏ដោយ ក៏ការវាយតម្លៃរបស់ពួកគេនៅតែមើលឃើញថាការប្រៀបធៀបកម្លាំង រវាងបដិវត្តន៍ និងប្រតិកម្មនៅកម្ពុជា មិនអំណោយផលដល់បដិវត្តន៍ទេ និងថាការបះបោរនៅកម្ពុជាមិនបំរើផលប្រយោជន៍ចំពោះមុខនៃបដិវត្តន៍វៀតណាមទេ ។ ពួកគេឯកភាពអំពីចំណុចចុងក្រោយនេះ ជាមួយប៉េកាំងនៅក្នុងខែមេសា ឆ្នាំ ១៩៦៧ នៅពេលពួកគេទាំងពីរ

បានបញ្ជាក់ជាថ្មីនូវជំនឿរបស់ពួកគេ ដែលថាមិនត្រូវមានការតស៊ូប្រដាប់អាវុធនៅកម្ពុជាទេ ពីព្រោះថានៅក្នុងគំរោងការណ៍ធំទូលាយជាងនេះ ជ័យជំនះរបស់បដិវត្តន៍នៅវៀតណាម គឺជាអាទិភាពខ្ពស់ជាង ហើយការបះបោររបស់កុម្មុយនីសកម្ពុជាណាមួយនោះ វានឹងកាត់ផ្តាច់ផ្លូវដឹកជញ្ជូនភស្តុភារឆ្លងកាត់ប្រទេសនេះ ។ ពួកគេយល់ស្របគ្នាថា កម្ពុជាមិនត្រូវរៀបចំឱ្យមានការបះបោរទេ ទោះបីជាសម្តេចសីហនុធ្វើការគៀបសង្កត់បែបណាលើកម្លាំងបដិវត្តន៍កម្ពុជាក៏ដោយ ។ ចិនបានយកចិត្តទុកដាក់ដើម្បីរក្សាជនកម្ពុជាឱ្យទាល់ច្រក ពួកគេមានការព្រួយបារម្ភចំពោះថាកុំឱ្យមានអាវុធណាមួយដែលពួកគេផ្តល់ទៅឱ្យវៀតណាមនោះ ធ្លាក់ទៅក្នុងដៃពួកកុម្មុយនីសខ្មែរឱ្យសោះ ។ វៀតណាមបានធានាជាមួយចិនថា ពួកគេតែងតែខិតខំបញ្ចុះបញ្ចូលជនខ្មែរអំពីគតិបណ្ឌិតនៃការអត់ធ្មត់ ហើយថានឹងខិតខំបន្តធ្វើដូច្នេះតទៅទៀត តាមរយៈទីបញ្ជាការ បពវ នៅភាគខាងត្បូងវៀតណាម ពោលគឺតាមរយៈ ភឹម និង នួន ។

ថ្នាក់ដឹកនាំ បពវ នៅហាណូយ បានណែនាំដល់កម្មាភិបាលជាន់ខ្ពស់ បពវ នៃភាគខាងត្បូង ង្វៀង វ៉ាន់ លិញ ឱ្យធ្វើការសង្កេតជាមួយជនកម្ពុជាអំពីព្រឹត្តិការណ៍នៅបាត់ដំបងនោះ ។ ទោះបីជារូបគេបានអំពាវនាវឱ្យបញ្ឈប់ការបះបោរនៅបាត់ដំបងក្តី ក៏ នួន បានឆ្លើយតបវិញដោយអធិប្បាយអំពីនិន្នាការនៃហឹង្សាបដិវត្តន៍កាន់តែខ្លាំងថែមទៀត ដោយនិយាយថា នៅក្នុងពេលឆាប់ៗនេះ ជនកម្ពុជាប្រហែលនឹងលែងមានជំរើសអ្វីក្រៅពី "ធ្វើការប្រយុទ្ធប្រឆាំងពួក លន់ ណុល ដែលជាឆ្កែបំរើរបស់ចក្រពត្តិអាមេរិក ពីព្រោះពួកគេបានធ្វើយុទ្ធនាការបង្ក្រាបដោយពេញទំហឹងប្រឆាំង ... បដិវត្តន៍" ។ ការវិភាគរបស់កម្ពុជា គឺថា លន់ ណុល ដឹកនាំស្លាបស្តាំបំផុតនៃវណ្ណៈកាន់អំណាច ដែលក្នុងនោះរួមមានពួកប្រតិកិរិយាទាំងអស់ ដែលឥឡូវមានចំណង់ខ្លាំងណាស់ដើម្បីធ្វើជាឆ្កែបំរើរបស់ចក្រពត្តិនិយមបរទេស ហើយដែលត្រូវតែឯកោពួកវា ។ ចំណែកសម្តេចសីហនុវិញ នៅតែត្រូវមើលឃើញថាខុសពីពួកនោះនៅឡើយ ដោយទោះបីជានៅរួមជាមួយវណ្ណៈដឹកនាំប្រឆាំងកុម្មុយនីសនិយមក៏ដោយ ក៏ព្រះអង្គអាចមានលទ្ធភាពគាំទ្រដល់ឯករាជភាពនៃប្រទេសកម្ពុជាផងដែរ ។ ទោះបីជាសម្តេចសីហនុ នៅមិនទាន់ដាច់ខាតទាំងស្រុងចំពោះការណ៍នេះក៏ដោយ ក៏ព្រះអង្គនៅអាចត្រូវប្រមូលជាផ្នែកមួយនៃរណសិរ្សរួបរួមមួយដឹកនាំដោយបក្ស ប្រឆាំងការជិះជាន់បរទេស បាននៅឡើយដែរ ។

ទស្សនៈកម្ពុជាអំពី លន់ ណុល គឺសមស្របទៅនឹងការពិត ដែលថាសហរដ្ឋអាមេរិកបានចាត់ទុករូបគេជាសម្ព័ន្ធភាពជិតស្និទ្ធបំផុតប្រឆាំងកុម្មុយនីសនិយមនៅកម្ពុជា ។ វៀតណាម បានទទួលស្គាល់ថា រូបគេគឺជាការគំរាមកំហែងចំពោះមុខរបស់ពួកកុម្មុយនីសខ្មែរ និងជាអ្នកដែលអាចធ្វើរដ្ឋប្រហារជាសក្តានុពលប្រឆាំងសម្តេចសីហនុ ប៉ុន្តែនៅមានគំនិតថារូបគេអាចជាផ្នែកមួយជាបណ្តោះអាសន្ននៃរណសិរ្សប្រឆាំងសហរដ្ឋអាមេរិកដែរ ពីព្រោះរូបគេមានការជិតស្និទ្ធជាមួយបារាំងជាងអាមេរិក ។ ពួកខ្មែរបានឆ្លើយតបវិញដោយបញ្ជាក់ឡើងវិញថា លន់ ណុល គឺជាអ្នកប្រឆាំងដ៏សាហាវយង់ឃ្នងរបស់បដិវត្តន៍ ដោយរូបគេជាតួយ៉ាងនៃ "យោធានិយមដាច់ខាត សក្តិភូមិនិយមដាច់ខាត និងប្រតិកិរិយាដាច់ខាត" ។

ដើមកំណើតនៃការទ្រគោះបោះបោករបស់កម្ពុជា គឺការបន្តការប្រកាន់ខ្ជាប់របស់ពួកគេ ទៅនឹងការវិភាគរបស់វៀតណាមអំពីការទាក់ទងរវាងសហរដ្ឋអាមេរិក - បារាំង ក្នុងរយៈពេលសង្គ្រាមឥណ្ឌូចិនលើកទី ១ ពោលគឺ ទីចុងបំផុត បារាំងត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់សហរដ្ឋអាមេរិក ដែលធ្វើអ្វីៗគ្រាន់តែជាតំណាងឱ្យសហរដ្ឋអាមេរិកតែប៉ុណ្ណោះ ។ ស្ថិតនៅពីក្រោយការស្នើរបស់ ង្វៀង វ៉ាន់លិញ គឺការដកខ្លួនចេញរបស់ បពវ ពីគោលជំហរដែលថាកម្ពុជាជាអាណានិគមនិយមថ្មីមួយរបស់សហរដ្ឋអាមេរិកនោះ ។ បន្ទាប់ពីសម្តេចសីហនុផ្តាច់ទូតជាមួយសហរដ្ឋអាមេរិកក្នុងឆ្នាំ១៩៦៥ មក កម្ពុជាលែងមានភាពត្រឹមត្រូវទៅនឹងនិយមន័យរបស់វៀតណាមជាងពេលណាៗទាំងអស់ ថាជាអាណានិគមនិយមមួយបែបនោះដែលជាកន្ទែងមួយឯករាជ្យតែឈ្មោះ ដោយបិទបាំងនូវការពិតដែលថា សេដ្ឋកិច្ច ហិរញ្ញវត្ថុ យោធា និងការទូត ដែលពឹងផ្អែកតែលើសហរដ្ឋអាមេរិកនោះ ។ ការវិភាគរបស់វៀតណាម បានបង្ហាញឱ្យឃើញថា កម្ពុជាបានគេចផុតពីស្ថានភាពបែបនេះ ដោយក្លាយ

ទៅជាអាណានិគមនិយមថ្មីរបស់បារាំងដែលប្រឆាំងនឹងអន្តរាគមន៍របស់សហរដ្ឋអាមេរិកនៅវៀតណាម និងបានសន្និដ្ឋានថា ដោយហេតុថាសម្តេចសីហនុ និងសូម្បីតែ លន់ ណុល ស្ថិតក្រោមឥទ្ធិពលបារាំង ពួកគេជាសម្ព័ន្ធមិត្តប្រឆាំងចក្រពត្តិអាមេរិក យ៉ាងហោចណាស់ក៏ចំពោះមុខដែរ។

ចិនឯកភាពចំពោះទស្សនៈរួមនេះ ។ ពួកគេសង្ឃឹមថា កម្ពុជាមានចំណងជាមួយបារាំង ដូចវៀតណាមជាមួយសហរដ្ឋអាមេរិកដែរ ធ្វើឱ្យសម្តេចសីហនុងាយទទួលការគៀបសង្កត់ ឱ្យទទួលយកនយោបាយប្រឆាំងអាមេរិក ។ ពួកគេក៏ទទូចផងដែរថា លន់ ណុល នៅអាចទាក់ទាញមកជាកម្លាំងប្រឆាំងចក្រពត្តិបានមួយរយៈណាមួយនៅឡើយទេ ។ ពួកគេកំណត់យកគោលជំហរនេះ ទោះបីជាពួកគេបានគិតថា លន់ ណុល មិនគួរឱ្យទុកចិត្តបានក៏ដោយៈ ទោះបីជាពេលខ្លះរូបគេ"ប្រើពាក្យសំដីល្អ" អំពីប្រឆាំងសហរដ្ឋអាមេរិកក៏ដោយ ក៏រូបគេមានជាតុពិតសក្តិភូមិ និងនាយទុន ដែរ ហើយហេតុដូច្នេះ រូបគេលំអៀងទៅខាងអាមេរិកក្នុងបេះដូង ។ ទោះបីយ៉ាងណាក៏ដោយ ចិនបានប្រាប់វៀតណាមថា ទោះបីពួកកុម្មុយនីសខ្មែរមិនអាចរួបរួមជាមួយ លន់ ណុល ក៏ដោយ ក៏វៀតណាម និងចិន ត្រូវតែបន្តសាកល្បងទាញយកសមានចិត្តរបស់គេ ដើម្បីរក្សាឱ្យបានទូវផ្លូវដឹកជញ្ជូនកស្តុការរបស់ចិនទៅឱ្យវៀតណាមឱ្យបាន ។ ទីបញ្ចប់ ចិនគាំទ្រដល់ការពារកែរបស់វៀតណាមថាកម្ពុជាទុំហើយដើម្បីធ្វើការតស៊ូប្រដាប់អាវុធនោះ ក៏ពួកគេយល់ស្របថាមិនជាការល្អទេចំពោះអ្នកណាដែលធ្វើនៅពេលលក្ខណៈសម្បត្តិមិនទាន់អំណោយផលឱ្យធ្វើនោះ ។

ទន្ទឹមនេះ នៅភ្នំពេញ ការរត់គេចខ្លួនដោយសម្ងាត់របស់ ខៀវ សំផន និង ហ៊ូ យន់ បានជំរុញបាតុកម្មប្រឆាំងសម្តេចសីហនុ ដោយពួកនិស្សិត និងពួកអ្នកផ្សេងទៀត ដែលពួកគេសន្មត់ថា លន់ ណុល បានអនុវត្តតាមការគំរាមកំហែងដល់អាយុជីវិតរបស់សម្តេចសីហនុ ប្រឆាំងវីរបុរសរបស់ពួកគេ ។ ដោយបានធ្វើដោយឯករាជ្យពី បពខ ពួកបាតុករបានបាចខិត្តប័ណ្ណប្រឆាំងសម្តេចសីហនុ ដែលត្រូវបានឃើញមាននៅតាមខេត្តដែរនោះ ដោយពេលខ្លះត្រូវបានបាចដោយពួកនិស្សិតដែលពុំមានការទាក់ទងជាមួយចលនាកុម្មុយនីសផងនោះ ។ ក្នុងខែឧសភា ឆ្នាំ ១៩៦៧ សម្តេចបានដកដំណែងជាមេដឹកនាំរដ្ឋាភិបាលចេញពី លន់ ណុល ដោយវិលមកធ្វើការប្រឆាំងកាន់តែខ្លាំងពួកឆ្វេងក្នុងទីក្រុង កុម្មុយនីសនិងមិនមែនកុម្មុយនីស ។ ការបង្ក្រាបរបស់សម្តេច ទៅលើមេដឹកនាំដែលនៅសេសសល់របស់ក្រុមបក្តប់ខ្លួនមិនមែនកុម្មុយនីសបង្កើតដោយ ហ៊ូ នឹម និង ហ៊ូ យន់ នៅក្នុងឆ្នាំ ១៩៦៦ ដើម្បីសម្របសម្រួលការប្រឆាំងសម្តេចសីហនុ និង លន់ ណុល ដែលរួមមាន និស្សិត គ្រូបង្រៀន និងសមាគមដទៃទៀតត្រូវបានហាមឃាត់ ។ នៅក្នុងខែមិថុនា ការរំជើបរំជួលក្នុងចំណោមនិស្សិត និងបញ្ញាជនបានផ្ទុះឡើងម្តងទៀត បន្ទាប់ពីការប្រឈមមុខគ្នាមួយរវាងសម្តេចសីហនុ និងសមាជិកសមាគមមិត្តភាពកម្ពុជា-ចិន ដែលក្នុងនោះ ហ៊ូ នឹម បានដើរតួនាទីដឹកនាំសំខាន់ ក្នុងនោះរួមមានអ្នកបកប្រែស្នាដៃរបស់ប្រធានម៉ៅម្នាក់ផង ។ រវាងខែសីហា-វិច្ឆិកា ទន្ទឹមនឹងការចាប់ខ្លួន និងការគំរាមកំហែងដល់អាយុជីវិត បពខ បានពង្រត់ ហ៊ូ នឹម ចេញដោយសម្ងាត់ ព្រមជាមួយបញ្ញាជនឆ្វេងនិយមមិនមែនកុម្មុយនីស និងកម្មាភិបាលរបស់ខ្លួនបង្កប់ក្នុងទីក្រុងជាច្រើននាក់ ទៅកាន់មូលដ្ឋានបក្សតាមជនបទ ជាពិសេស ជាថ្មីម្តងទៀត ទៅខាងនិរតី ។ ដោយពុំមានជម្រើសនយោបាយចំពោះមុខណាផ្សេងទៀត ខៀវ សំផន, ហ៊ូ យន់, ហ៊ូ នឹម និងយុវសកម្មជនមិនមែនកុម្មុយនីសជាច្រើននាក់ទៀត នៅទីបំផុត បានបង្ខំចិត្តរត់ទៅចូលជាមួយ បពខ ឬ សម្ព័ន្ធយុវកកររបស់ បពខ ។ ទោះបីពួកអ្នកទិតៀន"ស្តាំនិយម" នៃសម្តេចសីហនុ ដែលនៅតែស្ថិតនៅក្នុងទីក្រុងភ្នំពេញនៅឡើយ បានប្រតិកម្មទៅនឹងការបង្ក្រាប ដោយបែរមកប្រឆាំងកាន់តែខ្លាំងចំពោះ "សក្តិភូមិនិយម" របស់សម្តេចក៏ដោយ ក៏ពួកគេមិនបានចាត់ឱ្យមានការចាត់តាំងដ៏ខ្លីខ្លាអ្វីដែរ ។ ដូច្នេះ ការចាប់ផ្តើមការកកើតនៃសង្គមស៊ីវិលឯករាជ្យមួយនៅកម្ពុជាសឹងតែរលំដួលទាំងស្រុងហើយ បពខ បានអូសទាញបានសមាសភាពដែលជាសកម្មជននៃក្រុមនេះជាច្រើននាក់ ទាំងពួកអ្នកបដិរូបនិយម និងពួកដាច់ខាត ។ ពេលទៅដល់មូលដ្ឋាន បពខ

ពួកគេត្រូវទទួលរងការទិតៀនអំពីភាពទន់ខ្សោយខាងមនោគមវិជ្ជារបស់ពួកគេ ក្នុងនេះរួមមាន សេរីនិយម និងការប្រកាន់យកលទ្ធិម៉ៅនិយមដោយងងឹតងងុលផងៗ

ស្ថិតចំពោះមុខស្ថានភាពជាបន្តបន្ទាប់ទាំងនេះ សម្តេចសីហនុ មានជំនឿពេញទីថា ខៀវ សំផន និង ពួកខ្មែរក្រហមល្បីឈ្មោះដទៃទៀត គឺជាមេដឹកនាំចលនាកុម្មុយនីស ។ ពេញមួយទសវត្ស ១៩៦០ ក្រោយពីនោះមក សម្តេចបានទទូចថាពួកគេគឺជាមេដឹកនាំសំខាន់នៃការរំដើបរំជួលរបស់កសិករ ដែលបានផ្ទុះឡើងនៅខេត្តបាត់ដំបង ដោយបានអះអាងថាពួកអ្នកទាំងនេះដឹកនាំដោយពួកខ្មែរវៀតមិញជើងចាស់ ដែលបានបោះទីតាំងនៅទីនោះ ដើម្បីធ្វើការបះបោរនៅក្នុងអតីតមូលដ្ឋានរបស់ពួកកុម្មុយនីសវៀតណាម ដែលមានតាំងពីសង្គ្រាមឥណ្ឌូចិនលើកទី ១ មកម្ល៉េះ ។ ការចោទប្រកាន់ច្រំដែលៗបែបនេះ បានជួយដល់បក្សដើម្បីបិទបាំងការពិតដែលថា ថ្នាក់ដឹកនាំបក្ស ក្នុងការដាក់ស្តែង គឺស្ថិតនៅក្នុងកណ្តាប់ដៃរបស់ នួន និងអតីតខ្មែរវៀតមិញជាន់ខ្ពស់ជើងចាស់ដទៃទៀតរបស់បក្សនោះៗ នួន បានធ្វើការកោះប្រជុំជាសម្ងាត់ពួកអតីតសមមិត្តជាន់ខ្ពស់បំផុតនៃ បកគ របស់គេនៅក្នុងទីក្រុងភ្នំពេញ ដើម្បីពិភាក្សាអំពីសភាពការណ៍ ដោយអវត្តមានរបស់លេខាបក្ស ស ដែលកំពុងស្ថិតនៅក្រៅផ្ទៃនៃការធ្វើសេចក្តីសំរេចនានា ដោយស្ថិតនៅឯកោនៅឯព្រៃសានជាមួយ អៀង សារី និង សុន សេន ។

ក្នុងការប្រជុំគ្នាមួយក្នុងរាជធានី នាចមាសទី ១ នៃឆ្នាំ ១៩៦៧ ពួកអ្នកមានវត្តមានបានបន្ទរអំពី បព ខ ដោយបញ្ជាក់ថារដ្ឋប្រហារគាំទ្រដោយសហរដ្ឋអាមេរិក ប្រឆាំងសម្តេចសីហនុ គឺជៀសមិនរួចទេ តែពួកគេបានទៅឆ្ងាយពីជំហរបូទ្មានរបស់ បពវ ទៅទៀតដោយធ្វើការសន្និដ្ឋានថាជាការចាំបាច់ បពខ ត្រូវតែត្រៀមដើម្បីទទួលអាវុធបំពាក់ឱ្យអង្គភាពការពារសម្ងាត់ ដើម្បីពួកគេអាចមានលទ្ធភាពផ្តល់ការគាំទ្រដល់សកម្មភាពនយោបាយ ។ ចំពោះសេចក្តីសំរេចដាក់ស្តែង ថាតើនៅពេលណាដែលត្រូវបំពាក់អាវុធនោះ គឺត្រូវរង់ចាំការប្រជុំគណៈកម្មាធិការមជ្ឈឹមសិន ។ គោលជំហររបស់ នួន ក្នុងការប្រជុំទាំងនេះ ជាសញ្ញាថារូបគេឯកភាពទាំងស្រុងជាមួយការយកចិត្តទុកដាក់របស់ ស ដើម្បីឈានពីស្វ័យការពារ ក្នុងការគាំទ្រដល់សកម្មភាពនយោបាយទៅការឃោសនាប្រដាប់អាវុធ និងធ្វើផែនការរៀបចំកងទ័ពមួយដើម្បីប្រឆាំងរដ្ឋប្រហារ ដែលទាំងអស់គ្នាគិតថាច្បាស់ជាដឹកនាំដោយ លន់ ណុល ។ ឥឡូវ រូបគេបានស្នើឱ្យផ្អាកការតស៊ូប្រដាប់អាវុធនៅព្រៃសាន ថាជាវិធានការបណ្តោះអាសន្នអនុម័តឡើងដើម្បី "ចំណេញពេលដល់ភូមិភាគដទៃទៀត ដើម្បីបង្កើតឱកាសធ្វើការផ្ទុះអាវុធ" ។ គោលជំហររបស់គេនេះ បានធ្ងះបញ្ចាំងនូវសតិអារម្មណ៍របស់កម្មាភិបាលដឹកនាំនៃភូមិភាគដទៃទៀត ក្នុងនេះរួមមាន គឹម នៅបូព៌ាផង ។ ការខិតខំរបស់ គឹម ដើម្បីស្តាបនាបណ្តាញបង្កប់មួយនៅតាមភូមិនានានៃភូមិភាគ បានបង្កឱ្យមានរលកថ្មីៗទៀតនៃការបង្ក្រាបពីសំណាក់រដ្ឋាភិបាល បង្ខំឱ្យសកម្មជនជាកសិកររត់ចេញពីភូមិទៅនៅក្នុងព្រៃ ពីទីកន្លែងដែលពួកគេធ្វើការធក់ប្ញន់ទៅកាន់តំបន់មានប្រជាជនរស់នៅច្រើន ដើម្បីផ្សព្វផ្សាយការឃោសនាប្រឆាំងការបង្ក្រាបរបស់សម្តេចសីហនុ ។ ការដែល ខៀវ សំផន និងតំណាងពាស្ត្រឆ្វេងនិយមដទៃទៀតរត់ចេញពីភ្នំពេញ បានបំផ្លាញសេចក្តីសង្ឃឹមរបស់ គឹម ដែលថាពួកគេអាចមានលទ្ធភាពប្រើឥទ្ធិពលដើម្បីការពារកម្មាភិបាលមូលដ្ឋាននោះ ។ បន្ទាប់មក ផ្លូវតែមួយគត់ គឺមានតែការបំពាក់អាវុធដល់បដិវត្តន៍ នឹងដឹកនាំធ្វើសកម្មភាពប្រដាប់អាវុធប៉ុណ្ណោះ ។

## ជំពូក ៧

## សេចក្ដីសំរេចបានធ្វើឡើងហើយ

### ក្រោមស្រមោលនៃការរៀបចំសំរាប់ការវាយប្រហារ តេត

នៅចមាសទី ២ ឆ្នាំ ១៩៦៧ បពវ បានរៀបចំផែនការជាសម្ងាត់ ដើម្បីធ្វើការវាយសំរុកបកវិញដោយសព្វមុខ ប្រឆាំងកម្លាំងសហរដ្ឋអាមេរិកនិងព្រៃនគរ ដែលពួកគេបានពិភាក្សានៅហាណូយ ក្នុងខែមករា ឆ្នាំ ១៩៦៧ ។ នោះគឺការវាយសំរុកនិងការបះបោរទូទៅ ដោយមិនឱ្យដឹងខ្លួនជាមុន ដែលនឹងត្រូវធ្វើឡើងជាយថាហេតុនៅថ្ងៃទី ៣១ ខែមករា ឆ្នាំ ១៩៦៨ ឱ្យស្របគ្នានឹងថ្ងៃចូលឆ្នាំថ្មីវៀតណាម ហៅថា តេត ។ ការប្រថុយប្រថានដ៏អង់អាចក្លាហានធំមហិមា និងការបន្តធ្វើឱ្យពុទ្ធខ្ទរខ្ទារជាសាធារណៈ នៃយោធានិយមបដិវត្តន៍វៀតណាមនេះ បានលើកទឹកចិត្តជនកម្ពុជាថែមទៀតដើម្បីចាត់ធ្វើសកម្មភាព ដោយមិនអើពើនឹងដំបូន្មានរបស់វៀតណាម និងចិន និងទោះបីជាត្រូវបានបញ្ចប់ដោយបរាជ័យយ៉ាងធ្ងន់ធ្ងរ ដល់កម្លាំងបដិវត្តន៍នៃភាគខាងត្បូង ក៏ដោយ ។

ទោះបី បពវ អាចមិនបានផ្ដល់ព័ត៌មានដល់ បពខ ជាផ្លូវការ អំពីថាការវាយសំរុក តេត នេះនឹងត្រូវធ្វើឡើងទេក៏ដោយក៏យ៉ាងហោចណាស់ នួន និង ភឹម បានដឹងអំពីឡូហ្សីកពីក្រោយការវាយសំរុកនេះ និងអំពីការរៀបចំសំរាប់ការវាយសំរុកនេះ ដែលក្នុងនេះរួមមានការប្រមូលផ្ដុំកងទ័ពវៀតណាម និងការលាក់អាវុធ និងគ្រាប់រំសេវដ៏ច្រើនសន្ធឹកសន្ធាប់ នៅភូមិភាគឦសាន និងបូព៌ា ដែរ ។ ដើម្បីទុកដាក់របស់ទាំងអស់នេះ វៀតណាម បានសង់មូលដ្ឋានអចិន្ត្រៃយ៍ចំនួន ២០ កន្លែង ដោយបំពានលើកិច្ចព្រមព្រៀងស្ងាត់ៗជាមួយសម្ដេចសីហនុ ។

ការវាយសំរុក តេត ជាការឆ្លើយតបទៅនឹងបរាជ័យខាងនយោបាយ និងយោធា របស់ពួកកុម្មុយនីស នៅភាគខាងត្បូងថែមទៀត ហើយគណៈកម្មាធិការមជ្ឈឹម បពវ បានទទូចឱ្យបន្តការវាយសំរុកនេះតទៅទៀត ទោះបីជាជាក់ស្ដែងវាបានធ្វើឱ្យបាត់បង់ជំនឿរបស់ប្រជាជនលើបដិវត្តន៍នៅទីនោះយ៉ាងណាក៏ដោយ ។ ការណ៍នេះមានភាពកាន់តែច្បាស់ថែមទៀត មិនត្រឹមតែក្នុងចំណោមស្រទាប់កសិករកណ្ដាលនៃភាគខាងត្បូងវៀតណាម ដែលកំពុងកើនឡើងយ៉ាងរហ័សប៉ុណ្ណោះទេ តែចំពោះកសិករដទៃទៀតដែរ ដោយឆន្ទៈសហការ និងពលីកម្មរបស់ពួកគេចំពោះបដិវត្តន៍ ក៏បានថយចុះដែរ ។ ពួកគេមិនសប្បាយចិត្តចំពោះពន្ធដារ និងសេវាកម្មការងារ ដែលពួកកុម្មុយនីសទាមទារ ស្អប់ហឹង្សាកុម្មុយនីស និងមិនចង់ទទួលរងនូវហានិភ័យចំពោះអ្វីដែលពួកគេមើលឃើញថាជាពួកអ្នកចាញ់សង្គ្រាមនោះទេ ។ ទោះបីជាបានដឹងអំពីបញ្ហាទាំងនេះក៏ដោយ ក៏ថ្នាក់ដឹកនាំ បពវ អះអាងថាពួកកុម្មុយនីសភាគខាងត្បូង អាចជំនះលើការលំបាកទាំងនេះបាន បើពួកគេចាប់យកសេចក្ដីផ្ដើមគំនិតជាយុទ្ធសាស្ត្រដោយធ្វើការវាយប្រហារបកទៅវិញនោះ ។ ការណ៍នេះនឹងបង្ហាញឱ្យឃើញថា ពួកគេមិនមែនជាកម្លាំងខ្សោយដូចការស្មាននោះទេ និងបញ្ជាក់ឱ្យឃើញថាប្រជាជនប្រាកដជានៅខាងបដិវត្តន៍ ជាពិសេសកសិករក្រ ។ គោលជំហររបស់ បពវ នេះ គឺឈរលើសុទិដ្ឋិនិយម សេចក្ដីអង់អាចក្លាហាន និងសេចក្ដីសង្ឃឹមលើបដិវត្តន៍ ដែលកិច្ចការពារដ៏ល្អបំផុតនោះគឺធ្វើការវាយសំរុកឱ្យបានល្អៈ បក្សត្រូវបង្កសង្គ្រាមជាមួយខ្មាំង ឬសុខចិត្តរងការឈឺចាប់ដោយមហន្តរាយកាន់តែខ្លាំងជាងនេះថែមទៀត រហូតដល់រំលើងឫសគល់ទាំងស្រុងនោះ ។ កម្មាភិបាលដែលមានជំនឿពិតប្រាកដ បានអះអាងថា ពិសោធនៃសង្គ្រាមប្រជាជននៅភាគខាងត្បូង បានបញ្ជាក់ថា ការតស៊ូប្រដាប់អាវុធមិនត្រូវអភិវឌ្ឍន៍ជាជំហានៗ ដូចដែលបានកើតឡើងតាមគំរូរបស់ម៉ៅនិយមនៅប្រទេសចិនទេ តែវាអាចលោតផ្លោះដោយបង្រួមចូលគ្នានៃដំណាក់កាលអភិវឌ្ឍន៍នានា ដើម្បីសំរេចជោគជ័យឱ្យបានរហ័សជាងទោះបីជាខ្មាំងខ្លាំងជាងខាងបរិមាណច្រើនយ៉ាងណាក៏ដោយ ។

ទិសដៅយុទ្ធសាស្ត្រនៃការវាយសំរុក តែត គឺដើម្បីលាតសន្ធឹងបំបែកកម្លាំងសហរដ្ឋអាមេរិកនិងព្រៃនគរ ដោយវាយទៅលើមូលដ្ឋានបង្អែករបស់ទីក្រុង បង្ខំឱ្យកងទ័ពខ្មាំងដកចេញពីជនបទកុំឱ្យពួកគេប្រមូលផ្តុំដើម្បីវាយប្រហារបកវិញ និងផ្តល់ឱកាសឱ្យកសិករបដិវត្តន៍ងើបឡើងតាមភូមិនានានៅគ្រប់ទិសទី ។ ការនេះ នឹងបង្ខំសហរដ្ឋអាមេរិក និងព្រៃនគរឱ្យចុះចាញ់ ទោះបីជាការចុះចាញ់របស់ពួកគេអាចមិនត្រូវបានកើតឡើងមុនពេលមានការចរចាក៏ដោយ ។ ការរៀបចំផែនការជាក់ស្តែងបានចាប់ផ្តើមនៅទីក្រុងហាណូយ ក្នុងខែឧសភា ឆ្នាំ ១៩៦៧ អំពីអ្វីដែលពួកគេហៅថាជាការវាយប្រហារជាយុទ្ធសាស្ត្រមួយ ដើម្បីសំរេចការលោតផ្លោះនៃបដិវត្តន៍នៅភាគខាងត្បូង ។ អង្គភាពយោធាកុម្មុយនីសភាគខាងត្បូង ត្រូវបានណែនាំជាសម្ងាត់ នៅក្នុងខែមិថុនា ឱ្យចាប់ផ្តើមកសាងកម្លាំងដើម្បីឈានទៅមុខឱ្យបានលឿន ជាថ្មីម្តងទៀត បន្ទាប់ពីបានទទួលការធានាឡើងវិញថា ទោះបីជាបដិវត្តន៍ហាក់ដូចជាកំពុងស្ថិតក្នុងភាពច្របូកច្របល់ ខ្មាំងសត្រូវក៏មានការច្របូកច្របល់ខាងយោធានិងនយោបាយផងដែរ ដោយសារថាអាចទទួលការវាយប្រហារផ្តាច់ព្រាត់ណាមួយនោះ ។

ក្នុងខែតុលា-វិច្ឆិកា ឆ្នាំ ១៩៦៧ កម្មាភិបាលវៀតណាមនៅតំបន់ព្រំដែននៃភូមិភាគបូព៌ា និងឦសាន នៃ បពខ បានកំណត់ និងផ្សព្វផ្សាយដល់ថ្នាក់ក្រោមរបស់ពួកគេ អំពីផែនការលំអិតនៃការវាយសំរុក ដោយគិតថាតំបន់ព្រំដែនទាំងនេះ នឹងក្លាយជាសមរភូមិសំខាន់ និងផ្តាច់ព្រាត់ នៃការវាយសំរុក តែត ។ អង្គការបក្សភាគខាងត្បូង ត្រូវបានប្រាប់ឱ្យដឹងអំពីសភាពការណ៍ ថាបានទុំជាងពេលណាៗទាំងអស់សំរាប់ធ្វើការវាយប្រហារទៅលើតំបន់ទីក្រុង និងការបះបោរនៅជនបទហើយ ។ ពួកគេត្រូវឈានទៅមុខ និងឱ្យបានរហ័ស ដើម្បីចាត់យកសេចក្តីផ្តើមគំនិតខាងយោធា ។ ពួកគេបានទទួលការធានាថា ការវាយសំរុកនេះនឹងរុញច្រានខ្មាំងឱ្យធ្លាក់ក្នុងភាពវិកវរខាងនយោបាយ ហើយមិនថាប្រតិកម្មរបស់ខ្មាំងមានសភាពហឹង្សាយ៉ាងណាក្តី ពួកវាប្រាកដជានឹងរលំដួលជាដាច់ខាត ។ ផ្ទុយទៅវិញ ពួកគេត្រូវបានក្រើនរំលឹកថា បើសិនជាពួកគេខកខានមិនបានធ្វើដោយសារពួកគេមានការភ័យខ្លាចការលំបាកវេទនា នោះបដិវត្តន៍នឹងទទួលការឈឺចាប់ ដោយការបាត់បង់ដ៏ធ្ងន់ធ្ងរ និងធ្វើឱ្យប្រជាជាតិនិងប្រជាជនខកចិត្តជាពុំខាន ។ សកម្មជនបក្សភាគខាងត្បូងវៀតណាមជាច្រើន មានជំនឿថា បដិវត្តន៍កំពុងស្ថិតចំពោះមុខនៃការវាយប្រហារមួយ ដែលនឹងនាំឆ្ពោះទៅសំរេចទូវជ័យជំនះទាំងស្រុង និងជាស្ថាពរហើយ ។ នៅជនបទវៀតណាម មានការផ្សព្វផ្សាយគំនិតថា បដិវត្តន៍កំពុងធ្វើដំណើរឈានទៅសំរេចបានជ័យជំនះក្នុងពេលឆាប់ៗនេះ ដោយសព្វមុខ ទៅការបញ្ចប់សង្គ្រាម សំរេចបានឯករាជភាព ភាពត្រឹមត្រូវខាងសង្គម ដែលនឹងផ្តល់ឱកាសសំរាប់ការរីកចំរើនទៅមុខខាងនយោបាយ និងបុគ្គល ចំពោះអ្នកចូលរួមទាំងអស់គ្នា។

ទាំងអស់នេះបានផ្តល់ដល់ជនកម្ពុជានូវគតិបណ្ឌិតចាំបាច់មួយ ដែលថាមិនត្រូវបោះបង់ឬរាថយចំពោះមុខបរាជ័យនៃចលនារបស់ពួកគេនៅក្នុងទីក្រុងភ្នំពេញ និងនៅភូមិភាគនានាឡើយ ។ វិធីដែលត្រូវធ្វើនោះ គឺការវាយសំរុកបកវិញដើម្បីរុញច្រានការវាយប្រហាររបស់ពួក សីហនុ - លន់ ណុល ការពារបដិវត្តន៍ និងប្រជាជនពីការខូចខាតកាន់តែធ្ងន់ធ្ងរថែមទៀត និងទាក់ទាញការគាំទ្រ និងថាមពល របស់ប្រជាជន ដើម្បីជំរុញបដិវត្តន៍ឱ្យឈានទៅមុខ ។ វោហាសាស្ត្រជាសាធារណៈរបស់វៀតណាមដែលចេះតែលាន់ឮខ្លាំងឡើងៗ បានផ្តល់ការលើកទឹកចិត្តបន្ថែមទៀត ធ្វើឱ្យទំនាស់រវាងគោលជំហរទូទៅរបស់វៀតណាម និងការប្រយ័ត្នប្រយែង ដែលពួកគេនិងចិនបានដាក់សង្កត់លើ បពខ កាន់តែជ្រាលជ្រៅថែមទៀត ។

ក្នុងខែកក្កដា ឆ្នាំ ១៩៦៧ វៀតណាមបានប្រកាសថា ជនកុម្មុយនីសនៃប្រទេសដទៃទៀត អាចជួយពួកគេបានកាន់តែល្អ ក្នុងការប្រឆាំងសហរដ្ឋអាមេរិក ដោយការតស៊ូហឹង្សាប្រឆាំងចក្រពត្តិនិយម ដូចបដិវត្តន៍ បុលសេវីក ចិន និងវៀតណាម ។ ទោះបីមានតែបាតដៃទទេក៏ដោយ ក៏ពួកគេអាចងើបឡើងធ្វើការបដិវត្តន៍ប្រដាប់អាវុធបានដែរ ។ ការវាយប្រហារខ្មាំងសត្រូវរបស់ពួកគេដោយនយោបាយ សេដ្ឋកិច្ច និងការទូត ក៏ជាការចាំបាច់ដែរ កត្តាកំណត់គឺនៅតែការតស៊ូប្រដាប់អាវុធ និងនយោបាយរបស់មហាជនជានិច្ច ។ បក្ស ម៉ាក្ស-ឡេនីន ទាំងឡាយ ដែលមិនបានអនុម័តយកគោលជំហរវាយសំរុកជាយុទ្ធ

*សាស្ត្រនោះ ឬដែលមានការភ័យខ្លាចការតស៊ូដ៏ខ្លាំងក្លា និងពលីកម្ម នឹងបើកផ្លូវឱ្យចក្រពត្តិនិយមឈានទៅមុខដោយការធ្វើរដ្ឋប្រហារ ។ អ្នកណាដែលខកខានមិនបានធ្វើបដិវត្តន៍តាមរយៈហឹង្សានោះ នឹងបាត់បង់នូវឯករាជភាព សេរីភាព និងសិទ្ធិជាម្ចាស់លើវាសនារបស់ខ្លួន ដោយជៀសមិនរួចឡើយ ។ ដោយឃ្លាតចេញពីគន្លងហឹង្សា ពួកកុម្មុយនីសនឹងផ្តល់ឱកាសឱ្យខ្ញុំកញ្ជះចក្រពត្តិនិយមក្នុងស្រុក "កំទេចបក្សវណ្ណៈកម្មជីព និងធ្វើឱ្យអង្គការបដិវត្តន៍រប៉ាត់រប៉ាយ" ។ ជនកុម្មុយនីសទាំងអស់ត្រូវយល់ថា ពេលការតស៊ូនយោបាយបានអភិវឌ្ឍន៍ដល់កំរិតណាមួយ ពេលនោះបើពុំមានការគាំទ្រដោយការតស៊ូប្រដាប់អាវុធទេ នោះនឹងបណ្តាលឱ្យមានការខូចខាតយ៉ាងធ្ងន់ធ្ងរដល់បដិវត្តន៍ជាពុំខាន ។ ពួកគេត្រូវជឿជាក់ថា "បើប្រជាជនមួយ ទោះបីខ្សោយនិងមានចំនួនតិច រួបរួមគ្នាដើម្បីធ្វើការប្រយុទ្ធដាច់ខាតដើម្បីឯករាជ្យ និងសេរីភាព និងដើរតាមមាគ៌ាបដិវត្តន៍ត្រឹមត្រូវមួយនោះ ពួកគេមានលទ្ធភាពពេញទីនឹងដណ្តើមបានជ័យជំនះ" ។*

*ទន្ទឹមនឹងនេះ វៀតណាមមានសេចក្តីព្រួយបារម្ភយ៉ាងជ្រាលជ្រៅថា សហរដ្ឋអាមេរិកអាចឈ្លានពានប្រទេសកម្ពុជា ទោះបីមុនការវាយសំរុក តែត ដើម្បីបន្ទុចបង្អាក់វា ឬក្រោយការវាយសំរុកនេះ ក្នុងការប៉ុនប៉ងមួយដើម្បីប្រែក្រឡាស់សភាពការណ៍ជ័យជំនះរបស់វា ។ ក្នុងអត្ថបទឃោសនាដ៏ទូលំទូលាយមួយ នាខែកញ្ញា ឆ្នាំ ១៩៦៧ មេដឹកនាំកងទ័ពវៀតណាម វ៉ូ ង្វៀង យ៉ាប់ បានគូសបញ្ជាក់ជាថ្មីអំពីសេចក្តីបារម្ភរបស់វៀតណាម ថាសហរដ្ឋអាមេរិកកំពុងបំរុងពង្រីកសង្គ្រាមនៅជ្រោយឥណ្ឌូចិនទាំងមូលហើយ ។ បើសិនជាការនេះកើតឡើងនោះ រូបគេសង្ឃឹមថា ជនកម្ពុជានឹងត្រៀមខ្លួនជាស្រេចហើយដើម្បីធ្វើការប្រយុទ្ធស្មាទឹមស្មាជាមួយវៀតណាមជាមិនខាន ។ ក្នុងការវិភាគមួយនាខែតុលា មានការផ្សព្វផ្សាយដូចគ្នានេះ ដោយប្រព័ន្ធផ្សាយព័ត៌មានវៀតណាម ប្រធានបក្ស ឡេ យន់ បានលើកឡើងអំពីប្រផ្នូលនៃការកើតមានរដ្ឋប្រហារប្រតិកិរិយាមួយនៅកម្ពុជា ដែលជាលទ្ធផលនៃឧបាយកលទុច្ចរិតនៅទីនោះ ដោយយកប្រៀបលើការលំបាកខាងសេដ្ឋកិច្ច និងចំណុចខ្សោយខ្លះរបស់សម្តេចសីហនុ ដែលជាថ្មីម្តងទៀតជាគ្រោះថ្នាក់នៃការក្លាយជារណបនៃចក្រពត្តិអាមេរិក ។ នាចុងឆ្នាំនោះ វៀតណាមបានប្រកាសជាឯកតោភាគី ថាពួកគេមានការព្រួយបារម្ភជាងពេលណាៗទាំងអស់ អំពីការស្រេកឃ្លាននៃការប្រទូស្តរាយរបស់ចក្រពត្តិអាមេរិក ក្នុងការឈ្លានពានរបស់ពួកគេមកលើកម្ពុជា ដែលការនេះបានក្លាយយ៉ាងច្បាស់ហើយដោយវិសាលភាពដែលពួកសង្គ្រាមនិយមអាមេរិក "បានធ្វើឡើងជាបន្តបន្ទាប់ ដោយការបង្ករឿងយ៉ាងងងើលប្រឆាំងកម្ពុជា ខាងយោធា និងខាងនយោបាយ" ។*

*ការវិភាគរបស់ ឡេ យន់ នាខែតុលា ក៏បានអះអាងឡើងវិញដែរថា ជនកុម្មុយនីសដទៃទៀតត្រូវរៀនមេរៀនអំពីបដិវត្តន៍វៀតណាម ដើម្បីបំពេញភារកិច្ចរបស់ពួកគេជាអ្នកឈានមុខនៃបដិវត្តន៍ក្នុងប្រទេសពួកគេរៀងៗខ្លួន ។ ដើម្បីផ្តល់ដល់ការតស៊ូរបស់ពួកគេឱ្យមានលក្ខណៈប្រជាប្រិយ៍ នោះពួកគេត្រូវប្រើទាំងកម្លាំងនយោបាយ និងកម្លាំងយោធា ដើម្បីជំរុញការបះបោររបស់មហាជនដែលទទួលរងការជិះជាន់និងការគៃប្រវ័ញ្ច នៅពេលសភាពការណ៍ទុំសំរាប់ការធ្វើបដិវត្តន៍ហើយនោះ ។ រូបគេបានពន្យល់ថា តើត្រូវថ្លឹងថ្លែងយ៉ាងដូចម្តេចនៅពេលសភាពការណ៍នេះមកដល់:បើសិនជាខ្មាំងនៃបដិវត្តន៍ប្រើមធ្យោបាយឃោរឃៅនិងហ្វាស៊ីសបំផុត ដើម្បីសាបព្រោះភេរវកម្ម និងកាប់សម្លាប់មហាជនដោយទ្រង់ទ្រាយធំនោះ មានន័យថា ជាក់ស្តែងពួកគេបរាជ័យខាងនយោបាយជាមូលដ្ឋានហើយ ។ នេះគឺដល់ពេលវេលាដែលត្រូវងើបឡើងហើយ ដើម្បីធ្វើការតស៊ូស្លាប់រស់ ដោយប្រើមធ្យោបាយនយោបាយនិងយោធា ដើម្បីកំទេចការក្តោបក្តាប់រដ្ឋបាលរបស់ខ្មាំង និងបង្កើតឡើងនូវកម្លាំងប្រដាប់អាវុធ ដើម្បីធ្វើសង្គ្រាមប្រជាជនដ៏រីករាលដាលមួយនៅតាមជនបទដ៏ទូលំទូលាយ ។ ជនកុម្មុយនីសត្រូវហ៊ានចលនាមហាជនឱ្យធ្វើការបះបោរ ហើយមិនត្រូវមើលស្រាលចំពោះកម្លាំងរបស់បដិវត្តន៍ទេ ។ ទីបញ្ចប់ នៅពេលការបះបោរបានកើតឡើងហើយ នយោបាយរបស់ពួកគេគឺត្រូវជំរុញការវាយសំរុកជានិច្ច ដើម្បីជំរុញបដិវត្តន៍ឱ្យឈានទៅមុខ ដាច់ខាតមិនត្រូវបកមកប្រកាន់យកយុទ្ធសាស្ត្រការពារខ្លួនទេ ។*

*អ្នកទ្រឹស្តីនិយមវៀតណាមជាន់ខ្ពស់ ទ្រឿង ជីញ បានលើកឡើងចំណុចដូចគ្នានេះ ក្នុងសុន្ទរកថារបស់គេ នៅដើមខែវិច្ឆិកា ឆ្នាំ ១៩៦៧ ថា: កាលណាចលនាកុម្មុយនីសមួយ ត្រូវបានកំទេចដោយវិធីសាហាវឃោរឃៅបំផុតនោះ ចលនានេះពុំមានជំរើសអ្វីក្រៅពីការប្រើហឹង្សាបដិវត្តន៍នោះទេ ។ មធ្យោបាយត្រឹមត្រូវតែមួយគត់ គឺការប្រើហឹង្សាបដិវត្តន៍ដើម្បីកំទេចហឹង្សាប្រឆាំងបដិវត្តន៍ និងធ្វើការបះបោរប្រដាប់អាវុធ ។ ម្យ៉ាងទៀត នាយករដ្ឋមន្ត្រី ផាំ វ៉ាន់ដុង បានអះអាងថា មានលទ្ធភាពអាចចលនាប្រជាជនឱ្យពួកគេប្រកាន់យកការតស៊ូបដិវត្តន៍ដាច់ខាត យូរអង្វែង និងទ្រាំទ្រលំបាកវេទនា ដោយប្រើហឹង្សានយោបាយដើម្បីដណ្តើមអំណាចឱ្យបាន បក្សម៉ាក្ស-ឡេនីន ឈានមុខមួយត្រូវឈរដាច់ខាតលើគោលការណ៍ខ្លួនទីពឹងខ្លួន ។ ដូច្នេះ គោលជំហរវៀតណាម គឺថាពេលវេលាដល់ហើយដែលកម្លាំងបដិវត្តន៍គ្រប់ប្រទេសទាំងអស់ត្រូវប្រមូលកម្លាំងពួកគេ ដើម្បីធ្វើការតស៊ូប្រឆាំងចក្រពត្តិនិយម តាមរយៈការបះបោរប្រដាប់អាវុធ ។ ពួកគេបានបន្តកោតសរសើរដល់គន្លងដែលបានបញ្ជេះដោយប្រជាជនភាគខាងត្បូងវៀតណាម នៃការធ្វើការបះបោរនៅមូលដ្ឋានដោយខ្លាំងក្លា ឱ្យក្លាយទៅជាសង្គ្រាមប្រជាជនដោយសព្វមុខបាន ។ នេះគឺជាយុទ្ធសាស្ត្រដ៏សក្តិសិទ្ធសំរាប់ធ្វើឱ្យបរាជ័យខ្មាំងសត្រូវទាំងអស់ ។*

*ទាក់ទងនឹងបញ្ហាថា តើកម្ពុជាទុំខាងនយោបាយសំរាប់ធ្វើបដិវត្តន៍ហើយឬនៅនោះ ការវាយតម្លៃរបស់វៀតណាមដែលលើកឡើងថា កត្តានយោបាយសំខាន់ជារចនាសម្ព័ន្ធវណ្ណៈនោះ ហាក់ដូចជាសឹងតែត្រឹមត្រូវតតខ្វះហើយ ។ ចរន្តនៃព្រឹត្តិការណ៍ចាប់តាំងពីដើមទសវត្ស ១៩៦០ មក នាំឱ្យឃើញថាពុំមានជំរើសអ្វីផ្សេងទៀតទេ: ការបង្ក្រាបការប៉ុនប៉ងរបស់បក្សចូលរួមការបោះឆ្នោត និងការសម្លាប់ ទូ សាមុត ក្នុងឆ្នាំ ១៩៦២ ការគំរាមកំហែងដល់ ស, សារី, សុន សេន និងមេដឹកនាំ បពខ ដទៃទៀត នាដើមឆ្នាំ១៩៦៣, ការបណ្តេញ ខៀវ សំផន និងពួកអ្នកចំរើនដទៃទៀត ចេញពីរដ្ឋាភិបាលនាចុងឆ្នាំដដែលនោះ, រលកនៃការចាប់ខ្លួនសកម្មជនបង្កប់ជាបន្តបន្ទាប់ក្នុងទីក្រុងតាំងពីឆ្នាំ ១៩៦៥ មក, ការបង្ក្រាបដោយបង្ហូរឈាមចំពោះការបះបោរនៅជនបទនៃខេត្តបាត់ដំបង និងការគំរាមកំហែងចាប់ដាក់គុក ឬធ្ងន់ធ្ងរជាងនេះទៀតប្រឆាំងបញ្ញាជនឆ្វេងនិយមទាំងឡាយ ចាប់តាំងពីដើមឆ្នាំ ១៩៦៧ ។ ទាំងនេះបញ្ជាក់ថារបបសម្តេចសីហនុ និងជាពិសេស លន់ ណុល ដែលជាស្ទូលដ៏រឹងមាំខាងសន្តិសុខនៃរបបនេះ ត្រូវបានបង្កើនឡើងជាប្រភេទភេរវកម្មឃោរឃៅ ការសម្លាប់ និងការកំទេច ដែលជាសញ្ញានៃការដួលរលំខាងនយោបាយនៃរបបនេះ ដូច្នោះហើយ សេចក្តីត្រូវការឱ្យមានការប្រយុទ្ធប្រឆាំងនឹងហឹង្សាប្រឆាំងបដិវត្តន៍ដោយហឹង្សាបដិវត្តន៍ ដោយជំរុញវាឱ្យហួសពីការរៀបចំខ្លួនដើម្បីធ្វើការតស៊ូប្រដាប់អាវុធ ឱ្យទៅជាការតស៊ូប្រដាប់អាវុធជាក់ស្តែងមួយក្នុងពេលនេះតែម្តង។*

*អ្វីៗទាំងអស់ដែលវៀតណាមបាននិយាយ បានផ្តល់ដល់ជនកម្ពុជានូវហេតុផលថា ហេតុអ្វីបានជាគន្លងនេះ គឺជាមនោគមវិជ្ជាតែមួយគត់ដែលមានភាពត្រឹមត្រូវនោះ ។ វាគឺជាអ្វីមួយដែលត្រឹមត្រូវ ចំពោះប្រទេសតូច និងមានប្រជាជនតិច ទោះបីជាបក្សកុម្មុយនីសរបស់ពួកគេខ្សោយនិងមានតែបាតដៃទទេក៏ដោយ និងមិនថាចក្រពត្តិអាមេរិកហាក់ដូចជាខ្លាំងជាងប៉ុណ្ណាក៏ដោយ ។ វាគឺជាផ្លូវតែមួយគត់ ដើម្បីគេចផុតពីការកំទេចរបស់ចក្រពត្តិនិយម និងខ្ញុំកញ្ជះក្នុងស្រុករបស់វា និងជាផ្លូវល្អបំផុតដើម្បីជួយវៀតណាមក្នុងសង្គ្រាមប្រឆាំងអាមេរិករបស់ពួកគេ ។ អ្វីដែលវៀតណាមបាននិយាយជាសាធារណៈ ហាក់ដូចជាធ្វើឱ្យជនកម្ពុជាគ្មានជំរើសអ្វីក្រៅពីធ្វើការតស៊ូដោយអាវុធ មុនចក្រពត្តិអាមេរិកធ្វើសកម្មភាពប្រឆាំងសម្តេចសីហនុ និងប្រទេសកម្ពុជាទេ ។ បើពួកកុម្មុយនីសកម្ពុជារង់ចាំរហូតដល់សហរដ្ឋអាមេរិកឈ្លានពានកម្ពុជាហើយ ទើបធ្វើការតស៊ូប្រដាប់អាវុធ នោះ វាអាចយឺតពេលហើយ ។ ភាគខាងត្បូងវៀតណាម បានជំរុញទៅមុខយ៉ាងខ្លាំងបំផុតរបស់ពួកគេហើយ រវាងឆ្នាំ ១៩៥៩ និង ១៩៦៤ មុនកងទ័ពអាមេរិកត្រូវបានបញ្ជូនមកភាគខាងត្បូង ហើយយន្តហោះទម្លាក់គ្រាប់បែកអាមេរិកចាប់ផ្តើមវ៉ៃលើវៀតណាមជាទូទៅ ទាំងភាគខាងជើងនិងភាគខាងត្បូង ។ នៅពេលអ្វីៗទាំងនេះបានកើតឡើង ពួកកុម្មុយនីសត្រូវបានរងការបំផ្លាញ និងស្ថិតក្នុងភាពច្របូកច្របល់ គ្មានទីពឹង ។ ក្នុងការវិភាគផ្ទាល់របស់ពួកគេ អំពីរយៈកាលដំបូងៗនេះ បពវ បានបដិសេធថាការជំរុញខាងយោធាដ៏សំខាន់ ដើម្បីកំទេចរដ្ឋាភិបាលទីក្រុងព្រៃនគរក្នុងឆ្នាំ ១៩៦៤ អាចបង្កឱ្យសហរដ្ឋអាមេរិកអន្តរាគមន៍ភ្លាម អាស្រ័យ*

*ហេតុនេះរឿងអីដែល បពខ ត្រូវទទួលយកឡូហ្សិកនៃបរាជ័យដែលការបះបោរមួយនៅកម្ពុជានឹងធ្វើឱ្យមានឡើងនោះ? បើសិនជារដ្ឋប្រហារប្រឆាំងសម្ដេចសីហនុ និងការឈ្លានពានរបស់សហរដ្ឋអាមេរិក ប្រាកដជាកើតឡើងមែននោះ បើសិនជាសម្ដេចសីហនុ និងពួកអ្នកជាតិនិយមសង្គមរាស្ត្រនិយមដទៃទៀត - ទោះបីជាក្នុងរូបភាពបែបណាក៏ដោយ - មិនអាចគេចផុតពីការពឹងផ្អែកជាយថាហេតុលើចក្រពត្តិនិយមនោះ ហេតុអ្វីក៏មិនធ្វើសកម្មភាពប្រឆាំងរបបមួយដែលពួកគេពឹងផ្អែកទាំងស្រុងនោះពីឥឡូវនេះទៅ? ការជាប់ពាក់ព័ន្ធដោយច្បាស់នៃគោលជំហររបស់ បពវ នោះ គឺថានេះជាផ្លូវតែមួយគត់ដើម្បីរក្សាឯករាជភាពនៃប្រទេសកម្ពុជា និងបក្សកុម្មុយនីសកម្ពុជា ។ ការធ្វើអ្វីផ្សេងពីនេះ គឺជាសញ្ញានៃស្តាំនិយមមួយ និងអវិជ្ជមាននិយម ជាការខ្វះសេចក្ដីទុកចិត្តលើខ្លួនឯង និងប្រជាជនខ្លួន ។ ការមិនធ្វើដោយខ្លួនឯងនោះ នឹងផ្ទុយពីគោលការណ៍ ឯករាជ្យ ខ្លួនទីពឹងខ្លួន ស្វ័យគ្រប់គ្រាន់ និងភាពម្ចាស់ការលើវាសនាខ្លួនដោយខ្លួនឯង ។ ម្យ៉ាងទៀត សេចក្ដីត្រូវការឱ្យដើរតាមគន្លងនៃហ៊ឹង្សាបដិវត្តន៍ នៅតែជាច្បាប់ដែលជៀសមិនផុតនៃប្រវត្តិសាស្ត្រសកលលោកសម័យបច្ចុប្បន្ន ជាផ្នែកនៃបេសកកម្មជាប្រវត្តិសាស្ត្ររបស់បក្សកុម្មុយនីសទាំងអស់ ដែលត្រូវតែបំពេញជាភារកិច្ចឈានមុខមួយរបស់ពួកគេ ។ ការដើរតាមគន្លងនេះ ជាការធានាឱ្យមានការអភិវឌ្ឍន៍យ៉ាងលឿននៃកងទ័ពបដិវត្តន៍ ដែលគ្មានអ្នកណាអាចយកឈ្នះបាន ដែលមានសមត្ថភាពអាចប្រែក្លាយភាពទន់ខ្សោយខាងសម្ភារៈរបស់ចលនាបដិវត្តន៍ ឱ្យទៅជាកម្លាំងនយោបាយដែលខ្លាំង និងអាចធ្វើឱ្យបរាជ័យសត្រូវណាមួយ ឬទាំងអស់តែម្ដង ។*

*ដូច្នេះ ឡូហ្ស៊ិកនៃវោហាសាស្ត្រជាសាធារណៈរបស់វៀតណាម គឺថាពួកកុម្មុយនីសកម្ពុជា ត្រូវផ្ដើមគំនិតធ្វើឱ្យមានការបះបោរនយោបាយ ដើម្បីដណ្ដើមអាវុធ ហើយបន្ទាប់មកធ្វើកុប្បកម្មប្រដាប់អាវុធនៅតំបន់ជនបទ និងជាពិសេសនៅតំបន់ភ្នំ ។ ពួកគេត្រូវទៅឱ្យឆ្ងាយជាងស្វ័យការពារ និងត្រូវកំទេចរដ្ឋបាល និងកម្លាំងសន្តិសុខមូលដ្ឋាន ដែលទាំងពីរនេះជាការវាយបកទៅលើការបង្ក្រាបនាពេលកន្លងមក និងដើរមុនសភាពការណ៍ ក្នុងទស្សនៈដើម្បីបង្កើតមូលដ្ឋានបដិវត្តន៍នៅតំបន់ជនបទ ដែលនឹងផ្ដល់ការគាំទ្រដល់ការតស៊ូនយោបាយដែលកំពុងប្រព្រឹត្តទៅនៅភ្នំពេញ និងនៅទីកន្លែងដទៃទៀត ។*

*ស្ដីពីភាពទុំនៃសេដ្ឋកិច្ចសង្គមកម្ពុជា សំរាប់បដិវត្តន៍ប្រជាធិបតេយ្យប្រជាជាតិប្រជាជនវិញ ហាក់ដូចជាលែងជាបញ្ហាទៀតហើយ ។ នេះគ្រាន់តែជាផ្នែកមួយប៉ុណ្ណោះ ដោយសារតែនិន្នាការឆ្ពោះទៅការប្រសប់មុខគ្នា ក្នុងរចនាសម្ព័ន្ធសង្គមនៃភាគខាងត្បូងវៀតណាម និងកម្ពុជា: កសិកភាវូបនិយកម្មថ្នាក់កណ្ដាល និងការបែកខ្ញែកគ្នានៅជនបទក្នុងចំណោមពួកគេ ធ្វើឱ្យមើលឃើញថាពួកគេហាក់មានភាពដូចគ្នាយ៉ាងសម្បើម ទោះបីជានៅមានភាពខុសគ្នាខ្វះក៏ដោយ ។ នៅវៀតណាមខាងត្បូង ការចែកដីឡើងវិញរបស់រដ្ឋាភិបាលទីក្រុងព្រៃនគរ និង បពវ និងការដែលកសិកររត់ចូលទីក្រុងដើម្បីគេចចេញពីប្រតិបត្តិការយោធារបស់អាមេរិក និងរបស់ពួកព្រៃនគរ និងពីការធក់ប្ញន់របស់ពួកកុម្មុយនីស នាពាក់កណ្ដាលទសវត្ស ១៩៦០ បានបង្កើតឡើងនូវជនបទមួយពោរពេញទៅដោយវណ្ណៈថ្មីភាគច្រើននៃម្ចាស់ដីឯកជននៃបុគ្គល ។ ពួកម្ចាស់ដីត្រូវបាត់ស្រមោលក្នុងការជាក់ស្ដែង ហើយកសិករមានបានបន្ថយមកនៅត្រឹមអប្បភាគដ៏តូចមួយប៉ុណ្ណោះ ។ ជាការបញ្ច្រាសទៅវិញ ទោះបីជាមានការកើនឡើងនៃវណ្ណៈកម្មករកម្ពុជាក៏ដោយ ក៏វានៅតូចពេកនិងខ្សោយខាងនយោបាយនៅឡើយ ដើម្បីដើរតួនាទីដែលត្រូវបានផ្ដល់ឱ្យដល់ពួកគេនៅវៀតណាមក៏ដោយ អ្វីមួយដែលដូចជាជម្លោះជាមួយ"កសិករម្ចាស់ដីប្រឆាំង" ហាក់ដូចជាកំពុងធំធាត់ឡើងនៅកម្ពុជា ។ មិនត្រឹមតែនៅបាត់ដំបងប៉ុណ្ណោះទេ តែក៏នៅកន្លែងដទៃទៀតដែរ ទុគ៌តភាវូបនិយកម្មនៃកសិករបណ្ដាលមកពីការប្រមូលស្រូវដោយបង្ខំ និងការជំពាក់បំណុលក្នុងខេត្តដទៃទៀត បាននាំឱ្យមានលក្ខណៈសម្បត្តិ ដែលហាក់ដូចជាសមស្របសំរាប់ការអភិវឌ្ឍន៍ដែលមានមូលដ្ឋានមហាជនកុប្បកម្មបដិវត្តន៍ ទោះបីជាកសិករភាគច្រើនជាអ្នកស្រែចំការឯកជនធម្មតាមិនមែនជាកម្មករកសិកម្មក៏ដោយ ។ ទំនាស់វណ្ណៈនៅជនបទ ហាក់ដូចជាមានលក្ខណៈគ្រប់គ្រាន់ សំរាប់ទ្រទ្រង់ដល់ការជំរុញពីការតស៊ូនយោបាយទៅការតស៊ូប្រដាប់អាវុធ ដែលអាចធ្វើការជាប្រភេទអព្ភូតហេតុបដិវត្តន៍ ដែលវៀតណាមសំរេចបាននៅជាប់*

ភូមិផងរបងជាមួយគ្នាក្នុងឆ្នាំ ១៩៥៩-១៩៦០ ដោយធ្វើឱ្យគាំងរដ្ឋបាលរដ្ឋាភិបាលក្នុងតំបន់ជនបទជាច្រើន និងបង្កើតលក្ខណៈសម្បត្តិសំរាប់សម្របច្បាប់ដល់រដ្ឋបាលប្រឆាំងនៅមូលដ្ឋាន ។

ទោះបីយ៉ាងណាក៏ដោយ ដូចបានកត់សំគាល់ខាងលើស្រាប់ គោលជំហររបស់ បពវ ឆ្នាំ ១៩៦៧ ក្នុងការឃោសនា និងលើសពីនេះទៅទៀត ក្នុងការអនុវត្តន៍ នាំឱ្យយល់ថាការខុសគ្នាបែបនេះ ដូចដែលបានកើតមានក្នុងរចនាសម្ព័ន្ធសង្គមជនបទមិនត្រូវបកស្រាយថាជាសារសំខាន់ជាចំហបានទេ ។ ការនេះបានបដិសេធការទទួលស្គាល់ការពិតនៃកសិករភាវូបនីយកម្មថ្នាក់កណ្តាលនៅភាគខាងត្បូង ចូលប្រឡូកក្នុងការបត់បែន ដោយប្រើផ្លាកប្រភេទវណ្ណៈដើម្បីបិទបាំងវា ។ វាបានសង្កត់លើកត្តានយោបាយ និងសេចក្តីប្តេជ្ញាដើម្បីបន្តធ្វើបដិវត្តន៍ប្រជាធិបតេយ្យប្រជាជាតិប្រជាជនផ្ទាល់របស់គេ ទោះបីជាកសិករភាវូបនីយកម្មថ្នាក់កណ្តាលមិនបានធ្វើអ្វីដើម្បីបង្អាក់ បពខ កុំឱ្យបន្តចាត់ទុកសង្គមកម្ពុជាថាជាការចម្លងតាមសង្គមភាគខាងត្បូងវៀតណាម ដែលជាកន្លែងមួយដែលបដិវត្តន៍បែបនេះមួយ មានភាពសមស្រប ចាំបាច់ និងអាចសំរេចបាននោះទេ ។

### នួន ជីកនាំពីភ្នំពេញ: ស ធ្វើតាមនៅព្រៀសាន

ក្នុងឆមាសទី ២ នៃឆ្នាំ ១៩៦៧ នួន និងដៃគូសន្ទនារបស់គេ បានជំរុញឆ្ពោះទៅការតស៊ូប្រដាប់អាវុធ ដើម្បីបញ្ជាក់ថានេះគឺជាការពិត ដោយមិនរង់ចាំប្រជុំជាមួយ ស និងសមាជិកគណៈកម្មាធិការមជ្ឈឹមដទៃទៀតនៅព្រៀសាន ដើម្បីអនុម័តសេចក្តីសន្និដ្ឋាននេះឡើយ ។ ក្នុងពេលពិភាក្សាគ្នាជាមួយកម្មាភិបាលដែល នួន កោះប្រជុំនៅភ្នំពេញ ក្នុងខែកក្កដា ផែនការរបស់គេដើម្បីជំរុញកុប្បកម្ម ត្រូវបានធ្វើឡើងដោយជាក់លាក់ថែមទៀត ។ អនុលេខា បពខ បានសរុបបទពិសោធរបស់បក្ស ចំពោះព្រឹត្តិការណ៍នាពេលថ្មីៗកន្លងទៅនេះ ។ រូបគេបានសន្និដ្ឋានថា ដោយអាជ្ញាធរសង្គមប្រាកដជាបន្តការវាយប្រហារដោយហឹង្សាមកលើបក្ស និងពួកអ្នកគាំទ្របក្ស ចលនាកុម្មុយនីសកម្ពុជាត្រូវតែរៀបចំលក្ខណៈសម្បត្តិសំរាប់ធ្វើការបះបោរទូទាំងប្រទេសមួយក្នុងឆ្នាំ ១៩៦៨ ដឹកនាំដោយការប្រយុទ្ធដ៏មានពិសោធនិងសន្ធោរសន្ធៅនៅព្រៀសាន ។

សេចក្តីសំរេចជាជំរុញទៅមុខនេះ ត្រូវបានធ្វើឡើងក្នុងសន្និបាតមួយក្នុងរាជធានី នាចុងឆ្នាំ ១៩៦៧ ។ នួន ជាអ្នកដឹកនាំអង្គប្រជុំ ហើយកម្មាភិបាល បពខ សំខាន់ៗភាគច្រើននៃអតីត បកត មានវត្តមាន ក្នុងនោះ រួមមាន ភឹម, លេខាភូមិភាគនិរតី ម៉ាម៉ង់ និងអនុរបស់គាត់ តាម៉ុក ។ តាម នួន ឱ្យដឹង សេចក្តីសំរេចដែលបានប្រកាន់យក គឺ"ដឹកនាំធ្វើការតស៊ូនយោបាយរួមផ្សំអាវុធ ។ កន្លែងណាដែលអាចងើបឡើងបានមុន ត្រូវធ្វើភ្លាម ដូច្នេះមិនមានការចាំបាច់ត្រូវធ្វើព្រមគ្នាក្នុងពេលតែមួយឡើយ" ។ ទាំងនេះបានឈរលើមូលដ្ឋាននៃការអះអាងដែលថា"នៅចុងឆ្នាំ ១៩៦៧ , ... ការតស៊ូចូលដល់ដំណាក់កាលកាន់តែខ្លាំងឡើងៗហើយ", តែការឈានទៅមុខរបស់វាត្រូវស្ទះ ដោយសារ"ការបង្ក្រាបជាបន្តបន្ទាប់" របស់ខ្មាំង ដែលនឹងអាចជំនះបានតែតាមរយៈសកម្មភាពប្រដាប់អាវុធប៉ុណ្ណោះ ។ សេចក្តីសំរេចបានអំពាវនាវឱ្យដណ្តើមអាវុធ ដោយអង្គភាពការពារសម្ងាត់ ដែលបានបង្កើតឡើងនៅគ្រប់ភូមិភាគនៅពេលនោះ ។ ជាមួយអាវុធទាំងនេះ កងការពារ និងនិរសាបក្ស អាចប្រែក្លាយទៅជាអង្គភាពឈ្លប និងចាប់ផ្តើម"ធ្វើសង្គ្រាមឈ្លប"បានហើយ ដោយចាប់ផ្តើមពីខេត្តបាត់ដំបង ហើយបន្ទាប់មកជំរុញការវាយសំរុកទូទៅទូទាំងប្រទេសដើម្បីទប់ស្កាត់កងទ័ព លន់ ណុល កុំឱ្យប្រមូលផ្តុំកម្លាំង ដើម្បីប្រឆាំងការបះបោរនៅតំបន់ណាមួយបានឱ្យសោះ ។

ទស្សីករបស់ បពខ ក្នុងការគាំទ្រការតស៊ូប្រដាប់អាវុធ ច្បាស់ណាស់គឺជាការបន្ទរតាមអ្វីដែលបានធ្វើនៅភាគខាងត្បូងវៀតណាម នាចុងទសវត្ស ១៩៥០ និងដែលត្រូវបានបញ្ជាក់ឡើងវិញជាបន្តបន្ទាប់តាំងពីពេលនោះមក ។ ទី ១ ព្រឹត្តិការណ៍នៅបាត់ដំបង បានបង្ហាញថាសភាពការណ៍របស់ប្រជាជននៅទូទាំងប្រទេសនៅជនបទបានទុំហើយ។ ដោយសារថាសភាពការណ៍បានទុំនេះហើយ ទើបប្រជាជនផ្ទុះឡើងដោយខ្លួនឯង ដែលជាការបញ្ជាក់ថា កំហឹងវណ្ណៈរបស់ពួកគេបានពុះកញ្ជ្រោលហើយ។ ទី ២ បើបក្សមិនជំរុញឱ្យហួសពីស្វ័យការពារ នោះខ្មាំងនឹងកំទេចកម្លាំងបដិវត្តន៍ជាមិនខាន ។ ដូច្នេះ បើបក្សនៅតែបន្តត្រឹមតែ

*ធ្វើការតស៊ូនយោបាយប៉ុណ្ណោះ ហើយមិនចាប់យករូបភាពនៃការតស៊ូប្រដាប់អាវុធទេនោះ បក្សនឹងមិនត្រឹមតែមិនអាចការពារកម្លាំងបដិវត្តន៍បានប៉ុណ្ណោះទេ តែថែមទាំងមិនអាចពង្រឹង ឬពង្រីកវាបានថែមទៀតផង ។ ផ្ទុយទៅវិញ បើបក្សបូកបន្ថែមការតស៊ូប្រដាប់អាវុធទៅនឹងការតស៊ូនយោបាយ នោះនឹងមានលទ្ធភាពដើម្បីវាយប្រហារខ្មាំង ការពារបដិវត្តន៍ និងបង្កលក្ខណៈសម្បត្តិដើម្បីពង្រឹង និងពង្រីកកម្លាំងបដិវត្តន៍បានថែមទៀតផង ។ ទី៣ ខ្មាំងមានការយល់ច្រឡំ និងអសមត្ថភាព នឹងទប់ទល់នឹងកម្លាំងបដិវត្តន៍ ។*

*វៀតណាម និងចិន បានសាកល្បងបញ្ចុះបញ្ចូល បពខ ថាសេចក្តីសំរេចនេះមិនត្រឹមត្រូវទេ ។ ពួកគេអះអាងថា ផ្ទុយទៅវិញ នេះគឺជាប្រផ្នូលនៃការវិនាសអន្តរាយដល់បដិវត្តន៍កម្ពុជាទៅវិញទេ ដោយកុប្បកម្មរបស់ បពខ ធ្វើឡើងនៅពេលសម្តេចសីហនុ និងលន់ ណុល កំពុងស្ថិតនៅក្នុងអំណាច វាគ្រាន់តែជាការទាញទម្លាក់ទម្ងន់ទាំងមូលនៃសក្តិភូមិនិយម និងយោធានិយម មកលើខ្លួនតែប៉ុណ្ណោះ ព្រមពេលជាមួយគ្នាវានឹងធ្វើឱ្យមានគ្រោះថ្នាក់ដ៏ធ្ងន់ធ្ងរដល់សុច្ចន្ទៈរបស់សម្តេចសីហនុ និងមេបញ្ជាការកងទ័ព ក្នុងការបន្តបំរើដល់សេចក្តីត្រូវការរបស់ពួកកុម្មុយនីសវៀតណាម ផងដែរ។*

*នៅបូព៌ា លេខាភូមិភាគ ភឹម បានការពារសេចក្តីសំរេចដោយទឡ្ហីករដ៏គ្រេវគ្រោធ ជាមួយដៃគូសន្ទនាវៀតណាមរបស់គេ ។ ភឹម បានប្រាប់ពួកគេថា សីហនុ មានការងាយទទួលរងនូវការទម្លាក់ចេញពីអំណាចជាទីបំផុត ដោយពួកយោធាប្រតិកិរិយា ពួកសមាសភាពសក្តិភូមិ និងនាយទុន មានការងាយនឹងសម្របខ្លួនដោយពេញទីនិងដោយចំហជាមួយអាមេរិក ដើម្បីធ្វើឱ្យខូចប្រយោជន៍ដល់បដិវត្តន៍ មិនត្រឹមតែចំពោះកម្ពុជាប៉ុណ្ណោះទេ តែក៏ចំពោះភាគខាងត្បូងវៀតណាមផងដែរ ។ ពួកគេអាចនឹងអនុញ្ញាតឱ្យអាមេរិកនិងយោធារបស់គេ ចូលមកកម្ពុជាដើម្បីជួយបញ្ចប់បញ្ហាជាមួយ បពខ កាត់ផ្តាច់ខ្សែដឹកជញ្ជូនកសុ្កភាររបស់ចិនទៅឱ្យពួកកុម្មុយនីសវៀតណាម វាយសំរុកកំទេចជម្រករបស់ពួកកុម្មុយនីសវៀតណាមនៅក្នុងទឹកដីកម្ពុជា និងប្រើប្រទេសកម្ពុជាធ្វើជាមូលដ្ឋានដើម្បីវាយប្រហារទៅលើមូលដ្ឋានកុម្មុយនីសវៀតណាមក្នុងវៀតណាមពីក្រោយខ្នង ។*

*ការគាំទ្ររបស់ចិនចំពោះទស្សនៈវៀតណាម ត្រូវបានផ្តល់មកឱ្យ នួន នៅចុងឆ្នាំ ១៩៦៧ ពេល នួន បានជួបជាសម្ងាត់នៅភ្នំពេញ ជាមួយមន្ត្រីស្ថានទូតចិនម្នាក់នៅទីនោះ ក្នុងអ្វីមួយដែលគ្រាន់តែត្រូវបានដឹងថា ជាទំនាក់ទំនងផ្ទាល់រវាងចិន និងកម្ពុជា បន្ទាប់ពី ស ត្រឡប់មកពីប្រទេសចិនវិញ ។ មន្ត្រីទូតចិនរូបនោះបានសួរ នួន ថាតើកម្ពុជាប្រាកដជាមានសមត្ថភាពពិតប្រាកដសំរាប់ធ្វើការតស៊ូប្រដាប់អាវុធឬទេ តែរូបគេក៏មានការចចេសអំពីថា បពខ ត្រូវតែធ្វើយ៉ាងដូច្នោះ ។ បន្ទាប់ពីការប្រជុំនេះ ចិនបានគេចមិនឱ្យមានការទាក់ទងអ្វីទាំងអស់ជាមួយ បពខ ដោយខ្លាចសម្តេចសីហនុដឹង នាំឱ្យស្មុគ្រស្មាញដល់ការទាក់ទងរបស់ពួកគេជាមួយសម្តេច និងបំផ្លាញដល់ផ្លូវដឹកជញ្ជូនកសុ្កភាររបស់ពួកគេទៅឱ្យពួកវៀតណាម ។ ដើម្បីការពារកិច្ចការនេះ ពួកគេនៅតែបន្តផ្តល់អាវុធដល់ពួក លន់ ណុល ដោយបញ្ចេញការសំញ៉ែងដោយការដឹកជញ្ជូនមួយលើកថ្មីទៀត ក្នុងខែមករា ឆ្នាំ ១៩៦៨ ។*

*ស, អៀង សារី និង សុន សេន ត្រូវបានផ្តល់ព័ត៌មានពីសេចក្តីសំរេចធ្វើឡើងនៅភ្នំពេញ ដើម្បីចាប់ផ្តើមធ្វើសង្គ្រាមប្រជាជន តាមរយៈនិរសាដែលបានធ្វើដំណើរទៅព្រៀសាន ដែលជាដំណើរមួយត្រូវប្រើពេលរាប់ខែទើបដល់ ។ ការនេះវាបដិសេធចោលគោលជំហររបស់ ស ក្នុងសំបុត្រមួយច្បាប់ផ្ញើឱ្យចិន ក្នុងខែតុលា ឆ្នាំ ១៩៦៧ ផ្តល់ព័ត៌មានដល់ចិនថាពួកកុម្មុយនីសកម្ពុជាកំពុងស្ថិតនៅក្នុងណាក់កាលនៃការត្រៀមរៀបចំខាងមនោគមវិជ្ជា និងចាត់តាំង សំរាប់ការធ្វើកុប្បកម្មហឹង្សាប៉ុណ្ណោះ ។ វាទៅហួសពីសកម្មភាពរបស់ ស នៅក្នុងខេត្តរតនគីរី ចាប់តាំងពីរូបគេបានមកដល់ទីនោះក្នុងខែកក្កដា ឬសីហា ឆ្នាំ ១៩៦៧ ។ រូបគេបានដឹងថាមូលដ្ឋាន បពខ ដែលមានស្រាប់នៅក្នុងខេត្តរតនគីរី បានទទួលរងការវាយប្រហារដោយកងទ័ពរដ្ឋាភិបាល ដែលបានសម្លាប់អ្នកភូមិ ហើយកងទ័ពក៏ត្រូវបានសម្លាប់អស់ជាច្រើននាក់ទៀតដែរ ក្នុងពេលវាយប្រហារទៅលើមូលដ្ឋានកុម្មុយនីសមួយ ក្នុងខេត្តមណ្ឌលគីរី ដែលស្ថិតនៅជាប់គ្នានោះ ។ ស បានកោះប្រជុំរៀនសូត្រសំរាប់ពួកកម្មាភិបាលមូលដ្ឋាន*

ដើម្បីពិភាក្សាអំពីការរៀបចំសំរាប់ប្រើវិធីហឹង្សាដើម្បីទប់ទល់នឹងការវាយប្រហារបែបនោះ តែពេលបន្ទាប់មក នៅក្នុងឆ្នាំដដែលនោះ ពួកកុម្មុយនីសនៅព្រៃសានរបស់គេ មិនបានដឹកនាំធ្វើសកម្មភាពហឹង្សាប្រឆាំងរដ្ឋាភិបាលទេ ។ ជាជំនួស ពួកគេបានប្រមូលផ្តុំលើសកម្មភាពនយោបាយ ដូចជាធ្វើការតវ៉ាប្រឆាំងរដ្ឋាភិបាលអំពីការទារពន្ធដារ និងធ្វើការទាក់ទាញការគាំទ្រប្រជាជនពីសំណាក់អប្បភាគជន ដោយជួយរៀបចំការថែរក្សាផ្នែកពេទ្យដល់សុខភាពប្រជាជន ដែលកន្ទងមកត្រូវបានផ្តល់ឱ្យនៅក្នុងតំបន់ខ្លះដោយកងកម្លាំងកុម្មុយនីសវៀតណាម ដែលបានប្រើខេត្តរតនគីរីជាជម្រករបស់ពួកគេ ។ សកម្មភាពជ្រើសរើសទទួលបានជោគជ័យយ៉ាងខ្លាំង ជាពិសេសក្នុងចំណោមយុវជននៃជនជាតិភាគតិច ។ បើទោះបីជាបក្សបានធ្វើការឃោសនាដោយការស្តីបន្ទោស "វណ្ណៈសក្តិភូមិរបស់សម្តេចសីហនុ" ចំពោះការមិនយកចិត្តទុកដាក់ដល់សេចក្តីត្រូវការរបស់ជនជាតិភាគតិចក៏ដោយ ក៏ ស នៅតែមើលឃើញថាខ្មាំងគឺពួកឃោធារបស់ លន់ ណុល មិនមែន សម្តេចសីហនុទេ ។ រូបគេក៏បានអះអាងផងដែរថា "ចាំបាច់ត្រូវតែមានសាមគ្គីភាពរវាងវៀតណាម ... និង កម្ពុជា" ដែល"មិនត្រូវបោះបង់ចោលគ្នាទេ" ។

នៅដើមឆ្នាំ ១៩៦៨ ការរំពើករំពើងជាថ្មីបានផ្ទុះឡើងក្នុងចំណោមអប្បភាគជន ដែលរងការប៉ះពាល់ដោយការពង្រីកចំការកៅស៊ូ ។ ប្រជាជនប្រមាណ ៥០ ០០០ នាក់បាននាំគ្នារត់ចូលព្រៃ ទោះបីជា ស បានបើកវគ្គសិក្សាខ្លីៗនៅព្រៃសាន ស្តីពីការរៀបចំដើម្បីធ្វើសង្រ្គាម ដោយរៀបមូលដ្ឋានសំរាប់ធ្វើកុប្បកម្មដោយអាវុធថែមទៀតក៏ដោយ ។ ការណ៍នេះបានឡើងដល់កំរិតខ្ពស់បំផុត ក្នុងវគ្គសិក្សាយោធាលើកទី ១ សំរាប់ទូទាំងភូមិភាគតែម្តង ដោយ ស ជាអ្នកឧទ្ទេសនាម ។ មិនយូរប៉ុន្មាន ស្រាប់តែវគ្គនេះត្រូវបញ្ចប់ទៅវិញ ដោយសារ តាមការរាយការណ៍មក ថាកងទ័ពបានចាប់និងដកអាវុធពីកងការពាររបស់កម្មាភិបាលមូលដ្ឋានម្នាក់ ។ ស បានបញ្ជាឱ្យសិក្ខាកាម"ចេញទៅវាយប្រហារខ្មាំងជាសម្ងាត់មួយរយៈពេលខ្លី ហើយត្រឡប់មកវិញភ្លាមដើម្បីជួបជុំគ្នាធ្វើការដកពិសោធពីមេរៀនពីការប្រយុទ្ធគ្នានេះ" ។ ក៏ប៉ុន្តែ ទាំងនេះមិនមានន័យថាត្រូវធ្វើការតស៊ូប្រដាប់អាវុធនោះទេ ។

តាមពិតទៅ ស មិនបានយល់ស្របចំពោះសេចក្តីសំរេចនៅភ្នំពេញរហូតដល់ថ្ងៃទី ២៥ ខែកុម្ភៈ ឆ្នាំ ១៩៦៨ នៅពេលរូបគេចេញសារាចរមួយក្នុងនាមគណៈកម្មាធិការមជ្ឈឹមបញ្ជាក់ថា ពីនេះតទៅកុម្មុយនីសនិយមកម្ពុជានឹង"ដឹកនាំធ្វើនយោបាយដោយមានការគាំទ្រដោយអាវុធ" នៅទូទាំងប្រទេស ។ រហូតមកទល់ពេលនេះ ដូចនឹងឃើញនៅក្នុងជំពូកបន្ទាប់ កុប្បកម្មត្រូវបានធ្វើឡើងហើយក្រោមការដឹកនាំរបស់ នួន នៅភូមិភាគពាយ័ព្យនិងនិរតី ហើយនៅព្រៃសានមិនទាន់បាន"ផើបឡើង"ទេ រហូតដល់ចុងខែមីនា ។

ដូច្នេះ សារាចររបស់ ស គឺធ្វើឡើងសំរាប់ នួន អំពីអ្វីដែលគណៈកម្មាធិការមជ្ឈឹម បពវ បានធ្វើសំរាប់ពួកកុម្មុយនីសភាគខាងត្បូងវៀតណាមតាំងពីប្រមាណជិតមួយទសវត្សរ៍មុន ក្នុងសេចក្តីសំរេចចិត្តលេខ ១៥ ក្នុងឆ្នាំ ១៩៥៩ ដែលត្រូវបានអនុម័តឡើងបន្ទាប់ពីការដែលសេចក្តីសំរេចមួយដែលត្រូវបានធ្វើឡើងដោយកម្មាភិបាលដឹកនាំនៅនឹងកន្លែង ។ សារាចរនេះ ក៏ត្រូវបានចេញមកបន្ទាប់ពីការវាយសំរុក តែត របស់ បពវ ដែលត្រូវបានដឹកនាំធ្វើតាមការកំណត់ នៅថ្ងៃទី ៣១ ខែមករា ឆ្នាំ ១៩៦៨ ដែលដណ្តើមបានជោគជ័យដ៏រន្ធើខ្ទរខ្ទារក្នុងដំណាក់កាលដំបូងរបស់វា ។ ការចាប់អារម្មណ៍កើតឡើងពីការវាយសំរុកនេះ ថាពួកសុទិដ្ឋិនិយមបដិវត្តន៍វៀតណាម គឺមានភាពត្រឹមត្រូវនោះ ត្រូវបានលើកទឹកចិត្តបន្ថែមទៀតដល់ ស និងពួកកុម្មុយនីសកម្ពុជាដទៃទៀត ។ កងទ័ពកុម្មុយនីសវៀតណាម បានចូលដល់ក្នុងទីក្រុងព្រៃនគរ និងទីរួមខេត្តនិងស្រុកនៅទូទាំងភាគខាងត្បូង ធ្វើឱ្យគាំងដល់កងកម្លាំងប្រដាប់អាវុធអាមេរិក និងរដ្ឋាភិបាលមួយរយៈពេល ។ ការនេះបានជំរុញឱ្យកើតមានព្រឹត្តិការណ៍ឃោរឃៅប្រកបដោយហឹង្សានៃការចូលរួមបដិវត្តន៍របស់ប្រជាជនជនបទ ។ វាហាក់ដូចជាថា អាងទឹកដែលគួរឱ្យកត់សំគាល់នៃការគាំទ្រដែលមិនទាន់ចេញមុខនៃបដិវត្តន៍បានកើតមានហើយនៅក្រោមផ្ទៃទឹកនៃភាពអសកម្មជាបណ្តោះអាសន្ន នោះគឺសង្រ្គាមរបស់មនុស្សស្មៀកពាក់ជាកសិករ ។ អស់រយៈពេលជាច្រើនអាទិត្យ ក្នុងខែកុម្ភៈ ហាក់ដូចជាការវាយសំរុកនោះទទួលបានជោគជ័យដ៏

ខ្ទរខ្ទារ ដែលបញ្ជាក់ឱ្យឃើញថា តាមរយៈនៃភាពអង់អាចក្លាហាន បដិវត្តន៍មួយអាចធ្វើបានលឿនទៅមុខ ដែលពីមុនមក ត្រូវបានចាត់ទុកថាវាស្ថិតនៅឆ្ងាយហួសយ៉ាងច្រើនពីសមត្ថភាពរបស់ខ្លួនទៅទៀត ។

ដូច្នេះ ទោះបីជាតាមរយៈការជំរុញកុប្បកម្មដោយអាវុធក្នុងឆ្នាំ ១៩៦៨ ក៏ដោយ ក៏ បពខ ដូចដែលបាននិយាយនៅពេលក្រោយមកទៀត បានធ្វើអ្វី"ផ្សេងទាំងស្រុង" ពីអ្វីដែល បពវ ចង់ឱ្យពួកគេធ្វើនោះទៅវិញ ពួកគេនៅតែធ្វើតាមសេណារីយ៉ូរបស់វៀតណាមនៅឡើយ ។ ការបកស្រាយដូចគ្នានេះ ស្របទៅនឹងសេចក្តីថ្លែងរបស់ ស ក្នុងទសវត្ស ១៩៦០ ដែលថា ចលនាកុម្មុយនីសកម្ពុជា"មិនបានដើរតាមបរទេសណាទាំងអស់" ។ សេចក្តីថ្លែងការណ៍របស់ ស អំពីឯករាជភាពនេះគឺជាការពិត អំពីការដែលថា បពខ មិនបានធ្វើតាមដំបូន្មានរបស់វៀតណាម ឬចិន ប៉ុន្តែវាធ្វើឱ្យយល់ច្រឡំ ដោយមិនយកមកពិចារណានូវការដែលថាវាបានបញ្ចូលទ្រឹស្តីកុម្មុយនីសបរទេស ជាពិសេសទ្រឹស្តីរបស់វៀតណាម ។ ការបកស្រាយដូចគ្នានេះមួយ ត្រូវបានអនុវត្តចំពោះវត្តមានក្នុងការដាក់ស្តែងរបស់ ស នាពេលក្រោយមក ដែលថាជនកុម្មុយនីសកម្ពុជាដែលបានជឿលើមាគ៌ាមួយចម្លងមកពីអ្នកដទៃណាម្នាក់នោះគឺខុស អ្វីដែលត្រូវ ត្រូវធ្វើនោះគឺត្រូវកំណត់មាគ៌ាមួយដោយឈរលើគោលជំហរ ឯករាជ្យម្ចាស់ការ និងកាន់ក្តាប់វាសនាខ្លួននៅក្នុងដៃរបស់ខ្លួន ។ ភាពស្វ័យភាពនេះ មិនបានទាត់ចោលសេចក្តីសំរេច ដើម្បីធ្វើការចម្លងដ៏ច្រើនសម្បើមដោយឈរលើមូលដ្ឋានដដែលនេះដែរ ។

## *ជំពូក ៨*

## *ការអនុវត្តន៍ សង្គ្រាមប្រជាជន តាមឯកសារដើម*

### *ការតស៊ូប្រដាប់អាវុធនៅកម្ពុជា, ឆ្នាំ ១៩៦៨-១៩៦៩*

*ក្នុងការធ្វើការតស៊ូប្រដាប់អាវុធរបស់ពួកគេ ជនកម្ពុជាក៏បានធ្វើតាមការនាំមុខរបស់វៀតណាមអំពីការរួមបញ្ចូលគ្នានៃម៉ៅនិយមដែរ ដោយបំព្រួញចលនាឱ្យនៅតែមួយជំហានធ្លោះទៅធ្វើសង្គ្រាមប្រជាជននៅភាគខាងត្បូងវៀតណាម ពីឆ្នាំ ១៩៥៦ ដល់ ១៩៦០។ ដូច្នេះ ការខាតបង់ពេលវេលាត្រូវបានសងជំនួសបានមកវិញ ហើយការអះអាងអំពីភាពបន្ទាន់នៃសភាពការណ៍ត្រូវបានឆ្លើយតបវិញ ដោយកាត់ចោលនូវអ្វីដែលវៀតណាមបានធ្វើនៅភាគខាងត្បូង ក្នុងរយៈពេល ៥ ឆ្នាំនោះ ពោលគឺៈ បង្កើតក្រុមឃោសនាប្រដាប់អាវុធ នៅឆ្នាំ ១៩៥៦, ធ្វើឃាតអាជ្ញាធរមូលដ្ឋានរបស់រដ្ឋាភិបាល នៅឆ្នាំ ១៩៥៨, វាយប្រហារប៉ុស្តិ៍ជួរមុខរបស់រដ្ឋាភិបាលនៅឆ្នាំ ១៩៥៨, ធ្វើកុប្បកម្មប្រដាប់អាវុធទ្រង់ទ្រាយតូចដើម្បីកំទេចរដ្ឋបាលខ្មាំងនៅផ្នែកខ្លះនៃជនបទនៅឆ្នាំ ១៩៥៩, និងនៅទីបញ្ចប់ ប្តូរទិសក្នុងឆ្នាំ ១៩៦០ ទៅជាការប្រើដ៏រីកពាលដាលនូវភេរវកម្ម ("ការកំទេចការបង្ក្រាប") ដោយរួមផ្សំ ទី១ ជាមួយការធ្វើកុប្បកម្មដោយការរួបរួមគ្នានៅក្នុងខេត្តខ្លះ ហើយបន្ទាប់មក ធ្វើកុប្បកម្មក្នុងពេលតែមួយជាមួយគ្នានៅក្នុងខេត្តជាច្រើនតែម្តង ។*

*យោងតាម ស និង នួន ឆាកចាប់ផ្តើមសំដែងឡើងវិញនៃឯកសារដើមរបស់សង្គ្រាមប្រជាជននេះ គឺការដណ្តើមអាវុធដើម្បីយកមកបំពាក់ឱ្យកងស្វ័យការពារ ដែលជាស្នូលនៃក្រុមឃោសនាប្រដាប់អាវុធ និងជាទារកនៃកងទ័ពបដិវត្តន៍ ។ តាមផែនការរបស់ នួន "ការផ្ទុះអាវុធទី ១" ត្រូវធ្វើនៅពាយ័ព្យ នៅថ្ងៃទី ១៧ ខែ មករា ឆ្នាំ ១៩៦៨ ពេលដណ្តើមបានអាវុធបន្តិចបន្តួចពីពួកប៉ូលីសប៉ុស្តិ៍នៅបាត់ដំបង ។ ការនេះត្រូវបានធ្វើតាម នៅថ្ងៃទី ២៥ ខែកុម្ភៈ ដោយកុប្បកម្មជាច្រើននៅទីកន្លែងជាច្រើននៅនិរតីដែល នៅពេលនោះការិយាល័យឃុំ និងប៉ុស្តិ៍ប៉ូលីសមួយចំនួន ត្រូវបានដុតកំទេច ហើយអាវុធជាច្រើនត្រូវរឹបអូសយកបាន ។ សកម្មភាពតូចៗ មួយចំនួនបានធ្វើឡើងនៅភូមិភាគឧត្តរ និងបូព៌ា ក្នុងខែមីនា ។ ទីបញ្ចប់ ឦសានបានចាប់ផ្តើមធ្វើដោយទ្រង់ទ្រាយតូច នៅថ្ងៃទី ៣០ ខែមីនា ។ តាមការវាយតម្លៃដោយសុទិដ្ឋិនិយមជាទីបំផុតដែលអាចធ្វើទៅបាន អំពីព្រឹត្តិការណ៍ទាំងនោះ ស និង នួន បានប្រកាសថា រហូតដល់ខែឧសភា ឆ្នាំ ១៩៦៨ កុប្បកម្មត្រូវបានធ្វើឡើងក្នុងខេត្ត ១៤ នៃប្រទេសកម្ពុជាក្នុងចំណោមខេត្តទាំងអស់ ១៩ ដែលជាការបញ្ជាក់ថាទ្រឹស្តីវៀតណាមត្រឹមត្រូវ ពោលគឺៈ មិនចាំបាច់ប្រើអាវុធដើម្បីដណ្តើមអាវុធទេ, មានលទ្ធភាពអាចចាប់ផ្តើមដោយប្រើដំបង ព្រនង់ និងកាំបិតផ្គាក់ និងវាយប្រហារដោយជោគជ័យលើប៉ូលីសនិងទាហានខ្មាំងបាន ។ ដល់ខែកក្កដា ឆ្នាំ ១៩៦៨ កាំភ្លើងប្រមាណ ៣០០ ដើម ដែលអាចបំពាក់ឱ្យកងទ័ពបដិវត្តន៍មួយនោះ ត្រូវបានអះអាងថាដណ្តើមបាន ទោះបីកាំភ្លើងជាច្រើនដើមប្រើមិនកើតក៏ដោយ ។ តាមការបកស្រាយបំផ្លើសរបស់ នួន រហូតដល់ចុងឆ្នាំ ១៩៦៨ ចលនាប្រដាប់អាវុធបានកើតមាននៅគ្រប់ទិសទី ហើយសម្តេចសីហនុស្ថិតក្នុងស្ថានភាពលំបាក ។ ការបកស្រាយប្រកបដោយសេចក្តីសង្ឃឹមដូចគ្នានេះរបស់ ស បានប្រកាសថា ទោះបីជារដ្ឋាភិបាលបានចាត់វិធានការរប៉េះរប៉ោះវាយបកវិញក្នុងឆ្នាំ ១៩៦៨-១៩៦៩ ក៏ដោយ ក៏បក្សមានលទ្ធភាពពង្រឹង និងពង្រីកកម្លាំងរបស់ខ្លួនបាននៅទូទាំងប្រទេស ដោយសង្គ្រាមប្រជាជនដែរ ។ ក្រោយមក ប្រវត្តិសាស្រ្តផ្លូវការមួយបានផ្សព្វផ្សាយនៅភូមិភាគបូព៌ា ដោយបានអះអាងភាពវិជ្ជមានដូចគ្នានេះថា "ចលនានយោបាយគាំទ្រដោយអាវុធដណ្តើមបានជ័យជំនះជាបន្តបន្ទាប់ ច្រើន និងធំ ដែលធ្វើឱ្យចក្រពត្តិភ័យស្ទន់ស្ទោ … ហើយពួកសក្តិភូមិ, គហបតី … និងឆ្កែបំរើប្រតិកិរិយារបស់ពួកវា រត់ផាស់ក្រញ៉ាំ ។*

*បន្ទាប់ពីកុប្បកម្ម ត្រូវបានធ្វើដោយឥតបង្អង់នៅទូទាំងប្រទេសមក ដោយភូមិភាគឦសានចូលរួមផងដែរនោះ នួន បាន ធ្វើដំណើរទៅរតនគីរីដើម្បីប្រជុំជាមួយ ស ។ រូបគេបានត្រឡប់មកភ្នំពេញវិញ បន្ទាប់ពីពួកគេបានឯកភាពគ្នាថាបន្តធ្វើតាមចរន្ត ដែលបានអនុម័តរួចមកហើយនោះ ។ វៀតណាមនិងចិន នៅតែជំទាស់គោលជំហររួមរបស់ពួកគេ គឺថាដោយសារសម្តេច សីហនុអនុវត្តនយោបាយមិនចូលបក្សសម្ព័ន្ធនោះ ការប៉ុនប៉ងរបស់ពួកកុម្មុយនីសកម្ពុជា ដោយរួមផ្សំការតស៊ូប្រដាប់អាវុធជា មួយការតស៊ូនយោបាយ ហាក់ដូចជាការវាយប្រហារទៅលើ"ឪពុកផ្ទាល់"របស់ពួកគេ ។ ក្នុងកិច្ចពិភាក្សាជាមួយវៀតណាម នៅប៉េកាំង នៅខែមិថុនា ឆ្នាំ១៩៦៨ ចិនបានសំដែងសេចក្តីព្រួយបារម្ភរបស់ពួកគេថាសម្តេចសីហនុមុខជានឹងឆ្លើយតបដោយ ការបង្ក្រាបនូវអ្វីដែលបន្សល់ទុកឱ្យដោយ បព១ និងកាត់ផ្តាច់ផ្លូវដឹកជញ្ជូនគស្តុភាររបស់ចិនទៅឱ្យវៀតណាម ។ ពួកគេនៅតែ រសាប់រសល់ថា វៀតណាមមិនត្រូវផ្តល់អាវុធចិនទៅឱ្យពួកកុម្មុយនីសកម្ពុជាទេ ក្រែងលោការនេះនឹងជំរុញឱ្យមានវិបត្តិជាមួយ សម្តេចសីហនុ ។ ចិនបានសុំឱ្យវៀតណាមបញ្ចុះបញ្ចូល បព១ អំពីការត្រូវការយល់ពីគ្រប់ខណ្ឌដោយសព្វមុខ ពោលគឺ: ត្រូវ ដឹងអំពីភារកិច្ចធំបំផុត ធ្វើឱ្យពួកអាមេរិកបរាជ័យនៅវៀតណាមជាបញ្ហាទី ១ ។ ចិនបានបញ្ជាក់ឡើងវិញថា ជនកម្ពុជាត្រូវធ្វើឱ្យ យល់នូវការណ៍នេះ - ដូចវៀតណាមបាននិយាយតាំងពីសង្គ្រាមឥណ្ឌូចិនលើកទី ១ ដូច្នោះដែរ - ថាការធ្វើឱ្យអាមេរិកបរាជ័យ នៅវៀតណាម នឹងបង្កើតលក្ខណៈសម្បត្តិអំណោយផលសំរាប់បដិវត្តន៍កម្ពុជា ហើយដូច្នេះពួកគេត្រូវទទួលបានការធានាថ្មីមួយ ថានៅពេលអាមេរិកត្រូវបានបណ្តេញចេញពីវៀតណាមហើយ នោះបដិវត្តន៍កម្ពុជានឹងត្រូវជួយឱ្យទទួលបានជោគជ័យដែរ ។ ចិនបានស្នើដល់វៀតណាមឱ្យអញ្ជើញសមមិត្តកម្ពុជារបស់ពួកគេ ដើម្បីពិភាក្សាថា តើត្រូវរួមគ្នាខិតខំយ៉ាងដូចម្តេចដើម្បីប្រយុទ្ធ ជាមួយអាមេរិកជាមុនសិន បន្ទាប់មកនឹងវាយប្រហារកម្លាំងប្រតិកិរិយានៅកម្ពុជាជាក្រោយ ។*

*នួន ត្រូវបានកោះអញ្ជើញដោយត្រឹមត្រូវ ដើម្បីជួបប្រជុំម្តងទៀតជាមួយ ង្វៀង វ៉ាន់លីញ ដែលបានសុំដល់រូបគេ ថាតើ ជនកម្ពុជានឹងពិចារណាអំពាវនាវឱ្យបញ្ឈប់ធ្វើសកម្មភាពហឹង្សាបានឬទេ ។ នួន បានឆ្លើយតបទៅវិញជាថ្មីម្តងទៀតថា មានតែ អនុវត្តទម្លាក់របទដ្ឋានរបស់ បព១ ទៅនឹងសភាពការណ៍កម្ពុជាដែលថា: ល្គឹកណាតែជនកម្ពុជាចាប់កាន់អាវុធប៉ុណ្ណោះទេ ទើប បក្សមានលទ្ធភាពអាចរក្សាកម្លាំងរបស់ខ្លួនបាន ។ បើបក្សកម្ពុជាត្រូវតែធ្វើការតស៊ូនយោបាយតែមួយមុខនោះ នោះខ្មាំងរបស់ បក្សប្រាកដជានឹងកំទេចមូលដ្ឋានបដិវត្តន៍ទាំងអស់របស់គេជាមិនខានឡើយ បើសិនជាពួកគេមិនធ្វើការតស៊ូដោយអាវុធទេ នោះ នោះ ឆាប់ឬយូរ បដិវត្តន៍កម្ពុជាមុខជានឹងត្រូវរលាយសាបសូន្យជាមិនខាន ។ នៅពេលសង្កត់អំពីថា តើលក្ខណៈសម្បត្តិ មានពិតប្រាកដទេសំរាប់បដិវត្តន៍នៅកម្ពុជាធ្វើការលោតផ្លោះនោះ នួន ទទួលស្គាល់ថានេះអាចនឹងមិនទាន់មកដល់ភ្លាមៗទេ តែ បានសង្កត់ថាវានឹងកើតមានឡើងនៅពេលមានរដ្ឋប្រហារប្រឆាំងសម្តេចសីហនុ បានកើតឡើងនៅទីចុងបំផុតនោះ ។ ក្នុងគ្រា ដដែលនោះ លីញ បានសុំដល់កម្ពុជាឱ្យជៀសវាងកុំវាយប្រហារផ្លូវទាក់ទងគ្នាដែលចិនប្រើដើម្បីដឹកជញ្ជូនគស្តុភារផ្តល់ដល់ វៀតណាម និងត្រូវជៀសវាងកុំធ្វើសកម្មភាពកុប្បកម្មញុះញង់នៅតំបន់ជាប់ព្រំដែនវៀតណាម ។ ការសុំដ៏ទទូចនេះ ទីចុងបំផុត ត្រូវបានទទួលយកដោយប្រត្យ័ក្ស ។*

*នួន បានឆ្លៀតឱកាសនេះ ដើម្បីសុំអាវុធពីវៀតណាមម្តងទៀត ហើយការសុំនេះត្រូវបានបដិសេធ ។ ទន្ទឹមនេះ ស ក៏ បានសុំជាថ្មី ដោយមិនបានផលដូចគ្នាដែរ នូវអាវុធពីវៀតណាម ។ ការស្នើសុំអាវុធ និងការទទួលស្គាល់របស់ នួន ថាបដិវត្តន៍ មិនអាចលោតផ្លោះទៅមុខ បានឆ្លុះបញ្ចាំងឱ្យឃើញការលំបាក និងបរាជ័យ ចំពោះកុប្បកម្ម ដែលរូបគេ និង ស ទទួលស្គាល់ ដោយមិនប្រកែក ទោះបីមានការរៀបរាប់ដោយសុទិដ្ឋិនិយមរបស់ពួកគេ និងដែលត្រូវបានបញ្ជាក់ថាពិតពីប្រភពដទៃទៀត យ៉ាងណាក៏ដោយ ។*

*យោងតាម ស ឱ្យដឹង នៅឦសាន ភ្លាមៗបន្ទាប់ពីដណ្តើមអាវុធជាលើកទីមួយបានមួយចំនួនតូចមក រដ្ឋាភិបាលបាន វាយប្រហារបកវិញ ហើយការដឹកនាំធ្វើសកម្មភាពកុប្បកម្មថែមទៀតត្រូវបានខកខានទៅវិញ ។ នៅបូព៌ា រដ្ឋាភិបាលបានធ្វើការ*

វាយប្រហារមុន នៅពេលភូមិភាគកំពុងរៀបចំធ្វើកុប្បកម្ម ។ ក្នុងរយៈពេលធ្វើយុទ្ធនាការបង្ក្រាប ៣ ខែបន្ទាប់មកទៀត ការវាយប្រហាររបស់ខ្មាំងត្រូវបាន"វាយកំទេច" និងបានធ្វើឱ្យចលនាបដិវត្តន៍នៅទីនោះបែកខ្ញែកគ្នាអស់រលីង ទោះបីជាភូមិភាគមានលទ្ធភាពដណ្តើមបានកាំភ្លើងចំនួន ៧០ ដើមក៏ដោយ ។ នៅឧត្តរ មានតែអាវុធ ៤ ដើមប៉ុណ្ណោះ ដែលរឹបអូសយកបាន ហើយបន្ទាប់មកមានការលំបាកជាច្រើនដែលត្រូវប្រឈម ។ សកម្មភាពនៅភូមិភាគឦសានរបស់ ស ផ្កាល់ ដើមឡើយដណ្តើមបានកាំភ្លើងមិនលើសពី ៥ ដើមទេ ។ ទីចុងបំផុត ទោះបីជានៅនិរតី ទោះបីជាកាំភ្លើងចំនួន ២០០ ដើមត្រូវដណ្តើមបានក៏ដោយ ក៏មានមួយចំនួនត្រូវបានដណ្តើមយកទៅវិញ ការវាយប្រហារបកវិញរបស់រដ្ឋាភិបាលបានបង្ខំពួកកុប្បករមួយចំនួនរត់ទៅភ្នំពេញ ។

របាយការណ៍ពីអតីតកាល របស់កម្មាភិបាលពាក់ព័ន្ធ បានលាបពណ៌នូវរូបភាពមួយដែលកាន់តែងងឹតអាប់អួរថែមទៀតផង ជាពិសេសនៅ ពាយ័ព្យ ឧត្តរ បូព៌ា និង ភ្នំពេញ ។ យោងតាមការរៀបរាប់ទាំងនេះ អាវុធរឹបអូសបានស្ទើរតែទាំងអស់នៅពាយ័ព្យ នៅថ្ងៃទី ១៧ ខែមករា ឆ្នាំ ១៩៦៨ ត្រូវបានដណ្តើមយកទៅវិញ ហើយការបង្កើនវិធានការសន្តិសុខធ្វើឱ្យពួកគេគ្មានលទ្ធភាពដណ្តើមបានថែមទៀតទេ ។ ការវាយប្រហារបករបស់រដ្ឋាភិបាល បានរឹបអូសយកស្រូវលាក់ទុករបស់បក្ស និងទុកឱ្យពួកគេស្ថិតនៅដោយគ្មានអាហារ គ្រាប់រំសេវ ឬលទ្ធភាពក្តាប់ប្រជាជនណាម្នាក់បានឡើយ ។ ប្រជាជនរាប់ពាន់នាក់ដឹកនាំដោយភ្នាក់ងាររបស់បក្សទៅចូលព្រៃ បានជួបប្រទះនឹងការអត់បាយ ដោយមួយចំនួនបានស្លាប់ ពួកនៅសេសសល់បានបោះបង់ចោលបដិវត្តន៍ ឬរហូតដល់ធ្វើជាអ្នកនាំផ្លូវឱ្យប្រតិបត្តិការរបស់ពួក លន់ ណុល ថែមទៀតផង ។ អង្គការ បព២ បានជួបប្រទះនឹងការខូចខាតយ៉ាងធ្ងន់ធ្ងរ ហើយហាក់ដូចជាខូចខាតរហូតដល់មិនអាចស្តារឡើងវិញបានថែមទៀតផង ។ ដល់ឆ្នាំ ១៩៦៩ គណៈកម្មាធិការភូមិភាគពាយ័ព្យ បានធ្លាក់ចុះរហូតដល់ទម្លាក់កំហុសដាក់គ្នាទៅវិញទៅមក អំពីតើត្រូវធ្វើអ្វី និងតើអ្នកណាបានធ្វើខុស ។ ទោះបីជា លន់ ណុល បានកត់សំគាល់ឃើញអំពីការបន្តធ្វើការរំខាន ការពួនស្ទាក់វាយ គេរវកម្ម និងការឆក់ប្លន់ ឡើងវិញរបស់ពួកកុម្មុយនីស នៅផ្នែកខ្លះនៃពាយ័ព្យ នាចមាសទី ២ នៃឆ្នាំ ១៩៦៩ ក៏ដោយ ក៏រូបគេបានប៉ាន់ប្រមាណថាកម្លាំងជាសក្តានុពលរបស់ពួកកុម្មុយនីស នៅទីនោះ មានត្រឹមតែ ១៥០ នាក់ប៉ុណ្ណោះ ។

យោងតាម កុយ ធួន (ហៅ ធុច) លេខាបក្សភូមិភាគឧត្តរ របស់ បព២ ថាការតស៊ូប្រដាប់អាវុធនៅទីនោះបានទ្រេតទ្រោតតាំងពីថ្ងៃទី ១ ម៉េះ ។ កម្លាំង លន់ ណុល បានបញ្ជូនភ្នាក់ងារស៊ើបការណ៍ទៅ មុនពេលដែលការប៉ុនប៉ងដណ្តើមអាវុធនឹងត្រូវធ្វើឡើងហើយពួកទាហានបាននិយាយកុហក់ឱ្យរង់ចាំចាប់មនុស្ស ៤០ នាក់ ក្នុងចំណោមមនុស្ស ២០០ នាក់ ដែលត្រូវបានចលនាសំរាប់ធ្វើកុប្បកម្ម ។ ភ្លាមៗនោះ ពួកអ្នកក្លាហានជាងគេនៃពួកអ្នកដែលបានសាកល្បងជាមួយកាំភ្លើង ២ ដើម - ដែលសឹងតែគ្មានគ្រាប់សោះនោះ - ដើម្បីធ្វើសង្គ្រាមប្រជាជនត្រូវបានសម្លាប់ ។ មូលដ្ឋានជនបទដែលទើបចាប់កំណើតនៃភូមិភាគត្រូវបានឡោមព័ទ្ធ ហើយប្រជាជនរស់នៅក្នុងមូលដ្ឋានទាំងនោះបានវិលត្រឡប់មកប្រឆាំងបដិវត្តន៍វិញ ។ ដូច្នេះ "ផែនការរបស់បក្សធ្វើការវាយប្រហារដោយចលនាតស៊ូ ដោយរួមផ្សំអាវុធជាមួយនយោបាយនោះ...ត្រូវបរាជ័យទាំងស្រុង" ដោយទុកឱ្យ "កម្លាំងបដិវត្តន៍ស្ថិតក្នុងសភាពរយីករយាក"។ អនុលេខាភូមិភាគឧត្តរ កែ ពក បានផ្តល់នូវការរៀបរាប់ដូចគ្នានេះមួយថា: ក្នុងខែមេសា ឆ្នាំ ១៩៦៨ "អង្គរគ្មាន ខ្មាំងវ៉ៃ ។ យើងត្រូវបែកបាក់គ្នាអស់"។ កម្មាភិបាលបក្សភាគច្រើនបានចុះចូល ឬត្រូវចាប់ខ្លួននិងជាប់គុក អ្នកផ្សេងទៀតត្រូវសម្លាប់ ។ ក្នុងចំណោមពួកអ្នកស្លាប់ ឬជាប់គុក មានពីរនាក់ជាសមាជិកគណៈកម្មាធិការភូមិភាគ ។ នៅខែមិថុនា-កក្កដា ការបង្ក្រាបរបស់ លន់ ណុល បានកើនឡើង ហើយការរៀបចំកុប្បកម្មមិនបានសំរេច កម្លាំងបដិវត្តន៍ដែលនៅសកម្មនៅឡើយមានមិនលើសពី ២០ នាក់ទេ ។ លន់ ណុល បានកំណត់ភូមិភាគឧត្តរ ថាជាភូមិភាគមួយដែលគ្មានសកម្មភាពប្រដាប់អាវុធ ឬសកម្មភាពជាសក្តានុពល របស់កុម្មុយនីសទេ ។

ការប៉ុនប៉ងខាងបូព៌ាដើម្បីដណ្តើមអាវុធ ត្រូវបានរលូតទៅវិញ ពីព្រោះភូមិភាគបានពន្យារពេលអនុវត្តន៍សេចក្តីសំរេចឱ្យធ្វើដូច្នេះ បន្ទាប់ពីពួកវៀតណាមបានប្រាប់ថា "កុំធ្វើអ្វីឱ្យសោះ យើងមានអាវុធច្រើនណាស់ យើងអាចឱ្យអ្នកបាន" មក ។

បន្ទាប់ពីកុប្បកម្មនៅពាយ័ព្យ រដ្ឋាភិបាលបានការពារអាវុធពួកគេនៅបូព៌ាមិនឱ្យដណ្តើមយកបាន ។ នេះបានធ្វើឱ្យកូមិភាគមានលទ្ធភាពតិចណាស់ដើម្បីដណ្តើមអាវុធ ហើយបន្ទាប់មក វៀតណាមបានបំភ្លេច ដោយធ្វើជាមិនដឹងមិនឮចំពោះការសន្យារបស់ពួកគេ នៅពេលកូមិភាគសុំកាំភ្លើងមែនទែននោះ ។ ជាពិសេស ពួកគេបានធ្វើជាបង្វែងដានការស្នើសុំកាំភ្លើងរបស់ ភឹម ដែល ភឹម សង្ឃឹមថានឹងយកមកបំពាក់ឱ្យមនុស្ស ១២០ នាក់ ដែលរូបគេមាន ដើម្បីធ្វើសកម្មភាពឈ្លបនៅក្នុងខេត្តកំពង់ចាម និងព្រៃវែង ។ តាមការរាយការណ៍ វៀតណាមបាននិយាយថា "អ្នកមិនត្រូវធ្វើការតស៊ូ ឬស្នើសុំអាវុធទេ, ត្រូវរង់ចាំរហូតដល់យើងរំដោះវៀតណាម, បន្ទាប់មកយើងនឹងប្រយុទ្ធ" ។ ដោយមិនសប្បាយចិត្ត ភឹម ពុំមានជំរើសអ្វីក្រៅពីទៅរកកាំភ្លើងដោយខ្លួនឯងទេ ។ ការប៉ុនប៉ងរបស់គេក្នុងការធ្វើយ៉ាងដូច្នេះ បានកើតឡើងដោយការភ្ញាក់ផ្អើល ចំពោះការដែលរដ្ឋាភិបាលបានវាយប្រហារលើភូមិមួយ ដែលរូបគេធ្លាប់បានយកធ្វើមូលដ្ឋានរបស់គេ នាពេលមួយនោះមក ដែលក្នុងពេលនោះអ្នកភូមិជាច្រើនត្រូវបានសម្លាប់ ឬចាប់ខ្លួន ។ បន្ទាប់ពីនោះមក កម្មាភិបាលខ្លះបានទទួលលិខិតណែនាំឱ្យពួកគេរត់ចូលព្រៃ ដោយសភាពការណ៍បានទុំហើយសំរាប់ប្រើហឹង្សាបដិវត្តន៍ ។ នៅខែមីនា ពួកគេបានសាកល្បងដោយមិនបានសំរេច វាយដណ្តើមអាវុធពីប៉ុស្តិ៍ជួរមុខរបស់រដ្ឋាភិបាល បង្កឱ្យរដ្ឋាភិបាលធ្វើបាបក្រុមគ្រួសារពួកគេ ។ បន្ទាប់ពីនោះមក នៅពេលរដ្ឋាភិបាលកំពុងធ្វើការបង្ក្រាបកាន់តែខ្លាំងឡើង កម្មាភិបាលភូមិភាគបូព៌ាជាច្រើននាក់បានរត់ឆ្លងព្រំដែនចូលទៅវៀតណាម រីឯកម្មាភិបាល និងអ្នកភូមិដទៃទៀត បាននាំគ្នារត់ចូលព្រៃដែលពួកគេនៅរង់ចាំទីនោះ ក្នុងសេចក្តីសង្ឃឹមថាអាវុធនឹងមកដល់ក្នុងថ្ងៃណាមួយជាមិនខាន ទើបដឹងខ្លួនថាពួកគេកំពុងស្ថិតនៅពីក្រោយការវាយប្រហាររបស់ខ្មាំង ។ អង្គភាពដទៃទៀត បានសាត់ត្រាត់សែងត្រែងគ្មានទិសដៅនៅក្នុងព្រៃ នៅពេលរដ្ឋាភិបាលកំពុងសម្លាប់រង្គាលអ្នកភូមិកាន់តែច្រើនថែមទៀតនោះ ។

មានក្រុមមួយនោះបានរៃដោយជោគជ័យក្នុងខែមេសា តែបានរត់ទៅវៀតណាមនៅពេលក្រោយមក ។ នៅទីនោះ ភឹម បានសរសើរដល់ក្រុមនោះ តែអនុលេខាភូមិភាគរបស់គេបានផ្តល់យោបល់ថា ឱ្យសាកល្បងសុំគ្រាប់រំសេវ និងអាវុធថែមទៀតពីវៀតណាម។ នួន បានស្នើទៅ ភឹម ថាបើវៀតណាមមិនបានត្រៀមដើម្បីឱ្យអាវុធដល់ពួកគេទេ ភឹម ត្រូវលួចយកពីកន្លែងលាក់អាវុធរបស់វៀតណាមនៅក្នុងទឹកដីកម្ពុជាទៅ និងយកស្បៀងទៅដូរយកអាវុធពីពួកទាហានវៀតណាមផងដែរ ។

ទោះបីជាភូមិភាគបូព៌ាមានលទ្ធភាពធ្វើសង្គ្រាមប្រជាជនជាថ្មីឡើងវិញ ក្នុងខែសីហា ឆ្នាំ ១៩៦៨ ដោយវាយសំរុកទៅលើប៉ុស្តិ៍ពួកសេនាជនក៏ដោយ ក៏ផែនការសំរាប់ការវាយប្រហារថែមទៀតមិនត្រូវបានអនុវត្តទេ កម្មាភិបាលជាច្រើននាក់នៅតែស្ថិតនៅវៀតណាមដដែល ។ ការប៉ុនប៉ងធ្វើកុប្បកម្មមួយទៀត បានបញ្ចប់ដោយបរាជ័យខាងយោធា ។ ទន្ទឹមនេះ អនុរបស់ ភឹម ត្រូវបានសម្លាប់ នៅពេលរូបគេកំពុងសាកល្បងរៀបចំចាត់តាំងសកម្មភាពយោធានៅចុងឆ្នាំ ១៩៦៨ ។ ភឹម ខ្លួនឯងបានចំណាយពេលយ៉ាងច្រើនរស់នៅ តាយនីញ ក្នុងឆ្នាំ ១៩៦៨-១៩៦៩ ដែលជាកន្លែងសំរាប់ប្រើដើម្បីប្រជុំ និងរៀនសូត្រ ។

ក្នុងឆ្នាំ ១៩៦៩ ពួកកុម្មុយនីសបានធ្វើការវាយប្រហារនៅម្តុំជិតៗអតីតមូលដ្ឋាន បព២ ក្នុងខេត្តកំពង់ចាម និងខេត្តព្រៃវែងដែលនៅជាប់គ្នានោះ តែរដ្ឋាភិបាលបានឆ្លើយតបវិញ ដោយប្រតិបត្តិការថ្មីៗប្រឆាំងទៅលើកន្លែងដែលពួកបូព៌ាប្រើធ្វើជាកន្លែងសំរាប់ហ្វឹកហ្វឺនយោធា ។ ក្រុមមួយទៀតនៃកងឈ្លបរបស់ភូមិភាគបូព៌ា ត្រូវបានបង្ខំឱ្យភៀសខ្លួនទៅជ្រកក្នុងមូលដ្ឋានរបស់ ភឹម នៅវៀតណាម បន្ទាប់ពីពួកគេត្រូវដាច់ស្បៀងនិងគ្រាប់រំសេវ ។ ទោះបីជានៅចុងឆ្នាំនោះ ការហូរចូលនៃជនភៀសខ្លួនចេញពីបូព៌ាទៅអាចផ្តល់ដល់ភូមិភាគ នូវកម្លាំងជាទ្រឹស្តីជាកងឈ្លបចំនួន ៥០០ នាក់ក៏ដោយ ក៏តាមសេចក្តីរាយការណ៍ថា ពួកគេទាំងអស់គ្នាបានបោះមូលដ្ឋាននៅក្នុងទឹកដីវៀតណាម ដោយគ្រាន់តែធ្វើសកម្មភាពឆក់ប្លន់ក្នុងតំបន់ជាប់នឹងកម្ពុជាខ្លះៗប៉ុណ្ណោះ ។ ពួកគេនៅតែទទួលជំនួយយោធាពីវៀតណាមដដែល ទោះបីជាប្រតិបត្តិការរបស់អាមេរិកដើម្បីកាត់ផ្តាច់កស្តុការរបស់ពួកកុម្មុយនីសវៀតណាមនៅភាគខាងត្បូង ដោយបង្ខំឱ្យពួកគេពឹងផ្អែកលើអាវុធ និងគ្រាប់រំសេវនៅតាមបណ្តោយព្រំដែន

ក៏ដោយ ។ វៀតណាមមានអាវុធសំរាប់ប្រើជាក្រុម និងអាវុធដៃចំនួនជាង ២៥ ០០០ ដើម និងគ្រាប់រំសេវចំនួនជាង ១៦ ០០០ ០០០ គ្រាប់លាក់ទុកក្នុងទឹកដីកម្ពុជា ។

គឹម បានរៀបចំសាលាសំរាប់ហ្វឹកហ្វឺនយោធា ដើម្បីកសាងកងឈ្លបភូមិភាគមួយ ហើយនៅចុងឆ្នាំ ១៩៦៩ បានជំរុញផែនការវាយប្រហារក្នុងពេលតែមួយទៅលើទីតាំងផ្សេងគ្នាចំនួន ៣ នៅបូព៌ា ។ ក៏ប៉ុន្តែ ពុំមានរឹបអូសយកអាវុធបានទេ បើទោះបីជាការវាយប្រហារមួយនោះបានធ្វើឱ្យខូចខាតខ្លះដល់ប៉ុស្តិ៍យោធាជួរមុខមួយរបស់ លន់ ណុល ក៏ដោយ ។ ពេលនោះ មានសេចក្តីណែនាំឱ្យសម្លាប់ពួកអ្នកដែលត្រូវចោទថា ជាអ្នកផ្តល់ព័ត៌មានរបស់រដ្ឋាភិបាល ការសម្លាប់បែបនេះត្រូវបានអនុវត្តដោយក្រុមបែកខ្ញែកពីគ្នានៃកងឈ្លប ដែលធ្វើការឃោសនាប្រឆាំងរដ្ឋាភិបាលក្នុងពេលជាមួយគ្នា ។ កងឈ្លបនៃភូមិភាគបូព៌ាក៏បានតម្រង់ទិសទៅរកពួកមេឃុំ និងមន្ត្រីមូលដ្ឋានដទៃទៀតផងដែរ ។ នៅចុងឆ្នាំ ក្រុមតូចៗប្រមូលផ្តុំគ្នាជាអង្គភាពមានមនុស្ស ពី ៥០ ទៅ ៩០ នាក់ បានធ្វើប្រតិបត្តិការចេញពីមូលដ្ឋាន ៤ នៅតាយនីញ ដោយបានសាកល្បងចូលជ្រៅទៅក្នុងភូមិភាគបូព៌ាដើម្បីធ្វើការឃោសនាដល់អ្នកភូមិ ដោយអំពាវនាវឱ្យពួកគេផ្តួលរំលំរបបសង្គមដ៏អយុត្តិធម៌ និងជិះជាន់ ។ តែការខិតខំនេះ ត្រូវបានកំហិតឱ្យធ្វើត្រឹមតែនៅក្នុងតំបន់ក្បែរៗព្រំដែនតែប៉ុណ្ណោះ ។

ដូច្នេះ ការប៉ុនប៉ងបន្ថែមការតស៊ូនយោបាយដោយការតស៊ូប្រដាប់អាវុធនៅបូព៌ា នៅតែមិនទាន់ធ្វើកើតនៅឡើយទេ ។ ក៏ប៉ុន្តែ គឹម និងសមាជិកគណៈកម្មាធិការភូមិភាគបូព៌ាដទៃទៀត បានបន្តកោះប្រជុំរៀនសូត្រ ដោយពួកគេបានបញ្ជាក់ប្រាប់ពួកអ្នកស្ថិតក្រោមការគ្រប់គ្រងរបស់ពួកគេថាក្រុម លន់ ណុល កាន់តែជិតដល់ពេលធ្វើរដ្ឋប្រហារហើយ ។ អាស្រ័យហេតុនេះ ភូមិភាគនៅតែត្រូវសាកល្បងក្តាប់កម្លាំងប្រជាជនឱ្យបាន កសាងកងទ័ព និងកសាងមូលដ្ឋាន ដើម្បីត្រៀមខ្លួនជាស្រេច ចំពោះមុខព្រឹត្តិការណ៍ដែលជៀសមិនផុតនេះ ។

នៅនិរតីក៏ដូចនៅបូព៌ាដែរ កុប្បកម្មបានមកជំនួសសេចក្តីសង្ឃឹមនាពេលមុន ដែលការទាក់ទងជាមួយសមាជិករដ្ឋសភាអាចជួយការពារសកម្មជនបង្កប់ និងកសិករមានសមានចិត្តនោះ ។ ដូចនៅបូព៌ាដែរ ពួកគេបានធ្វើតាមការប៉ុនប៉ងមិនបានសំរេចក្នុងការបញ្ចុះបញ្ចូលវៀតណាម ឱ្យផ្តល់អាវុធសំរាប់ពួកគេបំពាក់ឱ្យកម្លាំងស្វ័យការពាររបស់ភូមិភាគ ។ ម្យ៉ាងទៀត កុបកម្មបានបង់តម្លៃដោយការបាត់បង់ជីវិតលេខាភូមិភាគ ម៉ា ម៉ង់ ហៅ ប៉ង់ ដែលបានធ្លាក់ខ្លួនគ្រុនយ៉ាងខ្លាំងក្រោយពីរូបគេបានរត់ចូលព្រៃជាមួយអាវុធដែលរឹបយកបាននោះ ។ រូបគេត្រូវបានជំនួសដោយ តាម៉ុក ដែលការចាត់តាំងនេះត្រូវបានធ្វើដោយ នួន ។ ដើមឡើយ កម្លាំងក្នុងតំបន់មូលដ្ឋានមានលទ្ធភាពអាចប្រើកាំភ្លើងរបស់ពួកគេ ដើម្បីការពារខ្លួនប្រកបដោយជោគជ័យបាន តែការនេះគ្រាន់តែបានអនុញ្ញាតឱ្យពួកគេទប់ខ្លួនបានចំពោះមុខសភាពការណ៍ប៉ុណ្ណោះ មិនអាចពង្រីកខ្លួនបានទេ ។ ពេញមួយឆ្នាំ ១៩៦៨ ជីវភាពនៅក្នុងមូលដ្ឋានភូមិភាគនិរតីសំខាន់ជាងគេនៅភ្នំឱរ៉ាល់ ក្នុងជួរភ្នំខាងជើងខេត្តកំពង់ស្ពឺ មានការ លំបាកវេទនាយ៉ាងខ្លាំង: ស្បៀងអាហារខ្វះខាតជាអតិបរមា ហើយអ្នករស់នៅទីនោះជាច្រើននាក់បានធ្លាក់ខ្លួនឈឺ និងស្លាប់ជាបន្តបន្ទាប់ ។ កងឈ្លបមានតែកាំភ្លើងខ្លី និងកាំភ្លើងវែងកញ្ចាស់ៗ ដែលរឹបអូសបានពីខ្មាំងមួយចំនួនតូចប៉ុណ្ណោះ ។ ក៏ប៉ុន្តែ ពួកគេហាក់ដូចជាទទួលបានការគាំទ្រពីប្រជាជនមួយចំនួន ខិតខំជណ្តើមអាវុធថែមទៀតពីកងកម្លាំងរដ្ឋាភិបាល ក្នុងចំណោមពួកគេ ពួកបង្កប់ខ្លួនបានឈរជើងដោយជោគជ័យ ។ ក្នុងឆ្នាំ ១៩៦៩ ក្រុមឈ្លបតូចៗ ត្រូវបានបញ្ចូលទៅក្នុងតំបន់វាលរាបនៃខេត្តកំពង់ឆ្នាំង និងកំពង់ស្ពឺ ដើម្បីដឹកនាំធ្វើការងារឃោសនា ហើយពួកគេបានខិតខំធ្វើការវាយប្រហារទៅលើប៉ុស្តិ៍ជួរមុខរដ្ឋាភិបាល។ អ្នកភូមិកាន់តែច្រើនបានស្ម័គ្រចិត្តចូលធ្វើកងឈ្លបច្រើនជាងអាវុធដែលពួកគេមាន ដើម្បីបំពាក់ឱ្យពួកគេហើយមានតែពួកអ្នកដែលត្រូវបានកំណត់ថាមានហានិភ័យថាអាចត្រូវសម្លាប់ដោយអាជ្ញាធរមូលដ្ឋានប៉ុណ្ណោះ ដែលត្រូវបានចាត់តាំងឱ្យចូលអង្គភាពកុបកម្ម ។ ប្រហែលជានៅចុងឆ្នាំ ១៩៦៩ មានកងឈ្លបចំនួន ១០០០ នាក់ដែលសកម្មនៅក្នុងខេត្តពីរនៃភូមិភាគនិរតី គឺខេត្តកំពង់ឆ្នាំង និងកំពង់ស្ពឺ ដែលជាចំនួនកើនឡើងពី ១០០ នាក់ក្នុងឆ្នាំ ១៩៦៨ ។ ទោះបីជា លន់ ណុល បានប៉ាន់ប្រមាណថាកម្លាំងកុម្មុយនីសជា

សក្តានុពលក្នុងភូមិភាគទាំងមូលថាតិចជាងនេះ ពោលគឺ ៧៥៥ នាក់ ក៏ភ្នាក់ងារសម្ងាត់របស់គេបានយល់ស្របថាកម្លាំងរបស់ពួកគេបានប្រតិបត្តិការក្នុងតំបន់ដ៏ទូលំទូលាយនៃខេត្តចំនួន ៥ ដោយបានបង្កើតជំរុំតូចៗ និងកន្លែងសំរាប់លាក់អាវុធជាច្រើន ហើយអាចមានសមត្ថភាពចាប់ផ្តើមតភ្ជាប់តំបន់ប្រតិបត្តិការរបស់ពួកគេទៅនឹងពួកពាយ័ព្យបាន ។ ដោយសារជោគជ័យនៃនិរតីក្នុងការដណ្តើមអាវុធនេះហើយ ដែលក្នុងពេលជាមួយគ្នានោះ តាម៉ុក មានលទ្ធភាពជួយដល់ភូមិភាគដទៃទៀត ដោយការផ្តល់អាវុធឱ្យពួកគេ ។ ក៏ប៉ុន្តែនៅចុងឆ្នាំ ១៩៦៩ មូលដ្ឋាននានានៃភូមិភាគនិរតី ទាំងនៅក្នុងខេត្តកំពត និងខេត្តកំពង់ស្ពឺ ក្នុងនេះរួមមានជំរុំជាគន្លឹះនៅភ្នំឱរ៉ាល់ផង - ដែលរកឃើញដោយ លន់ ណុល ថាជាកន្លែងប្រជុំសំខាន់បំផុតមួយសំរាប់កម្មាភិបាលជាន់ខ្ពស់ - ត្រូវបានវាយប្រហារ ។ កងឈ្លបត្រូវដកពីភូមិនានានៃតំបន់វាលរាបឱ្យទៅការពារមូលដ្ឋានវិញ ។ ពួកអ្នកភូមិត្រូវបានដាក់ឱ្យប្រឈមមុខនឹងការរំខានរបស់រដ្ឋាភិបាល ដែលបានរត់ចូលព្រៃ ប្រឈមមុខនឹងការអត់ឃ្លាន ។ស្បៀងកាន់តែខ្វះទៅៗ នៅឱរ៉ាល់ ហើយជម្ងឺគ្រុនចាញ់កាន់តែរាតត្បាតខ្លាំងឡើងៗ ។ ស, នួន និង ម៉ុក ត្រូវបានកម្មាភិបាលភូមិភាគថ្នាក់ខ្ពស់ទិតៀនថាបានបង្កើតឱ្យមានសភាពការណ៍ដ៏មហន្តរាយនេះ ទោះបីជាមូលដ្ឋាននៅផ្នែកផ្សេងទៀតនៅនិរតីនៅតែមានសុវត្ថិភាពក៏ដោយ ។

សភាពការណ៍នៃបដិវត្តន៍នៅក្នុងភ្នំពេញ ក៏បានក្លាយជាការអស់សង្ឃឹមដែរ ។ ក្នុងឆមាសទី ១ ឆ្នាំ ១៩៦៨ ការទាក់ទងរបស់អង្គការបក្សទីក្រុងជាមួយមូលដ្ឋានជនបទត្រូវបានកាត់ផ្តាច់ ហើយនៅខែកក្កដា-សីហា រលកនៃការចាប់ខ្លួនដ៏ធំមួយ ចាប់បានសកម្មជនបង្កប់ចំនួន ២០ នាក់ បន្ទាប់មកពួកគេជាច្រើននាក់ត្រូវបានសម្លាប់ ក្នុងនោះរួមមានអនុលេខាបក្សភ្នំពេញផង ។ មេដឹកនាំអង្គការបក្សទីក្រុងតាំងពីឆ្នាំ ១៩៦៣ មក និងជាសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ វន វេត បានខិតខំគេចខ្លួនស្ទើរតែមិនរួច ក្នុងពេលមានការបាញ់ដោយកាំភ្លើង រវាងប៉ូលីសសម្ងាត់និងកងការពាររបស់គាត់ ដែលត្រូវបានសម្លាប់ ។ សមាជិកបក្សដែលនៅសេសសល់ក្នុងទីក្រុង បានស្ថិតក្រោមការគៀបសង្កត់ រហូតដល់មិនអាចបន្តធ្វើសកម្មភាពអ្វីបានទាំងអស់ ។ នៅខែកញ្ញា ឆ្នាំ ១៩៦៨ នួន បានឯកភាពឱ្យបញ្ជូនពួកគេទៅនិរតី ។ វន ខ្លួនឯងបានទៅភ្នំឱរ៉ាល់នៅក្នុងខែ វិច្ឆិកា ឆ្នាំ ១៩៦៨ រួចត្រឡប់មកភ្នំពេញវិញមួយរយៈពេលខ្លីក្នុងខែមីនា ឆ្នាំ ១៩៦៩ មុនត្រឡប់ទៅនិរតីវិញ ។ នួន ក៏បានចុះឡើងរវាងភ្នំពេញ និងភ្នំឱរ៉ាល់ដែរ ។ នៅក្នុងរាជធានី រូបគេនៅតែមានលទ្ធភាពអាចធ្វើសកម្មភាពបានក្នុងកំរិតណាមួយដែរ ក្នុងនាម"បក្ស", ដោយផ្តល់ការណែនាំអំពីថាតើត្រូវសាកល្បង និងធ្វើការផ្គូផ្គងសភាពការណ៍នៅកន្លែងដែលការតស៊ូប្រដាប់អាវុធបរាជ័យ ដូចនៅពាយ័ព្យជាដើម យ៉ាងដូចម្តេច ។ ក្នុងការប្រជុំជាមួយកម្មាភិបាលជាន់ខ្ពស់មកពីពាយ័ព្យ នៅភ្នំឱរ៉ាល់ ក្នុងខែកុម្ភៈ ឬមីនា ឆ្នាំ ១៩៦៩ នួន បានព្រមានជាថ្មីម្តងទៀតថា លន់ ណុល នឹងធ្វើរដ្ឋប្រហារក្នុងពេលឆាប់ៗនេះហើយ ។ ដើម្បីរក្សាគំនិតផ្តើមបាន និងមានលទ្ធភាពចលនាប្រជាជននៅវាលរាបកើតឡើងបាននោះ នួន បានណែនាំពួកគេឱ្យធ្វើឃាត"ពួកប្រតិកិរិយា"នៅក្នុងភូមិ និងឃុំនៃភូមិភាគពាយ័ព្យ និងកសាងកងទ័ពមួយឱ្យបាន ។ បើទោះបីជានៅក្នុងខែមេសា-ឧសភា ឆ្នាំ ១៩៦៩ មានការងើបឡើងនៃសកម្មភាពកុប្បកម្មនៅក្នុងខេត្តមួយចំនួន ក្នុងរយៈ ៦ ខែដំបូងនៃឆ្នាំ ១៩៦៩ ក៏ដោយ ក៏ពួកអ្នកជាប់ចោទថាជាកុម្មុយនីស ឬថាមានសមានចិត្តជាមួយកុម្មុយនីស ចំនួនជិត ៣០០ នាក់ ត្រូវបានសម្លាប់, ធ្វើឱ្យរបួស, ចាប់ខ្លួន ឬបង្ខំឱ្យចុះចូល ដោយកម្លាំងសន្តិសុខរបស់រដ្ឋាភិបាល ។

ប៉ុន្តែ នៅពាយ័ព្យ ស បានប្រកាសថាកម្លាំងរបស់គេនៅភូមិភាគនេះ បានកើនឡើងពីអង្គភាពមួយមានមនុស្ស ៧០ នាក់ កាំភ្លើង ១០ ដើម ក្នុងឆ្នាំ ១៩៦៨ ទៅជាកងអនុសេនាធំមានគ្នា ១៥០ នាក់ មានកាំភ្លើង ៤៥-៦០ ដើម ក្នុងឆ្នាំ ១៩៧០ ។ ការនេះបានធ្វើឱ្យពាយ័ព្យ ព្រមជាមួយនិរតី ជាភូមិភាគមួយនៃភូមិភាគពីរនេះ "ដែលមានសកម្មភាពបក្ស និងយោធាខ្លាំងជាងគេ" ។ បន្ទាប់ពីការចាប់ផ្តើមក្លែងក្លាយ និងបរាជ័យមួយចំនួនបណ្តាលមកពីប្រតិបត្តិការបន្ទឹមបន្ទំរបស់ លន់ ណុល មក នៅឆ្នាំ ១៩៦៨ កម្លាំងកងឈ្លបនៅ រតនគីរី មានលទ្ធភាពដឹកនាំធ្វើសង្គ្រាមចល័ត និងទប់ទល់ការលុកលុយរបស់ខ្មាំងបាន ។ ដល់ឆ្នាំ១៩៦៩ ពួកនៅក្នុងខេត្តមណ្ឌលគីរី បាន"ដឹកនាំធ្វើសង្គ្រាមឈ្លបយ៉ាងខ្លាំងមិនធ្លាប់មានពីមុនមក រហូតដល់ចំណុចមួយ ដែល

ពួកគេអង់អាចក្លាហានហ៊ានវាយបន្ទាយយោធា ឬប៉ុស្តិ៍ប៉ូលីស ដោយបានកំទេចទាំងស្រុងបាននៅកន្លែងខ្លះថែមទៀតផង ... ដោយឃើញសភាពនេះ ស្មារតីប្រជាជនបានឡើងខ្ពស់ ធ្វើឱ្យពួកគេកាន់តែមានជំនឿលើបដិវត្តន៍" ។ នៅចន្លោះខែមេសា ដល់ខែវិច្ឆិកា ឆ្នាំ ១៩៦៩ លន់ ណុល បានចេញបញ្ជាឱ្យធ្វើប្រតិបត្តិការធំនៅខេត្តរតនគីរី ក្នុងទិសដៅស្វែងរកទីតាំងវៀតណាមនៅទីនោះ ។ ពេលខ្លះ ពួកគេបានបង្ខំឱ្យមូលដ្ឋានពួកកុម្មុយនីសកម្ពុជាជម្លៀសចេញជាបណ្តោះអាសន្នទៅក្បែរទីនោះ តែមិនបានដណ្តើមបានឬកាន់កាប់ទីតាំង ឬធ្វើឱ្យមានការខូចខាតដ៏គួរឱ្យកត់សំគាល់ណាមួយទេ ។ គណៈកម្មាធិការភូមិភាគឦសានគិតថានឹងមានការវាយប្រហាររបស់ពួក លន់ ណុល ច្រើនថែមទៀត ពួកគេបានធ្វើផែនការលំអិតដើម្បីរុញច្រានទៅវិញ ដោយពឹងផ្អែកជាសំខាន់ទៅលើអាវុធបុរាណ ធ្វើជាប្រភពសំខាន់តែមួយគត់របស់ពួកគេ ដើម្បីវាយដណ្តើមយកអាវុធសម័យពីកងទ័ពខ្មាំងប៉ុណ្ណោះ ។

ពួកកុម្មុយនីសទទួលបានជោគជ័យដោយប្រៀបធៀបនៅឦសាន ទោះបីជាការវាយប្រហាររបស់រដ្ឋាភិបាលមានភាពតឹងតែងជាងកន្លែងដទៃទៀតក្នុងប្រទេសក៏ដោយ ក៏មួយផ្នែកដោយសារមានចំណុចខ្សោយខាងនយោបាយផងដែរ ។ ប្រតិបត្តិការយោធា បាននាំទៅឱ្យមានការបំផ្លាញយ៉ាងទទឹងទទែង និងបង្ហូរឈាម នៅក្នុងភូមិជនជាតិភាគតិច ដែលបានបង្ខំឱ្យអ្នកភូមិជាច្រើនរត់ចូលព្រៃ ដែលនៅទីនោះពួកកុម្មុយនីសមានលទ្ធភាពអាចចាត់តាំងពួកគេឱ្យធ្វើសកម្មភាពប្រដាប់អាវុធ និងធ្វើការជំទាស់ខាងនយោបាយប្រឆាំងប្រព្រឹត្តកម្មយង់ឃ្នងរបស់រដ្ឋាភិបាល។ ជនជាតិភាគតិចដទៃទៀត ត្រូវបានបង្កឱ្យចូលបដិវត្តន៍ដោយនយោបាយរបស់សង្គមជំរុញឱ្យធ្វើខេមរយានកម្មឱ្យលឿន ដែលទាក់ទងទៅនឹងការពង្រីកកម្មវិធីគាំទ្រដោយយោធាដើម្បីការតាំងលំនៅដ្ឋានរបស់អតីតទាហានក្នុងតំបន់នេះ។

ក៏ប៉ុន្តែ ជោគជ័យកុម្មុយនីសនៅឦសាន ក៏ត្រូវបានសំរេចឡើងដោយយុទ្ធវិធីវាយបកប្រឆាំងភេរវកម្ម ក្នុងនេះរួមមានការសម្លាប់ដែលធ្លាប់តែធ្វើទៅលើមេភូមិនិងមេឃុំផងដែរ ។ ការសម្លាប់ទាំងនេះបានរំលឹកឡើងវិញនូវកម្មវិធី បកត ស្តីពីការសម្លាប់ពួកក្បត់ដែលបានអនុវត្តនៅកម្ពុជាក្នុងពេលសង្គ្រាមឥណ្ឌូចិនលើកទី ១ ដោយធ្វើតាមអ្វីដែលបានប្រើដោយ បពវ ដើម្បីចាប់ផ្តើមធ្វើការតស៊ូប្រដាប់អាវុធឡើងវិញនៅភាគខាងត្បូងវៀតណាមនៅឆ្នាំ ១៩៥៩-១៩៦០ ដែលដូចគ្នានឹងអ្វីដែលបានធ្វើកាលពីពេលថ្មីៗនេះដោយ បពវ នៅក្នុងតំបន់ជាប់គ្នានឹងខ្ពង់រាប តាយង្វៀង និងដូចគ្នាទៅនឹងអ្វីដែល គឹម បានប្រើនៅបូព៌ា ហើយ នួន បានណែនាំទៅខាងឦសាន ។

ក្នុងការរៀបរាប់របស់ពួកគេអំពីព្រឹត្តិការណ៍នៅឦសាន ស និង អៀង សារី មិនបានលើកឡើងអំពីភេរវកម្មប្រភេទ បពវ ទេ តែពួកគេបានរំជួលចិត្តអំពីសក្តានុពលបដិវត្តន៍របស់ជនជាតិភាគតិចនៅទីនោះ ក្នុងភាសាដូចគ្នាដែលបានប្រើដោយវៀតណាមក្នុងការនិយាយអំពី តាយង្វៀង និង វៀតបាក់ ។ តាម ស ជាប្រវត្តិ ប្រជាជនរតនគីរី និងមណ្ឌលគីរី បានស្គាល់តែភាពអាម៉ាស់ និងការមើលងាយ ហើយរស់នៅ"ដូចសត្វតិរច្ឆាន ក្រោមការជិះជាន់នៃរបបដ៏ឃោរឃៅរកទីបំផុតគ្មាន"។ ទោះបីជាល្ងង់ខ្លៅយ៉ាងណាក៏ដោយ ក៏ពួកគេទោរទន់ជាពិសេសទៅ"ធ្វើការប្រយុទ្ធក្រោមការដឹកនាំរបស់បក្ស"ដែរ ពីព្រោះពួកគេមានជាតុ"បដិវត្តន៍ជាងគេបំផុត" ។ ការនេះនាំឱ្យយល់ថា ហេតុអ្វីបានជា ស ពឹងផ្អែកលើពួកគេយ៉ាងខ្លាំង ឱ្យធ្វើជាបុគ្គលិកមន្ទីរ ១០០ រហូតដល់កម្មាភិបាលខ្មែរខ្លះមានអារម្មណ៍ថាពួកខ្លួនត្រូវបានទុកចោលមិនប្រើការផង ។ សារី ក៏បានរៀបរាប់ដូចគ្នានេះដែរចំពោះអប្បភាគជន ថា"មានជំនឿយ៉ាងខ្លាំងលើបដិវត្តន៍" ។

### សម្តេចសីហនុ បន្ទោស បពវ និង ខ្មែរក្រហម

សម្តេចសីហនុ មិនអាចយល់អំពីជោគជ័យនៃកងឈ្លបភូមិភាគឦសានរបស់ ស បានទេ ទោះបីជាមានប្រតិបត្តិការបោសសំអាតរបស់ពួក លន់ ណុល នោះក៏ដោយ ក្រៅតែពីថាវាជាលទ្ធផលនៃអន្តរាគមន៍កុម្មុយនីសបរទេសប៉ុណ្ណោះនោះ ។

ដើមឡើយ សម្តេចបានបន្ទុះបង្អាប់ពួកកុម្មុយនីសខ្មែរ ថាគ្រាន់តែជាប្រភេទនៃប្រលោមលោកមួយប៉ុណ្ណោះ ។ នៅពេលចលនាទាំងមូលមានសុទ្ធតែជាខ្មែរទាំងអស់ ហើយកុប្បកម្មរបស់ពួកគេកើតមាននៅទីកន្លែង ដូចជានៅពាយ័ព្យនៅតែជាខ្មែរវៀតមិញក៏ដោយ ក៏ពួកនៅព្រៃសានគឺជាភ្នាក់ងាររបស់ពួកកុម្មុយនីសឡាវ ដែលជាអប្បភាគជនបំបែករដ្ឋដែលបរទេសជួលឱ្យធ្វើ រៀបចំ និងដឹកនាំពីក្រៅ ដោយចលនាកុម្មុយនីសឡាវ ។ ការចោទប្រកាន់ទាំងនេះត្រូវបានធ្ងុះបញ្ចាំងឱ្យឃើញដោយការជាក់ស្តែងដែលថា ជាតិពន្ធមូលដ្ឋានឡាវខ្លះ ដែលធ្លាប់បានធ្វើការជាមួយ បកត នៅពេលសង្គ្រាមឥណ្ឌូចិនលើកទី ១ និងអ្នកឯទៀតដែលត្រូវបានជ្រើសរើសដោយ បពវ នាដើមទសវត្ស ១៩៦០ បានដើរតួជាគន្លឹះក្នុងការរៀបចំកុប្បកម្ម តែពួកគេបានធ្វើក្រោមការដឹកនាំនៃអតីតសមាជិកក្រុមប្រជាជន ដែលបានមកទីនេះ ពី តាយទីញ ជាមួយ ស និង សារី គឺថាមិនមែនពួកកុម្មុយនីសនៅប្រទេសឡាវទេ ។

ទោះបីយ៉ាងនេះក្តី ការពន្យល់ដ៏លើសលប់ជាងគេរបស់សម្តេចសីហនុ ចំពោះការរំដើបរំជួលនៅព្រៃសាន គឺថាវាត្រូវបានធ្វើឡើងក្រោមការដឹកនាំរបស់ បពវ ដោយសមាសភាពដែលបានបណ្តុះបណ្តាល និងបំពាក់អាវុធ ដោយពួកវៀតណាម ។ ទោះបីនៅមុនពេលភូមិភាគព្រៃសានធ្វើកុប្បកម្មរបស់ពួកគេនាចុងខែមីនា ឆ្នាំ ១៩៦៨ ក៏ដោយ ក៏សម្តេចសីហនុ បានចោទប្រកាន់ថាពួកអប្បភាគជនបំបែកខ្លួននៅរតនគីរីបានទទួលការណែនាំ និងកាំភ្លើងពីវៀតណាមដែលបានកាន់កាប់ខេត្តនេះមួយផ្នែកនោះ ។ ការចោទប្រកាន់បែបនេះ កាន់តែលាន់ឮខ្លាំងឡើងក្រោយពេលកុប្បកម្មបានកើតឡើង ពេលសម្តេចសីហនុបង្កើនការត្អូញត្អែរជាសាធារណៈអំពីការពង្រីកជំរកពួកកុម្មុយនីសវៀតណាមនៅក្នុងទឹកដីកម្ពុជា ជាពិសេសនៅរតនគីរី និងមណ្ឌលគីរី ។ ក្នុងឆ្នាំ ១៩៦៩ កងទ័ពរដ្ឋាភិបាលមិនអាចចូលជ្រៅទៅក្នុងខេត្តរតនគីរីបានទេ លន់ ណុល និងសម្តេចសីហនុ បានបន្ទោសអ្វីៗទាំងអស់ដែលបានកើតឡើងនៅព្រៃសាននេះទៅលើ បពវ ។ សម្តេចសីហនុ បានថ្លែងថា ពួកឧទ្ទាមខ្មែរក្រហមនៅរតនគីរី ត្រូវបានដឹកនាំនិងបំពាក់អាវុធឱ្យដោយពួកវៀតណាមដដែល ដែលបានកាន់កាប់ទឹកដីមួយភាគធំនៃខេត្តនេះ និងថាវត្តមានពួកវៀតណាមបានបញ្ជាក់អំពីវត្តមានពួកឧទ្ទាមនៅទីនោះ និងនៅខេត្តមណ្ឌលគីរី ។ មន្ត្រីរបស់សង្គម បាននិយាយថាការបះបោរនៅព្រៃសានត្រូវបានដឹកនាំធ្វើដោយ"ភ្នាក់ងារវៀតកុងចំនួន ៥០ នាក់" ។

មែនហើយកុប្បកម្មរបស់ ស នៅព្រៃសានគឺជាការឆ្លៀតឱកាសមួយភាគធំ ដោយវត្តមានពួកកុម្មុយនីសវៀតណាមនៅទីនោះ និងនៅតែរាប់អានគ្នាក្នុងការទាក់ទងរបស់ពួកគេជាមួយ បពវ ។ ការ"ដកចេញ" ពីតាយទីញ បានដាក់ ស និងកម្មាភិបាលមន្ទីរ១០០ ដទៃទៀត ទៅក្នុងតំបន់ដែលពួកគេទទួលផលចំណេញពីវៀតណាមជាងភូមិភាគដទៃទៀត ។ ដូចបូព៌ាដែរ ពួកគេទទួលបានជំរក ។ លើសពីនេះទៅទៀត ទោះបីជានៅខាងក្នុងកម្ពុជាក៏ដោយ ក៏ពួកគេប្រតិបត្តិការក្រោមឆ័ត្រយោធារបស់វៀតណាមដែរ ។ ពួកគេក៏មានលទ្ធភាពទទួលបានអាវុធខ្លះពីវៀតណាមផងដែរ ទោះបីជាដោយលួចឬដកហូតយកក៏ដោយ ។ ដោយធ្វើតាមគំរូវៀតណាម ពោលគឺសង្គ្រាមប្រជាជនប្រភេទតាយង្វៀង កងឈ្លបរបស់ ស ក្នុងការអនុវត្តន៍ជាក់ស្តែង បានតភ្ជាប់ទៅនឹងវត្តមាននិងការគាំទ្ររបស់វៀតណាម ទោះបីជាមិនពឹងលើជំនួយផ្ទាល់របស់វៀតណាម និងកាន់តែមិនស្ថិតក្រោមការដឹកនាំរបស់ពួកគេថែមទៀត ដូចដែលសម្តេចសីហនុ និង លន់ ណុល បានចោទប្រកាន់ និងមានជំនឿដោយការសន្មត់ ក៏ដោយ ។

ក្នុងឆ្នាំ ១៩៦៩ វៀតណាមមានមូលដ្ឋានសំខាន់ចំនួន ៦ នៅព្រៃសាន ដោយមានកម្លាំងច្រើនជាងពួកកុម្មុយនីសខ្មែរនៅទីនោះយ៉ាងលើសលប់ ។ ពួកគេក៏មានកម្លាំងយោធានៅក្នុងតំបន់ខ្លាំងជាងកម្លាំងពួក លន់ ណុល ឆ្ងាយណាស់ដែរ ទោះបីជាពួក លន់ ណុល ចេះតែបញ្ជូនបន្ថែមដើម្បីពង្រឹងវាយ៉ាងណាក៏ដោយ ។ ការនេះអាចពន្យល់ពីភាពមិនធម្មតា ដែលទោះបីជា ស ប្រកាសថាពួកគេមានកម្លាំងប្រដាប់អាវុធមិនលើសពី ៦០ នាក់ នៅព្រៃសានក៏ដោយ ក៏ លន់ ណុល បានប៉ាន់ប្រមាណចំនួនពួកជនជាតិភាគតិចបះបោរក្តោបក្តាប់ដោយវៀតណាមនៅទីនោះ ថាមានចំនួនរហូតដល់ ១០០ នាក់ដែរ ។ ដូច លន់ ណុល បាន

ចោទប្រកាន់ ភាគច្រើននៃពួកទាំងនេះអាចជាផ្នែកមួយរបស់អង្គភាពដឹកនាំដោយ បពវ ដំណើរការជាកម្លាំងបង្កប់សំរាប់វៀតណាម ដែលអាចធ្វើសកម្មភាពឃោសនាប្រដាប់អាវុធក្នុងភូមិជនជាតិភាគតិចខ្លះផងដែរ ។

លន់ ណុល និងសម្តេចសីហនុ ក៏យល់ដោយត្រឹមត្រូវដែរថាសម្ភារៈយោធារបស់ ស មួយចំនួនបានមកពីប្រភពវៀតណាម ហើយការនេះមានន័យថាកម្លាំងរបស់គេមានបំពាក់ទៅដោយអាវុធខ្លះមានគុណភាពខ្ពស់ជាងពួកបះបោរនៅភូមិភាគដទៃទៀត ។ ឦសានមានពោរពេញទៅដោយអាវុធនិងគ្រាប់រំសេវរបស់សូវៀត ដែលបានដឹកជញ្ជូនចូលវៀតណាមតាមផ្លូវលំហូ ជីមិញ ។ កម្មាភិបាលភូមិភាគប្រហែលជាបានខិតខំដើម្បីទទួលបានអាវុធមួយចំនួនតូច និងមួយចំណែកពីកងដឹកជញ្ជូនមូលដ្ឋានដែលវៀតណាមប្រើ ប្រហែលជាដោយប្ញន់យក និងដោះដូរ ដូចដែល នួន ធ្លាប់បានឱ្យយោបល់ទៅ គឹម អីចឹងដែរ ។ ពួកគេប្រហែលជាទទួលបានអាវុធស្វ័យប្រវត្តធ្វើនៅអាមេរិកមួយចំនួនតូចក្រៅផ្លូវការ ពីអង្គភាពវៀតណាមនៅមូលដ្ឋានផងដែរ ។ ទោះបីយ៉ាងណាក៏ដោយ ការចោទប្រកាន់ថាវៀតណាមបានផ្តល់អាវុធចិនធុនតូចឱ្យដល់កម្លាំងរបស់ ស ដែលក្នុងនោះភាគច្រើនជាអាវុធទំនើបបំពាក់ឱ្យកងឈ្លបខ្មែរនោះ គឺមិនពិតទេ ពីព្រោះអាវុធទាំងនេះគឺដណ្តើមបានពីកងកម្លាំងរបស់ លន់ ណុល ផ្ទាល់ដែលត្រូវបានបំពាក់ឱ្យដោយអាវុធចិន ។

ការចោទប្រកាន់របស់ពួករត់ចោលជួរថា ពួកកុម្មុយនីសខ្មែរនៅឦសានប្រើភាសានយោបាយរបស់វៀតណាមនោះ គឺគួរឱ្យជឿណាស់ ដោយហេតុថាទីកន្លែងរបស់កម្មាភិបាលខ្មែរជាច្រើនស្ថិតនៅក្នុងទឹកដីវៀតណាម ហើយនិងរយៈពេលជាច្រើនឆ្នាំដែលពួកគេជាប់ពាក់ព័ន្ធជាមួយវៀតណាម ។ ជាការគួរឱ្យជឿផងដែរ សេចក្តីប្រកាសទាំងឡាយរបស់ លន់ ណុល ដែលថាកម្លាំងរបស់គេដែលធ្វើប្រតិបត្តិការនៅឦសាន បានសម្លាប់ និង ចាប់បានទាហានវៀតណាម ដែលស្ពាយកាំភ្លើងមានសញ្ញាសំគាល់ជាភាសាវៀតណាម ។

ទោះយ៉ាងណាក្តី ពុំមានអ្វីជាកស្តុតាងបញ្ជាក់ថា ការសន្និដ្ឋានរបស់សម្តេចសីហនុ និងលន់ ណុល ដែលថាពួកបះបោរនៅឦសាន ស្ថិតក្រោមបញ្ជារបស់វៀតណាមនោះទេ ។ ផ្ទុយទៅវិញ នៅក្នុងបញ្ជីលំអិតរបស់រដ្ឋាភិបាល ដែលបានធ្វើឡើងនាពាក់កណ្តាលឆ្នាំ ១៩៦៩ អំពីទីតាំងនិងឈ្មោះក្រុមអ្នកបះបោរនៅរតនគីរីនោះ មានឈ្មោះមនុស្សធ្លាប់ស្គាល់ជាច្រើននាក់ដែលជាផ្នែកនៃរចនាសម្ព័ន្ធរបស់ភូមិភាគឦសាន ស្ថិតក្រោមគណៈកម្មាធិការដឹកនាំដោយ ស, អៀង សារី និង សុន សេន ។ ពុំមានអ្វីយកមកធ្វើជាមូលដ្ឋាន ចំពោះការពង្រីក នាពាក់កណ្តាលឆ្នាំ ១៩៦៩ របស់សម្តេចសីហនុ ស្តីពីការកំណត់ការទទួលខុសត្រូវរបស់វៀតណាម ចំពោះសកម្មភាពកុម្មុយនីសនៅទូទាំងប្រទេសកម្ពុជាបានទេ ។ សម្តេចបានធ្វើសេចក្តីថ្លែងការណ៍ដោយខុសថា ការបះបោរបានផ្ទុះឡើងនៅទូទាំងប្រទេស ពីព្រោះវៀតណាមបាន"ធ្វើឱ្យសកម្មឡើងវិញ" នូវសាខាខ្មែរដែលពួកវៀតមិញបង្កើតក្នុងរយៈពេលសង្គ្រាមឥណ្ឌូចិនលើកទី ១ ។

មានការខុសឆ្គងដូចគ្នានេះដែរ នៅពេលដែលសម្តេចសីហនុធ្វើការចោទប្រកាន់ជាបន្តថា បទបញ្ជារបស់វៀតណាមចំពោះការធ្វើឱ្យសកម្មឡើងវិញនោះ ត្រូវបានធ្វើឡើងតាមរយៈ ខៀវ សំផន, ហ៊ូ យន់ និង ហ៊ូ នឹម ដែលជាមេដឹកនាំខ្មែរសំខាន់នៃការតស៊ូប្រដាប់អាវុធនៅទូទាំងប្រទេស ។ ជាក់ស្តែង ពេញមួយឆ្នាំ ១៩៦៨ ខៀវ សំផន និង ហ៊ូ យន់ ពុំបានធ្វើអ្វីទាល់តែសោះនៅក្នុងភូមិនានាក្នុងខេត្តកំពត ភូមិភាគនិរតី ឬដែលរត់គេចពីការវាយប្រហារបករបស់រដ្ឋាភិបាលនៅទីនោះ ពេលដែល ហ៊ូ យន់ ស្ថិតនៅក្នុងទីបញ្ជាការភូមិភាគនិរតី របស់ តាម៉ុក នៅភ្នំឱរ៉ាល់ ដែលរូបគេបានធ្វើការឃោសនាក្រោមការដឹកនាំរបស់ តាម៉ុក នៅតាមភូមិនានាស្ថិតនៅក្បែរនោះ ។

*ដូច្នេះ ការពិតគឺថា អ្វីជាចុងក្រោយដែលសម្តេចសីហនុអាចគិតស្មាននោះ គឺថាថ្នាក់ដឹកនាំ បព២ គឺជាពួកខ្មែរវៀតមិញ ដែលមានចំនួនដ៏ច្រើនលើសលប់ តែពួកគេឯករាជ្យ ក្នុងន័យដែលថាការធ្វើសេចក្តីសំរេចផ្សេងៗ អំពីអ្វីដែលមិនមែនខាងទ្រឹស្តីទេនោះ ពីពួកវៀតណាម ក៏ដូចជាពីចិនដែរ ។*

## ជំពូក ៩

## ឆ្ពោះទៅរដ្ឋប្រហារមួយ

### សម្តេចសីហនុបែរមកប្រឆាំងវៀតណាមវិញ

ដោយមានជំនួយពីសហរដ្ឋអាមេរិក សម្តេចសីហនុបានទតឃើញនូវរូបភាពកាន់តែច្បាស់នៃជាតុពិតរបស់ជំរកវៀតណាមនៅក្នុងទឹកដីកម្ពុជា ហើយចាប់តាំងពីចុងឆ្នាំ ១៩៦៧ មក ទ្រង់បានចាប់ផ្តើមឃុបឃិតជាមួយសហរដ្ឋអាមេរិក ដើម្បីបណ្តេញ ឬយ៉ាងហោចណាស់កាត់បន្ថយវា ។ សម្តេចធ្វើយ៉ាងដូច្នេះ មិនមែនជាប្រតិកម្មទៅនឹងការបះបោររបស់ បពខ ទេ តែគឺទៅនឹងការពង្រីកជំរករបស់ពួកវៀតណាមនៅកម្ពុជា ក្នុងការរៀបចំសំរាប់ធ្វើការវាយសំរុក តែត នៅខែមករា ឆ្នាំ ១៩៦៨ ។ សម្តេចមានការខ្វាល់យ៉ាងខ្លាំង ដែលបានដឹង នៅក្នុងខែវិច្ឆិកា ឆ្នាំ ១៩៦៧ នូវកស្តុតាងនៃវត្តមាននៃជំរុំមូលដ្ឋាន និងគំនរគ្រាប់រំសេវរបស់វៀតណាមធំៗជាច្រើន ។ នៅខែធ្នូ សម្តេចបានបញ្ជាក់ថាការអត់ធ្មត់របស់ព្រះអង្គបានកន្លងផុតទៅហើយ ទ្រង់បានប្រកាសជាចំហថា ទ្រង់នឹងមិនជំទាស់ទៅនឹងសហរដ្ឋអាមេរិកឆ្លងចូលមកក្នុងប្រទេសទេ ដើម្បីដឹកនាំធ្វើការប្រយុទ្ធដោយមានព្រំដែនមួយ ប្រឆាំងវៀតណាម ។ ព្រះអង្គបានបញ្ជាក់ការនេះ តាមរយៈការឆ្លើយឆ្លងគ្នាតាមរលកទូរគមនាគមន៍ ទៅសហរដ្ឋអាមេរិកដែលបានចាប់ផ្តើមធ្វើការហោះហើរស៊ើបការណ៍នៅលើទឹកដីកម្ពុជា ដើម្បីពិនិត្យមើលទីតាំង និងចលនារបស់វៀតណាម ។ ទោះបីជា បពខ បានចាប់ផ្តើមធ្វើការតស៊ូប្រដាប់អាវុធនៅក្នុងខែមករា ឆ្នាំ ១៩៦៨ ក៏ដោយ ក៏សម្តេចបានយល់ស្របជាសម្ងាត់ក្នុងពេលប្រជុំមួយជាមួយអ្នកការទូតអាមេរិកម្នាក់ ដែលកំពុងបំពេញទស្សនៈកិច្ច ឱ្យកងទ័ពអាមេរិកធ្វើការវាយប្រហារៈដេញតាមដោយប្រើធម៌ក្តៅ" លើទឹកដីដែលមានកងកម្លាំងវៀតណាម ។ ព្រះអង្គបានសុំឱ្យអាមេរិកស៊ើបការណ៍លើទីតាំងរបស់ពួកគេ និងសន្យាថាធ្វើការជាសម្ងាត់ជាមួយសហរដ្ឋអាមេរិកដើម្បីបណ្តេញពួកគេ ដោយបញ្ចុះបញ្ចូលទីក្រុងវ៉ាស៊ីនតោនថា ព្រះអង្គពិតជាចង់ឱ្យវៀតណាមដកចេញមែន ។ ព្រះអង្គបានឱ្យសញ្ញាជាសាធារណៈអំពីបំណងរបស់ព្រះអង្គ ដើម្បីរៀបចំឡើងវិញនូវការទាក់ទងផ្លូវទូត សហរដ្ឋអាមេរិក-កម្ពុជា ។ យោងតាមកិច្ចព្រមព្រៀងជាសម្ងាត់ ការលើកឡើងអំពីប្រតិបត្តិការៈរបស់សហរដ្ឋអាមេរិកមួយ បានផ្តល់ដល់ការស្នើសុំឱ្យធ្វើការស៊ើបការណ៍ថ្វាយសម្តេចពេញមួយរយៈពេលនៃឆ្នាំ ១៩៦៨-១៩៦៩ ។ ភ្លាមៗ បន្ទាប់ពីផ្តល់ជូនរបាយការណ៍ស៊ើបការណ៍លើកទី ១ នៅក្នុងខែកុម្ភៈ ឆ្នាំ ១៩៦៨ កងទ័ព លន់ ណុល បានចាប់ធ្វើសកម្មភាពនៅក្នុងតំបន់ដែលពួកគេមានលទ្ធភាពអាចធ្វើបាន ដោយបណ្តេញពួកវៀតណាមចេញ និងកំទេចលេណដ្ឋានពួកគេ ។ នៅខែធ្នូ ឆ្នាំ ១៩៦៨ សហរដ្ឋអាមេរិកមានជំនឿជឿជាក់ថា សម្តេចសីហនុ បានពង្រឹងគោលជំហររបស់ព្រះអង្គប្រឆាំងវៀតណាម និងថា លន់ ណុល សង្ឃឹមថានឹងអាចបោសសំអាតពួកគេឱ្យចេញពីតំបន់ជាច្រើន ទោះបីជាមិនមែននៅកន្លែងដែលពួកគេមានការប្រមូលផ្តុំធំជាងគេបំផុតក៏ដោយ ជាពិសេសនៅភ្លៀសាន ។

នៅដើមខែមីនា ឆ្នាំ ១៩៦៩ សម្តេចសីហនុបានបញ្ជាក់ឡើងវិញថា ព្រះអង្គមានសេចក្តីព្រួយបារម្ភយ៉ាងជ្រាលជ្រៅចំពោះការពង្រាយទ័ពវៀតណាមដោយទ្រង់ទ្រាយធំបែបនេះនៅលើទឹកដីកម្ពុជា ដោយទ្រង់ត្អូញត្អែរថា "អាមេរិកមិនបានទម្លាក់គ្រាប់បែកលើពួកគេទាល់តែសោះ" ។ នៅពេលសហរដ្ឋអាមេរិកចាប់ផ្តើមគាំទ្រដោយការទម្លាក់គ្រាប់ពីលើអាកាសដោយមិនប្រកាស ទៅលើជំរក ១១ ថ្ងៃបន្ទាប់មក ព្រះអង្គបានគាំទ្រយ៉ាងទូលំទូលាយ ទោះបីជាមានការប្រឆាំងជាសាធារណៈមួយចំនួនក៏ដោយ ។ នៅខែមេសា ឆ្នាំ ១៩៦៩ អ្នកនាំពាក្យរបស់សង្គមម្នាក់បានបញ្ជាក់ថា ល្អិកណាតែគ្រាប់ធ្លាក់លើពួកវៀតណាម រដ្ឋាភិបាលនឹងមិនជំទាស់ទេ ។ ក្នុងពេលជាមួយគ្នានោះ សម្តេចសីហនុបានហាមឃាត់ការប្រើកំពង់ផែរសមុទ្រកម្ពុជា ដើម្បីទម្លាក់កស្តុការរបស់ចិនសំរាប់បញ្ជូនទៅឱ្យវៀតណាម ។ សហរដ្ឋអាមេរិក ដោយមានការពេញចិត្តនឹងការដែលសម្តេចសីហនុ

បានធ្វើការជាមួយពួកគេ ដើម្បីដាក់ការគៀបសង្កត់យ៉ាងខ្លាំងទៅលើវៀតណាមនោះ បានផ្តល់ជូនដោយឥតគិតថ្លៃដល់សេចក្តីស្នើសុំរបស់សម្តេចសីហនុ ឱ្យអាមេរិកទទួលស្គាល់ជម្លោះព្រំដែនរវាងកម្ពុជា និង វៀតណាម ថៃ និងឡាវ ជាថ្នូរនឹងការរៀបចំការទាក់ទងផ្លូវទូតឡើងវិញនោះ។ ការនេះបានកើតឡើងនៅក្នុងខែមិថុនា ឆ្នាំ ១៩៦៩ នៅពេល លន់ ណុល បណ្តេញពួកវៀតណាមចេញពីជំរុំតូចៗរបស់ពួកគេខ្លះ ក្នុងផ្នែកខ្លះនៃភូមិភាគបូព៌ា ។ ពេលប្រតិបត្តិការទាំងនេះបានបន្តធ្វើនៅខែសីហា លន់ ណុល បានទទួលដំណែងជានាយករដ្ឋមន្ត្រី ។

ជាលទ្ធផលនៃប្រតិបត្តិការរបស់កងទ័ពអាកាសសហរដ្ឋអាមេរិក និងកងទ័ព លន់ ណុល ដែលជាផលនៃកិច្ចសហប្រតិបត្តិការរបស់សម្តេចសីហនុ អង្គភាពវៀតណាមនៅក្នុងកម្ពុជា បានប្រឈមមុខទៅនឹងអ្វីដែលពួកគេរៀបរាប់នៅក្នុងឆ្នាំ ១៩៦៩ ថាជា"សភាពការណ៍មួយដ៏សាហាវ និងស្មុគ្រស្មាញ" ដែលប៉ះពាល់ដល់សតិអារម្មណ៍របស់ពួកគេ ។ ទោះបីជាសាធារណៈពួកកុម្មុយនីសវៀតណាមបានបន្តអង្វរករសម្តេចសីហនុ និងចាត់ទុកព្រះអង្គជាមិត្តជានិច្ចរបស់ពួកគេក៏ដោយ ក៏ការវិភាគផ្ទៃក្នុង បពវ ភាគខាងត្បូង បានចាត់ទុកព្រះអង្គថាជាជនប្រតិកិរិយាមួយព្រះអង្គ ដែលបានជួយសហរដ្ឋអាមេរិក ដើម្បីវាយផ្ចប់ជំរករបស់ពួកគេពីក្រោយខ្នង ដើម្បីសំរេចបានឧត្តមភាពខាងយោធាលើបដិវត្តន៍នៅភាគខាងត្បូង ។ ពួកអ្នកការទូតអាមេរិកនៅភ្នំពេញ បានឯកភាពគ្នាថាសម្តេចសីហនុមានបំណងចង់រក្សាការទាក់ទងជាមួយសហរដ្ឋអាមេរិក និងសហប្រតិបត្តិការខាងយោធា និងការទូត ជាមួយសហរដ្ឋអាមេរិក ប្រឆាំងជំរករបស់វៀតណាម ជាចំហ និងដោយសម្ងាត់ ។ ការណ៍ទាំងនេះបានចោទជាសំណួរថាតើរដ្ឋប្រហារមួយនៅកម្ពុជា ជាការចាំបាច់ពិតប្រាកដ ដើម្បីសំរួលដល់ការវាយប្រហាររបស់សហរដ្ឋអាមេរិក ទៅលើពួកកុម្មុយនីសវៀតណាមដែរឬទេ ។

ប្រហែលជាមូលដ្ឋាននៃភាពបន្ទាន់កាន់តែខ្លាំងចំពោះវិបត្តិមួយនោះ គឺការលំដួលនៃសេដ្ឋកិច្ចក្នុងស្រុក ដែលជាលទ្ធផលនៃ"រដ្ឋសត្តិកូមនិយម"អស់រយៈពេល ៦ ឆ្នាំមកហើយ ដែលពួកអ្នកទិតៀន"ស្តាំនិយម" ប្រឆាំងសម្តេច មានការសោកស្តាយកាន់តែខ្លាំង ហើយការលប់បំបាត់វាចោលនោះទាមទារឱ្យមានការមោះមុត ពីសំណាក់ពួកអ្នកជាមេកដាងនៃសហគមន៍ពាណិជ្ជកម្ម ដែលបានខិតខំដើម្បីសេចក្តីថ្កើងថ្កានរបស់ពួកគេ ទោះបីជាមានវិបត្តិដូច្នេះក៏ដោយ ។ មេគេក្នុងចំណោមពួកអ្នកទិតៀន និងពួកពាណិជ្ជករ ដែលចេញមុខដើម្បីចំណេញនោះ គឺព្រះអង្គម្ចាស់ ស៊ីសុវត្ថិ សិរិមតៈ ដែល លន់ ណុល បានតែងតាំងឱ្យធ្វើជាឧបនាយករដ្ឋមន្ត្រីរបស់គេនៅខែសីហា ។ វត្តមានរបស់ព្រះអង្គម្ចាស់ក្នុងរដ្ឋាភិបាល បានលើកទឹកចិត្តពួកប្រឆាំងសម្តេចសីហនុក្នុងទីក្រុង ចាប់ផ្តើមចេញមុខជាចំហ ធ្វើឱ្យសម្តេចមានការច្របូកច្របល់ខាងនយោបាយកាន់តែជ្រាលជ្រៅថែមទៀត ។

**បព៦ និង សម្តេចសីហនុ**

ស្ថិតក្នុងកាលៈទេសៈបែបនេះ បព៦ មានការលំបាកកាន់តែខ្លាំងជាង បពវ ទៅទៀត ក្នុងការទប់អារម្មណ៍របស់ពួកគេចំពោះសម្តេចសីហនុៈ ការតស៊ូដោយអាវុធ ត្រូវនាំមកនូវការវាយប្រហារផ្ទាល់ទៅលើព្រះអង្គ ដោយក្នុងនោះមានសមាសភាពជាបញ្ញាជនដែលបានរត់ចេញពីភ្នំពេញផង ។ សកម្មភាពឃោសនារបស់ ហ៊ូ យន់ ឱ្យតាម៉ុក នៅនិរតី មិនត្រឹមតែទម្លាក់កំហុសទៅលើរបបសង្គមចំពោះកំរិតជីវភាពរស់នៅទាប និង លន់ ណុល ចំពោះការរំលោភទៅលើប្រជាជនប៉ុណ្ណោះទេ វាក៏បានថ្កោលទោសសម្តេចសីហនុថា"បានសម្លាប់ពួកអ្នកស្នេហាជាតិអស់ជាច្រើន"ផងដែរ។ ការវាយប្រហារលើសម្តេចសីហនុ ត្រូវបានផ្តល់យុត្តិកម្មដោយស្របទៅតាមការវិភាគដែលចាត់ទុកព្រះអង្គ និងលន់ ណុល ជាខ្មាំង តែពួកគេនៅមើលឃើញថានឹងមានរដ្ឋប្រហារប្រឆាំងសម្តេចដែលនឹងធ្វើដោយ លន់ ណុល ដោយជៀសមិនរួចឡើយ ។ សង្គ្រាមឈ្លបប្រឆាំងរបប សម្តេច និងការវាយប្រហារផ្ទាល់លើព្រះអង្គ អាចបង្កឱ្យមានរដ្ឋប្រហារ តែនេះនឹងបង្កើតឱកាសសំរាប់បក្ស "ធ្វើការប្រមូលកម្លាំង" ដាក់ឱ្យស្ថិតនៅក្រោមការត្រួតត្រារបស់ខ្លួននូវពួកអ្នកប្រឆាំងរដ្ឋប្រហារ ក្នុងនោះរួមទាំងសម្តេចសីហនុព្រះអង្គឯងផង ។ បញ្ញាជនដទៃ

ទៀតដែលរត់ចេញពីទីក្រុង នឹងមានសុទិដ្ឋិនិយមតិចជាង ដោយបានប្រកាសក្នុងការឃោសនាដែលពួកគេបានសរសេរសំរាប់កងឈ្លបភូមិភាគនិរតី ថាសម្តេចសីហនុ "បានចុះចាញ់ទាំងស្រុង ចំពោះចក្រពត្តិនិយម និងជាខ្ញុំកញ្ជះរបស់វា" ។

ការឃោសនាប្រឆាំងសម្តេចសីហនុច្រើនជាងនេះទៀត ត្រូវបានផលិតឡើងនៅក្នុងឆ្នាំ ១៩៦៩ បន្ទាប់ ពី ខៀវ សំផន និង ហ៊ូ យន់ ត្រូវបានផ្លាស់ឱ្យទៅនៅភ្នំឱរ៉ាល់ ។ នួន បានផ្តល់ការអនុញ្ញាតពិសេសដល់ពួកគេ និង ហ៊ូ យន់ ឱ្យចូលរួមសន្និបាតមួយនៃសមាជិកគណៈកម្មាធិការមជ្ឈឹម បពខ មកពីពាក់កណ្តាលខាងលិចនៃកម្ពុជា ដែលនាពេលនោះ ហ៊ូ យន់ និង ហ៊ូ នឹម បានទិតៀនសម្តេចសីហនុយ៉ាងខ្លាំងក្លាបំផុត ។ ពួកគេត្រូវបានអនុញ្ញាតឱ្យសរសេរខិតប័ណ្ណប្រឆាំងសម្តេចសីហនុ ដែលត្រូវបានយកទៅផ្សព្វផ្សាយនៅភ្នំពេញ ក្រោមអំណាចរបស់ វន ដោយពួកនៅសេសសល់ចុងក្រោយរបស់អង្គការបក្សនៅទីនោះ ។ ហ៊ូ នឹម ត្រូវបានចាត់តាំងឱ្យចូលរួមជាមួយ ហ៊ូ យន់ ដើម្បីធ្វើការងារឃោសនានៅភូមិភាគនិរតី ។ រូបគេបានតែងបទចំរៀងបដិវត្តន៍ និងឯកសារដទៃទៀតសំរាប់កងអនុសេនាតូចនៃកងឈ្លប ដែលចំរៀងទាំងនោះទិតៀនទាំងសម្តេចសីហនុ ទាំង លន់ ណុល ។ ទោះបីយ៉ាងនេះក្តី ជាទូទៅអ្នកទាំងពីរនាក់នេះត្រូវបានដាក់ឱ្យនៅដាច់ពីប្រជាជនធម្មតា នៅក្នុងតំបន់ឈ្លប ដែលជាការច្បាស់ណាស់ ដើម្បីធានាថាវត្តមានរបស់ពួកគេស្ថិតនៅជាសម្ងាត់ តែប្រហែលជាដើម្បីការពារកុំឱ្យពួកគេប្រើឥទ្ធិពលនយោបាយឯករាជ្យ ទៅលើប្រជាជនកសិករ ។ ពួកគេបានបង្កើនការវាយប្រហារទៅលើបក្ស នយោបាយរបស់បក្ស និងថ្នាក់ដឹកនាំរបស់បក្ស ។ សូម្បីតែ ខៀវ សំផន ក៏ដោយ ក៏គេមិនទុកចិត្តដែរ ទោះបីជារូបគេមិនដែលទិតៀនអង្គការក៏ដោយ កម្មាភិបាលភូមិភាគនិរតីបាននិយាយបង្កាច់រូបគេថាជាប្រភេទជនគហបតីពេក ក្នុងការចាត់តាំងរូបគេជាសំខាន់គឺឱ្យស្វែងរកស្បៀង ដើម្បីយកមកចិញ្ចឹមកម្មាភិបាល និងប្រជាជនអ្នកភូមិដែលបានផ្លាស់ប្តូរទីកន្លែង ។

ការឃោសនាប្រឆាំងសម្តេចសីហនុ ដែលនឹងនាំទៅឱ្យមានការប៉ុនប៉ងរបស់ បពខ ដើម្បីធ្វើសង្គ្រាមប្រជាជន អាចឆ្លុះបញ្ចាំងអំពីការប្តូរទិសនយោបាយចំពោះសម្តេច ត្រូវបាន នួន និង ស យល់ស្របក្នុងការប្រជុំរបស់ពួកគេនៅឦសាន ក្នុងឆ្នាំ ១៩៦៨ ។ ក៏ប៉ុន្តែ នៅខែកក្កដា ឆ្នាំ១៩៦៩ បញ្ហានេះនិងបញ្ហាដទៃទៀតត្រូវបានពិនិត្យឡើងវិញនៅក្នុងការប្រជុំគណៈកម្មាធិការមជ្ឈឹម បពខ ដែលហាក់បីដូចជាត្រូវបានកោះឱ្យធ្វើដោយ ស នៅឦសាន ។ សេចក្តីសំរេចនានានៅក្នុងពេលប្រជុំនោះ បានធ្វើឱ្យ បពខ សម្រួបខ្លួនជាមួយវៀតណាម ក៏ដូចជាជាមួយសម្តេចសីហនុ ប៉ុន្តែបានបន្តបដិសេធការធ្វើសហប្រតិបត្តិការអ្វីទាំងអស់ជាមួយ លន់ ណុល ។

យោងតាមការរៀបរាប់ឱ្យដឹងមួយ អង្គប្រជុំបានសំរេចបន្តធ្វើសង្គ្រាមប្រជាជន ដើម្បីកំទេចពួក លន់ ណុល ដោយប្រើការតម្រង់ទិសយុទ្ធសាស្រ្ត និងយុទ្ធវិធី ពិនិត្យឡើងមួយ ក្នុងគោលបំណងសាកល្បងជំរុញអព្យាក្រិតភាពកម្ពុជា ដោយការមិនប្រឆាំងសម្តេចសីហនុ ។ ការបកស្រាយមួយផ្សេងទៀត បានបង្ហាញថា ការប្រជុំបានយល់ស្របជាមួយទស្សនៈរបស់ នួន និង ម៉ុក ដែលថា រដ្ឋប្រហារដែលជៀសមិនផុតរបស់ លន់ ណុល នឹងជំរុញឱ្យមានកម្លាំងថ្មីមកខាងបដិវត្តន៍ជាមិនខាន តែបានសំរេចបញ្ឈប់ការឃោសនាប្រឆាំងសម្តេចសីហនុទាំងអស់ ដើម្បីត្រៀមខ្លួនទទួលកម្លាំងថ្មីទាំងនោះ។ ណែនាំដោយការប្រកាន់ខ្ជាប់ជាថ្មីម្តងទៀត ទៅនឹងមាគ៌ារណសិរ្សរួបរួមជាតិរបស់ បពខ ឆ្នាំ ១៩៦០ លើការរួបរួមជាមួយសម្តេច ការប្រជុំបានទិតៀនសេចក្តីថ្លែងការណ៍របស់បញ្ញាជនប្រឆាំងសម្តេច សុំឱ្យធ្វើការឃោសនាផ្តោតតែទៅលើចក្រពត្តិអាមេរិក និងលន់ ណុល ដើម្បីឯកោខ្មាំងទាំងនេះ ។ អង្គប្រជុំបានសន្និដ្ឋានថា ទោះបីជាអព្យាក្រិតភាព និងអំណាចរបស់សម្តេច នៅសេសសល់តែបន្តិចបន្តួចក៏ដោយ ក៏អាមេរិកនឹងមិនអនុញ្ញាតឱ្យព្រះអង្គស្ថិតនៅក្នុងអំណាចតទៅទៀតដែរ ម្យ៉ាងទៀតរដ្ឋប្រហារប្រឆាំងព្រះអង្គដើម្បីដាក់កម្ពុជាទៅក្នុងមូលដ្ឋានអាមេរិក ដើម្បីវាយប្រហារទៅលើវៀតណាមនោះ នឹងជិតមកដល់ណាស់ហើយ ។ ការពង្រីកប្រតិបត្តិការលើដីរបស់អាមេរិក នៅតែជាការព្រួយបារម្ភដ៏ច្បាស់លាស់របស់ បពវ នៅពេលនេះ ។

*បន្ទាប់ពីការប្រជុំខែកក្កដាភ្លាម នួន បានទៅបំពេញទស្សនៈកិច្ចនៅវៀតណាមភ្លាម ដើម្បីពិភាក្សាជាមួយ ស ម្តងទៀត ។ ទោះបីជាកុប្បកម្មមិនបានទទួលជោគជ័យ លើកលែងតែនៅរៀសាន និងនិរតី (ដែលនឹងមានភាពអាក់រអួលក្នុងពេលឆាប់ៗនេះ) ក៏ ស បានសន្និដ្ឋាន បន្ទាប់ពី នួន បានរាយការណ៍ ថាចលនាបដិវត្តន៍កម្ពុជាកំពុងមានសន្ទុះខ្លាំងឡើងហើយ ។ ពួកគេឯកភាពគ្នាថានឹងបន្តគាំទ្រការតស៊ូនយោបាយរួមផ្សំអាវុធ និងថាដល់ពេលហើយដែល ស ត្រូវទៅបំពេញទស្សនៈកិច្ចម្តងទៀតនៅវៀតណាម និងចិន ដែលជាផែនការលើកឡើងនៅក្នុងខែសីហា ។ ស បានចេញដំណើរនៅចុងឆ្នាំ ១៩៦៩ ។*

*នួន បានត្រឡប់មកភ្នំឱរ៉ាល់វិញ ដែលនៅទីនោះ រូបគេបានណែនាំដល់កម្មាភិបាលដឹកនាំមកពីនិរតី, ពាយ័ព្យ, ភ្នំពេញ និងកន្លែងដទៃទៀត ឱ្យប្រើគ្រប់មធ្យោបាយទាំងអស់ដើម្បីធ្វើការតស៊ូប្រដាប់អាវុធនៅទូទាំងប្រទេស ដើម្បីផ្តល់ដល់សង្គ្រាមប្រជាជននូវសន្ទុះកាន់តែខ្លាំងថែមទៀត ប៉ុន្តែដាច់ខាតឈប់ធ្វើសេចក្តីថ្លែងការណ៍ប្រឆាំងសម្តេចសីហនុដើម្បីធ្វើឱ្យរស់និងពង្រឹងឡើងវិញយុទ្ធវិធីចាស់យកឈ្នះលើសម្តេចសីហនុ ។ មានភាពមិនច្បាស់លាស់អំពីវិសាលភាពដែលថា តើសេចក្តីណែនាំចុងក្រោយនេះត្រូវបានអនុវត្តកំរិតណា ។ ដោយលេខាបក្សភ្នំពេញ វន វ៉េត ធ្លាក់ខ្លួនឈឺត្រូវត្រឡប់ពីការប្រជុំមកផ្ទះវិញ ហើយក្រោយមកជាប់កុននៅឱរ៉ាល់ ដោយការវាយប្រហារទ្រង់ទ្រាយធំមួយរបស់ លន់ ណុល ការបាចខិតប័ណ្ណប្រឆាំងសម្តេចសីហនុ បានបន្តធ្វើនៅក្នុងរាជធានី ។ អង្គភាពឈ្លបខ្មែរនៅនិរតី ក៏នៅមិនទាន់ទទួលបានសេចក្តីណែនាំ ឬបំពានការហាមការធ្វើការឃោសនាប្រឆាំងសីហនុ ដែលពួកគេបន្តធ្វើដោយគ្មានស្រាក ។*

*ការផ្លាស់ប្តូរនេះបានផ្តល់ដល់ ស ឱ្យកាន់តែមានមូលដ្ឋានការទូត ដើម្បីបន្តអាណត្តិរបស់គេក្នុងការពិភាក្សាជាមួយវៀតណាម ដូចដែលបានឯកភាពគ្នាជាមួយ នួន រួចមកហើយ ដើម្បីនិយាយអំពី"ការទាក់ទងជាមិត្តភាពរវាងភាគីទាំងពីរ"។ ក្នុងរយៈពេលនេះ ខាងកម្ពុជាបានបន្តឈរលើគោលជំហរដែលថាវៀតណាម គឺជាមិត្តនៃបដិវត្តន៍កម្ពុជា ហើយបើទោះបីជាពួកគេមានជម្លោះជាមួយ បពវ ក៏ដោយ ក៏បញ្ហារវាងបក្សទាំងពីរមិនមែនជា "ទំនាស់" ទេ ។ ស អាចមានសង្ឃឹមថា ទីចុងបំផុត បពវ មុខជានឹងផ្តល់ជំនួយជាសម្ភារៈជាដុំកំភួនដល់កុប្បកម្មកម្ពុជាជាមិនខាន ល្អិតណារូបគេអះអាងថា នឹងគ្មានមុខព្រួញវាយទៅលើសម្តេចសីហនុទេនោះ តែមានបំណងដើម្បីរៀបមូលដ្ឋានសំរាប់ប្រឆាំងចក្រពត្តិនិយមអាមេរិក នៅពេលរដ្ឋប្រហារប្រឆាំងសម្តេចសីហនុដែលបានគិតទុកជាយូរមកហើយ និងការឈ្លានពានរបស់អាមេរិកមកលើកម្ពុជា ទីបំផុតត្រូវបានមកដល់នោះ ។ ស អាចលើកហេតុផលថា គឺជាផលប្រយោជន៍របស់ភាគីវៀតណាម ដើម្បីជួយអ្នកបដិវត្តន៍កម្ពុជា ពីព្រោះពួកគេធ្វើសកម្មភាពប្រឆាំង លន់ ណុល ដើម្បីការពារ និងអភិវឌ្ឍន៍កម្លាំងបដិវត្តន៍ផ្ទាល់របស់ពួកគេ និងដើម្បីបង្កើតមូលដ្ឋានសំរាប់ធ្វើសម្ព័ន្ធភាពប្រឆាំងអាមេរិកនាពេលអនាគត ជាមួយសម្តេចសីហនុ ។ ការនេះអាចជួយបដិសេធថាកម្ពុជាមិនមែនជាមូលដ្ឋានរបស់អាមេរិកដើម្បីវាយប្រហារទៅលើវៀតណាមទេ ។ យោងតាមទស្សនៈវិស័យនេះ បដិវត្តន៍កម្ពុជាគ្រាន់តែបំពេញភារកិច្ចចាត់តាំងឱ្យខ្លួនដោយ បកត នាសង្គ្រាមឥណ្ឌូចិនលើកទី ១ តែប៉ុណ្ណោះ ពោលគឺៈ បញ្ចៀសការគំរាមកំហែងនៃការវាយប្រហារទៅលើវៀតណាម ដោយអាយ៉ងរបស់អាមេរិកនៅកម្ពុជា ។ ការនេះ ក៏ជាការធ្វើតាមបញ្ញត្តិរបស់ បពវ ដែលថាបដិវត្តន៍ប្រជាធិបតេយ្យប្រជាជាតិប្រជាជន តម្រូវឱ្យមានរណសិរ្សរួបរួមជាតិប្រឆាំងចក្រពត្តិមួយ ដែលក្នុងនោះរួមមានសមាសភាពអ្នកស្នេហាជាតិចេញមកពីក្នុងចំណោមវណ្ណៈសក្តិភូមិ តែបដិសេធពួកភ្នាក់ងារដាច់ថ្លៃរបស់ពួកចក្រពត្តិនិយម ។*

### *វៀតណាម ១៩៦៨-១៩៦៩៖ បច្ច័យនៃការវាយសំរុក តែត*

*ជាសត្យានុម័ត ការទទួចរបស់ នួន និង ស ថាបដិវត្តន៍កម្ពុជា កំពុងឈានឡើងកាន់តែខ្លាំងនោះ មិនមែនជាមូលដ្ឋានគួរឱ្យជឿទុកចិត្តបាន ដែលត្រូវយកមកពិភាក្សានោះទេ ។ ជោគជ័យមានកំរិតនៃកុប្បកម្ម ឆ្នាំ ១៩៦៨-១៩៦៩ នៅកម្ពុជា ច្បាស់ណាស់មិនបានសំរេចដូចអ្វីដែលជាប្រភេទនៃការធ្វើឱ្យតាំងដោយឆាប់រហ័ស និងជាទូទៅ នៃរដ្ឋបាលខ្លាំង ដែល បពវ សំរេចបាននៅភាគខាងត្បូងក្នុងឆ្នាំ ១៩៦៨-១៩៦៩ នោះទេ ។ វាបានធ្វើឱ្យឈឺចាប់ដោយសើៗប្រឆាំងរបបសង្គម តែទាំងនេះវាមិនខ្លាំង*

និងពលដាលដូចអ្វីដែលបានប្រឆាំងទៅនឹងរបប យៀម ឡើយ ។ វាជាការបំផ្លាញដ៏ធ្ងន់ធ្ងរ សំរាប់សីហនុ និង លន់ ណុល និង បានបង្កើនការចាប់អារម្មណ៍ទូទៅ ថារបបសង្គមកំពុងមានវិបត្តិ តែនៅជនបទវាមិនទាន់រលំជាផ្ទាំងៗក្រោមការត្រួតត្រានៃបដិវត្តន៍ ដូចនៅភាគខាងត្បូងវៀតណាមទេ ។ នេះអាចបណ្តាលមកពីភាពខុសគ្នានៃរចនាសម្ព័ន្ធវណ្ណៈសង្គមជនបទពីរ នៅពេលការតស៊ូអាវុធបានផ្ទុះឡើង និងដោយសារសម្តេចសីហនុទទួលបានភាពអ្នកជាតិនិយម និងភាពស្របច្បាប់នៃរាជានិយម ជាង ខ្មោច យៀម តែប៉ុណ្ណោះ ។ កត្តាទាំងនេះ អាចធ្វើឱ្យមានការលំបាកកាន់តែខ្លាំង ដើម្បីជំរុញការរំកើបបដិវត្តន៍នៅជនបទកម្ពុជា ឬការប្រើភេរវកម្ម ដើម្បីប្រែក្លាយជញ្ជីងនៃការភ័យខ្លាច ដែលអំណោយផលដល់ពួកកុម្មុយនីសនៅទីនោះទេ ។ ក្នុងន័យនេះ វៀតណាម (និងចិន) ត្រូវបានបញ្ជាក់ថា ត្រឹមត្រូវ ។

យ៉ាងណាក៏ដោយ ក្នុងក្របខ័ណ្ឌនៃឆ្នាំ ១៩៦៩ សុទិដ្ឋិនិយមរបស់ ស-ទូន មិនទាន់ជាឧទាហរណ៍មួយទៀតនៃការឆ្លើយតបចំពោះកម្ពុជា ទៅនឹងគំនិតកុម្មុយនីសវៀតណាមបានទេ ។ វាស្របទៅនឹងសេចក្តីថ្លែងរបស់ពួកកុម្មុយនីសវៀតណាម ដែលថាបដិវត្តន៍នៅភាគខាងត្បូង ក៏បានជំជាត់ឡើងកាន់តែខ្លាំងនោះទេ ទោះបីជាមានភស្តុតាងជាច្រើន ដែលថាពួកគេទទួលរងនូវមហន្តរាយប្រកបដោយការឈឺចាប់បញ្ច្រាសមកវិញ ចាប់ពីជោគជ័យបឋមនៃការវាយសំរុក តែត នៅដើមឆ្នាំ ១៩៦៨ មកក៏ដោយ ។ ឡូហ្សិកនៃសុទិដ្ឋិនិយមបដិវត្តន៍ របស់ បពវ នៅចំពោះមុខនៃការថយក្រោយ មានន័យថាលែងមានហេតុផលអីទៀតដើម្បីបោះបង់ចោលការតស៊ូដោយអាវុធនៅកម្ពុជា ជាងការទទួលស្គាល់ថា តែត គឺជាបរាជ័យមួយនៅវៀតណាមនោះទេ ។

ជាក់ស្តែងគឺថា នៅខែឧសភា ឆ្នាំ ១៩៦៨ កម្លាំងអាមេរិក និងរដ្ឋាភិបាលព្រៃនគរ បានវាយបកវិញ ដោយការសង់សិក នៅជនបទនៃភាគខាងត្បូងវៀតណាម ហើយពេញមួយឆ្នាំកន្ទះបន្ទាប់មក ការវាយបកវិញនោះបានធ្វើឱ្យពួកគេបង់តម្លៃយ៉ាងធ្ងន់ធ្ងរបំផុត ។ ប្រពលកម្មនៃហឹង្សាប្រឆាំងបក្ស និងពួកអ្នកគាំទ្របានឡើងដល់កំរិតមិនធ្លាប់ជួបប្រទះពីមុនមក ជាសញ្ញាសំគាល់នៃចំណុចបត់មួយក្នុងវិចារណញ្ញាណរបស់ប្រជាជននៅភាគខាងត្បូង ការលេចធ្លោឡើងនាពេលមុននៃភាពរំភើបរបស់កសិករ ត្រូវបានជំនួសដោយការខកចិត្ត ដូចដែលបានសំដែងឱ្យឃើញជាសាធារណៈ នូវការធ្លាក់ចុះយ៉ាងឆាប់រហ័សនៃការគាំទ្រថ្នាក់ភូមិចំពោះពួកកុម្មុយនីស ។ ភាពព្រៃផ្សៃនៃសកម្មភាពយោធារបស់អាមេរិក និងរដ្ឋាភិបាល និងសន្តិការូបនីយកម្មដោយឃោរឃៅ បានធ្វើឱ្យពាយអស់ប្រជាជនយ៉ាងច្រើននៅជនបទ និងបណ្តាលឱ្យមានការខូចខាតយ៉ាងរង្គំរង្គាលដល់អង្គភាពយោធាកុម្មុយនីសភាគខាងត្បូងក្នុងការប្រយុទ្ធគ្នាយ៉ាងខ្លាំងក្លា ។ បពខ បានដឹងច្បាស់ពីបញ្ហារបស់ បពវ នៅភាគខាងត្បូង យ៉ាងហោចណាស់ដោយសារកម្មាភិបាល បពខ នៅតំបន់ព្រំដែននៃភូមិភាគបូព៌ា និង ឦសាន អាចសង្កេតឃើញកងកម្លាំងវៀតណាម ក្នុងនេះរួមមានទាំងកម្មាភិបាលដឹកនាំ បពវ ជាច្រើននាក់ផង បានមកប្រមូលផ្តុំគ្នានៅក្នុងទឹកដីកម្ពុជា ដើម្បីគេចពីការបំផ្លាញថែមទៀតនោះ ។

យ៉ាងណាក៏ដោយ បពវ ទទូចថា អ្វីៗបានប្រព្រឹត្តទៅដោយល្អ ថែមទាំងល្អជាងពេលណាៗទាំងអស់ផង ។ ពួកគេបានប្រកាសនៅខែមិថុនា ឆ្នាំ ១៩៦៨ ថា តែត បានបង្ហាញថា កម្លាំងនយោបាយរួមផ្សំអាវុធ របស់ប្រជាជនវៀតណាម មិនអាចអ្នកណាយកឈ្នះបានទេ ព្រមជាមួយខ្មាំងរបស់ពួកគេស្ថិតក្នុងស្ថានភាពជាអ្នកចាញ់ និងបដិវត្តន៍ក្នុងស្ថានភាពជាអ្នកឈ្នះនោះ ។ នៅខែតុលា ឆ្នាំ ១៩៦៨ ពួកគេបាននិយាយថា - ថ្វីបើមានការលំបាកជាបណ្តោះអាសន្ន"ក៏ដោយ - បដិវត្តន៍មានការលោតផ្លោះទៅមុខ ហើយរដ្ឋាភិបាលទីក្រុងព្រៃនគរអាចរលំដួលភ្លាមៗបាន ល្គឹកណាបក្សនៅតែរក្សាគោលជំហររឹងមាំនោះ។ ពួកគេបានបដិសេធមតិណាដែលថា សេចក្តីសំរេចវាយសំរុក តែត របស់ពួកគេគឺខុស ឬឥតបានផលអ្វីនោះ ។ នៅខែធ្នូ ឆ្នាំ ១៩៦៨ បពវ ភាគខាងត្បូង បានស្នើឱ្យបក្សជនទទួលស្គាល់ថា តាមរយៈ តែត បដិវត្តន៍សំរេចបាន"ជោគជ័យដ៏ធំ និងមិនធ្លាប់មាន លើគ្រប់វិស័យ" ប្រែប្រឡាស់សភាពការណ៍អំណោយផលដល់បដិវត្តន៍ និងបង្កើតលក្ខណៈសម្បត្តិសំរាប់ជ័យជំនះទីចុងបំផុត ។

ក្នុងខែកក្កដា ឆ្នាំ ១៩៦៩ ពួកគេបានអួតអាងអំពី តែត ម្តងទៀត ថាបានបង្កើតចំណុចរបត់ជាវិជ្ជមានមួយនៃសង្គ្រាម ស្តីបន្ទោសថាការលំបាកដែលបានកើតឡើងតាំងពីការវាយសំរុកនោះទៅលើកម្មាភិបាល "លំអៀងស្តាំ" ដែលគ្មានជំហរដាច់ខាតដោយបានវាយតម្លៃខ្មាំងខ្ពស់ពេក និងមើលស្រាលដល់សមត្ថភាពបដិវត្តន៍របស់មហាជន ។ អ្វីៗនឹងត្រូវបានដោះស្រាយ បើសិនជាពួកគេបញ្ឈប់ការមើលឃើញតែការលំបាក ហើយជាជំនួសកំណត់យកគោលជំហរវាយសំរុកឱ្យជាប់នោះ ។ នេះគឺស្របទៅនឹងអ្វីដែលមានចែងក្នុងការប្រកាសរបស់វៀតណាម អំពីការចាំបាច់នៃកុប្បកម្មហឹង្សានៅភាគខាងត្បូងវៀតណាម ដូចដែលមានចែងនៅក្នុងសុន្ទរកថារបស់អ្នកទ្រឹស្តីនយោបាយ បពវ ទ្រឿង ជីញ ដែលបានចែកផ្សាយដ៏ទូលំទូលាយពេញមួយឆ្នាំ ១៩៦៩ ។ គេបានប្រកាសថា ហឹង្សាបដិវត្តន៍ប្រជាជនដោយរួមផ្សំការតស៊ូដោយអាវុធ និងការតស៊ូនយោបាយ - ដោយយកការតស៊ូដោយអាវុធជាសំខាន់ - គឺជាផ្លូវតែមួយគត់ ដើម្បីធ្វើបដិវត្តន៍ប្រជាធិបតេយ្យប្រជាជាតិប្រជាជន ដើម្បីដោះស្រាយទំនាស់រវាងប្រជាជននិងពួកចក្រពត្តិ និងរវាងកសិករនិងវណ្ណៈម្ចាស់ដីសក្តិភូមិ ។

ម្យ៉ាងទៀត ការលើកឡើងវិញនូវជម្លោះរវាងម្ចាស់ដីនិងកសិករ ថាជាមូលដ្ឋាននៃបដិវត្តន៍នៅភាគខាងត្បូង បានបញ្ជាក់ដល់ជនកម្ពុជាថា ពួកគេមិនត្រូវប្តូររូបមន្តនៃទំនាស់នៅជនបទដែល បពខ បានចម្លងមកពី បពវ នៅឆ្នាំ១៩៦០ នោះទេ។ ជីញ បានប្រកាន់យ៉ាងខ្ជាប់ខ្ជួននូវការធ្វើមិនដឹងមិនឮ អំពីកសិករភាវូបនីយកម្មវណ្ណៈកណ្តាលកើនឡើងនៅជនបទនៃភាគខាងត្បូងវៀតណាម ដែលនាំឱ្យសន្មត់ថាទំនាស់រវាងម្ចាស់ដី និងកសិករ កាន់តែលែងអនុវត្តន៍បាននៅភាគខាងត្បូងវៀតណាមជាងនៅកម្ពុជាទៅទៀត ។ កម្មាភិបាល បពវ ខ្លះ បានដឹងថាឥរិយាបទរបស់កសិករមិនបានយល់ស្របទៅនឹងទ្រឹស្តីរបស់ ជីញ ទេ តែពួកគេត្រូវបានប្រាប់ឱ្យធ្វើបដិវត្តន៍ ដោយឈរលើការវិភាគមួយដែលហួសសម័យ មិនចំកន្លែង ។ បើសិនជាធាតុពិតវណ្ណៈនៅជនបទ លែងជាបញ្ហាតទៅទៀតហើយ ទោះបីចំពោះប្រធានទ្រឹស្តី បពវ នោះ ហេតុអ្វីក៏ បពខ ស្រាប់តែចាប់អារម្មណ៍ទៅលើវាក្លាមនោះ?

អ្វីដែល ស និង នួន ធ្វើការវាយតម្លៃលើការអនុវត្តន៍ទ្រឹស្តីវៀតណាមមកលើកម្ពុជារបស់ពួកគេ គឺថាពួកគេអាចធ្វើតាមឡូហ្សិក បពវ ដើម្បីសន្និដ្ឋានថា ការជំរុញវាឱ្យមានសុពលភាពនិងបញ្ជាក់អំពីជំនឿបដិវត្តន៍ នៃពួកអ្នកអនុវត្តន៍ ដូចនៅព្លៃសាន និងនិរតី ។ នៅទីណាដែលធ្វើមិនបានសំរេច ដូចជានៅឧត្តរ, បូព៌ា និង ពាយ័ព្យ នោះគឺមិនមែនដោយសារវាដំណើរការមិនបាននោះទេ តែគឺដោយសារមានអ្វីមិនធម្មតាដែលកើតឡើងចំពោះពួកអ្នកដែលត្រូវបានចាត់តាំងដើម្បីធ្វើឱ្យវាដំណើរការបាន ។ ជាការចំអក អ្វីដែលហាក់ដូចជាច្បាស់នោះ គឺថាៈ ការពន្យល់មិនមានអ្វីទាក់ទងទៅនឹងរចនាសម្ព័ន្ធវណ្ណៈជនបទទេ ។ គ្មានអ្វីត្រូវគ្នារវាងការពន្យល់នេះ និងជោគជ័យនៃបដិវត្តន៍ទេ ។ នៅទីណា - យោងតាមការវិភាគវណ្ណៈជាសត្យានុម័ត - ការវិភាគអំពីការប្រឆាំងគ្នារវាងម្ចាស់ដីនិងកសិករ អាចអនុវត្តបានកំរិតណាមួយ ដូចនៅពាយព្យ និងដោយកំរិតណាមួយនៅបូព៌ា កុបកម្មមិនទទួលបានជោគជ័យទេ ដោយប្រៀបធៀប ។ ផ្ទុយទៅវិញ វាធ្វើបានល្អជាងនៅកន្លែងណាដែលម្ចាស់ដីនិយមមិនទាន់កើតមានជាទូទៅនៅឡើយ ដូចជានៅព្លៃសាន និងនិរតី ជាដើម ។ ជោគជ័យនៅព្លៃសាន ជាពិសេស ហាក់ដូចជាដើម្បីបញ្ជាក់ថាទស្សនៈវិស័យរបស់ បពវ ស្តីពីសក្តានុពលបដិវត្តន៍នៃជនជាតិភាគតិចខ្ពង់រាប គឺមានពិតនៅកម្ពុជាក៏ដូចនៅវៀតណាម ។ ប៉ុន្តែនៅកន្លែងដទៃទៀត សភាពការណ៍មិនបញ្ជាក់ក្នុងន័យបដិវត្តន៍ទេ យ៉ាងហោចណាស់យោងតាមនិយមន័យរបស់ បពខ ដែរ ដែលថាៈ ទោះបីជាមានវិបត្តិសង្គមនយោបាយក៏ដោយ ក៏ បពខ មិនអាចធ្វើឱ្យបដិវត្តន៍ប្រជាធិបតេយ្យប្រជាជាតិប្រជាជនកើតឡើងបានដែរ ។

តាមប្រភពវៀតណាមឱ្យដឹង ពេល ស ស្ថិតនៅ ហាណូយ រូបគេបានសុំយោបល់ថាតើពួកកុម្មុយនីសខ្មែរត្រូវធ្វើយ៉ាងដូចម្តេច និងបានលើកឡើងពីបញ្ហាជំនួយយោធាជាថ្មីម្តងទៀត ។ ទោះបី បពខ បានធ្វើការកែសម្រួលគោលជំហររបស់ខ្លួនចំពោះសម្តេចសីហនុក៏ដោយ ក៏បក្សទាំងពីរនៅតែស្ថិតនៅឆ្ងាយពីគ្នាដដែល ។ វៀតណាមបានបន្តស្នើឱ្យ បពខ រិះរកផ្លូវណា

*មួយដើម្បីសហការជាមួយ លន់ ណុល ក្នុងសេចក្តីសង្ឃឹមថា ការនេះអាចនៅមានលទ្ធភាពសង្គ្រោះផ្លូវដឹកជញ្ជូនកស្តុភាររបស់ចិនបាននៅឡើយ ។ នៅក្នុងពេលប្រជុំរបស់ ស ជាមួយ ឡេ យន់ មេដឹកនាំវៀតណាមរូបនេះនៅតែប្រកាន់គោលជំហរជាមូលដ្ឋានរបស់ បពវ ដែលបានលើកឡើងនៅក្នុងឆ្នាំ ១៩៦៥ ដដែល នោះគឺៈ ចំពោះមុខត្រូវជៀសវាងកុំធ្វើការតស៊ូដោយអាវុធនៅកម្ពុជា ផ្ទុយទៅវិញ ពួកកុម្មុយនីសកម្ពុជាត្រូវរង់ចាំរហូតដល់វៀតណាមដណ្តើមបានជ័យជំនះរបស់គេសិន បន្ទាប់មកបក្សទាំងពីរ អាចសហការគ្នាដើម្បីវាយបុកមួយព្រឹប ហើយរំដោះភ្នំពេញតែម្តង ។ វៀតណាមមិនផ្តល់អាវុធឱ្យទេ ដោយបញ្ជាក់ថាជនកម្ពុជាប្រាកដជាមានការលំបាកទប់ទល់ចំពោះការតស៊ូដោយអាវុធ ដោយពុំមានការជួយមួយបែបនោះទេនោះ ។ ស បានឆ្លើយតបទៅវិញ ដូចការវិភាគរបស់ បពវ ដែល នួន ធ្លាប់បានឆ្លើយតបទៅ ង្វៀង វ៉ាន់ លីញ ក្នុងឆ្នាំ ១៩៦៨ ដែរ ពោលគឺ បក្សកម្ពុជា "ត្រូវតែធ្វើការតស៊ូដោយអាវុធ ពីព្រោះសភាពការណ៍ជាក់ស្តែងមិនអនុញ្ញាតឱ្យធ្វើអ្វីផ្សេងពីនេះទេ ។ បើពួកគេមិនធ្វើទេ ...នោះពួកគេនឹងត្រូវរលាយ ។ តែបើពួកគេមានះក្នុងការតស៊ូនេះ វត្តមានរបស់ពួកគេនឹងត្រូវធានាថានឹងមិនសាបសូន្យទេ" ។*

### *រដ្ឋប្រហារ និងការទន្ទ្រានកាន់កាប់*

*បន្ទាប់ពីការទស្សន៍ទាយអស់រយៈពេលជាច្រើនឆ្នាំមក សម្មតិកម្មទាំងអស់នេះត្រូវបានជំនួសដោយរដ្ឋប្រហារប្រឆាំងសម្តេចសីហនុ និងការឈ្លានពានរបស់សហរដ្ឋអាមេរិកមកលើកម្ពុជា ដែលបានកើតមានឡើងនៅទីចុងបញ្ចប់នោះ ។ សម្តេចត្រូវបានទម្លាក់ពីអំណាចដោយ លន់ ណុល, សរិមតៈ និងពួកអ្នកដទៃទៀត នៅថ្ងៃទី ១៨ ខែមីនា ឆ្នាំ ១៩៧០ ដែលជាលទ្ធផលនៃអ្វីដែលសម្តេចសីហនុ បពវ និង បពខ បានចោទ យ៉ាងហោចណាស់ជាសាធារណៈ ថាជាអំពើក្បត់ធ្វើឡើងដោយភ្នាក់ងារសេអ៊ីអាអាមេរិក ដូច្នេះការណ៍នេះ បានលើកតម្កើងទស្សនៈដើមរបស់ បកត ការវិភាគនាពេលកន្លងមករបស់ បពវ និងជាគោលជំហរឥតងាករេរបស់ បពខ ដែលវិភាគថា នៅទីចុងបំផុតចក្រពត្តិអាមេរិកត្រូវដឹកនាំកម្លាំងនៅពីក្រោយនយោបាយនៅកម្ពុជា ។ ទោះបីជាការរៀបរាប់របស់ប្រវត្តិវិទូខ្លះ បានផ្តល់ការឯកភាពចំពោះការចោទប្រកាន់ថាជាការចូលពាក់ព័ន្ធរបស់ពួកសេអ៊ីអាក៏ដោយ ក៏គ្មានភស្តុតាងយកមកបញ្ជាក់បានទេ ។ ប្រាកដណាស់ដែលថានៅចុងឆ្នាំ ១៩៦៩ - ដើមឆ្នាំ ១៩៧០ រដ្ឋបាលអាមេរិក និងរដ្ឋាភិបាលទីក្រុងព្រៃនគរ ហាក់ដូចជាមានការសប្បាយចិត្ត ដែលបានឃើញថាសម្តេចសីហនុ បានបន្តប្តេជ្ញាកាត់បន្ថយវត្តមានវៀតណាម ដោយធ្វើការរួមផ្សំការគៀបសង្កត់ខាងយោធាកាន់តែខ្លាំង តាមរយៈ លន់ ណុល និងបង្កើនការធ្វើការងារទូតដោយហ្មឺងម៉ាត់ដោយផ្ទាល់ព្រះអង្គនោះ ។ ការគៀបសង្កត់ខាងយោធា បានតម្លើងថ្នាក់ជាមួយប្រតិបត្តិការមួយចំនួនដែលបានធ្វើឡើង នៅខែធ្នូ ឆ្នាំ ១៩៦៩ ។ នៅខែកុម្ភៈ ឆ្នាំ ១៩៧០ អង្គភាពរបស់ លន់ ណុល ដោយសហប្រតិបត្តិការជាមួយកងកម្លាំងព្រៃនគរ បានបាញ់ផ្លោងនិងទម្លាក់គ្រាប់បែក លើជំរកនានានៅភូមិភាគបូព៌ា រួចហើយចូលទៅដល់ក្នុងជំរកទាំងនោះដើម្បីសុំឱ្យវៀតណាមចាកចេញ ។ ការណ៍នេះបានធ្វើឡើងស្របគ្នានឹងដំណើរទស្សនៈកិច្ចទៅកាន់បរទេសមួយរបស់សម្តេចសីហនុ ដែលបាននាំព្រះអង្គទៅប្រទេសបារាំងមុនគេ បន្ទាប់មកសហភាពសូវៀត និងមានគំរោងបន្តទៅកាន់ប៉េកាំងទៀត ។ នៅប្រទេសបារាំង សម្តេចបានបញ្ជាក់ថាលោកមានបំណងសុំការគាំទ្ររបស់សូវៀត និងចិន ដើម្បីជួយព្រះអង្គបញ្ចុះបញ្ចូលវៀតណាមឱ្យកាត់បន្ថយជាអតិបរមានូវជំរករបស់ពួកគេ បើមិនអាចដកចេញទាំងស្រុងទេនោះ ។ ព្រះអង្គត្រូវបានដកចេញពីដំណែង ពេលព្រះអង្គហៀបតែនឹងចេញដំណើរពីមូស្គូទៅកាន់ប្រទេសចិនហើយនោះ ។*

*ទោះបីជាជាប់ពាក់ព័ន្ធ ឬមិនជាប់ពាក់ព័ន្ធ ជាមួយរដ្ឋប្រហារក៏ដោយ ក៏សហរដ្ឋអាមេរិកមានប្រៀបខាងយោធារួចទៅហើយ ។ នៅថ្ងៃទី ១ ខែឧសភា កងទ័ពថ្មើរជើងអាមេរិក ជូនដំណើរដោយកងកម្លាំងនៃរបបវៀតណាមព្រៃនគរ បានឆ្លងព្រំដែនចូលទៅក្នុងប្រទេសកម្ពុជា ដើម្បីវាយប្រហារជំរក និងផ្លូវដឹកជញ្ជូន របស់វៀតណាម ។ កងទ័ពថ្មើរជើងអាមេរិក បានដកថយពីកម្ពុជាទៅវិញ នៅថ្ងៃទី ១ ខែកក្កដា ឆ្នាំ ១៩៧០ ទោះបីជាកងទ័ពអាកាសអាមេរិកនៅតែបន្តទម្លាក់គ្រាប់បែកលើប្រទេស*

នេះ អស់រយៈពេលជាង ៣ ឆ្នាំ ក្រោយមកទៀតក៏ដោយ ហើយកងទ័ពព្រៃនគរបានបន្តធ្វើប្រតិបត្តិការឆ្លងកាត់ព្រំដែនចូលក្នុងទឹកដីកម្ពុជា រហូតដល់ចុងឆ្នាំ ១៩៧២ ។

បន្ទាប់ពីបាននិយាយប្រាប់ ស និង នួន អស់រយៈពេលជាងពីរឆ្នាំមកហើយ ថានយោបាយរបស់ពួកគេខុសមក វៀតណាម និងចិន បានផ្តល់ព័ត៌មានដល់ ស-នួន ថា ការធ្វើការតស៊ូប្រដាប់អាវុធរបស់ពួកគេ នៅឆ្នាំ ១៩៦៨ គឺត្រឹមត្រូវ ។ អាកប្បកិរិយារបស់ បពវ ចំពោះភាពសកម្មប្រយុទ្ធរបស់ពួកកុម្មុយនីសកម្ពុជាបានប្តូរ ១៨០ អង្សារ ដោយកោតសរសើរកុប្បកម្មរបស់ពួកគេមុនពេលរដ្ឋប្រហារ ដោយបានធ្វើឱ្យមានការធានាថាប្រជាជនកម្ពុជា បានទទួលការហ្វឹកហ្វឺនបានល្អហើយសំរាប់ការតស៊ូបដិវត្តន៍ ហើយពួកគេមានប្រៀបលើចក្រពត្តិនិយម និង លន់ ណុល ជាស្រេចទៅហើយ ។

ការនេះបានផ្តល់នូវវេទិកាដែល ស អាចធ្វើសេចក្តីប្រកាសចំឡែកៗ អំពីលទ្ធផលដោយសព្វមុខនៃការតស៊ូប្រដាប់អាវុធរបស់អង្គការ រហូតមកដល់ឆ្នាំ ១៩៧០ ដែលជាការចម្លងចេញមកពីអ្វីដែល បកត បានបំផ្លើសតួលេខក្នុងពេលសង្គ្រាមឥណ្ឌូចិនលើកទី ១ ដើម្បីផ្តល់ដល់បដិវត្តន៍កម្ពុជានូវកម្លាំងកាន់តែខ្លាំងជាងអ្វីដែលពួកគេមានទៅទៀត ។ ស បានអះអាងថានៅពេលរដ្ឋប្រហារ អង្គការមាន"ទ័ពស្រួច"នៅទូទាំងប្រទេស ដែលអាចប្រមូលជាអង្គភាពបានចំនួន ៤០០ នាក់ បូកនឹងកងស្វ័យត្រាណប្រមាណ ៥០ ០០០ នាក់ ដែលបានដឹកនាំធ្វើសង្គ្រាមប្រជាជន ដែលអាចនិយាយបានថាជាសង្គ្រាមឈ្លបនោះ ។ រូបគេក៏បានប្រកាសផងដែរថា រហូតដល់ឆ្នាំ ១៩៧០ បក្សមានសមាជិកចំនួន ៤០០០ នាក់ និងប្រជាជនចំនួន ៦០ ០០០ នាក់ ស្ថិតក្រោមការត្រួតត្រាខាងរដ្ឋបាលផ្ទាល់របស់ពួកគេ នៅក្នុងរបស់ដែលហៅថា "មូលដ្ឋានដែលគួរឱ្យទុកចិត្តបាន", ប្រជាជនចំនួន ៣០០ ០០០ នាក់ ស្ថិតនៅក្នុង"មូលដ្ឋានឈ្លបប្រទាញប្រទង់" និងចំនួន ៧០០ ០០០ នាក់ ទៀត ស្ថិតនៅក្នុងបរិវេណដែលពួកគេអាចធ្វើសកម្មភាពបាន ហៅថា "តំបន់ឈ្លប" ។ តួលេខពិតប្រាកដនៃកម្លាំងយោធាគឺ ប្រហាក់ប្រហែលទៅនឹងការប៉ាន់ប្រមាណរបស់ភ្នាក់ងារស៊ើបការណ៍របស់ លន់ ណុល ដែលថាមាន ២៤០០ នាក់នោះ ។ ទាំងនេះអាចបំប៉ោងដោយរាប់បញ្ចូលដោយកាន់ច្រឡំនូវកងឈ្លបនៅឆ្លៀសាន ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ បពវ ដែលមិនមែនជារបស់អង្គការរបស់ ស នៅទីនោះទេ ។ ទោះបីជាក្នុងករណីណាក៏ដោយ នៅក្នុងខែមីនា ឆ្នាំ ១៩៧០ បពខ មានកងទ័ពតិចជាងចំនួនដែល បកត មានយុទ្ធជនកម្ពុជារបស់គេ នៅទូទាំងប្រទេសក្នុងឆ្នាំ ១៩៥៤ ទោះបីជាបក្សជនពិតប្រាកដមានចំនួន ៤០០០ នាក់ក៏ដោយ ក៏ចំនួននេះកើនឡើង ២ ដង នៃចំនួនដែលមាននៅពេលសន្និសិទទីក្រុងហ្សឺណែវ ។

## *សេចក្តីសន្និដ្ឋាន*
## *សង្គ្រាមប្រជាជន, បដិវត្តន៍ និង ប្រជាប្រិយភាព,*
## *ឆ្នាំ ១៩៧០-១៩៧៥*

### *អន្តរាគមន៍មិនសំរេចរបស់វៀតណាម*

*ទោះបីជា បពវ ធ្វើការវាយតម្លៃឡើងវិញដោយទន់ភ្លន់ អំពីសភាពការណ៍កម្ពុជាបន្ទាប់ពីរដ្ឋប្រហារក៏ដោយ ក៏ការទាក់ទងរវាងបក្សទាំងពីរមិនត្រូវបានកែលំអទេ ។ ជាការចំអក ស្រាប់តែភ្លាមៗ នោះ បពវ ផ្តល់ការគាំទ្រដោយឥតសំចៃដល់កម្ពុជា ។ ទាំងនេះបានធ្វើឱ្យកម្ពុជាផ្ទុះចេញនូវការភិតភ័យ អំពីសេចក្តីសង្ឃឹមរបស់ បពវ ដើម្បីធ្វើឱ្យរស់ឡើងវិញនូវផែនការចាស់របស់បកឥ ស្តីពីឥណ្ឌូចិនរួបរួមគ្នាខាងយោធា និងនយោបាយ ដែលជាសញ្ញាណដែល បពវ នៅតែចង់បានតទៅទៀតនោះ ។*

*ភ្លាមៗបន្ទាប់ពីរដ្ឋប្រហារ វៀតណាមបានផ្តល់ជំនួយយោធាដោយសព្វមុខដល់ បពខ ។ ការណ៍នេះ ស្របគ្នាទៅនឹងការស្នើរបស់ ឡេ យន់ នៅឆ្នាំ ១៩៦៥ ចំពោះ ស ដែលថាកម្លាំងប្រដាប់អាវុធវៀតណាម និងកម្ពុជា រួមបញ្ចូលគ្នាដើម្បីវាយចក្រពត្តិនិយម និងរំដោះភ្នំពេញ បើសិនជាសម្តេចសីហនុត្រូវទម្លាក់ពីអំណាច ។ នេះក៏ជាការឆក់ឱកាសយកប្រៀបលើសេចក្តីស្នើសុំជំនួយយោធាវៀតណាមជាសម្ងាត់ របស់សម្តេចដែល ដោយខ្វាល់នឹងការទម្លាក់ព្រះអង្គចេញពីអំណាច បានបំពេញនូវការសន្យារបស់សម្តេចជាមួយ ម៉ៅ សេទុង ក្នុង ឆ្នាំ ១៩៦៤ ថានឹងដឹកនាំការតស៊ូប្រឆាំងចក្រពត្តិក្នុងករណីមានរដ្ឋប្រហារមួយនោះ ។ យ៉ាងណាក៏ដោយ ស្របតាមសេចក្តីសំរេចរបស់ពួកគេ ក្នុងពេលបក្សជួបជុំគ្នានៅមន្ទីរ ១០០ នាចុងឆ្នាំ ១៩៦៦ នៅហាណូយ ស បានបដិសេធជំនួយរបស់ បពវ ដូចគ្នានិង អៀង សារី និង សុន សេន នៅភូមិភាគឦសាន និង នួន ដែលស្ថិតនៅភូមិភាគបូព៌ាជាមួយ ភឹម នាពេលនោះ ។ ទាំងអស់គ្នាមានសេចក្តីរីករាយ ដែលនៅទីចុងបំផុត វៀតណាម សុខចិត្តផ្តល់អាវុធ និងគ្រាប់រំសេវ ដែលពួកគេតែងតែចង់បានជានិច្ចនោះ តែបដិសេធការស្នើរបស់វៀតណាម ដើម្បីបង្កើត "បញ្ជាការយោធាចំរុះ" និងជំនួយរបស់ បពវ ដើម្បីបង្កើតរចនាសម្ព័ន្ធរដ្ឋបដិវត្តន៍មូលដ្ឋាន ។ ប៉ុន្តែ នៅពេលវៀតណាមចេះតែធ្វើដោយមិនអើពើនឹងអ្វីទាំងអស់ ដោយបញ្ជូនទ័ពនិងកម្មាភិបាលនយោបាយដើម្បីឱ្យទៅរៀបចំកម្លាំងប្រដាប់អាវុធ និងរដ្ឋបាលមូលដ្ឋាននោះ ពួកគេបានសុខចិត្តឱ្យធ្វើទៅចុះ ។ ពួកគេបានសំរេចថា ដោយមិនមានលទ្ធភាពទប់មិនឱ្យពួកវៀតណាមធ្វើយ៉ាងដូច្នេះបាននោះ វាជាការឥតប្រយោជន៍ទេ ដែលធ្វើការប៉ុនប៉ងដើម្បីបញ្ឈប់ពួកគេនោះ ។ ជាជំនួស ពួកគេបានសាកល្បង និងឆក់យកអ្វីដែលចំណេញដល់ពួកគេ ពីសកម្មភាពដែលមិនចង់បាន ពី"ភ្ញៀវដែលមិនបានអញ្ជើញ" នៃបដិវត្តន៍កម្ពុជាទាំងនេះ ។*

*នៅពេលដែលមិនសប្បាយចិត្ត អំពីលទ្ធភាពដែលអាចនឹងត្រូវត្រួតត្រាដោយ បពវ ជនកម្ពុជាបានបន្តអនុវត្តន៍សង្គ្រាមប្រជាជនបែបវៀតណាម និងដើរតាមដំបូន្មានរបស់ ឡេ យន់ កាលពីឆ្នាំ ១៩៦៥ ដោយប្រើឈ្មោះសម្តេចសីហនុជាខែលធ្វើការអំពាវនាវប្រជាជនកម្ពុជា ដើម្បីឱ្យគាំទ្រការតស៊ូរបស់ពួកគេ ។ ស បានទៅប៉េកាំងជាសម្ងាត់ និងសុំឱ្យចិនជួយជំរុញឱ្យសម្តេចសីហនុធ្វើសេចក្តីអំពាវនាវបែបនោះមួយ តែដាច់ខាតមិនឱ្យអ្នកណានិយាយអ្វីអំពីអនាគតសង្គមនិយម ឬកុម្មុយនីសនិយមសំរាប់ប្រទេសកម្ពុជាឱ្យសោះ ។ ដោយមិនបានដឹងអំពីតួនាទីរបស់ ស, នៅថ្ងៃទី ២៣ ខែមីនា ឆ្នាំ ១៩៧០ សម្តេចសីហនុបានប្រកាសអំពីបំណងរបស់ព្រះអង្គដើម្បីបង្កើតរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា (ហ្រ្គុង),រណសិរ្សរួបរួមជាតិកម្ពុជា (ហ្វ៊ុង) និងកងទ័ពរំដោះជាតិ ដើម្បីរំដោះប្រទេសកម្ពុជាពី"របបផ្តាច់ការ និងជិះជាន់ នៃបនក្បត់ និងប្រតិកិរិយាលំអៀងទៅខាងចក្រពត្តិនិយមដឹកនាំដោយ លន់ ណុល"។ ព្រះអង្គបានអំពាវនាវដល់ខ្មែរស្នេហាជាតិទាំងអស់ ឱ្យរត់ចូលព្រៃម៉ាគី ដែលព្រះអង្គសន្យាថានឹងបំពាក់អាវុធ និងផ្តល់ការហ្វឹកហ្វឺនយោធាដល់ពួកគេ ដែលទាំងនេះ ដើមឡើយភាគច្រើនលើសលប់បានមកពីវៀតណាម ។*

ដូច នួន, ស និង ម៉ុក បានទស្សន៍ទាយជាមុនមែន គឺថារដ្ឋប្រហារមានន័យថាសម្តេចសីហនុនឹងចូលខាងពួកគេ ផ្តល់ឱកាសមាសដល់ពួកគេដើម្បីទាញយកចំណេញលើប្រជាប្រិយភាពរបស់សម្តេចនៅជនបទ ដែលសេសសល់ដោយរួបរួមកម្លាំងគ្នានៅពីក្រោយរបស់ដែលហៅថាការដឹកនាំរបស់ព្រះអង្គ ។ ដូចកម្មាភិបាលកុម្មុយនីសកម្ពុជាម្នាក់បានកត់សំគាល់ "បន្ទាប់ពីសុន្ទរកថាថ្ងៃ ២៣ មីនា របស់សម្តេចសីហនុ យើងមិនដែលបានធ្វើការប្រយុទ្ធអ្វីមួយនៅឡើយទេ" ។ សេចក្តីណែនាំនាពេលនោះ គឺ "ត្រូវដកកម្លាំងចេញ... ហើយការនេះ យើងអាចធ្វើបានយ៉ាងស្រួលបំផុត" ។

ក្នុងឋានៈជាប្រមុខរដ្ឋ ហ្រ្គុង និងប្រធាន ហុង សម្តេចសីហនុ បានផ្តល់ដល់ពួកកុម្មុយនីសខ្មែរ នូវមុខមាត់មិនមែនកុម្មុយនីសដែលគួរឱ្យទុកចិត្តបានជាទីបំផុតមិនធ្លាប់មានពីមុនមក តែនៅពីក្រោយព្រះអង្គ គឺជាមុខមាត់ដែលនាំឱ្យពួកបញ្ញាជនទទួលការអប់រំពីប្រទេសបារាំងយល់ខុស មានៈ ខៀវ សំផន ជាឧបនាយករដ្ឋមន្ត្រី ហ្រ្គុង ទទួលបន្ទុកកិច្ចការការពារជាតិ, ហ៊ូ យន់ ជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ កែទម្រង់ជនបទ និងសហករណ៍, និង ហ៊ូ នឹម ជារដ្ឋមន្ត្រីក្រសួងឃោសនា និងអប់រំ ។ នៅថ្ងៃទី ២៦ ខែមីនា ពួកគេបានបំពេញតួនាទី ដោយឆ្លើយតបទៅនឹងសេចក្តីអំពាវនាវរបស់សម្តេចសីហនុ ព្រមទាំងធ្វើសេចក្តីអំពាវនាវប្រកបដោយអំនួតផ្ទាល់របស់ពួកគេ ឱ្យប្រជាជនកម្ពុជា "ចាត់តាំងជាអង្គភាពឈ្លបនិងជាកងកម្លាំងប្រដាប់អាវុធ...និងបង្កើតរដ្ឋអំណាចដ៏ត្រឹមត្រូវមួយ" នៅក្នុងប្រទេស ។

ពួកកុម្មុយនីសខ្មែរ បានព្យាយាមធ្វើឱ្យ ហ្រ្គុង និង ហ៊ុង ដំណើរការស្របទៅនឹងគំរូវៀតណាម ដូចមានចែងនៅក្នុងរដ្ឋាភិបាលបដិវត្តន៍បណ្តោះអាសន្ន និងរណសិរ្សរំដោះជាតិដែល បពវ បានបង្កើតឡើងដើម្បីធ្វើជាយានសំរាប់ប្រមូលមហាជននៅភាគខាងត្បូងវៀតណាម ។ ដូចដែលសមាជិកគណៈកម្មាធិការ ហ៊ុង ម្នាក់ បានរំលឹក, "បក្សកុម្មុយនីសទាំង ឡាយចាំបាច់ត្រូវប្រមូលកម្លាំងទាំងអស់ តាមរយៈ`រណសិរ្សរួបរួមជាតិ`មួយប្រឆាំងសត្រូវសំខាន់បច្ចុប្បន្នរបស់ពួកគេ ដើម្បីឈានទៅដល់ដំណាក់កាលខ្ពស់នៃបដិវត្តន៍ពួកគេ"។ នេះគឺជាតួនាទីរបស់ ហ្រ្គុង និង ហ៊ុង ដែលពួកអ្នកដឹកនាំខ្មែរក្រហមមានតែឈ្មោះ ដូចជា ខៀវ សំផន ជាដើម ត្រូវបានដាក់ឱ្យដើរតួជាផ្នែកមួយដូចគ្នាទៅនឹងអង្គការដែលសហភាគី បពវ របស់ពួកគេបានបង្កើតឡើងនៅភាគខាងត្បូងវៀតណាម ។ ការពិត បក្សកម្ពុជាមិនបានអភិវឌ្ឍន៍សិទ្ធិអំណាចធំដុំណាមួយ សំរាប់ ខៀវ សំផន, ហ៊ូ យន់ និង ហ៊ូ នឹម ទេ ។ បក្សនៅតែមិនទុកចិត្តពួកគេ និងមិនបានពិចារណាថាពួកគេមានលក្ខណៈសម្បត្តិដើម្បីក្លាយជាថ្នាក់ដឹកនាំកុម្មុយនីសបាននៅឡើយទេ ។ ការងារពួកគេ គឺដើម្បីធ្វើឱ្យមតិសម្តេចសីហនុ, ជាតិ និងអន្តរជាតិកក់ក្តៅ អំពីលក្ខណៈរបស់ចលនានៅពេលដែលសេចក្តីសំរេចទាំងអស់ត្រូវបានធ្វើឡើងដោយ ស, នួន, កឹម និងពួកអ្នកដទៃទៀត នៃគណៈកម្មាធិការអចិន្ត្រៃយ៍ចេញមកពីសមាជ បពខ ឆ្នាំ ១៩៦៣ នោះ ។

ក្នុងពេលជាមួយគ្នានេះ វៀតណាមបានធ្វើនូវអ្វីដែលពួកគេគិតថាល្អបំផុតសំរាប់បដិវត្តន៍កម្ពុជាដោយគិតខ្លួនឯងថាទោះបីជា បពខ មានការរំភើបនឹងបដិវត្តន៍ក៏ដោយ ក៏ពួកគេគ្មានសមត្ថភាពទាញយកផលប្រយោជន៍ដោយពេញលេញ លើសភាពការណ៍បានទេ ពីព្រោះពួកគេ "ខ្សោយ ហើយការចាត់តាំងរបស់ពួកគេនៅរយើករយាក"នៅឡើយ។ យោងតាមឯកសារ បពវ ពួកគេបានកំណត់ថា "បេសកកម្មរបស់មិត្តយើង គឺជាបេសកកម្មរបស់យើង"ដោយផ្តល់ដល់បដិវត្តន៍កម្ពុជានូវ"ការដឹកនាំប្រកបដោយប្រសិទ្ធភាពនិងកំរិតខ្ពស់"។ ដោយប្រើសេចក្តីអំពាវនាវរបស់សម្តេចសីហនុ, ខៀវ សំផន, ហ៊ូ យន់ និងហ៊ូ នឹម ដើម្បីធ្វើការឃោសនាក្នុងចំណោមអ្នកស្រុកនៅជនបទ ពួកគេបានកំណត់ផែនការមួយដើម្បីរំដោះខេត្តកម្ពុជាចំនួន ៧ ដែលស្ថិតនៅជាប់ព្រំដែនដែលគ្របដណ្តប់លើខេត្តស្ទើរតែទាំងអស់នៃភូមិភាគបូព៌ា និងឦសាន ដោយសំរេចបានភ្លាមចំនួន ៥ ខេត្តនៃខេត្តទាំង ៧ នេះ ។ ការវាយប្រហាររបស់វៀតណាម បានកំទេចកម្លាំងរស់របស់កងទ័ព លន់ ណុល ពង្រីកតំបន់មូលដ្ឋាន ហើយពួកគេបានបង្កើតហេដ្ឋារចនាសម្ព័ន្ធរដ្ឋាភិបាលកុម្មុយនីសនៅទីនោះ ។ តំបន់កាន់កាប់ត្រូវពួកគេក្តោបក្តាប់មុននឹងផ្ទេរទៅឱ្យពួកកុម្មុយនីសខ្មែរត្រួតត្រា នៅពេលណាមួយមិនច្បាស់លាស់ នាអនាគត ។

ដោយបានទទួលការណែនាំឱ្យប្រើការអនុវត្តន៍របស់ បពវ នៅភាគខាងត្បូងវៀតណាមធ្វើជាគំរូនោះ កម្មាភិបាលវៀតណាមបានបញ្ចុះបញ្ចូល និងប្រមូលជនកម្ពុជា ដើម្បីបង្កើតជាអង្គការរណសិរ្ស, យោធា, រដ្ឋាភិបាល និងសន្តិសុខ នៅថ្នាក់ភូមិ, ឃុំ និងស្រុក ។ ពួកគេបានខិតខំធ្វើយ៉ាងណាជៀសវាងកុំឱ្យមានការចាប់អារម្មណ៍ថា អង្គការទាំងនេះត្រូវបានបង្កើតឡើងតាមការផ្ដើមគំនិតរបស់វៀតណាម ដោយរក្សាការភូតភរថាបដិវត្តន៍កម្ពុជាដឹកនាំដោយសម្ដេចសីហនុ និង ហ៊ុង ។ ពួកគេបានរក្សាវត្តមានជាសម្ងាត់បំផុតនៃអង្គការបដិវត្តន៍កម្ពុជា លើកលែងតែក្នុងចំណោម"វណ្ណៈពលករ" និង"សមាសភាពល្អ" ដទៃទៀតដែលពួកគេចំរាញ់ឱ្យចូលក្នុងសាខាបក្សកុម្មុយនីសប៉ុណ្ណោះ ។ ពួកគេបានបណ្ដុះបណ្ដាលពួកអ្នកជ្រើសរើសថ្មីទាំងនេះឱ្យទៅជាកម្មាភិបាលនយោបាយនិងយោធា ដែលធ្វើសកម្មភាពក្រោមការដឹកនាំរបស់ឋានានុក្រមបក្សវៀតណាម ទោះបីជាពួកគេត្រូវបានសន្មត់ថាជាបណ្ដាញរបស់ពួកកុម្មុយនីសខ្មែរមូលដ្ឋានក៏ដោយ ។ កម្លាំងទាំងនេះមួយចំនួនត្រូវបានបញ្ជូនឱ្យចូលជ្រៅទៅក្នុងកម្ពុជា ដើម្បីផ្ដួលរំលំរដ្ឋបាល លន់ ណុល ដែលជាផ្នែកមួយនៃផែនការបង្កើតតំបន់ឈ្នបនៅភូមិភាគនិរតី, ឧត្តរ និងពាយ័ព្យ ។ ពួកនេះ សកម្មជាពិសេសនៅនិរតី ។ វៀតណាមបានត្រេកអរចំពោះផ្ទាល់ខ្លួនពួកគេថា នៅមូលដ្ឋានពួកអ្នកបដិវត្តន៍ខ្មែរភាគច្រើនលើសលប់"បានឯកភាពពេញទីទៅនឹងអ្វីៗ ដែលពួកគេបានស្នើឡើង" ដែលជាការផ្ដល់ឱ្យវៀតណាមអាចរៀបចំទ្រឹស្ដីរបស់ពួកគេជាប្រព័ន្ធ គូផែនទីនយោបាយរបស់ពួកគេ និងលើកឡើងនូវផែនការសកម្មភាពរបស់ពួកគេបាន ។

ក្នុងរយៈពេលមួយខែក្រោយរដ្ឋប្រហារ បពវ បានត្រួតត្រាលើការក្ដោបក្ដាប់ទឹកដីជម្រៅពី ២០ ទៅ ៦០ គីឡូម៉ែត្រ ក្នុងកម្ពុជា ។ បូករួមជាមួយតំបន់ដទៃទៀតដែលរដ្ឋបាល លន់ ណុល ត្រូវគាំងធ្វើអ្វីមិនកើតនោះ ការនេះបង្កើតបានតំបន់រំដោះមួយដែលមានប្រជាជនមួយលាននាក់ ។ បពវ បានកំណត់ថាការនេះ និងគោលជំហរប្រឆាំងរដ្ឋប្រហាររបស់សម្ដេចសីហនុ មានន័យថាបដិវត្តន៍កម្ពុជាមានការលោតផ្លោះទៅមុខមួយយ៉ាងធំ ដែលអាចជាផ្លូវមួយនាំឆ្ពោះទៅការបង្កើតរដ្ឋាភិបាលបដិវត្តន៍មួយបាន ។ នយោបាយវៀតណាមនៅ ឆ្នាំ ១៩៧០ គឺបង្កើនការខិតខំខាងយោធាផ្ទាល់របស់ពួកគេនៅកម្ពុជា ដោយការជួយជាសម្ភារៈដល់"កម្លាំងស្នេហាជាតិនៅមូលដ្ឋាន" ។ ពួកគេមានផែនការដាក់កងទ័ពវៀតណាមទាំងអស់ចំនួន ៧០ ០០០នាក់ នៅកម្ពុជា និងតម្លើងកងទ័ពកម្ពុជាឱ្យមានកម្លាំងស្មើគ្នានេះដែរ ដើម្បីធានាថាភាគខាងត្បូងវៀតណាម និងកម្ពុជា មានសមរភូមិតែមួយ ដោយ បពវ និងបពខ, កម្លាំងប្រដាប់អាវុធពួកគេ និងប្រជាជនវៀតណាមនិងកម្ពុជា រួបរួមគ្នាតែមួយ ។ តួនាទីដឹកនាំរបស់វៀតណាមនៅតែស្ថិតនៅជាសារសំខាន់ ពីព្រោះ បពខ នៅមិនទាន់ "រៀបចំបានល្អនៅឡើយទេ" ។ បពខ មានការខ្វះខាតកម្មាភិបាលថ្នាក់មេបញ្ជាការនិងថ្នាក់ដឹកនាំ ហើយកម្មាភិបាលដែលមាននៅខ្សោយនៅឡើយៈ ពួកគេមិនមានគំនិតផ្ដួចផ្ដើម ហើយមានការខកខានមិនបានអនុវត្តសេចក្ដីណែនាំរបស់ថ្នាក់លើទេ ។

ទន្ទឹមនឹងនេះ ក្នុងការយកមកបញ្ជាំងឡើងវិញនៃការខកចិត្តរបស់ បកត ក្នុងរយៈពេលសង្គ្រាមឥណ្ឌូចិនលើកទី ១ ការឃោសនាជាសាធារណៈរបស់ បពវ និងរបស់ពួកកុម្មុយនីសខ្មែរ បានសង្កត់ថាវៀតណាមមិនដើរតួផ្ទាល់ក្នុងព្រឹត្តិការណ៍ទេ ជាពិសេសនៅលើសមរភូមិនៃការប្រយុទ្ធគ្នានៅលើដី ។ នៅក្នុងខែមិថុនា ឆ្នាំ ១៩៧០ ទិន្នានុប្បវត្តិបក្សវៀតណាម ញ៉ិនហ្សិន បានកោតស្ញប់ស្ញែងថា"ជាការកម្រនឹងឃើញណាស់ នូវភាពរឹងប៉ឹង រហ័ស និងដាច់ខាត បែបនេះ នៅក្នុងការអភិវឌ្ឍន៍នៃសង្គ្រាមតស៊ូមួយ ដូចនៅក្នុងប្រទេសកម្ពុជា" ដែលទិន្នានុប្បវត្តិនេះបាននិយាយថា ត្រូវបានរៀបចំឡើងដោយប៉ិនប្រសប់ដោយប្រជាជនកម្ពុជាខ្លួនឯង ដើម្បីសំរេចឡើងនូវជំហានលោតផ្លោះដ៏ត្រឹមត្រូវមួយ នៅក្នុងដំណាក់កាលទី១ នៃការប្រយុទ្ធរបស់ពួកគេប្រឆាំងចក្រពត្តិនិយមអាមេរិក និង លន់ ណុល ។ សេចក្ដីប្រកាសមួយរបស់ ខៀវ សំផន ដែលមិនបាននិយាយដល់វៀតណាមនោះបានប្រកាសថា ការតស៊ូរបស់ប្រជាជនកម្ពុជាដើម្បីបង្កើតរដ្ឋអំណាចប្រជាជនត្រូវបានរាលដាលយ៉ាងខ្លាំងក្លា នៅពេលកងកម្លាំងប្រដាប់អាវុធរំដោះជាតិកម្ពុជាបានវិវត្តន៍យ៉ាងលឿន ដោយវាយប្រហារទៅលើទីរួមខេត្តចំនួន ១២ ក្នុងនេះរំដោះបាន ៤ ព្រមទាំងរំដោះទីរួមស្រុកបានជាច្រើននិងភូមិចំនួនរាប់រយ ។ ក្នុងខែសីហា ហ៊ុង បានប្រកាសថា កងកម្លាំងប្រដាប់អាវុធរបស់

ពួកគេបាន"បោសសំអាត" ទាហានខ្មាំង អាមេរិក, លន់ ណុល និង ព្រៃនគរ ចំនួន ៨០ ០០០ ក្បាល និងរំដោះបានទាំងស្រុង ខេត្តកម្ពុជាចំនួន ៥ ។ នៅខែកញ្ញា សេចក្តីថ្លែងការណ៍បាននិយាយថា ពួកគេប្រមូលបានប្រជាជនកម្ពុជាចំនួន ៣ លាននាក់ ក្នុងចំណោមប្រជាជនទាំងអស់ ៧ លាននាក់ ចំណែកកាសែតរបស់ បពវ ញ៉ិនហ្សិន បានអបអរសាទរចំពោះជ័យជំនះយោធាដ៏ខ្នះខ្នារនៅកម្ពុជា ដែលហាក់ដូចជាថាពួកគេសំរេចបានទាំងអស់នេះដោយសារ ហ៊ុង ។ បពវ បានឈរយ៉ាងខ្ជាប់ខ្ជួនលើមាត៌ានេះនៃការផ្តល់នូវភាពស្រាលស្មើកនៃកងទ័ពផ្ទាល់របស់ខ្លួន ទៅកងកម្លាំងប្រដាប់អាវុធកម្ពុជា ក្រោមការដឹកនាំពីចម្ងាយនៃជនបដិវត្តន៍កម្ពុជា ដែលពួកគេបានកោតសរសើរថាបាន"អភិវឌ្ឍន៍ និងពង្រឹងខ្លួនបានយ៉ាងលឿនលើគ្រប់វិស័យ" នោះ ។

នៅខែតុលា ឆ្នាំ ១៩៧០ ការប្រជុំគ្នាមួយរបស់ថ្នាក់ដឹកនាំ បពខ ក្រោមការដឹកនាំរបស់ ស បន្ទាប់ពីរូបគេវិលត្រឡប់មកកម្ពុជាវិញ បានសំរេចប្រែក្លាយរឿងប្រឌិតជាសាធារណៈឱ្យទៅជាការពិត ដោយទទួលយកមកកាន់កាប់ជាបណ្តើរៗ រចនាសម្ព័ន្ធទាំងអស់បង្កើតឡើង និងកម្លាំងកសាងឡើងដោយ បពវ ដោយទប់ទល់លែងឱ្យមានការដឹកនាំជាបន្ថែមទៀតរបស់ បពវ នូវសកម្មភាពបដិវត្តន៍កម្ពុជា ។ តាមប្រភពស៊ើបការណ៍របស់អាមេរិក និង លន់ ណុល ការនេះបានកើតឡើងនៅពេលដែលមានជនកម្ពុជារហូតដល់ ១០០០០ នាក់ ត្រូវបានបំពាក់អាវុធប្រឆាំងរដ្ឋាភិបាល ភាគច្រើននៅភូមិភាគបូព៌ា និងនិរតី ដែលបានរៀបចំជាវរសេនាតូច ចំនួន ២០ ដែលមានសុទ្ធតែខ្មែរ និង វរសេនាតូចចំរុះ កម្ពុជា-វៀតណាម ចំនួន ៥ ។

ជំហានទី ១ ក្នុងការអនុវត្តន៍សេចក្តីសំរេចរបស់ បពខ - ដោយមិនបានផ្តល់ព័ត៌មានដល់វៀតណាម - គឺបញ្ជាទៅភូមិភាគទាំងអស់ឱ្យឈប់អនុញ្ញាតឱ្យ បពវ ធ្វើការជ្រើសរើសកងទ័ពជាតិតទៅទៀតនិងចាប់ផ្តើមបញ្ចុះបញ្ចូលពួកអ្នកបំរើការងារក្រោមបញ្ជារបស់វៀតណាមឱ្យផ្លាស់មកនៅក្នុងអង្គភាពដឹកនាំដោយ បពខ វិញ ។ នេះគឺជា"បញ្ហានៃការដឹកនាំ" ពីព្រោះ ក្នុងឋានៈជាប្រទេសឯករាជ្យ កម្ពុជាត្រូវ"បង្កើតកម្លាំងសំរាប់ប្រើប្រាស់ខ្លួនឯង" ។ ការនេះក៏មានប្រជាប្រិយភាពក្នុងចំណោមកម្មាភិបាលមូលដ្ឋានជាច្រើនដែរ ជាពិសេសមូលដ្ឋានដែលមានប្រជាជនច្រើនរស់នៅ នៃភូមិភាគបូព៌ា និងនិរតី ដែលការប្រដែងគ្នាជាមួយវៀតណាមក្នុងការជ្រើសរើសទ័ព ធនធាន និងអំណាច មានសភាពខ្លាំងក្លា ហើយពេលខ្លះមានហឹង្សាថែមទៀតផង ។

យ៉ាងណាក៏ដោយ ក៏បក្សកម្ពុជានៅតែអំពាវនាវឱ្យមានការសម្របសម្រួលគ្នាដោយជិតស្និទ្ធ និងជួយគ្នាទៅវិញទៅមករវាងអង្គភាពយោធាវៀតណាមនិងកម្ពុជា និងអនុញ្ញាតឱ្យកម្មាភិបាលវៀតណាមផ្តល់ការហ្វឹកហ្វឺកដល់ពួកអ្នកជ្រើសរើសថ្មី ទោះបីជាពួកគេត្រូវបានដាក់ឱ្យនៅក្រោមបញ្ជាការរបស់កម្ពុជាក៏ដោយ ។ ចំពោះការទាក់ទងផ្ទៃក្នុងអង្គការកម្ពុជាបានបញ្ជាក់ឡើងវិញ អំពីគោលការណ៍នៃការឯកភាពគ្នាអំពីគោលបំណងបដិវត្តន៍ជាមួយវៀតណាម តែលើកឡើងអំពីសេចក្តីប្តេជ្ញាទទួលខុសត្រូវលើបញ្ហាផ្ទាល់របស់ខ្លួន។ ដូចមុនពេលរដ្ឋប្រហារដែរ ពួកគេចម្លងតាមគោលជំហរ បពវ របស់វៀតណាម អំពី "ខ្លួនទីពឹងខ្លួន" និង"ខ្លួនឧបត្ថម្ភខ្លួនដោយខ្លួនឯង" ។ ឈរលើមូលដ្ឋាននេះ នៅឆ្នាំ ១៩៧១ បកក បានចាប់ផ្តើមសុំជាផ្លូវការឱ្យវៀតណាមរំសាយ និងប្រគល់មកឱ្យខ្លួន នូវការត្រួតត្រាលើកម្លាំងប្រដាប់អាវុធ និងរចនាសម្ព័ន្ធនយោបាយ ដែលពួកគេបានរៀបចំនៅកម្ពុជា ជាពិសេសនៅភូមិភាគបូព៌ា និងនិរតី ដែលពួកគេមានចំនួនច្រើនជាងគេនោះ ។ ការចរចាជាមួយវៀតណាមនៅចុងឆ្នាំ ១៩៧១ និងពេញមួយឆ្នាំ ១៩៧២ ដើម្បីទទួលបានកិច្ចព្រមព្រៀងពីពួកគេ ទទួលបានជោគជ័យនៅកន្លែងខ្លះ តែនៅកន្លែងខ្លះទៀតមិនទទួលបានទេ ។ ការប្រេះឆារវាងគ្នាបណ្តាលមកពីការណ៍នេះ បាននាំទៅឱ្យមានការប៉ះទង្គិចគ្នាដោយអាវុធម្តងម្កាលផង ។

ក៏ប៉ុន្តែ ទោះបីជាត្រូវដាក់វៀតណាមឱ្យនៅឆ្ងាយពីតួនាទីដឹកនាំខាងនយោបាយ ទៅជាតួនាទីទីប្រឹក្សា និងខាងបណ្តុះបណ្តាលក៏ដោយ ក៏ពួកកុម្មុយនីសកម្ពុជានៅតែបន្តខ្ចីប្រើនូវទ្រឹស្តី និងមនោគមវិជ្ជារបស់ពួកគេដែរ ។ អង្គការបានបង្រៀនកម្មាភិបាលរបស់គេថា សហប្រតិបត្តិការដែលកំពុងប្រព្រឹត្តទៅរបស់ពួកគេជាមួយវៀតណាម មានន័យថារៀនយុទ្ធសាស្ត្រ និងយុទ្ធវិធីយោធា និងការដឹកនាំធ្វើការតស៊ូវណ្ណៈពីពួកគេ ។ ចំពោះគោលបំណងទី ១ វៀតណាមបន្តផលិតសៀវភៅហ្វឹកហ្វឺនយោធា

ជាភាសាខ្មែរ ។ អៀង សារី បានបញ្ជាក់ថា ទ្រឹស្តីរបស់វៀតណាម និងកម្ពុជា អំពីការដែលថាតើត្រូវដឹកនាំធ្វើសង្គ្រាមប្រជាជនយ៉ាងដូចម្តេចនោះ គឺ "ដូចគ្នា" ។ ការពិព័ណនារបស់គេអំពីរចនាសម្ព័ន្ធនិងការងារនៃរដ្ឋបាលបដិវត្តន៍របស់អង្គការនៅជនបទបង្ហាញឱ្យឃើញថា ពួកគេនៅតែជិតស្និទ្ធទៅនឹងគំរូដែលបានអនុវត្តន៍នៅភាគខាងត្បូងដដែល ។

ការនេះមិនទំនាស់នឹងការបោះជំហានទៅមុខថែមទៀត នៃស្វ័យភាពដែលចេញមកពីសេចក្តីសំរេច នៃការប្រជុំធ្វើឡើងដោយថ្នាក់ដឹកនាំ និងកម្មាភិបាល មួយចំនួនក្នុងឆ្នាំ ១៩៧១ នោះទេ ។ ទាំងនេះមានការរួមបញ្ចូលសមាជបក្សមួយ ដែលក្នុងនោះឯករាជភាពកម្ពុជាពីវៀតណាមត្រូវបាននិមិត្តដោយការបញ្ជាក់ថា បពខ នឹងផ្លាស់ឈ្មោះទៅជា បក្សកុម្មុយនីសកម្ពុជា (បកក) ទោះបីជាវត្តមានរបស់វានៅតែស្ថិតនៅជាការសម្ងាត់មួយនៅឡើយ លើកលែងតែចំពោះបក្សជន ហើយវានៅតែត្រូវហៅថាអង្គការដដែលចំពោះអ្នកនៅខាងក្រៅក៏ដោយ ។ គណៈកម្មាធិការអចិន្ត្រៃយ៍របស់វា ត្រូវបានពង្រីកដល់មានសមាជិក ៧ នាក់: ស, នួន, ភឹម, អៀង សារី, វន វ៉េត, តាម៉ុក និង សុន សេន ។

តាមសេចក្តីរាយការណ៍ សមាជបានសំរេចថា បកក មិនត្រូវអនុញ្ញាតឱ្យកងទ័ពវៀតណាមស្ថិតនៅកម្ពុជាតទៅទៀតទេ ទោះបីជាមានការសង្ស័យអំពីគតិបណ្ឌិតនៃគំនិតនេះក៏ដោយ ។ នេះគឺប្រាកដជាការប្រថុយប្រថានមួយ ទោះបីជាកងកម្លាំងប្រដាប់អាវុធប្រយុទ្ធរបស់ បកក នាពេលនោះ អាចបានកើនរហូតដល់ចំនួន ២០ ០០០ នាក់ក៏ដោយ ហើយចំនួនសរុបនៃរចនាសម្ព័ន្ធកុម្មុយនីសកម្ពុជា ក្នុងនេះរួមមានទាំងសមាសភាពជាកងកម្លាំងយោធាមូលដ្ឋាន និងនយោបាយផង អាចឡើងដល់ ៥០ ០០០ នាក់ ទាំងស្រី ទាំងប្រុស ។ កងកម្លាំងប្រដាប់អាវុធរបស់ លន់ ណុល លែងមានសកម្មភាពតទៅទៀតហើយ នៅក្នុងផ្នែកដ៏ធំទូលាយនៃជនបទ តែរដ្ឋាភិបាលរបស់គេ ជាក់ស្តែងនៅតែត្រួតត្រាប្រជាជនពី ៤ ទៅ ៥ លាននាក់នៅឡើយ និងមានសមត្ថភាពយោធាដែលអាចវាយជាមួយ បកក បានតែមិនមែនជាមួយវៀតណាមទេ ។ ការណ៍នេះ ត្រូវបានបង្ហាញឱ្យឃើញនៅខែចុងក្រោយៗនៃឆ្នាំ ១៩៧១ ដោយការវាយសំរុករបស់ លន់ ណុល ដែលធ្វើឱ្យ បកក បរាជ័យយ៉ាងធ្ងន់ធ្ងរ មុនវៀតណាមអន្តរាគមន៍ ដែលបណ្តាលឱ្យកងទ័ព លន់ ណុល ទទួលមហន្តរាយយ៉ាងធ្ងន់ធ្ងរ ។ រហូតដល់ចុងឆ្នាំ ១៩៧២ ជាថ្មីម្តងទៀត បកក ត្រូវបរាជ័យរហូតដល់មានអន្តរាគមន៍ពីកងទ័ពវៀតណាម ដើម្បីធ្វើឱ្យបរាជ័យការវាយសំរុកសំខាន់មួយរបស់ លន់ ណុល ហើយនៅចុងខែសីហា ឆ្នាំ ១៩៧៣ អង្គភាពអាវុធពិសេសវៀតណាមបានជួយដល់ការវាយប្រហាររបស់ បកក ។ ទោះបីយ៉ាងណាក៏ដោយ ក៏ពេញមួយឆ្នាំ ១៩៧២ ដល់ឆ្នាំ ១៩៧៣ បកក បានបន្តទិសដៅរបស់ខ្លួនឱ្យកងទ័ពវៀតណាមដកចេញពីតំបន់រំដោះរបស់ខ្លួន ។ នៅកន្លែងខ្លះ ពួកគេបានខិតខំចរចាអំពីការចាកចេញរបស់ពួកគេ តែនៅកន្លែងណាដែលការចរចាមិនបានសំរេច ពួកគេបានរៀបចំឱ្យប្រជាជនធ្វើបាតុកម្មប្រឆាំងវៀតណាម ឬធ្វើការវាយប្រហារដោយយោធាទៅលើពួកគេ ។ រហូតដល់ចុងឆ្នាំ ១៩៧៣ ពួកគេបានដកចេញពីតំបន់រំដោះដ៏ច្រើនលើសលប់ របស់ បកក ។

ព្រមជាមួយគ្នានោះ បកក បានបង្កហេតុជាមួយ បពវ លើបញ្ហាមួយផ្សេងទៀត។ ក្រោយរដ្ឋប្រហារភ្លាមៗ ពួកគេបានសំរេចថានឹងមិនឱ្យកំហុសដែលកើតមានឡើងនាទីក្រុងហ្សឺណែវកើតឡើងជាថ្មីម្តងទៀតទេ នោះគឺ: ការខកខានមិនធ្វើតាមគោលជំហរដើមរបស់ បកត ស្តីពីការតស៊ូដោយមិនឈប់ឈររហូតដល់ស្លាប់ ប្រឆាំងចក្រពត្តិអាមេរិក និងខ្ញុំបំរើរបស់វា ។ ពួកគេឈរយ៉ាងរឹងមាំលើគោលជំហរនេះ ទោះបីជា បពវ បានសំរេចនៅឆ្នាំ ១៩៧២ ថាបន្តបត់បែនតាមផ្លូវហ្សឺណែវ ដែលជាលទ្ធផល វៀតណាមបានចុះហត្ថលេខានៅក្នុងខែមករា ឆ្នាំ ១៩៧៣ លើកិច្ចព្រមព្រៀងសន្តិភាពជាមួយសហរដ្ឋអាមេរិក ដែលផ្តល់នូវការដោះស្រាយដោយសន្តិវិធីនៃសង្គ្រាមវៀតណាម ។ បកក បានបដិសេធការជំរុញជាសម្ងាត់របស់ បពវ ថាឱ្យពួកគេយល់ស្របលើអ្វីមួយដែលដូចគ្នានេះដែរនោះ ដែលការនេះបានបង្ខំឱ្យវៀតណាមគាំទ្រជាចំហចំពោះការតស៊ូដែលកំពុងតែបន្តធ្វើនៅកម្ពុជា ។ ទោះបីជា បពវ បានបង្ហាញឱ្យឃើញថាភាពមានះរបស់ បពខ នេះត្រឹមត្រូវ នៅពេលពួកគេបានសំរេចនាពាក់កណ្តាលឆ្នាំ ១៩៧៣ ថាការដោះស្រាយដោយនយោបាយមិនអំណោយផលដល់ពួកគេ និងបន្តធ្វើការតស៊ូដោយអាវុធជាបន្ត

ទៀតក៏ដោយ ក៏ឧបទ្ទវហេតុនេះជាការបញ្ជាក់បន្ថែមទៀតថាឯករាជភាពរបស់ បកក គឺចម្ងងតាមសង្គ្រាមប្រជាជននៅវៀតណាមដែរ ។

ទិដ្ឋភាពមួយទៀតនៃការប្រកាន់ខ្ជាប់មជ្ឈន្តិកៈរូបមន្តវៀតណាម គឺការទទូចរបស់ បកក ថាសង្គ្រាមប្រជាជនមិនឈប់ឈររបស់ពួកគេ គឺមានទិសដៅរំដោះខ្លួនចេញពីអាណានិគមនិយមថ្មីរបស់អាមេរិក ។ ដូច្នេះ ទោះបីជាកម្លាំងថ្មើរជើងអាមេរិកបានដកចេញពីកម្ពុជានាពាក់កណ្តាលឆ្នាំ ១៩៧១ ក៏ដោយ ក៏អាមេរិកបន្តទម្លាក់គ្រាប់បែកលើប្រទេសនេះរហូតដល់ខែសីហា ឆ្នាំ ១៩៧៣ ទើបចប់ កម្ពុជាបានពិព័ណនាដោយខ្ជាប់ខ្ជួនក្នុងពាក្យពេចនេះ ដូចភាគខាងត្បូងវៀតណាមដែរ ។ បនក្បត់ លន់ ណុល នៅភ្នំពេញ ក៏ដូចសហភាគីរបស់គេនៅព្រៃនគរដែរ លែងមានអ្វីលើសពីគ្រាន់តែជាខ្ញុំកញ្ជះរបស់ចក្រពត្តិអាមេរិកប៉ុណ្ណោះដែលមិនអាចធ្វើការចរចាអ្វីជាមួយពួកគេបានទៀតទេ ។ បពរ ជាសាធារណៈ បានឯកភាពចំពោះការនេះ ក៏ដូចសម្តេចសីហនុនៅប៉េកាំងដែរ ។

សម្តេចត្រូវបានហ៊ុំព័ទ្ធដោយសេចក្តីប្តេជ្ញារបស់ បកក ដើម្បីធានាដល់ ហ្រ្គុង និងហ៊ុង ដែលមិនដែលមានជីវិតដោយខ្លួនឯងនោះ ហើយដូច្នេះមិនមានលទ្ធភាពដើម្បីគំរាមកំហែងដល់ស្វ័យភាពរបស់ពួកគេជាង បពរ ទេ ។ តាំងពីឆ្នាំ ១៩៧១ មកអង្គការបានកំចាត់ចោលនូវអក្ខតកថានៃតួនាទីរបស់សម្តេចសីហនុ នៅក្នុងការតស៊ូនេះ ដោយបានប្រកាសនៅក្នុងតំបន់ត្រួតត្រាដោយពួកគេថា អ្វីៗដែលសំរេចបានទាំងអស់គឺបានមកពីការដឹកនាំរបស់ពួកគេ និងពលីកម្មរបស់កងកម្លាំងប្រដាប់អាវុធប្រជាជន ។ នៅក្នុងឆ្នាំដដែលនោះ អៀង សារី ត្រូវបានបញ្ជូនឱ្យទៅប៉េកាំង ដើម្បីតាមដានសម្តេច និងធ្វើវិទ្ធង្សនានិងត្រួតត្រាវចនាសម្ព័ន្ធរបស់ ហ៊ុង និង ហ្រ្គុង ដែលស្ថិតនៅនិរទេសខ្លួននៅទីនោះ ។ ការខិតខំរបស់ សារី មានសារសំខាន់ណាស់ដើម្បីធានាថាសម្តេចសីហនុ យល់ស្របការមិនធ្វើការចរចាជាមួយពួក"របបមហាឃាតករនៃពួកក្បត់នៅភ្នំពេញ" ទោះបីជា បកក បានបន្ទុះបង្អាប់សម្តេចនៅក្នុងប្រទេសក៏ដោយ ពីព្រោះថា ការសុខចត្តិចរចាមានន័យថា"ជាការទទួលស្គាល់សិទ្ធិឱ្យសហរដ្ឋអាមេរិករក្សាប្រព័ន្ធអាណានិគមនិយមថ្មីរបស់ពួកវាជារៀងរហូត" ។ នៅក្នុងប្រទេសកម្ពុជា បកក បានដាក់រដ្ឋមន្ត្រីក្រសួងឃោសនាការ ហ៊ូ នីម និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ហ៊ូ យន់ ក្នុងការឃុំខ្លួនក្នុងផ្ទះក្នុងការដាក់ស្តែង នៅពេលគេប្រវ័ញ្ចលើឈ្មោះពួកគេ ដើម្បីធ្វើការឃោសនា ដោយពេលខ្លះពួកគេសរសេរអត្ថបទដោយខ្លួនឯងផង ដែលធ្វើឱ្យអ្នកផងនៅតែចាប់អារម្មណ៍ថាពួកគេជាអ្នកដឹកនាំបដិវត្តន៍ ។ ក៏ប៉ុន្តែ ក្រៅផ្លូវការ ហ៊ូ យន់ បានទិតៀន បកក ថ្នាក់ដឹកនាំ និង នយោបាយបក្ស ជាចំហតែម្តង ។ ហ៊ូ នីម យល់ស្របជាមួយ ហ៊ូ យន់ ដែរ តែរូបគេចេះបត់បែន និងទន់ភ្លន់ជាង ។ ខៀវ សំផន ឧបនាយករដ្ឋមន្ត្រី ហ្រ្គុង ដែលជាមនុស្សចេះសម្របខ្លួនជាងគេ គឺជាមនុស្សចំឡែកម្នាក់: រូបគេត្រូវបានផ្តល់រង្វាន់ចំពោះការចុះចាញ់របស់គេ ដោយការតម្លើងជាសមាជិកត្រៀមគណៈកម្មាធិការមជ្ឈឹម និងតួនាទីជាអ្នកធ្វើការប្រកេទជាលេខាផ្ទាល់របស់ នួន ទោះបីជារូបគេគ្មានអំណាចធ្វើសេចក្តីសំរេចដោយឯករាជ្យយ៉ាងណាក៏ដោយ ។

ដូច្នេះ ការវាយសំរុកផ្តាច់ព្រាត់ថ្ងៃទី ១ មករា ឆ្នាំ ១៩៧៥ ដែលនាំទៅឱ្យដណ្តើមបានទីក្រុងភ្នំពេញទាំងស្រុងនៅថ្ងៃទី ១៧ ខែមេសា ឆ្នាំ ១៩៧៥ ប្រកបដោយជោគជ័យ នៃបដិវត្តន៍ប្រជាធិបតេយ្យប្រជាជាតិប្រជាជនកម្ពុជា ពីរអាទិត្យមុន បពរ វាយសង្គ្រប់យកបានទីក្រុងព្រៃនគរនោះ គឺស្ថិតក្រោមការដឹកនាំទាំងស្រុងរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ បកក ។ ទោះបីជា បកក បដិសេធដាច់អហំការក៏ដោយ ក៏ជ័យជំនះរបស់ពួកគេគឺបានមកពីជំនួយមិនស្វាគមន៍របស់វៀតណាមនៅឆ្នាំ ១៩៧០-១៩៧២ មួយផ្នែកធំដែរ នោះគឺអន្តរាគមន៍យោធារបស់វៀតណាម និងការចាត់តាំងនិងការបណ្តុះបណ្តាល ខាងវិស័យនយោ-បាយ និងយោធា ដែលបានផ្តល់ឱ្យពីក្រោយរបាំង បកក ដើម្បីអភិវឌ្ឍន៍កម្លាំងរបស់ពួកគេ ហើយកម្មាភិបាលនិងកម្លាំងជាច្រើនដែលបានក្លាយជាកម្លាំងទាំងនោះ គឺ បកក បានយកបានមកពីពួកគេដែរ ។ ម្យ៉ាងទៀត បកក ក៏បានបដិសេធដោយទទូចផងដែរថា ថ្នាក់ដឹកនាំបក្ស សមាជិកថ្នាក់ក្រោមរបស់បក្ស ចំនួន ៤០ ០០០ នាក់ និងយុទ្ធជនចំនួន ៣០ ០០០ នាក់នៃកងទ័ពស្រួច

*ទាំងអស់គ្នានៅតែទទួលឥទ្ធិពលយ៉ាងជ្រាលជ្រៅនូវនយោបាយ និងការអនុវត្តន៍របស់វៀតណាមផងដែរ ទោះបីជាមានការមិនយល់ស្របគ្នាជាច្រើនរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ ជាមួយ បពវ ស្តីពីការអនុវត្តន៍ទ្រឹស្តីវៀតណាមនៅកម្ពុជាក៏ដោយ ។*

## *ប្រជាប្រិយភាពរបស់បដិវត្តន៍*

*យ៉ាងណាក៏ដោយ ឯករាជភាពនៃបដិវត្តន៍ប្រជាធិបតេយ្យប្រជាជាតិប្រជាជនរបស់ពួកគេ ទទួលបានភាពសក្តិសិទ្ធក្នុងសង្គម និងនយោបាយ ដោយការបិទមុខ មិនត្រឹមតែវិសាលភាពដែលវាត្រូវបានបង្កើតឡើង លើមូលដ្ឋានគ្រឹះដើមនៃកម្លាំងយោធាវៀតណាមប៉ុណ្ណោះទេ តែលើសពីនេះទៅទៀតនោះ គឺវិសាលភាពដែល បកក បានបង្កើនការប្រើកម្លាំងដើម្បីជំរុញវាឱ្យទៅមុខ បន្ទាប់ពីការអះអាងស្វ័យភាពរបស់ពួកគេ ។ បន្ទាប់ពីមានការផុសផុលនៃការចូលរួមបដិវត្តន៍ដោយស្ម័គ្រចិត្ត ក្នុងរយៈពេលជាច្រើនខែនាពេលដំបូង នៅជនបទ តាមការអំពាវនាវរបស់សម្តេចសីហនុក្នុងខែមីនា ឆ្នាំ ១៩៧០ និងការយកសេចក្តីអំពាវនាវនេះមកប្រើប្រាស់បន្តដោយវៀតណាម និង បកក មក ការជះឥទ្ធិពលរបស់វាមកលើប្រជាជនបានចាប់ផ្តើមលេចចេញភ្លាមៗនូវចលនាប្រឆាំង លន់ ណុល នៅជនបទ ។ នៅចុងឆ្នាំ ១៩៧០ ដើមឆ្នាំ ១៩៧១ បពវ - ទោះបីជាស្ថិតនៅមានប្រៀប - និងបកក - នៅពេលចាប់ផ្តើមត្រួតត្រា - បានពឹងផ្អែកកាន់តែខ្លាំងលើការគៀបសង្កត់ខាងយោធារបស់ពួកគេ ដើម្បីរក្សានិងពង្រីកការត្រួតត្រា ។ កន្លែងណាដែលយោធាវៀតណាមបានធ្វើប្រតិបត្តិការ ដោយកម្លាំងច្រើនលើសលប់ ពួកគេបានធ្វើការរាំងខ្ទប់"តំបន់រំដោះ" ពីផ្នែកផ្សេងទៀតនៃប្រទេស ដាក់ឱ្យអនុវត្តន៍ការហាមឃាត់ចលនារបស់ប្រជាជនមិនឱ្យមានការទាក់ទងគ្នាដែលជានយោបាយមួយដែលពួកកុម្មុយនីសខ្មែរបន្តធ្វើតាមនិងពង្រឹងថែម ។ អ្នកស្រុកជនបទជាច្រើនបានធ្លាក់ចូលក្នុងអន្ទាក់នៃតំបន់រំដោះ សុខចិត្តស្ថិតនៅក្រោមការត្រួតត្រាកុម្មុយនីសទាំងស្ទាក់ស្ទើរ មិនថាជាវៀតណាម ឬខ្មែរទេ ។ ពួកគេបានលួចរត់បើមានឱកាសធ្វើបាន ពីបដិវត្តន៍មួយដែលទទួលបានការគាំទ្រពីប្រជាជនកាន់តែតិចទៅៗ ជាងនៅភាគខាងត្បូងវៀតណាមទៅទៀតនោះ (ដែលនៅទីនោះ ការគាំទ្របានបាត់បង់យ៉ាងធ្ងន់ធ្ងរ បើប្រៀបធៀបទៅដើមទសវត្ស៍ ១៩៦០) ។ ដូច្នេះ នៅពេលពួកកុម្មុយនីសវៀតណាម និងកម្ពុជា ប្រកាសថាបដិវត្តន៍កម្ពុជាកំពុងធ្វើដំណើរទៅមុខដោយល្បឿនដ៏លឿនអស្ចារ្យនោះ គឺជាការភាន់ច្រឡំដោយខ្លួនឯងទេ ។ ពួកគេភាន់ច្រឡំរូបភាពនៃការត្រួតត្រាដោយយោធារបស់ បពវ និងក្រោយមករបស់ បកក ព្រមជាមួយខ្លឹមសារនៃការគាំទ្ររបស់កសិករ ថាបានជំរុញឱ្យទៅមុខយ៉ាងលឿននោះ ។*

*នៅពេល នួន បានដឹងជាយថាហេតុថា កម្មាភិបាល បកក ត្រូវបានបង្ហោះយ៉ាងលឿនភ្លាមៗ ទៅក្នុងឋានៈមានអំណាចយ៉ាងខ្លាំងពីក្រោយខ្នងកម្លាំងយោធាវៀតណាមមក រូបគេបានឆ្លៀតប្រើអំណាចរបស់ពួកគេនេះ ដើម្បីប្រើដោយរំលោភក្នុងផ្លូវមួយដែលបានក្លាយយ៉ាងលឿនទៅជាការអនុវត្តន៍ធម្មតារបស់ពួកគេ ។ នៅពេល បកក បានក្លាយជាមានស្វ័យភាពខាងនយោបាយកាន់តែច្រើនឡើងៗ ពី បពវ នៅក្នុងឆ្នាំ ១៩៧១-១៩៧២ មក ប្រជាជនជាច្រើននៅតែ "អៀនខ្មាស់ មិនទុកចិត្ត និងខ្លាច" បដិវត្តន៍ ដែលបានរក្សាតួនាទីរបស់ពួកគេតាមរយៈការគំរាមកំហែង និងការសម្លាប់ ។ នៅពេល បកក បណ្តេញកម្លាំងប្រដាប់អាវុធវៀតណាមចេញ នៅឆ្នាំ ១៩៧២-១៩៧៣ បកក បានជំនួសការត្រួតត្រាខាងយោធា ដោយបង្កើនការបង្ខិតបង្ខំយ៉ាងខ្លាំងបំផុត ដើម្បីធានាថាកសិករត្រូវតែធ្វើតាមការទាមទាររបស់ពួកគេ ។ បកក បានក្លាយទៅជាកាន់តែឃោរឃៅ និងបង្ក្រាបកាន់តែខ្លាំងបន្ទាប់ពីឆមាសទី ២ ឆ្នាំ ១៩៧៣ នៅពេលពួកគេអនុវត្តន៍នយោបាយដាច់ខាត ដោយបង្ខំឱ្យបង្កើតសហករណ៍កសិកម្មក្នុងតំបន់ក្រោមការត្រួតត្រារបស់ពួកគេ កាត់បន្ថយការប្រតិបត្តិសាសនា បង្ខំដាក់ការហាមឃាត់ការធ្វើដំណើររបស់អ្នកភូមិ និងចលនាប្រជាជនឱ្យវាយប្រហារភ្នំពេញ ។ ទោះបីជាមានការមិនសប្បាយចិត្តយ៉ាងជ្រាលជ្រៅ ក្នុងចំណោមអ្នកភូមិដ៏ច្រើនក៏ដោយក៏កសិករភាគច្រើនគោរពកម្លាំងរបស់ បកក បានចូលរួមជាមួយ បកក ពេលមានការស្នើសុំឱ្យចូលរួម និងសូត្រតាមពាក្យស្លោករបស់ បកក ទោះបីជាពួកគេមិនជឿក៏ដោយ ។ ដោយកម្លាំងយោធាសំខាន់ដែលត្រូវបានប្រមូលផ្តុំទៅលើកសិករក្របំផុតនោះ ពួកគេនៅតែជឿលើការសន្យារបស់ បកក ចំពោះអនាគតដ៏ល្អប្រសើរមួយនោះដដែល បកក មិនដែល*

បានធ្វើឱ្យមនុស្សភាគច្រើនជឿថាបដិវត្តន៍ដែលពួកគេខំជំរុញនោះ គឺដើម្បីផលប្រយោជន៍របស់ប្រជាជននោះទេ ។ ការបង្ខិតបង្ខំដោយកម្លាំង និងការគំរាមកំហែង នៅតែជាភាពប្រហាក់ប្រហែលនៃការគាំទ្ររបស់មហាជន និងនៃជោគជ័យនៃបដិវត្តន៍ប្រជាធិបតេយ្យប្រជាជាតិប្រជាជន របស់ប្រជាជនតែមួយមុខគត់តែប៉ុណ្ណោះ ។ យ៉ាងណាក៏ដោយ ការស្រមើស្រមៃនៃជ័យជំនះរបស់ប្រជាជនក្នុងឆ្នាំ ១៩៧៥ ជាការគ្រប់គ្រាន់ ដើម្បីបញ្ជាក់ដល់ ស, នួន និងអ្នកដទៃទៀតនៃគណៈកម្មាធិការអចិន្ត្រៃយ៍ ថាពួកគេបានធ្វើត្រូវជានិច្ច អំពីការអនុវត្តន៍ទ្រឹស្តីវៀតណាមស្តីពីសង្គ្រាមប្រជាជន និងបដិវត្តន៍ប្រជាធិបតេយ្យប្រជាជាតិប្រជាជននៅកម្ពុជា ហើយការដែលពួកគេមានជោគជ័យលើដំបូន្មានរបស់វៀតណាម គឺជាការគ្រប់គ្រាន់ដើម្បីធ្វើឱ្យពួកគេជឿជាក់ថាពួកគេបានក្លាយជាជនបដិវត្តន៍ល្អជាងគ្រូឧបជ្ឈាពីដំបូងរបស់ពួកគេទៅទៀត ។